ទស្សនាវដ្តី
វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម

ឆ្នាំទី២
លេខ២

ចេញផ្សាយប្រចាំឆមាស
ការផ្សាយរបស់វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម

ខែកក្កដា - ធ្នូ
ឆ្នាំ២០២៣

និពន្ធនាយក

ឯកឧត្តមបណ្ឌិត **ផុន កសិកា**

រៀបចំចងក្រងដោយ៖

លោក **យិន ពោ**

រចនាក្របដោយ៖

លោក **ហ៊ាង សុចិត្រា**

អាសយដ្ឋាន ៖ មហាវិថីសហព័ន្ធរុស្សី សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ រាជធានីភ្នំពេញ
(ស្ថិតក្នុងបរិវេណសាកលវិទ្យាល័យភ្នំពេញ២)

គេហទំព័រ (Website) ៖ https://ihss.rac.gov.kh

ហ្វេសប៊ុក (Facebook) ៖ https://web.facebook.com/ វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម

យូធូប (Youtube) ៖ វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម IHSS

កថាមុខ

រាជបណ្ឌិត្យសភាកម្ពុជាជាស្ថាប័នស្រាវជ្រាវវិទ្យាសាស្ត្ររបស់ជាតិ ដែលប្រមូលផ្តុំដោយបញ្ញវន្ត និងអ្នកស្រាវជ្រាវជាន់ខ្ពស់ពីគ្រប់មជ្ឈដ្ឋានក្នុងព្រះរាជាណាចក្រកម្ពុជា ហើយត្រូវបានរាជរដ្ឋាភិបាលចាត់ទុកជាធនាគារខួរក្បាលដ៏សំខាន់របស់ជាតិ។ រាជបណ្ឌិត្យសភាកម្ពុជាមានតួនាទីយ៉ាងសំខាន់ក្នុងការសិក្សាស្រាវជ្រាវលើគ្រប់វិស័យ ដើម្បីផ្តល់ជាជាតុចូលជូនរាជរដ្ឋាភិបាលក្នុងការបម្រើដល់កិច្ចការស្តារ និង អភិវឌ្ឍសេដ្ឋកិច្ចសង្គម។

វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម គឺជាសេនាធិការមួយរបស់រាជបណ្ឌិត្យសភាកម្ពុជា ដែលមានភារកិច្ចជាច្រើនដូចជា ស្រាវជ្រាវលើវិស័យមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គមរួមចំណែកអភិវឌ្ឍប្រទេសកម្ពុជា អភិវឌ្ឍស្មារតី ចំណេះដឹង ពង្រីកសមត្ថភាពធនធានមនុស្ស ព្រមទាំងបោះពុម្ពផ្សាយលទ្ធផលនៃការសិក្សាស្រាវជ្រាវរបស់ខ្លួន ក្នុងស្មារតីសន្តិភាព អភិវឌ្ឍនភាពភាពសុខដុមរមនា ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ក៏ដូចជារាជបណ្ឌិត្យសភា កម្ពុជា។

*ស្របតាមតួនាទីភារកិច្ចរបស់ខ្លួន វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្របានបង្កើតទស្សនាវដ្តីមួយដែលមានឈ្មោះថា «**ទស្សនាវដ្តីមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម**» ដើម្បីរៀបចំចងក្រង និងបោះពុម្ពផ្សាយលទ្ធផលស្រាវជ្រាវរបស់ថ្នាក់ដឹកនាំ មន្ត្រីវិទ្យាស្ថាន អ្នកស្រាវជ្រាវរបស់រាជបណ្ឌិត្យសភាកម្ពុជា ក៏ដូចជាលទ្ធផលស្រាវជ្រាវបែបវិទ្យាសាស្ត្រពីគ្រប់មជ្ឈដ្ឋានផងដែរ។*

*"**ទស្សនាវដ្តីមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម**" ប្រមូលផ្តុំដោយអត្ថបទទាក់ទងនឹងប្រធានបទណាមួយ របកគំហើញថ្មីៗ និងអត្ថបទទស្សនៈរបស់អ្នកនិពន្ធជាដើម ក្នុងគោលបំណងចែករំលែកចំណេះដឹងទៅកាន់មជ្ឈដ្ឋានអ្នកស្រាវជ្រាវ សិស្ស និស្សិត ក៏ដូចជាអ្នកអានទូទៅ។*

*យើងខ្ញុំសង្ឃឹម និងជឿជាក់ថា «**ទស្សនាវដ្តីមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម**» នៃវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រ នៃរាជបណ្ឌិត្យសភាកម្ពុជា ពិតជាផ្តល់នូវមូលដ្ឋានឯកសារសម្រាប់និស្សិត ក៏ដូចជាអ្នកស្រាវជ្រាវទូទៅធ្វើការសិក្សាស្រាវជ្រាវបន្តទៀត។*

ថ្ងៃចន្ទ ១៤កើត ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែ កក្កដា ឆ្នាំ២០២៣

ប្រធានវិទ្យាស្ថាន

បណ្ឌិត ជុន កសិកា

មាតិកា

ទំព័រ

១. អត្ថបទ អ្នកនិពន្ធ នូ ហាច..... .....*១*

លោកបណ្ឌិត យិន យ៉ង់

២. បុណ្យវិសាខបូជា.....*២០*

លោកស្រីបណ្ឌិត ជា វណ្ណី

៣. ទំនាក់ទំនងរវាងអរិយធម៌និងច្បាប់.....*៣៤*

លោកបណ្ឌិត ហែម ឡាច

៤. ស្វែងយល់អំពីសុជីវធម៌ និង ទំនៀមទម្លាប់ខ្មែរ.....*៥៧*

លោកស្រីបណ្ឌិត ជា វណ្ណី

៥. ការវិវត្តនៃរដ្ឋបាលដែនដីខ្មែរ(តាំងពីសម័យមុនអង្គរ រហូតដល់ឆ្នាំ១៩៩៣).....*៧០*

លោកបណ្ឌិត ហែម ឡាច

៦. ចរាចរណ៍ក្នុងរាជធានីភ្នំពេញ និង ផលប៉ះពាល់.....*.៨៨*

លោក ហៃ សុគន្ធា

៧. ប្រភពនៃការអប់រំក្នុងពិភពលោកសម័យបុរាណ..... .....*១០៣*

លោកបណ្ឌិត សូ សុធីរ

៨-ប្រភពនៃការអប់រំក្នុងពិភពលោកចាប់ពីមជ្ឈិមសម័យ.....*១៣២*

លោកបណ្ឌិត សូ សុធីរ

៩. ការអប់រំជាកិច្ចការទាំងអស់គ្នា.....*១៥៥*

លោក ប៉ាន់ សំណាង

១០. តម្លៃនៃការអប់រំបរិយាបន្ន.....*១៧៥*

លោក ប៉ាន់ សំណាង

១១.ស្វែងយល់ពីទ្រឹស្តីអភិវឌ្ឍន៍ពឹងផ្អែក *១៩០*

លោកបណ្ឌិត តូច សុជារី និង លោក សាន ចេង

១២.ទស្សនៈជុំវិញបញ្ហានយោបាយសេដ្ឋកិច្ច... .....*២០១*

លោក បណ្ឌិត ឈឿន សាវន

១៣.ប្រព័ន្ធចំណាត់ថ្នាក់វិទ្យាប្ចឹម... .....*២៥០*

លោក មាឃ សារី,លោកបណ្ឌិត សូ សុធីរ, លោក លី តុង, លោកស្រី ឃាង ជានី

អត្ថបទ អ្នកនិពន្ធ នូ ហាច

ដោយៈ លោកបណ្ឌិត **ឃិន យ៉ង់**
នាយកដ្ឋានកិច្ចការទូទៅ,វិទ្យាស្ថានមនុស្សសាស្ត្រ
និងវិទ្យាសាស្ត្រសង្គម,រាជបណ្ឌិត្យសភាកម្ពុជា

១. ជីវប្រវត្តិអ្នកនិពន្ធ

លោក នូ ហាច ជាអ្នកនិពន្ធមួយរូប ដែលមានកេរ្តិ៍ឈ្មោះល្បីល្បាញក្នុងជំនាន់ស្របាលគ្នានឹងលោក រឹម គីនដែរ។ គាត់ក៏បានទទួលការសិក្សាពីសាលាទំនើបដែរ ហើយបានតែងនិពន្ធស្នាដៃប្រលោមលោកជាច្រើនក្នុងសម័យអាណាព្យាបាលបារាំង និងដើមសម័យឯករាជ្យ ជាអាទិ៍រឿងផ្កាស្រពោនដែលត្រូវបានបញ្ចូលក្នុងកម្មវិធីសិក្សាថ្នាក់មធ្យមសិក្សាបឋមភូមិ។

លោក នូ ហាច ប្រសូតនៅឃុំកំពង់ព្រៃ ស្រុកសង្កែ ខេត្តបាត់ដំបង។ ចំពោះកាលបរិច្ឆេទកំណើតរបស់លោកមានមតិពីរប្លែកគ្នាលើឆ្នាំកំណើតគឺ៖

ប្រភពពីបណ្ឌិត ឃីង ហុកឌី អ្នកនិពន្ធ នូ ហាច កើតពីថ្ងៃ២៦ មិថុនា ១៩១៦ នៅភូមិកំពង់ព្រៃ ស្រុកសង្កែ ខេត្តបាត់ដំបង។ លោក នូ ហាច ជាបុត្រារបស់លោកតា ឃួន នូ និង លោកយាយឱរមួច[1]។

ប្រភពពីលោក ស មុនី លោកសាស្ត្រាអ្នក ចួន និងទស្សនាវដ្តីអ្នកនិពន្ធខ្មែរបញ្ជាក់ថា លោក នូ ហាច កើតនៅថ្ងៃទី២០ មិថុនា ១៩១៨ នៅឃុំកំពង់ព្រៃ ស្រុកសង្កែ ខេត្តបាត់ដំបង។ បិតារបស់លោកឈ្មោះឃួន នូ មាតាឈ្មោះឃួន មុច[2]។

លោក ស មុនី បញ្ជាក់ថាបិតារបស់លោកឈ្មោះឃួន នូ មាតាឈ្មោះឃួន មុច។

តាមរយៈការសម្ភាសន៍ផ្ទាល់ជាមួយ លោក តា រីទី (តាន់ ទី) អាយុ ៧៩ឆ្នាំ ដែលជាប្អូនសាច់ធ្ងាយរបស់លោក នូ ហាច មានប្រសាសន៍ ថា ឪពុកលោក នូ ហាច ឈ្មោះ អ៊ុំ នៅ (នូ ?) មានដើមកំណើតជាអ្នកកំពង់ឆ្នាំង បានប្រពន្ធ ជាអ្នកកំពង់ព្រៃ ឈ្មោះ អ៊ុំមួច ប្រកបរបរធ្វើ ស្រែមានឧត្តុល

---

[1].រៀបរៀងដោយបណ្ឌិតសភាចារ្យ ឃីង ហុកឌី អារម្ភកថាដោយ បណ្ឌិតសភាចារ្យ ឃីង ហុកឌី Voir khing Hoc DY Ecrivains et expression littéraires du Cambodge au XXéme siécle volume2 L'Harmattan paris 1993.P.46.

[2].គឹម សែត ទំព័រទី២៥៥-២៥៧(ផ្នែកនេះអ្នកនិពន្ធបានលើកយកអត្ថបទលោក ស មុនី មកបញ្ចូលតែម្តង)

-អ៊ុក ចួន សាលាគរុវិជ្ជាជាន់ខ្ពស់ «សំរាវជ្រាវជីវ ប្រវត្តិអ្នកនិពន្ធ ខ្មែរ» ដងម ទំព័រទី៦១។

-សមាគមអ្នកនិពន្ធខ្មែរប្រវត្តិអ្នកនិពន្ធខ្មែរ ក្នុងទស្សនាវដ្តីអ្នកនិពន្ធខ្មែរឆ្នាំទី២ លេខ៣ ខែកុម្ភៈ ឆ្នាំ១៩៩៦ ទំព័រទី១៣។

ពីរបីដែលជាកេរខាងឪពុកក្មេក និងស្រែចាប់ព្រៃនៅបឹងឫស្សី[៣]។

មានការបកស្រាយផ្សេងគ្នាពីចំនួនបងប្អូនបង្កើតរបស់លោក នូ ហាច។ តាមរយៈការបទសម្ភាសន៍ជាមួយលោកយាយ អួន ឆែម អាយុ៨៨ឆ្នាំ ដោយក្នុងទស្សនាវដ្តីប្រជាប្រិយ បានប្រាប់ឱ្យដឹងថាក្នុងរឿង«ផ្កាស្រពោន»តួអង្គ ប៊ុន ធឿន គឺជារូបលោក នូ ហាច ត្រូវជា ក្មួយ សាច់ថ្ងៃមានឪពុកឈ្មោះ ឃួន នៅ និង ម្តាយឈ្មោះមួច(ទាំងអស់គ្នាស្លាប់អស់ហើយ)។ លោកយាយបន្តថា លោក នូ ហាច មានបង ប្អូនប្រុសស្រីទាំងអស់ដប់ពីរនាក់(ស្រីបីនាក់)ហើយសព្វថ្ងៃនៅរស់តែបួននាក់(ស្រីពីរនាក់)រស់នៅសហរដ្ឋអាមេរិកនិងថៃ គឺមានឈ្មោះ គុយ, កណ្តៀន, វ៉ាត់និងយឿត[៤]។ បទសម្ភាសន៍នេះលោកយាយ អ៊ួន ឆែម ក៏បានផ្តល់ផងដែរដល់កាសែតរស្មីកម្ពុជា តែគ្មានបញ្ជាក់ថាលោក នូ ហាច មានបងប្អូននៅប្រទេសថៃទេក្នុងពេលបច្ចុប្បន្ន[៥]។

តាមការជួបសម្ភាសន៍ផ្ទាល់ជាមួយអ្នកមីង រុំ ឌី អាយុ៦៦ឆ្នាំ មុខរបរធ្វើស្រែជាកូនស្រី លោកយាយដៀង (ប្អូនជីទួតមួយលោក នូ ហាច) ស្នាក់នៅថែរក្សាផ្ទះលោក នូ ហាច បានឱ្យដឹងថាលោក នូ ហាច មានបងប្អូនប្រាំបួននាក់ស្រីបីនាក់ (ប្រុសប្រាំមួយនាក់)ដែលមានរូបលោកផ្ទាល់ជាកូនច្បងនិងប្អូនៗប្រាំបីនាក់ ទៀតគឺ៖

១.ឈ្មោះ ឈឿន (មានប្រពន្ធជាអ្នកសៀម រាប)

២. ឈ្មោះ ឈឿយ (ស្រី)

៣. ឈ្មោះ ឆោម

៤. ឈ្មោះ ឈៀត

៥. ឈ្មោះ កណ្តៀន

៦. ឈ្មោះ យឿត (ស្រី)

៧. ឈ្មោះ វ៉ាត់ (ស្រី)

៨.ឈ្មោះ គុយ(ទៅមកបាងកក-ភ្នំពេញជាកូន៧)[៦]។

លោកតា តាន់ ទី បានបញ្ជាក់ថា លោក នូ ហាច បានរៀបការជាមួយស្រីម្នាក់ឈ្មោះ រ៉ែម (មិនដឹងកាលបរិច្ឆេទ)ជាអ្នកនៅខេត្តសៀមរាបក្រោយពីស្នេហាខកបំណងជាមួយគូស្នេហ៍ចាស់(នាងវិជាវី) ដោយនាងត្រូវម្តាយលើកឱ្យកូនអ្នកមានជាថៅកែដើរកាណូត។ ជីវិតអាពាហ៍

---

[៣] ការសម្ភាសន៍ជាមួយលោកតា រី ទី (តាន់ ទី) អាយុ៧៩ឆ្នាំ ជាប្អូនសាច់ឆ្ងាយរបស់លោក នូ ហាច ស្តីពី «ជីវប្រវត្តិលោក នូ ហាច» នៅឃុំកំពង់ព្រះ ថ្ងៃទី៧ ខែមករា ឆ្នាំ២០០២ វេលាម៉ោង៩:៤០នាទី។

[៤].សូមមើលទស្សនាវដ្តីប្រជាប្រិយ ឆ្នាំទី០៨ លេខ១៩២ ថ្ងៃទី ១១-២០ មករា ២០០២«ដំណើររឿងរបស់តួអង្គ ប៊ុនធឿន គឺជាជីវិត ពិតរបស់អ្នកនិពន្ធ នូ ហាច» ទំព័រទី៣២-៣៣។

[៥].សូមមើលកាសែតរស្មីកម្ពុជា លេខ២៥៥៨ ថ្ងៃសៅរ៍ ទី២២ ខែកញ្ញា ឆ្នាំ២០០១ «ឃុំកំពង់ព្រះ ប្រវត្តិរឿងប៊ុនធឿន-វិជាវី» ទំព័រ១-២៦។

[៦].ការសម្ភាសន៍ជាមួយអ្នកមីង រុំ ឌី អាយុ ៦៦ឆ្នាំ មុខរបរធ្វើស្រែ ជាកូនស្រីលោកយាយ ដៀង (ប្អូនជីទួតមួយ លោក នូ ហាច) ស្នាក់នៅថែរក្សាផ្ទះលោក នូ ហាច បានឱ្យដឹងថា«ជីវប្រវត្តិលោក នូ ហាច» នៅផ្ទះលោក នូ ហាច នៅឃុំកំពង់ព្រះ នាថ្ងៃច័ន្ទ ទី៧ ខែមករា ឆ្នាំ២០០២។

ពិពាហ៍របស់លោកបានផ្តល់កំណើតឱ្យកូនពីររូបដែលបច្ចុប្បន្នកំពុងរស់នៅសហរដ្ឋអាមេរិក។ ប្អូនៗលោក នូ ហាច ទាំងអស់សុទ្ធតែប្រើត្រកូលឃួន ដែលជាឈ្មោះជីតាទៅតាមទម្លាប់ប្រើឈ្មោះរបស់ខ្មែរ លើកលែងតែលោក នូ ហាច ជាកូនច្បងមានត្រកូល នូ ទៅតាមឈ្មោះ ឪពុកទៅវិញ។

តាមរយៈព័ត៌មានពីលោកតា តាន់ ទី ក៏ដូចជាអ្នកមីង ឌុំ រី បានឱ្យដឹងថាលោក នូ ហាច ក្រោយពេលទៅធ្វើការនៅភ្នំពេញ មានមុខមានមាត់មក លោកបានមកធ្វើផ្ទះក្បឿងពីរខ្នង ត្រង់ទីតាំងផ្ទះរបស់ឪពុកម្តាយគាត់នៅភូមិ-ឃុំកំពង់ព្រះ ស្រុកសង្កែ ខេត្តបាត់ដំបង។ នៅទីក្រុងភ្នំពេញ លោក នូ ហាច មានផ្ទះមួយដែលទីតាំងផ្ទះនោះ បច្ចុប្បន្នក្លាយជាផ្នែកមួយនៃយានដ្ឋានជួសជុលរថយន្ត នួន សំណាង (ផ្ទះលេខ ៣៤ ផ្លូវលេខ៩៥,ផ្លូវខាងលិចស្របជាមួយមហាវិថីព្រះមុនីវង្ស ក្រោយម្តុំមេក្ងើង ខាងជើងកោជនីយដ្ឋានក្រពើ)។ លោកតា ទា លឹមហេង អាយុ ៦៥ឆ្នាំ ស្នាក់នៅផ្ទះលេខ១៦ ផ្លូវលេខ១០៥ សង្កាត់បឹងព្រលឹត ខណ្ឌ៧មករា បញ្ជាក់ថា កាលពីមុនសម័យសង្គ្រាម គេហដ្ឋាននេះជារបស់លោក នូ ហាច មានចារឹកអក្សរ នូ ហាច នៅលើបង្គោលរបង។ ផ្ទះលោក នូ ហាច នេះសង់ឡើងជាលក្ខណៈថ្មក្រោម លើឈើប្រក់ក្បឿង។ ផ្ទះនេះនៅជាប់របងគ្នាជាមួយផ្ទះរបស់លោក យូ ហេង អតីតរាជអង្គរក្សព្រះបាទ សុរាម្រិត, អនុរដ្ឋលេខាធិការទទួលការៈខាងនគរបាលព្រះរាជាណាចក្ររបស់គណៈរដ្ឋមន្ត្រីសង្គមលើកទី១ នាសម័យសង្គមវាស្រ្តនិយម។ អក្សរចារឹកលើរបងទើបត្រូវគេបំផ្លាញក្នុងពេលប៉ុន្មានឆ្នាំមុននេះ។ ក្នុងពេលបំពេញបេសកកម្មជាទីប្រឹក្សាស្ថានឯកអគ្គរាជទូតប្រទេសកម្ពុជានាទីក្រុងបាងកក និងជាតំណាងអចិន្ត្រៃយ៍នៃប្រទេសកម្ពុជានៅអមអង្គការអេកាហ្វេ នាក្រុងបាងកក លោក នូ ហាច មានទីលំនៅ នាទីក្រុងបាងកក។

លោកតា តាន់ ទី បញ្ជាក់ថា ជីវិតបឋមវ័យរបស់លោក នូ ហាច បានចាប់ផ្តើមការសិក្សាដំបូងដោយការចូលរៀននៅសាលាវត្ត ក្នុងវត្តកំពង់ព្រះដែលស្ថិតនៅក្បែរផ្ទះ លុះក្រោយមកក៏បានទៅរៀននៅសាលាឯទីរួមខេត្ត[៧]។

តាមរយៈឯកសារបណ្ណិត ឃីង ហុកឌី កាលពីវ័យកុមារលោក នូ ហាច បានទទួលការសិក្សាតាមបែបប្រពៃណីនៅវត្តក្នុងភូមិរហូតចេះអានអត្ថបទសាស្ត្រាស្ទឹករឹតបានយ៉ាងស្ទាត់។ គាត់បានប្រឡងជាប់ចូលរៀនថ្នាក់ទី៦ នៅអនុវិទ្យាល័យស៊ីសុវត្ថិក្នុងឆ្នាំ ១៩៣៦។ គាត់បានទទួលសញ្ញាប័ត្រមធ្យមសិក្សាបត្រភាគទីមួយនៅឆ្នាំ ១៩៣៩[៨]។

ដោយស្ថិតក្នុងគ្រួសារដែលមានឪពុកនិងឪពុកធំជាអ្នកចេះដឹងខាងអក្សរសាស្ត្រ

---

[៧] ការសម្ភាសន៍ជាមួយលោកតា រី ទី ស្តីពី «ជីវប្រវត្តិលោក នូ ហាច» ដ>ឯ>ម។

[៨] Voir Khing Hoc Dy ***Ecrivains et expressions littéraires du Cambodge au XXéme siécle*** Op. cit. p. 46.

ជាដើមនោះ លោក នូ ហាច មានវាសនាបានទទួលការសិក្សាក្រោមការជំរុញលើកទឹកចិត្តដោយយកចិត្តទុកដាក់ឱ្យខំរៀនសូត្រជាខ្លាំង។ ក្នុងការសិក្សានេះលោក នូ ហាច បានទទួលការណែនាំឱ្យស្រឡាញ់អក្សរសាស្ត្រតាំងពីកុមារភាព ដោយលោកឃួន នៅជាបិតានិងលោកឱរ សុិន ជាឪពុកធំ[៥]។

ក្នុងវ័យសិក្សា លោក នូ ហាច ជាអ្នកស្រវាស្រទេញក្នុងការសិក្សា ទោះបីជាពេលត្រឡប់ទៅភូមិកំណើតពេលបុណ្យទានឬវិស្សមកាលម្តងៗ លោកតែងតែអានសៀវភៅជានិច្ច។ លោកតាតាន់ ទី រំឭកពីលោក នូ ហាច ថាពេលចូលឆ្នាំ វាកងមកលេងប្អូនៗនៅឯស្រែគាត់ កាន់សៀវភៅរឿង ឬ សៀវភៅមេរៀនតាមខ្លួនជាប់ពេលសួរគាត់ថាបងឯងខំរៀនយ៉ាងណា? គាត់ឆ្លើយថាឱ្យអញទៅលេងឯណាទៅអញទៅនិយាយនឹងគេខាងក្រៅមិនដឹងទៅនិយាយរឿងអីបើមើលសៀវភៅមិនសូវអផ្សុកអញមើលសៀវភៅបានសប្បាយ រៀនមើលរឿងវាមិនអផ្សុក...។ លោក នូ ហាច ជាមនុស្សសុភាពរាបសារ មិនចេះវាយឫកពេលសម្រាកវិស្សមកាលត្រឡប់មកផ្ទះម្តងៗ គាត់តែងចុះជួយធ្វើស្រែឪពុកម្តាយ បងប្អូនដោយមិនប្រកាន់ខ្លួនឡើយ។ គាត់ជាមនុស្សរួសរាយរាក់ទាក់ជាមួយញាតិមិត្តជិតខាងចេះជួយគ្នាគ្រាមានការងារពឹងពាក់ទុក្ខធុរៈផ្សេងៗ។

[៥] នូ ហាច មាលាដួងចិត្ត ដ.ឯ.ម ទំព័រ ៧។

២. រចនាបថអ្នកនិពន្ធ

ក្នុងសាដៃរបស់លោក លោក នូ ហាច បានស្ថាបនាតាមរចនាបថមួយប្លែកពីលោកញ៉ុក ថែម ក្នុង រឿងកុលាបប៉ៃលិន។ ទំរង់កាសា «ផ្កាស្រពោន» មានលក្ខណៈអណ្តែតអណ្តូងតាមបែបកាសាកវី។ ទាំងរចនាពាក្យ ទាំងរចនាឃ្លា សុទ្ធសឹងជាកាសាសាមញ្ញតែមានសភាពថ្លៃថ្នូរ ទន់ភ្ញន់ និងពីរោះជាប់ចិត្ត។

៣. ឥទ្ធិពលដែលអ្នកនិពន្ធទទួលបាន

ការដែលក្លាយទៅជាអ្នកនិពន្ធល្បីមួយរូបជាប្រការលំបាក។ លោក នូ ហាច ជាអ្នកនិពន្ធខ្មែរមួយរូបដែលមានឈ្មោះល្បីតាមរយៈស្នាដៃតែមួយចំនួនតូចតែប៉ុណ្ណោះ។ រឿងផ្កាស្រពោន ជាស្នាដៃដំបូងរបស់លោកដែលទទួលការគាំទ្រពីសំណាក់មជ្ឈដ្ឋានទូទៅជាច្រើន។ តាមរយៈប្រសាសន៍លោកតា តាន់ ទី បានឱ្យដឹងថា លោកតា នូ ដែលជាឪពុកលោក នូ ហាច នៅកំពង់ព្រះជាអ្នកចេះដឹងអក្សរសាស្ត្រអ្នកកំពង់ព្រះរាប់រក ពឹងពាក់ឱ្យធ្វើសំបុត្រស្នាម ជាភាសាខ្មែរ ចេះតែងកំណាព្យ អានកាសែតបានតែលោកមិនបានប្រកបរបរជាអ្នករាជការទេ។ ពត៌មាននេះ អាចឱ្យយើងសន្និដ្ឋានថា ក្នុងការសិក្សាតែងនិពន្ធលោកនូ ហាច បានទទួលមត៌កខ្លះពីបិតាលោក គឺឧបនិស្ស័យក្នុងការសិក្សាទេពកោសល្យក្នុងការតែងនិពន្ធ។

តាមការសាកសួរចំពោះអ្នកនិពន្ធរៀមច្បង់ខ្លះៗដូចលោក នូ ហាច នៅឆ្នាំ ១៩៧០

លោកបានបញ្ជាក់ច្រាប់ដោយត្រង់ថា លោកមានកំណើតនៅបាត់ដំបងបានស្គាល់អក្សរសាស្ត្រថៃច្បាស់ព្រោះលោកចេះអាន និងយល់អត្ថបទថៃ ដូចនេះលោកបានទទួលឥទ្ធិពលវប្បធម៌នេះខ្លះ ព្រោះអត្ថបទប្រលោមលោកមាននៅស្រុកថៃមុនស្រុកខ្មែរយើង ហើយជាពិសេស លោកបានទទួលឥទ្ធិពលពីអក្សរសាស្ត្របារាំងថែមទៀត អ្នកនិពន្ធបារាំងដែលលោកចូលចិត្តជាងគេ គឺ អាលហ្វុង ដូដេ(Alphonse Daudet)[10]។ លោក អាលហ្វុង ដូដេ ជាអ្នកនិពន្ធ បារាំងមួយរូប កើតនៅឆ្នាំ១៨៤០ ហើយស្លាប់ទៅវិញ នៅឆ្នាំ១៨៩៧។ គាត់ក្យា យជាអ្នកនិ ពន្ធ ល្បីល្បាញដោយការតែងនិពន្ធរឿងព្រេង ដោយ មានភាពល្បីល្បាញនៅក្នុងខេត្តកំណើតរបស់គាត់ដូចជារឿង Lettre de mon moulin និពន្ធ នៅឆ្នាំ១៨៦៦។ នៅក្នុងខ្សែរឿង Tartaring ដែល មាន ជាពិសេសការផ្សងព្រេងរបស់ Tartarin នៃ *Tarascon* និពន្ធនៅឆ្នាំ១៨៧២ គាត់ សរសេរបែបជារឿងព្រេងរីកឆាយនៃមនុស្សក្អេងក្អាងដែលមានអាកប្បកិរិយាផ្ទុយស្រឡះជាមួយ ការ ពិតធម្មតានៅលើឆាកឯស្រុកកំណើត។ ប្រលោមលោកដែលគាត់ផ្សព្វផ្សាយជាបន្ត បន្ទាប់មកទៀត (ដូចជារឿង Sapho និពន្ធ នៅ ឆ្នាំ១៨៨៤) ក្លាប់ទៅនឹងភាពប្រាកដនិយមរបស់Zola តាមវិធីសម្តែងគំនិត(ទាក់ទាញ ដល់) អ្នកមានអារម្មណ៍ចំពោះអក្សរសាស្ត្រ សិល្បៈ និងសិល្បករអណ្តែតអណ្តូង។

តាមរយៈរឿងផ្កាស្រពោន អ្នកនិពន្ធបានបង្ហាញពីស្ថានភាពសិស្សសាលាដែលធ្វើដំណើរតាមរថភ្លើងចេះច្រៀងទំនុកបារាំងដែលគេធ្លាប់ឮអ្នកលេងកុនឈ្មោះ ទីណូ រ៉ូសស៊ីច្រៀង[11]។ លោក ទីណូ រ៉ូសស៊ី កើតនៅឆ្នាំ ១៩០៧ នៅ Ajaccioស្លាប់នៅឆ្នាំ១៩៨៣។ លោកជាសិល្បករអណ្តែតអណ្តូងរបស់បារាំង។ លោកជាតួឯកនៅលើឆាកតន្ត្រី ស្ថានីយ៍វិទ្យុ ជាតារាឯកភាពយន្ត លើសពី ២៥រឿង ហើយក៏ជាអ្នកអត្ថាធិប្បាយផងដែរនៅលើឆាក ក្នុងស្នាដៃនិពន្ធរឿងល្ខោនដែលសម្តែងដោយតួរីករាយអមទៅដោយបទភ្លេងពិរោះៗ។ ជាប់ចិត្តនឹងប្រភេទសិល្បៈដែលនាំឱ្យគាត់មានភាពល្បីល្បាញដល់ឆ្នាំ១៩៣៣ ទីណូ រ៉ូសស៊ី ឈរជើងជាសិល្បករចម្រៀងបារាំងដែលមានប្រជាប្រិយភាពខ្លាំងរហូតដល់ពេលស្លាប់ ដោយគាត់មានសំឡេងធំពិសេសនៃមនុស្សប្រុស[12]។

ឥទ្ធិពលដែលទទួលបានពីរឿងប៉ូល និងវៀហ្ស៊ីនី “នាងនឹកឃើញកាលដែលប៊ុនធឿនទិទានរឿង «ប៉ូល និងវៀហ្ស៊ីនី» ប្រាប់នាង។ ថ្ងៃនោះឯង នាងបានហៅសំឡាញ់នាងជាល្បែងថា «បងប៉ូលៗ» ប៊ុនធឿន ក៏ឆ្លើយហៅនាងថា

[10] ឃីង ហុកឌី ទិដ្ឋភាពទូទៅនៃអក្សរសាស្ត្រខ្មែរ Éditions L'Har mattan, Paris, FRANCE, 1997, p. 166.

[11] *សូមមើល នូ ហាច ផ្កាស្រពោន ពោធិ៍ពុម្ពរស្មី ក្រសួងសិក្សាធិការជាតិ ភ្នំពេញ គ.ស ១៩៦០ ទំព័រទី២-៣។*

[12] voir Georges Pascal, Nouvelle Encyclopendie Bordas VIII compression/ Europe 1985, p.4842.

«អូនរៀហ្ស៊ីនី»វិញ។ ក្នុងរឿងមាលាដួងចិត្តអ្នក
និពន្ធបង្ហាញពីបានកវីអ្នកនិពន្ធបរទេសជាអាទិ
អ័ល ហ្វ្រេដ ដឺ មុស្សេត៍ ម្ចាស់អត្ថបទកំណាព្យ ឡឺ
សូលអត្ថបទកាព្យរបស់ H de R ប្រលោមលោក
ភាពយន្តបាវ៉ង់រឿងទ្វារចង្អៀតរបស់អង់ដ្រេ
ហ្ស៊ីដ (La Ports d'André Gide)។ អង់ដ្រេ ហ្ស៊ីដ
កើតនៅឆ្នាំ១៨៦៩ ស្លាប់នៅឆ្នាំ១៩៥១ ជាអ្នក
និពន្ធបាវ៉ង់ ជាក្មួយរបស់លោក ធាល ហ្ស៊ីដ។
លោកច្រើនសរសេរជាអត្ថបទសារណាស្រាវ
ជ្រាវ និងអត្ថបទទិតៀន ជាងសរសេរប្រលោម
លោក។ គាត់ជាអ្នកមានមុខម្នាក់ក្នុងចំណោម
អ្នកដែលមានឥទ្ធិពលខ្លាំងនៅក្នុងវិស័យអក្សរ
សាស្ត្របាវ៉ង់ទំនើបដោយបង្ហាញឱ្យឃើញ
ច្បាស់ ជាសាធារណៈក្រោយសង្គ្រាមឆ្នាំ១៩១៨
ដោយសារការចេញផ្សាយទស្សនាវដ្តីបាវ៉ង់ថ្មី
(Nouvvelle revue Française)ដែលគាត់ជាស្ថាប
និកម្នាក់។ គាត់ក្លាយជាគ្រូ(អ្នកនិពន្ធគំរូម្នាក់
ដែលគេតែងរឭកនឹកឃើញគ្រប់ជំនាន់) មាន
ឥទ្ធិពលរហូតទៅដល់ការតែងនិពន្ធអត្ថបទ ហួស
ពីការពិតនិយម(Surréalisme)និងអត្ថិភាពនិយម
ដោយធ្វើការវិភាគលើ(act garatuit notamment)។
បញ្ហា របស់តួអង្គ ជាស្នូលនៃស្នាដៃរបស់គាត់
បញ្ហាក់បង្ហាញឱ្យឃើញភាពសាហាវជាងឯកត្ត
បុគ្គលនិយម និងការស្រាវជ្រាវដ៏ប៉ងប៉ាល់នៃភាព
ស្និទ្ធស្នាលមួយ។ គេត្រូវស្គាល់ស្នាដៃសាកល្បង
របស់គាត់ ដូចជា Les Nourritures terrestres និពន្ធឆ្នាំ
១៨៩៧ ជាស្នាដៃសម្រាយអណ្តែតអណ្តូងដែល
ក្លាយជាសៀវភៅសំណប់ (អានប្រចាំថ្ងៃ)របស់
យុវជនជំនាន់ក្រោយ។ ស្នាដៃសាកល្បងចុង
ក្រោយ គឺរឿង Les Nouvelles Nourritures ជា
សញ្ញានៃការវិវត្តន៍ផ្នត់គំនិតរបស់គាត់។ ក្នុង
ចំណោមប្រលោមលោក រឿង L'immoralistes
និពន្ធឆ្នាំ១៩០២ រឿង *La Porte étroite* និពន្ធឆ្នាំ
១៩០៩ រឿង Les Caves du l'attican និពន្ធឆ្នាំ
១៩១៤ បទមហោរីឬបទគង្វាលចៀមឬបទ
ស្រុកស្រែចម្ការ (La Symphonie Pastroale) និពន្ធ
ឆ្នាំ១៩១៩ រឿង Les Faux-monnayeurs និពន្ធឆ្នាំ
១៩២៦ ដែលក្នុងនោះបកស្រាយការស្រាវជ្រាវ
យ៉ាងសំខាន់តាមលំនាំរឿង និងជីវប្រវត្តិផ្ទាល់
ខ្លួនក្នុងរឿង Si le grain ne meurt និពន្ធឆ្នាំ
១៩២៦ ការទិតៀនយ៉ាងប៉ិនប្រសប់ (Pretexte
ឆ្នាំ១៩៣០ Nouveaux Prêtextes ឆ្នាំ១៩១១ Inci-
dences ឆ្នាំ១៩២៤) ហ្ស៊ីដ បានឈានទៅរកការ
តែងនិពន្ធផ្នែកល្ខោន(រឿងPhiloctete ឆ្នាំ១៨៩៩
រឿង Edipe ឆ្នាំ១៩៣០)។ រយៈពេលប្រហែល
ជិត៤០ឆ្នាំ គាត់បានយកលំនាំតាម និង រៀបចំ
ការសម្តែងដើម្បី J-L Boarrolt រឿង Les Proces
de Kafka។ ក្នុងចំណោមអ្នកនិពន្ធបរទេសជា
ច្រើនដែលជាអ្នកមនុស្សនិយម ជានិច្ចកាល
តែងមានគំនិតចង់ដឹងចង់យល់ បានលើក
សរសើរលោកស្ទើនឹង Dostoievski ឬ Shakespeare។
សារពត៌មានជាកម្មសិទ្ធិផ្ទាល់ខ្លួន បានចេញ
ផ្សាយចាប់តាំងពីឆ្នាំ១៩៣៩ ហើយឆ្លុះបញ្ចាំង
ពីជីវិតនៃការត្រិះរិះ(ជាបញ្ញវន្ត)ពេញមួយ
ជំនាន់។ គាត់ក៏ជាអ្នកនិពន្ធរឿង Retour de
L'U.R.SS ឆ្នាំ១៩៣៦។ គាត់បានទទួលរង្វាន់

ណូបែលអក្សរសាស្ត្រ នៅឆ្នាំ ១៩៤៧[១៣]។ រឿងប្រិយនារីរបស់វ៉ូដ្វាយ៉ែ (La BIEN Aimée de Vandoer) រឿងម៉ា តាហារី និយាយពីនាង ម៉ាតា ហារី កើតនៅឆ្នាំ១៨៧៦ ស្លាប់ក្នុងឆ្នាំ ១៩១៧ ជាស្រីរបាំជាតិណេអង់ដេស៍ ល្បីល្បាញដោយការសម្តែងក្បាច់រាំឥណ្ឌូនេស៊ី។ នាងត្រូវគេបាញ់សម្លាប់នៅប្រទេសបារាំងក្នុងនាមជាចារកិច្ចដើម្បីផលប្រយោជន៍ឱ្យអាល្លឺម៉ង់ក្នុងសង្គ្រាមលោកលើកទី១[១៤]។ ប្រភពទាំងអស់នេះ អាចបង្ហាញថា អ្នកនិពន្ធ នូ ហាច មិនត្រឹមតែបានទទួលឥទ្ធិពលក្នុងការតែងនិពន្ធពីសាស្ត្រាល្បែងបែបបុរាណ ដែលនាំឱ្យលោកចេះរបៀបពិពណ៌នារៀបរាប់ទេសភាពបានយ៉ាងល្អប៉ុណ្ណោះទេ តែលោកក៏បានទទួលផងដែរពីអក្សរសិល្ប៍បស្ចឹមប្រទេស ពិសេសប្រលោមលោកបារាំងលើការអភិវឌ្ឍន៍ផ្នែកចិត្តគំនិត ការគិតគូរពិចារណាផ្សេងៗក្នុងជីវភាពរស់នៅក្នុងសង្គមការងារ ជាពិសេសលើបញ្ហាស្នេហា។

៤. និន្នាការរបស់អ្នកនិពន្ធ

ដោយសារតាមរយៈឥទ្ធិពលទាំងឡាយដែលអ្នកនិពន្ធទទួលបាន ទាំងឥទ្ធិពលពីអក្សរសិល្ប៍បស្ចឹមប្រទេសផងនោះ ទើបគេអាចមើលឃើញតាមរយៈស្នាដៃនិពន្ធ លោក នូ ហាច បានបង្ហាញពីផ្នត់គំនិតថ្មីលើរចនាបថវិធីសាស្ត្រតែងនិពន្ធខ្ចីមសារនៃរឿងនិងតម្លៃនៃរឿង ដែលមានទំនោរទៅរកភាពទំនើបជឿនលឿនមានលក្ខណៈមនុស្សនិយមតថនិយមបម្រើឱ្យផលប្រយោជន៍មនុស្សទូទៅ។ ការលើកយក«ស្នេហា» ធ្វើជាប្រធាន បទក្នុងរឿងផ្កាស្រពោនរបស់អ្នកនិពន្ធ នូ ហាច រួមជាមួយស្នាដៃរឿង កូលាបប៉ៃលិន រឿងបិសាចស្នេហារបស់អ្នកនិពន្ធ ញ៉ុក ថែម រឿងសុផាត របស់អ្នកនិពន្ធ រឹម គីន រឿងទឹកទន្ទេសាបរបស់អ្នកនិពន្ធ គីម ហាក់ ជាដើមនោះ បានបង្កើតការវិវឌ្ឍន៍ថ្មីមួយ គឺការបើកទំព័រនៃការចាប់ផ្តើមរបស់អក្សរសិល្ប៍ប្រលោមលោកពាក្យពេយខ្មែរ នាយុគសម័យថ្មីដែលដោះស្រាយបញ្ហាជីវិតរស់នៅប្រចាំថ្ងៃរបស់មនុស្សទូទៅលែងវិលទៅរកអច្ឆរិយភាពការស្រមើស្រម៉ៃការសណ្តំព្រលឹងវិញ្ញាណដែលទន់ខ្សោយអស់សង្ឃឹមដោយការនឿយ ណាយនឹងសង្គ្រាមការចាញ់សង្គ្រាមជាញឹកញាប់ចាប់ពីក្រោយសម័យអង្គរជាច្រើនសតវត្សឱ្យមានក្តីសង្ឃឹមថាថ្ងៃណាមួយនឹងចាកផុតទុក្ខទាំងឡាយ ដោយសារតួអង្គអច្ឆរិយៈណាមួយមកជួយប្រោសព្រំតាមរយៈសាស្ត្រាល្បែង។

ក្នុងការបកស្រាយពីបញ្ហាជីវភាពរស់នៅក្នុងរឿងផ្កាស្រពោន លោក នូ ហាច បានបង្ហាញអោយយើងឃើញនូវលក្ខណៈខុសឆ្គងទាំងក្នុងនិន្នាការទាំងក្នុងជីវភាពសង្គមខ្មែរដែលអាចចាត់ទុកថា ជាបុព្វហេតុសំខាន់ក្នុង

[១៣] Voir Georges Pascal, Nouvelle Encyclopedie Boras IV compression/ Europe,1985,p.2210.

[១៤] Voir Georges Pascal, Nouvelle Encyclopedie Boras IV compression/ Europe,1985,p.2210.

វិបត្តិស្នេហាយុវជន។ តាមដំណើររឿង យើងសង្កេតឃើញថា អ្នកនិពន្ធហាក់ដូចជា សង្កត់ធ្ងន់លើនិន្នាការពីរ៖ គឺ ការនិយមទ្រព្យសម្បត្តិ និងការនិយមបំបិទសិទ្ធិ សេរីភាពយុវក្នុងការជ្រើសរើសគូស្រករ។ ដោយសារនិន្នាការ ទាំងពីរនេះ តួអង្គទាំងអស់ ហាក់ ដូច ជាមានគុណវិបត្តិ ដែលសុទ្ធសឹងជាមូល ហេតុកំណត់វាសនាអាក្រក់ដល់នាងវិធារី[១៥]។

វិវឌ្ឍពីបញ្ហាស្នេហា និងការរក្សាកិត្តិយសរបស់តួអង្គ ប៊ុន ធឿន ក្នុងរឿងផ្កាស្រពោន ទៅជាឧត្តមគតិស្នេហាជាតិដែលស្តែងចេញតាមរយៈតួអង្គ ទីឃាវុធ ក្នុងរឿងមាលាដួងចិត្ត បានបង្ហាញពីនិន្នាការជាតិនិយមដ៏ជ្រាលជ្រៅរបស់អ្នកនិពន្ធ នូ ហាច ដែលគេមិនបានឃើញក្នុងស្នាដៃនិពន្ធនៃអ្នកនិពន្ធដទៃទៀត ដែលពោរពេញទៅ ដោយគំនិតសន្តិភាពនិយម ការផ្សះផ្សាប្រជាជាតិពីរជ្រកក្រោមម្លប់ព្រះពុទ្ធសាសនាតែមួយ ក្រោមរូបភាពស្នេហា។ ប្រឈមមុខនឹងសេចក្តីស្នេហាដ៏ជ្រាលជ្រៅដែលខ្លួនមានចំពោះនារីសៀមម្នាក់នេះ (នាងចន្ទមណី) ទីឃាវុធ បានធ្វើការសម្រេចចិត្តមួយដែលមានទម្ងន់រវាងផលប្រយោជន៍ក្នុងរឿងស្នេហាផ្ទាល់ខ្លួន និងអធិបតេយ្យភាព បូរណភាពទឹកដី កិត្តិយសជាតិដែលត្រូវជាតិសាសន៍របស់នាង (សៀម) ប្រមាថមើលងាយធ្វើការឈ្លានពានដោយប្រើកម្លាំងទ័ពលុកលុយយ៉ាងគគ្រឹនក្នុងបំណងលេបត្របាក់យកទឹកដីភាគពាយ័ព្យនៃប្រទេសខ្មែរ។ ទោះបីសង្គ្រាមបានចប់ទៅហើយក្តី ទោះបីដឹងថាព័ត៌មានដែលមិត្តអ្នកផ្តល់មកនោះជាការយល់ច្រឡំក្តី ទីឃាវុធ មិនបានសូម្បីតែមានបំណងបំភ្លេចពាក្យសម្បថចំពោះព្រះភ័ក្ត្រព្រះពុទ្ធរូបនៅអង្គរ ដែលបង្ហាញពីទឹកចិត្តជាតិនិយមរបស់គេឡើយ។

ក្រៅពីនេះ អ្នកនិពន្ធបានបង្ហាញពីសម្រស់ទេសភាពធម្មជាតិ ទឹកដី ព្រៃព្រឹក្សា ដែលជានិន្នាការសំខាន់មួយដែរ សម្រាប់លម្អផ្ទៃរឿងក្នុងវិធីតំណែងនិពន្ធរបស់អ្នកនិពន្ធសម័យមុន។

៥. ឧត្តមគតិរបស់អ្នកនិពន្ធ

លោកនូ ហាច ជាអ្នកនិពន្ធរឿង ប្រលោមលោកបែបមនោសញ្ចេតនាមួយរូប ដែលមានទឹកដៃប្រកបដោយទេពកោសល្យក្នុងការតែងនិពន្ធ។ ប្រធានបទសំខាន់នៅក្នុងស្នាដៃរបស់លោក គឺរឿងស្នេហា(សេចក្តីស្នេហារបស់យុវវ័យ និងឧត្តមគតិស្នេហាជាតិ)។

នៅក្នុងរឿងផ្កាស្រពោន អ្នកនិពន្ធបានឱ្យតម្លៃខ្ពស់ទៅលើការកសាងសុភមង្គលគ្រួសារ ដោយពឹងផ្អែក ទៅលើចំណេះដឹង និងការចេះយល់ចិត្តថ្លើមគ្នារបស់គូស្រករ។ ក្នុងការចាត់ចែងគូស្រករកូនចៅ អ្នកនិពន្ធមិនឱ្យតម្លៃទៅលើទ្រព្យសម្បត្តិតែម្យ៉ាងថាអាចផ្តល់សេចក្តីសុខ ដល់គូស្រករដែលនឹងចាប់ដៃ គ្នាកសាង

[១៥] សោម សុមុនី អក្សរសិល្ប៍ពាក្យរាយខ្មែរដ.ឯ.ម ទំព័រ១១៩។

គ្រួសារថ្មីមួយនោះទេ។ តាមរយៈយាយនួន បង្ហាញឱ្យឃើញថា ការប្រកាន់ឥរិយាបថរឹងត្អឹង ចូលចិត្តកៀបសង្កត់កូនចៅឱ្យធ្វើតម្រូវតាមចិត្តខ្លួនជាចាស់ទុំ នោះមិនមែនសុទ្ធតែត្រូវគ្រប់ពេលនោះទេ។ ការបំបិទសិទ្ធិសេរីភាពកូនចៅ ក្នុងការជ្រើសរើសគូស្រករ ជាប្រការមួយគួរត្រូវជៀសវាង ព្រោះការធ្វើបែបនេះមិនបាននាំអ្វីជាផលល្អដល់អ្នកជាមាតាបិតាអាណាព្យាបាល ឬបុត្រធីតាឡើយលទ្ធផលបានត្រឹមតែភាពសោកាដូចជាយាយនួន ជាម្តាយនាងវិជាវី តែប៉ុណ្ណោះ។

អ្នកនិពន្ធ នូ ហាច ផ្តល់បទពិសោធន៍ជាច្រើនក្នុងរឿងស្នេហាតាមរយៈនាងវិជាវី ប៊ុន ធឿន។ កត្តីភាពជាកត្តាសំខាន់ក្នុងការកសាងសុភមង្គលគ្រួសារ។ រឿងនេះអ្នកនិពន្ធឱ្យតម្លៃជាខ្លាំង លើស្នេហាធ្វើឱ្យស្នេហាមានឥទ្ធិពលគ្របដណ្តប់លើការស្ងាប់រស់របស់នារីខ្មែរ តាមរយៈនាងវិជាវី។ តាមរយៈតួអង្គនាងវិជាវី អ្នកនិពន្ធ ចង់បណ្តុះ ទឹកចិត្តស្មោះស្ម័គ្រគក្តីចំពោះស្នេហាដល់យុវជនទាំងឡាយដែលទោះបីជាស្ថិតក្នុងស្ថានភាពបែបណាក៏ដោយនាង នៅតែប្រកាន់ខ្ជាប់កក្តីភាពចំពោះគូស្នេហ៍មិនងាកឡើយ។

នាងវិជាវី ជាគំរូមួយយ៉ាងល្អក្នុងការប្រកាន់ ឥរិយាបថល្អ ទន់ភ្ញន់ សុភាពរាបសារ ស្រគត់ស្រគំ ស្តាប់បង្គាប់អ្នកមានគុណ ពិសេសកក្តីភាពចំពោះស្នេហា។ ថ្វីត្បិតតែនាងមិនបានទទួលផលតបស្នងយ៉ាងប្រពៃមួយឱ្យសមទៅនឹងតម្លៃនៃការប្រព្រឹត្តរបស់នាងក៏ពិតមែន ប៉ុន្តែសង្គមខ្មែរបានឱ្យតម្លៃនាងយ៉ាងខ្លាំង នាង ជានារីគំរូមួយរូបសម្រាប់សុភាពស្ត្រីទាំងឡាយប្រតិបត្តិតាមទង្វើល្អៗទាំងនោះ។

ចរិតរមទម្យពេក អៀនអន់ពេករបស់នារីមួយចំនួនដូចជានាងវិជាវី ជាកិរិយាមួយដែលគួរលះបង់ចោលព្រោះការប្រកាន់យកឥរិយាបថទាំងនេះមិនបានជួយអ្វីដល់នាងឡើយ វាបានត្រឹមតែនាំមកនូវក្តីទុក្ខសោកាដល់អ្នកប្រព្រឹត្តតែប៉ណ្ណោះ។

ការសិក្សា ជាមធ្យោបាយមួយដ៏ល្អសម្រាប់យុវជនគ្រប់រូបក្នុងការរៀបចំកសាងអនាគតរបស់ខ្លួនឱ្យប្រព្រឹត្តទៅបានល្អ ប្រកបដោយសុភមង្គល។

ការងប់ងល់តែលើការសិក្សាមួយមុខ ហើយមិនទទួលខុសត្រូវ មិនហ៊ានប្រឈមមុខនឹងការពិតចំពោះមុខ ក្នុងរឿងស្នេហា តាមរយៈ ប៊ុន ធឿន ត្រូវទទួលលទ្ធផលមួយ គឺការព្រាត់ប្រាស់ពីគូស្នេហ៍ ដែលខ្លួនប្រាថ្នាជាគូអនាគត។

អ្នកនិពន្ធ នូ ហាច បានបណ្តុះនូវទឹកចិត្តស្នេហាជាតិដ៏ឧត្តុង្គឧត្តមចំពោះបណ្តាអ្នកអានគ្រប់មជ្ឈដ្ឋាន ពិសេសស្រទាប់យុវជនខ្មែរដែលជាសសរទ្រូងដ៏រឹងមាំក្នុងបុព្វហេតុការពារនិងអភិវឌ្ឍន៍ជាតិមាតុភូមិទប់ទល់នឹងខ្លាំងសត្រូវគ្រប់ប្រភេទ(នឹមអាណានិគមការ រំលោភឈ្លានពានរបស់ប្រទេសដែលមានព្រំប្រទល់ជាប់គ្នា ភាពឱនថយលើគ្រប់វិស័យរបស់ជាតិ.)

គំនិតសន្តិភាពនិយមការផ្សះផ្សាប្រជាជាតិ ដែល នៅជិតខាងគ្នាមានទំនាស់គ្នាក្រោមម្លប់ដ៏ត្រជាក់នៃព្រះពុទ្ធសាសនាតាមរយៈរឿងមាលាដួងចិត្ត។ រឿងមាលាដួងចិត្ត បង្ហាញឱ្យអ្នកអាន ឃើញពីស្ថានភាពសង្គមខ្មែរនា សម័យអាណាព្យាបាលបារាំងដែលពោរពេញទៅដោយមន្ត្រីពុករលួយ អសមត្ថភាពការងារ រួមដៃជាមួយឈ្មួញកេងប្រវ័ញ្ចផលប្រយោជន៍ជាតិបំពេញមហិច្ឆតាផ្ទាល់ខ្លួនការបណ្តុះនូវគំនិតមនសិការការងារ ស្អប់ខ្ពើមអំពើពុករលួយ អសកម្មការងារតាមរយៈតួអង្គ ទីឃាវុធ ប្រាមោទវគី។

ការបណ្តុះឧត្តមគតិស្នេហាជាតិ ការចេះថ្លឹងថ្លែងរវាងផលប្រយោជន៍ជាតិ និងផលប្រយោជន៍បុគ្គលតាមរយៈតួអង្គ ទីឃាវុធ ដែលស៊ូលះបង់ស្នេហាដើម្បីបូរណភាពទឹកដី «យើងជួប មុខគ្នាពេលនេះ ប្រហែលជាលើក ក្រោយបំផុតហើយ ព្រោះបងបានទៅសច្ចាប្រណិធានចំពោះព្រះកត្រព្រះពុទ្ធរូបនៅអង្គរវត្តថាដរាបណាខេត្តខ្មែរ ដីខ្មែរដែលបានទៅសៀមក្នុងពេល ថ្មីៗនេះមិនត្រឡប់មកខ្មែរវិញទេ ដរាបនោះ បងប្តូរផ្តាច់មិនព្រមយកសៀមជាមិត្ត ជាក្ងៀជាម្រាក់អ្វីឡើយ»។

រឿងនេះក៏បានបង្ហាញផងដែរពីការបណ្តុះគំនិតសន្តិភាពនិយមរបស់អ្នកនិពន្ធ ចូលចិត្តរស់នៅក្នុងសុខសន្តិភាពគាតរភាពរវាងគ្នា និងគ្នាមិនចូលចិត្តសង្គ្រាមឈ្លានពាន ការរំលោក បំពានទៅលើអធិបតេយ្យភាពបូរណភាពទឹកដី ប្រទេសដទៃ។ គំនិតនេះ ស្តែងឡើងតាមរយៈសំបុត្រដែលវេគីផ្ញើឱ្យទីឃាវុធ«ដូចឯងបានស្តាប់ឮតាមវិទ្យុ ឬអានដឹងក្នុងកាសែតស្រាប់ហើយ ប្រទេសសៀមកំពុង ឆ្មៀត ឱកាសក្នុងបារាំងអន្ទាក់ ដើម្បីវាតអាណាចក្ររំលោកមកលើដែនដីខ្មែរនិងឡាវ។ មិនគួរធ្វើ យ៉ាងនេះសោះ!ប្រទេសដែលយើងទុកជារៀមច្បង បែរជាចង់ត្របាក់ប្អូនៗតូចៗមើលតែត្រីឆ្ពោរតែម្តង»។

បញ្ហាកិត្តិយសក៏ជារឿងសំខាន់មួយដែលអ្នកនិពន្ធលើកយកមកបង្ហាញតាមរយៈតួអង្គ ប៊ុនធឿន និង ទីឃាវុធ ផងដែរ។ តាមរយៈសកម្មភាពរបស់តួអង្គទាំងពីរគេអាចមើលឃើញថាអ្នកទាំងពីរសុទ្ធតែជាមនុស្សត្រូវការកិត្តិយស មិនចង់ឱ្យមានអ្នកណាម្នាក់ឬច្រើន ប្រមាថមើលស្រាលដល់គេឡើយ។ ប៊ុន ធឿន សុខចិត្តលះបង់នារីជាទីស្រឡាញ់ដោយមិនចង់មានបញ្ហារឿងទ្រព្យសម្បត្តិ ពាក្យដំណៀលផ្សេងៗ។ ការសម្រេចចិត្តក្នុងរឿង ស្នេហារបស់តួអង្គ ប៊ុន ធឿន ជាការសម្រេចចិត្តដែលប្រកបដោយការគិត គូរពិចារណា ថ្លឹងថ្លែងរវាងស្នេហា និងកិត្តិយស«ការប្រព្រឹត្តដូចប៊ុន ធឿនជាការប្រសើរវិសេសណាស់ ទោះជាចោទថា ប៊ុន ធឿន មិនអាចហ៊ានធ្វើ អន្តរាគមន៍អ្វីលើរឿងនេះក៏ដោយក៏ជាការផ្ទុយស្រឡះដែរ ព្រោះយើងអាចមើលឃើញថា ប៊ុន ធឿន បានរក្សានឹង ស្រឡាញ់កិត្តិយសជាង ស្រឡាញ់អ្វីៗទាំងអស់។ គំនិតម្យ៉ាងដែលយុវជនបានផ្តងឡើង គឺការអស់ចំណង់ ដែលមានបញ្ហាជុំវិញខ្លួនបានចោទឡើងជាប្រធាន។ បរិយាកាសជុំវិញខ្លួន

នោះ មានច្រើនយ៉ាងណាស់ គឺទី១អ្នកនឹកឃើញ ថា យាយនួន កាលដើមឡើយស្រឡាញ់អ្នក និង គ្រួសារអ្នកណាស់ ក៏ប៉ុន្តែក្នុងកាលនោះមាតា បិតាអ្នកនៅមានទ្រព្យ ពេញផ្ទះគ្រប់គ្រាន់ចាយ នៅឡើយ លុះទ្រព្យរលាយ យាយនួនក៏ដកចិត្ត ដៃវិញ ដូច្នេះការស្រឡាញ់កាលពីមុនក៏ ដោយសារ មានទ្រព្យជាគ្រឿងផ្សំផង។ ទី ២ ការយកបាត ដៃធ្វើជាខ្នងដៃយ៉ាងធាប់រហ័សនេះជាអំពើ១ គួរ ឱ្យស្អប់ បំផុត ហើយរូបអ្នកក្តី អ្នកឯទៀតក្តី គប្បី តែជៀសវាងឱ្យឆ្ងាយអំពីជនជំពូកនេះ។ ទីបីកាល បើអ្នកចូលធ្វើអន្តរាគមន៍ ហើយបានរូបនាង វិជារី ជានារីគួរឱ្យស្រឡាញ់មកធ្វើជាគូជីវិតហើយ ក៏ មិន ជាការវិសេសវិសាលឡើយ ព្រោះមាតា បិតា នាងគ្មានការពេញចិត្តចំពោះអ្នក។ ចុះបើគ្រា ក្រោយមានវិបត្តិខាងទ្រព្យសម្បត្តិធ្លាក់មកត្រូវធ្ងន់ ជាងនេះទៅទៀត តើយ៉ាងណាទៅវិញ អើគួរឱ្យ ធុញទ្រាន់នឹងរស់នៅជាមួយណាស់ ព្រោះមនុស្ស ណាក៏ដោយឱ្យតែយកទ្រព្យ ធ្វើជាឈ្នាន់សម្រាប់ ឡើងទៅកាន់ភាពសុខដុមរមនានឹងគ្នា ហើយ មនុស្សនោះនឹងយកធ្វើជាញាតិមិត្តពុំបានឡើយ ព្រោះកាលណាគ្មានទ្រព្យ មុខជាត្រូវវេទនាខាង ផ្លូវចិត្តសម្បើម។ អាស្រ័យហេតុនេះ បានជា ប៊ុន ធឿន ត្រូវដើរគេច ចេញឱ្យហើយ។ បែរទៅប្រព្រឹត្ត ធ្វើអាកប្បកិរិយានឹងនទៅវិញ មិនតែ ប៉ុណ្ណោះ សោតការធ្វើយ៉ាងនេះក៏ជាមធ្យោបាយ ១ នាំឱ្យ មានសុខស្រួលរាងខ្លួន និងជនជា សត្រូវ ផង នាំ ឱ្យ កិត្តិយសអនាគតរបស់ខ្លួនមានរស្មីល្អផង»។

ទីយាវុធមានការសេចក្តីក្រៃវក្រោធពេល ដែលដឹងថាខ្លួនចាញ់បោកគេតាមរយៈវេ គឺជា មិត្តជិតជិត និងជាសមាជិកក្រុមសម្ងាត់។ ការ ចាញ់ឧបាយគេនេះ គឺចាញ់យ៉ាងធ្ងន់សម្រាប់ រូបគេ ចាញ់ដោយសារចាញ់ចិត្តលង់ស្នេហ៍គេ ចាញ់ដោយសារគេបំពានលើសេចក្តីទុកចិត្តរប ស់ខ្លួនពិសេសគឺចាញ់ដោយសារគេយកសេចក្តី ស្នេហាបរិសុទ្ធរបស់ខ្លួនមកជាន់ឈ្លី បម្រើឱ្យ ប្រយោជន៍នយោបាយចារកម្ម ធ្វើឱ្យស្រុកទេស ខ្លួនមានវិបត្តិត្រូវគេប្រមាថ ឈ្លានពានយ៉ាង កម្រោល «ស្រី ចង្រៃ... ស្រីកាំឡកិណ្ណី...ស្រីថ្ងៃម ខ្មៅ... យ៉ាងនោះមែនឬអី ? ចិត្តធ្វើយក្ងាមថាពុំ មែនទេ ! ពុំមែនទេ ត្បិតអី កិរិយានាងទន់ភ្ន ន់ យ៉ាងនេះ សេចក្តីស្មោះត្រង់យ៉ាងនេះ មិនសម នឹងមានគំនិតអាក្រក់លាក់លៀមបានឡើយ។ ឯឪពុកសោតក៏គួរសំគាល់បានថា ជាមនុស្ស មានចិត្តធម៌ ចិត្តកក្តីឥតវៀចវេរបានទេ។ ទី យាវុធ អន្ទះអន្ទែង រិលវល់ក្នុងសេចក្តីសង្ស័យ ហើយបំផ្រុះឯកាក្នុងគ្រែមួយ ដែលមានសភាព ហាក់ដូចជា ក្រាលនូវបន្ទាដែលចាក់សាច់មុត ពេញខ្លួនរកផ្អៀងទៅខាងណាក៏ពុំផុតរំខាន ឡើយ។ ដោយធ្លាប់អានសៀវភៅ និង មើលកុន ហើយនឹកដល់រឿងម៉ាតាហារីក្នុងសង្គ្រាមលោក លើកទី១ បាល័ដ្ឋកម្ងោះក៏មានអារម្មណ៍មួយ ប្លែក។ គេថា ពួកចារបុរសឬចារនារីប្រសប់លាក់ គំនិតណាស់ក្លែងធ្វើឬកពារឱ្យឯងក្ងេចខ្លួន។ អីចឹងមែនហើយហ្ន៎ ! នាងចារនារី ចន្ទមណីជា បុត្រីចារបុរស ទេពកោសល្យ វិចិត្រករ។

ក្រុមសម្ងាត់ធ្វើការម៉ត់ចត់ល្អណាស់ មិនងាយចោទព្រាវៗកើតទេ។ មួយទៀត វេគីគឺជាមិត្តស្និទ្ធិស្នាលរបស់ខ្ញុំ មានការស្ងាត់កំបាំងយ៉ាងណាពុំដែលលាក់លៀមនឹងគ្នាទេ។ ឯទីឃាវុធធ្លាប់បាននិយាយប្រាប់សម្ងាញ់ថា ខ្ញុំនចាប់គួចស្នេហានាងចន្ទមណី។ ទាល់តែច្បាស់ការពិតប្រាកដណាស់ហើយ ទើបហ៊ានមករំលាយបេតីដ៏ធំទូលាយរបស់ខ្ញុំ។ ពិតជាក្រុមចោរកម្មទាំងឪពុកទាំងកូនមែនហើយ ទើបឥឡូវលៃងឱ្យដំណឹងមកសោះ។ ខ្ញុំនអើយខំស្រឡាញ់គេបង់ចិត្ត!ឥឡូវគេប្បីរកវិធីកែខ្ញុំនសងសឹកសេចក្តីស្នេហាថ្ងាបរិសុទ្ធ ដែលមានមនុស្សពាលយកមកឈ្លីលេងជាល្បែង»។ គេស្តាយក្រោយចំពោះការកំន្តច្រឡំរបស់ខ្ញុំនលើនាងចន្ទមណី ធ្វើឱ្យគេក្លាយជាមនុស្សរមើលគុណ «ឯងនិយាយនោះត្រូវហើយ។ ខ្ញុំបានទៅស្បថអង្គរស្រេចថាបើមិនបានបាត់ដំបងមកវិញទេ ខ្ញុំក៏មិនខ្ចី ទាក់ចិត្តរាប់រកសៀមណាថាជាក្មេីម្រាក់ជាមិត្តភក្តិឬជាអ្វីទៀតទាំងអស់។ ប៉ុន្តែមកទាស់ស្តាយបន្តិច ព្រោះការកំន្តច្រឡំរបស់ឯងបានបណ្តាលឱ្យខ្ញុំប្រព្រឹត្តអាកប្បកិរិយាមិនគប្បីតបនឹងសេចក្តីគួរសមនឹងការយកចិត្តទុកដាក់របស់គេ។ មិនគួរសោះ! មិនគួរសោះ! នេះជាពាក្យបន្ទោស ខ្ញុំនឯងក្នុងពេលកំពុងដើរត្រួតគុម្ពផ្កា។ មិនគួរសោះ ! ស្តាយណាស់ មិនគប្បីសោះឱ្យជាតិដទៃមកមើលងាយខ្ញុំនបានថាជាមនុស្សពាលមនុស្សជួរមើលគុណគេ»។

៦. ប្រវត្តិការងារ

ក្រោយបញ្ចប់ការសិក្សា លោក នូ ហាច បានបំពេញការងារជាច្រើនក្នុងរាជការខ្មែរនាសម័យនោះដោយ ពេលខ្លះលោកកាន់កាប់តំណែងតួនាទីធំដំជាសមាជិករាជរដ្ឋាភិបាលជាមន្ត្រីការទូតជាន់ខ្ពស់ទៀតផង។ ចាប់តាំងពីពេលចូលបម្រើការងាររហូតដល់វ័យចូលនិវត្តន៍ លោកជាមន្ត្រីបួនជំនាន់ក្នុងរាជការខ្មែរសម័យនោះ គឺសម័យ អាណាព្យាបាលបារាំង សម័យឯករាជ្យ សម័យសង្គមរាស្ត្រនិយម និងសម័យសាធារណរដ្ឋខ្មែរ។ ប្រវត្តិការងាររបស់លោកដែលគេអាចរកឃើញ ជាអាទិ៍ ៖

ឆ្នាំ១៩៣២ បានប្រឡងជាប់ចូលរៀននៅអនុវិទ្យាល័យស៊ីសុវត្ថិ រហូតដល់ឆ្នាំ១៩៣៩ ក្រោយដែលបានជាប់មធ្យមសិក្សាបឋមភាគទីមួយហើយ លោកបានចូលធ្វើជាចៅក្រមផ្ទាស់មកក្នុំពេញវិញ ក្រោយរៀបអាពាហ៍ពិពាហ៍។

ឆ្នាំ១៩៤៧ បានទៅបម្រើនៅក្រសួងឃោសនាការ កាន់កាប់ខាងការផ្សាយផ្សាយកាសែតកម្ពុជា។

ឆ្នាំ១៩៤៨ ធ្វើជាលេខាផ្ទាល់នៃទ្រង់យុត្តិវង្ស នាយករដ្ឋមន្ត្រី បន្ទាប់ពីទ្រង់យុត្តិវង្សសុគតទៅលោកត្រឡប់មកក្រសួងឃោសនាការវិញ ធ្វើជានាយខុទ្ទកាល័យ។

ឆ្នាំ១៩៥២ លោកចូលទៅបម្រើនៅក្រសួងការបរទេសវិញដែលមានមុខងារជាមន្ត្រីការទូតខ្មែរ។

ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ១៩៥២ ដល់ថ្ងៃទី២៣ ខែមករា ឆ្នាំ១៩៥៣ សម្តេចព្រះ នរោត្តម សីហនុ ជានាយករដ្ឋមន្ត្រី បានតែងតាំងលោក នូ ហាច ជារដ្ឋលេខាធិការក្រសួងសាធារណការ និងទូរគមនាគមន៍ ដោយក្រឹត្យលេខ ២៥២ ថ្ងៃ១៥ ខែមិថុនា ឆ្នាំ១៩៥២។

លោក នូ ហាច បានចូលជាសមាជិកនៃសមាគមអ្នកនិពន្ធខ្មែរតាំងពីថ្ងៃទី១៧ ខែមករា ឆ្នាំ១៩៥៨។

ក្នុងក្រសួងការបរទេស លោកបានទទួលមុខតំណែងចុងក្រោយបង្អស់ជាឯកអគ្គរាជទូតខ្មែរ ប្រចាំនៅប្រទេសឥណ្ឌូនេស៊ី ប្រហែលនៅឆ្នាំ១៩៦៥។ លោកចូលនិវត្តន៍ ចូលភ្នំពេញប្រហែលមុនឆ្នាំ១៩៧៥ [16]។

ឯកសារមួយផ្សេងបញ្ជាក់ថា ក្នុងគ.ស ១៩៦៨ លោកបានចូលទៅធ្វើជាសុភាចារបុរសនៅសាលាដំបូង ខេត្តសៀមរាប។ ក្រោយមកក្រសួងយុត្តិធម៌បានផ្ទាស់លោកឱ្យមកធ្វើការនៅសាលាឧទ្ធរណ៍។ លោកបានធ្វើជានាយកាប៊ីណេត៍ ក្រសួងឃោសនាការជាតិក្នុងគ.ស .១៩៦០។ ក្នុងឆ្នាំ១៩៥២ លោកធ្វើជារដ្ឋលេខាធិការក្រសួងសាធារណការនិងទូរគមនាគមន៍។ លោកធ្លាប់ធ្វើជានាយការិយាល័យនៅក្រសួងសេដ្ឋកិច្ចជាតិបន្ទាប់មកធ្វើជានាយការិយាល័យវប្បធម៌ និងសេដ្ឋកិច្ចនៅក្រសួងការ បរទេស។ លុះមកដល់ឆ្នាំ១៩៥៥៣ លោក នូ ហាច បានធ្វើជាទីប្រឹក្សាស្ថានអគ្គរាជទូតប្រទេសកម្ពុជាប្រចាំប្រទេសថៃរហូតសព្វថ្ងៃនេះ [17]។

ក្នុងឋានៈជាទីប្រឹក្សានៅស្ថានឯកអគ្គរាជទូតប្រទេសកម្ពុជានាក្រុងបាងកក រាជការបានចាត់តាំងលោក នូ ហាច ជាតំណាងអចិន្ត្រៃយ៍នៃប្រទេសកម្ពុជានៅអមអង្គការអេកាហ្វេ នាក្រុងបាងកក។ ជាមួយគ្នានេះ រាជការបានចាត់តាំង លោក នូ ហាច ឱ្យបំពេញបេសកកម្មជាប្រតិភូតំណាងប្រទេសកម្ពុជា ជាច្រើនលើកក្នុងសន្និបាតថ្នាក់តំបន់មួយចំនួន ដូចជា រាជក្រឹត្យលេខ៦៨៥-ប.រ. ចុះថ្ងៃទី២៤ ខែធ្នូ គ.ស.១៩៦០ បានចាត់តាំងក្នាក់ងាររាជការមួយក្រុមជាតំណាងប្រទេសកម្ពុជានៅក្នុងសន្និបាតលើកទី ៨ នៃគណៈកម្មាធិការដឹកនាំខាងក្នុង និងគមនាគមន៍ ដែលមានធ្វើនៅក្រុងបាងកក ពីថ្ងៃ១៨ ដល់ថ្ងៃ២៤ វិច្ឆិកា គ.ស.១៩៦០ ដោយមានលោក នូ ហាច តំណាងអចិន្ត្រៃយ៍នៃប្រទេសកម្ពុជា នៅអមអង្គការ អេកាហ្វេ នាក្រុងបាងកក ជាប្រធាន និងលោក ឈុត ឈឿ វិស្វករនៃសាធារណៈការ ជាសមាជិក។ រាជក្រឹត្យលេខ ៥៣៥-ប.រ. ចុះថ្ងៃទី៩ តុលា គ.ស.១៩៦១ បានចាត់ក្នាក់ងាររាជការមួយក្រុមជាតំណាងប្រទេសកម្ពុជានៅកិច្ចចរចាអំពីវឌ្ឍនភាព នៃពាណិជ្ជកម្មសម្រាប់ភូមិភាគ នឹងនៅសន្និបាតលើកទី៣

[16] សូមមើល នូ ហាច មាលាដួងចិត្ត ដ.ឯ.ម ទំព័រ ក-ខ-គ។

[17] គឹម សែត ដុម ទំព័រ២៥៥ ២៥៦។

នៃគណៈកម្មាធិការខាងពាណិជ្ជកម្មនៅក្រុងបាត់កកក្នុងដើមខែមករា ឆ្នាំ១៩៦០ ដោយមានលោក នូ ហាច ទីប្រឹក្សានៅស្ថានឯកអគ្គរាជទូត ប្រទេសកម្ពុជានាក្រុងបាត់កក ជាប្រធាន និងលោក អ៊ុង ប៊ុនហោ លោក អ៊ុង បួយគ័ន លោក លឹម សូភាព ជាសមាជិក[១៨]។ រាជក្រឹត្យលេខ៥៣៧-ប.រ. ចុះថ្ងៃទី៩ តុលា គ.ស.១៩៦១ បានចាត់ក្នាក់ងាររាជការមួយក្រុមជាតំណាងប្រទេសកម្ពុជា នៅសន្និបាតលើកទី១៦ នៃអង្គការអេកាហ្វេ ដែលមានធ្វើនៅក្រុងបាត់កក ពីថ្ងៃ៩ ដល់ថ្ងៃ២១ មីនា គ.ស.១៩៦០ ដោយមានលោក សុន វឺនសៃ ទីប្រឹក្សាជំនាញនៅក្រសួងផែនការ ជាប្រធាន លោក នូ ហាច តំណាងអចិន្ត្រៃយ៍នៃប្រទេសកម្ពុជា នៅអមអង្គការអេកាហ្វេនាក្រុងបាត់កក លោក កែ ណុល លោក ប៉េង ប៉ុន ជាសមាជិក[១៩]។ រាជក្រឹត្យលេខ៥៦១-ប.រ. ចុះថ្ងៃទី៩ តុលា គ.ស.១៩៦១ បានចាត់ក្នាក់ងាររាជការមួយក្រុម ជាតំណាងប្រទេសកម្ពុជានៅសន្និសីទលើកទី៣ ខាងស្ថិតិលេខកៈ នៃអាស៊ីដែលធ្វើនៅក្រុងបាត់កក ពីថ្ងៃទី៥ ដល់ថ្ងៃ ទី១៥ មេសា គ.ស.១៩៦០ ដោយមានលោក សរ គិមតួយ រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ ជាប្រធាន លោក នូ ហាច តំណាងអចិន្ត្រៃយ៍នៃប្រទេសកម្ពុជា នៅអម អង្គការអេកាហ្វេនាក្រុងបាត់កក,លោក ស៊ីន សាមុត, លោក សៅ ខាន់ ជាសមាជិក[២០]។ ព្រះរាជក្រឹត្យលេខ៦១២-ប.រ.ចុះថ្ងៃទី១៥កញ្ញា គ.ស. ១៩៦១ បានចាត់អ្នករាជការមួយក្រុមជាតំណាងប្រទេសកម្ពុជា នៅសន្និបាត លើកទី១ ស្តីអំពីមណ្ឌលនៃវិថីអន្តរជាតិ ប្រារព្ធនៅក្រុងបាត់កក ពីថ្ងៃ១៩ ដល់ថ្ងៃ២១ វិច្ឆិកា គ.ស.១៩៥៩ ដែលមានលោក នូ ហាច តំណាងអចិន្ត្រៃយ៍នៃប្រទេសកម្ពុជា នៅអមអង្គការអេកាហ្វេនាក្រុងបាត់កកជាប្រធាន និង លោក ឈុត ឈឿ ជាសមាជិក[២១]។

ក្រឹត្យលេខ២៥២ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៥២ តែងតាំងលោក នូ ហាច ជាសមាជិករាជរដ្ឋាភិបាល មានឋានៈជារដ្ឋលេខាធិការក្រសួងសាធារណការ និងទូរគមនាគមន៍ ត្រូវបានជំនួសបញ្ជាក់ជាថ្មីដោយក្រឹត្យលេខ២៥៤ N-S ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៥២ [២២]។

ក្នុងឋានៈជារដ្ឋលេខាធិការក្រសួងសាធារណការ និងទូរគមនាគមន៍ ក្រៅពីបំពេញ កិច្ចការក្រសួងសាមី លោក នូ ហាច បានឆ្លៀតឱកាស ចុះសាកសួរសុខទុក្ខបងប្អូនប្រជាជនពិនិត្យស្ថានភាពស្រុកទេសតាមបណ្តា ខេត្ត

[១៨] សូមមើល រាជកិច្ច ឆ្នាំទី១៧ លេខ២៣០ ថ្ងៃព្រហស្បតិ៍ ទី១៩ តុលា គស១៩៦១ ទំព័រ៧៧០៣។

[១៩] សូមមើល រាជកិច្ច ឆ្នាំទី១៧ លេខ២៣០ ដ៤ម ទំព័រ ៧៧០៦។

[២០] សូមមើល រាជកិច្ច ឆ្នាំទី១៧ លេខ២៣០ ដ ៤ ម ទំព័រ ៧៧០៦។

[២១] សូមមើល រាជកិច្ច ឆ្នាំទី១៧ លេខ២០៤ ថ្ងៃសៅរ៍ ទី១៦ កញ្ញា គស១៩៦១ ទំព័រ៦៧១៩។

[២២] សូមមើល Journal official du Cambodge, Muttiém Année No 25 Jeudi 26 Juin 1952.p.1226

នានាផងដែរ។ ជាអាទិ៍ នៅចន្លោះថ្ងៃទី២១-២៣ តុលា១៩៥២ លោក នូ ហាច បាន អម ព្រះរាជដំណើរទស្សនាការនៃសម្តេចក្រុមព្រះ មុនីរ៉ែត ឧបនាយករដ្ឋមន្ត្រី (ប្រមុខក្រុម ខេមរ ភូមិន្ទ) នៅខេត្តតាកែវ និងកំពត[២៣]។

លោក នូ ហាច ជាអ្នកការទូតមួយ ជាន់ខ្ពស់។ លោកធ្លាប់បំពេញការកិច្ចការទូត មានឋានៈជាឯកអគ្គរដ្ឋទូតខ្មែរប្រចាំប្រទេស ឥណ្ឌូណេស៊ី[២៤]។ លោក នូ ហាច បានបំពេញមុខតំណែងជាអ្នកការទូតបង្គ់ក្រោយបង្គ់ក្នុងឋានៈជាឯកអគ្គរាជទូតនៃព្រះរាជាណាចក្រកម្ពុជា ប្រចាំនៅទីក្រុងហ្សាការតា ប្រទេសឥណ្ឌូនេស៊ី នៅឆ្នាំ១៩៦៩។ លោកបានចូលនិវត្តន៍នៅឆ្នាំ១៩៧២[២៥]។

តាមរយៈពត៌មាននេះ គេអាចសន្និដ្ឋានបានថា លោក នូ ហាច បានបម្រើការរាជការក្នុងកំឡុងពេល៣៣ឆ្នាំ ស្មើនឹង៥៥,៩៣ភាគរយនៃជីវិត៥៩ ឆ្នាំរបស់លោក ប្រសិនបើ លោកត្រូវពួកខ្មែរក្រហម សម្លាប់នៅឆ្នាំ ១៩៧៥ ។

ក្រៅពីតួនាទីខាងលើ លោក នូ ហាច ក៏បានចូលរួមចំណែកក្នុងសមាគមអ្នកនិពន្ធខ្មែរផងដែរ។ លោក នូ ហាច បានចូលរួមជាសមាជិកសមាគមអ្នកនិពន្ធខ្មែរតាំងពីថ្ងៃទី១៧ខែ មករា ឆ្នាំ១៩៥[២៦]។ លោក យូ បូ ប្រធានសមាគមអ្នកនិពន្ធខ្មែរជំនាន់ទី៧ មានប្រសាសន៍កាល ពីថ្ងៃសៅរ៍ទី៨ខែកុម្ភៈឆ្នាំ២០០៣ វេលាម៉ោងពីរសៀលថា លោក នូ ហាច ជាមនុស្សល្អ ស្លូតត្រង់ មានប្រជាប្រិយដោយលោកចូលចិត្តនិយាយចំៗ ឃើញយ៉ាងម៉េចថាអញ្ចឹង។ លោក នូ ហាច បានចូលរួមធ្វើជាគ្រូបង្រៀនថ្នាក់បណ្តុះ បណ្តាលអ្នកនិពន្ធវគ្គទី១(រយៈពេលប្រាំបួន ខែ)និង វគ្គទី២(រយៈពេលពីរឆ្នាំ)ដោយ បង្រៀនវិធីសាស្ត្រតែងកាព្យបារាំង[២៧]។

៧. មរណភាព

តាមរយៈប្រសាសន៍លោក តារី ទី បញ្ជាក់ថា លោក នូ ហាច ត្រូវបានគេសម្លាប់ក្នុងសម័យខ្មែរក្រហម។ កាលនោះខ្មែរក្រហមចូល មកដល់ថា អញ្ជើញគាត់ទៅប្រជុំមិនយកទៅ សម្លាប់ទេ ម្តាយក៏ឱ្យលោកឈឿទៅតាមមើលបងតែគេមិនយកទៅប្រជុំ បែរជាយកទៅសម្លាប់ ចោល។

អ្នកមីង រុំឌីបានប្រាប់ឱ្យដឹងពីមូល ហេតុនៃមរណភាពរបស់លោក នូ ហាចនេះថា ឮគេថាឱ្យគាត់ទៅវាស់ដី អ៊ុំ ឈឿ ក៏សុំគេទៅជាមួយបងថាបងចាស់គេក៏វាយចោលទាំងពីរនាក់បង

---

[២៣] ទស្សនាវដ្តីរូបភាពកម្ពុជា ក្រសួងឃោសនាការ ឆ្នាំទី១ ខែធ្នូ លេខ៤ ថ្ងៃទី១០ ធ្នូ ១៩៥២ ទំព័រ១០-១១។

[២៤] . សមាគមអ្នកនិពន្ធខ្មែរ ប្រវត្តិអ្នកនិពន្ធខ្មែរ ក្នុងទស្សនាវដ្តីអ្នកនិពន្ធខ្មែរ ឆ្នាំទី២ លេខ៣ ខែកុម្ភៈ ឆ្នាំ១៩៩៦ ទំព័រ១៣។

[២៥] Voir Khing Hoc Dy ***Ecrivains et expressions littéraires du Cambodge au XXéme siécle*** Op. cit. p.46.

[២៦] . Ib. id p.13.

[២៧] ការសម្ភាសន៍លោក យូ បូ ប្រធានសមាគមអ្នកនិពន្ធខ្មែរជំនាន់ ទី៧ ថ្ងៃសៅរ៍ ទី៨ ខែកុម្ភៈ ឆ្នាំ២០០៣។

ប្អូន(យោធានិយាយថា ហេតុតែបងប្អូនមិនដឹងគេយកបងទៅសម្លាប់) នៅភ្នំពេញ (ខ្ញុះថាម្តុំវត្តលង្កា ខ្ញុះថាម្តុំ ព្រែកលៀប)។

លោក នូ ហាច បាត់ខ្លួនក្រោយពេលប្រទេសខ្មែរធ្លាក់ចូលក្នុងកណ្តាប់ដៃរបបកម្ពុជាប្រជាធិបតេយ្យ។ លោកក៏មានវាសនាអាក្រក់ដូចប្រជាជនខ្មែរដទៃទៀតនៅក្នុងប្រទេសដែរ។ មជ្ឈដ្ឋានអ្នកសិក្សាសន្និដ្ឋានថាការបាត់ខ្លួនរបស់លោក នូ ហាច ប្រហែលជាត្រូវខ្មែរ ក្រហមយកទៅសម្លាប់ចោលក្នុងពេលកាន់អំណាច(ចន្លោះឆ្នាំ១៩៧៥-១៩៧៩) ដូចប្រជាជនខ្មែរឯទៀតៗដែរ។

៨. ស្នាដៃ

លោក នូ ហាច ជាអ្នកនិពន្ធខ្មែរដ៏ល្បីល្បាញមួយរូបមុនសម័យខ្មែរក្រហម។ ក្នុងវិស័យតែងនិពន្ធ គេរកឃើញប្រលោមលោកផ្នែកមនោសញ្ចេតនាចំនួនប្រាំរឿង និពន្ធឡើងដោយលោក នូ ហាច។ ស្នាដៃទាំងនោះគឺ៖

-រឿងផ្កាស្រពោន និពន្ធឆ្នាំ១៩៦០ បោះពុម្ពឆ្នាំ១៩៦៩

-រឿងមាលាដួងចិត្ត និពន្ធឆ្នាំ១៩៥២ បោះពុម្ពឆ្នាំ១៩៧២

-រឿងនារីជាទីស្នេហា និពន្ធឆ្នាំ ១៩៥៣ បោះពុម្ពឆ្នាំ១៩៥៣

-រឿងលាវណ្យនិងវរិន្ទ និពន្ធឆ្នាំ ១៩៥៣ បោះពុម្ពឆ្នាំ១៩៥៥

-រឿងត្រួយជីវិត និពន្ធឆ្នាំ ? បោះពុម្ពឆ្នាំ១៩៧៣

ព្រមទាំងអត្ថបទរឿងខ្លីៗ អត្ថបទកំណាព្យខ្លីៗ មួយចំនួនទៀត។ តែជាប្រការគួរឱ្យសោកស្តាយដែលមកដល់ពេលបច្ចុប្បន្ននេះ ស្នាដៃមួយចំនួនរបស់អ្នកនិពន្ធ នូ ហាច ត្រូវបានបាត់បង់រកដានមិនឃើញ។ ស្នាដៃដែលបាត់បង់ទាំងនោះ មានជាអាទិ៍ រឿងលាវណ្យនិងវរិន្ទ រឿងនារីជាទីស្នេហា រឿងត្រួយជីវិតជាដើម។

ឯកសារពិគ្រោះ

ស្នាដៃបោះពុម្ពផ្សាយ និងនិក្ខេបបទ

ល.រ អ្នកនិពន្ធ ឈ្មោះសៀវភៅ ពាង់ពុម្ព ឆ្នាំ

1. *ក្រុមអ្នកចងក្រង ៖ សំរាវជ្រាវជីវប្រវត្តិអ្នកនិពន្ធខ្មែរ ? ១៩៨៦*
2. *គីន ណាន ៖ ក្រមុំចូលមួប់និងពិធីរើសគូស្រករ ?១៩៨២*
3. *គឹមសែត ៖ ប្រវត្តិអក្សរសាស្ត្រ ? ?*
4. *ឃីង ហុកឌី ៖ ទិដ្ឋភាពទូទៅនៃអក្សរសាស្ត្រខ្មែរ ដៃគ្រឹនស ល់គារមាតតាន១៩៩៧*
5. *ឃីង ហុក ឌី, មាលីបទអក្សរសិល្ប៍ខ្មែរ សតវត្សទី១៩, បណ្ណាគារអង្គរ,២០០៧*
6. *ឃីង ហុក ឌី, មាលីបទអក្សរសិល្ប៍ខ្មែរ សតវត្សទី២០, បណ្ណាគារអង្គរ,២០០៧*
7. *ឃឹម សាគុណ ៖ សិទ្ធិមនុស្សតាមរយៈអក្សរសិល្ប៍ខ្មែរ ?១៩៨២*
8. *ឃឹម សំឱ ៖ប្រវត្តិអក្សរសាស្ត្រខ្មែរ ?១៩៦១*
9. *ឃួន សុខម្ហូ: ប្រវត្តិអ្នកនិពន្ធខ្មែរ ? ?*
10. *ង៉ុយ ៖ ច្បាប់ក្រមង៉ុយ ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ ១៩៧២,២៥១៦*
11. *ជួន ណាត ៖ វចនានុក្រមខ្មែរភាគ១-២ ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ ១៩៦៧*
12. *(ព្រះអង្គ) ឌួង ៖ ច្បាប់ស្រី ពុទ្ធសាសនបណ្ឌិត្យ ១៩៦២,២៥០៥*
13. *ត្រឹង ងា,ប្រវត្តិសាស្ត្រខ្មែរ, ភាគ១ ការផ្សាយរបស់អ្នកនិពន្ធ ភ្នំពេញ, ១៩៧៤*
14. *ត្រឹង ងា ៖ ប្រវត្តិសាស្ត្រខ្មែរ ភាគ២ ការផ្សាយរបស់អ្នកនិពន្ធ ភ្នំពេញ, ១៩៧៤,២៥១៨*
15. *ធ សោ ៖ លក្ខណៈទីពីកក្នុងអក្សរសិល្ប៍ និងសិល្បៈខ្មែរ មេរៀនសរសេរដៃ ២០០២*
16. *ហ៊ុន គឹមសៀ ៖ មូលដ្ឋានដើម្បីយល់អក្សរសាស្ត្រ ? ?*
17. *ញ៉ សាមី ៖ លក្ខណៈទំនេរនៃអក្សរសិល្ប៍និងសិល្បៈ*
18. *ញ៉ សាមី ៖លក្ខណៈទំនេរនៃអក្សរសិល្ប៍និងសិល្បៈ*
19. *ញ៉ សាមី ៖ តឋនិយមក្នុងអក្សរសិល្ប៍ខ្មែរសតវត្សទី២០*
20. *ញ៉ សាមី ៖ មូលដ្ឋានទ្រឹស្តីអក្សរសិល្ប៍ ប្រើប្រាស់ផ្នែកក្នុងសាលាគរុវិជ្ជាជាន់ខ្ពស់ ១៩៨៧*
21. *រស់ ចន្ត្រាបុត្រ ៖ អំពីស្នេហា សារពត៌មានមហាជន ១៩៧១*
22. *លាង ហ័បអាន ៖ សិក្សាប្រវត្តិអក្សរសាស្ត្រខ្មែរ ភាគ១ ?១៩៦៧*
23. *លាង ហ័បអាន ៖ សិក្សាអត្ថបទ ភាគ១ ?១៩៦៦*
24. *លាង ហ័បអាន ៖ សិក្សាអត្ថបទ ភាគ២ ?១៩៦៦*

25. *លាង ហាប់អាន ៖ ប្រជុំវិញ្ញាសាតែងសេចក្តីគំរូសំរាប់ថ្នាក់ទី៥.៦.៣ ទំនើប ?*
26. *លាង ហាប់អាន ៖ សិក្សាសង្ខេបរឿងកុលាបប៉ៃលិន ??*
27. *លី ជាមតេង ៖ អ្នកនិពន្ធខ្មែរដែលមានឈ្មោះល្បី បណ្ណាល័យអប្សរា សមាគមអ្នកនិពន្ធខ្មែរ ១៩៧២*
28. *លី សុមុនី, កំណាព្យខ្មែរ, ក្រសួងអប់រំយុវជន និង កីឡា, ២០០២*
29. *វ៉ាន់ឌី កាអុន ៖ វិភាគទាននៃក្នុងការសិក្សាអក្សរសិល្ប៍ខ្មែរ ??*
30. *វ៉ាន់ឌី កាអុន ៖ក្បួនចិត្តសាស្ត្រ ?១៩៧៣*
31. *វ៉ាន់ ឌីកាអុន៖ វិភាគទានក្នុងការសិក្សាច្រាកដនិយមនិងអណ្តែតអណ្តូងនិយម?១៩៧៣*
32. *វ៉ាន់ឌី កាអុន ៖សង្គមសាស្ត្រ?១៩៧៣*
33. *សិន សំណាង (**E.d.**) ៖ ខេមរវិទ្យា ចំណេះដឹងអំពីអតីតកាល និង ការរួមវិភាគ ទានក្នុងការស្តារ និង*
34. *ស្តាបនាប្រទេសកម្ពុជាឡើងវិញ ភាគ២ ពោធិពុម្ពសាកលវិទ្យាល័យភូមិន្ទភ្នំពេញ, ១៩៩៩*
35. *សម្ព័ន្ធអ្នកសារពត៌មាន រដ្ឋាភិបាលកម្ពុជា ពីឆ្នាំ១៩៧៧ ដល់ឆ្នាំ១៩៩៣ ??*
36. *សមាគមអ្នកនិពន្ធខ្មែរ ៖ ជីវប្រវត្តិសង្ខេបរបស់អ្នកនិពន្ធសមាជិកនៃសមាគម ១៩៧០*
37. *សមាគមអ្នកនិពន្ធបទភ្លេង នឹងទំនុកច្រៀង ៖លក្ខន្តិក: ? ១៩៦២*
38. *សោម សុមុនី ៖ អក្សរសិល្ប៍ពាក្យពេយខ្មែរ និក្ខេបបទថ្នាក់បណ្ឌិត, សំណេរដៃ, ?*
39. *សែម សូរ ៖ វិជ្ជានិពន្ធន៍ខ្មែរចម្រុះ បណ្ណាគារភ្នំពេញ, ១៩៦៣*
40. *ស៊ុំ ឈុំប៊ុន៖ តួអង្គក្នុងអក្សរសិល្ប៍ទំនើបខ្មែរពីទសវត្សទី៤០ដល់ទី៦០ និក្ខេបបទថ្នាក់បណ្ឌិត, ?*
41. *ស៊ុំ ឈុំប៊ុន ៖ អក្សរសិល្ប៍ខ្មែរ សម័យទំនើប មេរៀនសរសេរដៃ, ២០០២*
42. *ស៊ុំ ឈុំប៊ុន៖ គោលសង្ខេបនៃការសិក្សាប្រវត្តិអក្សរសិល្ប៍ខ្មែរ មេរៀនសរសេរដៃ,២០០២*
43. *អ៊ុក ចួន ៖ ចំណោទ និងសំរាយបញ្ហាក្នុងអក្សរសិល្ប៍ខ្មែរ សកព, ១៩៨៨*
44. *អ៊ុក សាម៉ន ៖ សិក្សាកថារឿងទុំ-ទាវ បណ្ណាគារភ្នំពេញ, ១៩៦៦,២៥០៨*
45. Klairung Amratisha: ***The Cambodian Novel,A study of its Emergence and Development*** ?1998
46. *អក្សរសាស្ត្រ-មនុស្សសាស្ត្រ, សាកលវិទ្យាល័យភូមិន្ទភ្នំពេញ លេខ១៩ ត្រីមាសទី៣ ឆ្នាំ២០០២*
47. *ឯកសារ ៖ សន្និសីទជាតិស្តីពី ការបណ្តុះបណ្តាលធនធានមនុស្សនៅកម្ពុជា ៖ តុល្យការ និង ចក្ខុវិស័យ រាជបណ្ឌិតសភាកម្ពុជា ២០០០*

48. *អត្តបទរឿង ល.រ ឈ្មោះអ្នកនិពន្ធ ឈ្មោះអត្តបទ ផ្សាយពី ពោធិ៍ពុម្ព កាលបរិច្ឆេទ*
49. *គឹម ហាក់ ទឹកទន្លេសាប ? ១៩៣៦*
50. *ឃើង ហុក ឌី, ទាវឯក, បណ្ណាគារអង្គរ,២០០៥។*
51. *ញ៉ុក ថែម កុលាបប៉ែលិន គ្រឹះស្ថានបោះពុម្ព និងចែកផ្សាយ ក្រ.អ.យ.ក. ២០០១,២៥៤៥*
52. *នូ ហាច ផ្កាស្រពោន ក្រសួងសិក្សាធិការជាតិ ពោធិ៍ពុម្ពរស្មី១៩៦០.២៥០៣*
53. *នូ ហាច មាលាដួងចិត្ត មជ្ឈមណ្ឌលស្រាវជ្រាវអារ្យធម៌ខ្មែរ១៩៨១*
54. *នូ ហាច មាលាដួងចិត្ត ឯកសារប្រើប្រាស់ផ្ទៃក្នុង សាលាគរុវិជ្ជាជាន់ខ្ពស់ ១៩៨៩*
55. *រឹម គីន សូផាត បណ្ណាគារ សេង ង្ហឹនហួត ភ្នំពេញ ១៩៦៥,២៥០៧*
56. *រឹម គីន នាង់សមាការី បណ្ណាល័យជាតិ ភ្នំពេញ ២០១៣*
57. *សោម ទុំទាវ ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ ១៩៧១,២៥១៤*
58. *ស្លេក ស្លៀ រ៉ូមេអូ និង ស៊ុលីយែត ប្រែសម្រួលដោយ ហង្ស ធុនហាក់ ពោធិ៍ពុម្ពសារពត៌មាននគរធំ ១៩៧១*
59. *ចៅកក្តីឧក ហង្សយន្ត ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ ១៩៩៨,២៥៤២*
60. *ប៉ូល វីរហ្សីនី ប្រែសម្រួលដោយ ហង្ស ធុនហាក់ ??*

បុណ្យវិសាខបូជា

ដោយៈ លោកស្រីបណ្ឌិត **ជា ឥណ្ណី**
ប្រធានផ្នែកធម្មសាស្ត្រ ចរិយាសាស្ត្រ,វិទ្យាស្ថាន
មនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម,រាជបណ្ឌិត្យសភាកម្ពុជា

ព្រះពុទ្ធសាសនា ត្រូវបានរដ្ឋធម្មនុញ្ញនៃប្រទេសកម្ពុជាចាត់ទុកថាជាសាសនារបស់រដ្ឋ។ ពិធីបុណ្យពិសាខបូជា គឺឈ្មោះពិធីបុណ្យមួយយ៉ាងធំនៅក្នុងព្រះពុទ្ធសាសនា ពោលគឺគេអាចចាត់ទុកជាពុទ្ធានុស្សរណកិច្ចមួយដ៏សំខាន់ដើម្បីជាការរឭកនឹកដល់ព្រះសម្មាសម្ពុទ្ធសមណគោតម ដែលជាព្រះបរមគ្រូនៃពុទ្ធសាសនិក នាថ្ងៃពេញបូណ៌មី គឺថ្ងៃ១៥កើត ខែពិសាខ ដែលពុទ្ធសាសនិកទាំងគ្រហស្ថ និងបព្វជិតតែងធ្វើសក្ការបូជាប្រកបដោយជំនឿថា ជាមហាកុសលដ៏ប្រសើរ។

តើបុណ្យពិសាខបូជាមានអត្ថន័យយ៉ាងណាខ្លះសម្រាប់ពុទ្ធសាសនិកខ្មែរ?

បូជា សំ. បា.(ន.)ការថ្វាយឬជូនវត្ថុអ្វីៗចំពោះបូជនីយបុគ្គល;ការស្តាប់ឱវាទ ប្រព្រឹត្តតាមឱវាទរបស់បុគ្គលដែលគួរគោរព។ ខ្មែរយើងច្រើនប្រើជា កិ.ថ្វាយ,ជូន : សូមបូជាកម្រងផ្កានេះ ចំពោះព្រះរតនត្រ័យ; ដុត, រំលាយ (សព) : បូជាសព, បូជាព្រះសព (ច្រើនប្រើចំពោះតែសពបព្វជិត;ម.ព.ឈាបនកិច្ចទៀតផង)។ បូជារហបុគ្គល (--រៈហៈបុកគល់) ដូចគ្នានឹងបូជនីយបុគ្គលដែរ (ម.ព.បូជនីយៈ ទៀតផង) ។

ពិសាខ--សាកបា.;សំ.(ន.) (វិសាខ;វិគាខ) ឈ្មោះខែទី៦ តាមចន្ទគតិ:ខែពិសាខ។ ឈ្មោះនក្សត្រ ឬនក្ខត្តឫក្សទី១៦ : ពិសាខឫក្ស។

វិសាខពិធីបុណ្យ ពិសាខបូជា គឺឈ្មោះពិធីបុណ្យ ឬការធ្វើសក្ការបូជាក្នុងថ្ងៃពេញបូណ៌មីខែពិសាខ ជាថ្ងៃដែលព្រះសក្យមុនីសម្មាសម្ពុទ្ធទ្រង់ប្រសូត ទ្រង់បានបរមាភិសម្ពោធិ ទ្រង់រលត់ខន្ធចូលកាន់បរិនិព្វាន រំឭកដល់ព្រះគុណរបស់ព្រះអង្គជាការបូជាពិសេសម្យ៉ាង សម្រាប់ពុទ្ធសាសនិកជនទាំងបព្វជិតទាំងគ្រហស្ថតែងតែនាំគ្នាធ្វើរាល់ឆ្នាំ រាប់ថាជាបុណ្យសម្រាប់ពុទ្ធសាសនាថ្ងៃពិសាខបូជាធ្វើពិសាខបូជា។

១. អត្ថន័យនៃពិធីបុណ្យវិសាខបូជា

ពាក្យថា"***វិសាខបូជា***"មកពីពាក្យថា"***វិសាខបុណ្ណមីបូជា***" ប្រែថា ការបូជាក្នុងថ្ងៃពេញបូណ៌មី ខែ ពិសាខ គឺខែទី៦ ដោយរាប់ពីខែមិគសិរបុស្សមាឃផល្គុនចៃត្រ ពិសាខជាដើម។

ការដែលប្រារព្ធពិធីបូជានាថ្ងៃ១៥កើត ខែពិសាខនេះ អាស្រ័យដោយលោកអ្នកប្រាជ្ញខាងពុទ្ធសាសនាបានកំណត់ទុកក្នុងគម្ពីរបឋមសម្ពោធិថា ជាមហាមង្គល អកិលក្ខិតកាល គឺជាថ្ងៃមហាមង្គល ត្រូវនឹងថ្ងៃដែលព្រះសម្ពុទ្ធបរមគ្រូទ្រង់ប្រសូតចាកឧទរមាតា ទ្រង់ត្រាស់ដឹងអនុត្តរសម្មាសម្ពោធិញ្ញាណ និងទ្រង់រំលត់ខន្ធចូលកាន់ព្រះបរមនិព្វាន ពោលគឺព្រឹត្តិការណ៍ទាំងបីនេះ កើតឡើងនៅចំថ្ងៃ១៥កើត ពេញបូណ៌មី ដែលមានព្រះច័ន្ទពេញវង់ក្នុងខែពិសាខដូចគ្នា ខុសតែឆ្នាំប៉ុណ្ណោះ។

- ព្រះអង្គទ្រង់ព្រះប្រសូតចាកពីព្រះឧទរព្រះមាតា

នៅពេលដែលព្រះនាង**សិរិមហាមាយាទេវី** ព្រះអគ្គមហេសីរបស់ព្រះគម្តែង**សុទ្ធោទនៈ** នៃរាជធានីកបិលពស្តុដែនសក្កៈ ទ្រង់គក៌ហៀបនឹងដល់ថ្ងៃប្រសូតិកម្ម ព្រះនាងក៏លាព្រះស្វាមីធ្វើដំណើរទៅកាន់មាតុនគរ គឺទេវទហៈនគរ ដើម្បីសម្រាលព្រះរាជឱរសតាមទំនៀមនិយមរបស់ព្រាហ្មណ៍ក្នុងសម័យនោះ។ លុះធ្វើដំណើរទៅដល់ព្រំដែនឈ្មោះឧទ្យានលុម្ពិនីវ័នរវាងនគរកបិលពស្តុ និងទេវទហៈនគរ ព្រះនាងក៏ឈាងចូលទៅសម្រាកព្រះវរកាយក្រោមដើមសាលព្រឹក្ស។

នៅខណៈនោះ ព្រះនាងបានសម្រាលព្រះរាជឱរសក្រោមដើមសាលព្រឹក្សនោះឯង ដែលត្រូវនឹងពេលព្រឹកថ្ងៃសុក្រ តិថី ១៥កើត ខែពិសាខ ឆ្នាំច មុនពុទ្ធសករាជ៨០ឆ្នាំ។ លុះស្តាប់ព្រះដំណឹងថាព្រះមហេសីបានប្រសូតព្រះរាជឱរសដូច្នោះ ព្រះ**សុទ្ធោទនៈ**ក៏ត្រាស់បញ្ជាឱ្យក្បួនដង្ហែវិលត្រឡប់ចូលព្រះនគរវិញកាល បើប្រសូត បានចំនួន៥ថ្ងៃគត់ ហើយព្រះរាជឱរសអង្គនេះក៏ត្រូវបានសន្មតឱ្យព្រះនាមថា**សិទ្ធត្ថៈ** ប្រែថា អ្នកសម្រេចប្រយោជន៍ដល់សត្វលោកទាំងពួង។

-ថ្ងៃព្រះអង្គត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណ

ក្រោយពីព្រះអង្គចេញសាងព្រះក្នួសបានចំនួន៦ព្រះវស្សា ស្ថិតក្នុងព្រះជន្ម៣៥ព្រះវស្សា ព្រះសមណសិទ្ធត្ថអង្គនោះ បានប្រព្រឹត្តនូវតបធម៌ ហើយប្រព្រឹត្តនូវទុក្ករកិរិយាមក ព្រះអង្គបានត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណ ស្ថិតក្នុងថ្ងៃពុធ ពេញបូណ៌មី(១៥កើត)ខែវិសាខ ឆ្នាំរកា នៅក្នុងស្រុកឧរុវេលាប្រទេសសេនានិគមក្បែរនឹងស្ទឹងនេរញ្ជរា វេលាព្រឹកព្រាងទៀបភ្ញី ក្នុងគម្រប់ព្រះជន្ម៣៥ឆ្នាំ នៅឯពុទ្ធគយា។

- ជាថ្ងៃព្រះយាងចូលព្រះបរមបរិនិព្វាន

ក្រោយអំពីព្រះអង្គត្រាស់ដឹង និងផ្សព្វផ្សាយព្រះធម៌អស់រយៈពេល៤៥ព្រះវស្សា

រហូតដល់ព្រះជន្មបាន៨០ព្រះវស្សា ហើយព្រះអង្គក៏ទ្រង់រំលត់ព្រះខន្ធចូលកាន់ព្រះបរមនិព្វាន ដោយអនុបាទិសេសនិព្វានក្នុងថ្ងៃអង្គារពេញបូណ៌មី (១៥កើត) ខែវិសាខ ឆ្នាំម្សាញ់ វេលាពត្រីជិតភ្លឺ ក្នុងព្រះជន្មគម្រប់៨០ ព្រះវស្សាគត់ (មុនពុទ្ធសករាជ១ថ្ងៃ)ក្នុងសាលវនឧទ្យានចន្ទោះ ដើមរាំងទាំងគូ ក្បែរនគរកុសិនារា។

ការដែលពោលថាជាហេតុការណ៍ដ៏អស្ចារ្យ ពីព្រោះសម្តេចព្រះបរមសាស្ដាចារ្យរបស់យើង ព្រះអង្គ ប្រសូត ត្រាស់ដឹង និងបរិនិព្វាន នៅថ្ងៃ១៥កើត ខែពិសាខ ដូចគ្នា ទោះបី ជាថ្ងៃខាងសុរិយគតិ និងឆ្នាំខាង ចន្ទគតិខុសគ្នាក៏ដោយ ក៏ចាត់ថាជាហេតុការណ៍អស្ចារ្យបាន ព្រោះមនុស្សភាគច្រើនកើតនិងស្លាប់នៅតិថីនិងខែខាងចន្ទគតិផ្សេងៗគ្នា ប៉ុន្តែព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ប្រសូត ត្រាស់ដឹង និងបរិនិព្វាននៅតិថី និងខែខាងចន្ទគតិដូចគ្នា ចាត់ទុកថាជាអច្ឆរិយបុគ្គលដែលគួរដល់ការចងចាំរបស់ពិភពលោក។

ក៏ព្រោះហេតុនោះហើយបានជាអ្នកប្រាជ្ញចងក្រងជាគាថាទុកដូច្នេះថា **អាសាឡ បុណ្ណមោក្កន្តោ វិសា ខេ យេវ និក្ខមិ វិសាខបុណ្ណមី សម្ពុទ្ធោ វិសាខេ បរិនិព្វុតោ** ប្រែសេចក្តីថា៖ ព្រះពុទ្ធយាងចុះកាន់គភ៌នៃព្រះវរមាតាក្នុងថ្ងៃពេញបូណ៌មី ខែអាសាឍ ទ្រង់ប្រសូតក្នុងថ្ងៃពេញបូណ៌មី ខែពិសាខ បានត្រាស់ដឹងជាព្រះពុទ្ធក្នុងថ្ងៃពេញបូណ៌មី ខែពិសាខ និងទ្រង់ចូលបរិនិព្វាន ក៏ថ្ងៃពេញបូណ៌មី ខែពិសាខ(ផ្សេងតែឆ្នាំ)។ ជាប្រពៃណី ពិធីវិសាខបូជា គេតែងតែនាំគ្នាធ្វើនៅក្នុងវេលាពត្រី ពីព្រោះតម្រូវទៅតាមពាក្យថា"បុណ្ណមី"មានសេចក្តីថាខែពេញបូណ៌មី។

ម្យ៉ាងទៀតការប្រារព្ធពិធីបុណ្យវិសាខបូជានៅក្នុងពេលរាត្រី អាស្រ័យដោយលក្ខណៈងាយស្រួល២យ៉ាងគឺ៖

.ដើម្បីនឹងបានឱកាសអុជគ្រឿងប្រទីបជ្វាលា បូជាឱ្យភ្លឺរុងរឿងរន្ទាលច្រាលឆ្ពិនឆ្ពោះនិងដើម្បីបើកឱកាសឱ្យពុទ្ធបរិស័ទបានជួបជុំគ្នាដ៏ច្រើនកុះករទាំងប្រុសទាំងស្រី អាចបំពេញនូវបុណ្យកុសលកម្មមួយនេះដោយសេចក្តីសប្បាយរីករាយពីព្រោះពេលយប់ជាវេលាទំនេរផង។

២. ប្រវត្តិ និងដើមកំណើតនៃពិធីបុណ្យវិសាខបូជា

ពិធីវិសាខបូជានេះចាត់ទុកថាជាបុណ្យដ៏ធំមួយ ដែលមានមហាជនក្មេងចាស់ប្រុសស្រីបានជួបជុំគ្នាអ៊ូអរ ដោយនាំទៅជាមួយនូវគ្រឿងសក្ការបូជា មានទៀន ធូប ផ្កា ភ្លី និងប្រទីបជ្វាលាតូច-ធំ អុចបំភ្លឺ ព្រោងព្រាតនៅតាមទីវត្តអារាម។ និយាយរួមការធ្វើបុណ្យវិសាខបូជា គឺដើម្បីឲ្យក

ដល់ថ្ងៃដែលជាមហាមង្គលអតិលក្ខិតកាល[1] ទាំង៣ដូចពោលខាងលើ។ រីឯពិធីដែលធ្វើឱ្យបានត្រឹមត្រូវ គឺគួរតែមានការសម្តែងរឿងពុទ្ធប្រវត្តិតាំងអំពីដើមរហូតដល់ចប់ ដើម្បីជាគ្រោងបណ្តុះបសាទ[2]សទ្ធាឱ្យកើតមានក្នុងគុណព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃឱ្យកាន់ខ្ជាំងក្តាឡើង ហើយពិធីដែលប្រជាជនខ្មែរយើងធ្លាប់ធ្វើរួចហើយចាត់ទុកជាបែបផែនដែលល្អ និងសមស្របទៅនឹងប្រពៃណីពីបុរាណ។

ប្រការដែលគួរឱ្យកត់សម្គាល់មួយទៀត គឺអង្គការសហប្រជាជាតិក៏បានប្រកាសនៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៩៩ ទទួលស្គាល់វិសាខបូជាជាពិធីបុណ្យអន្តរជាតិមួយ ដែលគេអាចប្រារព្ធធ្វើនៅតាមការិយាល័យទាំងឡាយរបស់អង្គការសហប្រជាជាតិនៅលើពិភពលោក ព្រោះគេឃើញនូវគុណប្រយោជន៍របស់ព្រះពុទ្ធសាសនាៈ ទី១ជាសាសនាដែលមានចំណាស់យូរ គឺមានចំណាស់រហូតដល់ទៅ២៥៦១ឆ្នាំទៅហើយ ទី២ ជាសាសនាមានគោលការណ៍សន្តិភាពមិនកាប់សម្លាប់គ្នា គោរពសិទ្ធិគ្នាក្នុងការរស់នៅទៅវិញទៅមក និងទី៣ ពុំដែលមានសង្គ្រាមដែលកើតឡើងក្នុងនាមព្រះពុទ្ធសាសនានោះទេ ហើយនិងមានប្រជាជននៅលើពិភពលោកទាំងមូលរហូតដល់ទៅជាង ៥០០ លាននាក់នាពេលបច្ចុប្បន្ននេះ បានកាន់ព្រះពុទ្ធសាសនានេះ។ កត្តាទាំងអស់នេះហើយដែលអង្គការសហប្រជាជាតិបានលើកតម្កៃព្រះពុទ្ធសាសនា ថាបានចូលរួមចំណែកដ៏ក្រាស់ក្រែលធំធេងណាស់ក្នុងសន្តិភាពពិភពលោក និងការរួមរស់ជាមួយគ្នាដ៏សុខសប្បាយ។ ចាប់តាំងពីអង្គការសហប្រជាជាតិបានទទួលស្គាល់វិសាខបូជា ជាទិវាបុណ្យអន្តរជាតិមក ប្រទេសដែលគោរពព្រះពុទ្ធសាសនាជាច្រើននៅលើសកលលោក បាននាំគ្នាប្រារព្ធ

---

[1] *អតិលក្ខិតកាលអ:កិលៅក-ខិត:--បា.;សំ.(ន.)(< អតិ-លក្ខិត"ដែលកំណត់ទុក"+កាលឬសមយ;អតិ-លក្សិត--)កាលឬសម័យដែលកំណត់ទុក (ដូចយ៉ាងថ្ងៃមាឃបូជា, វិសាខបូជា, ថ្ងៃត្រូវធ្វើទក្ខិណានុប្បទានចំពោះបុព្វបុរស, ថ្ងៃរំឭកគុណឬរំឭកដល់ហេតុណាមួយជាដើម ដែលត្រូវធ្វើរៀងរាល់ឆ្នាំ) : ថ្ងៃ១៥កើត ខែមាឃនិងខែពិសាខ រៀងរាល់ឆ្នាំជាអតិលក្ខិតសម័យនៃការប្រជុំគ្នាធ្វើមាឃបូជា, ធ្វើវិសាខបូជា នៃពុទ្ធសាសនិកជនទាំងបព្វជិតទាំងគ្រហស្ថ។ (ជួន ណាត វចនានុក្រមខ្មែរ)*

[2] *បសាទ ឬ ប្រសាទ-សាត សំ.; បា.(ន.) (បសាទ) សេចក្តីជ្រះថ្លា ។ អាយតន:សម្រាប់ទទួលសម្ផស្សដឹងអារម្មណ៍គឺគ្រឿងវិសេសដែលមានប្រចាំតាមធម្មជាតិ នៅក្នុងរូបកាយមនុស្សសត្វសម្រាប់ទទួលដឹងនូវអារម្មណ៍ពីខាងក្រៅដែលមកប៉ះពាល់ : ភ្នែកអាចមើលឃើញរូបបាន ដោយសារប្រសាទសម្រាប់ភ្នែក, ត្រចៀកអាចស្តាប់ឮសំឡេងបានដោយសារប្រសាទសម្រាប់ត្រចៀក។ល។ កាលបើប្រសាទនោះវិនាសខូចហើយភ្នែកមិនអាចមើលឃើញរូប, ត្រចៀកមិនអាចស្តាប់ឮសំឡេងបានឡើយ (ម. ព.ចក្ខុបសាទ,ជិវ្ហាបសាទ ផង)។ កិ. ជ្រះថ្លា,ពេញចិត្ត : ប្រសាទពរ (ប្រសាត-ព) គឺឲ្យពរដោយពេញចិត្ត(ព.កា.) : ប្រជាពលរដ្ឋឈូសរមកដោយអំណរ ប្រសាទប្រសិទ្ធពរថ្វាយ។*

ធ្វើពិធីបុណ្យវិសាខបូជាជាសកល ដោយដាក់ឈ្មោះថា UN-**វិសាខ** ឬ **វិសាខបូជានៃអង្គការសហប្រជាជាតិ**។

បើគិតមកដល់បច្ចុប្បន្ននេះ វិសាខបូជាគឺជាបុណ្យប្រវត្តិសាស្ត្រមួយរបស់ព្រះពុទ្ធសាសនា ហើយក៏ជាអាយុរបស់ព្រះពុទ្ធសាសនា ដែលយើងបានកាន់ ពីព្រោះពុទ្ធសាសនាយើងរាប់ជាសកវាជឡើង នៅថ្ងៃបន្ទាប់ពីថ្ងៃដែលព្រះសម្មាសម្ពុទ្ធបានចូលបរិនិព្វាន។ ដូច្នេះថ្ងៃវិសាខបូជាគឺប្រារព្ធទៅដល់ថ្ងៃដែលព្រះសម្មាសម្ពុទ្ធបានប្រសូត ត្រាស់ដឹង និងចូលបរិនិព្វាន។ គ្រប់ប្រទេសទាំងអស់ដែលកាន់ព្រះពុទ្ធសាសនានៅភូមិភាគអាស៊ីអាគ្នេយ៍យើងនេះក្តី នៅក្នុងពិភពលោកទាំងមូលក្តី គឺពុទ្ធសាសនិកជនទាំងអស់តែងតែប្រារព្ធធ្វើទិវាវិសាខបូជានេះ។

ទាក់ទងនឹងប្រវត្តិដើមកំណើតនៃពិធីបុណ្យវិសាខបូជានេះ សៀវភៅ "ព្រះរាជពិធីទ្វាទសមាស" ដែលជាការបោះពុម្ពផ្សាយរបស់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ក្នុងគ្រិស្តសកវាជ ១៩៥១ បានសរសេរកត់ត្រាថា បន្ទាប់ពីព្រះពុទ្ធទ្រង់បានរំលត់ខន្ធចូលកាន់បរិនិព្វានអស់រយៈពេលជាច្រើនរយឆ្នាំទៅហើយ ទើបគេសង្កេតឃើញបុណ្យវិសាខបូជានេះ ត្រូវបានប្រារព្ធឡើងនៅក្នុងប្រទេសឥណ្ឌា។

ប៉ុន្តែទោះបីជាពិធីបុណ្យវិសាខបូជាត្រូវបានពុទ្ធបរិស័ទនាំគ្នាប្រារព្ធធ្វើជាទំនៀមទម្លាប់តាំងពីបុរាណយូរអង្វែងមកហើយក្តី ក៏អ្នកសិក្សាស្រាវជ្រាវផ្នែកពុទ្ធសាសនាខ្លះ បានបញ្ជាក់ថា ហាក់ដូចជាពុំមានឯកសារណាមួយកត់ត្រាអំពីកាលបរិច្ឆេទឬថ្ងៃខែ ឆ្នាំ នៃការប្រារព្ធពិធីបុណ្យវិសាខបូជាឱ្យបានច្បាស់លាស់នោះឡើយ។ បើតាមការស្រាវជ្រាវអំពីប្រវត្តិបុណ្យវិសាខបូជាដូចជា នៅក្នុងប្រទេសឥណ្ឌាជាដើម ទាំងនៅក្នុងសម័យកាលនៃស្តេចធម្មាសោក ឬព្រះបាទអសោក ដែលជាអធិរាជមួយអង្គមានសទ្ធាជ្រះថ្លា និងបានឧបត្ថម្ភ ព្រះពុទ្ធសាសនាយ៉ាងខ្លាំងក្លាក្រៃលែង ក៏គេមិនឃើញមានឯកសារបញ្ជាក់ថា ព្រះរាជាអង្គនោះបានធ្វើបុណ្យវិសាខបូជាក្នុងរជ្ជកាលរបស់ព្រះអង្គក្នុងរវាង២៧៣ឆ្នាំមុនគ្រិស្តសកវាជនោះឡើយ។ ម្យ៉ាងវិញទៀត មានឯកសារខ្លះនិយាយថា ក្រោយពីព្រះពុទ្ធទ្រង់បរិនិព្វានទៅក្នុងពុទ្ធសកវាជ១៥០០ កើតមានកលិយុគវិវាទផ្នែកសាសនាធ្វើឱ្យបពុទ្ធបរិស័ទនៅឥណ្ឌាក្នុងពេលនោះ មិនមានឱកាសក្នុងការប្រារព្ធបុណ្យវិសាខបូជាឡើយ...»។

នៅក្នុងសៀវភៅ "**ព្រះរាជពិធីទ្វាទសមាស**" ឬ "**ពិធីបុណ្យទាំង១២ខែ**" ដែលរៀបរៀងដោយលោកឧកញ៉ា **ឈឹម ក្រសេម**និងឃុនឧត្តមប្រីជា **ចាប ពីន** ក៏បានកត់ត្រាឱ្យដឹងផងដែរថា គឺបានផ្តើមក្នុងរជ្ជកាលព្រះបាទសម្តេចព្រះហរិរក្សរាមាឥស្សរាធិបតី ព្រះអង្គឌួង ដែលគង់នៅក្រុងឧដុង្គ ក្នុងពុទ្ធសកវាជ ២៣៩៧ ឬគ្រិស្តសកវាជ

១៨៥៤។ ១១ឆ្នាំក្រោយមក នៅពេលដែលព្រះអង្គបានលើកទីក្រុងមកតាំងនៅភ្នំពេញ ក្នុងពុទ្ធសករាជ២៦០៨ ពិធីបុណ្យវិសាខបូជា ក៏ត្រូវបានប្រារព្ធធ្វើជាទូទៅនៅគ្រប់វត្តអារាម ជាប់ជាទំនៀមមកដល់បច្ចុប្បន្ននេះ។ រីឯឯកសារដែលស្រាវជ្រាវចងក្រងដោយ លោក **ជា គាន** អគ្គលេខាធិការរងទី១ នៃគណៈកម្មាធិការរៀបចំបុណ្យជាតិ និងអន្តរជាតិ បានសរសេរបញ្ជាក់ថា ការប្រារព្ធពិធីបុណ្យវិសាខបូជានាពេលនោះ ជាទូទៅគេឃើញច្រើនធ្វើក្នុងវត្តអារាមនៅពេលរាត្រី ពីព្រោះគេចង់តម្រូវឱ្យត្រូវនឹងពាក្យថា បុណ្ណមី ឬព្រះច័ន្ទពេញបូណ៌មី។ ម្យ៉ាងទៀត គឺផ្តល់ឱកាសដល់ពុទ្ធបរិស័ទប្រុសស្រីចាស់ក្មេងឱ្យបានមកជួបជុំគ្នាធ្វើការគោរពបូជាដោយអុជភ្លើងទៀន ប្រទីបជ្វាលា ឱ្យបានភ្លឺព្រោងព្រាតឡើង។ **តើប្រទេសណាជាអ្នកចាប់ផ្តើមធ្វើបុណ្យវិសាខបូជានេះមុនគេ?**

នៅពេលដែលពុទ្ធបរិស័ទក្នុងប្រទេសកម្ពុជាគោរពប្រតិបត្តិពុទ្ធសាសនាទាំងឡាយ បានជ្រួតជ្រាបអំពី អភិលក្ខិតកាលនិយមគឺ៖ ថ្ងៃប្រសូត ត្រាស់ដឹង និងបរិនិព្វាន របស់ព្រះសម្មាសម្ពុទ្ធថា ដែលសុទ្ធតែជាថ្ងៃពេញបូណ៌មីខែវិសាខមកគេក៏នាំគ្នាធ្វើពិធីវិសាខបូជាជារៀងរហូតតាំងពីបុរាណកាលមក។ តាមការស្រាវជ្រាវឃើញថា ការធ្វើពិធីវិសាខបូជានេះ ពុំមែនធ្វើក្រោយព្រះពុទ្ធបរិនិព្វានទៅថ្មីៗនោះទេ គឺធ្វើក្រោយពេលដែលព្រះពុទ្ធបរមគ្រូទ្រង់បរិនិព្វានកន្លងទៅជាច្រើនរយឆ្នាំ។

បញ្ជាក់៖ បុណ្យវិសាខបូជា ត្រូវបានអង្គការសហប្រជាជាតិទទួលស្គាល់ចំពោះបណ្តាប្រទេសកាន់ព្រះពុទ្ធសាសនាលើសកលលោក ក្នុងនោះមានប្រទេសកម្ពុជាផងដែរ តាំងពីឆ្នាំ១៩៩៩ មកម៉្លេះ។

ចំណែកនៅប្រទេសកម្ពុជា ដែលមានព្រះពុទ្ធសាសនា បានមកប្រតិស្ឋានតាំងពីដំបូង ហើយស្ថិតនៅជាប្រទេសមានឥស្សរភាពជាយូរណាស់មកហើយ តែបើតាមការស្រាវជ្រាវពិនិត្យមើលនៅក្នុងព្រះរាជ ពង្សាវតារ ឬក្នុងសេចក្តីកំណត់ហេតុផ្សេងៗតាំងពីសម័យនគរភ្នំ"ហ្វូណន" រហូតមកដល់សម័យក្រុងលង្វែក មិនប្រាកដថាមានទំនៀមធ្វើវិសាខបូជានេះឡើយ។ តែបើយោងទៅលើសេចក្តីថា ព្រះពុទ្ធសាសនាលិទ្ធិលង្កា ក៏បានផ្សាយចូលមកកម្ពុជរដ្ឋក្នុងសម័យជាមួយគ្នានឹងក្រុងសុខោទ័យ គួរសន្និដ្ឋានបានថា មានទំនៀមធ្វើវិសាខបូជារួចមកហើយ ដូចជាប្រទេសថៃដែរ តែកម្ពុជាយើងពុំឃើញមានឯកសារជាកស្តាង ឬក៏មានដែរ តែត្រូវរលាយសាបសូន្យអស់ទៅ។ លុះចំណេរយូរលង់មក គឺក្នុងសម័យក្រុងអយុធ្យា(ខាងថៃ) និងក្នុងសម័យក្រុងលង្វែក(ខាងខ្មែរ) ទំនៀមទម្លាប់ធ្វើវិសាខបូជាត្រឡប់ជាសាបសូន្យទៅវិញដូចជាត្រូវបានបំភ្លេចសូន្យឈឹងទាំងស្រុង ព្រោះមិនមាន

ប្រាកដក្នុងឯកសារណាមួយថាបានធ្វើឡើយ។ ទាំងនេះព្រោះហេតុអ្វី?

តាមការសន្និដ្ឋានក៏បានបញ្ជាក់ឱ្យឃើញថា:

១-ព្រោះព្រះសង្ឃដែលនិមន្តមកអំពីលង្កានោះផុតរលត់អស់ទៅ

២-ព្រោះរឿងបឋមសម្ពោធិកថា ស្តីអំពីរឿងពុទ្ធប្រវត្តិក្នុងពេលនោះ មានតែជាភាសាបាលី ហើយនៅរ៉ាត់រាយក្នុងគម្ពីរព្រះត្រៃបិដកខ្ទះ ក្នុងអដ្ឋកថាខ្ទះ ពុំទាន់ចងក្រងរួបរួម និងពុំទាន់បានប្រែរៀបរៀងជាភាសាសម្រាយជាតិនៅឡើយ។ រីឯអ្នកស្រុកក៏ពុំទាន់ជ្រួតជ្រាបជាទូទៅគ្រប់គ្នាដែរ គឺមានតែព្រះសង្ឃដែលចេះភាសា បាលី ទើបអាចដឹងបានខ្ទះ ព្រោះហេតុនេះហើយទើបពិធីបុណ្យវិសាខបូជា ត្រូវបានសាបសូន្យទៅវិញ។

ចំណេរក្រោយមកប្រទេសថៃក្នុងសម័យក្រុងទេព "បាងកក" តាមសេចក្តីដែលមានក្នុងសៀវភៅ**ព្រះរាជពិធីសិបសងខឿន** ថា ក្នុងរជ្ជកាលទី២ក្នុងឆ្នាំឆ្លូវនព្វស័ក ពុទ្ធសករាជ២៣៦០ គ្រិស្តសករាជ ១៨១៧ ទើបកើតមានពិធីវិសាខបូជាដោយពេលនោះ មានសម្តេចព្រះសង្ឃរាជ១ព្រះអង្គ ព្រះនាម"**មី**" នៅវត្តរាជបូរណៈ:មកថ្វាយព្រះពរសុំឱ្យធ្វើពិសាខបូជាជាដំបូង។ ឯរបៀបធ្វើពិធីនេះក៏ប្រហាក់ប្រហែលគ្នានឹងរបៀបធ្វើនៅក្នុងក្រុងសុខោទ័យ ប៉ុន្តែមិនសូវជាអធិកអធមដូចគ្រានោះទេ។

ចំណែកនៅប្រទេសកម្ពុជាវិញក្នុងសម័យជាមួយគ្នានេះ ប្រហែលជាមិនទាន់មានទំនៀមធ្វើនៅឡើយ ដោយហេតុថា ការធ្វើវិសាខបូជានៅប្រទេសថៃក្នុងជំនាន់នោះ នៅមិនទាន់មាំមួននៅឡើយ ទាំងគម្ពីរបឋមសម្ពោធិ ដែលសម្រាយប្រើប្រាស់ក្នុងការនេះ ក៏មិនទាន់មាននៅឡើយដែរ ហើយទំនងជាមិនទាន់បានជិតជ្រាបដល់ប្រជាជនខ្មែរផង។

រីឯនៅក្នុងគម្ពីរបឋមសម្ពោធិជារឿងពុទ្ធប្រវត្តិតំណាលរឿងចាប់ផ្តើមតាំងពីព្រះអង្គចុះចាកស្ថានតុសិតទេវលោក មកយោនយកកំណើតជាព្រះរាជបុត្រនៃព្រះបាទសុទ្ធោទន: និងព្រះនាងសិរិមហាមាយាទេវី នៅក្នុងនគរកបិលពស្តុក្នុងមជ្ឈិមប្រទេស រៀងរាបជរាបដល់ព្រះអង្គទ្រង់បានត្រាស់ជាអង្គព្រះសម្ពុទ្ធ ប្រកាសសម្តែងធម៌ប្រោសសត្វលោក ហើយសម្តេចទ្រង់រំលត់ខន្ធចូលកាន់ព្រះបរមនិព្វានជាទីបំផុត។

គម្ពីរបឋមសម្ពោធិនេះ អ្នកប្រាជ្ញតែងលើកឡើងនូវសម្រាយប្រើប្រាស់ទេសនានៅក្នុងបុណ្យវិសាខបូជា ព្រោះថាការដែលនាំយកប្រវត្តិរបស់រឿងនេះមកសម្តែងដើម្បីជាកស្តុតាងបញ្ជាក់ឱ្យដឹងថា បុណ្យវិសាខបូជា កើតឡើងពិតប្រាកដនោះ ពីត្រឹមពេលដែលកើតគម្ពីរនេះឡើង។ គម្ពីរនេះកើតមានប្រាកដឡើងនៅ

ប្រទេសថៃ ស្ថិតក្នុងរជ្ជកាលព្រះបាទសម្តេច **ព្រះណាំង‌ក្លាវ** "រជ្ជកាលទី៣" ជាដំបូង ហើយក្នុងជំនាន់នោះ គម្ពីរនេះមាន២ប្រភេទគឺ ៖

១- គម្ពីរបឋមសម្ពោធិសង្ខេបមានចំនួន ២០បរិច្ឆេទ[៣]តែមិនមានឈ្មោះអ្នកនិពន្ធពិតប្រាកដនោះទេ ប្រហែលជានិពន្ធឡើងក្នុងរជ្ជកាលទី២។

២- គម្ពីរបឋមសម្ពោធិវិត្តារ ជាភាសាមគធៈមានចំនួន២១ខ្សែ ឬ ៣០បរិច្ឆេទ ទាំងជាភាសាបាលី និងសម្រាយ។ ព្រះបាទសម្តេច **ព្រះណាំង‌ក្លាវ** ទ្រង់អារាធនាសម្តេចក្រុមព្រះ **បរមានុជិត ជិនោរសសង្ឃរាជ** គង់នៅវត្តព្រះជេតព័នក្នុងក្រុងទេពឱ្យនិពន្ធឡើង។

សម្តេចក្រុមព្រះអង្គនេះបានរួបរួមសេចក្តីចេញពីគម្ពីរផ្សេងៗ និងនិពន្ធបន្ថែមឡើងខ្លះក្នុងពុទ្ធសករាជ២៣៨៧ គ្រិស្តសករាជ១៨៤៥។

ចំណែកប្រទេសខ្មែរយើង គម្ពីរបឋមសម្ពោធិជាភាសាមគធៈ មានចំនួន២១ខ្សែ ឬ៣០បរិច្ឆេទ។ គម្ពីរជាសម្រាយមាន៣បែប គឺ ៖

១. ហៅថា គម្ពីរបឋមសម្ពោធិសង្ខេប ឬហៅថា "បឋមត្រាស់" មានចំនួន៥-៦ខ្សែ ឬមួយខ្សែចប់ ពណ៌នាសេចក្តីតាំងពីព្រះអង្គយាងចុតិចាកតុសិតមកចាប់បដិសន្ធិជាឱរសព្រះបាទសុទ្ធោទនៈនិងព្រះនាងសិរិមហាមាយាទេវីរហូតមកត្រឹមព្រះអង្គចេញទ្រង់ព្រះផ្នួស បានត្រាស់ជាព្រះពុទ្ធ។ អត្ថបទនេះមិនដឹងថាអ្នកណាជាអ្នកនិពន្ធ ហើយនិពន្ធពីក្នុងពុទ្ធសករាជណានោះទេ។ តែតាមការសង្កេតមើលពាក្យពេចន៍ក្នុងគម្ពីរនោះ ឃើញថាមិនជាចាស់ណាស់ណានោះទេ យ៉ាងយូរណាស់ត្រឹមសម័យក្រុងឧដុង្គខាងដើម។ គម្ពីរនេះ គេច្រើនប្រើពាក្យសម្រាយទេសនាក្នុងពិធីបុណ្យអភិសេកព្រះពុទ្ធរូបផង។

២.ហៅថា "គម្ពីរបឋមសម្ពោធិវិត្តារ" មានចំនួន៣០បរិច្ឆេទ។ គម្ពីរនេះ សម្តេចព្រះមហាសុមេធាធិបតី ព្រះសង្ឃរាជ ជួន ណាត (កាលនៅជាសង្ឃនាយក) បានមានថេរដីកាថា មហាណាក មហាកូ និងអាចារ្យសន។ល។ នៅខេត្តបាត់ដំបង បានប្រែចេញពីបឋមសម្ពោធិវិត្តាររបស់សម្តេចក្រុមព្រះបរមានុជិត ជិនោរស ក្នុងសម័យព្រះយ៉ាកថា ថន "តទាធរ" ឈុម ធ្វើជាចៅមឿង (ចៅហ្វាយក្រុង) ខេត្តបាត់ដំបង ហើយដែលបានផ្សព្វផ្សាយ។

នៅប្រទេសកម្ពុជា បុណ្យវិសាខបូជានេះ តាមដែលចាស់ទុំ អ្នកមុខអ្នកការទាំងឡាយតំណាលតៗគ្នា បានឱ្យដឹងមកថា គេបានផ្តើមធ្វើក្នុងនៅរជ្ជកាលព្រះបាទសម្តេចព្រះហរិ

---

[៣] បរិច្ឆេទ ប-រិច-ឆែត សំ. ជ.(ន.)ការកាត់,ការកាត់ឲ្យដាច់ដោយសង្កាត់ដោយឡែកពីគ្នា សង្កាត់សេចក្តីមួយពួក ។,កណ្ឌ : បរិច្ឆេទទី១ បរិច្ឆេទទី២ មួយបរិច្ឆេទ ពីរបរិច្ឆេទ (ម. ព.កាលបរិច្ឆេទក្នុងពាក្យកាល ១ ន.ផង) ។

រក្សារាមាតស្សរាជធិបតី "ព្រះអង្គឌួង" ។ ដែលគង់នៅក្នុងក្រុងឧដុង្គជាដំបូង ព្រោះថាកាលក្នុងពុទ្ធសករាជ ២៣៩៧ គ្រិស្តសករាជ ១៨៥៤ សម្តេចព្រះអង្គឌួង ទ្រង់សព្វព្រះរាជហឫទ័យស្នើសុំទូទៅក្នុងកម្ពុជរដ្ឋ។

៣. ហៅថា "បឋមសម្ពោធិកថា" គឺបឋមសម្ពោធិវិត្តារនោះឯងដែលព្រះឥន្ទមុនី **ប៉ែន** គង់នៅវត្តបទុមវតីរាជវរាមក្រុងភ្នំពេញ ប្រែនិងរៀបរៀងចេញពីច្បាប់របស់សម្តេចព្រះមហាសង្ឃរាជ "**សា**" ក្នុងរជ្ជកាលព្រះបាទសម្តេច **ព្រះស៊ីសុវត្ថិ** មានចំនួន៣០បរិច្ឆេទដូចច្បាប់ដើម។ គម្ពីរនេះមានជាបែបបទសម្រាយទេសនាក្នុងថ្ងៃវិសាខបូជាក្នុងវត្តគណៈធម្មយុត្តិកនិកាយទូទាំងប្រទេសខ្មែរ។

ការធ្វើបុណ្យវិសាខបូជាក្នុងសម័យរជ្ជកាលទី២នោះ ប្រហែលជាមានធ្វើតែក្នុងក្រុងមិនទាន់បាន ផ្សព្វផ្សាយទៅគ្រប់វត្តអារាមនៅឡើយទេ ហើយក៏មិនទាន់មានភាពឱឡារិកអធិកអធមណាស់ណាដែរ។

ពុទ្ធសាសនិកប្រទេសថៃ បានអះអាងថាប្រពៃណីធ្វើវិសាខបូជាដែលត្រឹមត្រូវតាមលក្ខណៈកើតមានឡើងតាំងពីត្រឹមរជ្ជកាលទី៤ ដោយព្រះរាជាអង្គនេះជាអ្នកប្រាជ្ញក្នុងផ្លូវព្រះពុទ្ធសាសនា ទ្រង់ចេះគម្ពីរ ព្រះត្រៃបិដកជ្រៅជ្រះ ទ្រង់បានផ្តើមធ្វើវិសាខបូជាតាំងពីកាលទ្រង់ព្រះផ្នួសនៅឡើយ។ លុះដល់ទ្រង់ដាក់ព្រះផ្នួសមកទទួលរាជសម្បត្តិក៏ទ្រង់នៅតែបន្តធ្វើវិសាខបូជារៀងដរាបមក រហូតដល់ទ្រង់បញ្ជាឱ្យរៀបចំគម្ពីរសម្រាយទេសនានៅក្នុងពិធីបុណ្យនេះដូចបានពោលខាងលើ។ ព្រះមហា **ប៉ាន** គឺសម្តេចព្រះសុគន្ធាធិបតី ជាគណៈធម្មយុត្តិកនិកាយនៅក្នុងក្រុងទេព"បាងកក" អំពីព្រះបាទសម្តេចព្រះចមក្លាវ "រជ្ជកាលទី៤"។

បន្ទាប់មក ក្រោយនោះមួយឆ្នាំ គឺនៅក្នុងពុទ្ធសករាជ២៣៩៨ ព្រះមហា **ប៉ាន** ទើបនិមន្តមកអំពីទីក្រុងទេព ព្រះបាទសម្តេច **ព្រះហរិរក្ស** ទ្រង់មានព្រះរាជហឫទ័យសោមនស្សណាស់ ហើយបាននិមន្តឱ្យគង់នៅជាចៅអធិការវត្តសាលាគូ ហៅវត្តអម្ពិលបី នៅក្រុងឧដុង្គតរៀងមក។ ដោយហេតុថា ព្រះមហាថេរអង្គនេះកាលដែលលោកគង់នៅទីក្រុងទេព ធ្លាប់ធ្វើវិសាខបូជារួចមកហើយហើយកាលបានគង់នៅប្រទេសខ្មែរព្រមទាំងបានធ្វើជាធំនៅក្នុងគណៈធម្មយុត្តិកនិកាយផង លោកក៏ផ្តើមឡើងតាមដែលធ្លាប់ធ្វើកន្លងមក។ ប៉ុន្តែយើងពុំបានដឹងច្បាស់ថា នៅពេលដំបូងនោះ តើលោកចាប់ផ្តើមធ្វើក្នុងឆ្នាំណា សករាជប៉ុន្មាននោះទេ? ព្រោះគ្មានឯកសារជាក់ស្តែង គ្រាន់តែមានសេចក្តីអះអាងពីអ្នកមុខអ្នកការទាំងឡាយថាប្រាកដជាមានធ្វើវិសាខបូជា តាំងពីក្នុងពេលដែលលោកគង់នៅក្រុងឧដុង្គមកម្ល៉េះ។ លុះដល់ពេលលោកមកគង់នៅវត្តបទុមវតី ក្រុងភ្នំពេញ ក្នុងពុទ្ធសករាជ

២៤០៨ ក៏បានប្រារព្ធវិសាខបូជារហូតដល់អស់ព្រះជន្ម ហើយពិធីវិសាខបូជានេះ ត្រូវបានផ្សព្វផ្សាយទូទៅ នៅគ្រប់វត្តគណៈធម្មយុត្តិកនិកាយជាប់ជាទំនៀមរហូតមក។

ចំណែកវត្តខាងមហានិកាយ ទើបមានធ្វើក្នុងសម័យក្រុងភ្នំពេញ ក្នុងរជ្ជកាលព្រះបាទ **ស៊ីសុវត្ថិ**។ តាមដែលសម្តេចព្រះមហាសុមេធាធិបតី ព្រះសង្ឃរាជ **ជួន ណាត** (កាលនៅព្រះសង្ឃនាយក) តំណាលថា ក្នុងឆ្នាំមួយនោះលោកគ្រូព្រះវនរ័ត **ចន្ទ** គង់នៅវត្តឧណ្ណាលោម បាននិមន្តទៅក្រុងទេព ឃើញព្រះសង្ឃនៅក្រុងនោះ ទាំងគណៈធម្មយុត្តិកនិកាយ ទាំងគណៈមហានិកាយធ្វើវិសាខបូជា ក៏កើតជ្រះថ្លានៅពេលនិមន្តត្រឡប់មកវិញ បានក្រាបបង្គំទូលសម្តេចព្រះមហាសង្ឃរាជ ព្រះនាម "**ទៀង**" សុំឱ្យធ្វើវិសាខបូជា ទើបសម្តេចព្រះមហាសង្ឃរាជ**ទៀង** ក៏ទ្រង់បានព្រះរាជានុញ្ញាតតាមសំណូមពរ ដែលពេលនោះ វិសាខបូជាត្រូវបានធ្វើជាបន្តបន្ទាប់រៀងដរាបមក។ ប៉ុន្តែពេលនោះ ក៏ពុំទាន់បានធ្វើគ្រប់វត្តនៅឡើយ គឺមានធ្វើចំពោះតែវត្តនៅក្នុងក្រុង។ ឯវត្តនៅតាមខេត្តក្រៅមានធ្វើតែវត្តធំៗ វត្តតូចៗច្រើនពុំបានធ្វើនៅឡើយទេ។

ចំណែកព្រះមហាក្សត្រដែនដី តាំងពីរជ្ជកាលព្រះបាទសម្តេចព្រះហរិរក្ស "**ព្រះអង្គឌួង**" មកសុទ្ធតែទ្រង់ ជ្រះថ្លាបានទទួលធ្វើគ្រប់ៗព្រះអង្គ។

បើតាមឯកសារខ្លះបានលើកសរសើរព្រះគុណសម្បត្តិនៃព្រះបាទសម្តេចព្រះហរិរក្ស ដែលជាអ្នកផ្តួចផ្តើមធ្វើបុណ្យវិសាខបូជាឡើងជាដំបូង ពីព្រោះវាជាអង្គនេះ ទ្រង់ធ្លាប់ទៅគង់នៅក្នុងក្រុងទេព "បាងកក" និងទ្រង់ធ្លាប់សាងព្រះផ្នួសនៅទីនោះ។ ទ្រង់បានសិក្សាព្រះបរិយត្តិធម៌ជ្រួតជ្រាបគម្ពីរព្រះត្រៃបិដកជ្រៅជ្រះ។ នៅពេលដែលទ្រង់បានឡើងសោយរាជសម្បត្តិ ក៏ទ្រង់ផ្តើមធ្វើពិធីបុណ្យនេះតាមដែលទ្រង់ធ្លាប់បានជ្រួតជ្រាប និងធ្លាប់បានទតឃើញរបៀបបែបផែនដែលគេធ្វើនៅក្រុងទេព ទើបជាប់ជាប្រពៃណីរហូតមកដល់សព្វថ្ងៃ។

៣. សារៈសំខាន់នៃពិធីបុណ្យពិសាខបូជា

សារៈសំខាន់បំផុតនៃការគោរពបូជាបុណ្យវិសាខបូជា គឺត្រូវធ្វើវត្តប្រតិបត្តិ ដោយមានការឱ្យទាន រក្សាសីល និងចម្រើនសមាធិបញ្ញាផងដែរ ទើបមានឈ្មោះថាជាការបូជាដ៏ឧត្តម និងបានផលានិសង្សបុណ្យកុសលខ្ពង់ខ្ពស់ ហើយដើម្បីសម្តែងនូវការដឹងគុណដ៏ខ្ពង់ខ្ពស់ យើងត្រូវយល់អំពីខ្លឹមសារនៃព្រះពុទ្ធសាសនា ដែលចារក្នុងព្រះត្រៃបិដកជាគោល យ៉ាងហោចណាស់ក៏ថ្ងៃនេះយើងបូជារក្សាសីល ឬក៏ធ្វើសមាធិចិត្តឱ្យបានល្អ

គ្រប់ៗគ្នា គឺយើងជួបជុំគ្នារក្សាសីល យ៉ាងហោចណាស់យើងបានសីលថ្ងៃរៗ។

សារៈសំខាន់នៃថ្ងៃវិសាខបូជា៖

១.ថ្ងៃវិសាខបូជា ចាត់ជាថ្ងៃកំណើតរបស់ព្រះពុទ្ធសាសនា

២.ថ្ងៃវិសាខបូជាចាត់ជាថ្ងៃដែលអង្គការសហប្រជាជាតិ ទទួលស្គាល់ជាផ្លូវការនៅថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ១៩៩៩ ថា ពិធីបុណ្យវិសាខបូជានេះ គឺជាពិធីបុណ្យអន្តរជាតិមួយ ដែលគេអាចប្រារព្ធធ្វើទៅតាមការិយាល័យទាំងឡាយរបស់អង្គការសហប្រជាជាតិទូទាំងពិភពលោកហើយក៏ជាបុណ្យអន្តរជាតិផងដែរ។

ក្នុងសម័យប្រជុំអន្តរជាតិនៃក្រុមប្រឹក្សាផ្នែកពុទ្ធសាសនា ស្តីអំពី "ទិវា-យូអិន-វិសាខា" ឬ "បុណ្យវិសាខបូជានៃអង្គការសហប្រជាជាតិ" នេះ បានចាប់ផ្តើមដំបូងនៅក្នុងឆ្នាំ២០០៤ នៅក្នុងប្រទេសថៃ។ តាំងពីពេលនោះមក សន្និសីទអន្តរជាតិនេះបានប្រព្រឹត្តទៅជារៀងរាល់ឆ្នាំ ប៉ុន្តែភាគច្រើនតែធ្វើនៅមុនថ្ងៃ១៥កើត ខែពិសាខ ដែលជាថ្ងៃបុណ្យវិសាខបូជា។ ប្រទេសថៃ បានទទួលរៀបចំកិច្ចប្រជុំនេះជាច្រើនលើកមកហើយ។ រីឯប្រទេសវៀតណាម ក៏បានស្នើគ្រទទួលនាទីរៀបចំនូវសន្និសីទស្តីអំពី "ទិវា-យូអិន-វិសាខា" នេះចំនួនពីរដងរួចមកហើយដែរ គឺកាលពីអំឡុងឆ្នាំ២០១៣ និងឆ្នាំ២០០៨។

៣.ថ្ងៃវិសាខបូជានេះគឺចាត់ជាថ្ងៃសន្តិភាពពិភពលោកព្រោះព្រះសម្មាសម្ពុទ្ធជាម្ចាស់បង្រៀនមនុស្សជាតិឱ្យស្វែងរកសន្តិសុខនិងសន្តិភាពទាំងខាងក្នុង និងខាងក្រៅ។

៤.ថ្ងៃវិសាខបូជាចាត់ជាថ្ងៃរំឭកគុណ គឺព្រះមហាករុណាគុណ ព្រះវិសុទ្ធិគុណ និងព្រះបញ្ញាគុណរបស់ព្រះសមណគោតម ដែលជាព្រះបរមសាស្តានៃលោក។

៥.ថ្ងៃវិសាខបូជា ចាត់ជាថ្ងៃព្រះពុទ្ធព្រោះទាក់ទងនឹងខ្សែជីវិតរបស់ព្រះពុទ្ធជាម្ចាស់។

ប្រពៃណីក្នុងការប្រារព្ធពិធីបុណ្យវិសាខបូជានេះក៏ត្រូវបានរក្សាទុក និងធ្វើតាមជាទំនៀមមកដល់សព្វថ្ងៃនេះផងដែរ ដោយមានរៀបចំយ៉ាងអធិកអធមជាផ្លូវការរៀងរាល់ឆ្នាំនៅលើកំពូលភ្នំអដ្ឋរស្ស ឬភ្នំព្រះរាជទ្រព្យ[4] នៅក្នុង

[4] ភ្នំព្រះរាជទ្រព្យ ឬភ្នំអដ្ឋរស្ស ឬភ្នំឧតុង្គ គឺជាបូជនីយដ្ឋានមួយដ៏សមរម្យដែលព្រះករុណាសម្តេចព្រះបាទនរោត្តម **សីហនុ** សព្វព្រះរាជហឫទ័យយកទីនោះកសាងព្រះសក្យមុនីចេតិយ ដើម្បីតម្កល់ព្រះសារីរិកធាតុព្រះពុទ្ធបរមគ្រូ សម្រាប់ការគោរពបូជារបស់ពុទ្ធបរិស័ទទាំងអស់ ហើយព្រះចង្កូមកែវរបស់ព្រះសម្មាសម្ពុទ្ធ ត្រូវបានដង្ហែទៅតម្កល់ក្នុងព្រះសក្យមុនីចេតិយ នៅភ្នំអដ្ឋរស្សកាលពីថ្ងៃទី១៩ ខែ ធ្នូ ឆ្នាំ២០០២ ត្រូវនឹងថ្ងៃទី១៥កើត ខែមិគសិរ ឆ្នាំមមី ចត្វា

ស្រុកពញាឮ ខេត្តកណ្តាល ជាទីតម្កល់ព្រះសារីរិកធាតុរបស់ព្រះសម្មាសម្ពុទ្ធសមណគោតម ដោយមានទាំងកិច្ចនមស្សការសមាទាន សីល កិច្ចសម្តែងធម្មទេសនា និងពិធីដាក់បាត្រព្រះសង្ឃដែលពេលខ្លះក៏មានការយាង និងអញ្ជើញចូលរួមពីថ្នាក់ដឹកនាំជាតិ សម្តេចព្រះសង្ឃរាជទាំងពីរគណៈ ព្រះសង្ឃនិងពុទ្ធបរិស័ទទូទៅផងដែរ។ តាមការសង្កេតនៃការប្រារព្ធពិធីជារៀងរាល់ឆ្នាំនៅភ្នំអដ្ឋរស្ស ក៏ដូចជានៅតាមបណ្តាខេត្តនានា ជាទូទៅនាពេលរសៀល គេមានការរៀបចំធ្វើពិធីក្រុងពាលី និងពិធីផ្សេងៗទៀតតាមបែបព្រះពុទ្ធសាសនា លុះព្រឹកឡើងគេរៀបចំដង្ហែ ហើយមានប្រគេនចង្ហាន់ដល់ព្រះសង្ឃ ឬធ្វើពិធីរាប់បាត្រព្រះសង្ឃទៅតាមចំនួននៃព្រះសង្ឃដែលនិមន្តមកចូលរួម។

ស័ក ពុទ្ធសករាជ២៥៦៦ ព្រះចង្កូមកែវត្រូវបានដង្ហែចេញពីព្រះសក្យមុនីចេតិយចាស់ ដែលមានទីតាំងនៅមុខស្ថានីយរាជាយស្ស័យយានន្តា ក្រុងភ្នំពេញសព្វថ្ងៃនេះ បន្ទាប់ពីប្រារព្ធពិធីបុណ្យ៧យប់ ៧ថ្ងៃរួចមក។

ឯកសារយោង

១. ជួន ណាត *វចនានុក្រមខ្មែរ*

២. ពុទ្ធសាសនបណ្ឌិត្យ *ពិធីបុណ្យទ្វាទសមាស*

៣. https://khmerpalistudy.files.wordpress.com/

៤. http://5000-years.org/kh/read/2929

៥. https://kohsantepheapdaily.com.kh/article/9053.html

៦. https://wmc.org.kh/article/83972/

ទំនាក់ទំនងរវាងអរិយធម៌និងច្បាប់

ដោយៈ លោកបណ្ឌិត **ហោម ឆ្លាច**
មន្ត្រីនាយកដ្ឋាននីតិសាស្ត្រវិទ្យាស្ថានមនុស្សសាស្ត្រ
និងវិទ្យាសាស្ត្រសង្គមនៃរាជបណ្ឌិត្យសភាកម្ពុជា

១ កំណកំណើតអរិយធម៌ខ្មែរ

នៅក្នុងលោកនេះ ជាតិសាសន៍ណាក៏ដោយសុទ្ធតែមានអរិយធម៌ជាមូលដ្ឋាននៃប្រទេសជាតិរៀងៗខ្លួន។ ប្រទេសណាដែលមានអរិយធម៌លូតលាស់ជឿនលឿន ត្រូវបានចាត់ទុកជាអរិយប្រទេស។ ខ្មែរមានអរិយធម៌របស់ខ្លួនយ៉ាងជាក់លាក់ណាស់។ ប្រវត្តិសាស្ត្របានប្រាប់យើងថា ជាតិខ្មែរបានកសាងអរិយធម៌ដ៏ខ្ពស់ខ្ពង់ល្បីល្បាញសុសសាយពេញពិភពលោក ហើយដែលបន្សល់កេរដំណែលរហូតមកដល់សព្វថ្ងៃនេះ ដូចជាប្រាង្គប្រាសាទមានចំនួនរាប់រយ សិលាចារឹកមានចំនួនរាប់ពាន់ផ្នាំងនិងបណ្តាញព្រែកជីក វត្តបុរាណជាច្រើនមានរូបបដិមា រួចចម្ងាក់ជាដើម។ អរិយធម៌ខ្មែរបានឡើងដល់កម្រិតកំពូលនៅសម័យអង្គរ ជាហេតុនាំឱ្យអ្នកប្រវត្តិសាស្ត្រចាត់ទុកថា ប្រទេសខ្មែរក្នុងសម័យនោះ ជាមហាអំណាចមួយនៅភូមិភាគអាស៊ីអាគ្នេយ៍យើងនេះ។ អ្នកស្រាវជ្រាវជាតិ និងអន្តរជាតិបានបង្ហូរទឹកខ្មៅជាច្រើនដើម្បីពិពណ៌នាពន្យល់និងកោតសរសើរពីអរិយធម៌អង្គរ ជាពិសេសប្រាសាទអង្គរវត្តដែលគេបានមួលមតិចាត់ទុកថា ជាអច្ឆរិយវត្តុមួយក្នុងពិភពលោក។

អាស្រ័យហេតុនេះ គប្បីខ្មែរគ្រប់រូបព្យាយាមសិក្សាអរិយធម៌ជាតិរបស់ខ្លួន ដើម្បីស្គាល់ប្រភពលក្ខណៈផ្ទាល់ និងតម្លៃនៃអរិយធម៌ គឺការដឹង និង ស្គាល់តម្លៃ ហើយនិងជាតុផ្សេងៗយ៉ាងជាក់ច្បាស់នៃអរិយជាតិនេះ ហើយដែលធ្វើឱ្យយើងមានមោទនភាព និងពេញចិត្តស្រឡាញ់អរិយធម៌ជាតិរបស់យើង ក៏កើតមានឡើង។ ដរាបណាយើងមានចិត្តស្រឡាញ់ ដរាបនោះយើងមុខជានឹងព្យាយាមលើកតម្កើង ហើយខិតខំថែរក្សាការពារអរិយធម៌ជាកេរមរតក ដែលដូនតាបានកសាងទុកមកអស់រយៈពេលច្រើនសតវត្សឱ្យបានគង់វង្សយូរអង្វែងទៅទៀត។

ការស្គាល់ត្រឹមតែអរិយធម៌ជាតិរបស់ខ្លួនពុំទាន់គ្រប់គ្រាន់ទេ លុះត្រាតែបានស្គាល់អរិយ

ធម៌បរទេសថែមទៀតទើបប្រសើរ។ រៀន អរិយធម៌បរទេសពុំមែនរៀនដើម្បីធ្វើតាមគេទាំងស្រុង និងបណ្តោយឱ្យគេបំបាត់លក្ខណៈជាតិឯងទេ ប៉ុន្តែត្រូវចេះស្រូបយកគំនិតសំខាន់ៗ មកផ្សេងរុំ ឬច្នៃបញ្ចូលជាមួយអរិយធម៌ជាតិឱ្យកាន់តែល្អប្រសើរឡើង ដូចជាការរៀបចំ ស្រុកទេស ការរស់នៅ ការអប់រំ ទំនៀមទម្លាប់ដើម។ ការធ្វើឱ្យមានលក្ខណៈជាតិបែបនេះពុំមែនមានចំពោះតែការសិក្សាអរិយធម៌បរទេសប៉ុណ្ណោះទេ គឺមានចំពោះឥទ្ធិពលនៃអរិយធម៌បរទេសដែលជះមកលើអរិយធម៌ជាតិក្នុងពេលមានទំនាក់ទំនងគ្នា ឬក្នុងពេលទទួលការគ្រប់គ្រងនៃបរទេសផងដែរ។ ឯការប៉ះទង្គិចគ្នារវាងអរិយធម៌ជាតិ និងអរិយធម៌បរទេសគេចាត់ទុកជាការធម្មតា ព្រោះគេបានសង្កេតឃើញថា អរិយធម៌របស់ប្រទេសធំៗ ដែលរីកចំរើនគឺសុទ្ធតែផលរួមនៃអរិយធម៌ជាច្រើន ដូចជាអរិយធម៌ អឺរ៉ុប អាមេរិក រុស្សី ចិន ជប៉ុន ជាដើម។

២. ការវិវត្តអរិយធម៌ខ្មែរ

តើខ្មែរមានអរិយធម៌ផ្ទាល់ខ្លួនរឹងប៉ឹងមុនឥណ្ឌាចូលមកមែនឬទេ?

ចាប់ពីសតវត្សទី១មក ខ្មែរបានទទួលយកអរិយធម៌ឥណ្ឌាជាផ្លូវការដំបូងមកបញ្ជ្រាបលើអរិយធម៌ខ្មែរមានរបៀបរៀបរយជាស្រេចទៅហើយ ទើបធ្វើឱ្យអរិយធម៌ខ្មែរវិវត្តលូតលាស់ដល់កំពូលនៅសម័យអង្គរ។

អរិយធម៌ខ្មែរពុំមែនទើបតែរីកដុះដាលឡើងនៅពេលទទួលអរិយធម៌ឥណ្ឌាប៉ុណ្ណោះទេ ពោលគឺជាអរិយធម៌មួយមានចំណាស់ក្នុងចំណោមអរិយធម៌ដែលមានចំណាស់ៗក្នុងពិភពលោក ហើយដែលបានកើតឡើងនៅភូមិភាគអាស៊ីអាគ្នេយ៍នេះ តាំងពីសម័យ បុរេប្រវត្តិសាស្ត្រដ៏យូរលង់ណាស់មកហើយ គឺតាំងពីមុនអរិយធម៌ឥណ្ឌាចូលមកម៉្លេះ។

-អំណះអំណាងរបស់អ្នកប្រាជ្ញជាច្រើនដូចជាលោក ក្រូលីយេ (Groslier) ម៉ាសាល់ (Marshal) តាឡាបូ(Talabot) ជាតិខ្មែរជាជនជាតិពិសេសមួយនៅក្នុងអំបូរខ្មែរ-មន ហើយបានកើតឡើងនៅអាស៊ីអាគ្នេយ៍នេះតែម្តង។

-បើផ្អែកលើការស្រាវជ្រាវដែលធ្វើកំណាយនៅស្ថានីយនានា ក៏រឹងរឹតតែបញ្ជាក់ច្បាស់ថា ខ្មែរមិនមែនជាឥណ្ឌា។

នៅស្ថានីយស្អាងស្ពានៃភ្នំទាកទ្រាំង មានចម្ងាយប្រហែល៥គីឡូម៉ែត្រ ពីអណ្តូកហែល ខេត្តបាត់ដំបង លោកនិងលោកស្រីមួរេ (Mourer) បានដឹកនាំនិស្សិតមហាវិទ្យាល័យបុរាណវិទ្យាទៅធ្វើកំណាយនៅទីនោះ (ពីឆ្នាំ ១៩៦៦-១៩៦៩)។ វត្ថុដែលគេបានរកឃើញមានគ្រឿងប្រដាប់ធ្វើអំពីថ្មសំណល់ផ្ទះ សាកសពសត្វល្អិត បំណែកគ្រឿងចានឆ្នាំង ឆ្អឹងសត្វ

ឆ្នើមមនុស្ស វត្ថុទាំងនេះយកទៅធ្វើពិសោធន៍នៅប្រទេសបារាំងតាមវិទ្យុសកម្មដើម្បីកំណត់អាយុកាល។ ក្រោយពិសោធន៍គេបានឱ្យដឹងថា នៅទីនោះមានមនុស្សរស់នៅតាំងពី៥.០០០ឆ្នាំមុនគ្រិស្តសករាជ(គ.ស.)។

នៅស្ថានីយសំរោងសែន(ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង) នៅខាងជើងបឹងទន្លេសាប។ ស្ថានីយនេះរកឃើញដោយលោក រ៉ូក (Roques)នៅឆ្នាំ ១ ៩ ០ ២ លោក ម៉ង់ស៊ុយ (Mansuy) បានរកឃើញស្ថានីយអន្ទង់ផ្តៅ។ ស្ថានីយនេះស្ថិតនៅចម្ងាយ ៣០គីឡូម៉ែត្រត្រង់ទិសអាគ្នេយ៍សំរោងសែន ហើយមានបុពណវត្ថុដូចស្ថានីយសំរោងសែនដែរ។

នៅឆ្នាំ១៩៤៣ លោក ប៉ូល ឡេវី (Paul Levy) បានរកឃើញស្ថានីយថ្មីមួយទៀតគឺម្តងព្រៃ (ខេត្តព្រះវិហារ)។ នៅស្ថានីយនេះគេបានរកឃើញប្រដាប់ប្រដាធ្វើអំពីលោហធាតុជាច្រើន។ វត្ថុដែលគេបានរកឃើញនៅតាមស្ថានីយទាំង៣នេះមាន៖

-ឋ្នរំលើង៖ ពូថៅមានពន្ធូញ ញញួរ ស្មោងដំសំបកឈើ ទ្រនាប់កាំបិត កណ្តៀវ ឋ្នសំលៀង ពុម្ពចាក់កណ្តៀវ កងដៃ ត្បាល់ ត្រល់ អង្រែ ផ្ទៃសន្ទូច ។ល។

-សំបកខ្យង៖ អង្កាំ ទង្វា។ល។

-កុលាលភាជន៍៖ ក្អម ឆ្នាំង ចាន ។ល។

-សំរឹទ្ធិ៖ ផ្ទៃព្រួញ កណ្តៀវ ពូថៅ ជួង ផ្ទៃសន្ទូច ។ល។

-ដែក៖ មានតែពន្ធាកមួយគត់នៅស្ថានីយម្តងព្រៃ។

ស្ថានីយទាំងបីនេះមានអាយុកាលប្រហែលពី២ ទៅ៣ ពាន់ឆ្នាំមុន គ.ស។ វត្ថុតាងដែលគេបានស្រាវជ្រាវរកឃើញនេះ ជាការគ្រប់គ្រាន់អាចបញ្ជាក់ថា ខ្មែរបានកសាងអរិយធម៌មួយរឹងប៉ឹងរួចជាស្រេចទៅហើយ តាំងពីមុនខ្មែរទទួលយកអរិយធម៌ឥណ្ឌា។

ផ្អែកលើលក្ខណៈភាសាក៏ឃើញថាខុសគ្នាស្រឡះ។ ភាសាខ្មែរស្ថិតនៅក្នុងអំបូរខ្មែរ-មន ឯភាសាឥណ្ឌាស្ថិតនៅក្នុងអំបូរ ឥណ្ឌា អឺរ៉ុប។

ភាសាខ្មែរមានលក្ខណៈពិសេសរបស់ខ្លួន ជាភាសាមានព្យាង្គតិចភាសាគ្មានវិភត្តិ គ្មានវចនៈ គ្មានលិង្គ ទេ រីឯភាសាបាលី សំស្ក្រឹត ដែលឥណ្ឌាប្រើជាភាសាហុព្យាង្គ មានលិង្គ មានវិភត្តិ និងមានវចនៈ។

ឧទាហរណ៍៖

ភាសាខ្មែរមានព្យាង្គតិច ដូចជាពាក្យ ជួយផ្ទួរួម (១ព្យាង្គ) គ្រប់គ្រង (២ព្យាង្គ)។ល។ រីឯភាសាបាលី សំស្ក្រឹតជាភាសាពហុព្យាង្គដូចជាអន្តរាគមន៍សាធារណៈ ទេសាភិបាល (៤ព្យាង្គ)។ល។

ភាសាខ្មែរគ្មានវិភត្តិគឺ គ្មានការបំបែកនាម ឬកិរិយាសព្ទទេ ដូចជាពាក្យ ដើរ រីឯភាសា

បាលី សំស្ក្រឹត ចរ បំបែកជា ចរិត ចរន្តិ ចរិសិ ចរថ ចរមិ ចរាម។ល។

ភាសាបាលី សំស្ក្រឹតមានវចន: និងលិង្គ ដូចជាពាក្យមនុស្ស(ឯកវចន:)មនុស្ស(ពហុវចន:) មនុស្សី(មនុស្សស្រី)។ល។

-ផ្អែកលើជំនឿ: ខ្មែរមានជំនឿលើព្រលឹងដូនតា(មេបា)គឺគេមានជំនឿថាខ្មោចដែលស្លាប់ទៅនៅមានព្រលឹងចាំថែរក្សាកូនចៅ(អ្នកតា អ្នកជី)។

-ផ្អែកលើសិល្បៈ: គឺខ្មែរមានតាំងពីមុនរៀងរហូតមក ដូចជា ពេលរៀបអភិសេក ហ៊ុនទៀន និងនាង លីវយី ខ្មែរមានរបាំ ភ្លេង និងប្រពៃណីរួចជាស្រេចទៅហើយ។ ព្រះបាទហ៊ុន-ទៀន តោង ស្បែនាង លីវ-យី គឺជានិមិត្តរូបបញ្ជាក់យ៉ាងច្បាស់ថា អ្នកចំណូលពីក្រៅត្រូវគោរពតាម ដើរតាមប្រពៃណីអ្នកស្រុកអាយ។

-ពេលមានអ្នកឈឺក្តាត់ គេលេងភ្លេងបន់អ្នកជី ជីដូន ជីតា ដែរ។

-មុន ហ៊ុន-ទៀន ចូលមកដល់ ខ្មែរចេះធ្វើសិប្បកម្មត្បាញវៃ ធ្វើទូក សំពៅ ធ្នូ ស្នា និងចេះរៀបចំក្បួនយុទ្ធសាស្ត្រស្រេចទៅហើយ[9]។

ជារួម អំណះអំណាងទាំងប៉ុន្មាននេះបញ្ជាក់ថាខ្មែរមានវប្បធម៌ អរិយធម៌ផ្ទាល់ខ្លួនរឹងប៉ឹងរួចជាស្រេចទៅហើយ មុនឥណ្ឌាយកអរិយធម៌របស់ខ្លួនមកផ្សព្វផ្សាយ។

២.១-អរិយធម៌នគរភ្នំ

ក-ផ្នែកវប្បធម៌

យោងតាមឯកសារចិននិងផ្នែកលើសិលាចារឹកអ្នកនគរភ្នំមានជំនឿលើពុទ្ធសាសនា(ហីនយាន)និងព្រហ្មញ្ញសានា (គោរពព្រះឥសូរ)។ សិលាចារឹកពុទ្ធសាសនាពីរ:

-សិលាចារឹកវ៉ូកាញ់: ជាបឋមសិលាចារឹកខ្មែរ ហើយមានចំណាស់ជាងគេនៅអាស៊ីអាគ្នេយ៍ទំនងសរសេរនៅសតវត្សទី២ ឬទី៣ កត់ត្រាជាភាសាសំស្ក្រឹត ថ្លែងពីព្រះបាទស្រីមារ(ហ្វាន់ចេម៉ាន់) ទ្រង់មានសទ្ធាជ្រះថ្លាក្នុងព្រះពុទ្ធសាសនា។

-សិលាចារឹកទន្ទេបាទី: នៅប្រាសាទទន្ទេបាទី កត់ត្រាជាភាសាសំស្ក្រឹត សតវត្សរ៍ទី៦ នៃគ.ស. ពីព្រះបាទរុទ្រវរ្ម័ន គោរពព្រះបរមសារីរិកធាតុ និងព្រះកេសមួយសរសៃប្រវែង៣ ម៉ែត្រ ដែលព្រះចៅវាជវង្សស៊ីលួចទៅ។ សិលាចារឹកព្រហ្មញ្ញសាសនាពីរ:

-សិលាចារឹកអ្នកតាដំបងដែក (ខាងត្បូងខេត្តតាកែវ) កត់ត្រាជាភាសាសំស្ក្រឹតនិយាយអំពីព្រះនាងកុលប្រភាវតី ជាអគ្គមហេសីព្រះបាទកៅណ្ឌិន្យ កសាងទេវាល័យតម្កល់ព្រះបដិមាព្រះវិស្ណុធ្វើអំពីមាសសុទ្ធ ស្រះ និងលំនៅសម្រាប់ពួកព្រាហ្មណ៍ ។

[9] សាកលវិទ្យាល័យភ្នំពេញអន្តរជាតិ: **វប្បធម៌សាធារណៈ** ឆ្នាំសិក្សា២០១៦-២០១៧។

-សិលាចារឹកប្រាសាទប្រាំលែង ស្ថិតនៅស្រុកទឹកឃ្មៅ ខេត្តព្រៃកប្បស្សី (ត្រាវិញ) កម្ពុជាក្រោម កត់ត្រាជាភាសាសំស្ក្រឹត និយាយពីព្រះបាទគុណវរ្មនត្រូវបានព្រះបាទរុទ្រវរ្មនដែលព្រះមាតាជាស្នំឯកព្រះបាទកៅណ្ឌិន្យធ្វើគត ហើយឡើងសោយរាជ្យទ្រង់បញ្ជាឱ្យចារឹកទុកថា «ទីនេះព្រះវរបិតារបស់ព្រះអង្គយកបានពីទឹកកក់ ហើយតែងតាំងព្រះអង្គឱ្យត្រួតត្រា»។

ខ-ផ្នែកនយោបាយ និងរដ្ឋបាល

អាណាចក្រភ្នំរៀបចំនយោបាយតាមបែបឥណ្ឌា។ ព្រះរាជាជាអ្នកដឹកនាំមានឋានន្តរនាមថា «ក្រុងភ្នំ» គង់ក្នុងប្រាសាទឈើមានច្រើនជាន់ និងមានរបងព័ទ្ធជុំវិញ។ ធ្វើនយោបាយពង្រីកទឹកដីវាយយករដ្ឋជាច្រើនដាក់ក្រោមចំណុះ យកឈ្នួយសឹកមកធ្វើជា ទាសាទាសី។ រដ្ឋចំណុះសុទ្ធតែមានស្តេចសោយរាជ្យ «សាមន្តរាជ» ដែលជារាជបុត្រ និងជាព្រះញាតិវង្សរបស់អធិរាជភ្នំ ហើយត្រូវនាំសួយសារអាករមកថ្វាយអធិរាជជារៀងរាល់ឆ្នាំ។

នយោបាយក្រៅប្រទេស៖ អធិរាជភ្នំមានទំនាក់ទំនងវិស័យនយោបាយ ពាណិជ្ជកម្ម និងវប្បធម៌ ជាមួយប្រទេសធំៗ ដូចជា ឥណ្ឌា និងចិន។

-រាជបម្រើ៖មានមន្ត្រីធ្វេង អង្គុយខាងធ្វេង និងមន្ត្រីស្តាំ និងមន្ត្រីថ្នាក់បន្ទាប់ត្រួតត្រាតាមខេត្ត។

-ព្រះរាជាតែងតែប្រទានសវនការជាញឹកញាប់ដល់ប្រជារាស្ត្រ និងបរទេសដែលយកតង្វាយមកថ្វាយ។ ស្តេចយាងទៅណាមកណាតែងគង់ប្រថាប់លើដំរី ឯមន្ត្រីជាបរិវារ ជិះដំរីហែហមដែរ។

-ការបង់ពន្ធជូនរាជការ ត្រូវបង់ជាមាសប្រាក់ ត្បូង គជ់ និងគ្រឿងក្រអូប។

គ-ជីវភាពសង្គម

លក្ខណៈមនុស្សទំនៀមទម្លាប់៖ ឯកសារចិនបញ្ជាក់ថា អ្នកនគរភ្នំមានសម្បុរខ្មៅ សក់រួញ អង្គាដី ច្រើនលែងខ្លួន ស្បៀកសារុងអំបោះដើរជើងទទេ អ្នកមាន នាម៉ឺនពាក់ស្បែកជើងស្បៀកសារុងសារបាប់ ។ល។ ជាមនុស្សត្រង់មិនចេះលួចគ្នា ពេលទំនេរចូលចិត្តប្រជល់មាន់ និងប្រជល់ជ្រូក សង់ផ្ទះផុតពីដី ធ្វើឈើប្រក់ស្វឹកចាករស់នៅផ្តុំគ្នាជាភូមិ ពី៥០ ទៅ ៦០ខ្នង មានស្រះទឹករួម។ សង្គមអាណាចក្រភ្នំជាសង្គម "មេនិយម" ទុកស្ត្រីជាធំក្នុងគ្រួសារផង និងក្នុងសង្គមផង។ ក្នុងករណីកាន់ទុក្ខមនុស្សស្លាប់គេត្រូវតែកោរសក់ និងពុកមាត់។

ពិធីបូជាសពមាន៤យ៉ាង៖ បោះចោលក្នុងទឹក បូជាដោយភ្លើង យកសពទៅកប់ និងយកសពទៅបោះចោលក្នុងព្រៃ។ បើបូជាដោយភ្លើង គេយកធាតុដាក់ក្នុងកោដ្ឋបិទឱ្យជិត រួចយកទៅបោះចោលក្នុងទន្លេ។

វិធីរកយុត្តិធម៌ៈ កាលណាគេបាត់អ្វីមួយ គេយកបាយទៅជាក់ចំព្រះភក្ត្រទេព្តារួចសុំអង្វរឱ្យជួយបង្ហាញមុខជនទុច្ចរិត។ ស្អែកឡើងគេយកបាយនោះទៅឱ្យអ្នកសង្ស័យហូប បើអ្នកទៀងត្រង់គ្មានបញ្ហាទេ តែជនទុច្ចរិតពេលបរិភោគនឹងមានឈាមចេញតាមមាត់។

បើមានជនជាប់ចោទ គេឱ្យជននោះអត់បាយ៣ថ្ងៃ រួចគេឱ្យលូកយកវត្ថុផ្សេងៗពីក្នុងទឹកកំពុងពុះឬកាន់ពូថៅ ឬប្រវាក់ដុតក្រហមដើរ៧ជំហាន បើមានកំហុសមែនដៃជននោះរលាករលួយ ផ្ទុយទៅវិញបើគ្មានកំហុសគឺគ្មានអ្វីទាំងអស់។

ឃ-សកម្មភាពសេដ្ឋកិច្ច

សកម្មភាពចម្បងនៅសម័យនគរភ្នំ គឺកសិកម្ម ពាណិជ្ជកម្ម និងសិប្បកម្ម។

-កសិកម្មរីកលូតលាស់ខ្លាំងដោយមានជោគជ័យខាងនយោបាយទឹក។ គេជីកព្រែកខ្លាត់ខ្មែងសម្រាប់បញ្ចេញ បញ្ចូលទឹក (ពេលទឹកជំនន់)សម្រាប់បន្សាបជាតិអំបិលដែលជ្រាបទៅក្នុងដីសម្រាប់គមនាគមន៍(គេឃើញសល់ដានត្រង់កម្ពុជាក្រោមភាគខាងត្បូង)។ ក្នុងមួយឆ្នាំគេអាចធ្វើស្រូវបាន៣ដង ក្រៅពីធ្វើស្រែ គេដាំក្រូច អំពៅ ទទឹម ស្វាៗលៗ។

-ពាណិជ្ជកម្មលូតលាស់ខ្លាំងតាមរយៈកំពង់ផែអូរកែវ។ អាណាចក្រភ្នំជាកន្លែងកើតមាស ប្រាក់ ទង់ដែង សំណប៉ាហាំង គ្រឿងក្រអូបកុកដំរី និងពេជ្រ។ អ្នកនគរភ្នំបិនប្រសប់ក្នុងមុខរបរធ្វើជាងមាស ឬប្រាក់ សូនរូប ត្បាញសូត្រ ចរបាប់ ស្វៃកវៗលៗ។

សរុបសេចក្តីមក អរិយធម៌នគរភ្នំមានលក្ខណៈខ្ពង់ខ្ពស់ជាងជនជាតិជិតខាងក្នុងសម័យជាមួយគ្នានោះ។ វាជាមរតកដ៏សំខាន់សម្រាប់ជំនាន់ក្រោយៗយកទៅច្នៃប្រឌិតបង្កើតអរិយធម៌មួយរឹងប៉ឹង។

២.២-អរិយធម៌សម័យចេនឡា

ក-ផ្នែកវប្បធម៌

ក្រៅពីសិលាចារឹកប្រើភាសាសំស្ក្រឹត គេប្រទះឃើញសិលាចារឹក ប្រើភាសាខ្មែរបុពណាជាលើកដំបូងនៅអង្គរបុរីរវាង គ.ស. ៦១១។ តាមសិលាចារឹកដែលគេបានរកឃើញ អ្នកស្រុកចេនឡា គោរពព្រហ្មញ្ញសាសនា គណៈព្រះឥសូរ (សិវៈ) និងពុទ្ធសាសនាមហាយាន។

ប្រវត្តិសាស្ត្របញ្ជាក់ថា ចាប់ពីព្រះបាទភវវរ្ម័នទី១(បឋមក្សត្រចេនឡា) រហូតមក ព្រះមហាក្សត្រសុទ្ធតែគោរពសាសនាព្រាហ្មណ៍ទាំងអស់។ ព្រះបាទភវវរ្ម័នបានកសាងសិលាចារឹកនៅភ្នំបន្ទាយនាង (បន្ទាយមានជ័យ) និងស៊ីថែប (សៀម)។ ព្រះមហេន្ទ្រវរ្ម័ន (ចិត្រសេន) ប្អូនជីដូនមួយព្រះបាទភវវរ្ម័ន មុនពេលឡើងសោយរាជ្យបន្តពីព្រះបាទភវវរ្ម័ន បានកសាងសិលាចារឹកជាភាសាសំស្ក្រឹតខ្វី។ នៅតាមបណ្តោយទន្លេមេគង្គ និងនៅខាងលិចបុរីរ៉ាម

(សៀម)។ ក្រោយពេលឡើងសោយរាជ្យ ព្រះអង្គបានកសាងសិលាចារឹកផ្សេងៗជាច្រើនទៀត នៅតាមទន្លេមូល និងនៅសូរិន្ទ និយាយពីការកសាងលិង្គគិរសៈ និង គោនន្ទី។

នៅប្រាសាទអណ្តែត (ស្រុកស្នោង ខេត្តកំពង់ធំ) គេបានប្រទះឃើញបដិមាហរិហរៈ (សិវៈវិស្ណុ) មានពង់យ៉ាងសង្ហាសាងនៅ គ.ស.ទី ៨។ សព្វថ្ងៃតាំងនៅសារមន្ទីរជាតិភ្នំពេញ។ ពិតមែនតែព្រះរាជាគោរពព្រហ្មញ្ញសាសនាតែពុទ្ធសាសនាហីនយានក៏នៅតែមានឥទ្ធិពល[2]។

សិលាចារឹកពុទ្ធសាសនាហីនយាន៖

-សិលាចារឹកសំបូរព្រៃគុក (៦២៦) និយាយពីការគោរពព្រះពុទ្ធនាគរាជមុច្ចលិន។

-សិលាចារឹកនៅខៅវាំង(សៀម)និយាយពីការជ្រះថ្លារបស់ឧបាសកសិនាហ្វ កសាងព្រះវិហារ។

-សិលាចារឹកវត្តព្រៃវៀរ (កំពង់ត្របែក ព្រៃវែង) និយាយពីជាតិជាកូរត្រ (រាជបុត្រ) ពីរអង្គបួសនៅក្នុងព្រៃវៀរ។

នៅចុងសម័យចេនឡា មានបម្រែបម្រួលគួរឱ្យកត់សម្គាល់ គឺពុទ្ធសាសនាមហាយាន ហូរចូលមកប្រទេសកម្ពុជាលើកដំបូងបង្ស់។ សិលាចារឹកវត្តប្រាសាទ (កំពង់ត្របែក ព្រៃវែង) និយាយពីការថ្វាយ ទាសៈចំពោះពោធិសត្វបីអង្គគឺ ព្រះប្រាជ្ញាបរមី ព្រះសិអារ្យមេត្រី និង អវលោកេស្វៈ។ សិលាចារឹកប្រាសាទតាកៀម (៧៩១) នៅសៀមរាប និយាយពីការកសាងរូបពោធិសត្វ ដែលត្រូវគេគោរពជាង់គេនៅស្រុកខ្មែរយើង។ ព្រះពុទ្ធសាសនានេះចូលមកស្រុកខ្មែរនៅសតវត្សរ៍ទី៧ ហើយរីកលូតលាស់ដល់កំពូលនៅរជ្ជកាលព្រះបាទជ័យវរ្ម័នទី៧។

ខ-ផ្នែកនយោបាយ និងរដ្ឋបាល

ចាប់តាំងពីព្រះបាទឦសានវរ្ម័ន លើករាជធានីទៅនៅឦសានបុរៈ នៅកណ្តាលក្រុងមានសាលាប្រជុំមួយយ៉ាងធំសម្រាប់ព្រះរាជាប្រទានសវនការរៀងរាល់៣ថ្ងៃម្តង។ ចំពោះគារវកិច្ច មន្ត្រីឱនក្បាលដល់ជើង៣ដង។ ពេលព្រះរាជាហៅ មន្ត្រីត្រូវលុតជង្គង់នៅជុំវិញព្រះរាជា ដើម្បីពិភាក្សាការងារប្រទេសជាតិ។ គេឃើញមានទាហានពាក់អាវក្រោះឈរយាមគ្រប់ទីកន្លែង តាំងពីជុំវិញបល្ល័ង្ករហូតដល់ទ្វារទាំងឡាយ។

ការផ្ទេររាជសម្បត្តិ គឺមានតែរាជបុត្រនៃអគ្គមហេសីទេ ដែលអាចឡើងសោយរាជ្យបាន។ នៅថ្ងៃប្រារព្ធពិធីអភិសេកព្រះរាជាថ្មី គេកាត់ម្រាមដៃ ច្រមុះ បុត្រឯទៀតរួចយកទៅឃុំទុកនៅកន្លែងទីទៃពីគ្នា។

[2] សាកលវិទ្យាល័យភ្នំពេញអន្តរជាតិ៖ **រដ្ឋបាលសាធារណៈ** ដ.ឯ.ម.។

គ-ជីវភាពសង្គម

-លក្ខណៈមនុស្ស៖ អ្នកស្រុកចេនឡា មានមាឌតូច សម្បុរខ្មៅដូចអ្នកនរគភ្នំដែរ ប៉ុន្តែស្រីភាគច្រើនសម្បុរស ទាំងប្រុស ទាំងស្រីបួងសក់ ពាក់រយ៉ាថែមទៀត (ដូចខ្មែរសព្វថ្ងៃ)។

-ទំនៀមទម្លាប់៖ អ្នកស្រុកចេនឡា រាងវែណាស់ គេចាត់ទុកដៃស្តាំ ជាដៃបរិសុទ្ធ ដៃឆ្វេងមិនបរិសុទ្ធទេ។ រៀងរាល់ព្រឹកគេតែងលុបលាងដុសធ្មេញនិងសំបកស្ងា រួចអានសៀវភៅ ឬសូត្រធម៌។ មុនពេលទទួលទានអាហារ គេតែងតែធ្វើការលុបលាងសាជាថ្មី។ ពេលបរិភោគរួចគេចាក់ធ្មេញហើយសូត្រធម៌ម្តងទៀត។

សិលាចារឹកបញ្ជាក់ថា គេនិយមរាប់ញាតិតាមខ្សែខាងម្តាយ។ ក្នុងការជ្រើសរើសគូស្រករ គឺពួកប្រុសៗទៅដណ្តឹងស្រី។ ពេលការរួច កូនប្រុសត្រូវទទួលមរតកពីឪពុកម្តាយ រួចបែកផ្ទះ។ បើឪពុកម្តាយស្លាប់ កូនដែលនៅរស់អាចទទួលមរតកដែលនៅសេសសល់។ បើកូនមានប្តីប្រពន្ធ ហើយបានទទួលមរតករួចហើយ នោះទ្រព្យសម្បត្តិដែលនៅសេសសល់ត្រូវបញ្ចូលទៅក្នុងឃ្លាំងជាតិ។

ក្នុងពិធីបុណ្យសព កូនទាំងអស់ត្រូវអត់បាយ៧ថ្ងៃ កោរសក់ យំស្រែកយ៉ាងខ្លាំង។ គ្រួសារហៃសពមានក្ងេង ព្រះសង្ឃទៅប៉ាធាដែលសង់ដោយឈើក្រអូប។ កាលណាគេរើសជាតុរួចហើយ ត្រូវយកជាតុនោះទៅដាក់ក្នុងកោដ្ឋរួចយកទៅទម្លាក់ចោលក្នុងទឹក។ ជួនកាលគេគ្រាន់តែយកទៅដាក់ចោលក្នុងព្រៃ។ ពេលទៅណាមកណាអ្នកស្រុកពាក់អាវក្រោះ និងកាន់អាវុធទុកដើម្បីការពារសុវត្ថិភាពខ្លួន។

ឃ-សកម្មភាពសេដ្ឋកិច្ច

សម័យចេនឡា នយោបាលទឹកកាន់តែរឹងមាំ កសិកម្មកាន់តែរីកចម្រើនថែមទៀត។ ក្រុងធំៗច្រើនរៀបចំស្ថាបនានៅតាមមាត់ស្ទឹងព្រោះត្រូវបង្ហូរទឹកចូលក្នុងស្រះ ឬប្រព័ន្ធប្រឡាយព័ទ្ធជុំវិញទីក្រុង និងអាងទឹកនៅក្នុងទីក្រុង។ (ឧទាហរណ៍៖ ក្រុងវ៉ាសានបុរៈ សាងនៅក្បែរស្ទឹងសែន) ដំណាំស្រូវ និងដំណាំ ឯទៀតៗ គេដឹងថាមានសម្បូរបែប។

នៅសម័យចេនឡា ពុទ្ធសាសនាហីនយានថយឥទ្ធិពលបណ្តើរៗ តែពុទ្ធសាសនាមហា យានចាប់ផ្តើមរីកចម្រើនស្ថាបត្យកម្ម នៅជាប់ឥទ្ធិពលឥណ្ឌាបន្តិចបន្តួច តែភាគច្រើនបង្ហាញក្បាច់រចនាបែបខ្មែរ។ ផ្នែកនយោបាយនៅទន់ខ្សោយ ដោយបានទទួលការឈ្លានពានរបស់ជ្វាមកលើក្សត្របុរីខ្មែរឯវិស័យសេដ្ឋកិច្ចរីកលូតលាស់ខ្លាំងណាស់ដោយការរីកចម្រើនខាងនយោបាយទឹក។

២.៣-អរិយធម៌សម័យមហានគរ

អរិយធម៌ខ្មែរឈានដល់កំពូលចាប់ពីសតវត្សទី៩ ដល់សតវត្សទី១៥។ ខ្មែរឡើងហាន: ជាមហាអំណាចនៅអាស៊ីអាគ្នេយ៍ ទឹកដីធំ

ទូលាយ លាតសន្ធឹងស្ទើរតែអស់ផ្ទៃដីឥណ្ឌូចិន ទាំងមូល មានប្រាសាទសិលាពាប់ពាន់ សិលាចារឹកទាំងភាសាសំស្ក្រឹត ទាំងភាសាខ្មែរ ជួនកាលមានភាសាទាំងពីរលាយគ្នា។ ប្រឡាយ បារាយណ៍ ទំនប់ទឹក ស្ពានថ្ម មន្ទីរពេទ្យ សាលាសំណាក់។ល។ មានគ្រប់ទិសទីពេញផ្ទៃប្រទេស។

ក-ផ្នែកវប្បធម៌

-សាសនា៖ នៅសម័យអង្គរ សាសនាមានតួនាទីយ៉ាងសំខាន់ខាងនយោបាយ។ ព្រះរាជាកាន់សាសនាព្រាហ្មណ៍ គោរពព្រះឥសូរខ្លះកាន់សាសនាព្រហ្មណ៍ដែរ តែគោរពព្រះវិស្ណុ ហើយខ្លះទៀតកាន់ព្រះពុទ្ធសាសនាមហាយាន។ ពីសតវត្សរ៍ទី៩ ដល់ទី១១ គណៈសិវៈមានឧត្តមភាពជាងគេដោយព្រះរាជាចាត់ទុកជាសាសនារដ្ឋ (ធ្វើពីធីទេវរាជ)។

នៅសតវត្សរ៍ទី១២ ព្រះបាទសូរ្យវរ្ម័នទី២ គោរពរាប់អានយ៉ាងខ្លាំងគណៈវិស្ណុ មានប្រាសាទអង្គរវត្តជាវិមានតម្កល់បដិមាព្រះវិស្ណុ។ ឯក្បាច់រចនាផ្សេងៗ ក៏និយមអំពីរឿងព្រះវិស្ណុដែរ ដូចជា រឿងរាមកេរ្តិ៍ មហាភារតៈ កូរសមុទ្រដឹកដោះ។ល។

ក្រោយមក ព្រះបាទជ័យវរ្ម័នទី៧ គោរពព្រះពុទ្ធសាសនាមហាយាន ដែលនាំចូលមកតាំងពីសម័យចេនឡា ដែលព្រះបាទសូរ្យវរ្ម័នទី១ កាន់ម្តងរួចមកហើយ។ ព្រះអង្គកសាងប្រាសាទបាយ័នដើម្បីតម្កល់បដិមាព្រះពុទ្ធពិតមែន ក៏ប៉ុន្តែប្រាសាទនេះជានិមិត្តរូបខាងព្រហ្មញ្ញសាសនាផងដែរដោយសារព្រះកំត្រៃព្រះព្រហ្ម។ ដូចនេះទេវរាជក្តី វិស្ណុរាជក្តី (សូរ្យវរ្ម័នទី២) ពុទ្ធរាជក្តី សុទ្ធតែបានរួមចំណែកយ៉ាងសកម្មក្នុងការអភិវឌ្ឍសម័យអង្គរ។

កំណត់សម្គាល់៖ ពីសតវត្សរ៍ទី៩ដល់ទី១០ ក្រៅពីបដិមាទិទេព ឬពោធិសត្វ ឬព្រះពុទ្ធ គេឃើញមានបដិមា(តំណាងឱ្យបុគ្គលនិយម) ដែលជាព្រះរាជវង្ស ព្រះរាជគ្រូ ឬវីរជនរបស់ជាតិ។

ខ-នយោបាយ និងរដ្ឋបាល

-ព្រះរាជាប្រារព្ធពិធីទេវរាជ ឬវិស្ណុរាជ មានឋានៈស្មើនឹងអាទិទេព។

-ព្រះរាជាប្រារព្ធពិធីពោធិរាជ មានឋានៈស្មើនឹងពោធិសត្វ(ជ័យវរ្ម័នទី៧)។

-មុនពេលចូលទីវង្គត ព្រះអង្គនឹងឈានទៅកាន់ទេវលោក។

-ប្រាសាទភ្នំនៅពាក់កណ្តាលក្រុង ជានិមិត្តរូបភ្នំព្រះសុមេរុ កំពែង និងគូទឹកជានិមិត្តរូបជួរភ្នំនិងសមុទ្រព័ទ្ធជុំវិញភ្នំព្រះសុមេរុ។

ព្រះអង្គជាអ្នកជ្រើសរើសមន្ត្រីជាន់ខ្ពស់ជាអគ្គមេបញ្ជាការ ជាអ្នកកាត់ក្តីជាមេសាសនា។ ព្រះអង្គជាអ្នកមានអំណាចធំធេង ប៉ុន្តែមិនមែនជាអ្នកផ្តាច់ការទេ តែជាអ្នកគោរពវិន័យ វណ្ណៈ ក្បួន មានព្រហ្មវិហារធម៌ និងទសពិធរាជធម៌។

ឧទាហរណ៍៖ សិលាចារឹកព្រះគោ និយាយពីព្រះបាទឥន្ទ្រវរ្ម័នទី១រៀបរាប់ថា "ព្រះបាទឥន្ទ្រវរ្ម័នទី១ ធ្វើឱ្យប្រជារាស្ត្រសំបូរសប្បាយ ដោយការប្រតិបត្តិវិស័យ៣ប្រការ"។

សិលាចារឹកនិយាយពីព្រះបាទជ័យវរ្ម័ន នៅមន្ទីរពេទ្យ "ជំងឺប្រជារាស្ត្រ ធ្វើឱ្យព្រះអង្គឈឺចាប់ជាងជំងឺផ្ទាល់របស់ព្រះអង្គ"។

ការបន្តរាជ្យ៖ បុត្រច្បងឡើងសោយរាជ្យស្នងព្រះបិតា តែបើគ្មានបុត្រច្បង ញាតិមិត្តណាម្នាក់អាចឡើងសោយរាជ្យជំនួសបាន (ឯកសារខ្លះបញ្ជាក់ថាទាល់តែជាញាតិខ្សែខាងស្រីជាមួយស្តេចមុន ឬត្រូវយកកូរត្រណាមួយក្នុងគ្រួសារស្តេចមុនទើបអាចទទួលរាជសម្បត្តិបាន)។ ក្នុងករណីអ្នកស្នងរាជ្យនៅវ័យក្មេងពេកនោះ រាជកិច្ចត្រូវបានទៅព្រះគ្រូ ឬឧបរាជ ជាអ្នកទទួលខុសត្រូវជំនួសព្រះអង្គ[៣]។

-រដ្ឋបាលកណ្តាល៖ ការគ្រប់គ្រងរដ្ឋស្ថិតនៅក្នុងកណ្តាប់ដៃអភិជនមួយក្រុមតូចៗ តំណែងធំៗ ត្រូវបានទៅព្រះរាជវង្សានុវង្ស។ វណ្ណៈកូរត្រ និងព្រាហ្មណ៍ជាវណ្ណៈខ្ពស់ ហើយវណ្ណៈទាំងពីរតែងតែចងសម្ព័ន្ធមេត្រីនឹងគ្នា។ ព្រះរាជាប្រទានសវនការចំនួនពីរដងក្នុងមួយថ្ងៃ សម្រាប់ដោះស្រាយកិច្ចការរដ្ឋ ពួកនាហ្មឺន និងរាស្ត្រអង្គុយផ្ទាល់ដី។ មន្ត្រីធំៗខ្លះជាទីប្រឹក្សាខ្លះទទួលបន្ទុកធំក្នុងវាំង ឬកាន់ទ័ពឈរជើងនៅតាមខេត្ត ខណ្ឌ។ មន្ត្រីជាន់ទាបត្រូវជ្រើសរើសដោយមន្ត្រីជាន់ខ្ពស់។ គ្រែស្នែង (មាស ឬប្រាក់) និងចំនួនក្ងស់ (ដងមាស ឬដងប្រាក់) ជាតំណាងសញ្ញាសក្តិ។

-រដ្ឋបាលភូមិភាគ៖ មានចៅហ្វាយខេត្ត មេស្រុក មេភូមិ មេឃ្លាំង។ល។ ស្ត្រីមានមុខងារសំខាន់ដែរ ខ្លះធ្វើជាហោរា ខ្លះទៀតជាចៅក្រមក្នុងរាជវាំង។ល។

គ-សេដ្ឋកិច្ច និងសង្គមកិច្ច

នយោបាយទឹក ជាមធ្យោបាយមួយយ៉ាងសំខាន់ ក្នុងការអភិវឌ្ឍវិស័យកសិកម្មឱ្យបានលូតលាស់ជាអតិបរមា។ ឧទាហរណ៍: បារាយណ៍ច្រើនត្រូវបានកសាងឡើងដោយរាស្ត្រ។

បណ្តាញផ្លូវថ្នល់ បូករួមទាំងផ្លូវទឹកជាមធ្យោបាយយ៉ាងសំខាន់បំផុត ខាងផ្នែកពាណិជ្ជកម្មទាំងក្នុង និងក្រៅប្រទេស។

ផ្នែកស្ថាបត្យកម្មវិញ គេឃើញមានប្រាសាទ២បែបៈ

-ប្រាសាទភ្នំ ជាប្រាសាទសង់លើខឿនច្រើនជាន់សម្រាប់លទ្ធិទេវរាជ (បាខែង បាគង បក្សី ចាំក្រុង អង្គរវត្ត បាយ័ន។ល។

-ប្រាសាទសង់រាបនឹងដីសម្រាប់លទ្ធិបុគ្គលនិយម (ព្រះគោ លលៃ បន្ទាយឆ្មា ព្រះខ័ន

[៣] ពៅសារឿន៖ **ប្រវត្តិស្តាប័នខ្មែរ** បោះពុម្ពលើទី១ ឆ្នាំ២០១៥។

តាព្រហ្ម ។ល។) ពីស្តេចមួយទៅស្តេចមួយ ប្រាសាទកាន់តែធំ និងកាន់តែច្រើន។

យើងអាចសន្និដ្ឋានបានថា សម័យអង្គរ ជាសម័យដែលអរិយធម៌ខ្មែរឡើងដល់កំពូល ដោយវិស័យសេដ្ឋកិច្ច នយោបាយ និងវប្បធម៌ ឡើងដល់កំពូល។

ព្រះបាទជ័យវរ្ម័នទី៧ បានកសាង សាលាសំណាក់ចំនួន១២១ នៅតាមបណ្តោយ ផ្លូវទូទាំងប្រទេសពីមួយទៅមួយចម្ងាយ១៥គ.ម.៖

-ពីអង្គរ ទៅចម្ប៉ា មាន ៥៧សាលា

-ពីអង្គរ ទៅកីម៉ែ មាន ១៧សាលា

-កន្លែងដទៃទៀត មាន ៤៦សាលា

-ភ្នំជីសូរ មាន១សាលា

ព្រះអង្គបាន កសាងមន្ទីរពេទ្យចំនួន ១០២ នៅពាសពេញប្រទេស ដើម្បីឱ្យមនុស្ស ក្នុងវណ្ណៈទាំង៤ ចូលព្យាបាលជំងឺដូចគ្នា ។

ក្រោយពីរាជ្យព្រះបាទជ័យវរ្ម័នទី៧ ព្រះបាទជ័យវរ្ម័នទី៨ ត្រឡប់ទៅរកសិវៈនិយមវិញ ដែលជាហេតុបណ្តាលឱ្យមានប្រតិកម្ម យ៉ាងខ្លាំងក្លាពីពួកព្រហ្មណ៍ប្រឆាំងនឹងព្រះពុទ្ធសាសនា រហូតដល់មានការកម្ទេច ឬកោសលុបព្រះពុទ្ធបដិមាចោល[៤]។

[៤] ពៅ សារឿន ៖ **ប្រវត្តិស្ថាប័នខ្មែរ** ដ.ឯ.ម.។

៣. ទំនាក់ទំនងរវាងអរិយធម៌និងច្បាប់

នៅក្នុងស្នាដៃអក្សរសិល្ប៍ទាក់ទងនឹងយុត្តិធម៌ អ្នកដែលមានមុខងារកាត់ក្តីត្រូវបានកំណត់ឈ្មោះចំនួនបីយ៉ាងគឺ "ចៅក្រម" "សុកា" និង "តុលាការ" ។

វចនានុក្រមខ្មែរបានកំណត់និយមន័យនៃពាក្យ "ចៅក្រម" ថាជាមន្ត្រីតុលាការ ឬមន្ត្រីអ្នកជម្រះក្តីដោយពុំបានបញ្ជាក់អំពីឫសនៃពាក្យនេះឡើយ។ ការពិត "ចៅក្រម"មកពីពាក្យថា "ចៅ"និង"ក្រម"។ ក្នុងន័យនេះ ចៅក្រមសម្គាល់អ្នកនាយ អ្នកដែលមិនធ្លាប់បានបួសសោះ ម្ចាស់ ដូចជា "ព្រះចៅក្រុងកម្ពុជា" សំដៅដល់ម្ចាស់ក្រុងកម្ពុជា គឺស្តេចឬចៅទេស" សំដៅលើម្ចាស់ប្រទេស គឺព្រះរាជា។ រីឯ "ក្រម" មានន័យថា លំដាប់ក្បួន កម្រងមាត្រាច្បាប់សម្រាប់តុលាការកាត់ក្តីបែបពួកប៉ែក។ ដូច្នេះ "ចៅក្រម" សំដៅដល់ម្ចាស់ច្បាប់ អ្នកកាន់ច្បាប់អ្នកទ្រទ្រង់និងការពារច្បាប់ អ្នកដែលបានសិក្សាស្វែងយល់អំពីច្បាប់ អ្នកដែលអនុវត្តត្រឹមត្រូវតាមច្បាប់ អ្នកតំណាងច្បាប់។ ផ្អែកលើការពន្យល់នេះ "ចៅក្រម" សំដៅដល់អ្នកកាត់ក្តី ដែលផ្តោតមុខងារជាសំខាន់លើការអនុវត្តច្បាប់ ប្រតិបត្តិច្បាប់ ឬកាត់ក្តីផ្តល់យុត្តិធម៌ដោយអនុវត្តត្រឹមត្រូវ និងទៀងត្រង់តាមច្បាប់។

"សុកា" ជាពាក្យដែលប្រែក្លាយមកពី "សភា" ដែលមានន័យថា "ទីប្រជុំពិភាក្សាកិច្ច

ការ,ទីតុលាការ" រីឯ "សុកា" គឺអ្នកពិភាក្សាក្តី ឬ ឋានន្តរចៅក្រមខាងតុលាការជាអ្នកពិភាក្សាក្តី។ ដូច្នេះ "សុកា" សំដៅដល់អ្នកកាត់ក្តីដែលផ្តោតមុខងារចម្បងលើការពិភាក្សាជំនុំជម្រះសេចក្តី។

"តុលាការ" មកពីពាក្យ "តុលា" ប្រែថា ជញ្ជីង ឬ ត្រាជូ, ផ្សំជាមួយនឹង "ការៈ ឬអាការ" មានន័យថាការថ្លឹង ការស្មង់មិនឱ្យល្អៀងឬអ្នកស្មង់តម្រង់សេចក្តី ឬកិច្ចការដែលគេជម្រះក្តីគេកាន់យុត្តិធម៌ឱ្យស្មើដោយថ្លឹងដូចជញ្ជីងក្រសួងជម្រះក្តី ឬចៅក្រម អ្នកវិនិច្ឆ័យក្តី។ ដូច្នេះ "តុលាការ" គឺជាកាត់ក្តីឬស្ថាប័នកាត់ក្តីដែលលើកតម្កើងមុខងារសំខាន់ខាងការថ្លឹងថ្លែងមិនឱ្យល្អៀង។

ចំណែកឯពាក្យ "អ្នកកាត់ក្តី" គឺជាពាក្យទូទៅដែលសម្គាល់បានទាំងចៅក្រម ទាំងសុកា ទាំងតុលាការ ពីព្រោះបើវិភាគលើឫសនៃពាក្យនេះ "អ្នក" ប្រែថាបុគ្គលជន ឬមនុស្ស។ "កាត់" គឺផ្តាច់ដោយប្រដាប់មានមុខមុតមានកន្ត្រៃ រណារជាដើម ហេតុដូច្នេះហើយទើបមានពាក្យថា "អារកាត់" ដែលសំដៅដល់ការសម្រេចចិត្ត ការសម្រេចកិច្ចការអ្វីមួយឱ្យដាច់ស្រេចស្តាពរ។ ម្យ៉ាងទៀត "កាត់" នេះមានន័យជ្រាលជ្រៅណាស់ក្នុងអក្សរសាស្ត្រខ្មែរ ដូចជាកាត់សុបិន គឺជាការទស្សន៍ទាយ ឬដោះស្រាយន័យសេចក្តីរបស់សុបិន។ កាត់ប្រផ្នូលគឺជាការទស្សន៍ទាយ ឬដោះស្រាយ អាថ៌កំបាំងដែលបង្កប់នៅក្នុងប្រផ្នូលនោះ។ ពិធីកាត់សក់បង្កក់សិរីដល់កូនប្រុសស្រីរៀបមង្គលការ គឺជាពិធីដែលផ្តល់នូវសិរីសួស្តី ជ័យមង្គល ឱ្យសម្រេចប្រយោជន៍តាមសេចក្តីប៉ងប្រាថ្នាពោលគឺកាត់សក់ដើម្បីបង្កក់សិរី ដែលមានន័យថាធ្វើឱ្យមានជោគជ័យ សិរីសួស្តី។ កាត់ទោស គឺសម្រេចអំពីទោសដែលត្រូវអនុវត្ត ចំពោះអ្នកដែលបានប្រព្រឹត្តល្មើសច្បាប់។ កាត់ចិត្ត គឺសម្រេចចិត្តឱ្យដាច់ស្រឡះ កុំឱ្យចេះតែនឹកនាស្តាយស្រណោះតទៅទៀត។ ដូច្នេះ "កាត់" មានន័យសំខាន់ គឺជាកិរិយា ធ្វើឱ្យសម្រេចដល់ជោគជ័យដល់សេចក្តីពិតនៃអាថ៌កំបាំង។

រីឯ"ក្តី"មានន័យថា ដំណើរហេតុការណ៍ដែលទាស់ទែងគ្នា ដែលប្តឹងផ្តល់គ្នារហូតដល់ទីតុលាការវិនិច្ឆ័យ ដូចជា "ក្តីក្តាំ" សំដៅលើវិវាទអធិករណ៍។ កើតក្តី កើតមានវិវាទនឹងគ្នា។ "អ្នកកាត់ក្តី" សំដៅដល់បុគ្គលទាំងឡាយណាដែលមានមុខងារដោះស្រាយឬសម្រេចនូវទំនាស់ ឬវិវាទផ្សេងៗឱ្យបានដាច់ស្រេចជាស្តាពរដោយសិរីសួស្តី។ អាស្រ័យដោយពាក្យនេះមានលក្ខណៈទូទៅនិង សាមញ្ញ ប្រកបដោយប្រជាប្រិយភាពនៅក្នុងសង្គមខ្មែរ ទើបសាស្ត្រាដែលទាក់ទងនឹងការកាត់ក្តីមានឈ្មោះថា "កឹងកន្ត្រៃ" ដែលស្តែងឱ្យជាក់នូវការកាត់ក្តីដោយកន្ត្រៃយុត្តិធម៌។

សរុបសេចក្តីមក អ្នកកាត់ក្តី ទោះមានឈ្មោះជា ចៅក្រម សុភា ឬតុលាការ គឺអាស្រ័យលើការកំណត់របស់ថ្នាក់ដឹកនាំប្រទេស ឬការនិយមចូលចិត្តប្រើរបស់ប្រជាពលរដ្ឋ។ អ្វីដែលសំខាន់ គឺផ្តើមចេញពីនិយមន័យ ដែលបានវិភាគខាងលើនេះអ្នកកាត់ក្តីគឺជាអ្នកដោះស្រាយ សម្រេចរាល់បញ្ហាទំនាស់ ឬវិវាទដែលកើតមានឡើងឱ្យដាច់ស្រេចជាស្ថាពរ ប្រកបដោយសិរីសួស្តី ហើយការសម្រេចបានជោគជ័យលើការកិច្ចនេះត្រូវពឹងផ្អែកជាមូលដ្ឋាន លើការអនុវត្តច្បាប់ ការពិភាក្សាជំនុំសេចក្តីការថ្វឹងថ្លែងមិនឱ្យល្អៀង ដើម្បីសម្រេចជម្រះរឿងទំនាស់ ឬវិវាទទាំងអម្បាលឱ្យបានជ្រះស្រឡះដាច់ស្រេចដល់សេចក្តីពិត និងសេចក្តីត្រឹមត្រូវ។

ដូច្នេះ មុខងារកាត់ក្តី ដើម្បីផ្តល់យុត្តិធម៌យ៉ាងហោចណាស់តម្រូវឱ្យបំពេញការកិច្ចបីជំពូក គឺអនុវត្តច្បាប់ ពិភាក្សា និងថ្វឹងថ្លែងមិនឱ្យល្អៀង ទោះបីអ្នកកាត់ក្តីនោះមានឈ្មោះជាចៅក្រម សុភា ឬតុលាការក៏ដោយ។

៣.១-ក្រមសីលធម៌អ្នកកាត់ក្តី

ដើម្បីបំពេញមុខងាររបស់ខ្លួនក្នុងការផ្តល់យុត្តិធម៌ អ្នកកាត់ក្តីទាំងឡាយត្រូវរៀរចាកអគតិ ធម៌ផង និងប្រតិបត្តិតាមសុគតិធម៌ផង ព្រមទាំងកាន់សីលជ្រាំជាប្រចាំ និងចាំសីលជ្រាំបី នៅរៀងរាល់ថ្ងៃសីលផង។ ចំពោះ ព្រះមហាក្សត្រ ដែលជាចៅក្រមដ៏កំពូលនោះក្រៅពីករណីយកិច្ចទាំងនោះក៏ត្រូវបន្ថែមទសពិធរាជធម៌ ដែលមានដប់ប្រការថែមទៀត។

ក-ពាក្យទំនៀមបង្គារទំនាស់៖ តាមពាក្យទំនៀមខ្មែរ ចាស់បុពាណតែងទូន្មានឱ្យជនទាំងឡាយរៀរចាកនូវទំនាស់នឹងគ្នា ពីព្រោះកាលណាវិវាទឡើងដល់ចៅក្រមកាត់ក្តី ភាគីទំនាស់ទាំងសងខាងរមែងតែងតែខាតបង់ដូចៗគ្នាពុំលែងឡើយ។ ដើម្បីបង្គារមិនឱ្យមានទំនាស់ ចាស់បុពាណតែងហាមថា "កុំធ្វើស្រែប្រវាស់ កុំសង់ផ្ទះជាមួយ" ឬ "កុំធ្វើស្រែប្រវាស់កុំសង់ផ្ទះចូលគ្នា" ពីព្រោះ លោកតែងសង្កេតឃើញមានទំនាស់ជាញឹកញាប់ ទាក់ទងនឹងការបែងចែកភាគផលដំណាំស្រូវ និងការសង់ផ្ទះរំលោកបំពានគ្នាទៅវិញទៅមក បង្កជាទំនាស់ដ៏ពុំរ៉ៃដូចឃុនឧត្តម ប្រីជាចាប ពិន បានពន្យល់សុភាសិតនេះថា៖ «សុភាសិតនេះពោលត្រង់ៗ បើយើងពិនិត្យដោយផ្ចិតផ្ចង់ ក៏គង់ឃើញជាក់ច្បាកដណាស់។ បានជាលោកឃាត់អំពើនៃការធ្វើស្រែប្រវាស់ ព្រោះរមែងច្រើនតែទាស់ ទំនាស់នាំកើតទុក្ខវេទនា។ មួយទៀតការសង់ផ្ទះសំបែង ចូលគ្នាតែងតែទាស់គ្នា ហេតុនេះទើបលោកហាមឃាត់ថា "កុំធ្វើចូលគ្នាឱ្យសោះឡើយ"។»

ក្នុងរឿងទិញដូររបស់ទ្រព្យ បុពាណលោកតែងតែទូន្មានថា "សូវទិញ កុំឱ្យដូរ" ពីព្រោះកាលណាទិញទៅគឺតែងតែដាច់ស្រេចល្អ រីឯដូររបស់គ្នាវិញរមែងនាំមកនូវការមិនពេញ

ចិត្តដោយប្រការផ្សេងៗ។ ចំពោះរបស់ជាបញ្ញើ គេ បុរាណលោកទូន្មានថា"បញ្ញើស្មើ បំណុល" ពីព្រោះកាលណាទ្រព្យបញ្ញើដែលគេផ្ញើនោះ ប្រែបាត់បង់ ឬវិនាសហិចហោចដោយប្រការណាមួយ អ្នកទទួលបញ្ញើរមែងមានកាតព្វកិច្ចសងទ្រព្យបាត់នោះទៅម្ចាស់បញ្ញើវិញ ដូច្នេះ អ្នកទទួលបញ្ញើមិនត្រូវគិតឆ្ងេសប្រហែល ឬទទួលបញ្ញើឱ្យតែរួចពីដៃនោះទេ គោងគិតអំពីទំហំការទទួលខុសត្រូវរបស់ខ្លួនផងក្នុងករណីមានការបាត់បង់។

បុរាណលោកទូន្មានបន្តទៀតថា "កុំឈ្លោះនឹងស្រី កុំក្តីនឹងចិន" ពីព្រោះលោកយល់ឃើញថាមនុស្សស្រីតែងតែមានចិត្តមិននឹងនរ។ ច្រើនធាប់ខឹងហើយក៏ធាប់ជាដៃរចំណែកឯឈ្លោះនឹងគ្នាឯងរមែងនាំមកនូវការបាត់បង់ទ្រព្យា ពុំលែងឡើង ហើយបើឈ្លោះនឹងចិនវិញ គឺមុខជាមិនអាច ឬកម្រនឹងឈ្នះក្តីណាស់ដ្បិតអីចិននៅស្រុកខ្មែរតែងមានឈ្មោះល្បីខាងពូកែរកស៊ីរបរជំនួញ មានមាសប្រាក់ធនធានច្រើនសម្រាប់សូកចៅក្រមកាត់ក្តីឱ្យខ្លួនឈ្នះជានិច្ច។ សុភាសិតនេះ ឃុនឧត្តមប្រីជា ចាបពិនបានអធិប្បាយទុកមកថា៖

"ពាក្យនេះលោកពោលថាឃាត់ កុំឱ្យប្រុសៗធ្វើភ្ងាំងភ្ងាត់ ទាស់មាត់ទាស់ឈ្លោះវិាទ។ ដ្បិតលោកចាត់ស្រីទៅដោយប៉ែក ចម្ងៃកពីប្រុសដោយធម្មជាតិ ទាំងចិត្តគំនិតឫកមារយាទសឹងឃ្លាតពីប្រុសមិនដូចគ្នា។ ធម្មជាតិស្រីៗ ចិត្តមិននឹង ច្រើនធាប់ខេខឹងតែធាប់ជា ប្រុសណាធាប់ខឹងនឹងប៉ះពាល់ឈ្លោះទាស់ទែងគ្នាជាមិនខាន។ ទើបលោកថា "កុំឈ្លោះនឹងស្រី" វាអាប់សួស្តីដល់ខ្លួនប្រាណ មិនបានជាការអ្វីប៉ុន្មានបានតែរុះខានចិត្តអាត្មា។ មួយទៀតទុកជាប្រុសឬស្រី មិនត្រូវកើតក្តីអ្វីនឹងគ្នាព្រោះក្តីតែងខូចខាតទ្រព្យា ទាំងអស់គ្នាទាំងឈ្នះចាញ់។ អ្នកឈ្នះក៏ដាច់ទ្រព្យាធនធានាំឱ្យរំខានចិត្តខ្នួលខ្នាញ់ ចំណែកខាងឯអ្នកដែល ចាញ់ខូចទ្រព្យាកើតក្នាញ់យ៉ាងក្រៃលែង។

ដូច្នេះ ការបង្កជម្លោះក្តីក្តាំនឹងគ្នា តែងនាំមកនូវសេចក្តីវិនាសក្រលំបាក ដូចសុភាសិតមួយបានពោលថា "ធូន់នឹងថ្ម ក្រនឹងក្តី" ឬ "ធូន់នៅថ្ម ក្រនៅក្តី" ហើយដែលឃុនឧត្តមប្រីជា ចាប ពិន បានពន្យល់ជាពាក្យកាព្យដូចខាងក្រោមនេះ៖

សុភាសិតនេះបើរិះរក តាមន័យបុរាណលោកពោលមក អស់យើងគួរយកជាគោលបាន ។ ជាពាក្យបន្ទាចជនស្រីប្រុស មិនឱ្យគិតខុសហួសប្រមាណ ប្រមាថអ្នកផងមិនគិតប្រាណ កើតបានជារឿងក្តីក្តាំឡើយ។ ព្រោះការក្តីក្តាំនាំបង្កើនចម្រើនវេលាទោសឥតស្បើយទាំងខាងចោទចុងចម្ងើយ ម្ល៉ោះហើយតែខាតខូចទ្រព្យា។ ដូចកលត្បាល់កិនតែងរេចព្រម ទាំងលើទាំង

ក្រោម ស្មើៗគ្នាហេតុនេះទើបប្រាជ្ញលោកពោលថា ដូចមាតិកាខាងដើមនោះ។

អ្នកព្រះកិរម្យភាសា អ៊ូ ហៅ ង៉ុយ ក៏បានទូន្មានកូនចៅអ្នកស្រុកស្រែចម្ការឱ្យវៀរចាកអំពើដែលបង្កឱ្យមានកើតក្តីក្តាំផងដែរ នៅក្នុងការប្រកបជីវភាពរស់នៅប្រចាំថ្ងៃរបស់ខ្លួន។ លោកបានទូន្មានអ្នកស្រែចម្ការទាំងឡាយកុំឱ្យលើកដីឯងទៅដាក់នៅស្រែខាងគេតាមបទកំណាព្យនៅក្នុងច្បាប់ល្បើកថ្មីដូច្នេះថា៖

"កូនអើយធរណី បើតាមគម្ពីរ ដែលលោកសម្តែង កុំចង់បានធំ ប្រមុំឆ្មៀលឆ្មែង កុំលើកដីឯងលបដាក់ស្រែគេ។ អំពើអាក្រក់ មួយចំរៀកសក់ ជ្ងាក់ទៅនិរយេ បច្ចុប្បន្នលោកិយ កើតក្តីវាយជេរ មិនដែលសុខទេ ព្រោះដីមួយហត្ថ។

លោកបានផ្តាំដល់អស់កូនចៅអ្នកស្រែចម្ការឱ្យឧស្សាហ៍ស្រាស់របង តែកុំឱ្យស្រាស់របងឆ្ងងចូលទៅក្នុងដីគេ៖

"របៀបចម្ការ ថែទាំរក្សា យូរៗស្រាស់ម្តងស្រាស់ឱ្យត្រូវជួរ មើលគួរសមផង កុំបើកមុងឆ្ងងទៅស្រាស់ខាងក្រៅ។ មិនគាប់ប្រសើរ របងវាដើរ អ្នកម្ខាងវាក្តៅ កើតក្តីកើតក្តាំ អស់ខោអស់អាវ ខឹងអស់ញាតិផៅ ពីព្រោះចម្ការ"។

ចំពោះរឿងប្រគល់ទ្រព្យខ្លួនដល់អ្នកផងដែលទុរគត ក្រខ្សត់ខ្លីនេះលោកទូន្មានឱ្យមើលពិនិត្យឱ្យល្អិតល្អន់អំពីឫកមារយាទរបស់ជននោះជាមុនសិន ក្រែងត្រូវប៉ះចំលើជនដែល "ធ្វើគុណបានទោស" មកវិញនោះជាហេតុនាំឱ្យកើតក្តីក្តាំអស់ស្រែចម្ការ ចាន ផ្ទាំង ទំរាំដីងចាញ់ដីងឈ្នះ៖

"ចិត្តល្អក្រខ្ជិន ចាំទុកជាក្បួន ជាក្បាលនិទាន ឃើញអ្នកទុរគត កម្សត់អត់ឃ្លាន មិនស្គាល់ពោះវៀន ហ៊ានឱ្យជើខ្ចី។ ទៅទារមិនឱ្យតឹងតឿនញាយៗ ខឹងប្តឹងកើតក្តី ខាតទាំងទ្រព្យចាស់ អស់ទាំងទ្រព្យថ្មី ស្តមគោក្របី រវល់ក្តីខានថែ។ ចិត្តល្អមួយ មេត្រីជាញាតិ សម្តីខ្ជីស្រែ បានស្រូវស៊ីស្តប់ ត្រឡប់កាច់កៃ រំលងឆ្នាំខែ ដកហូតមិនបាន។ ឯងប្តឹងវាត ក្តីទាល់តែក្រ អស់ឆ្នាំងអស់ចាន របស់ក៏ខាត របរក៏ខាន ដីងអស់ប៉ុន្មានទំរាំចាញ់ឈ្នះ។ ទ្រព្យធនអ្វីៗ ចងការជើខ្ចីមើលមុខឱ្យច្បាស់ កុំចោលច្បាប់ខ្មែរ កុំក្ងេចច្បាប់ព្រះ តាមតែប្រទះ ប្រទាញសងខាង"[៥]។

សុភាសិតនិងពាក្យទំនៀមពីបុពណដែលអ្នកប្រាជ្ញលោកបានទូន្មានជាបណ្តាំសម្រាប់កូនចៅជំនាន់ក្រោយ ឱ្យជៀសវាងវិវាទឬក្តីក្តាំនឹងគ្នានេះ ទំនងជាមានមូលហេតុមកពីវិវាទទាំងឡាយពុំអាចដោះស្រាយបានដោយការប្តឹងផ្តល់ទៅចៅក្រមឡើយ។ ពីព្រោះលោកយល់ថា ជាទូទៅ នៅក្នុងសង្គមខ្មែរចៅក្រម

[៥] អង្គការសន្តិស្ម័គ្រចិត្តកម្ពុជា៖ បណ្តាំក្រមង៉ុយ គ.ស. ២០០៥។

ទាំងឡាយពុំអាចផ្តល់យុត្តិធម៌ជូនដល់អ្នកផង ឡើយ។ សុភាសិតទាំងនេះស្តែងបញ្ជាក់អំពីការ បាត់បង់ជំនឿលើប្រព័ន្ធយុត្តិធម៌ខ្មែរស្ទើរតែ ទាំងស្រុងអស់ជាច្រើនសតវត្សកន្លងមកហើយ។ តែទោះជាយ៉ាងណាក៏ដោយនៅក្នុងសង្គម ទំនាស់គឺជារឿងដែលមិនអាចជៀសវាងបាន ឡើយ។ រីឯការប្តឹងផ្តល់គ្នាឡើងដល់ចៅក្រមក៏ តែងជាមធ្យោបាយ ដោះស្រាយទំនាស់នេះផង ដែរ ហេតុដូច្នេះហើយទើបមានបុរាណភាសិត មួយបានពោលទុកមកថា "ខ្ពើមអាចម៍ឡើងជិះ ដំរី ខ្ពើមក្តីឡើងចុងស្នោត" ហើយបើកើតក្តី មិន ត្រូវប្រទាំងតវ៉ានឹងពាក្យបង្គាប់បញ្ជារបស់ចៅ ក្រមឡើយ ព្រោះបុរាណលោកបានពោលថា"កុំ កាច់ឧសប្រកួតដំរី កើតក្តីកុំប្រកួតនឹងចៅក្រម"។ ពាក្យទំនៀមនេះ ឃុនឧត្តមប្រីជា ចាប ពិន បានពន្យល់ជាពាក្យកាព្យទុកដូច្នេះថា៖

"ពាក្យនេះអ្នកប្រាជ្ញពោលឃាត់ឃាំង មិនឱ្យមនុស្សយើងប្រព្រឹត្តឆ្នាំង ប្រណាំង វាសនានឹងដំរី។ ពីព្រោះដំរីជាសត្វកាច មានចិត្ត កំណាចខ្លួនឥតបី ក្នុងព្រៃណាមួយមានដំរី កុំបី កាច់ឧសប្រកួតវា ។ កាលបើប្រកួតដំរីកាច វា អាចនឹងព្រេចឱ្យមរណា ហេតុនេះបុរាណ លោកពោលថា កុំហ៊ានតវ៉ានឹងសត្វធំ។ ពាក្យ នេះអ្នកប្រាជ្ញលោកស្រដីថាដូចកូនក្តីជាដំណាំ ត្រូវកុំប្រកួតនឹងចៅក្រមគឺលោកអ្នកជំនាប្រជាន។ ក្នុងរឿងក្តីក្តាំរបស់ខ្លួន ត្រូវសួនចិត្តលោកកុំ ឈ្លានពាន តែមិនត្រូវខ្លាចត្រូវតែហ៊ានពោល រឿងខ្លួនមានឱ្យច្បាស់លាស់"។

ខ-ពាក្យទំនៀមទូន្មានអ្នកកាត់ក្តី៖ ក្រៅពី ទូន្មានប្រជាជនទូទៅឱ្យជៀសវាងទំនាស់ ឬការ បង្កជារឿងក្តីប្តឹងផ្តល់គ្នា ចាស់បុរាណក៏បាន ទូន្មានអស់អ្នកកាត់ក្តីទាំងឡាយឱ្យប្រកបដោយ សុចរិតនិងយុត្តិធម៌ ដោយបានពោលជា សុភាសិតទុកមកជាអាទិ៍ថា "ល្មោភតតខ្មាស វិនាសច្បាស់"។ ពាក្យទំនៀមនេះចង់ពោល សំដៅដល់ចៅក្រមទាំងឡាយដែលលោភលន់ ប្រាថ្នាប្រយោជន៍ ឬលាភសក្ការៈផ្ទាល់ខ្លួនពី រឿងក្តីដែលខ្លួនត្រូវជំនុំជម្រះ ដែលជាហេតុនាំឱ្យ ចៅក្រមនោះបំពានច្បាប់ ឬពុំយកច្បាប់មកអនុ វត្តដើម្បីផ្តល់យុត្តិធម៌ឡើយ។ ជួនកាលទៀត ចៅក្រមមានញាតិមិត្តសាច់សាលោហិតជាភាគី ទំនាស់ ដែលជាមូលហេតុនាំឱ្យចៅក្រមលម្អៀង ទៅរកគូក្តីនោះ ហើយក្នុងករណីនេះ ការជំនុំ ជម្រះក្តីក៏ត្រូវប្រាសចាកពីច្បាប់និងយុត្តិធម៌ផង ដែរ ដូចពាក្យទំនៀមមួយបានពោលទុកថា " យល់ញាតិ ឃ្លាតច្បាប់"។ ខ្លឹមសារនៃសុភាសិត នេះ ត្រូវបានបកស្រាយជាពាក្យកាព្យដោយ ឃុនឧត្តមប្រីជា ចាប ពិន ដែលមានសេចក្តីដូច តទៅ៖

"បុរាណភាសិតនេះ ថ្លៃថ្លាជាពាក្យត្រង់ៗ មិនប្រស្នាដែលយើងពាល់គ្នាក៏អាចឃើញពិត។ ធម្មតាពួកជនជាព្រៀងលានជាញាតិសន្តាន

ទាំងឆ្ងាយជិត កាលបើស្រឡាញ់គ្នាយ៉ាងស្និទ្ធ តែគិតយោគយល់មុខមាត់គ្នា។ បើកើតរឿងអ្វីនីមួយតែងជួយសង្គ្រោះឱ្យវឌ្ឍនា ទោះបីជាមានទោសធ្ងន់យ៉ាងណា ក៏កែកុនគ្នាឱ្យបានស្រាលៗ បើទោសស្រាលស្រាប់តែសម្រួល ឱ្យញាតិបានស្រួលយ៉ាងវិសាលដើម្បីឱ្យញាតិបានត្រកាលឈឺឆ្អាលឱ្យបានសុខសេរី។ ទោះបីច្បាប់ថាត្រូវមានទោសក៏ គង់សន្តោសប្រោសប្រណីសម្រាប់ច្បាប់នោះឱ្យស្រាល ដោយក្តីយល់មុខញាតិសន្តាន។ កាលបើដូច្នោះតែងឃ្លៀងឃ្លាតចាកច្បាប់ព្រោះញាតិនាំរំខាន ហេតុនេះអ្នកប្រាជ្ញពីបុរាណ ទូន្មានឱ្យយើងខំប្រយ័ត្ន"។

ដូច្នេះភាពមិនលម្អៀងនៃចៅក្រម គឺជាលក្ខខណ្ឌសម្រាប់ឱ្យបានយុត្តិធម៌ ពោលគឺយុត្តិធម៌ ពុំអាចស្តែងចេញជារូបរាងបានឡើយ ដរាបណាចៅក្រមនៅតែលម្អៀងនោះ។ នេះគឺជាករណីយកិច្ចរបស់អ្នកកាត់ក្តីទាំងឡាយ ដែលត្រូវប្រុងប្រយ័ត្នជាប់ជានិច្ច និងជៀសវាងឱ្យខាងតែបានទូវសេចក្តីលម្អៀង ដូចបុរាណភាសិតមួយបានពោលបណ្តាំទុកថា៖

"ហោរាប្រយ័ត្នមាត់រអិល ជាងទង់កាន់សីលប្រយ័ត្នទៀង ចៅក្រមប្រយ័ត្នមិនលម្អៀង អ្នកផ្លៀងប្រយ័ត្នបាត់អក្ខរ"។

រីឯអ្នកព្រះកិរម្យភាសា អ៊ូ ហៅ ង៉ុយ ក៏បានផ្តាំទុកសម្រាប់ចៅក្រមទាំងឡាយឱ្យប្រកាន់យកធម៌កណ្តាលជៀសវាងអគតិធម៌ទាំងឡាយកុំភ្លើតភ្លើនមើលឃើញតែមាសប្រាក់ឱ្យតាំងខ្លួនជាទឹកដែលត្រូវរំលត់ភ្លើងវិវាទនៃគូទំនាស់ ជាពិសេសគឺសម្របសម្រួលរវាងច្បាប់ចាស់ និងច្បាប់ថ្មីឱ្យសមស្របតាមការវិវត្តនៃសង្គមដូចមានសេចក្តីបញ្ជាក់ក្នុងច្បាប់ថ្មីជាពាក្យកាព្យខាងក្រោមនេះស្រាប់៖

"ចេះច្បាប់បារាំង កុំភ្លេចសច្ចំ កតញ្ញូខន្តី កុំឆ្មើងហួសមាឌ ភ្លេចញាតិប្រុសស្រី ជំនុំកាត់ក្តីយកឧបេក្ខា។ កុំកាន់សីហលោ កុំកាន់លោភោ ទោសោមោហោ កុំជក់អាភៀន កុំឃ្វានផឹកស្រា កុំស្អប់ខាងណាសច្ចាយកត្រង់។ លួងលោមពិសោធកុំធបញ្ឆោតបញ្ឆិលឱ្យបង់ឱ្យបែកឱ្យបាក់ពាក្យសត្យពាក្យសង្ឃ កូនអើយផ្ចិតផ្ចង់តម្រង់ស្មារតី។ កុំភ្លើនឃើញប្រាក់ កុំភ្លើនភ្ញាត់សក្តិ ជ្ងាក់ទៅអវិចី កាន់ធម៌ទសពិធ រឹតឡើងវាសីគាប់ពីលោកិយដល់បរលោកនាយ។ អ្នកក្តីជាភ្លើងកុំកាត់កាន់ជើង អ្នកម្ខាងមើលងាយ ចៅក្រមជាទឹក រំពុកលាយ កុំជេរកុំវាយ បង្ខំនាំខុស។ ចោរខូចលួចប្លន់ រីចោរស្មើគ្រស្នន់ តណ្ហាស្រីប្រុស កុំស្អប់ខាងណោះ បញ្ចោះខាងណោះ លួមលោមបញ្ចុះបញ្ចូលចិត្តក្តី។ កុំដុតឱ្យក្តៅ បើឃើញគ្នាខ្ចៅ ប្រាជ្ញាគ្នាខ្វី កុំឃ្វានប្រាក់ប្រុសបន្តុះខាងស្រី បើកាន់ច្បាប់ថ្មី កុំចោលច្បាប់ចាស់"។

ដោយសង្កេតឃើញថា ចៅក្រមទាំងឡាយពុំបដិបត្តិតាមករណីយកិច្ចរបស់ខ្លួនអយុត្តិធម៌ចេះតែរីករាលពាសពេញក្នុងសង្គម

ប្រជាជនខិតខំស្វែងយល់ពីមូលហេតុនាំឱ្យកើតមានអយុត្តិធម៌នោះ។ ក្នុងគោលបំណងស្វែងយល់អំពីមូលហេតុទាំងនេះ មានអ្នកប្រាជ្ញខ្មែរខ្លះបានបកស្រាយថានេះជាពុទ្ធទំនាយដែលបានទស្សន៍ទាយតាំងពីសម័យពុទ្ធកាលមកម្ល៉ះថា អំពើអយុត្តិធម៌នឹងកើតមានជៀសមិនរួចឡើយដរាបណាការរៀបចំនិងការគ្រប់គ្រងប្រទេសជាតិពុំប្រកបដោយធម៌បញ្ញត្តិ។

គ-ខ្លឹមសារនៃអគតិធម៌៖ តាមឫសនៃពាក្យ យុត្តិធម៌គឺជាសេចក្តីត្រឹមត្រូវទៀងត្រង់តាមធម៌ ឬច្បាប់។ ដើម្បីសម្រេចបាននូវសេចក្តីត្រឹមត្រូវតាមច្បាប់នេះប្រពៃណីយុត្តិធម៌ខ្មែរ ដែលផ្អែកលើមូលដ្ឋាននៃលទ្ធិពុទ្ធសាសនា បានចង្អុលមូលហេតុនៃដំណើរដែលមិនត្រឹមត្រូវ ឬមិនទៀងត្រង់តាមច្បាប់។ មូលហេតុនោះមានឈ្មោះថា "អគតិធម៌" ដែលសំដៅដល់សេចក្តីលម្អៀងទាំង៤ ប្រការគឺ ឆន្ទាគតិ លម្អៀងព្រោះស្រឡាញ់, ទោសាគតិ លម្អៀងព្រោះស្អប់ ឬក្រោធ ភយាគតិ លម្អៀងព្រោះភ័យ ឬខ្លាច និងមោហាគតិ លម្អៀងព្រោះវង្វេង ឬល្ងង់[1]។

៣.២-គោលការណ៍យុត្តិធម៌

ក-ច្បាប់ហេតុផល៖"ច្បាប់ហេតុផល" គឺជាសំណុំវិធានដែលមានគោលបំណងកំណត់ផលរបស់ហេតុ ឬ កំណត់ផលដែលត្រូវនឹងហេតុ ឬកំណត់ចំណងដែលចងភ្ជាប់ហេតុទៅនឹងផលដែលអាចហៅថា "ចំណងហេតុនិងផល" ឬ ចំណងហេតុផល"។ ច្បាប់នេះមានគោលដៅស្វែងរកផលដែលសមចំពោះហេតុស្របតាមសុភាសិតបុរាណបានពោលថា "ទំពក់វាទៅ ទើបញ្ឆៅវាជ្រុះ" "មានប្រឡាយ ទើបទឹកវាហូរ" "មានសំរាម ទើបឆ្កែវាជុះ" "មានភ្លើងទើបមានផ្សែង" ជាដើម។ ដោយអនុលោមតាមច្បាប់ហេតុផលនេះ គោលការណ៍ច្បាប់មួយចំនួនបានបង្កើតឡើងនិងបង្កប់នៅក្នុងសេចក្តីវិនិច្ឆ័យរបស់អ្នកកាត់ក្តីទាំងឡាយ។

ខ-ច្បាប់ពិត៖ ច្បាប់ពិតសំដៅដល់ច្បាប់ឬវិធានទាំងឡាយណាដែលកើតចេញពីការសង្កេតលើដំណើរប្រព្រឹត្តិទៅនៃធម្មជាតិ ពោលគឺជាច្បាប់ធម្មជាតិដែលកើតមានឡើងជាក់ស្តែងទៀងទាត់ និងប្រាកដប្រជាពុំអាចប្រកែកបាន។ ច្បាប់នេះកើតចេញពីព្រឹត្តិការណ៍ធម្មជាតិដែលមនុស្សលោកសង្កេតឃើញនិងស្រង់យកទុកជាវិធានដឹកនាំ និងគ្រប់គ្រងសង្គមពីព្រោះជាច្បាប់ដែលមានលក្ខណៈពិតប្រាកដដោយឯកឯង តាមលក្ខណធម្មជាតិ។ សិល្បៈនៃការកាត់ក្តីក្នុងរឿងព្រេងខ្មែរ បានបំភ្លឺបន្ថែមចំពោះនិយមន័យនេះ ដោយបានលើកឡើងនូវច្បាប់ពិតឬច្បាប់ធម្មជាតិមួយចំនួនទុកជា

[1] ហ៊ែល ចំរើន ៖ ***មរតកយុត្តិធម៌ខ្មែរ*** ភ្នំពេញ ឆ្នាំ២០០៩-២០១០

ឧទាហរណ៍ ដែលក្នុងនោះមានសេចក្តីសង្កេតលើសភាពធម្មជាតិជាអាទិ៍ថា៖

-"ដេកនៅលើរន្ធពស់រមែងត្រូវពស់ចឹកមិនខាន"

-"ត្រីឯណាទៅជាប់ជុចលើចុងឈើកើត"

-"កម្ទាំងប្រាជ្ញាតែងមានជ័យជម្នះ លើកម្ទាំងកាយជានិច្ច"

-"ដើម្បីអាចដេកកណ្តាលគ្រប់គ្នា គឺត្រូវដេកយកក្បាលឈមជុំចូលគ្នា"

-"ម្តាយពិតអាណិតកូន ទុកឱ្យម្តាយក្មែងជណ្តើមកូនឥតអាសូរយកតែឈ្នះដៃ"។

គ-ច្បាប់គោរពពាក្យសន្យា៖ សំដៅដល់ច្បាប់ ឬសំណុំវិធានទាំងឡាយណា ដែលតម្រូវឱ្យបុគ្គលម្នាក់ៗប្រកាន់ខ្ជាប់នូវពាក្យសន្យារបស់ខ្លួនចំពោះអ្នកដទៃ ព្រមទាំងចាប់បង្ខំអ្នកសន្យាឱ្យទទួលខុសត្រូវចំពោះការបំពានពាក្យសន្យារបស់ខ្លួន។ វិធាននេះទំនងជាមានប្រភពចេញពីក្រមសីលធម៌របស់បុគ្គលម្នាក់ៗ ដែលត្រូវប្រកាន់យកនូវពាក្យសត្យ ឬពាក្យពិត រក្សាសេចក្តីទៀងត្រង់ជាប់ជានិច្ចទាំងផ្នែកពាក្យសម្តី ទាំងផ្នែកអំពើប្រព្រឹត្តរបស់ខ្លួន ក្រមសីលធម៌នេះត្រូវបានចាស់បុពណលើកយកមកប្រៀនប្រដៅជនជំនាន់ក្រោយ ដោយចារឹកទុកជាសុភាសិតមួយចំនួនដែលខ្មែរយើងនៅចងចាំ និងនិយាយរត់មាត់ដល់សព្វថ្ងៃ។ សុភាសិតមួយបានពោលថា "មនុស្សយកសម្តី ដំរីយកក្ងុក"៖ សុភាសិតនេះធ្វើការប្រៀបធៀបតម្លៃនៃការប្រកាន់ពាក្យសម្តីរបស់មនុស្សម្នាក់ៗ ទៅនឹងក្ងុកដំរីដែលខ្មែរយើងមានទំនៀមទុកដូចជាវត្ថុដ៏មានតម្លៃខ្ទាំងណាស់ក្នុងចំណោមអវយវៈមួយគួខ្លួនដំរី ទាំងមូល។ ការគោរពពាក្យសន្យា ឬការប្រកាន់ពាក្យសម្តីមិនត្រឹម តែជាតម្លៃសីលធម៌នៅក្នុងសង្គមប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាបុព្វហេតុដែលអាចនាំមកនូវសេចក្តីសុខឬសេចក្តីទុក្ខ អាស្រ័យលើលក្ខណៈល្អ ឬអាក្រក់នៃពាក្យសម្តីនោះ ទៀតផងដូចសុភាសិតមួយបានពោលថា "អណ្តាតជាអាទិ៍កន្ទង បានសុខទុក្ខផងពីព្រោះអណ្តាត"។ ដូច្នេះអណ្តាតដែលតំណាងឱ្យពាក្យសម្តីឬពាក្យសន្យានោះ គឺជាដើមហេតុដំបូងបង្ហស់ដែលអាចញ៉ាំងទាំងសេចក្តីសុខ ទាំងសេចក្តីទុក្ខដល់អ្នកពោលពាក្យសម្តីនោះ។ ស្ថិតក្នុងន័យនេះ ពាក្យសម្តីឬពាក្យសន្យារបស់មនុស្សម្នាក់ៗ តម្រូវជាចាំបាច់ឱ្យអ្នកស្រដីនោះទទួលខុសត្រូវទាំងស្រុងចំពោះខ្លឹមសារនៃពាក្យសន្យា សម្តីនោះ ដូចមានសុភាសិតជាច្រើនបានពោលទុកមកថា"រនាបបាក់យករនាបជួស សម្តីហួសមានតែបង់ប្រាក់" ឬ "ជំពប់ដើងគង់បាក់ជំពប់មាត់បង់ប្រាក់"។ ការទទួលខុសត្រូវចំពោះពាក្យសម្តី ឬពាក្យសន្យារបស់បុគ្គលម្នាក់ៗអាចមានទម្ងន់រហូតដល់ធ្វើឱ្យមានម្ចាស់សម្តី ឬម្ចាស់សន្យានោះបាត់បង់ជីវិតបានទៀតផង បើយោងតាមខ្លឹមសារនៃសុភាសិតមួយចំនួន៖ "កំភ្លាញ

ស្ងាប់ព្រោះមាត់" ឬ "ងាប់នឹងសម្តីដូចត្រីកំភ្លាញ" ពីព្រោះបុរាណលោកបានសន្មតថាសម្តីដែលពោលហួសទៅពុំអាចវិលត្រឡប់ក្រោយបានឡើយ "បន្ទាមុតយកបន្ទាជោះសម្តីហួសជួសមិនបានឡើយ" ឬ "រនាបបាក់យករនាបជួស សម្តីហួសគ្មានអ្វីជួសបានឡើយ"។ ក្នុងន័យនេះ ច្បាប់បណ្តាំបិតាបានទូន្មានទុកមកថា "ទូកហួសកំពង់ រាចែវបង្ហិង ថយមកចូលចាប់ ពាក្យលឿនហួសខ្នាត ហៅឥតគំនាប់ ថយមករកគាប់ពុំបានឡើយណា"។ ផ្តើមចេញពីតម្លៃជាសីលធម៌ដែលឆ្លុះបង្ហាញតាមរយៈពាក្យទំនៀមដែលបានពោលទុកជាសុភាសិតទាំងនេះយើងសង្កេតឃើញថា ការវិនិច្ឆ័យក្តីរឿងព្រេងខ្មែរ ក៏ពុំឃ្លាតអំពីគោលការណ៍គោរពពាក្យសម្តី ឬពាក្យសម្តីសន្យានេះដែរ។ ជាក់ស្តែងដូចជានៅក្នុងរឿងឈ្លួញម្នាក់មានដើមទុនតែ១ហួង សម្តេចព្រះវររាជមាតា ក្នុងឋានៈជាអ្នកកាត់ក្តីបានសម្រេចយក "ទ្រព្យសម្ងាញ់ពេញចិត្ត" តាមការសន្យារបស់ឈ្លួញចំពោះអ្នកចម្ងឹមមកធ្វើជាមូលដ្ឋាននៃការបែងចែករវាងគូវិវាទទាំងពីរ ដោយអនុលោមតាមការសន្យាផង និងគោលការណ៍បែងចែកទ្រព្យតាមទំហំគុណកម្មផង។

ឃ-ច្បាប់បដិការៈ គឺជាច្បាប់ ឬវិធានទាំងឡាយណាដែលតម្រូវឱ្យតបស្នងសងវត្ថុឬអំពើអ្វីមួយទៅឱ្យម្ចាស់វត្ថុ ឬអំពើនោះវិញ មានន័យថាបើជនណាម្នាក់ប្រព្រឹត្តអំពើអ្វីមួយ ជាទោសជននោះនឹងទទួលបានតបស្នងសងទោសនោះវិញ។ តែបើជនណាប្រព្រឹត្តអំពើជាគុណ ជននោះនឹងទទួលបានទូវការតបស្នងសងគុណវិញ។ ជាឧទាហរណ៍ក្នុងរឿង*ដីដសង*ដីដ*អំបែងសងអំបែង* ព្រះមហាក្សត្របានយកច្បាប់បដិការនេះមកអនុវត្តចំពោះវិវាទ ដែលកើតមានឡើងរវាងសេដ្ឋី និង បុរសប្តីប្រពន្ធកំសត់។ នៅពេលដែលបុរសកំសត់ធ្វើឱ្យបាត់ដីងរបស់សេដ្ឋីៗបានតម្រូវឱ្យបុរសកំសត់ យកកូនប្រុសរបស់ខ្លួនមកធ្វើជាខ្ញុំបម្រើសេដ្ឋី លុះដល់ពេលសេដ្ឋីធ្វើឱ្យបែក អំបែងក្អមបុរសកំសត់វិញ ព្រះមហាក្សត្រក៏បានកាត់ក្តីសម្រេចឱ្យសេដ្ឋីយកកូនស្រីរបស់ខ្លួនទៅធ្វើជាខ្ញុំបម្រើបុរសកំសត់នោះវិញដែរ ដោយព្រះអង្គឈ្វេងយល់ថាធ្វើបែបនេះទើបត្រឹមត្រូវតាមដោយគន្ធង់ធម៌។ គន្ធង់ធម៌នេះគឺព្រះអង្គទ្រង់ពោលសំដៅដល់ "ច្បាប់បដិការ" នេះឯង។

ង-ច្បាប់សមធម៌ៈ គឺជាវិធានដែលពិបាកនឹងកំណត់និយមន័យឱ្យបានច្បាស់ដណាស់ ពីព្រោះជាវិធានដែលប្រែប្រួលទៅតាមហេតុ ទៅតាមកាល:ទេស: តែមានលក្ខណៈសម្គាល់រួមមួយគឺជាមាគ៌ាកណ្តាលផ្លូវកណ្តាលឬជាវិធានកណ្តាល ដែលបានមកពីការថ្វឹងថ្លែងឱ្យបានស្មើភាព ដោយប្រៀបធៀបទៅនឹងលក្ខណៈជ្រុលនិយម។ សមធម៌អាចមានន័យថាសេចក្តី

ត្រឹមត្រូវតាមធម៌ តាមច្បាប់ ឬវិធានដែលចែងអំពីសេចក្តីស្មើ ដំណើរស្មើឬផ្លូវកណ្តាល។ សមធម៌ គឺជាវិធានទាំងឡាយណាដែលគ្រប់គ្រងនិងដោះស្រាយទំនាក់ទំនងសង្គមដោយធម៌ស្មើប្រាសចាកសេចក្តីលម្អៀង ដោយហេតុអគតិទាំងបួនប្រការ ពោលគឺជាវិធានដែលកំណត់យកផ្លូវកណ្តាលមួយដែលមិនស្រាលពេក មិនធ្ងន់ពេក មិនខ្សោយពេក មិនខ្លាំងពេក មិនខ្ពស់ពេក មិនទាបពេកជាដើម។

នៅក្នុង "រឿងបុរសកំសត់ខ្មមក្បែរផ្ទះសេដ្ឋីធ្វើត្រាប់សេដ្ឋី" ព្រោះតែមានចិត្តប្រកបដោយកតញ្ញូកតវេទិតាធម៌ បុរសកំសត់ដែលធ្វើត្រាប់អំពើប្រកបរបរចិញ្ចឹមជីវិតរបស់សេដ្ឋីរហូតមានទ្រព្យសម្បត្តិច្រើនសន្ធឹកសន្ធាប់បានយកមាសមួយស្នក់មកជូនសេដ្ឋីទុកជាដង្វាយគុណ។ សេដ្ឋីចិត្តលោភបានទាមទារឱ្យបុរសកំសត់យកទ្រព្យទាំងអស់មកចែកគ្នា។ បុរសកម្សត់ពុំសុខចិត្តក៏បានប្តឹងផ្តល់គ្នារហូតដល់ព្រះមហាក្សត្រ។ ព្រះមហាក្សត្រពុំបានជំនុំជម្រះសេចក្តីឱ្យភាគីណាមួយឈ្នះឬចាញ់ឡើយ តែបែរជាគ្រាស់បង្អាប់ឱ្យសេដ្ឋី និងបុរសកំសត់ចងសម្ព័ន្ធមេត្រីនឹងគ្នា ដោយប្រទានមង្គលការដល់កូនប្រុសសេដ្ឋី និងកូនស្រីបុរសកំសត់ឱ្យបានគ្នាជាប្តីប្រពន្ធតទៅដើម្បីបញ្ចប់វិវាទដណ្តើមទ្រព្យនេះ។ ការវិនិច្ឆ័យនេះផ្អែកលើគោលការណ៍មួយដែលអាចកំណត់បានថា "មូលទ្រព្យដ្បិតចងពន្ធ" ហើយនេះជាគោលការណ៍ដែលអាចចាត់ទុកថាជា សមធម៌ ដោយហេតុថាការកាត់ក្តីនេះពុំបានភាពចាញ់-ឈ្នះ ដល់គូវិវាទណាមួយឡើយ។ ភាគីទំនាស់ទាំងសងខាងអាចចាត់ទុកថាស្មើគ្នា មិនឈ្នះមិនចាញ់ ព្រោះតែការកាត់ក្តីរបស់ព្រះមហាក្សត្របានអនុវត្តតាមវិធានសមធម៌មួយគឺ "មួយទ្រព្យដ្បិតចងពន្ធ"។

ឆ្ងងតាមរយៈការកាត់នៅក្នុងរឿងព្រេងផ្សេងទៀត សមធម៌ធ្លាប់បានធ្វើជាមូលដ្ឋាននៃការជម្រះសេចក្តីផ្តល់យុត្តិធម៌ជាច្រើនលើកផងដែរ។ ក្នុងន័យនេះ "ការសង្គ្រោះអ្នកទន់ខ្សោយឱ្យរួចផុតពីការបៀតបៀននៃជនមានអំណាច"។ គឺជាវិធានសមធម៌ដែលជានាភាពស្មើគ្នាក្នុងការរស់នៅ ដោយមិនត្រូវឱ្យអ្នកទន់ខ្សោយទទួលរងការប្រមាថពីអ្នកកាចសាហាវយង់ឃ្នងឡើយ។ ដូចគ្នាដែរ "បង្ក្រាបជនអកតញ្ញូ និងសង្គ្រោះអ្នកធ្វើគុណ" អាចចាត់ទុកថាជាសមធម៌ពីព្រោះអំពើជាគុណកម្មសមតែទទួលបានទូវកុសលកម្ម មិនគួរណាទទួលបានទូវការបៀតបៀនពីជនរមិលគុណឡើយ។ ម៉្យាងទៀត "កម្ចាត់បង់នូវអំពើពុករលួយគ្រប់ជាន់ថ្នាក់" គឺជាសមធម៌ដែលមានគោលបំណងសង្គ្រោះជនស្លូតត្រង់ដែលទទួលរងអំពើអយុត្តិធម៌ និងការធ្វើទុក្ខបុកម្នេញពីជនពុករលួយ។

ច-ច្បាប់ទំនៀម៖ គឺជាវិធានទាំងឡាយដែលកើតចេញពីទម្លាប់ជាប់ជាទំនៀមប្រពៃណី

របស់អ្នកស្រុកដ៏យូរលង់ណាស់មកហើយ។ ច្បាប់ទំនៀមនេះមានជាអាទិ៍គឺ"ក្រមុំដណ្តឹងម្តាយមេម៉ាយដណ្តឹងចិត្ត"។ ដើម្បីស្វែងយល់អំពីខ្លឹមសារនៃពាក្យទំនៀមនេះ យើងសូម លើកយកសេចក្តីពន្យល់ជាពាក្យរបស់ឃុនឧត្តម ប្រីជា ចាប ពិន មកបង្ហាញដូចតទៅ[1]៖

"ពាក្យនេះលោកពោលតាមធម្មតានៃស្ត្រី ដែលនៅជាកញ្ញា គឺជាក្រមុំព្រហ្មចារី។ អ្នកណាចង់បានជាភរិយា ត្រូវតែនាំគ្នាចូលទៅស្តីដល់ម្តាយឪពុកទើបគប្បីតាមផ្លូវលោកិយពីព្រេងនាយ។ ព្រោះស្រីក្រមុំតូចទ្រលុកនៅក្នុងបន្ទុកឪពុកម្តាយមិនអាចសម្រេចលើរូបកាយចាត់ចាយខ្លួនឯងពុំទាន់បាន។ បើដល់ទៅចាស់ជាមេម៉ាយ ទើបអាចចំណាយរៀបខ្លួនប្រាណតាមខ្លួនពេញចិត្តល្មមប្រមាណ។ ព្រោះគេធ្លាប់រៀបការមុនម្តង។ អ្នកដែលដណ្តឹងត្រូវសួរចិត្តបញ្ជាក់ឱ្យពិតតាមទំនង កុំបីរំលោភហួសរំលងបើគេស្ម័គ្រផងសឹមយកចុះ។"

នៅក្នុង "រឿងស្រី២នាក់ឈ្មោះដណ្តើមធ្មេញឈើ" ព្រះមហាក្សត្របានវិនិច្ឆ័យសេចក្តីដោយអនុវត្តច្បាប់ទំនៀមដែលបានសន្មតថាកូនបុរាណត្រូវបានទ្រព្យ២ភាគ ចំណែកឯកូនបច្ចុប្បន្នបានទ្រព្យតែមួយភាគប៉ុណ្ណោះ។ ក្នុងន័យនេះ "កូនបុរាណ" សំដៅជនទាំងឡាយដែលបានបិទមាត់ត្រឡប់ក្អែកឱ្យមនុស្សដែលស្ថាប់លើភ្លៅរបស់ខ្លួន។ នេះបង្ហាញឱ្យឃើញថាតាមទំនៀមទម្លាប់កូនចៅទាំងឡាយត្រូវស្តិតនៅជិតជាប់ជុំវិញឪពុកម្តាយ ដែលឈឺរៀបនឹងស្ថាប់ដើម្បីមើលថែទាំជំងឺតម្កាត់របស់លោករហូតដល់ផុតជន្ម មិនត្រូវដើរចោល ឬចាកឆ្ងាយពីលោកអ្នកមានគុណឡើយ។

[1] ហ៊ែល ចំរើន៖ ***មរតកយុត្តិធម៌ខ្មែរ*** ដ.ឯ.ម.។

ឯកសារពិគ្រោះ

1. ជួន ណាត ៖ **វចនានុក្រមខ្មែរ** ភ្នំពេញ ការផ្សាយរបស់វិទ្យាស្ថានពុទ្ធសាសនាបណ្ឌិត្យឆ្នាំ១៩៦៧
2. ត្រឹង ង៉ា ៖ អរិយធម៌ខ្មែរ ការផ្សាយរបស់អ្នកនិពន្ធ គ.ស. ១៩៧៥
3. ញ៉ សារឿន ៖ ប្រវត្តិស្ថាប័នខ្មែរ បោះពុម្ពលើទី១ ឆ្នាំ២០១៥
4. មីសែល ត្រាណោ ៖ មូលដ្ឋានគ្រឹះអរិយធម៌ខ្មែរ ភាគ១ គ.ស. ២០១៣
5. សាកលវិទ្យាល័យភ្នំពេញអន្តរជាតិ ៖ រដ្ឋបាលសាធារណៈ ឆ្នាំសិក្សា២០១៦-២០១៧
6. សាយ បូរី ៖ នីតិរដ្ឋបាលទូទៅ បោះពុម្ពលើកទី៣ ភ្នំពេញ ២០០២
7. ហែម ឡាច ៖ ស្ថាប័ននយោបាលកម្ពុជាបច្ចុប្បន្ន៖ សាលាភូមិន្ទរដ្ឋបាល ឆ្នាំ២០១៩
8. ហ៊ែល ចំរើន ៖ មរតកយុត្តិធម៌ខ្មែរ ភ្នំពេញ ឆ្នាំ២០០៩-២០១០
9. អង្គការសន្តិស្ម័គ្រចិត្តកម្ពុជា៖ បណ្តាំក្រមង៉ុយ គ.ស.២០០៥

ស្វែងយល់អំពីសុជីវធម៌ និង ទំនៀមទម្លាប់ខ្មែរ

ដោយៈ លោកស្រីបណ្ឌិត **ជា ឥណ្ណី**
ប្រធាននាយកដ្ឋានធម្មសាស្ត្រ ចរិយាសាស្ត្រ និង យេនឌ័រ,
វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម,ពជបណ្ឌិត្យសភាកម្ពុជា

ការរស់នៅរបស់មនុស្សក្នុងសង្គមនីមួយៗសុទ្ធតែចង់បានការរស់នៅប្រកបដោយសិទ្ធិសេរីភាព សុភមង្គល និងសេចក្តីថ្លៃថ្នូរ។ ដើម្បីសម្រេចបំណងនេះ បុគ្គលគ្រប់រូបត្រូវប្រព្រឹត្តិតាមច្បាប់ ប្រពៃណី ទំនៀមទម្លាប់សុជីវធម៌របស់សង្គមឱ្យបានត្រឹមត្រូវព្រមទាំងចេះទទួលស្គាល់ចំណុចល្អ និងចំណុចអាក្រក់របស់ខ្លួនដែលបានប្រព្រឹត្តកន្លងមក ហើយត្រូវព្យាយាមស្វែងយល់ និងកែលម្អនូវគ្រប់ចំណុចខ្វះខាតទាំងនោះ ដើម្បីឱ្យខ្លួនក្លាយជាបុគ្គលមានតម្លៃ មានសេចក្តីថ្លៃថ្នូរសម្រាប់ខ្លួនឯង គ្រួសារនិងសង្គមជាតិ។ មនុស្សម្នាក់ៗត្រូវតែចេះរស់នៅជាមួយអ្នកដទៃ រស់នៅជាមួយសង្គមមនុស្សដែលមានទំនាក់ទំនងគ្នាទៅវិញទៅមក។ ទំនាក់ទំនងរវាងមនុស្សនិងមនុស្សនិងការរស់នៅក្នុងសង្គមតែងនាំមកនូវភាពសុខដុមរមនា គ្មានការប៉ះទង្គិច គ្មានការសៅហ្មងដោយសារការយល់ដឹង និងការប្រកាន់ខ្ជាប់នូវសុជីវធម៌។

តើអ្វីទៅជាសុជីវធម៌?[1]

សុជីវធម៌សម្គាល់ការរស់នៅល្អ មានរបៀបរៀបរយ ចេះគួរសមក្នុងការប្រាស្រ័យទាក់ទងជាមួយអ្នកដទៃ។ សុជីវធម៌ពុំមែនជាបទបញ្ជាឬជាច្បាប់ទេប៉ុន្តែជាវិជ្ជាមួយសម្រាប់ឱ្យមនុស្សរៀនធ្វើខ្លួនឱ្យបានសមរម្យទៅតាមទំនៀមទម្លាប់ សុជីវធម៌សង្គម ជៀសវាងការប៉ះទង្គិចអារម្មណ៍រវាងមនុស្សដែលរស់នៅជាមួយគ្នា។ សុជីវធម៌ជាសោភ័ណ និងវិធីសម្រាប់អប់រំមនុស្សឱ្យមានឫកពាថ្លៃថ្នូរ មានភាពស្លូតបូត មានសេចក្តីសុចរិត ស្មោះត្រង់ មានសណ្តាប់ធ្នាប់ ចេះរៀបចំរបៀបរស់នៅឱ្យបានសមរម្យ និងមានតម្លៃនៅក្នុងសង្គម។ លក្ខណៈសម្បត្តិនៃសុជីវធម៌នេះហើយ ដែលបង្កើតឱ្យមានទំនាក់ទំនងរវាងមនុស្សនឹង

[1] *ក្រសួងអប់រំ យុវជន និងកីឡា រៀវភៅសិក្សាសង្គមថ្នាក់ទី១០ ឆ្នាំ២០១៧ ទំព័រទី២១៦។*

មនុស្សហើយឱ្យមានការអភិវឌ្ឍទៅមុខ។ សុជីវធម៌នៅក្នុងសង្គមនេះហើយ ដែលដឹកនាំសង្គមមនុស្សឱ្យចេះអប់រំគ្នាជារៀងរាល់ថ្ងៃ ដើម្បីសេចក្តីសុខ និងការអភិវឌ្ឍ។

ហេតុអ្វីយើងត្រូវសិក្សាអប់រំពីសុជីវធម៌?

សុជីវធម៌ជាវិជ្ជាមួយសម្រាប់អប់រំមនុស្សគ្រប់រូប ទាំងបុរសទាំងស្ត្រីឱ្យមានឫកពាអាកប្បកិរិយាថ្លៃថ្នូរ មិនធ្លាក់ឆ្គងនឹងទង្វើរបស់ខ្លួន។ វិជ្ជានេះធ្វើឱ្យមនុស្សមាន អត្តចរិតស្លូតបូត សុភាពរាបសា សមរម្យ មានភាពថ្លៃថ្នូរ មានទំនាក់ទំនងល្អ និងចេះរស់នៅចុះសម្រុងជាមួយអ្នកដទៃនៅក្នុងសង្គម។ សុជីវធម៌បានប្រៀនប្រដៅមនុស្សអំពីលក្ខណៈល្អគ្រប់បែបយ៉ាង ដែលមនុស្សត្រូវប្រកាន់ខ្ជាប់ និងជៀសវាងអំពើឆ្គងចំពោះខ្លួនឯង មិត្តភក្តិគ្រួសារ សហគមន៍និងសង្គម។ ម្យ៉ាងទៀត សុជីវធម៌អប់រំមនុស្សឱ្យប្រកាន់សេចក្តីសុចរិត សេចក្តីស្មោះត្រង់ សេចក្តីសូប់ សេចក្តីសន្តោសមានចរិយាល្អ។

សុជីវធម៌គ្របដណ្តប់ទៅលើជីវភាពមនុស្សទូទៅដែលរស់នៅក្នុងសង្គម។ សុជីវធម៌អប់រំមនុស្សឱ្យស្គាល់ករណីកិច្ច ដែលត្រូវប្រព្រឹត្តចំពោះខ្លួនឯង និងចំពោះអ្នកដទៃ។ សុជីវធម៌តម្រូវឱ្យមនុស្សគ្រប់រូប ត្រូវមានអាកប្បកិរិយាសមរម្យជាទីគាប់ចិត្តចំពោះគ្នាគ្រប់ពេលវេលា គ្រប់ទីកន្លែង ដូចជា នៅក្នុងគ្រួសារ នៅសាលារៀន កន្លែងធ្វើការ វត្តអារាម និងកន្លែងទីសាធារណៈជាដើម។ សុជីវធម៌តម្រូវឱ្យមនុស្សម្នាក់ៗចេះរៀបចំខ្លួនកុំឱ្យធ្លាក់ឆ្គងក្នុងឥរិយាបទណាមួយដូចជា ការទទួលទាន ការនិយាយ ការដេក ការដើរ ការឈរ ការអង្គុយ ។ល។ គឺត្រូវចេះរៀបចំឫកពាឱ្យសមរម្យតាមទីសាធារណៈនិងកាលៈទេសៈ រៀបចំកាយវិការក្នុងការសន្ទនាជាមួយអ្នកដទៃ ឬក្នុងពេលទទួលទានអាហារ ក៏ដូចជាការប្រើសម្លៀកបំពាក់សមរម្យទៅតាមពេលវេលា ជាពិសេសរបៀបនិយាយនិងសរសេរឱ្យបានត្រឹមត្រូវតាមក្បួនខ្នាត និងទទួលភ្ញៀវដោយពាក់ទាក់ និងគោរពសិទ្ធិ ទ្រព្យសម្បត្តិ សេចក្តីទុក្ខសោករបស់អ្នកដទៃ។

សុជីវធម៌ចំពោះខ្លួនឯង៖ គឺត្រូវគោរពបទបញ្ជា ក្បួនអនាម័យនិងស្មៀកពាក់ឱ្យមានសមរម្យ និងតាមកាលៈទេសៈ ដើម្បីអាការខាងក្រៅមានសោភ័ណភាព និងការឱ្យតម្លៃដល់ខ្លួនឯង។ មនុស្សថ្លៃថ្នូរជាបឋម គឺការថែរក្សាខ្លួនឱ្យមានភាពល្អស្អាត ការលាងសម្អាតនិងថែរក្សាខ្លួនប្រាណឱ្យបានស្អាតឱ្យបានទៀងទាត់។

សុជីវធម៌សាធារណៈ៖ គឺត្រូវប្រកាន់ខ្ជាប់សុជីវធម៌ ទម្លាប់ល្អ មិនមែនចង់ធ្វើអ្វីមួយតាមតែចិត្តនឹកឃើញឡើយ ព្រោះទីសាធារណៈជាកន្លែងដែលមានទំនាក់ទំនងចំពោះមនុស្ស។

១. សុជីវធម៌នៃការទទួលទានអាហារ

ទម្លាប់ក្នុងការរស់របស់មនុស្សម្នាក់ៗនៅមិនដូចគ្នាឡើយ ដោយហេតុថា ក្នុងគ្រួសារនីមួយៗមានការអប់រំ ក៏ដូចជា ស្ថានភាពរស់នៅផ្សេងៗគ្នា។ យ៉ាងណាមិញ ការទទួលទានអាហារ មិនមែនគ្រាន់តែជាសកម្មភាពដើម្បីតម្រូវការក្រពះប៉ុណ្ណោះទេ តែទំនៀមទម្លាប់ខ្មែរបានចាត់ទុកការទទួលទានអាហារជាសុជីវធម៌ក្នុងការរស់នៅមួយ សូម្បីតែការអង្គុយទទួលទាន ក៏ដូចជារបៀបនៃការដួសអាហារដាក់ក្នុងមាត់ ក៏មានត្រូវតែមានរបៀបរបបៗទម្លាប់នៃការទទួលទានអាហារកន្ទងមកមានមតិពីរប្រពាំងគ្នា ដោយអ្នកខ្លះថា ការទម្លាប់ទទួលទានអាហារឱ្យអស់ពីចាន ជាពិសេសអ្នកដែលទទួលទាននៅតាមហាង គឺមើលទៅមិនសមរម្យ ហាក់ដូចជាមិនធ្លាប់បានទទួលទានអាហារអ្វីពីមុនមក។ ចំណែកឯអ្នកខ្លះទៀត គឺគេតែងតែទទួលទានអាហារអស់ពីចានស្ទើរតែមិនមានសេសសល់សោះឡើយ ដោយគេបានយល់ឃើញថា អាហារទាំងនោះយើងរកមកដោយពិបាក ហើយវាចេញពីកម្លាំងញើសឈាមរបស់ប្រជាកសិករដែលខិតខំធ្វើការ ដើម្បីផលិតជាស្រូវ ជាអង្ករ ជាអាហារ ដូច្នេះមិនត្រូវខ្ជះខ្ជាយឡើយ ព្រោះមានមនុស្សច្រើនណាស់ក្នុងពិភពលោកដែលត្រូវស្លាប់ដោយសារអត់អាហារ។

ពាក់ព័ន្ធនឹងសុជីវធម៌ក្នុងការទទួលទានអាហារនេះ តាមសៀវភៅ *ទំនៀមទម្លាប់និងប្រពៃណីខ្មែរ* របស់ឧកញ៉ាមហាមន្ត្រី **ញឹក នូវ** គឺមាន២៤ចំណុច ដែលលោកអ្នកគួរតែយល់ដឹងនិងយកមកអនុវត្ត[៦]

១-ដៃដែលកាន់ស្លាបព្រាត្រូវកាន់ផ្ងារបាតដៃទំនងដូចកាន់ដងប៉ាកកា មិនផ្តាប់ ឬក្តាប់ដៃទេ។

២-កិរិយាដួសចាប់ម្ហូបមកដាក់ក្នុងមាត់ កុំដួសឱ្យទាល់តែពេញស្លាបព្រា ឬហូរហៀរស្រក់សស្រាក់ប្រឡាក់កម្រាលតុ។

៣-មុនដាក់ម្ហូបចំណីក្នុងមាត់ កុំហាមាត់ធំពេកទេ កុំលៀនអណ្តាតទទួលអាហារ កុំងើបក្បាលហើយបានហាមាត់ទទួលអាហារពោលគឺកុំឱនពេក កុំងើយពេក រីឯធ្មេញទៀតសោតក៏មិនត្រូវឱ្យប៉ះនឹងស្លាបព្រាឱ្យឮសូរដែរ។

៤-អាហារគឺបាយនិងម្ហូបដែលពាប់ថាមួយម៉ាត់នោះ ពុំមែនញាត់ឱ្យទាល់តែពេញមាត់ប៉ោងថ្ពាល់ទាំងសងខាងនោះឡើយ។

៥-បើមិនទាន់ទំពាលេបអស់មួយម៉ាត់ទេ គឺមិនត្រូវដាក់អាហារថែមទៀតឡើយ។

[៦] *ញឹក នូវ ទំនៀមទម្លាប់និងប្រពៃណីខ្មែរ*។

៦-ដៃទាំងពីរដែលលើកដាក់ចុះឡើង គួរបង្រួមកែងដៃឱ្យនៅតាមទំហំខ្លួនកុំឱ្យច្រវែងច្រវាងកួយដៃទើសនឹងដៃអ្នកអង្គុយជិត។

៧-អាហារដល់មាត់ហើយ គេមិនស្រូបអាហារឱ្យឮគ្រូក។ ឬមិនត្រូវទំពាឱ្យឮនោះទេ។

៨-បាយដែលចូកនឹងស្លាបព្រា គេចូកឱ្យល្មមឱ្យមូលត្រកួលក្នុងស្លាបព្រា កុំឱ្យលើកដាក់ក្នុងមាត់ហើយ ជ្រុះពីមាត់មកក្នុងចាន។

៩-មិនត្រូវយកម្ហូបណាមួយដែលត្រូវមាត់ខ្លួនមកប្រឡាក់បាយដូចញាំឬស្រូបបាយដោយទឹកសម្ល្អណាមួយមុខឡើយ។

១០-មិនត្រូវចាប់រំលែកម្ហូបណាមួយឱ្យបានច្រើនមកដាក់ក្នុងចានបាយខ្លួនឡើយ។

១១-មិនត្រូវបរិភោគតែម្ហូបណាមួយមុខដែលខ្លួនពេញចិត្ត ឬដែលធ្លាញ់ជាងគេនោះទេ។

១២-មិនត្រូវបរិភោគរឡិបរឡប់ញាប់ដៃគ្មានបង្អន់ ឱ្យតែបានឆ្អែតមុនគេនោះទេ។

១៣-ត្រូវមើលនាយមើលអាយ កុំយឺតពេក កុំញាប់ពេក បើនឹងឈប់ក៏ត្រូវឈប់បន្តៗគ្នា ឬស្មើគ្នាក្នុងវង់ជាមួយគ្នា។

១៤-មិនត្រូវទារថែមតែម្ហូបណាដែលធ្លាញ់នោះទេ គឺត្រូវរអែងអធ្យាស្រ័យដល់ម្ចាស់កម្មវិធី ឬអ្នកដែលជាម្ចាស់ផ្ទះ ក្រែងខ្វះខាតផង។

១៥- កុំទាវរករបស់ដែលខុសទំនង ឬរបស់ដែលគេពុំដាក់ឱ្យ។ បើប្រសិនជាសាបប្រៃយ៉ាងណា គួរស៊ូទ្រាំនៅស្ងៀម។

១៦-មិនត្រូវចោលឆ្អឹងត្រី ឬកាកសំណល់លើតុបាយ គឺចោលតែក្នុងធុងសំរាមឬទុកក្នុងចានបាយរបស់ខ្លួន។

១៧-មិនត្រូវទង្គិចសម ស្លាបព្រានឹងចានបាយ ឬចានសម្ល្អឱ្យឮខ្លាំងទេ។

១៨-មិនត្រូវទុកម្ហូបដែលមានឱជារសធ្លាញ់នោះនៅតែមុខខ្លួនទេ គឺត្រូវផ្ទាស់ប្តូរកន្ទែងម្ហូបខ្លះ ដើម្បីជាការគួរសមដល់លោកអ្នកដែលលូកមិនដល់ឬដែលពិបាកនឹងឈោងឱ្យដល់។

១៩-ពេលលែងបរិភោគចំអាបកុំបរិភោគបង្អែមមុនគេតែម្នាក់ឯងទេ ត្រូវបង្អង់ចាំឱ្យហើយគ្រប់គ្នា ទើបបរិភោគព្រមគ្នា។

២០-កាលបើបរិភោគហើយ មានសាច់ឬអ្វីមួយចូលសៀតស៊កនៅចន្ទោះធ្មេញ គួរពុំទាន់ចាក់យកចេញ លុះត្រាតែឈឺទ្រាំពុំបាន។ បើទ្រាំបានគួរតែកុំអាលចាក់ បើមានភ្ញៀវតុជាមួយគេមិនទាន់លែងកុំឱ្យមានការខ្ពើមរអើម។ កិរិយាចាក់ធ្មេញនេះត្រូវតែយកដៃម្ខាងខ្ទប់មាត់ ឬបាំងមាត់កុំឱ្យអ្នកជិតឃើញធ្មេញក្នុងមាត់ និងមាត់ដែលហាឡើងនោះមិនជាទីទស្សនាការដល់ភ្នែកទាំងពួង។

២១-កាលបើលែងបរិភោគហើយ ត្រូវប្រមូលសម និងស្ងាបព្រាដាក់ផ្លារទន្ទឹមគ្នានៅកណ្តាលចានបាយ។ យ៉ាងនេះអ្នកបម្រើសេវានឹងដឹងថាយើងឈប់ហើយ។

២២-ពេលឈប់បរិភោគហើយ គេមិនដែលលាងដៃក្នុងចាន គេមិនដែលលាងមាត់ឬខ្ពុរមាត់នៅកន្លែងនោះទេ ហើយគេមិនដែលខ្ទល់នឹងចាក់ទឹកលាងគ្រលែងចានបាយដែរ។

២៣-កាលបើបរិភោគលែងមុនគេ កុំអាលប្រញាប់ជក់បារីបង្គុយផ្សែងដាក់គេដែលកំពុងតែបរិភោគមិនទាន់រួច។

២៤-ពេលកំពុងបរិភោគមិនត្រូវខាកស្តោះឡើយ។ បើកណ្តាស ឬក្អកទប់មិនបានក៏ត្រូវងាកមុខចេញពីតុឬយកកូនកន្សែងខ្ទប់មាត់កុំព្រួសបាយឬទឹកមាត់ចូលស្តុកបាយឡើយ។

ទាំងនេះគឺជាវិធីក៏ដូចជាសុជីវធម៌នៅក្នុងការទទួលទានអាហារដ៏សមរម្យដែលលោកអ្នកគួរតែអនុវត្តជាប្រចាំ ជាពិសេសនាពេលបច្ចុប្បន្ននេះ ក្នុងបរិបទការពារការចម្លងរោគឆ្លងផ្សេងៗ យើងមិនត្រូវយកស្ងាបព្រាសម ឬចង្កឹះរបស់យើងទៅដួសអាហារក្នុងចានរួមនោះទេ គឺត្រូវប្រើស្ងាបព្រា សម ចង្កឹះរួមដែលគេទុកសម្រាប់តែដួសអាហារទាំងអស់គ្នា។

២. សុជីវធម៌ក្នុងការនិយាយស្តី

មិនថាជាការនិយាយគ្នាផ្ទាល់ ឬការនិយាតាមទូរសព្ទនោះទេ គឺត្រូវបានគេឱ្យតម្លៃគ្រប់សកម្មភាព ព្រោះជាការបង្ហាញថាយើងជាមនុស្សយល់កាល:ទេស:និងមានសុជីវធម៌ជាមួយដៃគូសន្ទនា។

. កុំទុកឱ្យដៃគូសន្ទនារង់ចាំយូរ (បើទូរសព្ទរោទ៍ គួរកុំទុកឱ្យរោទ៍យូរពេក ដ្បិតអ្នកហៅទូរសព្ទចូលមក មិនថាក្នុងន័យការងារ ឬសួរសុខទុក្ខទេ សុទ្ធតែចាត់យើងជាមនុស្សសំខាន់ និងមានអ្វីត្រូវជជែកជាមួយយើងជាមិនខាន)។

. ខណៈកំពុងជជែក គួរធ្វើយ "បាទ/ចាំឬខ្ញុំយល់ហើយឬខ្ញុំកំពុងស្តាប់" ជាដើមទៅកាន់ដៃគូសន្ទនា ទោះបីធ្វើយខ្លីៗក៏ដោយ គឺដើម្បីបង្ហាញឱ្យគូសន្ទនាម្ខាងទៀតយល់ថាយើងកំពុងស្តាប់គាត់ និងយល់ពីអ្វីដែលគាត់កំពុងនិយាយ។

. ប្រើសំឡេងសមរម្យ ព្រោះសំឡេងបញ្ជាក់ពីអារម្មណ៍។ បើនិយាយដោយប្រើសំឡេងតិចពេកអាចដៃគូសន្ទនាស្តាប់មិនបាន និងមិនយល់សាច់ការ។ ប៉ុន្តែបើយើងប្រើសំឡេងធ្ងន់ៗ ឬខ្លាំងៗពេកនឹងធ្វើឱ្យដៃគូភ័យខ្លាច ដូច្នេះត្រូវប្រើសំឡេងសមរម្យ មិនតិចមិនខ្លាំង បង្កឱ្យការសន្ទនារលូនល្អ។

. យកចិត្តដាក់ស្តាប់ និងមិនបង្កសំឡេងរំខាន (បើនិយាយទូរសព្ទកុំគិតថា ការជជែកគ្នាតាមទូរសព្ទ គេមិនឃើញមុខ)។ នៅពេលយើងមានកាយវិការបែបណា សំឡេងដែលនិយាយទៅក៏គេអាចដឹងបាន ដូច្នេះគួរតែធ្វើជាអ្នកស្តាប់ដ៏ល្អ ធ្វើខ្លួនឱ្យបានសមរម្យ និងញញឹមទទួលដើម្បីឱ្យដៃគូទទួលអារម្មណ៍ពេញចិត្ត។

. កុំបរិភោគអាហារ ឬផឹកអ្វីក្នុងពេលសន្ទនា (ទោះបីជានៅពេលទទួលទូរសព្ទក៏ដោយ) ព្រោះបង្កសំឡេងរំខាន និងសបញ្ជាក់ថា អ្នកមិនយកចិត្តទុកដាក់ ព្រមទាំងមិនឱ្យតម្លៃដៃគូសន្ទនា។

. បើសន្ទនាជាផ្លូវការ គួរមានសៀវភៅ និងប៊ិកសម្រាប់ត្រៀមកត់ត្រា (បើពេលមានគេទូរសព្ទចូលមក យើងគួរតែត្រៀមសៀវភៅ និងប៊ិច ដើម្បីកត់លេខទូរសព្ទ កត់លេខកូដអ្វីមួយឬអាសយដ្ឋានជាដើម)។ ខណៈដែលយើងមិនបានត្រៀម លុះពេលត្រូវការក៏ស្រវេស្រវាកមិនទាន់នាំឱ្យខាតពេលនិងរំខានដៃគូ។

. កុំបញ្ឈប់ការសន្ទនា ឬដាក់ទូរសព្ទចុះភ្លាម។(ចំពោះការហៅទូរសព្ទចូលណាមួយដែលនិយាយទៅហាក់មិនស្របគ្នា ឬមាននរណាម្នាក់ចង់រំខានយើងក្តី សុជីវធម៌ល្អគួរកវិធីសាស្ត្របដិសេធ ឬជម្រាបលាឱ្យបានត្រឹមត្រូវ)។ ទង្វើបញ្ឈប់ការសន្ទនាភ្លាមៗ ឬបិទទូរសព្ទភ្លាមៗធ្វើឱ្យដៃគូម្ខាងទៀតមានអារម្មណ៍មិនល្អ និងអាចមើលស្រាលយើងថាមិនមានការគោរពចំពោះគេ។

ដូច្នេះការរស់នៅក្នុងសង្គម ត្រូវតែមានចំណេះដឹងសណ្តាប់ធ្នាប់ ការដឹងប្រមាណ ចេះគួរសមក្នុងកិច្ចការនិយាយច្រាស្រ័យជាមួយអ្នកដទៃផងគ្នា បើយើងមិនមានសុជីវធម៌ទេ មិនថាយើងរៀនដល់កម្រិតណា វាហាក់ដូចជាអ្នកអត់បានរៀនដូច្នោះដែរ។ ដូចជាការនិយាយស្តីត្រូវតែសុភាពរាបសាជានិច្ច មិនត្រូវពោលពាក្យអាក្រក់នោះឡើយ ពេលដែលចូលក្នុងវត្តអារាមជាកន្លែងសក្ការបូជា ជាទីគោរពមិនគួរនិយាយស្តីពាក្យមិនល្អ ពាក្យអសុរសឬសម្តែងកិរិយាមិនគប្បីសោះឡើយ។ បើតាមទ្រឹស្តីព្រះសម្មាសម្ពុទ្ធ រូបមន្តនៃការនិយាយស្តីមាន៖

១.ពាក្យសម្តែងដែលមិនពិត មិនត្រឹមត្រូវ មិនជាប្រយោជន៍មិនជាទីគួរឱ្យចង់ស្តាប់សម្រាប់អ្នកដទៃ ព្រះអង្គមិនពោល។

២.ពាក្យសម្តីដែលពិតត្រឹមត្រូវ មិនជាប្រយោជន៍ មិនជាទីគួរឱ្យចង់ស្តាប់សម្រាប់អ្នកដទៃ ព្រះអង្គមិនពោល។

៣.ពាក្យសម្តីដែលពិតត្រឹមត្រូវ ជាប្រយោជន៍តែមិនជាទីគួរឱ្យចង់ស្តាប់សម្រាប់អ្នកដទៃ ព្រះអង្គមិនពោល។

៤.ពាក្យសម្តីដែលពិតត្រឹមត្រូវ មិនជាប្រយោជន៍ទោះជាទីគួរឱ្យចង់ស្តាប់សម្រាប់អ្នកដទៃ ក៏ព្រះអង្គមិនពោល។

៥.ពាក្យសម្តីដែលពិត ត្រឹមត្រូវ មិនជាប្រយោជន៍ទោះជាទីគួរឱ្យចង់ស្តាប់សម្រាប់អ្នកដទៃ ក៏ព្រះអង្គមិនពោល។

៦.ពាក្យសម្តីដែលពិតត្រឹមត្រូវជាប្រយោជន៍ជាទីគួរឱ្យចង់ស្តាប់សម្រាប់អ្នកដទៃ ទើបព្រះអង្គពោល។

៣. សុជីវធម៌ក្នុងកន្លែងការងារ

ភាគច្រើននៃបុគ្គលម្នាក់គឺមានទម្ងាប់កាន់ជើងខ្លួនឯង ដែលទម្ងាប់នេះអាចត្រូវ ឬអាចខុស វាអាស្រ័យថា យើងកាន់ជើងខ្លួនឯងជ្រុលពេករហូតលែងដឹងខុសត្រូវ លែងចង់កែប្រែ បើដឹងថាខ្លួនខុសហើយនោះ។ បើយើងចង់ក្លាយខ្លួនជាបុគ្គលបែបណា វាអាស្រ័យលើខ្លួនយើងជាកំណត់។ នៅក្នុងកន្លែងធ្វើការក៏ដូចគ្នា តើយើងចង់ក្លាយជាបុគ្គលិកបែបណា? ជាថ្នាក់លើបែបណា? ជាថ្នាក់ក្រោមបែបណា? និងជាមិត្តរួមការងារបែបណា?

បុគ្គលម្នាក់ៗ អ្នកណាក៏ចង់ល្អដែរ អ្នកណាក៏ចង់ធ្វើជាមនុស្សដែលអ្នកគ្រប់គ្នាចូលចិត្ត ហើយយើងពិបាកចៀសផុតពីបញ្ហាណាស់ តែយើងអាចកាត់បន្ថយបញ្ហាបានតាមរយៈឥរិយាបថប្រកបដោយសុជីវធម៌នៅក្នុងកន្លែងការងារដូចជា៖

១.មិនពាក់ព័ន្ធក្នុងការនិយាយដើមគេ៖ មនុស្សយើងតែងចៀសមិនផុតពីការនិយាយដើមគ្នា យើងអាចឮគ្រប់កន្លែងនិងគ្រប់ពេល។ មនុស្សភាគច្រើនចូលចិត្តនិយាយលេងជាមួយមិត្តភក្តិនូវរឿងដែលពួកគេចាប់អារម្មណ៍ នេះជាធម្មជាតិដែលមិនអាចប្រកែកបាន។ ប៉ុន្តែនេះអាចជាទម្ងាប់មិនល្អមួយដែលយើងគួរចៀសវាងឱ្យបាននៅកន្លែងបំពេញការងារ។ ថ្ងៃណាមួយយើងក៏អាចក្លាយជាប្រធានបទដែលគេនឹងយកមកនិយាយដើមដែរ។ វិធីសាស្ត្រល្អក្នុងស្ថានភាពនេះ គឺធ្វើមិនដឹងមិនឮ កុំពាក់ព័ន្ធនឹងពាក្យចចាមអាំ៉ាម បើទោះជាអ្នកត្រូវបានគេទាក់ទាញយ៉ាងណាក៏ដោយ។ បើសិនជាយើងអាចនៅឆ្ងាយពីការនិយាយដើមគ្នា ការចែកចាយពាក្យខ្សឹបខ្សៀវចចាមអាំ៉ាមបាន យើងនឹងមានអារម្មណ៍ថាខ្លួនយើងជាអ្នកធ្វើការប្រកបដោយវិជ្ជាជីវៈនិងក្រមសីលធម៌ម្នាក់។

២.យកបញ្ហា ឬការងារ ពិភាក្សាជាមួយអ្នកដែលពាក់ព័ន្ធ៖ យើងនឹងពិបាកក្នុងការដែលអាចស៊ីចង្វាក់នឹងមនុស្សគ្រប់គ្នាណាស់ ហើយក៏មិនមែនគ្រប់គ្នាដែលយើងជួបសុទ្ធតែមានទស្សនៈដូចយើងនោះទេ។ ក្នុងករណីខ្លះ បុគ្គលិកលក្ខណៈរបស់យើង

នឹងអ្នកដទៃអាចមិនត្រូវគ្នាខ្លាំង។ ប៉ុន្តែវាវិតតែសំខាន់ដែលត្រូវតែរក្សាភាពជាអ្នកជំនាញនៅកន្លែងការងារ បានន័យថា រឿងនិងអារម្មណ៍ផ្ទាល់ខ្លួនត្រូវទុកដោយឡែក។ ត្រូវតែគ្រប់គ្រងនូវអារម្មណ៍អវិជ្ជមានឱ្យបានយើងត្រូវតាំងខ្លួនយើងឱ្យខ្ពស់ជាងអារម្មណ៍អវិជ្ជមាន ហើយកុំព្យាយាមសងសឹកចំពោះរឿងណាមួយ។ ប្រសិនបើមានបញ្ហាណាមិនស្រួល គួរផ្តល់ព័ត៌មានជូនអ្នកដែលមានហាន:ខ្ពស់ជាងដើម្បីឱ្យគាត់បានដឹងជាមុន។ វាមិនមែនជាការរាយការណ៍ចាក់រុកនោះទេ បើសិនជាយើងប្រាប់អំពីផលលំបាកដែលយើងជួប ឬបញ្ហាដែលអាចកើតមានឡើង ឬក៏បញ្ហាការយល់ច្រឡំណាមួយ។ គួរចងចាំដែរថា យើងនឹងមិនអាចចូលចិត្ត និងចុះសម្រុងបានគ្រប់មនុស្សនោះទេ។ វាអាស្រ័យលើឧបនិស្ស័យដែរ តែកុំបូករឿងផ្ទាល់ខ្លួនចូលជាមួយរឿងការងារ។

៣. ជួយនៅពេលណាដែលអ្នកអាចជួយបាន: ជាសុជីវធម៌ក្នុងការធ្វើការងារជាក្រុម គឺជារឿងដ៏ល្អមួយ បើការងារត្រូវបានបែងចែកច្បាស់លាស់។ កុំប្រមូលការងារមកធ្វើតែឯង បើសិនជាយើងមិនអាចធ្វើអស់ប៉ុន្តែគួរតែផ្តល់ជំនួយ បើសិនជាយើងអាចធ្វើបាន។ យើងអាចនឹងត្រូវបានគេបដិសេធ ប៉ុន្តែយើងអាចនឹងត្រូវបានគេមើលឃើញ។ ពេលខ្លះយើងអាចចាប់ផ្តើមដោយពាក្យថា "មានអីឱ្យខ្ញុំជួយទេ?"។ បើយើងឃើញមិត្តរួមការងារកាន់របស់ធ្ងន់ យើងអាចជួយបានភ្លាមឬក៏ជួយបើកទ្វារ និងទប់ទ្វារឱ្យបើសិនជាដៃរបស់គាត់កំពុងរវល់ ដែលនេះជាទង្វើរតិចតួច តែធ្វើជាប្រចាំនឹងក្លាយជាទម្លាប់ល្អ។

៤. ផ្តល់ការយកចិត្តទុកដាក់: នៅពេលដែលមានអ្នកណាម្នាក់ដើរមកជិតតុរបស់យើង ឬក៏និយាយជាមួយយើង ហើយបើទោះជាយើងមានការងារគរដូចភ្នំក៏ដោយ ក៏យើងគួរតែអាចមើលគេបន្តិច ហើយងក់ក្បាលដើម្បីទទួលដឹងនូវវត្តមានរបស់គេដែរ។ ព្យាយាមផ្តល់ការចាប់អារម្មណ៍ និងយកចិត្តទុកដាក់ដល់អ្នកដែលមករកយើង បើសិនជាយើងមិនមានពេល ផ្តល់ឱ្យគាត់ទេនោះ យើងអាចសុំឱ្យគាត់មកម្តងទៀតនៅពេលដែលយើងទំនេរ។

៥. បង្កើតបរិយាកាសវិជ្ជមាន: គ្រប់គ្នាសុទ្ធតែអាចមានអារម្មណ៍មិនល្អ! បើសិនជាយើងសង្កេតឃើញថា អ្នករួមការងាររបស់យើងអារម្មណ៍មិនល្អទេនោះ យើងគួរតែធ្វើខ្លួនយើងឱ្យមានអារម្មណ៍ល្អដោយប្រាប់គាត់ថា "បើមានអីឱ្យយើងជួយ អាចប្រាប់យើងបាន" ព្រោះពេលដែលយើងមានអារម្មណ៍មិនល្អ ពួកគេក៏អាចជួយយើងបានវិញដូចគ្នា

ពោលគឺបង្កើតភាពរីករាយ និងស្រស់ស្រាយក្នុងក្រុមការងារ។

៦.ស្វាគមន៍សិស្សប្អូន៖ ជាទូទៅអាចនឹងមានអ្នកចំណូលថ្មី ឬសិស្សប្អូន ក្នុងកន្លែងបំពេញការងារ។ បើទោះបីយើងមិនធ្វើការជិតស្និទ្ធនឹងគាត់ក៏ដោយ បើសិនជាអាចគួរតែស្វាគមន៍គាត់ ឱ្យគាត់មានអារម្មណ៍កក់ក្តៅ ឱ្យគាត់មានអារម្មណ៍ថាគ្នាឯង។ ចាប់ផ្តើមដោយសួរនាំពីគាត់ខ្លះ បបួលគាត់ញ៉ាំអាហារថ្ងៃត្រង់ជាមួយគ្នាឬក៏ធ្វើការហ្វូឱ្យដើម្បីស្វាគមន៍យ៉ាងហោចណាស់ក៏សម្រាប់ពេលពីរបីថ្ងៃដំបូងដែរ។

៤. សុជីវធម៌ក្នុងការសំពះគោរព

កម្ពុជាជាប្រជាជាតិមួយដែលឱ្យតម្លៃខ្ពស់លើវិស័យសិល្បៈវប្បធម៌និងទំនៀមទម្លាប់របស់ខ្លួន មានចរិតលក្ខណៈល្អៗ មានភាពទន់ភ្លន់ និងរួសរាយរាក់ទាក់។

ចំពោះកិច្ចស្វាគមន៍ តាមធម្មតាប្រជាជនខ្មែរបានបង្ហាញការគោរវៈកិច្ចស្វាគមន៍ដោយការសំពះ ដែលជាការលើកម្រាមដៃទាំងពីរផ្គុំគ្នា នៅមុខទ្រូងជាមួយនឹងការអោនលំទោននិងស្វាគមន៍យ៉ាងទន់ភ្លន់អមដោយភាសានិយាយថា "ជម្រាបសួរ"។

ប្រពៃណីទំនៀមទម្លាប់ខ្មែរដែលប្រើការសំពះគ្នាក្នុងកិច្ចការបដិសណ្ឋារកិច្ចស្វាគមន៍ និងលាគ្នាទៅវិញទៅមកនោះ គឺអ្នកមានវ័យក្មេងជាងត្រូវលើកដៃសំពះមនុស្សចាស់មុន និងអ្នកមានឋានៈតួនាទីតូចជាងត្រូវលើកដៃសំពះអ្នកមានឋានៈតួនាទីធំជាងមុន។

ក្នុងការសំពះ ខ្មែរមាន៥បែប គឺ៖

. ដាក់ចុងម្រាមដៃកណ្តាលត្រឹមទ្រូង (ដោយផ្គុំបាតដៃជាសណ្ឋានផ្កាឈូកក្រពុំ) ជាការសំពះបុគ្គលដែលមានឋានៈប្រហាក់ប្រហែលគ្នាឬមិត្តភក្តិជាដើមនិងសម្រាប់បុគ្គល ដែលមានវ័យចាស់ជាងដែលត្រូវសំពះតបវិញចំពោះអ្នកដែលមានវ័យក្មេងជាងខ្លួន។

. ដាក់ចុងម្រាមកណ្តាលត្រឹមមាត់ ជាការសំពះបុគ្គលដែលមានវ័យចំណាស់ជាងថៅកែ ឬថៅហ្វាយនាយ។

. ដាក់ចុងម្រាមកណ្តាលត្រឹមចុងច្រមុះ ឱនក្បាលបន្តិចជាការសំពះឪពុកម្តាយជីដូនជីតាអាណាព្យាបាលគ្រូបាអាចារ្យ ឬអ្នកមានគុណ។

. ដាក់ចុងម្រាមកណ្តាលត្រឹមចិញ្ចើម ឱនក្បាលខ្លាំង ជាការសំពះព្រះសង្ឃ ស្តេច ឬហៅថាជាការក្រាបបង្គំគាល់ ឬថ្វាយបង្គំ។

. ដាក់ចុងម្រាមមេដៃផ្គុំលើចញ្ចើម ជាការសំពះ ព្រះឥន្ទ្រ ព្រះព្រហ្ម ទេវតា អ្នកតា គឺសំពះអ្វីៗដែលខ្ពស់ហួសពីមនុស្ស។

ការលើកដៃឡើងខ្ពស់ ហើយក្បាលខិនឱ្យទាបបង្ហាញថាកាន់តែគោរព។ ប៉ុន្តែក្នុងការជួបក្នុងជំនួបមន្ត្រីរដ្ឋាភិបាលនិងជនបរទេស សម្រាប់បុរស ទំនៀមទម្លាប់នេះត្រូវបានជំនួសដោយការចាប់ដៃគ្នា តែបើអាចគួរតែជម្រាបសួរជាមុន មុននឹងចាប់ដៃនោះវិតតែប្រសើរដែលបង្ហាញពិការរក្សានូវអត្តសញ្ញាណជាតិរបស់ខ្លួន។

៥. សុជីវធម៌ក្នុងជំឿសាសនា

ប្រទេសកម្ពុជាមានសាសនាច្រើន ព្រះពុទ្ធមានប្រជាជនគោរពជឿប្រមាណជា ៩៥% និងមានសាសនាដទៃទៀតមានប្រជាជនប្រមាណជា ៥%ដែលក្នុងនោះ ដូចជាសាសនាអ៊ីស្លាម សាសនាគ្រិស្តជាដើម។

ដោយសារប្រជាជនខ្មែរភាគច្រើនជឿលើព្រះពុទ្ធសាសនា ដូច្នេះវត្តអារាមគឺជាកន្លែងបដិបត្តិធម៌វិន័យរបស់ព្រះសង្ឃ ជាស្រែបុណ្យនិងជាទីកន្លែងសន្សំបុណ្យកុសលធ្វើឱ្យចិត្តស្ងប់នោះ គឺត្រូវបានប្រជាជនខ្មែរនិយមទៅទីនោះ។ ការស្លៀកពាក់ឱ្យបានសមរម្យចូលវត្តអារាម គឺជារឿងប្រពៃថ្លៃថ្នូរគួរគប្បីធ្វើឱ្យបានព្រមគ្នា ដើម្បីសេចក្តីថ្លៃថ្នូររបស់ខ្លួនឯងផង និងដើម្បីរក្សាវប្បធម៌ប្រពៃណីជាតិដ៏ល្អផូរផង់ផង។ ជាទូទៅប្រជាជនខ្មែរ តែងតែស្លៀកសំពត់ហូល ជាមួង សំពត់បត់ និងពាក់អាវប៉ាក់ អាវស ដែលសមរម្យ ដោយចៀសវាងការស្លៀកពាក់បែបវាលមុខ វាលក្រោយ ឬខើចលើ ខើចក្រោម ឬក៏រឹបរាង ខើចខ្ចីបង្ហាញសាច់ខ្ចី។ គេសង្កេតឃើញមានស្ត្រីមួយចំនួនបានស្លៀកសម្លៀកបំពាក់ខើចខ្ចី ខ្លះឆែកពីមុខ ឆែកពីក្រោយ ខ្លះវាលខាងមុខ ខ្លះវាលខាងក្រោយខ្លាំងដែលជាការមិនគួរគាប់ និងជាការចូលរួមចំណែកបំផ្លាញទំនៀមទម្លាប់ វប្បធម៌ដ៏ល្អផូរផង់របស់ខ្មែរ។ បើនិយាយអំពីសេរីភាពនៃការស្លៀកពាក់វិញ ពិតជាមានមែនហើយ ប៉ុន្តែគេក៏ត្រូវមើលពីកម្មវិធីដែលគួរចូលរួម បើមិនដូច្នោះទេ វានឹងបង្កឱ្យមានការរិះគន់ ហើយក៏បង្ហាញពីការធ្លាក់ចុះសីលធម៌សង្គម ជាពិសេសគឺការបាត់បង់ទំនៀមទម្លាប់ប្រពៃណីជាតិខ្មែរតែម្តង។ ការតុបតែងខ្លួននិងការស្លៀកពាក់បែបមិនសមរម្យ វានឹងជះឥទ្ធិពលយ៉ាងខ្លាំងទៅលើស្ត្រីខ្មែរជាច្រើនដែលពួកគេស្លៀកពាក់គោរពតាម វប្បធម៌ប្រពៃណីដ៏ត្រឹមត្រូវ។ ស្ត្រីខ្មែរមួយចំនួនទៀតការស្លៀកពាក់របស់គាត់មិនត្រឹមតែសមរម្យទេ គឺគាត់ស្លៀកពាក់ត្រូវតាមពណ៌នៃថ្ងៃនីមួយៗដើម្បីនាំមកនូវសិរីសួស្តីផងដែរ គឺថ្ងៃអាទិត្យពណ៌ក្រហម ថ្ងៃចន្ទពណ៌លឿង ថ្ងៃអង្គារពណ៌ស្វាយ ថ្ងៃពុធពណ៌ស៊ីលៀប ថ្ងៃព្រហស្បតិ៍ពណ៌បៃតង ថ្ងៃសុក្រពណ៌ទឹកប៊ិក និងថ្ងៃសៅរ៍ពណ៌គ្រាប់អំពិល។

ចំពោះឥរិយាបថវិញ ពេលចូលមកដល់ទីវត្តអារាមត្រូវធ្វើនូវឥរិយាបថថ្លៃថ្នូរ សុភាពរាបសារ រម្យទម ទន់ភ្ញន់ អង្គុយបត់ជើងដោយមិនត្រូវនិយាយគ្នាឮៗ មិនត្រូវប្រលែងគ្នាលេងឡេះឡោះ និងត្រូវចេះដោះមួកមុនពេលចូលក្នុងទីអារាម។ ការប្រព្រឹត្តនូវឥរិយាបថល្អក្នុងទីវត្តអារាម គឺជាសកម្មភាពល្អសម្រាប់ពុទ្ធបរិស័ទ។

៦. សុជីវធម៌ក្នុងការស្លៀកពាក់

សម្លៀកបំពាក់ប្រពៃណីខ្មែរ គឺជាសម្លៀកបំពាក់ដែលបង្ហាញពីអត្តសញ្ញាណជាតិខ្មែរ គ្រប់សម័យកាលពីមួយជំនាន់ទៅមួយជំនាន់។ សម្លៀកបំពាក់ប្រពៃណីខ្មែរដែលផ្តោតទៅលើម៉ូដសម្លៀកបំពាក់ដែលបែងចែកទៅលើវណ្ណៈនៃការស្លៀកពាក់ទៅតាមក្រិតក្រមក្នុងកម្មវិធីផ្សេងៗ ដូចជា៖ សម្លៀកបំពាក់មង្គលការ សម្លៀកបំពាក់ទៅវត្តអារ៉ាម សម្លៀកបំពាក់ទៅពិធីបុណ្យ និងសម្លៀកបំពាក់រាំរបាំផ្សេងៗទៅតាមពេលវេលា និងកម្មវិធីច្បាស់លាស់។

សម្លៀកបំពាក់ខ្មែរមានច្រើនរចនាបថ និងមានច្រើនទម្រង់ដែលបែងចែកទៅតាមរស់និយមក្នុងសម័យកាលនីមួយៗ ដែលចែកប្រភេទនៃក្រណាត់សូត្រខ្មែរជាច្រើនប្រភេទ ដូចជា៖ក្រណាត់ហូលក្រណាត់ផាមួង ក្រណាត់សឹង ក្រណាត់ត្រៃដែលមានការរចនាប្លែកៗពីគ្នា។

យោងតាមកំណត់ត្រាពាជទូតចិន គឺលោក ជីតាក្វាន់ (Zhou Daguan) ដែលបានមកដល់ចក្រភពខ្មែរនាសម័យអង្គរ ឆ្នាំ១២៩៦ នៃគ.ស. បានសរសេរក្នុងកំណត់ហេតុរបស់លោកថា[៣] ស្ត្រីខ្មែរវ័យកណ្តាលនាសម័យអង្គរច្រើនបួងសក់ ប្រើក្រណាត់ចងពីងនៅលើដើមទ្រូង និងបញ្ចេញផ្ចិត ចំណែកឯស្ត្រីវ័យចំណាស់ច្រើនចោមពុង នៅពេលដែលពួកគេចេញដំណើរទៅណាមកណា ពួកគេបន្ថែមផ្ទាំងក្រណាត់ធំមួយមកពាត់រុំខ្លួនដល់ត្រឹមស្មារីឯបុរសច្រើនព្រលែងខ្លួនទទេ ដែលស្លៀកតែសំពត់ចងក្បិនប៉ុណ្ណោះ។

សម្លៀកបំពាក់ចូលរួមពិធីអាពាហ៍ពិពាហ៍ជាទូទៅ គេស្លៀកពាក់បែបប្រពៃណីគឺហូល ផាមួង អាវប៉ាក់។ ពីមួយឆ្នាំទៅមួយឆ្នាំ ការរៀបចំពិធីមង្គលការតាមប្រពៃណីខ្មែរតែងតែមានការកែប្រែត្រង់ចំណុចខ្លះដោយសារតែការប្រែប្រួលតាមភាពទាន់សម័យរបស់សង្គម។ ភាពខុសប្លែកគ្នារវាងអាពាហ៍ពិពាហ៍កាលពីអតីតកាល និងបច្ចុប្បន្នត្រូវបានស្តែងចេញតាមរយៈទំនៀមទម្លាប់តាម

[៣] សូមមើល លី ជាមតេង៉ កំណត់ហេតុរបស់ជីវតាក្វាន់ អំពីប្រពៃណីនៃអ្នកស្រុកចេនឡា ភ្នំពេញ ឆ្នាំ១៩៧៣។

តំបន់និងភូមិស្រុក។ តែនៅសម័យសម្ភារៈជឿនលឿននាពេលបច្ចុប្បន្ននេះ ជាពិសេសនៅទីក្រុង ការរៀបអាពាហ៍ពិពាហ៍ គេច្រើនប្រារព្ធធ្វើនៅហាងទទួលទានអាហារ ឬភោជនីយដ្ឋាន ហើយពិធីជប់លៀងមង្គលការ ត្រូវមើលឃើញជាកន្ទែងបង្ហួតសម្រស់និងបង្ហាញគ្រឿងអលង្ការទៅវិញ។ ក្នុងពិធីអធិកអធមនេះដែរ គឺស្ត្រីបានក្លាយជាក្បៀវទាក់ទាញជាងគេ។ ការទាក់ទាញ មានការបង្ហួតសម្លៀកបំពាក់គ្រឿងអលង្ការ បង្ហួតសក់ទាន់សម័យ។ នេះគឺជាការចំណាយរបស់ស្ត្រីដែលត្រូវចាយច្រើនជាងបុរសបន្តិចនៅពេលស្ត្រីចូលរួមមង្គលការម្តងៗមានដូចជា សម្លៀកបំពាក់ការ ផាត់មុខធ្វើសក់ និងការលាបថ្នាំក្រចក ហើយមានរហូតដល់កាត់សម្លៀកបំពាក់ជាដើម គឺត្រូវចំណាយប្រាក់គ្រប់បែបយ៉ាង មិនដូចបុរសទេដ្បិតបុរស។ គេស្លៀកតែខោជើងវែង ពាក់អាវកឌុប ដៃវែងឬដៃខ្លី ដោយដាក់អាវក្នុងខោ ដែលមានក្រវាត់ខ្សែក្រវាត់ និងពាក់ស្បែកជើងប៊ូជាការស្រេច ហើយបើមានពាក់ក្រវាត់ក ទៀតគឺវិតតែសមរម្យ។

ជាសរុបសេចក្តីមក ការរស់នៅប្រកបដោយសុជីវធម៌និងចេះស្វែងយល់ពីប្រពៃណីទំនៀមទម្លាប់ នោះនឹងញុំាងជីវិតរស់នៅប្រកបដោយភាពជោគជ័យ ដោយភាពជឿជាក់មានទំនាក់ទំនងល្អ មានការស្រឡាញ់ពេញចិត្តដោយបេះដូងពិត និងទទួលបាននូវការគោរពរាប់អានពីអ្នករស់នៅជាមួយយើង។ ប៉ុន្តែគោងចងចាំថា សុជីវធម៌ សីលធម៌ និងគុណធម៌ ត្រូវបានសង្គមចាត់ទុកថាជាបណ្តុំនៃគុណតម្លៃដែលមនុស្សម្នាក់ៗមិនអាចខ្វះបានឡើយគ្រាន់តែថាធម៌ទាំងបីនេះមានគុណតម្លៃផ្សេងៗពីគ្នាប៉ុណ្ណោះ។ សុជីវធម៌មិនអាចកំណត់បានថា ជាមនុស្សល្អឬអាក្រក់បានឡើយ។ អ្នកខ្លះមើលទៅដូចជាមានសុជីវធម៌ល្អដែរ ដូចជាបង្ហាញឥរិយាបថសុភាពពាបសា ទន់ភ្ន់ ចេះគួរសម ហើយត្រឹមត្រូវណាស់ ប៉ុន្តែបែរជាមានចិត្តច្រណែនឈ្នានីសនិងរុកកួនរំខានអ្នកដទៃទៅវិញក៏មានដែរ។ ដូច្នេះសុជីវធម៌ គ្រាន់តែរូបភាព ឬជាទង្វើខាងក្រៅរបស់មនុស្សប៉ុណ្ណោះ មិនអាចកំណត់បានទាំងស្រុងថា មនុស្សនោះជាមនុស្សល្អ មានសីលធម៌ ឬគុណធម៌ឡើយ។ មានសុជីវធម៌ តែមិនមានសីលធម៌ និងខ្វះគុណធម៌ ក៏មិនទាន់គ្រប់គ្រាន់ដែរ។ ទាល់តែមានសីលធម៌ផង ទើបអាចកំណត់បានថា ជាមនុស្សល្អ។ អ្នកដែលមិនធ្វើអំពើអាក្រក់ជាក់អ្នកដទៃ គឺជាអ្នកដែលមានសីលធម៌ឬហៅថាសីល។ ក្នុងចំណោមធម៌ទាំងបី គុណធម៌ហាក់មានតម្លៃខ្ពស់ជាងគេ។ បុគ្គលណាដែលមានគុណធម៌តែងមានលក្ខណៈពីរយ៉ាងគឺ តាំងចិត្តធ្វើទង្វើល្អត្រឹមត្រូវជានិច្ច ដោយមិនធ្វើអំពើទុច្ចរិតជា

ដាច់ខាត និងផ្តល់ប្រយោជន៍ដល់អ្នកដទៃ។ បុគ្គលណាដែលព្យាយាមស្វែងយល់ ស្គាល់ល្អ ស្គាល់អាក្រក់ ចេះគោរពគ្នា និងកែលម្អនូវពាល់ចំណុចខ្វះខាតដើម្បីឱ្យខ្លួនក្លាយជាបុគ្គលមានតម្លៃ មានសេចក្តីថ្លៃថ្នូរសម្រាប់ខ្លួនឯង គ្រួសារ និងសង្គមជាតិជាបុគ្គលដែលមានសុជីវធម៌ បុគ្គលណាមិនធ្វើអាក្រក់ដាក់អ្នកដទៃចាត់ទុកថា មានសីលធម៌ ហើយបើចេះជួយអ្នកដទៃទៀតផងនោះ គឺនឹងឈានដល់កម្រិតមួយទៀត គឺគុណធម៌។

ឯកសារពិគ្រោះ

1. ក្រសួងអប់រំ យុវជន និងកីឡា ***សៀវភៅសិក្សាសង្គម*** ថ្នាក់ទី១០ ឆ្នាំ២០១៧ ទំព័រទី២១៦
2. ជា វណ្ណៈ តម្លៃអប់រំនៃការបណ្តុះធម្មចរិយា ឆ្នាំ២០២២
3. ញឹក នូវ ***ទំនៀមទម្លាប់ និងប្រពៃណីខ្មែរ***
4. កី ជានឡាយ ***កម្រងសុជីវធម៌***
5. លី ធាមតេង កំណត់ហេតុរបស់ជីវតាក្វាន់ អំពីប្រពៃណីនៃអ្នកស្រុកចេនឡា ភ្នំពេញ ឆ្នាំ១៩៧៣។

ការវិវត្តនៃរដ្ឋបាលដែនដីខ្មែរ
(តាំងពីសម័យមុនអង្គរ រហូតដល់ឆ្នាំ១៩៩៣)

ដោយៈ លោកបណ្ឌិត **ហែម ឆ្លាច**
មន្ត្រីនាយកដ្ឋាននីតិសាស្ត្រ,វិទ្យាស្ថានមនុស្សសាស្ត្រ
និងវិទ្យាសាស្ត្រសង្គម,រាជបណ្ឌិត្យសភាកម្ពុជា

សេចក្តីផ្តើម

ការរៀបចំរដ្ឋបាលដែនដីគឺជាការកិច្ចដ៏ចម្បង និងមានសារៈសំខាន់បំផុតដែលថ្នាក់ដឹកនាំរដ្ឋទូទាំងពិភពលោក ត្រូវតែផ្តោតការយកចិត្តទុកដាក់ដើម្បីធ្វើយ៉ាងណាធានាឱ្យបាននូវការអភិវឌ្ឍមួយប្រកបដោយសមភាពយុត្តិធម៌ និរន្តរភាព និងភាពសុខដុមរមនា។

ការរៀបចំរដ្ឋបាលដែនដីនៃព្រះរាជាណាចក្រកម្ពុជាមានប្រវត្តិវែងឆ្ងាយនិងលំបាកស្មុគស្មាញដោយហេតុថា ប្រទេសកម្ពុជាយើងបានឆ្លងកាត់នូវប្រវត្តិសាស្ត្រនៃសង្គ្រាមនិងបដិវត្តន៍ផ្ទៃក្នុងជាច្រើនលើកច្រើនសាច្រើនតំណមកហើយ។ យោងតាមឯកសារប្រវត្តិសាស្ត្រខ្មែរបញ្ជាក់ថារហូតមកដល់បច្ចុប្បន្ននេះ ខ្មែរយើងបានឆ្លងកាត់សម័យកាលប្រវត្តិសាស្ត្រជាបន្តបន្ទាប់ ដូចជា នគរភ្នំ ចេនឡា អង្គរចតុម្មុខ លង្វែក ឧត្តុង្គ អាណានិគមនិយមបារាំង សង្គមរាស្ត្រនិយម សាធារណរដ្ឋខ្មែរ កម្ពុជាប្រជាធិបតេយ្យ សាធារណរដ្ឋប្រជាមានិតកម្ពុជា រដ្ឋកម្ពុជា និងចុងក្រោយនេះគឺព្រះរាជាណាចក្រកម្ពុជា។

ពីសម័យកាលមួយទៅសម័យកាលមួយរបៀបរបបនៃការរៀបចំរដ្ឋបាលដែនដីមានការប្រែប្រួលជានិច្ច អាស្រ័យដោយកត្តាសំខាន់ពីរ គឺ អំណាច និងសិទ្ធិនៃការគ្រប់គ្រងទឹកដី។

នៅសម័យមុនអង្គរ និងសម័យអង្គរ អំណាចនៃការរៀបចំរដ្ឋបាលដែនដី ពេលខ្លះជារបស់ស្តេចដែលជាអំណាចកណ្តាល ពេលខ្លះស្ថិតនៅលើស្តេចត្រាញ់ដែលចំណុះអំណាចកណ្តាលចំណែកឯប្រជារាស្ត្រគ្រាន់តែជាទាសករ ឬជាបរិវារមានសិទ្ធិត្រឹមតែសុំរស់ដោយប្រកបរបរអាជីវកម្ម កសិកម្ម ដាំដុះ ចិញ្ចឹមសត្វលើដីធ្លីតែប៉ុណ្ណោះ ពុំមានសិទ្ធិពេញលេញក្នុងការកាន់កាប់ បែងចែកមរតកដីធ្លីជូនកូនចៅឡើយ។

ក្រោយសម័យអង្គរ គេសង្កេតឃើញថា មានវិបត្តិក្នុងរាជវង្សជាញឹកញាប់ ជាហេតុបណ្តាលឱ្យមានចម្បាំងក្នុងស្រុក គឺចម្បាំងគ្នា

ឯង អស់រយៈពេលជាច្រើនឆ្នាំ។ មូលហេតុនៃចម្បាំងទាំងនេះគឺបណ្តាលមកពីការគិតប្រយោជន៍ផ្ទាល់ខ្លួនច្រើនជាងប្រយោជន៍រួម។ លុះជម្ងោះកើតឡើងហើយអ្នកដឹកនាំជាតិមិននិយមដោះស្រាយជាតិតាមសម្រួលទៅបែរជាសុខចិត្តទៅពឹងពាក់ប្រទេសជិតខាងមកផ្សះផ្សារវិវាទផ្ទៃក្នុងរបស់ខ្មែរទៅវិញ។

នៅសម័យអាណានិគមនិយមបារាំងរដ្ឋបានរៀបចំប្រតិបត្តិការបច្ចេកទេសគតិយុត្តិងរដ្ឋបាលដើម្បីគ្រប់គ្រងដីធ្លីតាមរយៈការធ្វើបញ្ជីដីធ្លីឱ្យបានច្បាស់លាស់ដើម្បីជាប្រយោជន៍ដល់ការបែងចែកដីធ្លីកម្មសិទ្ធិដល់ប្រជាពលរដ្ឋ។ សន្ធិសញ្ញា អនុសញ្ញា បារាំង-ខ្មែរ និងកំណែទម្រង់ព្រះរាជបញ្ញត្តិ មានចែងអំពីរដ្ឋបាលដែនដី។

ក្រោយពីទទួលបានឯករាជ្យទាំងស្រុងពីសាធារណរដ្ឋបារាំង នយោបាយផ្ទៃក្នុងប្រទេសមានការផ្លាស់ប្តូរ ប៉ុន្តែការគ្រប់គ្រងរដ្ឋបាលដែនដីនៅសម័យនោះគឺយើងយកគំរូចាត់តាំងដែនដីតាមបែបប្រទេសបារាំង។ ព្រះរាជាណាចក្រកម្ពុជាទាំងមូលត្រូវបែងចែកជាភូមិភាគ ខេត្ត ស្រុក និងឃុំ។ ក្រុងភ្នំពេញ ជារាជធានីនៃព្រះរាជាណាចក្រកម្ពុជាដែលត្រូវគ្រប់គ្រងដោយរាជប្រតិភូក្រុង ហើយត្រូវបែងចែកជា៧សង្កាត់។ អ្វីៗហាក់ដូចជាបានប្រសើរ ហើយកម្ពុជាមានការរីកចម្រើនស្ទើរគ្រប់វិស័យ។

ជាអកុសល ប្រទេសកម្ពុជាយើងបានជួបប្រទះនូវសង្គ្រាមស៊ីវិលរ៉ាំរ៉ៃអស់ជាច្រើនទសវត្សរ៍ ដែលធ្វើឱ្យកម្ពុជារងការខូចខាតយ៉ាងធ្ងន់ធ្ងរ ទាំងសំណង់អគារ រោងចក្រ ឧស្សាហកម្ម ផ្ទះសម្បែង ផ្លូវគមនាគមន៍ និងបណ្តាហេដ្ឋារចនាសម្ព័ន្ធជាច្រើនទៀត។ ចំណែកធនធានមនុស្សក៏ត្រូវបាត់បង់ផងដែរ ជាពិសេសធនធានបញ្ញវន្តរបស់ជាតិ។

១-សម័យមុនអង្គរ

១.១-សម័យនគរភ្នំ

ពាក្យថា ហ្វូណាននេះ ចិនបុរាណអានថា ប៊ីយូណាម។ ពាក្យ ប៊ីយូណាម ជាសំដីប៉ៃឡាំរបស់អ្នកស្រុកចិនដែលខំត្រាប់តាមសំឡេងខ្មែរដើមថា រ្នុំ។ ពាក្យ រ្នុំ នេះក៏បានក្លាយជាពាក្យខ្មែរសព្វថ្ងៃហៅថា ភ្នំនេះឯង។ ដែនដីសណ្តាទន្លេមេគង្គនៅដើមគ្រិស្តសករាជជាទឹកដីដែលស្ថិតនៅក្រោមការដឹកនាំរបស់ព្រះនាង លីវ យី។

លុះប្រមាណឆ្នាំ៥០នៃគ្រិស្តសករាជ ព្រះនាង លីវ យី ត្រូវច្បាំងតទល់នឹងទ័ពសំពៅរបស់ឥណ្ឌាក្រោមការដឹកនាំរបស់ព្រាហ្មណ៍ ហ៊ុន ទៀន ដែលមកកាន់ទឹកដីរបស់ព្រះនាង។

សំពៅរបស់ព្រាហ្មណ៍ហ៊ុន ទៀន បានយកជ័យជម្នះលើកងទ័ពព្រះនាង លីវ យី ហើយពេលនោះព្រះអង្គក៏បានរៀបអភិសេកជាមួយព្រះនាង លីវ យី និងបានប្រកាសតាំង

ខ្លួនជាព្រះមហាក្សត្រត្រួតត្រាលើដែនដីសណ្តា
នេះជារៀងរហូតមក។

នៅសម័យអាណាចក្រភ្នំ ខ្មែរមានទឹក
ដីធំទូលាយណាស់និងមានរដ្ឋចំណុះជាច្រើន។
សាមន្តរដ្ឋ គឺជារដ្ឋចំណុះ ដែលស្ថិតក្រោម
អំណាចគ្រប់គ្រងរបស់អាណាចក្រភ្នំ ហើយ
សុទ្ធតែមានស្តេចសោយរាជ្យ ប៉ុន្តែស្តេចទាំង
នោះជា សាមន្តរាជ របស់អធិរាជអាណាចក្រ
ភ្នំ ហើយសាមន្តរាជទាំងនោះត្រូវនាំសួយសារ
អាករមកថ្វាយអធិរាជអាណាចក្រភ្នំរៀងរាល់
ឆ្នាំ។ រដ្ឋខ្លះទៀតមានស្តេចសោយរាជ្យដែរ តែ
ស្តេចទាំងនោះជារាជបុត្រ ឬជាព្រះញាតិ
របស់អធិរាជភ្នំ។ ព្រះបាទកៅណ្ឌិន្យទី១ បាន
ប្រទានរដ្ឋបែបនេះថ្វាយទៅព្រះរាជបុត្ររបស់
ព្រះអង្គ។ រដ្ឋបែបទី២នេះ ហៅថា វិស័យរដ្ឋ
ដែលជារដ្ឋចំណុះ ហើយជាសម្បត្តិផ្ទាល់របស់
អធិរាជភ្នំ។

ក្នុងវិស័យនយោបាយក្រៅប្រទេស
អាណាចក្រភ្នំនិយមចងស្ពានមេត្រីជាមួយ
ប្រទេសឥណ្ឌានិងប្រទេសចិន។

១.២.សម័យចេនឡា

កាលដើមឡើយចេនឡាជាសាមន្តរដ្ឋ
មួយរបស់អាណាចក្រភ្នំ។ ប៉ុន្តែក្រោយមក
សាមន្តរដ្ឋនេះបានវាយយកអាណាចក្រភ្នំ
បញ្ចូលជាចេនឡាធំ ហើយទទួលបានឋាន:
ជារដ្ឋអធិបតេយ្យរហូតដល់ពាក់កណ្តាលទី២
នៃសតវត្សរ៍ទី៨។

ឈ្មោះចេនឡាជាពាក្យដែលអ្នកសិក្សា
ស្រាវជ្រាវហៅត្រាប់តាមចិន ហើយរហូតមក
ដល់សព្វថ្ងៃនេះគេមិនទាន់បានដោះស្រាយ
បញ្ហាឈ្មោះចេនឡានេះនៅឡើយទេ។
ចំពោះបញ្ហាឈ្មោះនេះអ្នកសិក្សាស្រាវជ្រាវ
បានខិតខំដោះស្រាយបញ្ចេញជាទស្សន:ផ្សេងៗ
ដូចជា:

លោក ប៉ូល ប៉ែលីយ៉ូត (Paul Pelliot)
យល់ឃើញថា ពាក្យចេនឡាទំនងមកពីពាក្យ
ចិន និងរាប: ចិន + រាប›ចិនឡា›ចេនឡា។

អ្នកដែលគាំទ្រទស្សន:នេះបាន
ព្យាយាមពន្យល់ថា ពួកខ្មែរចេនឡាមានព្រំ
ប្រទល់ជាប់នឹងអាណាខេត្តចិនភាគខាងជើង
ប្រហែលជាធ្លាប់មានជម្លោះនឹងគ្នា ហើយចិន
ទទួលបរាជ័យ ដូច្នេះហើយបានជាគេដាក់
ឈ្មោះម្ល៉ុំនោះថា ចិនរាបៗទៅ ហើយចិនហៅ
តាមខ្មែរមិនច្បាស់ក៏ក្លាយជា ចិនឡា› ចេនឡា
វិញ។

លោក កេង វ៉ាន់សាក់ មានទស្សន:
និងគំនិតប្រហាក់ប្រហែលនឹងទស្សន:ខាង
លើដែរ តែលោកយល់ថា ពាក្យចេនឡាក្លាយ
មកពីពាក្យ ចិនលា ទៅវិញ។

ចិន+លា›ចិនលា›ចិនឡា›ចេនឡា

លោក ឆត្រា ប្រេមឫឌី តាមទស្សន:
ក្នុងជំពូកទី២នៃសៀវភៅស្តីពីខ្មែរ-មន ក្នុងអត្ថ
បទមួយមានចំណងជើងថា ខ្មែរមកពីណា?
ផ្សាយតាមវិទ្យុជាតិកាលពីខែកុម្ភៈឆ្នាំ១៩៧៣
លោកបានបញ្ចេញយោបល់ថា កាលពី

សម័យបុរាណ ប្រទេសខ្មែរផ្នែកខាងលើហៅថា ជាន់លើ ឯផ្នែកខាងក្រោមហៅថាជាន់ក្រោមឬក្រោមពូជ។

ពាក្យ ជាន់លើ ចិនហៅមិនច្បាស់ក៏ក្លាយទៅជា ចេនឡាះ ជាន់លើ ចេនឡា។

តាមឯកសារចិនបានឱ្យដឹងថា អាណាចក្រចេនឡាស្ថិតនៅនិរតីនៃប្រទេស លិន យី ហើយពីដើមជាសាមន្តរដ្ឋមួយរបស់ហ្វូណន។ មជ្ឈមណ្ឌលរបស់ចេនឡាស្ថិតនៅត្រង់វាលទំនាបភាគកណ្តាលនៃទន្លេមេគង្គ ក្នុងតំបន់បាសាក់នៃប្រទេសឡាវសព្វថ្ងៃ។ ឯចំណែករាជធានីគឺស្ថិតនៅត្រង់ប្រាសាទវត្តភូតែម្តង។

ចាប់តាំងពីរជ្ជកាលព្រះបាទ ឦសានវរ្ម័ន រាជធានីតាំងនៅឦសានបុរៈ(ចិនហៅអ៊ីចូណា)មាន២០០០០គ្រួសារ។ នៅកណ្តាលក្រុងមានសាលធំមួយជាទីដែលព្រះរាជាទ្រង់ប្រទានសវនាការ និងប្រជុំពួកមន្ត្រីសេនាបតី។

ក្រៅពីរាជធានី នៅមានក្រុងចំនួន៣០ទៀត ក្រុងនីមួយៗមានច្រើនពាន់គ្រួសារ ហើយត្រួតត្រាដោយអភិបាលម្នាក់។

ចំពោះការផ្ទេររាជសម្បត្តិ គឺមានតែបុត្រានៃអគ្គមហេសីទេ ទើបអាចឡើងសោយរាជបន្តបាន។ នៅថ្ងៃប្រារព្ធពិធីអភិសេកព្រះរាជាថ្មី គេកាត់ម្រាមដៃ កាត់ចុងច្រមុះនៃក្បត្រាឯទៀតៗ រួចយកទៅឃុំទុកនៅកន្លែងដទៃៗពីគ្នាដោយមិនឱ្យកាន់តំណែងអ្វីសោះឡើយ[1]។

២. សម័យអង្គរ

នៅសម័យអង្គរ ខ្មែរមានឈ្មោះជាមហាអំណាចមួយ នៅអាស៊ីអាគ្នេយ៍។ យ៉ាងណាមិញ អរិយធម៌ខ្មែរបានរីកចម្រើនដល់កម្រិតកំពូលនៅសម័យកាលនោះ ជាពិសេសនៅសតវត្សរ៍ទី១៣។ ភាពរុងរឿងនេះគេអាចសំគាល់បានដោយសារផ្ទៃដីដ៏ធំទូលាយលាតសន្ធឹងសឹងតែអស់ផ្ទៃដីអាស៊ីអាគ្នេយ៍ដីគោកមួយភាគធំ មានប្រាសាទសិលាពាប់ពាន់ប្រកបដោយក្បាច់រចនាគួរឱ្យកោតស្ងប់ស្ងែង ហើយមានផ្ទាំងសិលាចារឹកច្រើនសន្ធឹកសន្ធាប់ជាភាសាសំស្ក្រឹត ភាសាបាលី និងភាសាខ្មែរបុរាណឬជួនកាលមានភាសាទាំងនោះលាយចម្រុះគ្នា មានរូបបដិមាគ្រប់ប្រភេទ និងបុរាណវត្ថុផ្សេងៗទៀត មានបារាយណ៍ ទំនប់ទឹក បណ្ណាល័យ មន្ទីរពេទ្យស្ពាន និងបណ្តាញផ្លូវគមនាគមន៍ខ្វាត់ខ្វែង។ ប៉ុន្តែ ចាប់ពីពាក់កណ្តាលទី១នៃសតវត្សរ៍ទី១៣ ការចុះដុនដាបក៏ចាប់មានបន្តិចម្តងៗ រហូតដល់ត្រូវបោះបង់រាជធានីអង្គរចោលនៅសតវត្សរ៍ទី១៥ដោយព្រះបាទពញាយ៉ាត។

---

[1] ពៅ សារឿន៖ ***ប្រវត្តិស្ថាប័នខ្មែរ*** បោះពុម្ពលើទី១ ឆ្នាំ ២០១៥។

ការគ្រប់គ្រងរដ្ឋត្រូវស្ថិតនៅក្នុងកណ្តាប់ដៃរបស់អភិជនមួយក្រុមតូច។ តំណែងធំៗត្រូវបានទៅពាជវង្សានុវង្ស ឯតំណែងជាបុរោហិត(អ្នកប្រារព្ធពិធីទេវរាជឬ ពាជគ្រូ)ត្រូវបានទៅសមាជិកត្រកូលព្រាហ្មណ៍ដែលនិយមការបន្តតំណែងដោយរាប់ញាតិតាមខ្សែខាងស្រី។

ព្រះរាជាទ្រង់ប្រទានសវនាការ២ដងក្នុងមួយថ្ងៃសម្រាប់ដោះស្រាយរាជកិច្ច។ ពួកនាម៉ឺនឬពួកប្រជារាស្ត្រដែលមានការចូលមកបង្គំគាល់ត្រូវវង់ចាំព្រះអង្គដោយអង្គុយផ្ទាល់ដី។ ពេលដែលព្រះអង្គយាងមកដល់ ទាំងមន្ត្រីទាំងប្រជារាស្ត្រត្រូវលើកដៃប្រណមហើយឱនក្បាលដល់ដី។

នៅក្នុងរដ្ឋបាលកណ្តាលគេឃើញមានមន្ត្រីជាច្រើន មន្ត្រីជាន់ខ្ពស់ខ្លះមានមុខងារជាទីប្រឹក្សា ខ្លះទៀតទទួលបន្ទុកកិច្ចការធំៗនៅក្នុងវាំង ឬកាន់ទ័ព និងឈរត្រួតនៅតាមខេត្តខណ្ឌ ឯមន្ត្រីជាន់ទាបត្រូវបានជ្រើសរើសដោយមន្ត្រីជាន់ខ្ពស់ ហើយមានភារកិច្ចបម្រើពួកនេះ។ សញ្ញាសក្តិគេសម្គាល់ដោយប្រភេទគ្រែស្នែង (មាសឬ ប្រាក់) និងចំនួនក្ងស់(ដងមាសឬដងប្រាក់)។

នៅក្នុងរដ្ឋបាលភូមិភាគ គេឃើញមានមន្ត្រីច្រើនជាន់ច្រើនថ្នាក់ទៀត គឺមានតាំងពីអធិការអាជ្ញាហួង ចៅហ្វាយខេត្ត មេស្រុក មេឃុំ មេភូមិ មេឃ្លាំង មេខ្នង មេត្រួត។ល។ ស្ត្រីក៏មានមុខងារសំខាន់ដែរ ខ្លះធ្វើជាហោរាខ្លះទៀតធ្វើចៅក្រមក្នុងរាជវាំង។ ចំពោះការធ្វើសច្ចាប្រណិធានរបស់មន្ត្រី ថាស្មោះត្រង់ចំពោះព្រះមហាក្សត្រនោះ គេមិនដឹងថា នេះជាវិធានការទូទៅ ឬគ្រាន់តែជាមធ្យោបាយសម្រាប់ចងភ្ជាប់មន្ត្រីទៅនឹងព្រះរាជាកាលណាទ្រង់ឡើយសោយរាជ្យមិនស្របច្បាប់នោះទេ។

ស្ថាប័នដែលជាប់ទៅនឹងព្រះមហាក្សត្រ ឬអំណាចនីតិប្រតិបត្តិ មានការបង្កើតក្រុមនាម៉ឺន មន្ត្រី ការរៀបចំសង្គម ការបែងចែក រៀបចំទឹកដី ភូមិស្រុក និងការបែងចែកធនធានដែលបង្ហាញឱ្យយើងឃើញកាន់តែច្បាស់នូវការគិតគូររបស់ថ្នាក់ដឹកនាំនៅសម័យនោះ[២]។

៣. ក្រោយសម័យអង្គរ(ចតុម្មុខលង្វែក ឧត្តុង្គ)

គេសង្កេតឃញថា មានវិបត្តិក្នុងរាជវង្សជាញឹកញាប់ ជាហេតុបណ្តាលឱ្យចម្បាំងក្នុងស្រុក គឺចម្បាំងគ្នាឯង៖ ចម្បាំងរវាងស្រីរាជា-ស្រីសុរិយោទ័យ-ធម្មរាជា អស់រយៈពេល១០ឆ្នាំ(១៤៧៥-១៤៨៥) ចម្បាំងរវាងស្រីសុគន្ធបទនិងស្តេចកន(១៥០៩-១៥១២) និងចម្បាំងរវាងព្រះបាទចន្ទរាជានិងស្តេចកន(១៥១៦-១៥២៥) ជាដើម។

[២] រាជបណ្ឌិត្យសភាកម្ពុជា៖ ***ទស្សនវិជ្ជាខ្មែរសម័យអង្គរ*** ឆ្នាំ២០០៨។

មូលហេតុនៃចម្បាំងទាំងនេះគឺបណ្តាលមកពីការគិតប្រយោជន៍ផ្ទាល់ខ្លួនច្រើនជាងប្រយោជន៍រួម។

យ៉ាងណាមិញ ព្រះស្រីសុរិយោទ័យ ច្បាំងនឹងព្រះស្រីរាជា មកតែពីគិតប្រយោជន៍ផ្ទាល់ខ្លួន គឺសិទ្ធិត្រូវបានសោយរាជ្យស្នងព្រះបិតា ឯព្រះបាទស្រីសុគន្ធបទ រកកលសម្ងាប់ស្តេចកនមកតែពីខ្វាចមន្ត្រីរូបនេះដណ្តើមរាជសម្បត្តិ។ ចំណែកព្រះសន្តាទី១ បានដាក់រាជ្យថ្វាយទៅបុត្រដែលសុទ្ធតែមានវ័យនៅក្មេងៗ ព្រោះតែខ្វាចរាជសម្បត្តិបានទៅព្រះអនុជស្រីសុរិយោពណ៌ ដែលមានសមត្ថភាពនិងមានប្រជាប្រិយភាពជាង។

លុះជម្ងោះកើតឡើងហើយអ្នកដឹកនាំជាតិមិននិយមដោះស្រាយជាតិតាមសម្រួលទេបែរជាសុខចិត្តទៅពឹងពាក់បរទេសជិតខាងចូលមកផ្សះផ្សារវិវាទផ្ទៃក្នុងរបស់ខ្មែរទៅវិញ។

នៅសម័យនេះ ប្រទេសខ្មែរលែងជាមហាអំណាចខាងទឹកដីទៀតហើយ។ ស្រុកសុខោទ័យ ស្រុកស្រីអយុធ្យា ស្រុកលពបុរី ស្រុកគោត្របុរ ត្រូវបាត់បង់អស់ទៅហើយ ឯប្រទេសសាមន្តរដ្ឋ ដូចជាចម្ប៉ា អាណ្ណាម ជ្វាមន ក៏លែងមានទៀតដែរ។ ព្រំដែនខាងជើងរបស់ខ្មែរធ្លាក់មកត្រឹមទន្លេមូល ឬនៅលើនេះបន្តិចជាប់នឹងប្រទេសលាវ។ ព្រំដែនខាងលិចទល់នឹងបស្ចិមបុរី និងរយ៉ង ខាងពាយ័ព្យទល់នឹងស្រុកនាងរេនគរវាជ ខាងកើតទល់នឹងប្រទេសចម្ប៉ា ខាងត្បូងទល់នឹងសមុទ្រចិន និងឈូងសមុទ្រសៀម។

បើតាមរាជពង្សាវតារព្រះរាជាណាចក្រខ្មែរសម័យនោះមានប្រមាណជា៧០ខេត្ត គឺ៖ លង្វែក អម្រិន្ទបូរ ក្រគរ គ្រង ពោធិ៍សាត់ បាត់ដំបង ឫស្សីសាញ តាមសីមា មង្គលបូរី រយ៉ង សុរិន្ទ សិង្គារ កំពង់សៀម ស្ទឹងត្រែង ជើងព្រៃ គោកសេះ អន្ទង់រាជ ព្រំទេព ព្រៃក្តី ស្មោង ជីក្រែង រលួស សៀមរាប កំពង់ស្វាយ ម្ទឹព្រៃ ជាំក្សាន្ត ស្នោត ទឹកជោរ សៀមបូក សម្បុកសម្បរណ៌ ក្រចេះ ឆ្នូង ត្បូង ទទឹងថ្ងៃ ព្រៃវែង ត្បូងឃ្មុំ រំដួល ស្វាយទាប រោងដំរី ព្រៃនគរ លង់ហោ ជើងបាដែន សំរោងទង បាទី លើកដែក កំពត កំពង់សោម ទឹកឃ្មៅ ពាមមេសា ព្រះត្រពាំងក្រមួនសដូនណៅ។ល។

ខេត្តនីមួយៗត្រូវបែងចែកជាស្រុក ហើយស្រុកនីមួយៗត្រូវបែងចែកជាឃុំ និងភូមិជាច្រើនទៀត។ ប៉ុន្តែ ខេត្តជាច្រើន ត្រូវបានប្រមូលផ្តុំជាតំបន់ធំៗដែលគេឱ្យឈ្មោះថា ដែនដី។

ដោយហេតុថា ព្រះរាជាជាប្រភពនៃអំណាចទាំងឡាយ ហើយពួកបរិវាររបស់ព្រះអង្គសុទ្ធតែជារាជវង្សានុវង្ស និងមន្ត្រីជាន់ខ្ពស់ផងនោះ គេអាចយល់បានថា ពួកបរិវារនេះហើយជាអ្នកញុំាងឱ្យម៉ាស៊ីនរដ្ឋបាលកណ្តាលអាចប្រព្រឹត្តទៅបាន។ ដូចយើងបានរៀបរាប់រួចមកហើយក្នុងវគ្គនិយាយពីព្រះរាជបរិវារឃើញថា បន្ទាប់ពីស្តេចទ្រង់រាជ្យមាន

ឧកយោ ភជ ឧបភជឬមហាឧបភជ ព្រះវរភជ មាតាឬព្រះវរភជអយ្យកា ចៅហ្វ៊ាទឡះ និងមន្ត្រីជាន់ខ្ពស់៤រូបដែលគេនិយមហៅថា ចតុស្តម្ភ គឺ៖

-ឧកញ៉ាយមភជ(រដ្ឋមន្ត្រីក្រសួងយុត្តិធម៌)

-ឧកញ៉ាក្រឡាហោម(រដ្ឋមន្ត្រីក្រសួងទ័ពជើងទឹក)

-ឧកញ៉ាវាំង(រដ្ឋមន្ត្រីក្រសួងព្រះបរមភជវាំង)

-ឧកញ៉ាចក្រី(រដ្ឋមន្ត្រីក្រសួងទ័ពជើងគោក)

ចៅហ្វ៊ាទឡះ និងមន្ត្រីជាន់ខ្ពស់ទាំង៤រូបនេះ ប្រៀបបាននឹងគណៈរដ្ឋមន្ត្រីសព្វថ្ងៃ ហើយដែលពីដើមគេនិយមហៅថា សេនាបតី។

មន្ត្រីជាន់ខ្ពស់ទាំង៥រូបនេះ គេហៅថា មន្ត្រីសម្រាប់ឯក គឺជាមន្ត្រីដែលត្រូវឡើងទៅព្រះមហាក្សត្រ។មន្ត្រីទាំងនេះមានមុខងារញ៉ាំងឱ្យរដ្ឋបាលកណ្តាលអាចប្រព្រឹត្តទៅផង ហើយមានអំណាចត្រួតត្រាលើខេត្តខ្លះផងដែរ។ ក្រៅពីនេះមាន មន្ត្រីសម្រាប់ទោ ត្រូវឡើងទៅព្រះឧកយោភជ។ មន្ត្រីសម្រាប់ត្រី ត្រូវឡើងទៅព្រះឧបភជឬមហាឧបភជ។ មន្ត្រីសម្រាប់ចត្វា ត្រូវឡើងទៅព្រះវរភជមាតាឬព្រះវរភជអយ្យកា។

មន្ត្រីទាំង៤សម្រាប់នេះ លើកលែងចៅហ្វ៊ាទឡះចេញ ដែលមានឋានន្តរសក្តិជាសម្តេចចៅពញា សុទ្ធតែមានឋានន្តរសក្តិជាឧកញ៉ាសក្តិ១០ហ៊ូពាន់(ហ៊ូពាន់៖ ពាក្យសៀមមានន័យថា ក្បាលពាន់ គឺ ទ័ព១០០០នាក់ដែលនៅក្រោមបង្គាប់របស់មន្ត្រីណាម្នាក់)។

ចំណែកឯខ្ញុំពជការដែលមិនទាន់បានទទួលយសសក្តិនៅឡើយទេនោះឱ្យហៅថា នាយ។

ចំពោះការបែងចែកអាណាចក្រវិញ យើងបានឃើញថា ទឹកដីខ្មែរត្រូវចែកជាប្រមាណ៧០ខេត្ត ហើយខេត្តទាំងនោះត្រូវប្រមូលផ្តុំជាតំបន់ដែលគេហៅថា ដែនដី។ ក្នុងតំបន់ឬដែនដីនីមួយៗមានស្តេចត្រាញ់មួយអង្គឈរត្រួត។ ស្តេចត្រាញ់មួយអង្គៗមានទាំងគ្រប់គ្រងតំបន់ផង ហើយមានទាំងគ្រប់គ្រងខេត្តរបស់ខ្លួនផ្ទាល់ផង។ បើតាមឯកសារពជពង្សាវតារខ្មែរ ក្នុងរជ្ជកាលព្រះបាទធម្មពជាទី១ មានការតែងតាំងស្តេចត្រាញ់៥អង្គគឺ៖

-ពញាតេជោ ចៅហ្វាយស្រុកខេត្តកំពង់ស្វាយ

-ពញាសួគ៌ាលោក ចៅហ្វាយស្រុកខេត្តពោធិ៍សាត់

-ពញាស្រីធម្មតេជោ ចៅហ្វាយស្រុកខេត្តបាភ្នំ

-ពញាពិស្ណុលោក ចៅហ្វាយស្រុកខេត្តទ្រាំង

-ពញាអរជូន ចៅហ្វាយស្រុកខេត្តត្បូងឃ្មុំ

ដូចបានពោលរួចខាងលើនេះ យើងឃើញថា ក្នុងខេត្តនីមួយៗមានមន្ត្រីជាន់ខ្ពស់

ម្នាក់ឈរត្រួតត្រា។ មន្ត្រីនេះគេនិយមហៅថា ចៅហ្វាយស្រុក។ ឧទាហរណ៍ មន្ត្រីឈរត្រួតត្រាខេត្តទ្រាំង គេហៅថា ចៅហ្វាយស្រុកខេត្តទ្រាំង ជាដើម[៣]។

៤. សម័យចំនើប

៤.១-សម័យអាណានិគមនិយមបារាំង

ព្រះរាជាដែលមានទំនាក់ទំនងជាមួយបារាំងមុនគេគឺ អង្គឌួង ឆ្នាំ១៨៥៤ ប៉ុន្តែទំនាក់ទំនងនេះត្រូវទទួលបរាជ័យពីព្រោះមានការពារាំងយ៉ាងខ្លាំងពីសំណាក់ព្រះចៅសៀម។ មុនឡើងសោយរាជ្យ ព្រះបាទនរោត្តមមានព្រះនាមថា អង្គច្រឡឹង។ នៅដើមរជ្ជកាលព្រះបាទនរោត្តមគេឃើញមានការបះបោរជាច្រើនកើតឡើងដើម្បីប្រឆាំងជាមួយសៀមនិងយួន។ ដូច្នេះហើយដើម្បីរំដោះខ្លួនចេញពីអំណាចនៃការឈ្លានពានរបស់សៀមនិងយួន ព្រះបាទនរោត្តម បានសម្រេចព្រះទ័យធ្វើទំនាក់ទំនងជាមួយបារាំងតាមរយៈសន្ធិសញ្ញាមួយនៅឆ្នាំ១៨៦៣។

ស្ថាប័នរដ្ឋបាលដែនដីត្រូវបានបញ្ជាក់នៅក្នុងកំណែទម្រង់ និងសន្ធិសញ្ញាដូចខាងក្រោម៖

-សន្ធិសញ្ញាបារាំង-ខ្មែរ ថ្ងៃទី១១ ខែសីហា ឆ្នាំ១៨៦៣ ចែងថា៖ ជនជាតិបារាំងមានសិទ្ធិសេរីភាពពេញលេញក្នុងការទៅមកនិងរស់នៅលើទឹកដីខ្មែរដោយគ្រាន់តែសុំការអនុញ្ញាតពីរ៉េស៊ីដង់បារាំងប៉ុណ្ណោះ។

កប៉ាល់ពាណិជ្ជកម្មបារាំងមានសេរីភាពពេញលេញក្នុងការធ្វើជំនួញលើទឹកដីខ្មែរដោយមិនបាច់បង់ពន្ធគយអ្វីទាំងអស់ លើកលែងតែអាកៀនចេញ និងជួយខ្មែរក្នុងការហូតពន្ធព្រមទាំងផ្តល់ការងាយស្រួលក្នុងការធ្វើទំនាក់ទំនងខាងសមុទ្រ។

ព្រះរាជាខ្មែរបានផ្តល់ដីសម្បទាននៅម្តុំជ្រោយចង្វាឱ្យទៅបារាំងដើម្បីស្ថាបនាជាឃ្លាំងធ្យូង ឃ្លាំងស្បៀងនិងកសាងបន្ទាយសម្រាប់ទាហានបារាំងទៀតផង។

ព្រះរាជាខ្មែរបានផ្តល់សិទ្ធិឱ្យអាជ្ញាធរបារាំងកាប់ឈើក្នុងព្រៃទាំងឡាយតាមចិត្តយកមកធ្វើកប៉ាល់បារាំង។

-កំណែទម្រង់ព្រះរាជបញ្ញត្តិ ថ្ងៃទី១៥ ខែមករា ឆ្នាំ១៨៧៧

កំណែទម្រង់នេះបានចែងនូវចំណុចសំខាន់ៗដែលទាក់ទងជាមួយនឹងស្ថាប័នរដ្ឋបាលដែនដី មានដូចជា៖

នៅក្នុងបញ្ញត្តិទាក់ទងនឹងរាជវង្សានុវង្ស បានចែងថា ព្រះអង្គទ្រង់បានសន្យាថានឹងពន្យារយៈពេលនៃការជួលដីសម្រាប់ធ្វើស្រែចម្ការឱ្យបានវែងជាងមុន។

នៅក្នុងបញ្ញត្តិទាក់ទងនឹងរដ្ឋបាលបានចែងថា ទឹកដីខ្មែរទាំងមូលត្រូវបែងចែកជា មណ្ឌលរដ្ឋបាលធំៗ៥ (ហៅថាកំណាន់

[៣] ពៅ សារឿន៖ ***ប្រវត្តិស្ថាប័នខ្មែរ*** ដ.ឯ.ម.។

ខេត្ត)ស្របតាមចំនួននៃរដ្ឋមន្ត្រីទាំង៥ដែលត្រូវគ្រប់គ្រងមណ្ឌលនីមួយៗ។

ចំនួនខេត្ត ត្រូវបង្រួមពី៥៧ខេត្តមកនៅត្រឹម៥០ខេត្តវិញ។

អំណឹះតទៅ ពួកមន្ត្រីត្រូវទទួលប្រាក់បៀវត្សដែលមានកម្រិតជាក់លាក់ហើយត្រូវហាមឃាត់ការធ្វើជំនួញ។

ពួកឧកញ៉ាហួង ដែលមានការៈទៅត្រួតពិនិត្យមើលតាមខេត្តនានាត្រូវលប់ចោលព្រោះពួកនេះបានទាញយកប្រយោជន៍ពីព្រះរាជផង និងពីប្រជារាស្ត្រផង។

ប្រជារាស្ត្រមានសិទ្ធិជ្រើសរើសមេស្រុក មេឃុំ និងជំទប់របស់ខ្លួនដោយខ្លួនឯង។

នៅក្នុងបញ្ញត្តិទាក់ទងនឹងពន្ធដារ បានចែងអំពីកំណែនឱ្យធ្វើការជូនរដ្ឋត្រូវរក្សាទុកឱ្យនៅដដែល ប៉ុន្តែថេរវេលាត្រូវបន្ថយមកនៅត្រឹម៩០ថ្ងៃក្នុង១ឆ្នាំ ហើយដែលគេអាចយកប្រាក់ទៅលស់បាន។

នៅក្នុងបញ្ញត្តិទាក់ទងនឹងទាសភាព គេបានកំណត់ថា ពួកទាសាទាសីដែលត្រូវទៅនៅបម្រើម្ចាស់បំណុលអស់មួយជីវិតពីមុននោះ អាចលស់ខ្លួនឱ្យរួចផុតពីខ្ញុំគេបាន។ ចំពោះការលក់ដូរពួកមនុស្សព្រៃនិងកូនក្មេងត្រូវហាមឃាត់។

-អនុសញ្ញាបារាំង-ខ្មែរថ្ងៃទី១៧ខែមិថុនាឆ្នាំ១៨៨៤ មាត្រា៣ ចែងថា ក្នុងការគ្រប់គ្រងខេត្តនិងក្រសួងនានា មន្ត្រីខ្មែរត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យរបស់អាជ្ញាធរ បារាំង។

មាត្រា៤-៥ ចែងថា រដ្ឋាភិបាលបារាំងមានសិទ្ធិតែងតាំងរ៉េស៊ីដង់និងរ៉េស៊ីដង់រងបារាំងឱ្យត្រួតពិនិត្យមន្ត្រីខ្មែរនៅតាមបណ្តាខេត្តនានា និងនៅគ្រប់ទីកន្លែងដែលបារាំងយល់ថាគួរដាក់។ រ៉េស៊ីដង់មន្ត្រីបារាំងទាំងអស់នោះត្រូវស្ថិតនៅក្រោមឱវាទរបស់រ៉េស៊ីដង់ជាន់ខ្ពស់បារាំងម្នាក់ដែលអាចសុំធ្វើសវនាការជាមួយព្រះរាជាបានជានិច្ច។

មាត្រា៩ ចែងថា ដីធ្លីក្នុងព្រះរាជាណាចក្រកម្ពុជាទាំងមូល ពីដើមជាកម្មសិទ្ធិផ្តាច់មុខរបស់ព្រះរាជា ឥឡូវពួកអាជ្ញាធរ បារាំងនិងអាជ្ញាធរខ្មែរ អាចរៀបចំឱ្យមាន កម្មសិទ្ធិឯកជនលើដីធ្លីនេះបាន។

មាត្រា១០ ចែងថា ទីក្រុងភ្នំពេញត្រូវគ្រប់គ្រងដោយមន្ត្រីបារាំងម្នាក់ និងអមដោយក្រុមប្រឹក្សាមួយដែលមានសមាជិក១២នាក់ ក្នុងនោះមានជនជាតិបារាំង៦រូប ជនបរទេស៣នាក់និងជនជាតិខ្មែរ៣នាក់។

ប៉ុន្តែក្រោយមក ដោយមានការតស៊ូធ្វើការបះបោរ ពីសំណាក់ព្រះរាជា ពួកនាម៉ឺនមន្ត្រី អ្នកស្នេហាជាតិ និងប្រជារាស្ត្រខ្មែរ រដ្ឋាភិបាលបារាំងបានយល់ព្រមប្រគល់អំណាចឱ្យមកខ្មែរវិញដូចជា៖

អាជ្ញាធរបារាំងបានយល់ព្រមប្រគល់បណ្តាខេត្តនានាឱ្យមកខ្មែរវិញ លើកលែងតែខេត្ត៤ដែលត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់អាជ្ញាធរបារាំងដដែលគឺ ខេត្តកំពត ខេត្តកំពង់ធំ ខេត្តក្រចេះ និងខេត្តពោធិ៍សាត់

ហើយចៅហ្វាយខេត្តទាំងនោះលែងលើកសួយសារអាករថ្វាយទៅឧកញ៉ាណាមួយទៀតហើយគឺលើកឱ្យអាជ្ញាធរ បារាំងផ្ទាល់តែម្តង។

ចំណែកខេត្តដទៃទៀតត្រូវគ្រប់គ្រងដោយមន្ត្រីខ្មែរ ហើយចៅហ្វាយខេត្តទាំងនោះត្រូវលើកសួយសារអាករទៅថ្វាយព្រះរាជា។

៤.២-សម័យសង្គមរាស្ត្រនិយម

កាលណាគេនិយាយពីសង្គមរាស្ត្រនិយម គេតែងនឹកឃើញដល់ស្តាបនិកម្នាក់ដែលពុំអាចបំភ្លេចបាននោះគឺ សម្តេចព្រះនរោត្តម សីហនុ។ ព្រះអង្គគឺជាព្រះមហាក្សត្រដែលមានលក្ខណសម្បត្តិប្រពៃ។ ទ្រង់មានសិទ្ធិដាច់ខាតលើការសម្រេចចិត្តផ្សេងៗ ហើយព្រះអង្គក៏ជាព្រះមហាក្សត្រដែលយករបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ និងយកច្បាប់ជាធំក្នុងការគ្រប់គ្រងប្រទេសជាតិ។

នៅឆ្នាំ១៩៤៩ ទ្រង់បានទាមទារឱ្យបារាំងលុបចោលសន្ធិសញ្ញាអាណាព្យាបាលលើប្រទេសកម្ពុជាដែលបានចុះហត្ថលេខានាឆ្នាំ១៨៦៣ និងឆ្នាំ១៨៨៤ ហើយព្រះអង្គបានឡាយព្រះហស្តលេខាលើសន្ធិសញ្ញាឯករាជ្យដែលប្រទេសបារាំងព្រមទទួលស្គាល់តាមផ្លូវច្បាប់នូវឯករាជ្យរបស់ប្រទេសកម្ពុជា និងការលុបចោលសន្ធិសញ្ញាអាណាព្យាបាលលើប្រទេសកម្ពុជាជាផ្លូវការ។ ពីឆ្នាំ១៩៥២ដល់ឆ្នាំ១៩៥៣ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុ បានយាងបំពេញព្រះរាជបូជនីយកិច្ចទាមទារឯករាជ្យមួយរយភាគរយជូនជាតិមាតុភូមិ ហើយនៅថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣ ព្រះរាជាណាចក្រកម្ពុជា បានទទួលឯករាជ្យទាំងស្រុងពីសាធារណរដ្ឋបារាំង ដែលនាំឱ្យប្រជារាស្ត្រខ្មែរទាំងមូល ថ្វាយព្រះកិត្តិនាមព្រះអង្គថាជា ព្រះមហាវីរបុត្រជាតិ និងព្រះបិតាឯករាជ្យជាតិ។

នៅសម័យនោះ ការបែងចែកនិងការគ្រប់គ្រងរដ្ឋ ត្រូវបែងចែកដូចខាងក្រោម៖

ក-ការបែងចែកដែនដី

ព្រះរាជាណាចក្រកម្ពុជាទាំងមូល ត្រូវបែងចែកជា៖

-ភូមិភាគ មានចំនួន៨ភូមិភាគ។

ភូមិភាគនីមួយៗមានខេត្តមួយឬច្រើនអាស្រ័យតាមស្ថានភាពជាក់ស្តែង។ ប៉ុន្តែភូមិភាគទាំងនេះមិនមែនជាមណ្ឌលរដ្ឋបាលទេ គឺគ្រាន់តែជាមណ្ឌលបោះឆ្នោតប៉ុណ្ណោះ។ មណ្ឌលបោះឆ្នោតនីមួយៗត្រូវជ្រើសរើសតំណាងម្នាក់ ដើម្បីធ្វើជាសមាជិកនៃក្រុមប្រឹក្សាព្រះរាជអាណាចក្រ។

-ខេត្ត ត្រូវបែងចែកជាស្រុក។

-ស្រុក ត្រូវបែងចែកជាឃុំ។

ខ-ការគ្រប់គ្រងរដ្ឋបាលដែនដី

នៅក្នុងប្រទេសកម្ពុជានាសម័យនោះ យើងយកគំរូចាត់តាំងដែនដីតាមបែបប្រទេសបារាំង គឺ រមជ្ឈការនៅថ្នាក់ខេត្តនិងឃុំ និងវិសហមជ្ឈការពីថ្នាក់កណ្តាលទៅថ្នាក់តំបន់។

នៅតាមបណ្តាខេត្តនិងរាជធានី មានការគ្រប់គ្រងតាមបែបប្រជាធិបតេយ្យ ពោលគឺមាន៖

+សភាប្រជាជនប្រចាំខេត្ត និងប្រចាំរាជធានី

-លក្ខខណ្ឌនៃសមាជិក

សមាជិកនៃសភានេះត្រូវជ្រើសរើសតាមវិធីបោះឆ្នោតជាសកល និងចំពោះ។

អ្នកដែលមានសិទ្ធិបោះឆ្នោតគឺពលរដ្ឋខ្មែរទាំងពីរភេទដែលមានអាយុយ៉ាងតិច២០ឆ្នាំបរិបូណ៌ ហើយមានលំនៅនៅក្នុងស្រុក ឬនៅក្នុងសង្កាត់នោះ។

សភាខាងលើត្រូវប្រជុំនៅទីប្រជុំខេត្ត ឬនៅក្នុងរាជធានីក្នុងមន្ទីរមួយជាក់លាក់។

អ្នកដែលមានសិទ្ធិឈរឈ្មោះជាបេក្ខជនឱ្យគេបោះឆ្នោតជ្រើសតាំង ជាសមាជិកសភាប្រជារាស្ត្របាននោះគឺពលរដ្ឋខ្មែរទាំងពីរភេទដែលមានអាយុយ៉ាងតិច២៥ឆ្នាំបរិបូណ៌ឡើងទៅ[៤]។

-អាណត្តិនៃសមាជិក

សមាជិកសភាប្រជារាស្ត្រ ត្រូវជ្រើសតាំងសម្រាប់អាណត្តិពីរឆ្នាំ។

អាណត្តិនេះនឹងបដិសេធចោលមុនបាន។

-សិទ្ធិនិងការកិច្ច

សមាជិកសភាប្រជារាស្ត្រខេត្ត និងរាជធានី ត្រូវបំពេញលក្ខណសម្បត្តិដូចតំណាងរាស្ត្ររដ្ឋសភាដែរ ហើយត្រូវមានសិទ្ធិនិងអភ័យឯកសិទ្ធិដូចរដ្ឋសភាដែរ ប៉ុន្តែត្រូវទទួលប្រាក់បំណាច់តិចជាងប្រាក់បំណាច់របស់សមាជិករដ្ឋសភា។ ប្រាក់បំណាច់នេះត្រូវកំណត់តាមច្បាប់ដោយប្រៀបស្មើទៅនឹងប្រាក់បៀវត្សអ្នករាជការថ្នាក់ណាមួយនៃក្របខ័ណ្ឌបន្ទាប់។

សភាប្រជារាស្ត្រខេត្ត និងរាជធានី ត្រូវមានការបញ្ចេញមតិ ជូនយោបល់ ចំពោះការអនុម័តនូវថវិកាជាតិ សេចក្តីព្រាងនានារបស់រដ្ឋាភិបាល។ ឯសន្ធិសញ្ញាដែលត្រូវជាមួយបរទេស ក៏ត្រូវដាក់ឱ្យសភានេះជូនយោបល់ផងដែរ។

សភាប្រជារាស្ត្រខេត្ត និងរាជធានី ត្រូវអនុម័តចំពោះថវិកាខេត្តនិងរាជធានីព្រមទាំងថវិកាឃុំដែលនៅក្នុងដែនចំណុះរបស់ខ្លួន ហើយអនុម័តចំពោះបញ្ជីស្រង់ប្រាក់ចំណូលចំណាយផ្តាច់ឆ្នាំនៃសមូហភាព ទាំងនេះ។

សភាទាំងនេះ មានសិទ្ធិសម្រេចបង្កើតឬលុបពន្ធអាករសម្រាប់ខេត្ត ឬសម្រាប់រាជធានីក្នុងដែនចំណុះរបស់របស់ខ្លួនក្នុងក្របខ័ណ្ឌនៃច្បាប់ទាំងឡាយ ដែលរដ្ឋសភាបានអនុម័តហើយ។

សភាប្រជារាស្ត្រខេត្ត និងរាជធានីមានសិទ្ធិធ្វើញត្តិជូនដល់រដ្ឋសភាឬរដ្ឋាភិបាល

---

[៤] ហួត វុទ្ធី៖ **ប្រជុំរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាពីឆ្នាំ ១៩៦៣-២០០៧៖** ភ្នំពេញ ឆ្នាំ២០០៧។

អំពីការចាត់ចែងនៃរាជការសាធារណៈក្នុងដែនការជាតិ។

សភាប្រជារាស្ត្រខេត្ត និងរាជធានី ត្រូវតាមពិនិត្យមើលរាជការចាត់ចែងការសាធារណៈក្នុងខេត្ត ឬរាជធានី។

អំពីរាជធានី

ក្រុងភ្នំពេញ ជារាជធានីនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវគ្រប់គ្រងដោយរាជប្រតិភូក្រុង។

ក្រុងភ្នំពេញ ត្រូវបែងចែកជា៧សង្កាត់ ដែលគ្រប់គ្រងដោយប្រធានសង្កាត់ ឬចៅសង្កាត់ម្នាក់ តែងតាំងដោយប្រកាសរបស់ប្រតិភូក្រុងភ្នំពេញ។

អំពីខេត្ត

ខេត្ត បង្កើតជាសមូហភាពដែនដីពីព្រោះមានសភាប្រជារាស្ត្រប្រចាំខេត្តក្នុងការកំណត់បញ្ញត្តិនានាក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ហើយត្រូវគ្រប់គ្រងដោយទេសាភិបាល ឬចៅហ្វាយខេត្តនិងមានប្រឈួយខេត្តជាជំនួយការ។

សមាជិកសភាប្រជារាស្ត្រខេត្ត មានអាណត្តិ៦ឆ្នាំ ដោយការបោះឆ្នោតជាសកលនិងចំពោះ។

ខេត្ត ចែកជាស្រុកដែលគ្រប់គ្រងដោយប្រធានស្រុកឬចៅហ្វាយស្រុកនិងបាឡាត់ស្រុកជាជំនួយការ។

អំពីឃុំ

ឃុំ មានលក្ខណៈជានីតិបុគ្គលក្នុងន័យនេះឃុំមានសិទ្ធិកម្មសិទ្ធិលើទ្រព្យសម្បត្តិរបស់ឃុំទាំងអស់ និងសិទ្ធិស្ម័យសម្រេចនៅក្នុងដែនដីរបស់ខ្លួនតាមអំណាចច្បាប់ជាធរមាន។

ចំណែកការគ្រប់គ្រងវិញ ឃុំបានរៀបចំអង្គការសមូហភាពមួយសម្រាប់សម្រេចកិច្ចការនានាក្នុងដែនដីឃុំ ដែលគេហៅថា ក្រុមប្រឹក្សាឃុំ។

សមាជិកក្រុមប្រឹក្សានេះមានអាណត្តិ ៤ឆ្នាំ ជ្រើសតាំងដោយការបោះឆ្នោតជាសកលនិងចំពោះ។

ក្រុមប្រឹក្សាឃុំ មានភារកិច្ចកំណត់ទិសដៅ និងត្រួតពិនិត្យសកម្មភាពរបស់ឃុំ។

ចំណែកសកម្មភាពរបស់ឃុំ ដឹកនាំដោយមេឃុំដែលមានតួនាទីជាតំណាងឱ្យរដ្ឋផង និងតំណាងឱ្យសមូហភាពដែនដីផង។

៤.៣-សម័យសាធារណរដ្ឋខ្មែរ

រដ្ឋប្រហាររបស់ឧត្តមសេនីយ៍ លន់ នល់ បានចាប់ផ្តើមឡើងនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ ១៩៧០ ហើយនៅពេលនោះ សម្តេចព្រះនរោត្តម សីហនុ ត្រូវបានក្រុមប្រឹក្សាព្រះរាជាណាចក្រនិងសភាជាតិ ធ្វើការដកសេចក្តីទុកចិត្ត។ នៅក្រោយធ្វើរដ្ឋប្រហារមួយថ្ងៃ ក្រសួងការបរទេសសហរដ្ឋអាម៉េរិក បានធ្វើសេចក្តីថ្លែងការណ៍ស្តីពីការទទួលស្គាល់អំណាចរបស់ឧត្តមសេនីយ៍ លន់ នល់ និងសិរិមតៈ ជាអ្នកដឹកនាំ។

ចាប់តាំងពីរដ្ឋាភិបាលថ្មីបង្កើតឡើងរបបគ្រប់គ្រងរដ្ឋត្រូវបានផ្លាស់ប្តូរពីរបបរាជានិយម មករបបសាធារណរដ្ឋខ្មែរ ដែលធ្វើឱ្យប្រជារាស្ត្រមួយចំនួនមានក្តីសង្ឃឹម ដូចជាការធ្វើបដិវត្តន៍ផ្តួលរំលំរបបរាជានិយមនៅប្រទេសបារាំងនាឆ្នាំ១៧៨៩។ របបសាធារណរដ្ឋខ្មែរ នេះត្រូវបានបង្កើតឡើងស្របច្បាប់ ព្រោះមានការបោះឆ្នោតជាសម្ងាត់នៅថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៧០ យោងតាមច្បាប់នៃការបោះឆ្នោតដែលជាច្បាប់មួយអាស្រ័យរដ្ឋធម្មនុញ្ញ ដោយបញ្ញត្តិថា ការប្រកាសនេះនឹងប្រព្រឹត្តទៅនៅថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧០។

បន្ទាប់ពីមានភាពរីកចម្រើនយ៉ាងធាប់រហ័សលើគ្រប់វិស័យនាសម័យសង្គមរាស្ត្រនិយម នៅឆ្នាំ១៩៥៥ ប្រាក់ចំណូលរបស់ប្រជាពលរដ្ឋម្នាក់ៗជាមធ្យមមានចំនួន១៦៩ដុល្លាអាម៉េរិកក្នុងមួយឆ្នាំ បានចាប់ផ្តើមមានឱនភាពបន្តិចម្តងៗដោយសារស្ថានភាពនយោបាយ និងការគ្រប់គ្រងរដ្ឋពុំបានល្អ រហូតធ្វើឱ្យប្រាក់ចំណូលរបស់ប្រជាពលរដ្ឋម្នាក់ៗជាមធ្យមធ្លាក់មកនៅត្រឹម១៣២ដុល្លាអាម៉េរិកក្នុងមួយឆ្នាំ។

ដោយសារតែនិន្នាការនយោបាយងាកទៅរកលទ្ធិកុម្មុយនីស្តបានធ្វើឱ្យថ្នាក់ដឹកនាំជាតិផ្លាស់ប្តូរទំនាក់ទំនងពីប្រទេសសេរីមកប្រទេសសមាជិកលទ្ធិកុម្មុយនីស្តវិញ គឺនៅខែវិច្ឆិកា ឆ្នាំ១៩៦៣ កម្ពុជាបានបដិសេធជំនួយរបស់សហរដ្ឋអាម៉េរិក ហើយទទួលជំនួយសព្វាវុធពីចិនវិញ។ រយៈពេលនេះហើយដែលធ្វើឱ្យការនាំចេញនាំចូលរបស់កម្ពុជាដំណើរការតែក្នុងកម្រិតជាតិប៉ុណ្ណោះ ឯធនាគារឯកជនមួយភាគធំត្រូវបិទទ្វារ។ ទាំងនេះហើយដែលធ្វើឱ្យប្រាក់ចំណូលជាតិទទួលការបាត់បង់យ៉ាងច្រើនៗចំណែកស្ថានភាពនយោបាយក្នុងប្រទេស មានសង្គ្រាមស៊ីវិលកើតឡើងពាសពេញផ្ទៃប្រទេសធ្វើឱ្យប្រជាពលរដ្ឋរងការលំបាកយ៉ាងខ្លាំង។

ដោយសារប្រទេសមានសង្គ្រាមស៊ីវិលពាសពេញផ្ទៃប្រទេស ជាហេតុនាំឱ្យមានការបែងចែកស្ទើរតែគ្រប់ផ្នែកនៃការគ្រប់គ្រងរដ្ឋតាមលក្ខណៈបែបយោធានិយម ដូចជា៖

ក-ផ្នែកយោធា បានចែកទៅជា៣ គឺ៖

-កងទ័ពអាកាស មានមូលដ្ឋានសំខាន់នៅពោធិ៍ចិនតុង និងខេត្តបាត់ដំបង។

-កងទ័ពជើងទឹក មានទីតាំងនៅតាមបណ្តោយទន្លេមេគង្គ ទន្លេសាប និងនៅវាមៗ។

-កងទ័ពជើងគោក

ប្រទេសកម្ពុជាទាំងមូលត្រូវបានបែងចែកទៅជា៦ភូមិភាគ៖

១-យោធភូមិភាគពិសេស៖ ខេត្តកណ្តាល និងរដ្ឋធានីភ្នំពេញ។

២-យោធភូមិភាគទី១៖ ខេត្តកំពង់ចាម ស្វាយរៀង និងព្រៃវែង។

៣-យោធភូមិភាគទី២៖ ខេត្តកំពង់ស្ពឺ តាកែវ កំពត កោះកុង រួមទាំងខេត្តបង្កើតថ្មីនៅឆ្នាំ១៩៧២ គឺ ត្រាំខ្នារ និងគិរីរម្យ។

៤-យោធភូមិភាគទី៣៖ ខេត្តបាត់ដំបង កំពង់ឆ្នាំង ពោធិ៍សាត់ រួមទាំងខេត្តបង្កើតថ្មី នៅឆ្នាំ១៩៧២ គឺ ឧត្តុង្គ កំពង់ត្រឡាច ប៉ៃលិន និងថ្មពួក។

៥-យោធភូមិភាគទី៤៖ ខេត្តកំពង់ធំ ព្រះវិហារ សៀមរាប និងឧត្តរមានជ័យ។

៦-យោធភូមិភាគទី៥៖ ខេត្តក្រចេះ ស្ទឹងត្រែង រតនគិរី និងមណ្ឌលគិរី។

ការពង្រឹងផ្នែកយោធានេះ គឺក្នុងគោលបំណងទប់ទល់នឹងចម្បាំង ដូចដែលសេចក្តីថ្លែងសុន្ទរកថាមួយរបស់ឧត្តមសេនីយ៍ឯក លន់ នល់ នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋខ្មែរ នាថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧០ បានលើកឡើងថា យើងត្រូវតែធ្វើចម្បាំងគ្រប់វិស័យទាំងអស់។ ចម្បាំងរបស់លោកផ្តោតទៅលើចំណុចសំខាន់៥ គឺ៖

-ចម្បាំងដោយអាវុធប្រឆាំងការឈ្លានពានរបស់យៀកកុង យៀកមិញ និងប្រទេសឡាវ។

-ចម្បាំងខាងផ្នែកវប្បធម៌។

-ចម្បាំងខាងផ្នែកសាសនា។

-ចម្បាំងខាងផ្នែកសង្គមកិច្ច។

-ចម្បាំងខាងផ្នែកសេដ្ឋកិច្ច។

លោក លន់ នល់ បានថ្លែងបន្តទៀតថា ការតស៊ូប្រឆាំងនឹងវិបត្តិសេដ្ឋកិច្ចជាការងារចម្បងមួយព្រោះសេដ្ឋកិច្ចបានជួយឱ្យយើងមានកម្លាំងតស៊ូនឹងសង្គ្រាមផង និងជួយលើកតម្កើងជីវភាពរស្ត្រក្នុងដំណាក់កាលក្ងើងសង្គ្រាមផង។

ដើម្បីសង្គ្រោះប្រទេសជាតិ ក្នុងនាមជាប្រធានាធិបតី លោក លន់ នល់ បានធ្វើការផ្ទាស់ប្តូររដ្ឋាភិបាលជាច្រើនដង។

ទោះបីជាយ៉ាងណាក៏ដោយស្ថានភាពសង្គមសម័យសាធារណរដ្ឋពុំបានផ្តល់សន្តិ-សុខសង្គម និងសន្តិភាពនៅក្នុងប្រទេសកម្ពុជាឡើយ។ សម្តេចព្រះនរោត្តម សីហនុ ដែលត្រូវបានលោក លន់ នល់ ធ្វើរដ្ឋប្រហារ បានជ្រកកោណផ្នែកនយោបាយនៅទីក្រុងប៉េកាំង។ ព្រះអង្គបានប្រកាសឱ្យប្រជាជនចូលព្រៃម៉ាកគីដើម្បីធ្វើការតស៊ូប្រឆាំងការធ្វើរដ្ឋប្រហារទម្លាក់ព្រះអង្គ។ ស្របជាមួយនេះ ចលនាខ្មែរក្រហម ដែលលេចរូបរាងច្បាស់ឡើងតាំងពីឆ្នាំ១៩៦៧ មានចលនានិងកម្លាំងកាន់តែខ្លាំងឡើងៗ ហើយបានបង្កអសន្តិសុខគ្រប់បែបយ៉ាងក្នុងសង្គមកម្ពុជា រហូតដល់ការតស៊ូធ្វើបដិវត្តរបស់ខ្មែរក្រហមបានទទួលជោគជ័យនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។

ខ-ការគ្រប់គ្រងតាមមូលដ្ឋាន

នៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ១៩៧០ លន់ នល់ បានចេញក្រឹត្យប្រកាសធ្វើកំណែនទូទៅ ដើម្បីរៀបចំស្ថាប័នការពារពីសំណាក់ប្រជាពលរដ្ឋស៊ីវិល។ ការរៀបចំកំណែននេះគេបែងចែកជា អនុអ៊ីឡូត៍តាមចំនួន១០ខ្នង ឬ ៥០ខ្នង ដែលគេឱ្យឈ្មោះថា មេ១០ខ្នង ឬមេ ៥០ខ្នង។ រួចគេយកអនុអ៊ីឡូត៍ជាច្រើនមកចង

ក្រង ទៅជាអ៊ីឡូត៍ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ចៅសង្កាត់។ ការជ្រើសរើសប្រធានអ៊ីឡូត៍នេះ សុទ្ធតែជាជនជាតិចិនកាត់ខ្មែរ ឬចិនសុទ្ធតែម្តង ហើយពួកនេះឆ្លៀតឱកាសកេងយកចំណេញពីមុខរបរជំនួញរបស់ខ្លួនជាមួយនឹងតំណែងប្រធានអ៊ីឡូត៍។

សមូហភាពដែនដីនៃសាធារណរដ្ឋ គឺ សង្កាត់ ខេត្ត និង ក្រុង។ សមូហភាពទាំងនេះនឹងត្រូវគ្រប់គ្រងខ្លួនតាមលក្ខខណ្ឌមានចែងក្នុងច្បាប់រៀបចំអង្គការមួយ[៥]។

៤.៤-សម័យកម្ពុជាប្រជាធិបតេយ្យ

បន្ទាប់ពីមានភាពរន្ធត់រន្ធើផ្នែកនយោបាយ សង្គមកិច្ច និងសេដ្ឋកិច្ច ក៏ដូចជារបបគ្រប់គ្រងរដ្ឋនាសម័យសាធារណរដ្ឋខ្មែរអស់រយៈពេល៥ឆ្នាំ ប្រទេសកម្ពុជាបានធ្លាក់ក្នុងសង្គ្រាមស៊ីវិលយ៉ាងក្តៅគគុកនៅដើមឆ្នាំ ១៩៧៥។ ដោយសារស្ថានភាពនយោបាយពុំមានស្ថេរភាព និងអំពើពុករលួយក្នុងជួរ រដ្ឋាភិបាល ធ្វើឱ្យមានអត្រាអតិផរណាកាន់តែខ្ពស់ វិសមភាពសង្គមនិងជីវភាពរស់នៅរបស់ប្រជាជនកាន់តែលំបាកខ្លាំងឡើងៗ។ កត្តានេះ បានធ្វើឱ្យប្រជាជនមួយភាគធំដែលនៅតាមតំបន់ជនបទក្រោមការដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជា ងើបឡើងធ្វើបដិវត្តប្រឆាំងនឹងរបបសាធារណរដ្ឋខ្មែរហួតទទួលបានជោគជ័យនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។

ក្រោយពីប្រទេសកម្ពុជាត្រូវបានរំដោះទាំងស្រុង រដ្ឋាភិបាលកុម្មុយនីស្តមួយត្រូវបានបង្កើតឡើងដើម្បីរៀបចំប្រទេសជាតិ និងខឿនសេដ្ឋកិច្ចជាតិឡើងវិញ។

នៅឆ្នាំ១៩៧៦ បក្សកុម្មុយនីស្តកម្ពុជាបានបែងចែកកម្ពុជាប្រជាធិបតេយ្យទៅជា៦ភូមិភាគ ដែលរួមមាន៣២តំបន់។ ភូមិភាគនីមួយៗគឺយកខេត្តពីរឬច្រើនមកបញ្ចូលគ្នា ឬកាត់ចេញពីខេត្តនេះខ្លះឬខេត្តនោះខ្លះមកបញ្ចូលគ្នា។ ភូមិភាគនិងតំបន់ទាំងអស់សុទ្ធតែត្រូវបានដាក់កំណត់សម្គាល់ជាលេខ។ ភូមិភាគនីមួយៗចែកចេញជាច្រើនតំបន់ហើយតំបន់នីមួយៗចែកជាស្រុក ឃុំ និងសហករណ៍។

ភូមិភាគបូព៌ា(ភូមិភាគ២០៣) ដឹកនាំដោយ សោ កឹម ដែលធ្វើអត្តឃាតនៅខែឧសភា ឆ្នាំ១៩៧៨។ ភូមិភាគនេះរួមមានខេត្តព្រៃវែង និងខេត្តស្វាយរៀងទាំងមូល ផ្នែកខ្លះនៃខេត្តកំពង់ចាមដែលស្ថិតនៅត្រើយខាងកើតទន្លេមេគង្គទាំងអស់ និងកាត់ចេញពីស្រុកមួយក្នុងខេត្តក្រចេះ គឺស្រុកឆ្លូង និងកាត់យកស្រុកខ្លះពីខេត្តកណ្តាល ដែលរួមមានស្រុកខ្សាច់កណ្តាល ល្វាឯម និងមុខកំពូល។ ភូមិភាគនេះចែកជាប្រាំតំបន់ ដែលរួមមានតំបន់២០ តំបន់២១ តំបន់២២ តំបន់២៣ និងតំបន់២៤។

ភូមិភាគនិរតី(ភូមិភាគ៤០៥) ដឹកនាំដោយ ឈិត ជឿន ហៅតាម៉ុក។ ភូមិភាគនេះ

[៥] ហួត វុទ្ធី៖ **ប្រជុំរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាពីឆ្នាំ ១៩៤៧-២០០៧៖** ដ.ឯ.ម.។

រួមមានខេត្តកំពត និងខេត្តតាកែវ ទាំងមូល ស្រុកពីរក្នុងខេត្តកំពង់ស្ពឺ គឺស្រុកសំរោងទង និងគងពិសី និងស្រុកជ្រាំក្នុងខេត្តកណ្តាល ដែលរួមមានស្រុកកណ្តាលស្ទឹង ស្អាង កោះធំ កៀនស្វាយ និងលើកដែក។ ភូមិភាគនេះចែកជាបួនតំបន់ ដែលរួមមានតំបន់១៣ តំបន់៣៣ តំបន់៣៥ និងតំបន់២៥។

ភូមិភាគឧត្តរ(ភូមិភាគ៣០៣) ដឹកនាំដោយ កុយ ធួន ហៅធុច ពីឆ្នាំ១៩៧០ដល់ដើមឆ្នាំ១៩៧៦។ បន្ទាប់ពីកុយ ធួន ត្រូវបានចាប់ខ្លួន និងសម្លាប់នៅគុកទួលស្វែងនៅឆ្នាំ១៩៧៦ កែ ពក ត្រូវបានចាត់តាំងជាលេខាភូមិភាគ។ នៅឆ្នាំ១៩៧៧ កែ ពក ត្រូវបានចាត់តាំងឱ្យធ្វើជាលេខាភូមិភាគកណ្តាលដែលទើបបង្កើតថ្មី លេខាថ្មីរបស់ភូមិភាគឧត្តរគឺ កង ចាប។ ភូមិភាគនេះរួមមានខេត្តកំពង់ធំទាំងមូល ផ្នែកខាងលិចទន្លេមេគង្គទាំងអស់នៃខេត្តកំពង់ចាម និងស្រុកមួយនៃខេត្តក្រចេះ គឺស្រុកព្រៃកប្រសប់។ ភូមិភាគនេះចែកជាបីតំបន់ គឺ តំបន់៦១ តំបន់៦២ និងតំបន់៦៣។

ភូមិភាគពាយ័ព្យ(ភូមិភាគ៥៦០) ដឹកនាំដោយ ញឹម រស់។ ភូមិភាគនេះរួមមានខេត្តពោធិ៍សាត់ និងខេត្តបាត់ដំបងទាំងមូល ហើយចែកចេញជាប្រាំពីរតំបន់ រួមមាន តំបន់១ តំបន់២ តំបន់៣ តំបន់៤ តំបន់៥ តំបន់៦ និងតំបន់៧។

ភូមិភាគបស្ចិម(ភូមិភាគ៤០១) ដឹកនាំដោយ ជូ ជេត។ ភូមិភាគនេះ រួមមានខេត្តកោះកុង និងខេត្តកំពង់ឆ្នាំងទាំងមូល និងផ្នែកខ្លះនៃខេត្តកំពង់ស្ពឺ ហើយចែកជាប្រាំតំបន់គឺ តំបន់៣១ តំបន់៣២ តំបន់៣៧ តំបន់១៥ និងតំបន់១១។

ភូមិភាគឦសាន(ភូមិភាគ១០៨) ដឹកនាំដោយ ណៃ សាវ៉ាន់ ហៅយ៉ា(សម្លាប់នៅឆ្នាំ១៩៧៦)។ ភូមិភាគនេះរួមមានខេត្តរតនគិរី និងខេត្តមណ្ឌលគិរីទាំងមូល ផ្នែកខ្លះនៃខេត្តក្រចេះ និងផ្នែកខ្លះនៃខេត្តស្ទឹងត្រែង ដែលស្ថិតនៅត្រើយខាងលិចទន្លេមេគង្គ។ ភូមិភាគនេះចែកជាប្រាំមួយតំបន់គឺ តំបន់១០១ តំបន់១០២ តំបន់១០៤ តំបន់១០៥ តំបន់១០៧ និងតំបន់៥០៥។

ក្នុងឆ្នាំ១៩៧៦នេះ កម្ពុជាប្រជាធិបតេយ្យបានបង្កើតតំបន់ស្វយ័តចំនួនពីរផ្សេងទៀតដែលទាក់ទងការងារផ្ទាល់ជាមួយគណៈកម្មាធិការមជ្ឈិមបក្ស ប៉ុន្តែមិនតាមរយៈភូមិភាគណាមួយទេ។ តំបន់ទាំងនេះរួមមានតំបន់សៀមរាបឧត្តរមានជ័យ(តំបន់១០៦)និងតំបន់ព្រះវិហារ(តំបន់១០៣)។ ក្រុង កំពង់សោមក៏ត្រូវបានចាត់តាំងដោយឡែកពីភូមិភាគដែរ។

នៅឆ្នាំ១៩៧៧ ភូមិភាគថ្មីមួយទៀត គឺភូមិភាគកណ្តាល ត្រូវបានបង្កើតឡើង។ ភូមិភាគនេះមានទីតាំងស្ថិតនៅត្រង់អតីតភូមិភាគឧត្តរ ចំណែកភូមិភាគឧត្តរថ្មីត្រូវបានប្តូរទីតាំងទៅតំបន់សៀមរាប ឧត្តរមានជ័យ និងតំបន់ព្រះវិហារ។ តំបន់ក្រចេះ(តំបន់៥០៥) និង

តំបន់មណ្ឌលគិរី(តំបន់១០៥) ត្រូវបានបំបែកចេញពីភូមិភាគឦសាន និងចាត់តាំងជាតំបន់សូយ័ត[៦]។

៤.៥-សម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា និង រដ្ឋកម្ពុជា

ក្នុងដំណើរឆ្ងង់កាត់ការវិវត្តឥតឈប់ឈរនៃរបបសង្គមខ្មែរយើង ការរៀបចំ រដ្ឋបាលដែនដីក៏មានការវិវត្តទៅតាមទម្រង់បែបបទនៃរបបទាំងនោះផងដែរ ពោលគឺមានលក្ខណៈប្លែកៗគ្នាពីរបបនយោបាយមួយទៅរបបនយោបាយមួយទៀត។

ការរៀបចំរដ្ឋបាលដែនដីនៅសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា និងរដ្ឋកម្ពុជាមានលក្ខណៈប្រហាក់ប្រហែលគ្នា។ ទាំងនេះក៏អាស្រ័យទៅដោយរបបនយោបាយដែលសម័យទាំងពីរនេះយកមកប្រើមានលក្ខណៈស្រដៀងគ្នាផងដែរ។

នៅចន្លោះឆ្នាំ១៩៧៩-១៩៩៣ ប្រទេសកម្ពុជាបានឆ្ងង់កាត់របបពីរខាងលើ ដែលនាំឱ្យមានរដ្ឋធម្មនុញ្ញពីរផ្សេងគ្នាផងដែរ។ ប៉ុន្តែបន្ទាត់នយោបាយធំៗ និងការគ្រប់គ្រងរដ្ឋបាលដែនដីនៅតែមានលក្ខណៈប្រហាក់ប្រហែលគ្នាដដែលពោលគឺគ្រាន់តែមានប្តូរឈ្មោះប្រទេសពីសាធារណរដ្ឋប្រជាមានិតកម្ពុជាមកជារដ្ឋកម្ពុជា ប៉ុណ្ណោះ ដែលបានប្រកាសនៅថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៨៩។

នៅសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែនដីត្រូវបែងចែកជាខេត្ត ក្រុង ចំណុះឱ្យរដ្ឋអំណាចមជ្ឈិមផ្ទាល់។ តាមរដ្ឋធម្មនុញ្ញរបស់រដ្ឋកម្ពុជាចែងថា ដែនដីត្រូវចែកជាខេត្តនិងក្រុង។ ខេត្តចែកជាទីរួមខេត្ត និងស្រុក។ ទីរួមខេត្តចែកជាសង្កាត់ ហើយស្រុកចែកជាឃុំ។ ក្រុងចំណុះរដ្ឋអំណាចមជ្ឈិមផ្ទាល់ត្រូវបែងចែកជាខណ្ឌ និងស្រុកជាយក្រុង។ ខណ្ឌត្រូវបែងចែកជាសង្កាត់។ ស្រុកជាយក្រុង ត្រូវបែងចែកដូចស្រុកចំណុះខេត្ត[៧]។

ចំណែកការគ្រប់គ្រងរដ្ឋបាលដែនដីរបបទាំងពីរមានលក្ខណៈខុសគ្នាខ្លះៗដូចជា៖

-នៅសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជារដ្ឋបាលដែនដីត្រូវគ្រប់គ្រងដោយគណៈកម្មាធិការប្រជាជនបដិវត្តន៍មូលដ្ឋានមានថ្នាក់ខេត្ត និងស្រុកជាដើម។

-នៅសម័យរដ្ឋកម្ពុជា រដ្ឋបាលដែនដីត្រូវគ្រប់គ្រងដោយគណៈកម្មាធិការប្រជាជនមូលដ្ឋានមានថ្នាក់ខេត្ត និងស្រុកជាដើម។

សមាជិកនៃគណៈកម្មាធិការទាំងពីរខាងលើនេះ ត្រូវជ្រើសរើសតាមគោលការណ៍បោះឆ្នោតជាសកល ដោយស្មើភាព ដោយ

---

[៦] ឌី ខាំបូលី៖ **ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ**, ១៩៧៥-១៩៧៩ មជ្ឈមណ្ឌលឯកសារកម្ពុជា ២០០៧។

[៧] ហួត វុទ្ធី៖ **ប្រជុំរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាពីឆ្នាំ ១៩៤៧-២០០៧៖** ដ.ឯ.ម.

ចំពោះនិងដោយសម្ងាត់ នៅតាមតំបន់នីមួយៗ។ បេក្ខជនទាំងនោះជាតំណាងគណៈ កម្មាធិការប្រជាជន តំណាងរណសិរ្ស និងតំណាងអង្គការមហាជននានា។

ប្រធាន អនុប្រធាន និងសមាជិកនៃគណៈកម្មាធិការទាំងពីរ មានអាណត្តិ៥ឆ្នាំ ចំពោះគណៈកម្មាធិការថ្នាក់ខ្ពស់ និងអាណត្តិ៣ឆ្នាំ ចំពោះគណៈកម្មាធិការថ្នាក់ទាប។

ឯកសារពិគ្រោះ

1. ជួន ណាត៖ **វចនានុក្រមខ្មែរ** ភ្នំពេញ ការផ្សាយរបស់វិទ្យាស្ថានពុទ្ធសាសនាបណ្ឌិត្យ ឆ្នាំ១៩៦៧។
2. ឌី ខាំបូលី៖ **ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ**, ១៩៧៥-១៩៧៩, មជ្ឈមណ្ឌលឯកសារកម្ពុជា, ២០០៧។
3. ពៅ សារឿន៖ **ប្រវត្តិស្ថាប័នខ្មែរ** បោះពុម្ពលើទី១ ឆ្នាំ២០១៥។
4. រាជបណ្ឌិត្យសភាកម្ពុជា៖ **ទស្សនវិជ្ជាខ្មែរសម័យអង្គរ** ឆ្នាំ២០០៨។
5. សាកលវិទ្យាល័យភ្នំពេញអន្តរជាតិ៖ **រដ្ឋបាលសាធារណៈ** ឆ្នាំសិក្សា២០១៦-២០១៧។
6. ហួត វុទ្ធី៖ **ប្រជុំរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាពីឆ្នាំ១៩៤៧-២០០៧៖** ភ្នំពេញ ឆ្នាំ ២០០៧។
7. ហែម ឡាច៖ **ស្ថាប័ននយោបាលកម្ពុជាបច្ចុប្បន្ន៖** សាលាភូមិន្ទរដ្ឋបាល ឆ្នាំ២០១៩។

ចរាចរណ៍ក្នុងរាជធានីភ្នំពេញ និង ផលប៉ះពាល់

Phnom Penh Traffic Issue and Its Impact

ដោយ៖ លោក **ហៃ សុគន្ធា**

មន្ត្រីស្រាវជ្រាវនាយកដ្ឋានភូមិវិទ្យានិងនគរូបនីយកម្ម.វិទ្យាស្ថាន

មនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម,រាជបណ្ឌិត្យសភាកម្ពុជា

Email: haysokunthea@yahoo.co

សេចក្តីផ្តើម

ភ្នំពេញ គឺជារាជធានីប្រវត្តិសាស្ត្ររបស់ព្រះរាជាណាចក្រកម្ពុជា ដែលមានអាយុប្រមាណជាង៥០០ឆ្នាំ មានទីតាំងស្ថិតនៅចំណុចប្រសព្វនៃទន្លេបួនមុន រួមមានមេគង្គលើ និងក្រោម ទន្លេសាប និងទន្លេបាសាក់។ វាជាមជ្ឈមណ្ឌលពាណិជ្ជកម្ម នយោបាយ និង វប្បធម៌នៃព្រះរាជណាចក្រកម្ពុជា ដែលមានប្រជាជនរស់នៅកុះករ ប្រមាណជាង២,២លាននាក់ ពោលគឺប្រមាណជា១៤% នៃប្រជាជនទូទាំងប្រទេស[1]។ រាជធានីភ្នំពេញ គឺជាតំបន់ដែលមានសក្តានុពលទាក់ទាញច្រើន រាប់បញ្ចូលទាំងទម្រង់នៃការរៀបចំទីក្រុង ផ្សារភ្ជាប់ទៅនឹងប្រវត្តិសាស្ត្ររបស់ប្រទេស និងអគារវប្បធម៌ប្រវត្តិសាស្ត្រជាច្រើនទៀត។

ផ្ទុយទៅវិញ ព្រះរាជាណាចក្រកម្ពុជាបានធ្លាក់ចូលទៅក្នុងសង្គ្រាមស៊ីវិលជិត៣ទសវត្ស ជាពិសេសរបបប្រល័យពូជសាសន៍ពី ឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ បានធ្វើឱ្យសេដ្ឋកិច្ចនៃប្រទេសកម្ពុជាមានការធ្លាក់ចុះយ៉ាងខ្លាំង ដោយសារធនធានមនុស្សដ៏សំខាន់របស់ប្រទេសត្រូវបានបាត់បង់យ៉ាងច្រើនលើសលប់។ មិនត្រឹមតែធនធានមនុស្សទេ ហេដ្ឋារចនាសម្ព័ន្ធរូបវន្តជាច្រើន ក៏ត្រូវបានបំផ្លាញផងដែរ ដូចជាពោងចក្រឧស្សាហកម្មជាច្រើន ទទួលរងនូវការបំផ្ទិចបំផ្លាញ ឬស្ថិតនៅក្នុងស្ថានភាពដ៏អាក្រក់ដែលពុំអាចនឹកស្មានដល់។ ការស្ថាបនាវិញ ការស្ថាបនាវិញរាជធានីភ្នំពេញឡើងវិញ ក្រោយរបបខ្មៅងងឹតរយៈ ៣ឆ្នាំ ៨ខែ និង២០ថ្ងៃ គឺចាប់ផ្តើមចេញពីចំណុចសូន្យ ពោលគឺចាប់ផ្តើមពីដំណាក់កាលអភិវឌ្ឍន៍ តាមរយៈជំនួយផ្នែកមនុស្សធម៌ពីសហគមន៍អន្តរជាតិរហូតដល់ដំណាក់កាលសហប្រតិបត្តិការសេដ្ឋកិច្ចជាមួយ បណ្តាលប្រទេសសង្គមនិយមមួយចំនួន។ ដោយឡែកកិច្ច

[1] វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ: ជំរឿនទូទៅប្រជាជននៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩។

សហប្រតិបត្តិការទ្រង់ទ្រាយធំ គឺទើបតែចាប់ផ្តើមក្រោយការបោះឆ្នោតសកលនាឆ្នាំ១៩៩៣ ដែលរៀបចំដោយអង្គការសហប្រជាជាតិ (UNTAC)។

ជាក់ស្តែងរាជធានីភ្នំពេញ ត្រូវបានយកចិត្តទុកដាក់យ៉ាងខ្លាំង ពីរាជរដ្ឋាភិបាលកម្ពុជា ដើម្បីធ្វើឱ្យក្លាយទៅជាមជ្ឈមណ្ឌលពាណិជ្ជកម្ម វប្បធម៌ នយោបាយ សេដ្ឋកិច្ច ទេសចរណ៍ និងសេវាកម្មផ្សេងៗទៀត សម្រាប់ប្រទេសទាំងមូល ពោលគឺធ្វើឱ្យល្បឿនអភិវឌ្ឍន៍ នៅក្នុងរាជធានីភ្នំពេញ មានការរីកចម្រើនយ៉ាងខ្លាំង ជាពិសេសគឺក្នុងរយៈពេលប្រមាណជាងមួយទសវត្សចុងក្រោយនេះ។

ដោយសារតែ សក្តានុពលទាក់ទាញជាច្រើនរបស់រាជធានីភ្នំពេញ និងតំបន់ជុំវិញ បានធ្វើឱ្យកំណើនប្រជាជន ពីមួយឆ្នាំទៅមួយឆ្នាំចេះតែកើនឡើងជាលំដាប់ ជាហេតុនាំទីក្រុងមួយនេះ ជួបប្រទះនូវបញ្ហាជាច្រើន ដូចជាសំណង់លំនៅឋានមិនស្របច្បាប់ ការធ្វើឱ្យបរិយាកាសនៅក្នុងតំបន់មិនស្អាតបរិសុទ្ធ និងភាពអនាធិបតេយ្យ តាមទីសាធារណៈជាច្រើនទៀតជាដើម។ ប្រព័ន្ធផ្លូវថ្នល់ចាស់ៗដែលមានទំហំតូចចង្អៀត បន្សល់ទុកតាំងពីទសវត្សឆ្នាំទី៥០ មិនបានធ្វើយតបទៅនឹងកំណើនមធ្យោបាយធ្វើដំណើរ របស់មនុស្ស ដែលកាន់តែកើនឡើងពីមួយថ្ងៃទៅមួយថ្ងៃ។ ការខិតខំពង្រីកហេដ្ឋារចនាសម្ព័ន្ធ ដូចជាផ្លូវគមនាគមន៍និងប្រព័ន្ធលូបង្ហូរទឹក ក៏ដូចជាការបំពាក់ផ្ទាំកសញ្ញាចរាចរណ៍នៅតាមដងផ្លូវសាធារណៈនៅមានកម្រិតនៅឡើយ។ លើសពីនេះទៀត ចំណេះដឹងរបស់អ្នកបញ្ជាមធ្យោបាយធ្វើដំណើរតាមដងផ្លូវសាធារណៈមួយចំនួន នៅមានកម្រិត ជាមួយនឹងស្ថានភាពនៃមធ្យោបាយធ្វើដំណើរមួយចំនួនមិនត្រឹមត្រូវ តាមបទដ្ឋានបច្ចេកទេសផងនោះ បានធ្វើឱ្យការធ្វើដំណើររបស់មនុស្សនៅក្នុងរាជធានីភ្នំពេញ ជួបប្រទះនូវបញ្ហាស្ទើរគ្រប់ពេលវេលា។ បញ្ហាទាំងនេះ បានធ្វើឱ្យប៉ះពាល់ និងខូចនូវផលប្រយោជន៍យ៉ាងច្រើនដល់ការរស់នៅរបស់ប្រជាពលរដ្ឋ ជាពិសេសការខាតបង់នូវពេលវេលា ដែលជាប្រភពនាំទៅដល់ការខាតបង់ប្រាក់ចំណូលប្រចាំគ្រួសារ។ ពីមួយថ្ងៃទៅមួយថ្ងៃ ភាពស្មុគស្មាញនៃការធ្វើដំណើររបស់អ្នកធ្វើដំណើរ រាប់បញ្ចូលទាំងមន្ត្រីរាជការ សិស្ស និស្សិត អាជីវករ និងប្រជាពលរដ្ឋនៅក្នុងរាជធានីភ្នំពេញកាន់តែកើនឡើងជាលំដាប់។

ដោយសារការចង់ដឹងឱ្យកាន់តែច្បាស់អំពីការខាតបង់សារៈប្រយោជន៍របស់អ្នកធ្វើដំណើរ ក៏ដូចជាសារៈប្រយោជន៍របស់ជាតិតាមរយៈភាពស្មុគស្មាញនៃចរាចរណ៍ទាំងនោះ និងម៉្យាងទៀតចង់ចូលរួមចំណែកជាអនុសាសន៍ ដើម្បីកែលម្អឱ្យកាន់តែប្រសើរឡើងដល់បញ្ហានេះ ទើបប្រធានបទ "បញ្ហាចរាចរណ៍ក្នុងរាជធានីភ្នំពេញនិងផលប៉ះពាល់" ត្រូវបានជ្រើសរើសដើម្បីសាកល្បងសិក្សាស្រាវជ្រាវ។

១- និយមន័យបញ្ហាចរាចរណ៍

តាមវចនានុក្រមខ្មែរ ពាក្យ "ចរាចរណ៍" មានន័យថា គឺជាការដើរទៅមក ដំណើរខ្វាត់ខ្វែងចុះឡើង ដំណើរតាមផ្លូវសាធារណៈតាមផ្លូវណាក៏ដោយ [២]។ "បញ្ហា" មានន័យថា គឺសកម្មភាពអ្វីមួយ ដែលមានលក្ខណៈអវិជ្ជមាន មិនត្រឹមត្រូវ និងមិនសមហេតុសមផលៗ

តាមវចនានុក្រម The World English Dictionary ពាក្យ "ចរាចរណ៍-traffic" មានន័យថា គឺជាចលនា ឬសកម្មភាពនានារបស់មនុស្ស ឬជាមួយនឹងមធ្យោបាយធ្វើដំណើរផ្សេងៗនៅក្នុងទីកន្លែងមួយហើយមានគោលដៅដូចគ្នាឬដោយឡែក [៣]។

ដូចនេះ ពាក្យ **"បញ្ហាចរាចរណ៍" មានន័យថា គឺជាចលនាឬសកម្មភាពស្មុគ្រស្មាញនានាដែលកំពុងតែប្រឈម ក្នុងកំឡុងពេលធ្វើដំណើរតាមផ្លូវសារធារណៈ ទោះបីក្នុងគោលដៅណាមួយក៏ដោយ។** ជាការពិត សកម្មភាពស្មុគ្រស្មាញនានានៅតាមផ្លូវ គឺជាការកកស្ទះចរាចរណ៍ដែលត្រូវបានធ្វើការប៉ាន់ស្មានជាជំហានៗ ទៅលើដំណើរការ នៃការចំណាយរបស់អ្នកធ្វើដំណើរនៅក្នុងការស្ទះចរាចរណ៍ ពោលគឺការកំណត់នូវតម្រូវការនានា នៃការធ្វើដំណើរនៅលើបណ្តាញផ្លូវថ្នល់។ អ្នកនិពន្ធខ្លះ បានកំណត់នូវនិយមន័យនៃការស្ទះចរាចរណ៍ ដោយធ្វើការអង្កេតទៅលើកម្រិតនៃសេវាកម្មនៅលើបណ្តាញផ្លូវថ្នល់ និងអ្នកខ្លះទៀតបានធ្វើការកំណត់ដោយត្រួតពិនិត្យអត្រានៃបរិមាណចរាចរណ៍ ទៅលើសមត្ថភាពផ្លូវថ្នល់ ស្ថានភាពយានជំនិះ និងអត្តចរិករបស់អ្នកបញ្ជាយានជំនិះជាដើម។

២. បរិយាកាសទូទៅនៃចរាចរណ៍

នៅក្នុងរាជធានីភ្នំពេញ ក៏ដូចជាទូទាំងព្រះរាជាណាចក្រកម្ពុជាដែរ ភាពស្មុគ្រស្មាញនៃការធ្វើចរាចរណ៍ ជាពិសេសគ្រោះថ្នាក់ចរាចរណ៍បានគម្រាមកំហែងយ៉ាងខ្លាំង និងជារៀងរាល់ថ្ងៃដល់ប្រជាពលរដ្ឋកម្ពុជា។ តាមពិត ការកកស្ទះចរាចរណ៍ គឺជាបញ្ហាប្រឈមដ៏ចម្បងមួយនៅក្នុងរាជធានី ទីក្រុង និងទីប្រជុំជនដែលកំពុងតែកើតមានស្ទើរទូទាំងប្រទេសក្នុងពិភពលោក។ បញ្ហាមួយនេះ គឺត្រូវបានទទួលស្គាល់ជាសាកលថា ជាបញ្ហាសម្រាប់ទាំងអស់គ្នា ពោលគឺពិភពលោកទាំងមូលបានចំណាយថវិកាយ៉ាងច្រើនឥតប្រយោជន៍សម្រាប់ចំណាយចំពោះបញ្ហាខាងលើនេះ ជាពិសេសនៅក្នុងប្រទេសកំពុងអភិវឌ្ឍរួមទាំងកម្ពុជាផងដែរ។ បញ្ហាចរាចរណ៍បានជះឥទ្ធិពលជាអវិជ្ជមានយ៉ាងខ្លាំងដល់សុខមាលភាពសង្គមនិងសេដ្ឋកិច្ចជាតិ មានន័យថាករណីជាច្រើនដែលបណ្តាលមកពីចរាចរណ៍ ជាពិសេសគ្រោះថ្នាក់ចរាចរណ៍តែម្តងបានធ្វើឱ្យរាំងស្ទះមួយផ្នែកដល់ការអភិវឌ្ឍន៍ប្រទេសជាតិ ដូចជាការបាត់បង់នូវសន្តិសុខសង្គម ការចំណាយពេលវេលាលើការសម្រាកព្យាបាលជំងឺដែលអូសបន្ទាយ និងការស្តារលទ្ធភាពពលកម្មមានរយៈ

---

[២] ជួន ណាត:វចនានុក្រមខ្មែរ ភ្នំពេញ ១៩៦៧ ទំព័រ ២១៣។

[៣] dictionary.reference.com/browse/traffic

ពេលវែង រួមផ្សំជាមួយនឹងការខាតបង់ប្រាក់ចំណូលដោយសារពិការភាព ឬដោយសារការបាត់បង់ជនបង្គោលក្នុងគ្រួសារ(មេគ្រួសារ) ហើយអាចបណ្តាលឱ្យធ្លាក់ទៅក្នុងស្ថានភាពក្រីក្របានទៀតផងក៏មាន។

ព្រះរាជាណាចក្រកម្ពុជា ដែលជាប្រទេសទើបតែនឹងឆ្ងងផុតពីសង្គ្រាម ហើយទទួលបាននូវសុខសន្តិភាពពេញបរិបូណ៌ទាំងស្រុង ដែលអាចបញ្ជាក់បានថា រាជរដ្ឋាភិបាលបាននិងកំពុងខិតខំស្តារឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធសាធារណៈការពង្រឹងសន្តិសុខ សណ្តាប់ធ្នាប់ ស្ថាប័នសិក្សាធិការ និងវិស័យផ្សេងៗទៀតជាច្រើន ដើម្បីចូលរួមអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ ក្នុងគោលដៅឆ្ពោះទៅរកការកាត់បន្ថយភាពក្រីក្រ។ ទន្ទឹមនឹងការរីកចម្រើននៃហេដ្ឋារចនាសម្ព័ន្ធ យើងក៏សង្កេតឃើញកំណើននៃយានយន្តកាន់តែមានការកើនជាលំដាប់ដែរ។ ដោយសារតែកំណើនយានយន្តមានសំទុះលឿនជាងកំណើននៃការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ នៅក្នុងព្រះរាជាណាចក្រកម្ពុជាជាពិសេសរាជធានីភ្នំពេញតែម្តងបានបង្ករឱ្យការធ្វើដំណើរមានភាពស្មុគស្មាញឡើងៗពីមួយថ្ងៃទៅមួយថ្ងៃ ដែលជាហេតុធ្វើឱ្យស្ថានភាពនៃការធ្វើចរាចរណ៍នៅលើដងផ្លូវសាធារណៈកាន់តែលំបាកនិងប្រថុយប្រថានទៀតផង។

២.១កំណើនប្រជាជនក្នុងរាជធានីភ្នំពេញ

ភ្នំពេញ មានទីតាំងស្ថិតនៅត្រង់ចំណុចប្រសព្វនៃទន្លេសាប ទន្លេមេគង្គ និងទន្លេបាសាក់ ដែលទន្លេទាំងនេះ បានផ្តល់នូវប្រព័ន្ធអេកូឡូស៊ីទឹកសាបប្រកបដោយសក្តានុពល ពោលគឺទ្រទ្រង់ដល់ការរស់នៅរបស់ប្រជាជន តាំងពីអតីតកាលរហូតមកដល់បច្ចុប្បន្ន។ ស្ថានភាពប្រជាជនរាជធានីភ្នំពេញនាឆ្នាំ១៨៦៣ មិនទាន់មានលក្ខណៈប្រមូលផ្តុំ ហើយក៏ពុំទាន់មានឯកសារណាមួយបញ្ជាក់ច្បាស់ថា មានចំនួនប៉ុន្មាននាក់ដែរ (ចំនួនប៉ាន់ស្មាន២៥ ០០០នាក់) ព្រោះការលើករាជធានីពីកន្លែងមួយទៅកន្លែងមួយច្រើនលើកច្រើនសារ ដោយសារសង្គ្រាមឈានពីប្រទេសជិតខាង និងការច្បាំងដណ្តើមរាជក្នុងវង្សត្រកូលក្សត្រខ្លួនឯង គឺពិតជាពិបាកណាស់ក្នុងប្រមូលផ្តុំប្រជាជន។ ម៉្យាងទៀត ការផ្ទាស់ប្តូរទីតាំងរាជធានីពិតជាបានធ្វើឱ្យប្រជាជនមានការនឿយហត់ក្នុងការផ្ទាស់ទីលំនៅព្រោះមធ្យោបាយដឹកជញ្ជូនពេលនោះ គឺគ្មានអ្វីក្រៅពីរទេះគោ រទេះសេះ ដំរី ឬការដឹកជញ្ជូនតាមផ្លូវទឹកដែលមានតែទូកតូចៗ។ តាមការសន្និដ្ឋានដោយផ្នែកទៅលើកត្តាផ្សេងៗទាក់ទងទៅនឹងលក្ខខណ្ឌប្រវត្តិសាស្ត្រ លក្ខខណ្ឌធម្មជាតិ សេដ្ឋកិច្ចសង្គម និងសន្តិសុខ បានបង្ហាញថា រាជធានីភ្នំពេញនាឆ្នាំ១៨៦៣ មានប្រជាជនរស់នៅប្រមាណជា២៥ ០០០ នាក់[៤] ហើយភាគច្រើនប្រជាជនទាំងនោះ តែងប្រមូលផ្តុំគ្នារស់នៅតាមត្រើយខាងលិចនៃដងទន្លេសាប។ មុនឆ្នាំ១៩៥៣ ពេលប្រទេសកម្ពុជាពុំទាន់ទទួលបានឯករាជ្យពីប្រទេសបារាំង ការកើន

[៤] *សាលាក្រុងភ្នំពេញ៖ ប្រវត្តិរាជធានីភ្នំពេញ: មិនា ១៩៩៨ ទំព័រ១១។*

ឡើងនៃចំនួនប្រជាជនរាជធានីភ្នំពេញមានល្បឿនគួរឱ្យកត់សម្គាល់គឺក្នុងរយៈពេលប្រមាណជិតមួយសតវត្ស ពីឆ្នាំ១៨៦៥ដល់ឆ្នាំ១៩៥៥ ប្រជាជនរាជធានីភ្នំពេញបានកើនឡើងរហូតដល់ជា១០ដង ហើយបន្តការកើនឡើងនៅឆ្នាំបន្តបន្ទាប់។ ការកើនឡើងនៃចំនួននេះ គឺផ្តើមចេញពីចលនាបម្ងាស់លំនៅចូល ច្រើនជាងអត្រាកំណើនធម្មជាតិ ហើយបានតម្រូវឱ្យរាជធានីភ្នំពេញ ធ្វើការពង្រីកផ្ទៃដីជាបន្តបន្ទាប់។ ភ្នំពេញចាប់ផ្តើមមានទិដ្ឋភាពជាទីក្រុងពេញលេញឡើង។ ដោយសារមានការពង្រីកខ្លួនពីមួយថ្ងៃទៅមួយថ្ងៃ ពោលគឺការពង្រីកកាន់តែធំឡើងៗ ឆ្ពោះទៅទិសខាងលិចរួមទាំងការកសាងហេដ្ឋារចនាសម្ព័ន្ធឡើងវិញ និងបន្ថែមថ្មី ស្របទៅតាមតម្រូវការនៃការអភិវឌ្ឍទីក្រុងជាបន្តបន្ទាប់នៅចុងសតវត្សទី១៩ និងដើមសតវត្សទី២០ និងបន្តនៅក្នុងសតវត្សទី២១នេះ។

កំណើនចំនួនប្រជាជនរាជធានីភ្នំពេញ(គិតជាពាន់នាក់)

ឆ្នាំ	១៨៦៣	១៩៥៥	១៩៩៨	២០០៨	២០១៩
ប្រ.ជ	២៩	២៧២	៩៩៩	១៣២៧	២២៨១

វិទ្យាស្ថានស្ថិតិ ក្រសួងផែនការ

២.២ ស្ថិតិយានយន្តក្នុងរាជធានីភ្នំពេញ

កំណើនប្រជាជន នាំឱ្យមានកំណើនយានជំនិះដោយសារតម្រូវការបម្ងាស់ទីជាប្រចាំសម្រាប់ជីវភាពរស់នៅប្រចាំថ្ងៃ។ ការអភិវឌ្ឍសេដ្ឋកិច្ចនៃប្រទេសកម្ពុជា ជាពិសេសរាជធានីភ្នំពេញ មានកំណើនគួរឱ្យកត់សម្គាល់ ប៉ុន្តែនៅតែមិនអាចបំពេញតាមតម្រូវការ យ៉ាងគំហុករបស់ប្រជាពលរដ្ឋបាននៅឡើយទេ។ ជាក់ស្តែងដោយសារតែកំណើនយានជំនិះនៅក្នុងរាជធានីភ្នំពេញពីមួយថ្ងៃទៅមួយថ្ងៃ ចេះតែមានការកើនឡើងជាលំដាប់ បានធ្វើឱ្យលំនៅដ្ឋានជាន់ផ្ទាល់ដីមួយចំនួនក្លាយទៅជាកន្លែងចតយានជំនិះគ្រប់ប្រភេទ ហើយទ្រូងផ្លូវមួយចំនួនក៏ត្រូវបានប្រជាពលរដ្ឋយកធ្វើជាកន្លែងចតដោយមិនត្រឹមត្រូវដែលចាំបាច់តម្រូវឱ្យមានការគ្រប់គ្រងច្បាស់លាស់ និងត្រឹមត្រូវជាមួយនឹងការបង្កើនល្បឿនអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធបន្ថែមទៀត។

ស្ថិតិយានយន្តក្នុងរាជធានីភ្នំពេញឆ្នាំ២០១៩

ប្រភេទ	ចំនួនចុះបញ្ជី/គ្រឿង
រថយន្ត	៥០៨១៦៣
ទោចក្រយានយន្ត	១៩៦៦៣២២

ប្រភព: កាសែតរស្មី កម្ពុជា ចេញថ្ងៃទី ១៤ ខែមករា ឆ្នាំ២០២០ "លោក សាំ ពិសិដ្ឋ ប្រធានមន្ទីរសោធារណការណ៍និងដឹកជញ្ជូនរាជធានីភ្នំពេញ"

ចំនួនខាងលើនេះ គឺនៅមិនទាន់បានរាប់បញ្ចូលនូវចំនួនយានជំនិះផ្សេងទៀត ដែលកំពុងប្រើប្រាស់ផ្លូវថ្នល់ នៅក្នុងរាជធានីភ្នំពេញផងទេ ដូចជាយានជំនិះកម្មសិទ្ធរបស់កងទ័ព នរគបាលជាតិ រដ្ឋសភា ព្រឹទ្ធសភា រដ្ឋ រាជរដ្ឋាភិបាល អង្គទូត អង្គការមិនមែនរដ្ឋាភិបាល និងក្រុមវិនិយោគជាដើម។ យានជំនិះដែលគ្មានម៉ាស៊ីនជាច្រើនទៀត ក៏បានធ្វើចរាចរណ៍តាមដងផ្លូវក្នុង

រាជធានីភ្នំពេញផងដែរ ដូចជាស៊ីកូ រទេះរុញសម្រាប់អេតចាយ និងរទេះរុញសម្រាប់អាជីវកម្មផ្សេងៗរួមមាន រទេះរុញលៀសហាល(តាមរដូវ) រទេះរុញលក់ចំណីអាហារ និងសម្ភារផ្សេងៗទៀតផងដែរ។ ជាងនេះទៅទៀត សាលារាជធានីភ្នំពេញបានចាប់ផ្តើមដាក់ឱ្យដំណើរការរថយន្តក្រុងសម្រាប់ដឹកជញ្ជូនសាធារណៈចាប់តាំងពីថ្ងៃទី៥ កុម្ភៈ ឆ្នាំ២០១៤ ដែលមានខ្សែរត់រហូតដល់ទៅបីខ្សែនិងមានរថយន្តដឹកជញ្ជូនរាប់រយគ្រឿង ប៉ុន្តែហាក់បីដូចជាមិនទាន់បានជួយសម្រួលដល់ការកកស្ទះចរាចរណ៍ នៅក្នុងរាជធានីភ្នំពេញនៅឡើយទេ[៥]។

៣. មូលហេតុនានានៃការកកស្ទះចរាចរណ៍

មានមូលហេតុជាច្រើនដែលជំរុញឱ្យមានការកកស្ទះចរាចរណ៍រហូតអាចឈានទៅដល់គ្រោះថ្នាក់ចរាចរណ៍ថែមទៀតផង។ កត្តាចម្បងមួយចំនួនដែលរុញច្រានឱ្យស្ថានភាពនៃចរាចរណ៍កាន់តែអាក្រក់ឡើង។ ពីពេលមួយទៅពេលមួយ គឺកត្តាមនុស្ស កត្តាផ្លូវ កត្តាយានយន្ត និងកត្តាអប់រំជាដើម។ ទាំងអស់នេះសុទ្ធសឹងតែជាកត្តាចម្បងៗដែលអាចបង្កឱ្យមានបញ្ហាចរាចរណ៍។

៣.១-កត្តាមនុស្ស

ការស្ទះចរាចរណ៍ភាគច្រើន គឺបានកើតឡើងដោយសារអ្នកបើកបរដែលគ្មានក្រមសីលធម៌ខ្ពស់ក្នុងពេលកំពុងបញ្ជាយានជំនិះ នៅលើទ្រូងផ្លូវ។ អ្នកបើកបរមួយចំនួន គឺបើកបរក្រោមឥទ្ធិពលនៃគ្រឿងស្រវឹង អ្នកបើកបរខ្វះមិនចេះនិងមិនយល់ស្វាគសញ្ញាចរាចរណ៍ អ្នកខ្វះបើកបរក្រោមអាយុដែលកំណត់ដោយច្បាប់ និងអ្នកខ្វះទៀតបើកបរហួសល្បឿនកំណត់។ ចំណែកមនុស្សមួយចំនួនទៀតព្រោះតែដើម្បីប្រយោជន៍ផ្ទាល់ខ្លួន បានយកចិញ្ចើមឬទ្រូងផ្លូវមួយចំនួនធ្វើអាជីវកម្មផ្សេងៗដែលជាហេតុបង្កលក្ខណៈពិបាកដល់អ្នកធ្វើចរាចរណ៍លើទ្រូងផ្លូវរហូតធ្វើឱ្យអ្នកថ្មើរជើងមួយចំនួនយកទ្រូងផ្លូវធ្វើដំណើរថ្មើរជើងទៅវិញ។

[៥] រស្មីកម្ពុជា: ថ្ងៃពុធ ទី១៦ ខែសីហា ឆ្នាំ២០១៩

ការយកចិញ្ចើមផ្លូវសាធារណៈធ្វើអាជីវកម្ម

ប្រភព៖ ថតថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ២០២២

អ្នកបើកបរជាច្រើន មិនទទួលខុសត្រូវរួមទាំងការឈប់ និងការការចតយានយន្តមិនត្រឹមត្រូវទៅតាមច្បាប់កំណត់ គឺជាមូលហេតុបណ្តាលឱ្យមានការកកស្ទះចរាចរណ៍នៅតាមដងផ្លូវ ជាពិសេសរថយន្តតែម្តង សូម្បីតែម៉ូតូដែលបើកបរនៅលើចំណែកណាមួយនៃទ្រូងផ្លូវខុស ក៏ជាកត្តាមួយដែលអាចនាំទៅដល់ការកកស្ទះចរាចរណ៍បានដែរ។ បញ្ហាដែលកាន់តែលំបាកទៀតនោះ គឺអ្នកបញ្ជាយានយន្តទាំងឡាយមានអារម្មណ៍ថាពួកគាត់បានប្រព្រឹត្តដ៏ត្រឹមត្រូវ ដូចជាការបត់ស្តាំឬបទឆ្វេងមិនបានគិតអំពីចរាចរណ៍នៅខាងក្រោយខ្លួនដែលអាចមានបញ្ហាឬអត់។

ចំណែកឯការអប់រំ ដែលទាក់ទងទៅនឹងការបណ្តុះបណ្តាលការបើកបរយានយន្តវិញ គឺនៅមានលក្ខណៈធូរលុងនៅឡើយ ពោលគឺការរៀនបើកបរមួយចំនួន គ្រាន់តែរៀនឱ្យចេះបើកបរតែប៉ុណ្ណោះ ដោយមិនចាប់អារម្មណ៍នឹងការចង់ចេះ ចង់ស្គាល់ស្វាគសញ្ញាចរាចរណ៍អ្វីនោះទេ។ ម្យ៉ាងវិញទៀត ការទទួលបានប័ណ្ណបើកបរខ្លះ នៅក្នុងប្រទេសកម្ពុជា ហាក់នៅមានភាពមិនប្រក្រតីនៅឡើយរួមទាំងការសូកប៉ាន់ដើម្បីទទួលបានប័ណ្ណបើកបរទៀតផង។

រូបភាពខុសច្បាប់ដដែលៗនៃប្រើប្រាស់ផ្លូវថ្នល់ដោយមនុស្សមួយចំនួនតូចនៅតែត្រូវបានគេមើលឃើញជារៀងរាល់ថ្ងៃ។ ផ្លូវដែលតម្រូវឱ្យធ្វើចរាចរណ៍ជាឯកទិសក៏នៅតែត្រូវបានអ្នកបើកបរទោចក្រយានយន្តប្រើប្រាស់ពេលខ្លះមានរហូតទៅដល់រថយន្តធំ និងរថយន្តទំនើបៗ បើកបញ្ច្រាស់ទិសដែលបង្កឱ្យមានការកកស្ទះចរាចរណ៍ទៀតផង ពោលគឺអ្នកបើកបរយានយន្តទាំងនេះគ្មានអារម្មណ៍ខ្មាស់អៀន និងគ្មានស្មារតីគោរពសញ្ញាចរាចរណ៍ទេ បើទោះបីជាមានរនាំង និងទួលថ្មសម្រាប់ពុះចែកទ្រូងផ្លូវក៏ដោយ។ ជាក់ស្តែងនាពេលបច្ចុប្បន្ននេះ ប្រសិនបើគ្មានសមត្ថកិច្ចនោះទេ អ្នកបើកបរមួយចំនួនតូចទាំងនោះនៅតែបើកបញ្ច្រាស់ទិសរំលោភគន្លងផ្លូវ ដោយគ្មានការអៀនខ្មាស់ រហូតដល់ហ៊ានបន្ថែមល្បឿននៅពេលមានភ្ញៀងសញ្ញាចរាចរណ៍ពណ៌ក្រហមទៀតផង។ សកម្មភាពទាំងនេះ ហាក់បង្ហាញនូវភាពរស់រវើករបស់ពលរដ្ឋកម្ពុជា ក្នុងការបំពេញការងារដើម្បីប្រយោជន៍ដោយមិនទុកពេលទំនេរចោល សូម្បីតែភ្ញៀងចរាចរណ៍ពណ៌ក្រហមៗ ប៉ុន្តែផ្ទុយទៅវិញ សកម្មភាពទាំងនេះ គឺជាសកម្មភាពឥតសណ្តាប់ធ្នាប់មួយដែលតែងតែកើតមាននៅលើទ្រូងផ្លូវនៅក្នុងរាជធានីភ្នំពេញ។

ជាងនេះទៅទៀត ការបំពេញការងារសាធារណៈនៅតាមដងផ្លូវរបស់មនុស្ស ដូចជា ការ

ងារជួសជួលនិងថែទាំផ្លូវថ្នល់ ការងារបច្ចេកទេសទឹកស្អាតនិងប្រព័ន្ធលូបង្ហូរ ការងារបច្ចេកទេសអគីសនី ការងារបរិស្ថាន នៅពេលដែលចរាចរណ៍កំពុងមមាញឹក គឺកាន់តែធ្វើឱ្យស្ថានភាពនៅលើដងផ្លូវកាន់តែតានតឹងថែមមួយកម្រិតទៀត។ បើទោះបីការចំណាយលើកម្លាំងពលកម្មនៃការជួលជុល និងការថែទាំសេវាទាំងនោះ មិនបន្ថែមកម្រៃក្តី (ការងារពេលយប់ត្រូវចំណាយខ្ពស់ជាងពេលថ្ងៃ) ប៉ុន្តែសកម្មភាពការងារទាំងនោះ បានការបន្ថែមបន្ទុកដល់ការកកស្ទះចរាចរណ៍ដែលបានធ្វើឱ្យប៉ះពាល់ទៅដល់អ្នកធ្វើដំណើរនៅតាមដងផ្លូវយ៉ាងច្រើនឥតគណនា ដូចជា ចំណាយខ្ពស់នៃតម្លៃប្រេងសាំង ខាតពេលវេលាបំពេញការងារសមត្ថភាពយានយន្តកាន់តែទ្រុឌទ្រោមជាដើម។

៣.២- កត្តាហេដ្ឋារចនាសម្ព័ន្ធ

ហេដ្ឋារចនាសម្ព័ន្ធនានា ជាពិសេសផ្លូវថ្នល់ជាច្រើននៅក្នុងរាជធានីភ្នំពេញមានលក្ខណៈតូចចង្អៀត និងមានក្រហូងមួយចំនួនជាច្រើនកន្លែងដែលមិនត្រឹមត្រូវទៅតាមស្តង់ដារផ្លូវថ្នល់ ហើយផ្លូវខ្លះក៏នៅខ្លះគំនូសទ្រូងផ្លូវភ្លើងសញ្ញាចរាចរណ៍ ផ្ងាកសញ្ញាចរាចរណ៍ ឬក៏ផ្ងាកសញ្ញាមួយចំនួនត្រូវបានបិតបាំងដោយស្វាកអាជីវកម្មផ្សេងៗ ជាមួយនឹងតំហៃទាំមិនទាន់មានប្រសិទ្ធភាពនៅឡើយ។

ដូចគ្នានេះដែរ ប្រព័ន្ធលូបង្ហូរទឹកនៅក្នុងរាជធានីភ្នំពេញ និងការគ្រប់គ្រងកាកសំណល់នៅតាមលូបង្ហូរទឹកជាច្រើននៅមានកម្រិត ដែលជាហេតុបង្កឱ្យកើតមានជាការកកស្ទះចរាចរណ៍ជាពិសេសគឺនៅពាល់រដូវភ្លៀងម្តងៗ អ្វីដែលជាកត្តីកង្វល់របស់ប្រជាពលរដ្ឋ នៅក្នុងរាជធានីភ្នំពេញ គឺការស្ទះលូនិងការលិចផ្លូវធ្វើដំណើរមួយចំនួនដែលជាកត្តាមួយ ជំរុញទិសចរាចរណ៍ឱ្យឆ្ពោះទៅតំបន់ប្រមូលផ្តុំនៅផ្លូវខ្ពស់ៗ។

ភ្លើងសញ្ញាចរាចរណ៍ គឺជាឧបករណ៍ត្រួតពិនិត្យនូវចលនាចរាចរណ៍ ប៉ុន្តែជាញឹកញាប់ភ្លើងសញ្ញាចរាចរណ៍ខ្វះ មិនដំណើរការដោយមូលហេតុប្រព័ន្ធអគ្គិសនី និងដោយមូលហេតុបច្ចេកទេស។ ប្រព័ន្ធសេណារីយូនៃភ្លើងសញ្ញាចរាចរណ៍ដែលមិនមានលទ្ធភាពទទួលយកបាននេះ បានបង្កឱ្យចរាចរណ៍មានភាពរឹតវែរនៅចំណុចផ្លូវប្រសព្វនានា។ ម្យ៉ាងវិញទៀត នៅក្នុងប្រទេសអភិវឌ្ឍលំហែទាំផ្លូវ គឺត្រូវធ្វើឡើងនៅពេលយប់ដែលជាពេលដែលចរាចរណ៍មិនសូវមមាញឹកឬគ្មានចរាចរណ៍តែម្តង។ ប៉ុន្តែនៅក្នុងរាជធានីភ្នំពេញ គេសង្កេតឃើញ ក្រុមអ្នកថែទាំផ្លូវថ្នល់ភាគច្រើនបំពេញការងារនៅពេលថ្ងៃ ជាពិសេសម៉ោងដែលចរាចណ៍មមាញឹក ដូចជា ការអ៊ិតកៅស៊ូបន្ថែម ការគូសគំនូសលើទ្រូងផ្លូវជាដើម។

៣.៣- កត្តាយានជំនិះ

ចំនួនឡាន ម៉ូតូ និងយានជំនិះផ្សេងទៀតដែលបានចរាចរណ៍លើទ្រូងផ្លូវ នៅក្នុងរាជធានីភ្នំពេញបច្ចុប្បន្ន មានការកើនឡើងពីមួយថ្ងៃទៅមួយថ្ងៃ។ ក្រុមគ្រួសារ ដែលមានជីវភាពមធ្យមអាចមានឡានមួយគ្រឿង និងម៉ូតូមួយគ្រឿង ហើយជាមធ្យមយ៉ាងហោចណាស់ ក៏មានម៉ូតូ២គ្រឿងដែរ ចំពោះគ្រួសារដែលមានសមាជិកចាប់

ពី៤នាក់ឡើងទៅ។ ទោះយ៉ាងនេះក្តី គេមិនអាចហាមឃាត់ប្រជាជនមិនឱ្យទិញរថយន្តច្រើននោះទេ ព្រោះនេះជាសិទ្ធិ និងស្របតាមប្រទេសកាន់របបទីផ្សារសេរី។ យានយន្តមួយចំនួនដែលធ្វើចរាចរណ៍នៅក្នុងរាជធានីភ្នំពេញមានអាយុកាលហួសកំណត់ដែលមានលក្ខណៈខូចរខេករខាក ជាប់ហ្វ្រាំង គ្មានភ្លើងបំភ្លឺត្រឹមត្រូវកែច្នៃខុសបច្ចេកទេសជាដើម។ ប្រកេទរទេះរុញជាច្រើនដែលចរាចរណ៍នៅតាមដងផ្លូវក្នុងរាជធានីភ្នំពេញ គឺជាយានសម្រាប់មធ្យោបាយអាជីវកម្មដែលមានវត្តមានស្ទើរគ្រប់ដងផ្លូវ។ ដោយមិនមានផ្លូវដោយឡែករបស់ខ្លួនរទេះរុញក៏បានចូលរួមចំណែកក្នុងការធ្វើឱ្យមានការកកស្ទះចរាចរណ៍ផងដែរ តាមរយៈល្បឿនយឺតៗបង្អាក់យានយន្តផ្នែកនៅខាងក្រោយ។

ស្ថានភាពចរាចរណ៍ក្នុងរាជធានីភ្នំពេញ

ប្រភព: កាសែតរស្មីកម្ពុជា ១៤ មេសា ២០២០

៤- បញ្ហាចរាចរណ៍ និង ផលប៉ះពាល់

ការកកស្ទះចរាចរណ៍បានបណ្តាលឱ្យកាត់បន្ថយដល់សកម្មភាពសេដ្ឋកិច្ច និងការកើនឡើងនូវតម្លៃនៃការធ្វើដំណើរដែលប៉ះពាល់យ៉ាងធ្ងន់ធ្ងរទៅដល់សេដ្ឋកិច្ចជាតិ និងតំបន់ទាំងមូលតែម្តង។ លើសពីនេះទៅទៀតការកកស្ទះចរាចរណ៍បានធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរទៅដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ពោលគឺវាបានធ្វើឱ្យកាំងស្ទះទៅដល់សមត្ថភាពនៃការកសាងទីលំនៅការធ្វើដំណើរ និងការធ្វើឱ្យខូតខាតទៅដល់គុណភាពនៃការរស់នៅក្នុងតំបន់ និងក្នុងពិភពលោកផងដែរ។ ការស្ទះចរាចរណ៍ត្រូវបានយកមកធ្វើជាមូលដ្ឋានដើម្បីសិក្សាក្នុងការកសាងទីប្រជុំជននគរូបនីយកម្ម និងរបេកក្រុងជាដើម ព្រោះការរៀបចំការតាំងទីលំនៅរបស់ប្រជាពលរដ្ឋ នៅក្នុងតំបន់នីមួយៗត្រូវមានគោលដៅសម្រាប់សុខុមាលភាពនិងភាពសុខដុមនៃប្រជាពលរដ្ឋគ្រប់ស្រទាប់វណ្ណៈ។

ការកកស្ទះចរាចរណ៍បានធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរ ដល់សុខុមាលភាពរបស់ប្រជាពលរដ្ឋ និងផ្តល់ផលអវិជ្ជមានជាច្រើន ដូចជា ខាតបង់ពេលវេលាសម្រាប់អ្នកបើកបរ និងអ្នកធ្វើដំណើរដែលជាហេតុនាំទៅដល់ភាពយឺតយ៉ាវនៃការមកដល់របស់អ្នកចូលរួមសកម្មភាពការងារពាណិជ្ជកម្ម ការងារអប់រំ ការងារផលិតកម្មផ្សេងទៀត ហើយអាចធ្វើបញ្ជាំងឱ្យឃើញអំពីការខាតបង់ខាងផ្នែកពាណិជ្ជកម្ម និងសេដ្ឋកិច្ចទាំងអង្គភាព និងបុគ្គលជាដើម។ ម្យ៉ាងទៀត ការកកស្ទះចរាចរណ៍បានធ្វើឱ្យខ្លះខ្ជាយនូវឥន្ធនៈរួមទាំងធ្វើឱ្យមានការកើនឡើងនៃការបំពុលបរិស្ថានតាមរយៈការសាយភាយនៃឧស្ម័នកាបូនិកជាច្រើនទៅក្នុងបរិយាកាស។

ប្រមាណជាង៥មួយទសវត្សចុងក្រោយនេះ ការធ្វើដំណើរទៅមកក្នុងគោលដៅផ្សេងៗនៅក្នុងរាជធានីភ្នំពេញ តែងតែកើតមាននូវការកកស្ទះចរាចរណ៍ស្ទើរពាល់ថ្ងៃ ជាពិសេសនៅក្នុងម៉ោងមមាញឹកនៃការធ្វើដំណើររួមមានពេលព្រឹក(ចាប់ពីម៉ោង៦.៣០ រហូតដល់ម៉ោង៨.៣០) និងពេលល្ងាច(ចាប់ពីម៉ោង៥.៣០ រហូតដល់ម៉ោង៧.៣០)សម្រាប់ថ្ងៃធម្មតា(ថ្ងៃចន្ទ-សុក្រ)ប៉ុន្តែសម្រាប់ថ្ងៃសៅរ៍-អាទិត្យ និងថ្ងៃបុណ្យវិញ ចរាចរណ៍នៅក្នុងរាជធានីភ្នំពេញហាក់បី ដូចជា មិនបង្កឱ្យមានភាពកកស្ទះឡើយ លើកលែងតែតំបន់ ជាច្រកសំខាន់ៗសម្រាប់ចេញចូលរាជធានី រួមមានតំបន់ច្បារអំពៅ តំបន់ស្ពានជ្រោយចង្វារ តំបន់អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ តំបន់ស្ទឹងមានជ័យ ជាដើម។ បច្ចុប្បន្ននេះ មិនថាជាថ្ងៃណាទេ ម៉ោងណា ជាម៉ោងណាទេ ពោលគឺចរាចរណ៍កកស្ទះស្ទើរគ្រប់ទីកន្លែងនៅក្នុងរាជធានីភ្នំពេញតែម្តង ដែលវាបានក្លាយទៅជាទម្លាប់របស់អ្នកធ្វើដំណើរទៅហើយ។ ប្រជាពលរដ្ឋទូទៅនាំគ្នានិយាយតៗគ្នាថា "ការស្ទះចរាចរណ៍នៅក្នុងរាជធានីភ្នំពេញ គឺជារឿងធម្មតា ប៉ុន្តែផ្ទុយទៅវិញ ការមិនកកស្ទះចរាចរណ៍ទេ ដែលជារឿងមិនធម្មតា"។

៤.១-ការខាតបង់ប្រាក់ចំណូលប្រចាំគ្រួសារ

បញ្ហាចរាចរណ៍ បានធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់ផ្នែកសេដ្ឋកិច្ច ជាពិសេសគឺសេដ្ឋកិច្ចគ្រួសារតែម្តង។ មូលហេតុទាំងនេះ អាចនាំទៅដល់ការរស់នៅក្នុងស្ថានភាពក្រីក្រដោយសារភាគច្រើននៃអ្នកទទួលរងផលប៉ះពាល់ដោយសារបញ្ហាចរាចរណ៍ ជាពិសេសគ្រោះថ្នាក់ចរាចរណ៍ គឺជាក្រុមមនុស្សដែលស្ថិតក្នុងចំណោមសមាជិកសំខាន់ៗសម្រាប់គ្រួសារ ពោលគឺអ្នកដែលអាចចូលរួមចំណែក ក្នុងការរកចំណូលប្រចាំគ្រួសារ ឬអ្នករកចំណូលទាំងស្រុងតែម្តង។ តាមរបាយការណ៍របស់ប្រព័ន្ធព័ត៌មានជនរងគ្រោះ និងគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោកនៅកម្ពុជាឆ្នាំ២០១៩ បង្ហាញថា មនុស្សប្រមាណជា៧៦% ជាបុគ្គលដែលស្ថិតនៅក្នុងវ័យពេញកម្លាំងពលកម្មសម្រាប់សកម្មភាពសេដ្ឋកិច្ច[៦]។

គ្រួសារជាច្រើនដែលមានប្រាក់ចំណូលដោយសារមធ្យោបាយធ្វើដំណើរត្រូវបានកាត់បន្ថយដោយមូលហេតុត្រូវចំណាយពេលវេលាច្រើននៅក្នុងភាពចង្អៀតនៃចរាចរណ៍ ពោលគឺត្រូវចំណាយពេលវេលាច្រើន ក្នុងចម្ងាយផ្លូវដ៏ខ្វីនិងការចំណាយដ៏ខ្ពស់លើប្រេងឥន្ធនៈ។ ម្យ៉ាងទៀតការកកស្ទះការចរាចរណ៍អាចធ្វើឱ្យយានយន្តធាប់ខូច ហើយអាចធ្វើឱ្យសុខភាពរបស់អ្នកបើកបរចុះខ្សោយដោយសារការបំពុលបរិស្ថាន។

៤.២- ផលប៉ះពាល់ចិត្តសាស្ត្រ និង សុខភាព

ជាការពិតណាស់ ភាពចម្រុះនៃយានជំនិះនៅតាមផ្លូវសាធារណៈ គឺបានបង្កភាពអាប់អួរ

[៦] របាយការណ៍របស់ប្រព័ន្ធព័ត៌មានជនរងគ្រោះ និងគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោកនៅកម្ពុជាឆ្នាំ២០១៩។

ទៅដល់បរិយាកាសស្រេចទៅហើយ ជាពិសេស គឺការបំពុលបរិស្ថាន ដែលតែងតែធ្វើឱ្យជីវិតនៅជុំវិញមិនទទួលបាននូវប្រសិទ្ធិភាពនៃការរស់នៅ។ ជាងនេះទៀត ការកកស្ទះចរាចរណ៍ដែលបានបង្កការបំពុលបរិស្ថាន និងភាពស្មុគស្មាញខាងផ្នែកចិត្តសាស្ត្រដល់អ្នកធ្វើដំណើរទាំងឡាយ អាចជាមូលដ្ឋាននៃបង្កវិនាសកម្មភាពបន្តបន្ទាប់នានារបស់បុគ្គលទាំងនោះ ដូចជា ទម្លាប់គេចចេញពីចរាចរណ៍មកញឹក ដោយមិនខ្វល់អំពី ទង្វើខុសច្បាប់ឬបង្កើតហានិភ័យផ្សេងៗ និងបង្កើនអារម្មណ៍តានតឹងក្នុងគ្រួសារជាដើម។

៤.៣.ផលប៉ះពាល់ប្រយោជន៍សាធារណៈ

សេវាសាធារណៈជាច្រើនត្រូវបានពន្យាពេលដោយសារ អ្នកផ្តល់សេវាសាធារណៈមួយចំនួនមិនទទួលបានប្រសិទ្ធភាពខ្ពស់ក្នុងការធ្វើចរាចរណ៍តាមផ្លូវសាធារណៈ ពោលគឺមន្ត្រីផ្តល់សេវាសាធារណៈ ត្រូវខកខានដោយជារការស្ទះចរាចរណ៍ដែលជាកត្តាមួយនាំទៅដល់ការខូចប្រយោជន៍ជាតិជាធំដូចជាៈ

- កិច្ចការរដ្ឋបាលថ្នាក់ជាតិ
- កិច្ចការរដ្ឋបាលក្នុងតំបន់
- កិច្ចការរដ្ឋបាលផ្សេងទៀត

ប្រការ ដែលសំខាន់ជាងនេះទៅទៀតនោះ គឺសេវាសាធារណៈសង្គ្រោះបន្ទាន់ផ្សេងៗ ដែលចាំបាច់បំផុត ក៏ត្រូវបានយឺតយ៉ាវឬពន្យាពេលវេលា ដោយសារការកកស្ទះចរាចរណ៍ផងដែរ ដូចជា សេវាសន្តិសុខសង្គម សេវាសង្គ្រោះបន្ទាន់ សេវាសុខភាពសង្គម និងសេវាសាធារណៈផ្សេងទៀត ជាដើម។

៥. ការអប់រំអំពីសុវត្ថិភាពចរាចរណ៍

ការអប់រំ ត្រូវអនុវត្តន៍សម្រាប់ទាំងអស់គ្នា ព្រោះការធ្វើចលនានៅលើដងផ្លូវ កើតចេញពីមនុស្សគ្រប់ស្រទាប់វណ្ណៈក្រោមលក្ខខណ្ឌនៃច្បាប់កំណត់ ពោលគឺអប់រំមនុស្សដើម្បីទទួលបានចំណេះដឹង ផ្នែកសីលធម៌ក្នុងការបើកបរ។ ការអប់រំអំពី សីលធម៌ សុជីវធម៌ និងច្បាប់ចរាចរណ៍ដល់អ្នកបើកបរ គឺជាកត្តាចាំបាច់បំផុតដើម្បីសុវត្ថិភាពចរាចរណ៍។ ការយោគយល់អធ្យាស្រ័យគ្នាក៏ជាកត្តាដែលមិនអាចមើលរំលងបានឡើយ ដើម្បីធ្វើឱ្យការបើកបរអាចប្រព្រឹត្តទៅបាន មានរបៀបរៀបរយ និងមានសណ្តាប់ធ្នាប់ល្អប្រសើរ ហើយអាចជួយកាត់បន្ថយអារម្មណ៍តានតឹងអារម្មណ៍ខឹងសម្បារក្នុងពេលកំពុងបើកបរបានទៀតផង។

ម្យ៉ាងទៀត អ្នកបើកបរទាំងឡាយ ត្រូវតែរៀននិងមានស្មារតីគោរព និងទទួលខុសត្រូវនៃស្វាកសញ្ញាចរាចរណ៍ទាំងឡាយ។ ចំណែកផ្នែកសណ្តាប់ធ្នាប់ដែលទទួលបន្ទុករៀបចំសណ្តាប់ធ្នាប់តាមដងផ្លូវសារណៈក៏ចាំបាច់ត្រូវទទួលបានការអប់រំដើម្បីអនុវត្តន៍ឱ្យបានប្រសើរឡើង។

ការអប់រំ ដែលសំខាន់ជាងនេះទៅទៀតនោះ គឺការអប់រំដល់អ្នកបើកបរផ្ទាល់ ពោលគឺអ្នកបើកបរត្រូវតែធ្វើការបណ្តុះបណ្តាល

ដោយមានការប្រឡងដែលមានលក្ខណៈត្រឹមត្រូវ និងច្បាស់លាស់។

ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំជាសៀវភៅ "ការអប់រំសុវត្ថិភាពចរាចរណ៍ផ្លូវគោក" តាំងពីឆ្នាំ២០០៦ ហើយផ្សព្វផ្សាយជាបន្តបន្ទាប់ រហូតដល់បច្ចុប្បន្ន។ មេរៀនពេញលេញមានក្នុងកម្មវិធីសិក្សា មុខវិជ្ជាសិក្សាសង្គម ជាពិសេស សីលធម៌ ពលរដ្ឋវិជ្ជាតាំងពីបឋមសិក្សារហូតដល់មធ្យមសិក្សាទុតិយភូមិ។ ជារួមខ្លឹមសារនៃការអប់រំ គឺផ្តោតជាសំខាន់ទៅដល់ការបើកបរដោយគោរពច្បាប់ចរាចរណ៍ និង ប្រើប្រាស់សុភវិនិច្ឆ័យពេលកំពុងបើកបរជារឿងចាំបាច់ដោយប្រកាន់ខ្ជាប់នូវ៖

- ការកំណត់ល្បឿន
- ការគោរពផ្លាកសញ្ញា និងសញ្ញាចរាចរណ៍
- ត្រូវគោរពគ្នាទៅវិញទៅមក
- ឆ្លងកាត់ដោយប្រុងប្រយ័ត្ន
- កុំប្រើប្រាស់គ្រឿងស្រវឹង
- ។ល។

៦- សន្និដ្ឋាននិងអនុសាសន៍

ប្រសិនបើពិនិត្យបរិបទខាងលើអាចនិយាយបានថា ដំណោះស្រាយបញ្ហាចរាចរណ៍នៅក្នុងប្រទេសកម្ពុជា ជាពិសេសនៅក្នុងរាជធានីភ្នំពេញ គឺពិតជាមិនងាយស្រួលប៉ុន្មានទេ ស្របតាមបរិយាកាសនៃនគរូបនីយកម្មនិងការអភិវឌ្ឍសេដ្ឋកិច្ចបច្ចុប្បន្ន។ ជាការពិត យន្តការផ្លូវច្បាប់ដើម្បីស្រាយបញ្ហានេះគឺពិតជាមាន ពោលគឺនៅពេលណាដែលមានបញ្ហា គឺប្រាកដណាស់ត្រូវតែមានដំណោះស្រាយ ឬវិធីសាស្ត្រផ្សេងៗដើម្បីការពារមិនឱ្យកើតមានបន្តទៀត។

បញ្ហាចរាចរណ៍ នៅក្នុងរាជធានីភ្នំពេញហាក់បានដើរមកដល់សម័យកាលមួយ ដែលអ្នកបញ្ជាប់យានជំនិះដោយការគោរពភ្លើងស្តុប (គោរពច្បាប់) ក្វាយទៅក្រុមមនុស្សភាគតិច ហើយត្រូវខ្មាស់អ្នកបើកបរដទៃទៀត ជាក្រុមមនុស្សភាគច្រើន ដែលមិនគោរពភ្លើងចរាចរណ៍ និងសញ្ញាចរាចរណ៍។ ជាញឹកញាប់ អ្នកបើកបរខ្លួនឯង ក៏បានដឹងថា ពួកគេបានប្រព្រឹត្តល្មើសដោយការមិនគោរពភ្លើង ឬសញ្ញាចរាចរណ៍។ សកម្មភាពទាំងនេះ គឺជាបញ្ហាចម្បងមួយ ដែលអ្នកបើកបរត្រូវតែកែប្រែអកប្បកិរិយា និងទម្លាប់អាក្រក់ទាំងនេះ។ ម្យ៉ាងទៀត សិទ្ធិអំណាចរបស់ប៉ូលិសចរាចរណ៍ ហាក់អនុវត្តន៍នៅមានកម្រិត ពោលគឺមិនទាន់មានប្រសិទ្ធភាព តម្លាភាព និងស្មើភាព ដូចមានចែងក្នុងតួនាទីនិងភារកិច្ចរបស់ប៉ូលិសចរាចរណ៍។ ក្នុងន័យនេះ ថ្នាក់ដឹកនាំរបស់ប៉ូលិសចរាចរណ៍ ត្រូវធ្វើយ៉ាងណាបង្កើនការឱ្យតម្លៃប៉ូលិសចរាចរណ៍បន្ថែមតាមរយៈការផ្តល់ប្រាក់បៀវត្សរសមរម្យ និងការហ្វឹកហាត់បំប៉នសមត្ថភាពបន្ថែមដើម្បីការអនុវត្តស្មើភាព តម្លាភាព និងប្រសិទ្ធភាពនៃច្បាប់ចរាចរណ៍។

ជារួម បញ្ហាចរាចរណ៍ក្នុងរាជធានីភ្នំពេញអាចនិយាយថា វាបានក្វាយជាដំបៅមហារីកទៅហើយ ដែលទាមទារនូវឱសថល្អ និងពេលវេលា

មួយសមល្មមដើម្បីព្យាលបាល និងកែលម្អឱ្យមានប្រសិទ្ធភាព។ តាមរយៈលទ្ធផលនៃការសិក្សាស្រាវជ្រាវខាងលើ មូលដ្ឋានខ្លះៗអាចជាទស្សនទាន ដើម្បីចូលរួមចំណែកកែលម្អបញ្ហាចរាចរណ៍នៅក្នុងរាជធានីភ្នំពេញ ឆ្ពោះទៅរកប្រសិទ្ធភាព មានដូចខាងក្រោម ៖

-បង្កើនសេវាឡានក្រុងបន្ថែម និងត្រូវធ្វើឱ្យមានប្រសិទ្ធភាព ពោលគឺគួរតែមានផ្លូវអទិភាពដើម្បីធ្វើឱ្យទៀងទាត់ពេលវា និងទាក់ទាញអតិថិជនក្នុងគោលដៅកាត់បន្ថយមធ្យោបាយធ្វើដំណើរផ្ទាល់នៅតាមដងផ្លូវសាធារណៈនានាក្នុងរាជធានីភ្នំពេញ។

-បន្ថែមភ្លើងចរាចរណ៍ សញ្ញាចរាចរណ៍ និងគំនូសចរាចរណ៍ ឱ្យបានគ្រប់លក្ខណៈតាមស្តង់ដារ និងធ្វើតំហែទាំជាប្រចាំនិងឱ្យមានប្រសិទ្ធភាពខ្ពស់។

-គួររៀបចំឱ្យមានចំណតរថយន្តត្រឹមត្រូវ ចៀសវាងការយកទ្រូងផ្លូវសាធារណៈសម្រាប់ចតរថយន្ត និងយានជំនិះ។

-អាជីវកម្មណាដែលយកចិញ្ចើមផ្លូវសាធារណៈធ្វើជាកម្មសិទ្ធត្រូវហាមឃាត់។

-រៀបចំផ្លូវសម្រាប់ថ្មើរជើងនិងឱ្យមានប្រសិទ្ធភាព។

លើសពីនេះទៀត វិធានការណ៍បន្ទាន់មួយចំនួនដូចខាងក្រោមប្រហែលជាអាចចូលរួមចំណែក ក្នុងការរកដំណោះស្រាយនៃបញ្ហាស្ទះចរាចរណ៍ នៅក្នុងរាជធានីភ្នំពេញផងដែរ ៖

វិធានការណ៍ទី១៖ ការបញ្ជៀសទីតាំងវិនិយោគធំៗ ទៅតាមបណ្តាខេត្ត ឬក៏នៅតាមជាយរាជធានីភ្នំពេញវិញ រួមទាំងស្ថាប័នសាធារណៈធំៗមួយចំនួនផងដែរ ដូចជាមន្ទីរពេទ្យ សាលកវិទ្យាល័យ ព្រលានយន្តហោះ ជាដើម ។

វិធានការណ៍ទី២៖ ការពង្រីកទ្រូងផ្លូវ និងសាងសង់បន្ថែមដូចជា ស្ពានអាកាស ផ្លូវអាកាសសម្រាប់អ្នកថ្មើរជើង ផ្លូវក្រោមដី និងផ្លូវល្បឿនលឿនជាដើម។

វិធានការណ៍ទី៣៖ គួរកំណត់ម៉ោងការងារទាំងស្ថាប័នរដ្ឋ ក្រុមហ៊ុនឯកជន អង្គការសង្គមស៊ីវិល ទាំងម៉ោងពេលចូលនិងម៉ោងចេញខុសៗគ្នា។ ដោយបច្ចុប្បន្ននេះ ម៉ោងការងារនៃអង្គភាពទាំងនោះ ស្ទើរដូចគ្នាទាំងស្រុង ពោលគឺចូលធ្វើការចន្លោះម៉ោង៧ទៅម៉ោង៨ព្រឹក និងចេញមកវិញចន្លោះម៉ោង៤ទៅម៉ោង៥ល្ងាច។

វិធានការណ៍ទី៤៖ សមត្ថកិច្ចពាក់ព័ន្ធគួរតែចាត់វិធានការណ៍ដល់ម្ចាស់អាជីវកម្មនានា ដូចជា ហាងលក់ទំនិញ គោជនីយដ្ឋាននិងហាងលក់ចំណីអាហារ ហាងលក់សម្ភារៈផ្សេងៗជាដើម ដែលយកផ្លូវសាធារណៈធ្វើចំណតផ្ទាល់ខ្លួន។ ជាក់ស្តែង មានហាងនិងគោជនីយដ្ឋានថ្មីៗមួយចំនួនបានសាងសង់ដោយមានរៀបចំឱ្យមានចំណតក្រោមដីផ្ទាល់ខ្លួនដែលនេះវិធានការណ៍មួយល្អ ដើម្បីទុកទ្រូងផ្លូវសាធារណៈសម្រាប់ការធ្វើចរាចរណ៍បានប្រសើរឡើង ប៉ុន្តែនៅមានម្ចាស់អាជីវកម្មខ្លះ ដែលគិតតែពីប្រយោជន៍ផ្ទាល់ខ្លួន

នៅតែយកទ្រូងផ្លូវសាធារណៈប្រើប្រាស់ជាលក្ខណៈឯកជន។

វិធានការណ៍ទី៥៖ *គួរកំណត់ឱ្យមានការបើកបររថយន្តផ្ទាកលេខសេស និងរថយន្តផ្ទាកលេខគូចូលរាជធានីភ្នំពេញ តាមថ្ងៃសេសនិងថ្ងៃគូ ដើម្បីការត់បន្ថយបរិមាណយានយន្តលើទ្រូងផ្លូវនានាក្នុងរាជធានីភ្នំពេញ។ វិធានការណ៍នេះត្រូវបានប្រទេសមួយចំនួនអនុវត្តន៍ហើយ ព្រោះថាអាចកាត់បន្ថយទាំងការកកស្ទះ និងការបញ្ចេញផ្សែងពុលក្នុងបរិយាកាស ផងដែរ។*

គន្ថនិទ្ទេស

1. *កាសែតរស្មីកម្ពុជា: ថ្ងៃពុធ ទី១២ ខែសីហា ឆ្នាំ២០១៥ ទំព័រ៤*
2. *កាសែតរស្មីកម្ពុជា: ថ្ងៃពុធ ទី១៤ ខែមករា ឆ្នាំ២០២០ ទំព័រ៣*
3. *អង្គការហែនឌីខេប: របាយការណ៍របស់ប្រព័ន្ធព័ត៌មានជនរងគ្រោះ និងគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោកនៅកម្ពុជាឆ្នាំ២០១៩ ភ្នំពេញ*
4. *វេទិកាអង្គការក្រៅរដ្ឋាភិបាល: ការឃ្លាំមើលការអភិវឌ្ឍនៅកម្ពុជា ភ្នំពេញ ខែធ្នូ ឆ្នាំ២០១៧ ចំនួន១៣ទំព័រ*
5. *សាលាក្រុងភ្នំពេញ: ផែនការយុទ្ធសាស្ត្រអភិវឌ្ឍក្រុងឆ្នាំ២០០៥-២០១៥ ភ្នំពេញ ឆ្នាំ២០០៥ ចំនួន៦៦ទំព័រ*
6. *គណៈកម្មការជាតិចរាចរណ៍ផ្លូវគោក: ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ភ្នំពេញ ឆ្នាំ២០០៧ ចំនួន ១០០ទំព័រ*
7. *ក្រសួងផែនការ: វិទ្យាស្ថានជាតិស្ថិតិ: ជំរឿនប្រជាជននៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩ ៧២ ទំព័រ*
8. *ខុប សុខុម: ការបំពុលបរិស្ថានក្នុងរាជធានីភ្នំពេញ របាយការបូកសរុបការងារប្រជាជននិការអភិវឌ្ឍន៍ សកលវិទ្យាល័យភ្នំពេញ ២០០៩*
9. *បណ្ឌិត បេងហុង សុជាតិ ខេមរ៉ូ: ការកសាងរៀបចំដែនដីក្នុងទីក្រុងនិងទីប្រជុំជន អត្ថបទសិក្ខាសាលាថ្នាក់ជាតិស្តីពី ការរៀបចំដែនដីក្នុងទីក្រុង ចំនួន៥៩ទំព័រ*
10. ADB-Asean Regional Safety Program, Road Safety Report in Cambodia, Annual Report 2005, 39 p.
11. ADB-Asean Regional Safety Program, The Cost of Road Traffic Accidents in Cambodia, Phnom Penh, Report 2015, 35 p.

12. Handicap, Road Safety in Low income country setting: Experience from Handicap International in Cambodia, Stockholm, 2006. 24 p.
13. Handicap, Cambodia Road Traffic Accident and Victim Information System, Handicap International Belgium, Annual Report 2007, 64 p.
14. Ea Sophy, Study on Development Plans of Phnom Penh Metropolitan Area, January 2002, Case study. 47 p.

ប្រភពនៃការអប់រំក្នុងពិភពលោកសម័យបុរាណ

The World Roots of Ancient Education

ដោយ៖ លោកបណ្ឌិត **សូ សុចិរ**

មន្ត្រីស្រាវជ្រាវនាយកដ្ឋានវិទ្យាសាស្ត្រអប់រំ.វិទ្យាស្ថាន

មនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម.ពជបណ្ឌិត្យសភាកម្ពុជា

១. ការអប់រំនៅក្នុងសង្គមដែលមនុស្សមិនចានចេះបង្កើតអក្សរ (Education in the preliterate society)

ក-ការផ្ទេរវប្បធម៌ (Cultural transmission)

និទានកថា នៅទីនេះ បានចាប់ផ្តើមពីសម័យដែលមនុស្សមិនទាន់ចេះអាន និងសរសេរ មុនពេលមានការបង្កើតថ្មីនៃការអាន និងការសរសេរ នៅពេលដែលបុព្វបុរស ផ្ទេរវប្បធម៌ដោយផ្ទាល់មាត់របស់គេ ពីជំនាន់មួយទៅជំនាន់មួយទៀត។ គេអាចស្វែងរកឃើញប្រភពដើមកំណើតនៃការសិក្សាមិនផ្លូវការតាមគ្រួសារ និងវាយតម្លៃថា តើមូលហេតុអ្វីបានជាវានៅតែមានឥទ្ធិពលរហូតមកដល់សព្វថ្ងៃនេះ។ ថ្វីបើយើងរស់នៅក្នុងសម័យកាលមួយដែលព័ត៌មានត្រូវបានផ្ទុកក្នុងប្រព័ន្ធអេឡិកត្រូនិក និងរក្សាទុកក្នុងកុំព្យូទ័រក៏ដោយ ក៏ការពិនិត្យមើលការអប់រំនៅសម័យដែលមនុស្សមិនទាន់ចេះអាន និងសរសេរ អាចជួយឱ្យយើងយល់ដឹងពីមូលហេតុដែលសាលារៀន ជាញឹកញាប់ មិនព្រមផ្លាស់ប្តូរនៅពេលដែលគេបណ្តុះបណ្តាលយុវវ័យនូវបំណិនគង់នៅដ៏សំខាន់ (Essential survival skills)។

ខ-ការសិក្សាតាមបែបសាកល្បង និងមានកំហុស (Trial-and-error learning)

មនុស្សនៅសម័យដែលមិនទាន់ចេះអាន និងសរសេរបានប្រឈមមុខនឹងបញ្ហាដ៏ច្រើនលើសលុបនៃការរស់នៅក្នុងបរិស្ថានដែលបានទប់ទល់នឹងគ្រោះរាំងស្ងួតនិងទឹកជំនន់សត្វសាហាវ និងការវាយប្រហារពីក្រុមសត្រូវផ្សេងៗ។ តាមការសាកល្បងនិងមានកំហុស ពួកគេបានអភិវឌ្ឍបំណិនដែលមានគង់នៅក្នុងអំឡុងពេលមួយបានក្លាយជាវប្បធម៌គំរូ។

ដើម្បីឱ្យវប្បធម៌មានអត្ថិភាព វាត្រូវតែផ្ទេរពីមនុស្សចាស់ទៅឱ្យកុមារ។ តាមការបង្កើតឱ្យមានវប្បធម៌ កុមារបានសិក្សាបំណិន និងភាសារបស់ក្រុមហើយធ្វើឱ្យជ្រួតជ្រាបតម្លៃខាងសាសនា និងសីលធម៌។

គ-គោលការណ៍សីលធម៌

(Moral codes)

ក្នុងអំឡុងពេលមួយ ក្រុមបានអភិវឌ្ឍបំណិនគង់នៅ ហើយបានបន្តបំណិនទាំងនេះទៅឱ្យយុវវ័យ។ ពួកគេបានយកចិត្តទុកដាក់ទៅលើដំណើរឆ្ងង ពីកុមារទៅមនុស្សចាស់ជាមួយ

នឹងរបាំដែលកើតមានជាទម្ងាប់ តន្ត្រី និងការសម្តែងដែលគួរឱ្យរំកើបចិត្ត ដើម្បីបង្កើតនូវអត្ថន័យអភិធម្មជាតិដ៏មានឥទ្ធិពលនិងបួងសួងដល់ប្រសិទ្ធភាពខាងសីលធម៌។ កុមាររៀនសូត្របទប្បញ្ញត្តិរបស់ក្រុម (Group's prescriptions) (អាកប្បកិរិយាដែលគួរទទួលយកបាន) ព្រមទាំងការហាមឃាត់ ឬអ្វីដែលគេហាមមិនឱ្យប៉ះ ឬប្រើប្រាស់ (Proscriptions or taboos)។

ឃ-ប្រពៃណីផ្ទាល់មាត់ (Oral tradition)

ដោយខ្វះខាតផ្នែកសំណេរ ឬការកត់ត្រាក្នុងអតីតកាលសង្គមដែលមិនទាន់មានសំណេរនិងការអានពឹងផ្អែកទៅលើប្រពៃណីដែលធ្វើដោយមាត់ទទេ គឺការនិទានរឿង (Storytelling) ដើម្បីផ្ទេរមរតកវប្បធម៌របស់គេ (Cultural heritage)។ មនុស្សចាស់ ឬបព្វជិត ជាញឹកញាប់ជាមនុស្សមានតួនាទីខាងនិទានរឿង ច្រៀង ឬសូត្រការនិទានរឿងនៃប្រវត្តិអតីតរបស់ក្រុម។ ដោយផ្សំជំនឿសាមញ្ញ (Myths) និងរឿងព្រេង (Legends)ប្រពៃណី ដែលធ្វើដោយមាត់ទទេ បាននិទានប្រាប់មនុស្សក្មេងៗអំពីវីរជនរបស់ក្រុមជ័យជំនះ និងការបរាជ័យ។ ចម្រៀង និងរឿងនិទានបានជួយដល់យុវវ័យសិក្សាភាសានិយាយរបស់ក្រុម និងអភិវឌ្ឍនៃការគិតអរូបី (Abstract thinking) អំពីកាល និងលំហ។

ង-ការនិទានរឿង (Storytelling)

រឿងនិទាន និងការនិទានរឿងនៅតែជាល្បិចដ៏សំខាន់ និងការចូលរួមផ្នែកអប់រំនាពេលសព្វថ្ងៃ ជាពិសេសនៅមត្តេយ្យ និងថ្នាក់បឋមសិក្សា។ តាមរយៈរឿងនិទានកុមារទទួលបានបទពិសោធពីវប្បធម៌របស់គេ ហើយនិងវីរបុរស រឿងនិទាន និងប្រវត្តិរបស់ខ្លួន។

ច-អក្ខរកម្ម (Literacy)

ក្នុងនាមជាអ្នកបង្កើត ឧ.មនុស្សបានបង្កើតនឹងប្រើប្រាស់លំពែង (Spears) ពូថៅ និងឧបករណ៍ផ្សេងទៀត ជាឧទាហរណ៍នៃបច្ចេកវិទ្យាជំនាន់ដើមបង្អស់។ ស្រដៀងគ្នានេះ ក្នុងនាមជាអ្នកប្រើប្រាស់ភាសាមនុស្សបានបង្កើតនឹងបានប្រើប្រាស់យ៉ាងប៉ិនប្រសប់នូវសញ្ញាទាំងឡាយ។ ដោយបានចាប់ផ្តើមបញ្ជាក់បង្ហាញសញ្ញាទាំងនេះក្នុងសញ្ញាទាំងឡាយអក្សររូប និងអក្សរ ហើយនិងការបង្កើតភាសាសរសេរពាក់បញ្ចូលទាំងការលោតផ្លោះខាងវប្បធម៌ដ៏ធំធេងចំពោះការចេះអាន និងសរសេរ ហើយបន្ទាប់មក គឺការអប់រំ។

ក្របខណ្ឌសកលមួយ នៃការនិយាយយោងដល់នេះ នឹងជួយអ្នកឱ្យយល់ដឹងនូវចលនាពិភពលោក ដើម្បីអភិវឌ្ឍសាលារៀនក្នុងសង្គមអក្ខរកម្ម។ ព្រោះហេតុដូច្នេះហើយ ការបង្កើតជាប្រវត្តិសាស្ត្រ បានចាប់ផ្តើមជាមួយនឹងចក្រភពចិន និងឥណ្ឌាបុរាណ។

២. អប់រំតាមអរិយធម៌ចិនបុរាណ

(Education in the Ancient Chinese Civilization)

ប្រវត្តិសាស្ត្រអរិយធម៌ចិនដ៏យូរអង្វែងនិងឥទ្ធិពលដ៏ធំធេងផ្តល់នូវជម្រៅការយល់ដឹងដ៏សំខាន់ទៅជាការវិវត្តការអប់រំ។ ដោយមានចំនួនប្រជាជនដ៏ច្រើនបំផុតក្នុងពិភពលោក ប្រទេស

ចិនសម័យទំនើបគឺជាអំណាចសកលដ៏សំខាន់មួយ។ តាមប្រវត្តិសាស្ត្រចិនជាអតីតចក្រភពដ៏ធំមួយ ដែលអរិយធម៌របស់ខ្លួនបានឈានដល់កម្រិតកំពូលបំផុតខាងផ្នែកការអភិវឌ្ឍនយោបាយ សង្គម និងអប់រំ។ ចក្រភពនោះបានគ្រប់គ្រងទៅដោយសន្តតិវង្ស (Dynasties) ជាបន្តបន្ទាប់អស់រយៈពេលជាង៤០សតវត្សពីឆ្នាំ២២ ០០មុនគ.ស. ដល់ឆ្នាំ១៩១២[1]នៃគ.ស.។ ប្រពៃណីអប់រំជាច្រើនជាពិសេស ខុង ជឺនិយម មានប្រភពពីចក្រភពចិននៅតែមានឥទ្ធិពលដល់សព្វថ្ងៃ។

មរតកអប់រំនៅចិន បានបង្ហាញនូវការតស៊ូប្រឹងប្រែងជាខ្លាំងដើម្បីរក្សានូវនិរន្តរភាពវប្បធម៌ ដែលមិនអាចបំបែកបាន។ ប្រៀបដូចជាមនុស្សជាច្រើន ចិនសម័យដើម មានភាពប្រកាន់ពូជសាសន៍ ហើយជឿថា ភាសានិងវប្បធម៌របស់គេមានភាពកំពូលជាងជាតិសាសន៍ណាៗទាំងអស់[2]។ ដោយប្រមាថបរទេសថាជាអនារ្យជនជនជាតិចិន មើលតែភាពខាងក្នុង ដោយមើលឃើញតម្លៃតិចតួចនៅក្នុងវប្បធម៌ផ្សេងទៀត។ តាមពិតទៅភាពស្ងាត់ស្ងៀររបស់ចក្រភពចិនដើម្បីសម្របទៅនឹងបច្ចេកវិទ្យា ពីវប្បធម៌ផ្សេងទៀតធ្វើឱ្យចិននៅដាច់ពីគេ និងចុះទន់ខ្សោយហើយត្រឹមសតវត្សទី១៩ រងការឈឺចាប់ពីការកេងប្រវ័ញ្ចពីពួកបរទេស។ ការខិតខំអស់សមត្ថភាពពីរបៀបសម្របទៅនឹងគំនិតថ្មីៗជាពិសេសវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ហើយនិងការរក្សាវប្បធម៌ផ្ទាល់ខ្លួននៅតែជាបញ្ហាអប់រំដ៏សំខាន់នៅក្នុងប្រទេសចិនបច្ចុប្បន្ន ហើយនិងក្នុងប្រទេសផ្សេងទៀតផងដែរ។ ការខិតខំរបស់គេ ជួយយើងឱ្យយល់បានបញ្ហាដែលថា អ្នកក្នុងនាមជាគ្រូ ត្រូវតែសួរខ្លួនឯង៖ តើអ្នកអាចផ្តល់ឱ្យសិស្សជាមួយនឹងការវាយតម្លៃ ចំពោះសមិទ្ធផលវប្បធម៌ និងវិទ្យាសាស្ត្រអតីតកាល ព្រមទាំងបើកចំហចំពោះការផ្លាស់ប្តូរវប្បធម៌ និងសង្គមឬទេ? អ្វីជាទំនាក់ទំនងរវាងនិរន្តរភាពវប្បធម៌និងការផ្លាស់ប្តូរ ហើយការអប់រំជំរុញដល់ទំនាក់ទំនងនិរន្តរភាពវប្បធម៌ និងការផ្លាស់ប្តូរមួយ ឬផ្សេងទៀតយ៉ាងដូចម្តេច?

២-១-ការអប់រំតាមបែបខុងជឺ (Confucian education)

ក-ភាពស្មោះត្រង់នៅក្នុងក្រុម (Group loyalty)

មនុស្សជាច្រើន ជាពិសេសក្នុងប្រទេសចិន ជប៉ុន កូរ៉េខាងត្បូង សិង្ហបុរី ឱ្យតម្លៃទៅលើខុងជឺ (៥៥១-៤៧៩មុនគ.ស.) ថាជាទស្សនវិទូដ៏ល្បីបំផុតរបស់ពិភពលោក និងជាគ្រូបង្រៀនអស់រយៈពេលជាង២០០០ឆ្នាំ ប្រព័ន្ធសីលវិទ្យារបស់ខុងជឺ ដោយមានការសង្កត់ធ្ងន់ទៅលើវិន័យបុគ្គលភាពស្មោះត្រង់ចំពោះគ្រួសារ និងក្រុម និងតម្រូវការសម្រាប់ភាពស្របគ្នាខាងនយោបាយ និងសង្គមបានបង្កើតរូបភាពការអប់រំ និងអរិយធម៌ចិន[3]។

---

[1] Edward Shaughnessy, *China: Empire and civilization* (New York: Oxford University Press, 2000).

[2] Roxann Praznik, *Dialogues Across Civilization: Sketches in World History from the Chinese and European experiences* (Boulder, Colo.: Westview HarperCollins, 1996

[3] See Peimin Ni, *On Confucius* (Belmont, Calif.: Wadsworth, 2002) and Jennifer Oldstone More, Conf-

ខ-តម្រូវការសម្រាប់តាពចុះសម្រុងនឹងគ្នា (Need for harmony)

ខុងជឺ បានរស់នៅក្នុងអំឡុងពេលមានសង្គ្រាមរវាងរដ្ឋនានា (The warring states period) នៃប្រវត្តិសាស្ត្រចិនដែលជាសម័យកាលមួយនៃភាពចលាចលវឹកវរ (Chaotic turmoil) អំពើក្បត់ (Treachery) និងទំនាស់។ មេទ័ពដែលមានការប្រកួតប្រជែង(Rival warlords) ដោយប្រើប្រាស់ភាពឈ្លាសវៃ ចិត្តវៀចវេរ (Duplicity) និងកម្លាំងដូចសត្វតិរច្ឆាន (Brute force) បានតស៊ូប្រយុទ្ធដើម្បីអំណាច។ សន្ធិសញ្ញាផ្សេងៗ ត្រូវបានគេបង្កើតឡើង ហើយបន្ទាប់មក មិនត្រូវបានគេយកមកអនុវត្ត។ អំពើស៊ីសំណូកសូកប៉ាន់ (Bribery) ធ្វើឱ្យពួកគេពេញចិត្តជាខ្លាំង ការលួចធ្វើឃាត (Assassi- nations) គឺជារឿងធម្មតា។ ដើម្បីឆ្លើយតបទៅនឹងសម័យកាលបែបនេះ ខុងជឺ បានបង្កើតទស្សវិជ្ជាអប់រំ និងសីលវិទ្យាដើម្បីស្តារសន្តិភាព និងភាពចុះសម្រុងគ្នានៅក្នុងប្រទេសចិន។ ដោយជឿជាក់ថាចំណេះដឹងអាចជំនួសកម្លាំង គាត់បានបង្កើតសាលារៀនមួយ ដែលគាត់អាចអប់រំមន្ត្រីរដ្ឋាភិបាលនាពេលអនាគតដើម្បីគ្រប់គ្រងប្រទេសចិនដោយយុត្តិធម៌ ភាពត្រឹមត្រូវ និងសណ្តាប់ធ្នាប់។

គ-ទម្លាប់ និងមារយាទ (Rituals and manners)

សម្រាប់ខុងជឺ គោលដៅឧត្តុង្គឧត្តមរបស់ការអប់រំ គឺត្រូវអភិវឌ្ឍមនុស្ស ដែលមានអត្តចរិតថ្លៃថ្នូរដែលតាមការសិក្សាដោយយកចិត្តទុកដាក់ និងជាបន្តបន្ទាប់ទទួលបានចំណេះដឹងចាំបាច់ដើម្បីអនុវត្តតាមរបៀបមធ្យោបាយមួយដែលនាំទៅដល់ចិត្តមេត្តា (Benevolence) ជាជាងអំពើហិង្សា (Violence)។ តាមការស្វែងរកការកាត់បន្ថយអកុលតាដែលបណ្តាលឱ្យមានការផ្លាស់ប្តូរភ្លាមៗនោះ ខុងជឺ បានរៀបចំចាត់ចែងប្រព័ន្ធអប់រំ និងសីលវិទ្យា នៅជុំវិញការសិក្សាពីរបៀបសង្កេតទម្លាប់និងរបៀបរបប ដែលគ្រប់គ្រងទំនាក់ទំនងមនុស្ស តាមឋានានុក្រមសង្គម។ ឧត្តមគតិរបស់គាត់នៃទំនាក់ទំនងតាមឋានានុក្រម អាចត្រូវបានពិពណ៌នា ថាជាកាំជណ្តើរសីលវិទ្យាដែលមនុស្សកំពុងតែឈរ នៅលើកាំនីមួយៗ ត្រូវបានភ្ជាប់ទៅនឹងមនុស្ស ដែលកំពុងតែឈរ នៅខាងលើ និងខាងក្រោម។ មនុស្សរាល់គ្នាតាមឋានានុក្រមគួរតែដឹងយ៉ាងច្បាស់លាស់នូវឋានៈរបស់ខ្លួន និងការទទួលខុសត្រូវ ហើយនិងរបៀបដ៏សមរម្យនៃការប្រព្រឹត្តចំពោះមនុស្សផ្សេងទៀត។

ឃ-ឋានានុក្រម (Hierarchy)

ក្នុងនាមជាគ្រូបង្រៀនម្នាក់ តើអ្នកនឹងជួយសិស្សរបស់ខ្លួនដើម្បីឱ្យអភិវឌ្ឍទំនាក់ទំនងនិងតម្លៃមនុស្សជាវិជ្ជមានយ៉ាងដូចម្តេច? តើតម្លៃទាំងនេះ នឹងធ្លុះបញ្ចាំងស្តង់ដារប្រពៃណី ឬវានឹងមិនមានដែនកំណត់? បញ្ញត្តិនៃទំនាក់ទំនងសីលវិទ្យាតាមឋានានុក្រមមានការអនុវត្តជាសំខាន់សម្រាប់ការអប់រំ ជាពិសេសការបង្កើតអត្តចរិត។ បញ្ញត្តិរបស់ខុងជឺ នៃទំនាក់ទំនងតាមឋានានុក្រមដែលបុគ្គលមួយចំនួន មានភាពខ្ពង់ខ្ពស់ ហើយ

---

ucianism (Oxford and New York: Oxford Univ-ersity Press, 2002).

អ្នកផ្សេងទៀត មានតួចតាច ខុសគ្នាយ៉ាងខ្លាំងពី គំនិតសាមញ្ញរបស់យើងសព្វថ្ងៃនៃទំនាក់ទំនងមនុស្សដោយផ្អែកលើសមភាព។

តាមលក្ខខណ្ឌសមភាពបុគ្គល ដែលចូលរួមក្នុងទំនាក់ទំនងមួយកំណត់ជាបន្តបន្ទាប់នូវទំនាក់ទំនង និងបង្កើតការបើកចំហថ្មីៗចំពោះគ្នាទៅវិញទៅមក ហើយជាញឹកញាប់បង្កើត ឬបង្កើតឡើងវិញនូវដែនកំណត់ទាំងឡាយ។ ការអប់រំអត្តចរិតនៅក្នុងស្ថានភាពនៃសមភាពនាំទៅដល់បញ្ញត្តិសីលវិទ្យាដែលយើងគួរប្រព្រឹត្តដល់បុគ្គលម្នាក់ៗ ថាមានភាពស្មើៗគ្នា ហើយយើងគួរតែគោរព និងវាយតម្លៃនូវភាពខុសគ្នារបស់គេពីយើង។

ផ្ទុយទៅវិញ សីលវិទ្យាខុងជឺ បង្កើតគំរូជាក់លាក់នៃអាកប្បកិរិយា ជាជាងភាពបត់បែន ឬទន់ភ្លន់។ មនុស្សត្រូវបានអនុញ្ញាតឱ្យមានកម្រិតគោរពផ្សេងៗគ្នា ដោយផ្អែកទៅលើតំណែងឬឋានៈ និងសមិទ្ធផល។ ការអប់រំអត្តចរិត មានន័យថារៀនពីតួនាទីនៅក្នុងបណ្តាញនៃទំនាក់ទំនងដែលបង្កើតបានសហគមន៍ និងដើម្បីបំពេញអាកប្បកិរិយាតួនាទីទៅតាមបញ្ញត្តិដែលជានាដល់ភាពចុះសម្រុងគ្នានៅក្នុងសង្គម។

ពីព្រោះតែការផ្លាស់ប្តូរភាពថ្មីថ្មៃកៗ នាវនុវត្តន៍អាចនាំដល់ក្តីមិនរំពឹងទុកមុន ហើយការផ្លាស់ប្តូរដោយមិនរំពឹងទុកមុន គឺជាបញ្ហាសង្គមមួយនោក្នុងពេលនេះ ខុង ជឺ បានផ្អែកប្រព័ន្ធសីលវិទ្យាទៅតាមប្រពៃណី។ ការប្រតិបត្តិដ៏ពិតប្រាកដមួយឬអាកប្បកិរិយាដែលរួមចំណែកដល់ការរក្សាសន្តិភាព សន្តិសុខនិងភាពរំងាប់ចិត្ត(Tranquility) ក្នុងអតីតកាលនៃតម្លៃដែលត្រូវបានស្រោបក្នុងរបៀបតាមទម្លាប់នៃការប្រព្រឹត្ត ហើយត្រូវបានផ្ទេរនិងប្រតិបត្តិ ដោយមនុស្សនាពេលបច្ចុប្បន្ន។ ដោយយោងទៅតាមខុងជឺ "មនុស្សម្នាក់ដែលមានតម្លៃជាគ្រូត្រូវចេះដឹងពីអ្វីដែលថ្មីតាមការរក្សាចំណេះដឹងថ្មីៗក្នុងចិត្តនូវអ្វីៗដែលគាត់បានចេះដឹងរួចមកហើយ"[៤]។

ខ-ការគោរព ចំពោះគ្រូ (Respect for teachers)

នៅប្រទេសចិន ទំនាក់ទំនងគ្រូ-សិស្ស ដូចទំនាក់ទំនងផ្សេងទៀតដែរ គឺមានភាពល្បីល្បាញ និងត្រូវមានភាពជាក់លាក់។ សិស្សត្រូវគោរពគ្រូរបស់គេជាខ្លាំង និងខ្ពង់ខ្ពស់។ សិស្សផ្ទាល់របស់ខុង ជឺ បានហៅគាត់ថា លោកម្ចាស់(The master)។ ការគោរពចំពោះការអប់រំ ការសិក្សា និងគ្រូ បានក្លាយជាលក្ខណៈពិសេសដ៏សំខាន់នៃការអប់រំក្នុងប្រទេសចិន និងអាស៊ីអាគ្នេយ៍ ដែលជាកន្លែងដែលខុងជឺ បានក្លាយជាបញ្ញវន្តចម្បង និងកម្លាំងអប់រំ[៥]។

២-២-ការរួមចំណែករបស់ចិន ចំពោះការអប់រំពិភពលោក(Chinese's contribution to world education)

សារៈសំខាន់នៃការប្រឡង គេរដំណែលអប់រំដ៏សំខាន់ពីចិនបុពណ គឺប្រព័ន្ធការប្រឡង

[៤] Confucius, *The Analects*, Book II, in D. C. Lau, Introduction, *The Analects*, trans. D. C. Lau (New York: Penguin Books, 1979), p. 64.

[៥] T.R. Reid, *Confucius Lives Next Door: What living in the East Teaches Us about Living in the West* (New York: Vintage Press, 2000).

ថ្នាក់ជាតិ។ គរុវិទូចិន បានអភិវឌ្ឍការប្រឡងបែបសរសេរតាមការយល់ដឹង ដើម្បីវាយតម្លៃសមត្ថភាពសិក្សារបស់សិស្ស។ សិស្សបានត្រៀមរៀបចំដើម្បីប្រឡងតាមការសិក្សាអក្សរសិល្បចិនបុរាណ និងអត្ថបទ ខុង ជឺ ជាមួយគ្រូនៅសាលាតាមព្រះវិហារ ឬព្រះបរមរាជវាំង។ ការប្រឡងសង្កត់ធ្ងន់ទៅលើការចងចាំ ដោយទន្ទេញព័ត៌មានជាជាងដោះស្រាយបញ្ហាជាក់ស្តែង។ ដំណើរការប្រឡង ដូចជាសង្គមបានដំណើរការតាមឋានានុក្រម និងតាមការជ្រើសរើស។ សិស្ស ត្រូវតែប្រឡងជាប់នូវលំដាប់នៃការប្រឡងដ៏លំបាក តាមលំដាប់កើនឡើង។ ប្រសិន បើគេប្រឡងធ្លាក់ គេនឹងត្រូវបណ្តេញចេញពីដំណើរការនោះ[៦]។ នៅក្នុងសម័យកាលនោះ មានតែអ្នកប្រឡងដល់ទីបញ្ចប់តិចតួចតែប៉ុណ្ណោះអាចទទួលបានតំណែងសេវាកម្មស៊ីវិលជាន់ខ្ពស់បំផុតរបស់ចក្រភពចិន។ ប្រព័ន្ធអប់រំនិងការប្រឡងត្រូវបានរក្សាទុកឱ្យទាំងស្រុងតែមនុស្សប្រុសវណ្ណៈខ្ពស់ប៉ុណ្ណោះ។ ស្ត្រីដែលមិនអាចទទួលតំណែងក្នុងរដ្ឋាភិបាលនោះមិនមានសិទ្ធិចូលរៀនផងដែរ។

៣. ការអប់រំតាមអរិយធម៌ឥណ្ឌាបុរាណ

ក-សមាគមប្បធម៌

ដូចជាប្រទេសចិន ឥណ្ឌា មានអរិយធម៌បុរាណមួយ។ អរិយធម៌ទាំងឡាយដែលមាននៅតាមជ្រលងភ្នំ ទន្លេ លូតលាស់បានល្អនៅតាមច្រាំងទន្លេឥណ្ឌុស (Indus) របស់ឥណ្ឌានៅ Mohenjodaro and Harrapa ពី៣០០០មុនគ.ស. ទៅដល់១៥០០មុនគ.ស។ ប្រវត្តិអប់រំរបស់ឥណ្ឌាបានលាតត្រដាងនូវគំរូនៃការឈ្លានពានជាទូទៅដោយអ្នកលុកលុយឈ្លានពានដែលបន្ទាប់មកដោយការប៉ះទង្គិចខាងវប្បធម៌ ជាមួយជនជាតិដើម ហើយបន្ទាប់មកគឺការស្ពារសមតាវប្បធម៌សង្គម។ នៅក្នុងសមតាវប្បធម៌នេះ អ្នកឈ្លានពានត្រូវបានគេស្រូបទាញយកទៅជាវប្បធម៌ឥណ្ឌាដែលនៅពេលជាមួយគ្នានោះ ជនជាតិដើមបានខ្ចីគំនិតពីអ្នកឈ្លានពានលុកលុយមួយចំនួន[៧]។

ខ-ប្រវត្តិសង្ខេប

នៅក្នុងចំណោមអ្នកលុកលុយជំនាន់ដើមរបស់ឥណ្ឌា គឺពួកអារ្យ៉ន (The Aryans) ជាបុព្វបុរសនៃអម្បូរជនភាគច្រើនដែលនិយាយភាសាហិណ្ឌូ (Hindi-speaking majority) របស់ឥណ្ឌាដែលបានចូលលុកលុយឥណ្ឌាក្នុង១៥០០ឆ្នាំមុនគ.ស. ហើយបានបង្ខំការត្បូតត្រាពួកស្រុកដើមទ្រាវិទ (The indigenous Dravidian inhabitants)។ បន្ទាប់មកមានពួកអ្នកកាន់សាសនាអ៊ីស្លាមដែលបានបង្កើតសន្តតិវង្ស Mughul ក្នុងសតវត្សទី១៣។ បន្ទាប់មកទៀត ក្នុងសតវត្សទី១៨ ចក្រភពអង់គ្លេស បានត្បូតត្រាប្រទេសឥណ្ឌា។

ការផ្លាស់ប្តូរវប្បធម៌ ដែលបាននាំមកដោយពួកអារ្យ៉នបានបង្កើតឥទ្ធិពលអប់រំ និងសង្គមដ៏មានអំណាចដែលបានបន្តមកដល់ពេល

[៦] Conrad Schriokauer, *A Brief History of Chinese Civilization* (New York: Harcourt Brace Jovanovich, 1991), pp. 57, 124, 128.

[៧] See Stanley A. Wolport, Herman Kulke and Dietmar Rothermunt, *A history of India* (New York: Routlege, 1998

សព្វថ្ងៃៗពួកអារ្យ៉ែនបាននាំមកនូវសាសនាព្រាហ្មណ៍និងវណ្ណៈសង្គមដ៏ខ្ពង់ខ្ពស់របស់គេដែលគេបានហៅថា ប្រព័ន្ធវណ្ណៈ(The caste system)។

គ-សាសនាឥណ្ឌា

សាសនាឥណ្ឌា ដែលជាកម្លាំងដ៏មានឥទ្ធិពលមួយ នៅក្នុងប្រទេសឥណ្ឌានោះ រួមបញ្ចូលទាំងជំនឿសាសនាដ៏ទូលំទូលាយមួយ និងទម្លាប់ដ៏ល្អិតល្អន់ទាំងឡាយ។ សាសនាឥណ្ឌា សង្កត់ធ្ងន់ទៅលើការផ្ទាស់ប្តូរនៃព្រលឹង(Transmigration of souls) គឺព្រលឹងរបស់មនុស្សម្នាក់ បានឆ្លងកាត់ការចាប់បដិសន្ធិជាថ្មី (Reincarnations) ជាច្រើនហើយតំណែងរបស់មនុស្សម្នាក់ នៅក្នុងកម្រិតលោកធាតុ អាស្រ័យទៅលើមនុស្សម្នាក់ ប្រកាន់នូវករណីកិច្ច និងទម្លាប់បានល្អយ៉ាងដូចម្តេច។ ការចាប់បដិសន្ធិជាថ្មី (Reincarnations) បញ្ចប់តែនៅពេលដែលព្រលឹង បានឈានដល់កម្រិតខាងផ្លូវចិត្តឬស្មារតីខ្ពស់បំផុត ហើយត្រូវបានស្រូបទាញឡើងវិញដោយព្រហ្ម (Brahma) ដែលជាអំណាចមកពីអាទិទេព[ជ]។

ឃ-ប្រព័ន្ធឥណ្ឌា:

វណ្ណៈដែលជាប្រភពដើម មាន៤គឺ៖

-ព្រាហ្មណ: (Brahmins) = អ្នកអប់រំដែលជាបព្វជិត (Priest-educators)

-ក្សត្រិយ: (Kshatriyas) = អ្នកគ្រប់គ្រង (rulers) ចៅក្រម (Judges) និងអ្នកចម្បាំង (Warriors)

-វៃស្យ: (Vaishyas) = ពាណិជ្ជករ ម្ចាស់ដី (Merchants)

-សូទ្រ: (Sudras)= កសិករ ទាសករ (The farmers)។

ស្រទាប់វណ្ណៈក្រោមគេបំផុត គឺអ្នកដែលគេមិនឱ្យប៉ះពាល់ ឬមនុស្សក្រៅវណ្ណ: (The untou- chables) ដែលធ្វើការងារថោកទាបបំផុត (The most menial work)។ ចល័តភាពសង្គម មិនមានទាល់តែសោះ។ មនុស្សនៅតែស្ថិតក្នុងវណ្ណៈដដែល តាំងពីពេលដែលគេបានកើតមក ហើយបានរៀនសូត្រនូវករណីកិច្ច និងតួនាទីរបស់ខ្លួនដោយត្រាប់តាមឪពុកម្តាយ និងមនុស្សចាស់ផ្សេងទៀត។ ការសិក្សាអប់រំ ទុកឱ្យតែមនុស្សវណ្ណៈខ្ពស់តែប៉ុណ្ណោះ ជាពិសេស គឺពួកព្រាហ្មណ:។ ដោយចាត់ទុកថា ការរើសអើងវណ្ណៈជាការខុសច្បាប់ឥណ្ឌាសម័យទំនើបបានបង្ខំឱ្យមានសកម្មភាពវិជ្ជមានសម្រាប់សមាជិកវណ្ណៈទាប។ ទោះជាយ៉ាងនេះក្តី ការរើសអើងនៅតែកើតមាន។

៣-១-ការវិវត្តនៃការអប់រំឥណ្ឌា

ការអប់រំនៅឥណ្ឌា បានឆ្លុះបញ្ចាំងនូវគំរូជាប្រវត្តិសាស្ត្រទូទៅនៃការរស់នៅ លាយឡំនឹងវប្បធម៌ផ្សេងៗគ្នា។ សាលារៀនសម័យដើម បានឆ្លុះបញ្ចាំងនូវការផ្ទាស់ប្តូរវប្បធម៌ ដែលនាំមកដោយពួកអារ្យ៉ែន។ ឥណ្ឌាបុរាណ មានប្រភេទសាលារៀនដូចតទៅ៖

ក-វេទ: (Veda = Knowledge)

1-សាលារៀនពួកព្រាហ្មណ៍សម្រាប់វណ្ណៈបព្វជិត សង្កត់ធ្ងន់ទៅលើសាសនា ទស្សនវិជ្ជា។

[ជ] Arvrin Sharma, ed. *The Study of Hinduism* (Columbia: University of South Carolina Press, 2003; also see Mehdi Nakosteen, *The History and Philosophy of Education* (New York: Ronald Press, 1965), pp.23-30

វេទ (Vedas) the Bhagavad Gita (& The Upanishads) និងឧបនិស័ទ សៀវភៅសាសនាដ៏ពិសិដ្ឋរបស់ព្រាហ្មណ៍ ពណ៌នាគោលដៅនៃជីវិតថា ជាការស្រាវជ្រាវសច្ចភាពខាងស្មារតីសកល។ ការស្វែងរកសច្ចភាព ដែលអ្នកអប់រំឥណ្ឌាជឿជាក់នោះ គឺថា ការទាមទារឱ្យមានការតាំងភាវនាដ៏មានវិន័យ។ ការតាំងភាវនាអព្ភោហារិកនាសម័យទំនើប និងយោគៈ ធ្វើតាមគោលការណ៍ឥណ្ឌាបុរាណដើម្បីស្វែងរកសច្ចភាព និងភាពស្ងប់ស្ងៀម (Serennity) ខាងស្មារតី។

2-Tols ជាសាលារៀនដែលមានតែមួយបន្ទប់ ដែលមានតែគ្រូបង្រៀនតែម្នាក់ បង្រៀនសាសនា និងច្បាប់។

3-សាលារៀនវាំង ទទួលខុសត្រូវដោយព្រះអង្គម្ចាស់ បង្រៀនអក្សរសាស្ត្រ ច្បាប់ និងរដ្ឋបាល។

ខ-សាលារៀន និងការបង្រៀន

ទស្សនវិជ្ជាអប់រំឥណ្ឌា ដោយបានសង្កត់ធ្ងន់ទៅលើសាសនាបានបញ្ជាក់ទំនាក់ទំនងគ្រូសិស្សយ៉ាងសមរម្យ។ គ្រូត្រូវតែលើកទឹកចិត្តសិស្ស (ឱ្យចេះគោរពជីវិត?) និងចេះស្រាវជ្រាវរកសច្ចភាព។ សិស្សត្រូវតែគោរពគ្រូដែលជាប្រភពនៃគតិបណ្ឌិត ហើយគ្រូត្រូវតែចេះទប់អារម្មណ៍ កុំធ្វើឱ្យសិស្សអា ម៉ាស់មុខ[9]។

គ-Mughuls

សន្តតិវង្ស Mughulsដែលបង្កើតឡើងក្រោយពេលមានការចូលលុកលុយនៃពួកមូស្លីមបាននាំមកនូវសាសនាអ៊ីស្លាម និងទស្សនវិជ្ជាពួក Persian និងអារ៉ាប់ វិទ្យាសាស្ត្រ អក្សរសាស្ត្រ តារាសាស្ត្រ(Astronomy)គណិតវិទ្យា វេជ្ជសាស្ត្រ សិល្បៈ តន្ត្រី និងស្ថាបត្យកម្ម (Architecture)។

ឃ-ការចូលមកដល់នៃពួកអង់គ្លេស

ត្រឹមពេលដែលជនជាតិអង់គ្លេសបានចូលមកដល់ប្រទេសឥណ្ឌានៅចុងសតវត្សទី១៨ សាលារៀនរបស់ពួកឥណ្ឌាដឹកនាំដោយពួកឥណ្ឌាឬមូស្លីមឬដោយនិកាយតូចៗដូចជា ពុទ្ធសាសនិកជន Jains, and Parsis។ មានតែ១០% នៃកុមារឥណ្ឌា ភាគច្រើនក្មេងប្រុសបានចូលរៀន។ សាលារៀនជាន់ខ្ពស់ឥណ្ឌា ដឹកនាំដោយពួកព្រាហ្មណ៍ដោយសង្កត់ធ្ងន់លើអក្សរសិល្ប៍ខាងសាសនា គណិតវិទ្យា តារាសាស្ត្រ និងវេយ្យាករណ៍សំស្ក្រឹត។ សាលារៀនពួកមូស្លីមហៅថា Madrassahs ត្រូវបានផ្សារភ្ជាប់ទៅនឹងព្រះវិហារម៉ូស (Mosques) ហើយនិងសង្កត់ធ្ងន់ទៅលើវេយ្យាករណ៍ និងគម្ពីរកូរ៉ាន (Korans)[10]។

នៅពេលដែលចក្រភពអង់គ្លេសបានបង្កើតការគ្រប់គ្រង តាមបែបអាណានិគម នៅក្នុងប្រទេសឥណ្ឌា ពួកគេ បានប៉ះទង្គិចនឹងអរិយធម៌ជាមួយនឹងភាសា និងសាសនាជាច្រើន។ ពួកអង់គ្លេសដោយឱ្យតម្លៃទៅលើភាសាអង់គ្លេស

[9] Nandish Patel, A Comparative Exposition of Western and Vedic Theories of the Institution of Education, *International Journal of Educational Management 8* (1994), pp-9-14

[10] Lawrence James, Raj: The Making and Unmaking of British India (New York: St. Martin's Press, 1998).

ជាង៣សាសកំណើតរបស់ឥណ្ឌា បានបង្កើតភាសាអង់គ្លេសជាភាសាផ្លូវការសម្រាប់រដ្ឋាភិបាលនិងពាណិជ្ជកម្មហើយនិងបានបង្កើតសាលារៀនដែលប្រើប្រាស់ភាសាអង់គ្លេសដើម្បីបណ្តុះបណ្តាលជនជាតិឥណ្ឌាសម្រាប់មុខតំណែងនៅក្នុងសេវាកម្មស៊ីវិល ដែលគ្រប់គ្រងដោយជនជាតិអង់គ្លេស។

៣.២-ការរួមចំណែករបស់ឥណ្ឌាចំពោះការអប់រំពិភពលោក

កេរដំណែលរបស់ឥណ្ឌាបុរាណ ចំពោះពិភពលោក គឺជាគំរូនៃរបៀបអប់រំ អាចជួយ ដល់អរិយធម៌មួយអស់រយៈពេលជាច្រើនសតវត្សរ៍ តាមរយៈការធ្វើឱ្យជ្រួតជ្រាបវប្បធម៌និងការសម្របសម្រួលឡើងវិញនោះ អរិយធម៌ឥណ្ឌាបានស្ថិតនៅរហូតដល់បច្ចុប្បន្ន។ នៅក្នុងបរិយាកាសពូថៃ ដែលមានភាពតានតឹងខាងសាសនា និងជាតិសាសន៍ ដែលចេះតែមានការកើនឡើងនោះ ឥណ្ឌាបានប្រឈមមុខនឹងការប្រឆាំងយ៉ាងខ្លាំងក្នុងការធ្វើឱ្យជ្រួតជ្រាប និងគោរពវប្បធម៌ផ្សេងៗ។ សហរដ្ឋអាម៉េរិក និងជាតិដែលមានពហុភាពខាងវប្បធម៌ផ្សេងៗប្រឈមមុខនឹងការប្រឆាំងដូចៗគ្នា។ ស្ថានភាពរបស់ឥណ្ឌាបានលាតត្រដាងពីរបៀបដែលវណ្ណៈ ដូចជា ជាតិសាសន៍និយម នៅក្នុងសហរដ្ឋអាម៉េរិក ត្រូវបានធ្វើឱ្យមាននិរន្តរភាពដោយសង្គម និងការអប់រំ ប៉ុន្តែឥឡូវនេះ កំពុងត្រូវបានកែលំអ តាមរយៈលំនាំការអប់រំ។ លោកអ្នកក្នុងនាមជាគ្រូបង្រៀនម្នាក់ទំនងជានឹងត្រូវបានប្រឆាំងតាមភាពផ្សេងៗនៃសិស្សរបស់អ្នក។ តើអ្នកនឹងប្រើពហុវប្បធម៌និយមជាមធ្យោបាយដំរុញភាពផ្សេងៗគ្នាខាងវប្បធម៌ក្នុងថ្នាក់រៀនរបស់អ្នក?

៤. ការអប់រំ នៅប្រទេសអេហ្ស៊ីបបុរាណ

អេហ្ស៊ីបបុរាណ ដែលជាប្រទេសមួយមានអរិយធម៌ដំបូងបង្អស់ក្នុងពិភពលោកនោះ បានអភិវឌ្ឍ ដូចជាចំនួនប្រជាជនសម័យដើមផ្សេងទៀត ជាវប្បធម៌ជ្រលងភ្នំ និងទន្លេ។ ដោយសារតែទឹក ដែលកំពុងតែទ្រទ្រង់ដល់ជីវិតនៃទន្លេនីល(៦,៨៥៣គម)នោះ ក្រុមកសិកម្មបានបង្កើតការតាំងទីលំនៅជាភូមិតូចៗ រៀបចំទៅជារាជាណាចក្រតាមកុលសម្ព័ន្ធនៅតាមច្រាំងទន្លេ។ ប្រហែលជា៣០០០មុនគ.ស. រាជាណាចក្រទាំងនេះបានពង្រឹងខ្លួនឱ្យទៅជាចក្រភពដ៏ធំមួយ ដែលតាមពិតទៅក្លាយទៅជាប្រទេសដែលមជ្ឈមណ្ឌលសក្តានុពលខាងនយោបាយ និងការរៀបចំដ៏ខ្ពង់ខ្ពស់។

លោកជាតុដែលមិនប្រែប្រួល

គោលការណ៍នយោបាយ និងសាសនាអេហ្ស៊ីបដ៏សំខាន់ បានអះអាងថា ផារ៉ាអុង (Pharaoh) ដែលជារាជាធិរាជនោះ (Emperor) មានប្រភពពីអាទិទេព។ បញ្ញត្តិនៃរាជាធិរាជភាពផ្តល់នូវស្ថិរភាពខាងនយោបាយ អប់រំ វប្បធម៌ និងសង្គមទៅដល់ចក្រភពអេហ្ស៊ីបដោយផ្តល់មូលដ្ឋានគ្រឹះសមស្របតាមអតិ ធម្មជាតិ។ ចំណេះដឹង និងតម្លៃ ត្រូវបានគេមើលឃើញថា ជាការធ្វេះបញ្ចាំងលោកជាតុអនន្តមិនផ្លាស់ប្តូរ និងមានរបៀបរៀបរយ។

បញ្ញត្តិនៃបព្វជិតភាជា ក៏ផ្តល់ផងដែរនូវហាន:យ៉ាងខ្ពស់នៃវរជនដែលជាបព្វជិត និងអំណាចដ៏ខ្លាំងនៅក្នុងអេហ្ស៊ីប។ ប្រព័ន្ធអប់រំពង្រឹងហាន: និងអំណាចដោយបង្កើតឆ្មាំវរជនដែលជាបព្វជិតនៃវប្បធម៌របស់រដ្ឋ។

៤.១-ការយកចិត្តទុកជាក់ធម្មចក្រ និងអាណាចក្រ

ទាក់ទិននឹងការអប់រំ ជនជាតិអេហ្ស៊ីបមានទំនាក់ទំនងនឹងលោកិយ និងមិនមែនលោកិយ។ ទោះបីជាមានអភិធម្មជាតិពីមុន ពួកគេក៏បានអភិវឌ្ឍបច្ចេកវិទ្យា ដើម្បីនាំទឹកទន្លេនីលរៀបចំនិងស្ថាបនាប្រាសាទពីរ៉ាមីដដ៏ច្រើន។ ដើម្បីគ្រប់គ្រង និងការពារចក្រភពដ៏ធំទូលាយរបស់គេ ពួកគេបានសិក្សាជំនាញក្នុងការគ្រប់គ្រងរដ្ឋ (Statecraft) និងការយកចិត្តទុកជាក់របស់ពួកគេជាមួយការរក្សាសពមិនឱ្យរលួយ(Mummification) ដែលបាននាំឱ្យពួកគេ សិក្សាវេជ្ជសាស្ត្រ កាយវិភាគវិទ្យា និងការអប់សព(Embalming)។ ជនជាតិអេហ្ស៊ីប ក៏បានអភិវឌ្ឍផងដែរនូវប្រព័ន្ធនៃការសរសេរអក្សរ គឺអក្សររូប(Hiero- glyphic script) ដែលជួយឱ្យពួកគេបង្កើតនិងផ្ទេរវប្បធម៌ការសរសេរអក្សរ។

ក-សាលារៀន តាមព្រះវិហារ និងវាំង

ចក្រភពអេហ្ស៊ីប ទាមទារឱ្យមានការិយាធិបតេយ្យ ដែលមានការអប់រំ ដើម្បីប្រមូល និងកត់ត្រាបន្ទុក។ ត្រឹមឆ្នាំ២៧០០មុនគ.ស. ជនជាតិអេហ្ស៊ីប មានប្រព័ន្ធសាលារៀន តាមព្រះវិហារ និងវាំងយ៉ាងទូលំទូលាយ។ មុខងារសាលារៀនមួយត្រូវបណ្តុះបណ្តាលមនុស្សឱ្យចេះបង្កើតការកត់ត្រា(Scribes) ដែលភាគច្រើននៃពួកគេ គឺជាបព្វជិតក្នុងការអាន និងសរសេរ។ សាលារៀនជាញឹកញាប់ គឺជាផ្នែកមួយនៃអគារជាច្រើនផ្តុំគ្នា នៅតាមព្រះវិហារដែលធ្វើឱ្យរីកចម្រើនដល់ទំនាក់ទំនងយ៉ាងជិតស្និទ្ធ រវាងការអប់រំក្នុងប្រព័ន្ធ និងសាសនា[99]។ ក្រោយពេលទទួលបានការអប់រំជាលើកដំបូងក្មេងប្រុសបានសិក្សាអក្សរសាស្ត្រសមស្របទៅនឹងវិជ្ជាជីវៈនាពេលអនាគតរបស់គេ។ សាលារៀនជាន់ខ្ពស់ ពិសេសបានបង្កើតឡើងសម្រាប់បព្វជិតពិតប្រាកដ មន្ត្រីរដ្ឋាភិបាល និងគ្រូពេទ្យ។

ខ-ការអប់រំមនុស្សឱ្យចេះកត់ត្រា

នៅក្នុងសាលារៀន ដែលបង្ហាត់មនុស្សឱ្យចេះកត់ត្រា សិស្សរៀនសរសេរអក្សររូប តាមការចម្លងឯកសារនៅលើក្រដាសម្ស៉ាងផលិតចេញពីដើមត្រែង ឬបបុសដែលដុះនៅតាមដងទន្លេនីល។ គ្រូហៅឱ្យសិស្សកត់ត្រានូវអ្វីដែលគេបានឮ។ គោលដៅ គឺត្រូវបង្កើតឡើងវិញនូវការកត់ត្រាអត្ថបទឱ្យបានត្រឹមត្រូវដូចដើម។ ជាញឹកញាប់ សិស្សស្រែកសូត្រដដែលៗនូវអត្ថបទខ្លីៗ រហូតដល់ពួកគេចាំបានច្បាស់លាស់។ អ្នកទាំងឡាយដែលបានរៀនពូកែ ត្រូវបានសិក្សា គណិតវិទ្យា តារាសាស្ត្រ សាសនា កំណាព្យ អក្សរសិល្ប៍ វេជ្ជសាស្ត្រ និងស្ថាបត្យកម្ម។

---

[99] James Mulhern, *A History of Education, A Social Interpretation* (New York: Ronald Press, 1959), pp.55-79

៤.២-ទិសាទជាប្រភពវិសាស្ត្ររបស់អេហ្ស៊ីប

ក-ការបកស្រាយតាមប្រពៃណី

តួនាទីអេហ្ស៊ីបបុរាណ នៅក្នុងការបង្កើតអរិយធម៌លោកខាងលិច បានក្លាយទៅជាវិវាទនៅឆ្នាំ៣៣២មុនគ.ស. ប្រទេសអេហ្ស៊ីប ត្រូវបានចូលលុកលុយដោយ Alexander the Great និងបានបង្កើតជាអរិយធម៌ Hellenistic ដែលត្រូវបានបង្កើតដោយវប្បធម៌ក្រិកបុរាណ។ ការបកស្រាយប្រវត្តិសាស្ត្រដោយសន្មត គឺថា អរិយធម៌អេហ្ស៊ីបបុរាណ គឺការកាន់អំណាចផ្តាច់ការនិយមដ៏យូរ ហើយកេរដំណែលវប្បធម៌ចម្បង គឺវិមានស្តាបត្យកម្មដ៏ធំធេងរបស់ខ្លួន។ ការបកស្រាយនេះ បានបង្ហាញឱ្យឃើញវប្បធម៌របស់ក្រិក ជាពិសេសប្រជាធិបតេយ្យក្រុងអាថែន ជាទីកន្លែងចាប់កំណើតនៃអរិយធម៌លោកខាងលិច។

ខ-ទ្រឹស្តីរបស់ប៊ែរណាល

(Bernal's Theory)

ការបកស្រាយប្រកបដោយវិវាទជាខ្លាំងដោយ Martin Bernal អះអាងថា ជនជាតិក្រិកបានខ្ចីបញ្ញត្តិជាច្រើនអំពីរដ្ឋាភិបាល ទស្សនវិជ្ជា សិល្បៈ និងវិទ្យាសាស្ត្រពីអេហ្ស៊ីបបុរាណ។ លើសពីនេះទៀត ជនជាតិអេហ្ស៊ីបមានទីតាំងភូមិសាស្ត្រនៅអាហ្វ្រិកខាងជើង គឺជាជនជាតិអាហ្វ្រិក និងជាប្រភពវប្បធម៌លោកខាងលិច គឺជនជាតិអាហ្វ្រិកនេះឯង[១២]។ ថ្វីបើគេបានទទួលស្គាល់អន្តរកម្ម រវាងជនជាតិអេហ្ស៊ីប និងក្រិក ការរិះគន់របស់ Bernal អះអាងថា ការសង្កត់យ៉ាងធ្ងន់នៃឥទ្ធិពលរបស់អេហ្ស៊ីប ទៅលើក្រិកបុរាណ។ នៅពេលដែលប្រវត្តិវិទូ បន្តពិភាក្សាបញ្ហានេះ របកគំហើញ ដែលគ្រាន់តែជាការស្នាបស្នង់នោះចង្អុលបង្ហាញថា ទំនាក់ទំនងអេហ្ស៊ីប-ក្រិក ជាពិសេសនៅកោះ Crete នាំយកមកប្រើប្រាស់ដោយជនជាតិក្រិក ទៅជាចំណេះដឹងជនជាតិអេហ្ស៊ីប ដូចជា គណិតវិទ្យា និងទម្រង់សិល្បៈអេហ្ស៊ីប។

គ-អតីតកាលគឺជាប្រតពនៃអំណាច

វិវាទប្រវត្តិសាស្ត្រ ដែលគួរឱ្យចង់ដឹង មានខ្លឹមសារជាមនោគមវិជ្ជាដ៏សំខាន់។ អ្នកណាក៏ដោយដែលបានបកស្រាយពីអតីតកាលទទួលឥទ្ធិពលនៃការបំភ្លឺឱ្យច្បាស់លាស់ និងបង្កើតរូបភាពដល់បច្ចុប្បន្ន។ ក្នុងករណីពិសេស វិវាទ មានទំនាក់ទំនង ដល់ការពិភាក្សា នាពេលបច្ចុប្បន្នអំពីមជ្ឈមណ្ឌលអាហ្វ្រិកនិយម និងកម្មវិធីសិក្សាពីទ្វីបអាហ្វ្រិកនៅសាលារៀនទាំងឡាយ។ នៅផ្នែកបន្ទាប់មកទៀត យើងត្រឡប់ទៅមើលជនជាតិក្រិកបុរាណ។ ថាតើ ទទួលបានឥទ្ធិពលដោយផ្ទាល់ឬមិនផ្ទាល់ ដោយជនជាតិអេហ្ស៊ីប ជនជាតិក្រិកបន្តការរក្សាទីកន្លែងដ៏សំខាន់ក្នុងប្រវត្តិនៃការអប់រំ។ យ៉ាងក៏ដោយ ចូររក្សាក្នុងចិត្តថា វប្បធម៌ ជាប្រវត្តិភាគច្រើនបំផុត បានខ្ចីពីគ្នាទៅវិញទៅមក តាមរបៀបជាច្រើនបែប ហើយដើមកំណើតនៃគំនិតជនជាតិក្រិក អាចត្រូវបានរកឃើញ នៅអេហ្ស៊ីប ឬកន្លែងផ្សេងទៀត។

---

[១២] Martin Bernal, *Black Athena: The Afroasiatic Roots of Classical Civilization: The Fabrication of Ancient Greece 1785-1985* (New Brunswick, N. J.,: Rutgers University Press, 1987), pp.2-3

៥. ការអប់រំតាមអរិយធម៌ក្រិកនិងរ៉ូម៉ាំងបុរាណ

ប្រវត្តិអប់រំនៃក្រិក និងរ៉ូមបុរាណ បានបំភ្លឺដល់ដើមកំណើតនៃបញ្ហាដែលតស៊ូជាច្រើនដែលគ្រូនាពេលសព្វថ្ងៃត្រូវប្រឈមមុខ។ ក្នុងចំណោមបញ្ហាអប់រំ ជនជាតិក្រិក និងរ៉ូម៉ាំង ដែលបានពិភាក្សាគឺ អ្វីគឺពិត ល្អ ល្អស្អាត? អ្នកណា ជាគំរូដ៏មានតម្លៃសម្រាប់កុមារត្រាប់តាម? តើការអប់រំបង្កើតពលរដ្ឋល្អឬទេ? តើការអប់រំ គួរតែធ្វើយតបទៅនឹងការផ្លាស់ប្តូរខាងសង្គម សេដ្ឋកិច្ច និងនយោបាយដូចម្តេច?

ក-ការអប់រំតាមបែបហូមែរ (Homeric Education)

ជំនាន់មនុស្សទាំងឡាយបានធ្វើឱ្យរំកើបនូវចំណោទសួរនៃកំណាព្យរឿកថារបស់ Homer គឺ Iliad and Odyssey។ ដោយបានបង្ហាញខ្លួននៅប្រហែលឆ្នាំ១២០០មុនគ.ស. រឿកថារបស់ Homer ជួយឱ្យជនជាតិក្រិក កំណត់ខ្លួនគេ និងវប្បធម៌របស់គេ។ ប្រៀបដូចជាពិធីទាំងឡាយនៅក្នុងសង្គមមនុស្សមិនទាន់ចេះអាន និងសរសេរនោះ ការពិពណ៌នាគួរឱ្យរំកើបចិត្តរបស់ Homer នៃអ្នកធ្វើចម្បាំងជាតិក្រិកប្រឆាំងនឹងTrojans ត្រូវបានយកមកប្រើជាគោលបំណងអប់រំដ៏សំខាន់ៈ

1-វាបានរក្សាវប្បធម៌តាមការផ្ទេរវាពីមនុស្សចាស់ទៅមនុស្សក្មេង។

2-វាបានអប់រំអត្តសញ្ញាណវប្បធម៌ជនជាតិក្រិក ដោយផ្អែកលើប្រភពរឿងនិទាន និងប្រវត្តិសាស្ត្រ។

3-វាបង្កើតអត្តចរិតយុវវ័យ[១៣]។

Agamemnon, Ulysses, Achilles និងអ្នកចម្បាំងផ្សេងទៀត បានដើរតួគួរឱ្យរំកើបនូវទំហំជីវិតវីរបុរស។ ដោយប្រើវីរបុរសទាំងនេះ ជាតួនាទីគំរូ ជនជាតិក្រិកក្មេងៗបានសិក្សាអំពីតម្លៃដែលបានបង្កើតជីវិតឱ្យមានតម្លៃអាកប្បកិរិយាដែលបានរំពឹងចេញពីវីរជនសង្គ្រាម និងអនិបុណាភាពអត្តចរិត ដែលនាំទៅដល់ការចុះរាសីរបស់គេ។

ខ-ការអប់រំតាមជាពលរដ្ឋ

ក្រិកបុរាណ បានធ្វើឱ្យចម្រើនដល់តួនាទីការអប់រំ ក្នុងការបង្កើតពលរដ្ឋល្អ។ ដូចជា ជនជាតិអាម៉េរិក ទំនងជាមិនយល់ស្របទៅលើរូបមន្តជាក់លាក់ សម្រាប់អប់រំពលរដ្ឋល្អ ដូច្នេះជនជាតិក្រិក ក៏បានពិភាក្សាទៅលើបញ្ហានេះ។ មិនដូចមហាចក្រតពចិន និងអេហ្ស៊ីប ក្រិកបុរាណបានចែកជាផ្នែកតូចៗ ហើយជាញឹកញាប់ប្រកួតប្រជែងរដ្ឋដែលជាទីក្រុងដែល ដូចជាអាថែន និងស្ប៉ាត (Athens and Sparta) បានកំណត់ន័យការទទួលខុសត្រូវ និងសិទ្ធិពលរដ្ឋខុសគ្នា។ ក្រោយពេលធ្វើការពិសោធជាមួយទម្រង់រដ្ឋាភិបាលផ្សេងៗគ្នាអាថែន បានក្លាយជារដ្ឋប្រជាធិបតេយ្យដែលសង្កត់ធ្ងន់ទៅលើការទទួលខុសត្រូវជាសាធារណៈនៃពលរដ្ឋរបស់ខ្លួន។ ស្ប៉ាតដែលជាគូប្រជែងរបស់អាថែន គឺជារដ្ឋប្រើអំណាចផ្តាច់ការ

[១៣] Louis Goldman, Homer, Literacy, and Education, *Educational Theory* (Fall 1989), pp. 391-400.

ខាងយោធា (Authoritarian military dictatorship)[១៤]។ ដើម្បីប្រៀបធ្វើមរដ្ឋាភិបាលខុសគ្នា រដ្ឋជាទីក្រុងនីមួយៗ មានប្រភេទនៃការអប់រំពលរដ្ឋរបស់ខ្លួន។

គ-ការបង្កើតការអប់រំ និងការអប់រំក្នុងប្រព័ន្ធ

ជនជាតិក្រិក ទទួលស្គាល់សារៈសំខាន់នៃការអប់រំ ដែលកំពុងមានអន្តរកម្ម គឺការធ្វើឱ្យមានការជ្រួតជ្រាប និងការចូលរួមក្នុងវប្បធម៌ទាំងមូលរបស់រដ្ឋជាទីក្រុងជាមួយការអប់រំក្នុងប្រព័ន្ធ។ តាមរយៈការបង្កើតឱ្យមានការអប់រំ យុវវ័យជនជាតិក្រិក ត្រូវបានត្រៀមរៀបចំដើម្បីឱ្យក្លាយជាពលរដ្ឋនៃសង្គមរបស់គេ។ ការអប់រំក្នុងប្រព័ន្ធផ្តល់ចំណេះដឹងចាំបាច់ ដើម្បីបំពេញក្តីសង្ឃឹមនៃជីវិតល្អក្នុងសង្គមទាំងមូលថែមទៀត។ ឧ. អាថែនជឿថាមនុស្សដែលមានសេរីភាព ចាំបាច់ត្រូវការការអប់រំដែលប្រកបដោយសេរីភាពដើម្បីបំពេញករណីកិច្ចពលរដ្ឋ ព្រមទាំងអភិវឌ្ឍជាបុគ្គល[១៥]។ ផ្ទុយទៅវិញ ស្ប៉ាតប្រើការអប់រំក្នុងប្រព័ន្ធសម្រាប់ការបណ្តុះបណ្តាលយោធា។

ឃ-តួនាទីនៃទាសករ

សង្គមក្រិក ជាប់ពាក់ព័ន្ធទៅតាមផ្នែកជាមួយទាសករ។ ភាគច្រើននៃទាសករ ដែលរួមបញ្ចូលទាំងស្ត្រី និងកុមារ គឺជាឈ្លើយសង្គ្រាម ឬអ្នកទាំងឡាយ ដែលបានភ្ជាលទោសដោយច្បាប់ចំពោះសេរគតិភាព។ ទោះបីជាទាសករ ដែល មានការអប់រំតិចតួច បានបង្រៀនកូនសិស្សទោលជាអ្នកមានក្នុងក្រុងអាថែនក៏ដោយ ក៏ទាសករភាគច្រើនត្រូវបានគេបណ្តុះបណ្តាល ដើម្បីឱ្យចេះធ្វើកសិកម្ម ឬបំណិនខាងពាណិជ្ជកម្ម។ ពួកអាថែន ជឿជាក់ថា ការអប់រំប្រកបដោយសេរីភាពសមរម្យសម្រាប់មនុស្សសេរី គឺឥតមានប្រយោជន៍សម្រាប់ទាសករ។ ការពិភាក្សាសម័យទំនើបរវាងអ្នកគាំទ្រនៃការអប់រំសេរី និងវិជ្ជាជីវៈបានវិលត្រឡប់ទៅរកភាពខុសគ្នានៃពួកអាថែនរវាងការបណ្តុះបណ្តាលវិជ្ជាជីវៈសម្រាប់ពួកទាសករ និងការអប់រំសេរី សម្រាប់ពលរដ្ឋសេរី។

ង-ការអប់រំស្ត្រី

នៅក្នុងសង្គមក្រិក ដែលគ្របដណ្តប់ដោយពួកបុរស មានតែស្ត្រីក្នុងករណីលើកលែងភាគតិចប៉ុណ្ណោះ ដែលទទួលបានការអប់រំក្នុងប្រព័ន្ធខ្លះៗ។ ក្នុងក្រុងអាថែន ស្ត្រីមានសិទ្ធិខាងសេដ្ឋកិច្ច និងស្របច្បាប់តាមដែនកំណត់បំផុត ហើយស្ត្រីភាគតិចបំផុត បានចូលរៀន។ ស្ត្រីក្មេងៗ ដែលមានសំណាងជាងទទួលបានការបង្រៀននៅនឹងផ្ទះពីគ្រូបង្រៀនសិស្សទោល។ ស្ត្រីផ្សេងទៀត ដូចជា បព្វជិត ជាស្ត្រីនៃនិកាយសាសនាផ្សេងៗបានសិក្សាទម្លាប់ខាងសាសនានៅសាលារៀនតាមព្រះវិហារ។ ផ្ទុយទៅវិញ ស្ត្រីក្មេងៗរបស់ពួកស្ប៉ាតទទួលបានការបណ្តុះបណ្តាលខាងយោធា និងកីឡាកាយសម្ព័ន្ធ ដើម្បីរៀបចំពួកគេជាម្តាយដែលមានសុខភាពនៃទាហានស្ប៉ាតនាពេលអនាគត។

---

[១៤] Nigel M. Kennel, *The Gymnasium of Virtue: Education and Culture in Ancient Sparta* (Chapel Hill: Univer- sity of South Carolina Press, 1995)

[១៥] Kevin Robb, *Literacy and Paideia in Ancient Greece* (New York: Oxford University Press, 1994).

៥-១-ពួកសូហ្វីស (The Sophists)

នៅក្នុងសតវត្សទី៥មុនគ.ស.សេដ្ឋកិច្ច ដែលកំពុងផ្ទាស់ប្តូរបាននាំមកនូវគំរូខាងអប់រំ និងសង្គមថ្មី ទៅដល់ក្រិក ជាពិសេស អាថែន។ វណ្ណៈអភិជន (Aristocracy) ដែលមានវ័យចំណាស់បានប្តូរកន្លែងដោយវណ្ណៈពាណិជ្ជកម្មថ្មី ដែលមានផលចំណេញពីការរីកដាលនៃពួកអាថែន និងអាណានិគមកម្ម។ ការផ្ទាស់ប្តូរសេដ្ឋកិច្ចសង្គមនេះ បង្កើតបានលក្ខខណ្ឌសម្រាប់ពួកសូហ្វីស។

ក-ត្រូដែលដើរត្រាច់ចរ

ពួកសូហ្វីស ដែលជាក្រុមអ្នកអប់រំដែលធ្វើដំណើរបានអភិវឌ្ឍវិធីបង្រៀនថ្មី ដើម្បីបង្រៀនវណ្ណៈពាណិជ្ជកម្មថ្មី តាមបំណិនការនិយាយសាធារណៈ។ គាពគ្រប់គ្រាន់ក្នុងសិល្បៈនៃការថ្លែងសុន្ទរកថាសំខាន់ខ្លាំងណាស់ក្នុងសង្គមប្រជាធិបតេយ្យ ដូចជាអាថែនដែលវាត្រូវបានគេប្រើដើម្បីបញ្ចុះបញ្ចូលកិច្ចប្រជុំ និងព្រះពជបរិវារឱ្យពេញចិត្ត[១៦]។

ខ-វេយ្យាករណ៍ តក្កវិទ្យា និង ខោ ហារសាស្ត្រ

ពួកសូហ្វីស ស្វែងរកអភិវឌ្ឍបំណិនទំនាក់ទំនងរបស់សិស្ស ដើម្បីឱ្យគេអាចក្លាយជានីតិពន្ធ និងអ្នកគាំទ្រដ៏មានជោគជ័យ។ មុខវិជ្ជាសំខាន់បំផុតរបស់ពួកសូហ្វីស គឺតក្កវិទ្យា វេយ្យាករណ៍ និងវោហារសាស្ត្រជាប្រធានបទដែលត្រូវបានអភិវឌ្ឍនៅពេលក្រោយមកទៅជាសិល្បៈសេរី។ ***តក្កវិទ្យា គឺជាវិធាននៃអំណះអំណាងដ៏ត្រឹមត្រូវ*** *បានបណ្តុះបណ្តាលនិស្សិតឱ្យចេះរៀបចំការបង្ហាញរបស់គេបានច្បាស់លាស់ ហើយនិង* ***វេយ្យាករណ៍ បានអភិវឌ្ឍថាមពលនៃការប្រើប្រាស់ភាសាឱ្យមានប្រសិទ្ធភាព។ វោហារសាស្ត្រដែលជាការសិក្សាសម្តីបញ្ចុះបញ្ចូល*** *មានសារៈសំខាន់ពិសេសសម្រាប់អ្នកថ្លែងសុន្ទរកថា នាពេលអនាគត។*

គ-ចំណេះដឹងជាឧបករណ៍

ពួកសូហ្វីស អះអាងថា គេអាចអប់រំសិស្សរបស់គេ ឱ្យទទួលបានការពិភាក្សាជា សាធារណៈតាមការបង្រៀនពួកគេ៖

1-របៀបប្រើប្រាស់ចិត្តវិទ្យាក្នុងហូងមនុស្សដើម្បីដឹងពីអ្វីដែលនឹងសុំ ឬអំពាវនាវដល់ ទស្សនិក ជន។

2-របៀបរៀបចំអំណះអំណាង ដែលប្រកបដោយការជឿជាក់ និងបញ្ចុះបញ្ចូល។

3-បំណិនក្នុងការនិយាយជាសាធារណៈ គឺដោយដឹងថា អ្វីជាពាក្យ ឧទាហរណ៍ និងប្រភេទនៃហេតុផល ដើម្បីយកមកប្រើប្រាស់ឱ្យទទួលបានការពិភាក្សាឬករណីរឿងណាមួយ បានជោគជ័យ។

ប្រសិនបើពួកគេនៅរស់ដល់សព្វថ្ងៃ ពួកសូហ្វីស ទំនងជាអះអាងថា គោលវិធីអប់រំរបស់ពួកគេផ្តល់ឱ្យមនុស្សនូវអ្វីដែលគេចង់បាន គឺបំណិនរៀបចំគំនិត និងដើម្បីបង្ហាញពួកគេដោយមានប្រសិទ្ធភាពខ្លាំងពេករហូតដល់មនុស្សនឹងត្រូវបានគេបញ្ចុះបញ្ចូលឱ្យទទួលយកការប្រកាសរបស់ពួកគេ។ ទោះជាយ៉ាងណាក៏ដោយ ការរិះគន់របស់ពួកសូហ្វីស បានចោទប្រកាន់ពួក

[១៦] The Philosophy of the Sophists, **http:www.radicalacademy.com/philosophists.htm**

គេ ពីការសង្កត់ធ្ងន់ផ្នែកបច្ចេកទេសដែលទទួលបានការអះអាងទៅលើការស្វែងរកសច្ចភាពនៃបញ្ហាដែលនៅជិតៗ ឬហៀបនឹងកើតឡើង។

ពួកសូហ្វីស គឺប្រៀបដូចជាអ្នកបង្កើតរូបភាពសម័យទំនើបដែលប្រើប្រាស់ប្រព័ន្ធឃោសនាដើ ម្បីក្តោបយកបេក្ខជនខាងនយោបាយ និងវិស្សុតជន(Celebrities)។ ថ្វីបើការពិភាក្សាខាងនយោបាយនាពេលសព្វថ្ងៃ និងការពិភាក្សាបេក្ខជន កើតមានឡើងតាមទូរទស្សន៍ ជាជាងរស់នៅក្នុងមជ្ឈមណ្ឌលក្រុងអាថែននោះ ពួកសូហ្វីសនឹងអះអាងពីបច្ចេកទេសរបស់ពួកគេ នៅតែមានភាពរឹងមាំ។ វានៅតែមានសារៈសំខាន់ដើម្បីយល់ដឹងពីទស្សនិកជនដើម្បីអំពាវនាវសុំពីតម្រូវការរបស់គេ និងដើម្បីប្រើប្រាស់ការបញ្ចុះបញ្ចូលប្រកបដោយបំណិនដើម្បីធ្វើឱ្យពួកគេជឿជាក់។ ពួកគេ គួរតែពិចារណាទៅលើក្រុមដែលមានការផ្តោតអារម្មណ៍ ការស្ទង់មតិមហាជនជាសាធារណៈ ហើយនិងឧបករណ៍បញ្ចុះបញ្ចូលដែលមានប្រយោជន៍កំពុងផ្សព្វផ្សាយជាអវិជ្ជមាន។

ឃ-និងProtagoras

តាមមធ្យោបាយជាច្រើន ពួកសូហ្វីសបានអភិវឌ្ឍគោលវិធីទំនើបគួរទាក់ទាញអារម្មណ៍ចំពោះការអប់រំ។ Protagoras (485-414 B.C.) ដែលជាពួកសូហ្វីសដ៏សំខាន់បំផុតម្នាក់នោះបានអភិវឌ្ឍល្បិចបង្រៀន៥ជំហានប្រកបដោយប្រសិទ្ធភាពខ្ពស់[៧]៖

1-ផ្តល់សុន្ទរកថា (Speech) ដ៏ចំណានដើម្បីឱ្យសិស្សយល់ដឹងថា គ្រូរបស់គេអាចធ្វើអ្វីនៅពេលដែលគាត់មានបំណងនឹងបង្រៀនគេ។ សុន្ទរកថានេះ ក៏ផ្តល់ឱ្យគេនូវគំរូមួយអាចអនុវត្តតាម។

2-ឱ្យសិស្សពិនិត្យមើលសុន្ទរកថាដ៏អស្ចារ្យនៃវាគ្មិនដ៏ល្បីល្បាញ (Famous orators) ដើម្បីបរិយាយគំរូទាំងឡាយ ដែលអាចយកទៅប្រើប្រាស់បាន។

3-សិក្សាមុខវិជ្ជាគន្ធឹះនៃតក្កវិទ្យា វេយ្យាករណ៍ និងវោហារសាស្ត្រ។

4-ផ្តល់ការប្រតិបត្តិសុន្ទរកថា (Oration) ដែលគាត់អាចវាយតម្លៃដើម្បីផ្តល់ព័ត៌មានត្រឡប់ទៅសិស្ស។

5-វាគ្មិន ដែលជាសិស្ស ផ្តល់សុន្ទរកថាជាសាធារណៈ។

វិធីរបស់ Protagoras ប្រដូចកម្មវិធីអប់រំគ្រូនាពេលសព្វថ្ងៃដែលក្នុងនោះ អនាគតគ្រូបង្រៀនសិក្សាសិល្បៈសេរី និងមុខវិជ្ជាដែលទាក់ទងនឹងវិជ្ជាជីវៈសិក្សាល្បិចបង្រៀនផ្សេង។ និងធ្វើកម្មសិក្សានៅក្រោមការដឹកនាំពីគ្រូដែលជួយសហប្រតិបត្តិការប្រកបដោយ បទពិសោធ។

ង-សច្ចភាពស្ថិតស្ថេរ ឬសច្ចភាពមិនរឹងមាំ

ការបង្ហាញខ្លួនរបស់ពួកសូហ្វីស នៅធាកឱ្យគេមើលឃើញក្នុងសម័យបុរាណបានលើកឡើងនូវបញ្ហាអប់រំដ៏សំខាន់ដែលចម្ងាយនាំទៅ

[៧] Edward Schiappa, *Protagoras and Logos: A Study in Greek Philosophy and Rhetoric* (Columbia: University of South Carolina Press, 2003;also see L. Glenn Smith, *Lives in Education: People and Ideas in the Development of Teaching* (Ames, Iowa: Education Study Press, 1984), pp.7-9

ដល់វិាទរហូតដល់សព្វថ្ងៃនេះ។ ពួក សូហ្ស៊ីស គឺជាពួកដែលមានសច្ចភាពខាងសីលធម៌មិនរឹងមាំ (Moral relativists)ដែលបានអះអាងថា អ្វីដែលយើងចាំបាច់យល់ដឹង អាស្រ័យទៅលើកាល:ទេស:ដែលយើងរស់នៅ។ សូក្រាត ប្លាតុង និងអារីស្តូត បានប្រឆាំងនឹងសច្ចភាពមិនរឹងមាំរបស់គេ ហើយបានទទូចចង់បានអត្ថិភាពនៃសច្ចភាពស្ថិតស្ថេរ ដែលយើងត្រូវតែយល់ដឹង។ Isocrates ដែលជាគ្រូសិល្ប:ខាងការថ្លែងសុន្ទរកថា បានព្យាយាមដោះស្រាយវិវាទ ដោយនិយាយថា យើងចាំបាច់ត្រូវយល់ដឹងអ្វីដែលជាការពិត ប៉ុន្តែក៏អនុវត្តវាផងដែរទៅនឹងស្ថានភាពដែលយើងរស់នៅ។ យើងនឹងពិភាក្សាទស្សន:នៃទស្សនវិទូអប់រំទាំង៤នាក់នេះ។

៥-២-Socrates: ការអប់រំតាមការស្ទង់ពិនិត្យ

ក-គោលការណ៍សកល

មិនដូចជាពួកសូហ្ស៊ីស ដែលបានអះអាងថា ចំណេះដឹងអាស្រ័យទៅលើស្ថានភាព ដែលមនុស្សប្រើវា។ សូក្រាត (៤៦៩-៣៩៩មុនគ.ស.) ជឿជាក់ថា ចំណេះដឹង គឺត្រូវផ្អែកទៅលើអ្វីដែលជាសច្ចភាពសកល គឺគ្រប់ទីកន្លែង និងគ្រប់ពេលវេលា។ គំនិតសូក្រាត មានសារ:សំខាន់ក្នុងប្រវត្តិអប់រំ ពីព្រោះគាត់បានការពារយ៉ាងរឹងមាំថា សេរីភាពខាងការសិក្សាដើម្បីគិតសួរ និងបង្រៀន។ គាត់ក៏មានសារ:សំខាន់ផងដែរក្នុងនាមជាគ្រូរបស់ Plato ដែលក្រោយមកបានធ្វើឱ្យគំនិតរបស់ Socrates ជាច្រើនមានលក្ខណ:ជាប្រព័ន្ធ[៧៨]។

ខ-ឧត្តមភាពសីលធម៌

ទស្សនវិជ្ជា Socrates សង្កត់ធ្ងន់ទៅលើគោលការណ៍សីលវិទ្យា ដែលមនុស្សម្នាក់ គួរតែខិតខំ សម្រាប់ឧត្តមភាពសីលធម៌ រស់នៅដោយភាពវាងវៃ និងធ្វើសកម្មភាពប្រកបដោយវិចារណញ្ញាណ។ Socrates ជឿជាក់ថា ឧត្តមភាពសីលធម៌មានភាពកំពូលខ្ពាំងជាងការបណ្តុះបណ្តាលបច្ចេកទេសរបស់ពួកសូហ្ស៊ីស។

គ-តួនាទីគ្រូរបស់សូក្រាត

បញ្ញត្តិរបស់សូក្រាតនៃគ្រូបង្រៀនខុសប្លែកពីពួកសូហ្ស៊ីស។ គាត់មិនបានជឿថាចំណេះដឹងឬគតិបណ្ឌិតអាចផ្ទេរពីគ្រូទៅសិស្សម្នាក់បានទេពីព្រោះគាត់បានជឿជាក់ថាបញ្ញត្តិ នៃចំណេះដឹងពិតមានពិតមែន តែវាបានកប់បាត់នៅក្នុងចិត្តមនុស្ស។ គ្រូត្រូវតែសួរសំណួរឱ្យបានត្រឹមត្រូវដើម្បីឱ្យសិស្សគិតដោយល្អិតល្អន់ អំពីសំណួរសំខាន់ៗ។ ការអប់រំប្រកបដោយសេរីភាពពិតប្រាកដមួយ នឹងក្តោចសិស្សស្រាជ្រាវរកគំនិតដោយនាំទៅដល់ញាណនូវការពិតដែលមានតែមិនទាន់បញ្ចេញឱ្យឃើញនៅក្នុងចិត្តរបស់គេ។

ឃ-ស្ទង់ពិនិត្យ ការសន្ទនា និងវិធីសូក្រាត

គោលបំណងអប់រំបែបសូក្រាត គឺត្រូវជួយបុគ្គលឱ្យកំណត់ខ្លួនគេតាមស្ទង់ពិនិត្យ។ តាម

[៧៨] Gary Alan Scott, Plato's Socrates as Educator (Albany: State University of New York Press, 2000), pp. 1-12. Also see Alven Neiman, Ironic Schooling: Socrates, Pragmatism and the Higher Learning, *Educational Theory* (Fall 1991), pp.371-384

របៀបនេះ បុគ្គលម្នាក់ៗ អាចស្វែងរកការពិតដែលមានជាសកលក្នុងគ្រប់មនុស្សទាំងអស់។ ក្នុងនាមជាគ្រូម្នាក់ សូក្រាតបានសួរសំណួរនាំមុខដែលក្រោចសិស្ស ដើម្បីស៊ើបអង្កេតនូវការយកចិត្តទុកដាក់របស់មនុស្សតាំងពីយូរ (Perennial human concerns)អំពីអត្ថន័យនៃជីវិតការពិតនិងយុត្តិធម៌។ បន្ទាប់មកសិស្សមានការពិភាក្សាយ៉ាងសកម្ម តែឱ្យមានភាពលំបាក ឬការសន្ទនា ដែលក្នុងនោះសិស្សបញ្ចាក់អះ អាង ទិតៀន នឹងបង្កើតឡើងវិញនូវបញ្ញត្តិមូលដ្ឋានរបស់ពួកគេ។ ចំពោះសូក្រាតការសន្ទនាមិនមែនមានន័យថា គ្រាន់តែចែករំលែកគំនិតនោះទេ។ វាមានន័យថា ការឆ្ទុះបញ្ចាំង និងការទិតៀនពួកគេឱ្យរកឃើញសច្ចភាពជាមូលដ្ឋាន (The underlying truth)។ គោលវិធីនេះ នៅតែត្រូវបានគេទទួលស្គាល់ ថាជាវិធីសូក្រាត។ ក្នុងនាមជាគ្រូម្នាក់ អ្នកអាចប្រើវិធីសូក្រាតតាមការសួរសំណួរដល់សិស្សដែលបានរៀបចំជាស្រេចដើម្បីចម្រាញ់យកការគិតល្អិតល្អន់របស់ពួកគេទៅលើបញ្ហាថ្មីៗឬ ជាប្រវត្តិសាស្ត្ររបស់ពួកគេ ឬអំពីស្នាដៃអក្សរសាស្ត្រដែលត្រូវបានដាក់ឱ្យសិស្សអាន។

ដោយប្រៀបបាននឹងទីផ្សារអាថែន ដែលបានកើតឡើងជាញឹកញាប់នោះ សូក្រាត បានទាក់ទាញក្រុមមនុស្សក្មេងៗដែលបានចូលរួមជាមួយគាត់ក្នុងការពិនិត្យដោយល្អិតល្អន់នៃប្រភេទនៃបញ្ហាទាំង**អស់ ដូចជា** សាសនា នយោបាយ សីលធម៌ និងសោភ័ណវិទ្យា (Aesthetics)។ ក្នុងនាមជាអ្នករិះគន់ទៅលើសង្គមវិញ សូក្រាត បានបង្កើតសត្រូវដ៏មានឥទ្ធិពល។ ដូច្នេះហើយ ក្នុងពេលឥឡូវនេះ មនុស្សមួយចំនួនដោយរាប់បញ្ចូលទាំងមនុស្សដែលមានឋានៈខ្ពង់ខ្ពស់ផងដែរ បានភ័យខ្លាចថា ការគិតដ៏ល្អិតល្អន់អាចប្រឆាំងនឹងការងាររបស់ពួកគេ ហើយនាំទៅដល់ចលាចល។ នៅក្នុងឆ្នាំ៣៩៩មុនគ.ស. ក្រោយពេលបានវិនិច្ឆ័យការចោទប្រកាន់ពីការខ្វះសេចក្តីគោរព(Impiety) ដល់ព្រះជាម្ចាស់ និងអំពើពុករលួយទៅលើយុវជនអាថែន សូក្រាត ត្រូវបានគេកាត់ទោសប្រហារជីវិត (Socrates was condemned to death) ជាកាត់ទោសមួយដែលគាត់មិនបានប្រកែកតវ៉ា។

៥-៣-ច្បាប់ធម្មជាតិ និងតម្លៃអនន្ត

ក-តថភាព ជាគំនិតសកល និងអនន្ត

ថ្មាតុង ជាកូនសិស្សរបស់សូក្រាត(៤២៧-៣៤៦មុនគ.ស.) បានដើរតាមផ្លូវជាអ្នកអប់រំរបស់គាត់។ ថ្មាតុង បានបង្កើតបណ្ឌិត្យសភា ដែលជាសាលារៀនខាងទស្សនវិជ្ជា នៅឆ្នាំ៣៨៧មុនគ.ស.។ គាត់បាននិពន្ធ Protagoras ដែលជាសេចក្តីថ្លែងស្តីអំពីគុណធម៌ និងសាធារណរដ្ឋ និងច្បាប់ អភិប្រាយអំពីនយោបាយ ច្បាប់ និងការអប់រំ[19]។ ដោយជំទាស់នឹងសច្ចភាពមិនមានលំនឹងរបស់ពួកសូហ្វីស ថ្មាតុងបានអះអាងថា ភាពពិតកើតមាន ពីពិភពមិនប្រែប្រួលនៃគំនិតឥតខ្ចោះ គឺបញ្ញត្តិសកល ដូចជា សច្ចភាព កុសល យុត្តិធម៌ និងសោភណភាព។ ករណីបុគ្គលនៃបញ្ញត្តិទាំងនេះ

[19] Devin Stuffer, *Plato's Introduction to the Question of Justice* (Albany: State University of New York Press, 2000).

ដូចដែលវាបានបង្ហាញខ្លួន ចំពោះវិញ្ញាណរបស់យើង គឺគ្មានអ្វីក្រៅពីការបង្ហាញអសុក្រឹតនៃបញ្ញត្តិសកល និងអនន្ត ដែលមាននៅក្នុងគំនិតជាច់ខាត គឺទម្រង់នៃកុសល។

ខ-ការរំឭកពីរឿងអតីតកាល

ទ្រឹស្តីប្វាតុងនៃចំណេះដឹង គឺផ្អែកលើការរំឭកពីរឿងដើម (Reminiscence) គឺជាលំនាំ ដែលបុគ្គលចងចាំគំនិត ដែលមាន តែមិនទាន់បង្ហាញឱ្យឃើញក្នុងចិត្ត។ ការរំឭករឿងដើម អះអាងថា ព្រលឹងមនុស្ស មុនពេលចាប់កំណើត បានរស់នៅក្នុងពិភពខាងស្មារតី គឺជា ប្រភពនៃសច្ចភាព និងចំណេះដឹង។ នៅពេលកើត គំនិតពីកំណើតទាំងនេះ ត្រូវបានទប់នៅក្នុងគំនិតអនុញ្ញាណ។ ចំពោះប្វាតុង ការសិក្សាមានន័យថា គេអាចរកឃើញឡើងវិញឬចងចាំគំនិតឥតខ្ចោះទាំងនេះ[២០]។

គ-សកលនិយម ទល់នឹងសច្ចភាពមិនមានលំនឹង

មិនដូចសភាពផ្ទាស់ប្តូរបានរបស់សច្ចភាពមិនមានលំនឹង សកលនិយម អះអាងថា ស្មាមដិតខាងវិញ្ញាណធ្វើឱ្យខុសពីភាពពិតចំណេះដឹងពិត គឺខាងបញ្ញាមិនផ្ទាស់ប្តូរ និងអនន្តមិនមែនឥន្ទ្រីយារម្មណ៍ទេ។ មិនមានគំនិតណាមួយល្អឥតខ្ចោះសម្រាប់មនុស្សទាំងអស់ដោយមិនគិតពីពេល ឬកន្លែងដែលគេរស់នៅ។ ពីព្រោះការពិតនៅតែជាការពិត ការអប់រំ គួរតែមានលក្ខណៈសកល និងមិនប្រែប្រួលផងដែរ។

ឃ-គំនិតពីកំណើត

ជំនឿដែលថា គំនិតពីកំណើតមានតែមិនទាន់បង្ហាញឱ្យឃើញនៅក្នុងចិត្តមានឥទ្ធិពលខាងអំណាច ទៅលើការអប់រំលោកខាងលិចពីសម័យដើម។ ការអប់រំនៅឥណ្ឌា ក៏បានឆ្លុះបញ្ចាំងជំនឿក្នុងគំនិតពីកំណើត។ ការអប់រំផ្នែកវេទ បានលើកទឹកចិត្តឱ្យមានការតាំងការនាដើម្បីរកឱ្យឃើញចំណេះដឹងពីកំណើត។ នៅលោកខាងលិច ទ្រឹស្តីគំនិតពីកំណើតត្រូវបានប្រធាំងដោយអ្នកធ្វើកំណែទម្រង់ផ្នែកអប់រំនាពេលក្រោយមក ដូចជា Locke, Pestalozzi, Dewey និងអ្នកផ្សេងទៀតដែលគំនិតរបស់គេត្រូវបានសិក្សានៅពេលក្រោយ។ រីឯទស្សនៈផ្នែកអប់រំនាពេលក្រោយជាច្រើនដែលសូម្បីតែប្រយោជន៍នាពេលបច្ចុប្បន្នក្នុងអ្នកស្ថាបនានិយមអាចត្រូវបានគេមើលឃើញថា ជាការអះអាងតប ចំពោះទ្រឹស្តីនៃគំនិតរបស់ប្វាតុងដែរ។

ង-សាធារណរដ្ឋ

វាជាសង្គមប្រកបដោយឧត្តមគតិរបស់ប្វាតុង។ នៅក្នុងសាធារណរដ្ឋរបស់ប្វាតុង គាត់បានរៀបចំគម្រោងផែនការសម្រាប់សង្គមល្អឥតខ្ចោះមួយដែលគ្រប់គ្រងដោយអធិរាជទស្សនវិជ្ជាដែលជាវរជនខាងបញ្ញា។ ទោះបីជារដ្ឋដែលជាឧត្តមគតិរបស់ប្វាតុង មិនដែលត្រូវបានគេអនុវត្តក៏ដោយ ក៏គំនិតរបស់គាត់មានប្រយោជន៍ក្នុងការពិពណ៌នាកំណែប្រែថ្មី ដែលជាឧត្តមគតិនៃ

[២០] Gerald L. Gutek, *Historical and Philosophical Foundations of Education: A Biographical Introduction* (Columbus, Ohio: Merril / Prentice Hall, 2005), pp.37-40.

ប្រភេទការអប់រំដ៏ពិតប្រាកដមួយ[21]។ សាធារណរដ្ឋ បានបែងចែកជាវណ្ណៈ៣៖

1-អធិរាជទស្សនវិជ្ជា៖ អ្នកដឹកនាំដែលជាបញ្ញវន្ត។

2-អ្នកជំនួយ៖ អ្នកការពារដែលជាកងទ័ព។

3-កម្មករ៖ អ្នកផលិតទំនិញផ្តល់សេវាកម្ម។

សមត្ថភាពប្រកបដោយភាពឈ្វាសវៃរបស់មនុស្សម្នាក់ នឹងកំណត់កិច្ចការខាង វណ្ណៈរបស់ខ្លួន។

ភាពស្រដៀងគ្នា បានកើតមានឡើងរវាងគំនិតខុងជឺ ឥណ្ឌាបុរាណ និងច្វាតុង។ តាមគំនិតទាំង៣នេះសង្គមគួរតែត្រូវបានរៀបចំរចនាសម្ព័ន្ធទៅតាមឋានានុក្រមជាមួយមនុស្សដែលមានប្រាជ្ញាបំផុត ស្ថិតនៅក្នុងតំណែងកម្រិតខ្ពស់បំផុតនៃអាជ្ញាធម៌។ ផ្ទុយទៅវិញសង្គមតាមបែបឋានានុក្រមបែបនេះ ពួកសូហ្វីស អះអាងថា អ្នកណាម្នាក់ក៏អាចឡើងទៅដល់កម្រិតកំពូលបានដែរ ប្រសិនបើគេទទួលបានបច្ចេកទេស ដែលផ្តល់អំណាចដល់ពួកគេបាន។

ច-ការអប់រំដែលចាក់ឫសដល់តួនាទីសង្គម

ក្នុងការរៀបចំវណ្ណៈបុគ្គលម្នាក់ៗ នៅក្នុងសាធារណៈរដ្ឋ គួរទទួលបានការអប់រំ ដែល សមរម្យទៅតាមតួនាទីសង្គមរបស់គេ៖

1-អធិរាជទស្សនវិជ្ជា ដែលត្រូវបានគេអប់រំសម្រាប់ភាពជាអ្នកដឹកនាំ ក៏ទទួលខុសត្រូវផងដែរ សម្រាប់កំណត់អត្តសញ្ញាណអ្នកដែលមានសមត្ថភាពខាងបញ្ញា ទៅតាមមនុស្សជំនាន់ក្រោយ ហើយរៀបចំឱ្យគេ ទៅតាមតួនាទីជោគវាសនា នាពេលខាងមុខ។

2-វណ្ណៈទី២ ដែលជាអ្នកចម្បាំងជាអ្នកការពារសាធារណរដ្ឋ ហើយនិងទទួលបទបញ្ជាពីអធិរាជទស្សនវិជ្ជា។

3-វណ្ណៈទី៣ និងជាវណ្ណៈធំជាងគេបំផុត គឺពួកកសិករ គួរត្រូវបានបណ្តុះបណ្តាល ជាកសិករ និងសិប្បករ។

ដោយមានការអប់រំមួយសម្រាប់ក្រុមនីមួយៗសាធារណរដ្ឋ បានត្រៀមរៀបចំសមាជិករបស់ខ្លួន សម្រាប់មុខងារដ៏សមរម្យរបស់គេ ដែលជាបន្តបន្ទាប់ បានរួមចំណែកដល់ភាពចុះសម្រុងគ្នា នៅក្នុងសហគមន៍ និងអនុវត្តមុខងារ ទៅតាមសមត្ថភាព។ ការរិះគន់ក្នុងសម័យទំនើបសព្វថ្ងៃនៃការរៀបចំសិស្សនៅក្នុងសាលារៀន អះអាងថាឧបករណ៍សម្រាប់បិទបាំង ពិតជាមានបំណងបង្កើតឡើងវិញនូវស្ថានភាពវណ្ណៈដែលមានរួច ហើយជាជាងលើកទឹកចិត្តចលនាក្នុងចំណោមវណ្ណៈសង្គមទាំងឡាយ។

ឆ-ការអប់រំស្ត្រី

មិនដូចពួកអាថែន ច្វាតុងជឿជាក់ថា ស្ត្រីគួរតែមានអភ័យឯកសិទ្ធិដូចគ្នា និងការទទួលខុសត្រូវស្មើនឹងបុរស[22]។ ស្ត្រីផងដែរ បានជ្វាក់ទៅក្នុង

[21] Plato, *Republic* (London: Folio Society, 2003; also see *Selected Dialogues of Plato: The Benjamin Jowett Translation* (New York: Modern Library, 2001)

[22] Robert S. Brumbaugh, Plato's Ideal Curriculum and Contemporary Philosophy of Education, Educational Theory (Spring 1987), pp.169-177

វណ្ណៈ:៣ ដែលថ្នាតុង៍បានដាក់ចំពោះមនុស្សៗ ស្ត្រី ដែលមានឥទ្ធិពលពុទ្ធិកម្រិតខ្ពស់ អាចក្លាយជា សមាជិកនៃវរជនខាង៍ទស្សនវិជ្ជាដែលសម្រាប់ គ្រប់គ្រង៍។ អ្នកផ្សេង៍ទៀត ដែលជាបញ្ញាជនជាន់ ទាបជាង៍ គួររៀបចំឱ្យមានឋាន:ទាបជាង៍។ ដូចជា បុរសផង៍ដែរ ស្ត្រីគួរទទួលបានការអប់រំ ឬការ បណ្តុះបណ្តាល ដែលសមរម្យទៅនឹង៍សមត្ថភាព និង៍មុខរបរដែលបានកំណត់។

៨-ឧារកដ្ឋាន ដែលរៀបចំដោយរដ្ឋ

កម្មវិធីសិក្សារបស់ថ្នាតុង៍ សមស្របនឹង៍វត្ថុ បំណង៍អប់រំ ទៅតាមឋានានុក្រមជាជាង៍ ទៅតាម សមភាពសង្គម។ ដោយភ័យខ្លាចឪពុកម្តាយ បន្ត មរតកភាពល្ងង៉ៃខ្លៅ និង៍បុរេនិច្ច័យ ទៅឱ្យកូនថ្នា តុង៍ចង់ឱ្យកុមារមានការចិញ្ចឹមដោយអ្នកជំនាញ ខាង៍ការមើលថែទាំកុមារ។ កុមារ ដែលត្រូវបាន បំបែកចេញពីឪពុកម្តាយនោះ គួរត្រូវរស់នៅក្នុង៍ កន្លែង៍មើលថែទាំកុមាររបស់រដ្ឋ ដូច្នេះហើយ កុមារទទួលបានទម្លាប់ល្អ និង៍វិសុទ្ធកម្មភាព អាក្រក់ចេញ។

ឈ-កម្មវិធីសិក្សាជាមូលដ្ឋានរបស់ថ្នា តុង

ពីអាយុ៦ឆ្នាំដល់១៨ឆ្នាំ កុមារគួររៀននៅ សាលា ជាកន្លែង៍ដែលគេត្រូវសិក្សាតន្ត្រី និង៍កីឡា កាយសម្ព័ន្ធ។ តន្ត្រី តាមនិយមន័យរបស់ ថ្នាតុង៍ គឺ ជាមុខវិជ្ជាទូលំទូលាយ ដែលត្រូវបានរាប់បញ្ចូល ទាំង៍ការអាន ការសរសេរអក្សរសិល្ប៍ នព្វន្តសាស្ត្រ ការច្រៀង៍ជាក្រុម និង៍ការរាំ។

ក្រោយពេលចេះអាន និង៍សរសេរស្ទាត់ ហើយ សិស្សគួរនឹង៍អានអក្សរសិល្ប៍ក្រិក និង ឡា តាំង៍។ ថ្នាតុង៍ បានចាត់ទុកអក្សរសិល្ប៍ ជាកម្ទាំង៍ ដ៏មានឥទ្ធិពលក្នុង៍ការបង្កើតអត្តចរិត និង៍ជឿជាក់ ថា កុមារគួរតែអានកំណាព្យ និង៍រឿង៍ ដែលត្រូវ យកជាគំរូភាពពិត ស្តាប់បង្គាប់ដល់អាជ្ញាធម៌ សេចក្តីក្លាហាន និង៍ការគ្រប់គ្រង៍ចិត្ត រំភើប។

ក្រោយពេលដែលទទួលបានមូលដ្ឋាននព្វ ន្តសាស្ត្រច្បាស់លាស់ហើយសិស្សនឹង៍អនុវត្តដោយ ខ្លួនគេទៅនឹង៍ធរណីមាត្រសាស្ត្រ និង៍តារាវិទ្យា។

កីឡាកាយសម្ព័ន្ធ ដែលមានមុខងារខាង៍ លំហាត់ប្រាណមានប្រយោជន៍សម្រាប់ការហាត់ ទ័ព ដូចជា ការចាក់សាប ការបាញ់ធ្នូ ការគប់ លំពែង៍ និង៍ការជិះសេះ គឺត្រូវបានចាត់ ទុកជា រឿង៍សំខាន់បំផុត សម្រាប់ការកសាង៍អត្តចរិត និង៍ ការអភិវឌ្ឍខាង៍រាង៍កាយ។ ថ្នាតុង៍ ក៏បានរាប់ បញ្ចូលក្បួនច្បាប់នៃការតមអាហារ និង៍អនាម័យ នៅក្នុង៍កម្មវិធីសិក្សារបស់គាត់។

ញ-ការអប់រំនៅឧត្តមសិក្សា

ពីអាយុ១៨ឆ្នាំ ដល់២០ឆ្នាំ សិស្សនឹង៍បន្ត ការហ្វឹកហាត់យោធា និង៍រាង៍កាយច្រើនថែមទៀត។ នៅអាយុ២០ឆ្នាំ អធិរាជទស្សនវិជ្ជានាពេល អនាគត នឹង៍ត្រូវបានជ្រើសរើស សម្រាប់រៀននៅ ឧត្តមសិក្សា១០ឆ្នាំបន្ថែមទៀត ខាង៍គណិតវិទ្យា ធរណីមាត្រសាស្ត្រ តារាសាស្ត្រ តន្ត្រី និង៍វិទ្យាសា ស្ត្រ។ នៅអាយុ៣០ឆ្នាំ អ្នកមានសមត្ថភាពខាង៍ បញ្ញាទាប នៅក្នុង៍ចំណោមក្រុមនេះ នឹង៍ក្លាយទៅ ជាមន្ត្រីរាជការ (Civil servants)។ រីឯអ្នកដែលមាន សមត្ថភាព បញ្ញាខ្ពស់បំផុត នឹង៍បន្តការសិក្សា ទស្សនវិជ្ជាជាន់ខ្ពស់ជាង៍នេះទៀត ផ្នែកបរមត្ថ

វិទ្យា ការស្រាវជ្រាវរកគោលការណ៍ដែលបានពន្យល់តថភាពកម្រិតខ្ពស់បំផុត។ នៅពេលដែលការសិក្សារបស់គេ ត្រូវបានបញ្ចប់ អធិរាជទស្សនវិជ្ជា នឹងចាប់ផ្តើមដឹកនាំកិច្ចការនយោបាយ និងយោធារបស់សាធារណរដ្ឋ។ នៅអាយុ៥០ឆ្នាំ អធិរាជទស្សនវិជ្ជា នឹងក្លាយជារដ្ឋបុរស ដែលមានវ័យចំណាស់។

៥-៤-អារីស្តូត: ការអប់រំនៃសនិទានភាព

សិស្សរបស់ប្លាតុង ឈ្មោះអារីស្តូត (៣៨៤-៣២២មុនគ.ស.) ជាគ្រូបង្រៀនសិស្សតែម្នាក់របស់ Alexan derthe Great។ អារីស្តូតបានបង្កើតLyceum ជាសាលាទស្សនវិជ្ជាអាថែន ហើយបាននិពន្ធជាច្រើនផ្នែករូបវិទ្យា តារាសាស្ត្រ សត្តសាស្ត្រ ភូតគ្រាមសាស្ត្រ តក្កវិទ្យា សីលវិទ្យា និងបរមត្តវិទ្យា។ សីលវិទ្យា និងនយោបាយរបស់គាត់បានពិនិត្យមើលការអប់រំ ដែលមានទំនាក់ទំនងទៅនឹងសង្គម និងរដ្ឋាភិបាល[២៣]។

ក-តថភាពសត្យានុម័តិ (An Objective Reality)

វាមិនដូចអ្នកប្រៀនប្រដៅរបស់គាត់ ឈ្មោះប្លាតុង ដែលជឿថា តថភាព កើតមាន នៅក្នុងវិស័យគំនិតបរិសុទ្ធ។ អារីស្តូត យល់ថា តថភាព កើតមានជាសត្យានុម័តិ។ ថ្វីបើប្លាតុងបានបង្កើតទស្សនវិជ្ជាមនោនិយមក៏ដោយ ក៏អារីស្តូត បានបង្កើតទស្សនវិជ្ជាតថនិយមដែរ (ដែលមានសិក្សានៅផ្នែកខាងក្រោយ)។

អារីស្តូត បានកត់សម្គាល់ឃើញថា វត្ថុ ឬរូបធាតុ កើតមាននៅខាងក្រៅចិត្តរបស់ មនុស្ស តែជឿថា តាមឥន្ទ្រីយារម្មណ៍ និងអរូបី យើងអាចទទួលបានចំណេះដឹងអំពីវា។ អារីស្តូត នៅតែអះអាងដោយទទូចថា មនុស្សមានបញ្ញា គឺថាមពលដើម្បីគិតនិងធ្វើវិចារ។ ក្នុងនាមជាសត្វដែលមានវិចារណញ្ញាណ គេមានសក្តានុពលយល់ដឹងនិងរស់នៅយោងទៅតាមច្បាប់ធម្មជាតិដែលគ្រប់គ្រងចក្រវាឡ។

ខ-ឥន្ទ្រីយារម្មណ៍ជាប្រភពនៃចំណេះដឹង

ចំពោះអារីស្តូត ការយល់ដឹងចាប់ផ្តើមចេញពីឥន្ទ្រីយារម្មណ៍នៃវត្ថុរបស់អ្នកណាម្នាក់នៅក្នុងបរិស្ថាន។ ពីបទពិសោធនៃសរីរាង្គឥន្ទ្រីយ គេអាចបង្កើតបញ្ញត្តិអំពីវត្ថុឬរូបធាតុ។ ការបញ្ជាក់អះអាងរបស់អារីស្តូតទៅលើបទពិសោធតាមរយៈ សរីរាង្គឥន្ទ្រីយ ដែលជាការចាប់ផ្តើមនៃការយល់ដឹងនិងការបង្រៀនដែលក្រោយមកត្រូវបានអះអាងដោយអ្នកអប់រំនៅសតវត្សទី១៨ និងទី១៩ ដូចជា Locke and Pestalozzi។

គ-ការអប់រំជាការបណ្តុះសនិទានភាព

អារីស្តូត ស្តីពីការអប់រំ: ក្នុងផ្នែកនយោបាយរបស់គាត់ អារីស្តូត អះអាងថា សហគមន៍ល្អស្ថិតនៅលើសនិទានភាពរបស់សមាជិក។ ប្រសិនបើការអប់រំដែលជាអ្នកបណ្តុះសនិទានភាពនោះត្រូវបានធ្វេសប្រហែស ដូច្នេះ សហគមន៍នឹងទទួលរងគ្រោះថ្នាក់។ ដូចជា ប្លាតុង អារីស្តូត បាន

---

[២៣] Christopher Rowe and Sarah Brodie, *Aristotle: Nicomachean Ethics* (Oxford U.K.: Oxford University Press, 2002; also see Mary M. Spangler, *Aristotle on Teaching* (Lanham, Md.: University Press of America, 1998).

បែងចែកភាពខុសគ្នារវាងការអប់រំសេរី និងការបណ្តុះបណ្តាលបច្ចេកទេស។ អារីស្តូត បានមើលឃើញសិល្បៈសេរីថា ជាការពង្រីកនភាពរបស់មនុស្សញាណ និងការជ្រើសរើស និងគាត់បានមើលឃើញការបណ្តុះបណ្តាលវិជ្ជាជីវៈថា ជារឿងមានតម្លៃតាមដែនកំណត់របស់វាតែម្យ៉ាង។ ការពិភាក្សានាសម័យទំនើបរវាងអ្នកអប់រំសេរី និងមុខរបរ ជាញឹកញាប់ខ្ទុះបញ្ចាំងបញ្ហាតែមួយដែលអារីស្តូត និងអ្នកទ្រឹស្តីដទៃទៀតបានពិនិត្យមើល ហើយក្នុងនាមជាគ្រូម្នាក់អ្នកអាចនឹងជួបប្រទះកំណែប្រែថ្មីនៃការពិភាក្សាតែមួយនៅពេលដែលសិស្សសួរអ្នកពីមូលហេតុដែលគេគួរសិក្សាអ្វីមួយដែលគេជឿជាក់ថា វានឹងមិនត្រូវបានប្រើប្រាស់។ អ្វីជាសនិទានកម្មរបស់អ្នកដើម្បីបង្រៀនបំណិនពិតប្រាកដ និងមុខវិជ្ជាទាំងឡាយតែមិនមែនមុខវិជ្ជាផ្សេងទៀត។

ឃ-កម្មវិធីសិក្សារបស់អារីស្តូត

អារីស្តូត បានផ្តល់ឱ្យមានការអប់រំជាកាតព្វកិច្ច។ ការអប់រំកុមារតូច គឺត្រូវមានការលេងសកម្ម ភាពខាងរាងកាយ និងរឿងនិទានដែលសមរម្យ។

កុមារពីអាយុ៧ឆ្នាំដល់១៤ឆ្នាំ ត្រូវរៀនលេខនិងការអាន សរសេរនិងទម្ងាប់សីលធម៌សមរម្យដើម្បីត្រៀមរៀបចំពួកគេឱ្យសិក្សានាពេលអនាគតខាងសិល្បៈសេរី។ កម្មវិធី សិក្សារបស់គេក៏បានរាប់បញ្ចូលការអប់រំកាយ និងតន្ត្រី ដើម្បីបណ្តុះផ្នែកអឌ្ឍស័យចិត្តរំកើបសមរម្យ។

ពីអាយុ១៥ឆ្នាំរហូតដល់២១ឆ្នាំ យុវជនត្រូវសិក្សាគណិតវិទ្យា ធរណីមាត្រសាស្ត្រ តារាសាស្ត្រ វេយ្យាករណ៍ រៀហារសាស្ត្រ សីលវិទ្យា និងនយោបាយ។

នៅអាយុ២១ឆ្នាំ សិស្ស ត្រូវបន្តរៀនមុខវិជ្ជាខាងទ្រឹស្តីថែមទៀត ដូចជារូបវិទ្យា លោកធាតុវិទ្យា ជីវវិទ្យា ចិត្តវិទ្យា តក្កវិទ្យា និងបរមត្ថវិទ្យា។

ង-តួនាទីតាមដែនកំណត់របស់ស្ត្រី

ដោយជឿជាក់ថា ស្ត្រីមានប្រាជ្ញាអន់ជាងបុរស អារីស្តូត បានយកចិត្តទុកដាក់តែការអប់រំបុរសតែប៉ុណ្ណោះ។ ក្មេងស្រី ត្រូវបានគេអប់រំសម្រាប់តែឱ្យធ្វើការងារផ្ទះ និងតួនាទីចិញ្ចឹមកូនដែលចាំបាច់សម្រាប់ពេលអនាគតជាប្រពន្ធ និងជាមាតា។

ចំណេះដឹងជាឃ្លាត្តិដែលធ្លាក់ចុះលើភាព

ទ្រឹស្តីរបស់អារីស្តូតនៃចំណេះដឹង: អារីស្តូត ជាជនតថនិយម ខុសប្លែកពីថ្វាតុង ជាជនមនោនិយម នៅក្នុងបញ្ញត្តិរបស់គាត់ស្តីពីចំណេះដឹងកើតឡើងពីវត្ថុជាជាងពីគំនិត ដែលកើតឡើងមុននៅក្នុងចិត្ត។ យោលទៅតាមអារីស្តូត ចំណេះដឹងតែងតែអំពីវត្ថុ។ ការអប់រំ ផ្តោតទៅលើការចាត់ថ្នាក់របស់វត្ថុ ទៅជាបញ្ហាប្រធានបទ ឬមុខវិជ្ជា។

ឧទាហរណ៍៖ ប្រសិនបើអ្នកកំពុងតែបង្រៀនភូតគ្រាមសាស្ត្រ ដោយប្រើប្រាស់វិធីអារីស្តូតនោះ អ្នកអាចបង្រៀន អំពីដើមឈើទាំងឡាយជាថ្នាក់មួយ ដែលជាប្រភេទទូទៅមួយក្នុងតថភាពភូតគ្រាមសាស្ត្រ និងអំពីដើមឈើជាពិសេស ដែលជាសមាជិកមួយៗនៃថ្នាក់នេះ។

ឆ-ឥទ្ធិពលដែលស្ថិតនៅរបស់អារីស្តូត

គោលដៅបឋមរបស់សាលារៀនអារីស្តូត គឺត្រូវបណ្តុះសនិទានភាព។ ក្នុងនាមជាស្ថាប័នសិក្សាសាលារៀនគួរ តែផ្តល់កម្មវិធីសិក្សាទៅតាមបញ្ហាប្រជានបទ ដែលបានកំណត់ដោយផ្អែកលើមុខវិជ្ជាវិទ្យាសាស្ត្រ និងមានខ្លឹមសារ។ គ្រូ ត្រូវតែមានចំណេះដឹង ជំនាញទៅលើមុខវិជ្ជារបស់ខ្លួន និងមានជំនាញនៅក្នុងការជំរុញទឹកចិត្តសិស្ស និងផ្ទេរចំណេះដឹងទៅឱ្យសិស្ស។ ទស្សនវិជ្ជារបស់អារីស្តូត មានខ្លឹមសារដ៏សំខាន់ទៅលើការអប់រំលោកខាងលិច។ ក្នុងចំណោមលទ្ធិរបស់សាសនាគ្រិស្ត វាក្លាយជាមូលដ្ឋានគ្រឹះនៃការអប់រំសិក្សានៅមជ្ឈិមសម័យ (ខ្លឹមសារលំអិតនឹងបកស្រាយនៅពេលក្រោយ)។

៥-៥-អ៊ីសូក្រាតៈ សិល្បៈនៃការថ្លែងសុន្ទរកថា និងវោហារសាស្ត្រ

អ្នកវោហារសាស្ត្រជនជាតិក្រិក ឈ្មោះ Isocrates(436-388B.C.)ជាមនុស្សដ៏សំខាន់សម្រាប់ទ្រឹស្តីអប់រំ ដែលមានរចនាសម្ព័ន្ធត្រឹមត្រូវលើសគេឯង ដែលសង្កត់ធ្ងន់ទៅ លើចំណេះដឹង និងបំណិនវោហារសាស្ត្រ[២៤]។ ទ្រឹស្តីរបស់គាត់ប្រកាន់ តាមផ្លូវកណ្តាល រវាងទំនាស់នៃពួកសូហ្វីស និងប្លាតុង។ អភិប្រាយរបស់អ៊ីសូក្រាត ប្រឆាំងនឹងពួកសូហ្វីស បានពន្យល់នូវវិធី ដែលបានប្រើប្រាស់ក្នុងសាលារៀននេះ។

ក-ការសង្កត់ធ្ងន់ទៅលើវោហារសាស្ត្រ

អ៊ីសូក្រាត ចាត់ទុកគោលដៅបឋមនៃការអប់រំថា ត្រូវតែត្រៀមរៀបចំរដ្ឋបុរស ឱ្យមានការគិតច្បាស់លាស់ប្រកបដោយវិចារណញ្ញាណ និងសច្ចភាព។ គាត់ជឿជាក់ថា កំណែទម្រង់ស៊ីវិល ទាមទារឱ្យមានការអប់រំអ្នកដឹកនាំ ដែលប្រកបដោយគុណធម៌ ដែលអាចជាអ្នករដ្ឋបាល មានប្រសិទ្ធភាព។ ក្នុងចំណោមការសិក្សាដោយសេរីIsocrates យល់ថា វោហារសាស្ត្រ ដែលបានកំណត់ន័យថា ជាការបង្ហាញគំនិតប្រកបដោយវិចារណញ្ញាណនោះ គឺជារឿងសំខាន់ បំផុតក្នុងការបណ្តុះសីលធម៌ និងភាពជាមេដឹកនាំនយោបាយ។ ការអប់រំវោហារសាស្ត្រគួរតែផ្សំបញ្ចូលគ្នាសិល្បៈ និងវិទ្យាសាស្ត្រ និងទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព។ អ្នកជំនាញខាងថ្លែងសុន្ទរកថាដ៏មានតម្លៃ គួរតែអះអាងសម្រាប់បុព្វហេតុកិត្តិយសដែលបានជំរុញដល់កុសលសាធារណៈ។ តាមគោលវិធីខាងលើ អ្នកមានជំនាញខាងថ្លែងសុន្ទរកថា នឹងបញ្ចុះបញ្ចូលមនុស្សឱ្យធ្វើតាមគោលនយោបាយដ៏ល្អ។ Isocrates ប្រឆាំងនឹងការបង្រៀនរបស់ពួក សូហ្វីសនៃវោហារសាស្ត្រ ដែលគ្រាន់តែជាផ្លូវបញ្ចុះបញ្ចូលដដែលៗ ឬបច្ចេកទេសទំនាក់ទំនងសាធារណៈ។

សិស្សរបស់Isocrates ដែលបានសិក្សា នៅសាលារបស់គាត់រយៈពេល៤ឆ្នាំនោះ បានសិក្សាវោហារសាស្ត្រ នយោបាយ ប្រវត្តិសាស្ត្រ និងសីលវិទ្យា។ ពួកគេបានវិភាគ និងត្រាប់តាមសិល្បៈនៃការថ្លែងសុន្ទរកថាគំរូ និងប្រតិបត្តិការនិយាយ ជាសាធារណៈ។ ក្នុងនាមជាគ្រូគំរូម្នាក់ Isocrates ជឿជាក់

[២៤] Ekaterina V.Haskins. *Logos and Power in Isocrates and Aristotle* (Columbbia: University of South Carolina Press, 2004), also see Gerald L. Gutek, *A History of the Western Educational Experience* (Prospect Heights, III.: Waveland Press, 1995), pp52-54.

ថា គាត់ទទួលខុសត្រូវចំពោះការជះឥទ្ធិពលដល់សិស្ស តាមការបកស្រាយផ្ទាល់របស់គាត់នៃចំណេះដឹងបំណិន និងចរិយាខាងសីលវិទ្យា។

ខ-ការធ្វើតុល្យភាពឆ្លាតវៃ និង ពួកសូហ្វីស

ទោះបីជា Isocrates ប្រឆាំងនឹងកាលានុវត្តនិយមដ៏កម្រោលរបស់ពួកសូហ្វីស គាត់បានបដិសេធការអះអាងរបស់ប្លាតុងដែលថា ការអប់រំមានតែទ្រឹស្តីសុទ្ធ និងអរូបី។ ចំពោះការអប់រំ Isocrates បានរួមចំណែកដល់សេវាកម្មសាធារណៈដែលត្រូវបានដឹកនាំដោយចំណេះដឹង។ Isocrates មានឥទ្ធិពលទៅលើប្រពៃណីខាងវោហារសាស្ត្រក្នុងការអប់រំ ជាពិសេស អ្នកទ្រឹស្តីអប់រំរបស់រ៉ូម៉ាំងឈ្មោះQuintilian។ ដោយទទួលស្គាល់វិសាលភាពវោហារសាស្ត្ររបស់មនុស្សជាតិ Isocrates ក៏បានរួមចំណែកដល់ឧត្តមគតិរបស់មនុស្ស ដែលមានការអប់រំដោយសេរី។

៥-៦-ការអប់រំ នៅក្រុងរ៉ូមបុរាណ

នៅពេលដែលវប្បធម៌ និងការអប់រំរបស់ក្រិក កំពុងតែបានអភិវឌ្ឍនៅសមុទ្រមេឌីទែរ៉ាណេប៉ែកខាងលិចនោះ ពួករ៉ូម៉ាំង កំពុងតែពង្រឹងជំហរខាងនយោបាយនៅលើឧបទ្វីបអ៊ីតាលី (Italian Peninsula) និងពាសពេញសមុទ្រមេឌីទែរ៉ានេប៉ែកខាងលិច។ នៅក្នុងចលនារបស់គេពីសាធារណរដ្ឋដ៏តូច ទៅជាចក្រភពដ៏ធំនោះ ពួករ៉ូម៉ាំងបានផ្តើមកាន់កាប់ឬត្រួតត្រាជាមុនដោយសង្គ្រាមនិងនយោបាយ។ នៅពេលមួយនោះ ពួកគេបានក្លាយទៅជាអំណាចចក្រភពនោះ ពួកគេបានផ្ទង់អារម្មណ៍ទៅលើរដ្ឋបាល ច្បាប់ និងការទូតដែលចាំបាច់ដល់ការថែរក្សាចក្រភព។ ដោយមូលហេតុដែលគេបានកត់សម្គាល់ឃើញថា ពួកក្រិក យកចិត្តទុក ដាក់តែទៅលើទស្សនវិជ្ជានោះ ពួករ៉ូម៉ាំងបែរជាផ្តោតអារម្មណ៍ទៅលើការអប់រំអ្នកនយោបាយជាក់ស្តែង អ្នករដ្ឋបាល ដែលមានសមត្ថភាព និងជំនាញទូទៅ។

ក-ការចូលរៀន

នៅក្នុងប្រទេសក្រិកបុរាណ មានតែពួករ៉ូម៉ាំងមួយភាគតូចប៉ុណ្ណោះ ដែលបានទទួលការអប់រំក្នុងប្រព័ន្ធ។ ការអប់រំទុកសម្រាប់តែមនុស្សដែលមានលុយបង់ថ្លៃសាលារៀន និងពេលវេលាសិក្សា។

ខ-សាលាបឋមសិក្សា និងមធ្យមសិក្សា

ដោយហេតុថា ក្មេងស្រីវណ្ណៈខ្ពស់ជារឿយៗបានរៀនអាន និងសរសេរនៅផ្ទះ ឬត្រូវបានបង្រៀនដោយគ្រូបង្រៀនសិស្សទោលនោះ ក្មេងប្រុសដែលមកពីគ្រួសារទាំងនេះ បានចូលរៀន នៅសាលាបឋមសិក្សា (Ludus) ហើយបន្ទាប់មកមធ្យមសិក្សាដែលត្រូវបានបង្រៀនដោយគ្រូដែលបង្រៀនវេយ្យាករណ៍ក្រិក និងឡាតាំង។ ក្មេងប្រុសត្រូវបានគេជួនទៅរៀននៅសាលារៀនទាំងនេះដោយពួកទាសករក្រិកដែលមានការអប់រំ ត្រូវបានគេហៅថា Pedagogues (=Teachers)ដែលពាក្យគរុកោសល្យ (Pedagogy) មានន័យថា សិល្បៈនៃការបង្រៀន បានក្លាយចេញពីពាក្យនេះឯង។

គ-ឧត្តមគតិនៃទាក្ខិន

ឧត្តមគតិអប់រំរបស់ពួករ៉ូម ត្រូវបានបញ្ជាក់ដោយវាគ្មិន។ វាគ្មិនរ៉ូម៉ាំង ដែលប្រកបដោយ ឧត្តមគតិ គឺជាមនុស្ស ដែលមានការអប់រំពីជីវិតសាធារណៈយ៉ាងទូលំទូលាយនិងដោយសេរី ដូចជាសមា

ជិតព្រឹទ្ធសភា មេធាវី គ្រូបង្រៀន មន្ត្រីរាជការ និង អ្នកនយោបាយ។ ដើម្បីពិនិត្យ មើលឧត្តមគតិនៃ សិល្បៈខាងការថ្លែងសុន្ទរកថារបស់រ៉ូម៉ាំង យើងត្រូ ឡប់ទៅមើលQuintilian។

Quintilian៖ ជំនាញច្បាស់លាស់នៃការថ្លែង សុន្ទរកថា ៖ Marcus Fabias Quintinius (A.D. 35-95) ឬ ហៅថា Quintilian គឺជាវោហារសាស្ត្រវិទូ ដែលត្រូវ បានគេទទួលស្គាល់ដោយកម្រិត ខ្ពស់បំផុតរបស់ ចក្រភពរ៉ូម៉ាំង។ អធិរាជ បានតែងតាំងគាត់ ទៅដល់ កម្រិតប្រធាន នៃវោហារសាស្ត្រឡាតាំងទីមួយ។

ឃ-ការបង្រៀនដោយផ្អែកលើដំណាក់ កាលនៃការលូតលាស់

Quintilian's Institutio Oratoria ដែលជាអកិ ប្រាយអប់រំជាប្រព័ន្ធ បានពាប់បញ្ចូល៖

1-ការអប់រំដែលជាបរិវច្ឆ័ណ ដើម្បីសិក្សា វោហារសាស្ត្រ។

2-ទ្រឹស្តីអប់រំ និងវោហារសាស្ត្រ។

3-ការប្រតិបត្តិនៃការនិយាយជាសាធារណៈ ឬការថ្លែងទៅកាន់ទស្សនិកជន។

Quintilian បានបង្កើតចំណុចអប់រំដ៏សំខាន់ ដែលការបង្រៀន គួរតែផ្អែកទៅលើដំណាក់កាល នៃការលូតលាស់ និងការអភិវឌ្ឍមនុស្ស។ ដោយ ការប្រមើលមើលការយកចិត្តទុកដាក់របស់គ្រូ សម័យទំនើប នៃភាពខុសគ្នារបស់សិស្សម្នាក់ៗ នោះ គាត់បានផ្តល់ដំបូន្មានថា ការបង្រៀន គួរតែ មានភាពសមរម្យដល់ភាពត្រៀមជាស្រេច និង បំណិនរបស់សិស្ស។ គាត់បានបញ្ជាក់នូវសារៈ សំខាន់នៃវ័យដើមកុមារភាពក្នុងការបង្កើតអាកប្ប កិរិយា ហើយគាត់បានផ្តល់ យោបល់ថា គ្រូ បង្រៀនត្រូវជំរុញទឹកចិត្តសិស្សដោយធ្វើឱ្យការ សិក្សា មានការចាប់អារម្មណ៍និងការទាក់ទាញ។

សម្រាប់ដំណាក់កាលដំបូង ពីពេលកើត រហូតដល់អាយុ៧ឆ្នាំនៅពេលដែលកុមារកំពុងមាន សន្ទុះចិត្ត និងយកចិត្តទុកដាក់ជាមួយនឹងតម្រូវការ និងចំណង់ក្ងាមៗនោះ គាត់បានផ្តល់ដំបូន្មានដល់ ឪពុម្ពាយឱ្យចេះជ្រើសរើសមេដោះគ្រូបង្រៀន ដែលមានការបណ្តុះបណ្តាលល្អ និងនិយាយបាន ត្រឹមត្រូវនិងមិត្តភ័ក្តិ សម្រាប់កុមារផង។

ង-ការអាន និងការសរសេរ

ក្នុងដំណាក់កាលទី២នៃការអប់រំរបស់ Quintilian ពីអាយុ៧-១៤ឆ្នាំ កុមារគួររៀនពីបទ ពិសោធដែលទាក់ទងដល់តន្ត្រីយារម្មណ៍ បង្កើត គំនិតច្បាស់លាស់ និងបណ្តុះបណ្តាលលំនឹក របស់គេ។ ឥឡូវនេះ គេរៀនសរសេរភាសាដែលគេ ចេះនិយាយរួចហើយ។ គ្រូបង្រៀនដំបូង (litterator) ដែលបានបង្រៀនអាន និងសរសេរ នៅបឋមសិក្សា នោះ ត្រូវតែមានអត្តចរិតថ្លៃថ្នូរ និងមានសមត្ថភាព បង្រៀន។ ការបង្រៀនខាងអំណាន និងសំណេរគួរ តែយឺតៗ និងហ្មត់ចត់ ហើយកុមារ គួររៀនអក្ខរក្រម ដោយប្រើប្រាស់លំដាប់អក្សរធ្វើពីភ្នក។ ដូចជា Montessori ច្រើន សតវត្សក្រោយមក Quintilian បាន ផ្តល់ដំបូន្មានថា កុមាររៀនសរសេរអក្សរ ដោយតាម ដានរូបរាងតួអក្សរ។ ដោយប្រមើលមើលការអប់រំ សម័យទំនើប គាត់បានអះអាងថា សាលារៀនសព្វ ថ្ងៃនេះ ពាប់បញ្ចូលទាំងការចេញលេងដើម្បីលេង

ល្បែង និងការកម្សាន្តផ្សេងៗដើម្បីឱ្យសិស្សមានកម្លាំង និងថាមពលថ្មីឡើងវិញ។

ច-ការសិក្សាសិល្បៈសេរី

សម្រាប់ដំណាក់កាលទី៣ នៃការអប់រំនេះ ពីអាយុ១៤-១៧ឆ្នាំ បានសង្កត់ធ្ងន់ទៅលើ សិល្បៈសេរី។ សិស្ស បានសិក្សាវេយ្យាករណ៍ក្រិក និងឡាតាំង អក្សរសិល្ប៍ ប្រវត្តិវិទ្យា ទេវកថា វិទ្យាដោយប្រើភាសា និងវប្បធម៌ទាំង២។ សិស្សក៏បានសិក្សាផងដែរនូវតន្ត្រី ធរណីមាត្រសាស្ត្រ តារាសាស្ត្រ និងកីឡាកាយសម្ព័ន្ធ។

ឆ-ការសិក្សាវោហារសាស្ត្រ

វាគ្មិនសម្រាប់ពេលអនាគត ទទួលបានការសិក្សាខាងវោហារសាស្ត្រ ជាដំណាក់កាលទី៤ ពីអាយុ១៧-២៤ឆ្នាំ។ ក្នុងការសិក្សាវោហារសាស្ត្រ Quintilianរាប់បញ្ចូលទាំងវិនាដសាស្ត្រកំណាព្យ ច្បាប់ ទស្សនវិជ្ជា ការនិយាយជាសាធារណៈការថ្លែងទៅកាន់ទស្សនិកជននិងការពិភាក្សា[២៥]។ ការថ្លែងទៅកាន់ទស្សនិកជនដែលជាលំហាត់និយាយជាប្រព័ន្ធគឺមានសារៈសំខាន់ណាស់។ ក្រោយពេលត្រៀមរៀបចំបានសមរម្យ វាគ្មិនថ្មីៗ ថ្លែងទៅកាន់ទស្សនិកជនជាសាធារណៈនៅលើវេទិកា ហើយបន្ទាប់មកត្រឡប់ទៅរកវោហារសាស្ត្រវិទូសម្រាប់ការរិះគន់ទៅតាមជំនាញ។ គ្រូបង្រៀនបានកែកំហុសសិស្ស ដោយមានសុភវិនិច្ឆ័យពីអ្នកជំនាញដោយមានអំណត់ជំនាញដោយសុឆន្ទៈនិងការពិចារណា។

៥-៧-ការរួមចំណែករបស់ក្រិក និងរ៉ូម៉ាំងចំពោះការអប់រំលោកខាងលិច

សិល្បៈសេរី: ការអប់រំ និងវប្បធម៌លោកខាងលិច បានទទួលកេរដំណែលដ៏ច្រើនលើសលុបពីក្រិក និងរ៉ូមបុរាណ។ ភាគច្រើននៃរចនាសម្ព័ន្ធអប់រំ និងវប្បធម៌ ដែលបង្កើតបាន ជាអរិយធម៌លោកខាងលិច បានអភិវឌ្ឍក្នុងក្រិក និងរ៉ូមបុរាណ។ ដោយមានការជឿជាក់ថា វាអាចធ្វើទៅបានដើម្បីបណ្តុះឧត្តមភាពរបស់មនុស្ស ពួកក្រិក និងរ៉ូម៉ាំងបានផ្តល់ការអប់រំនូវមុខងារដ៏សំខាន់នៅក្នុងសុខុមាលភាពនយោបាយសង្គម។ ទោះជាយ៉ាងណាក្តី ការប្រតិបត្តិការអប់រំរ៉ូម៉ាំងក្រិកមួយចំនួនដោយរាប់បញ្ចូលទាំងភាពខុសគ្នា រវាងការអប់រំសេរី និងការបណ្តុះបណ្តាលវិជ្ជាជីវៈបាននាំទៅដល់វិវាទពិសេសដែលបានស្ថិតនៅក្នុងប្រវត្តិសាស្ត្រលោកខាងលិច។

គំនិតជាច្រើននៃពួកក្រិក និងរ៉ូម៉ាំង បានជះឥទ្ធិពលភាពមានវិជ្ជាជ្រៅជ្រះ ដល់ពួកអារ៉ាប់ដែលបានរក្សាទុក និងបានបកប្រែវា។ នៅពេលដែលពួកអឺរ៉ុប បានពើបប្រទះភាពមានវិជ្ជាជ្រៅជ្រះរបស់អារ៉ាប់ គំនិតទាំងនេះ ត្រូវបានផ្ទេរទៅកាន់អឺរ៉ុប ហើយបន្ទាប់មកដល់វប្បធម៌អាម៉េរិក។

៦-អ៊ីស្លាម: ការសិក្សាពីអារ៉ាប់ និងការអប់រំ

អរិយធម៌អ៊ីស្លាម ដែលមានប្រភពពីអារ៉ាប់ បានក្លាយជាកម្លាំងអប់រំ និងវប្បធម៌សកលតាមបំណងដើម្បីស្រូបទាញបកស្រាយឡើងវិញ និងផ្ទេរចំណេះដឹងពីតំបន់មួយនៅក្នុងពិភពលោក

[២៥] James J. Murphy, ed., *Quintilian on the Teaching of Speaking and Writing* (Cabondale: Southern Illinois University Press, 1987)

ទៅតំបន់មួយទៀត[២៦]។ ដើមកំណើតវប្បធម៌អ៊ីស្លាម បានចាប់ផ្តើមជាមួយម៉ូហាមេត Mohammed (569-632)អ្នកកែទម្រង់សាសនាជនជាតិអារ៉ាប់ និងជាអ្នកញ៉ាំងឱ្យផ្ទាស់សាសនា(proselytizer)។ Mohammed បានចាប់ផ្តើមបេសកកម្មសាសនា នៅអារ៉ាប់ក្នុងទីក្រុងម៉ិកកា (Mecca) នៅឆ្នាំ៦១០ ដែលជាកន្លែងគាត់បានទេសនាចាំបាច់សម្រាប់កុក្កច្ច: និងការរស់នៅដោយមានសីលធម៌ និងទៀងត្រង់។ បន្តិចម្តងៗ គាត់បានរៀបចំគំនិតរបស់គាត់ទៅជាអ៊ីស្លាម ដែលជាសាសនាថ្មីមួយ។ សព្វថ្ងៃនេះ អ៊ីស្លាម ជាជំនឿខាងសាសនា ដែលមានចំនួនប្រជាជន ១/៨ ក្នុងពិភពលោក។ វាជាសាសនាដែលបានគ្របដណ្តប់ក្នុងប្រទេសអារ៉ាប់ទាំងឡាយ នៅមជ្ឈិមបូព៌ា និងអាហ្វ្រិកខាងជើង ហើយឥទ្ធិពលរបស់វាបានរាលដាលដល់ឥណ្ឌូនេស៊ី ម៉ាឡេស៊ី និងប៉ាគីស្តាន ព្រមទាំងប្រទេសផ្សេងៗទៀត នៅទ្វីបអាស៊ី។ លើសពីនេះទៀត ជនម៉ូស្លីម ដែលជាអ្នកគោរពសាសនាអ៊ីស្លាម បានរស់នៅក្នុងប្រទេសជាច្រើនពាសពេញពិភពលោក ទោះបីជាញឹកញាប់បានក្លាយជាជនជាតិភាគតិចក៏ដោយ។ ដោយត្រូវបានគេគោរពយ៉ាងជ្រាលជ្រៅថាជាព្យាការី សិស្សរបស់ Mohammed បានជឿជាក់ថា គាត់បាននិយាយដល់ពិភពលោក ដែលបានលាតត្រដាងដោយ Allah ឬព្រះ (God) ដែលត្រូវបានកត់ត្រាក្នុងគម្ពីរកូរ៉ាន (Koran)។ ដោយត្រូវបានសរសេរជាភាសាអារ៉ាប់ គម្ពីរកូរ៉ាន មិនគ្រាន់តែក្លាយជាសៀវភៅសាសនាដ៏ពិសិដ្ឋបំផុតរបស់អ៊ីស្លាមប៉ុណ្ណោះទេ ប៉ុន្តែ ថែមទាំងជាប្រភពច្បាប់ និងសីលវិទ្យាអាជ្ញាព្រឹត្តផងដែរក្នុងអារ៉ាប់ និងប្រទេសកាន់សាសនាអ៊ីស្លាមផងដែរ។ គម្ពីរកូរ៉ានភាគច្រើនបានរួមចំណែកដល់សុភនិច្ឆ័យនៃការរួបរួមវប្បធម៌អ៊ីស្លាម និងអារ៉ាប់។ នៅពេលមួយនោះ បក្សសម្ព័ន្ធអារ៉ាប់ដែលមានការឈ្លោះប្រកែកគ្នានោះ បានរួបរួមគ្នានៅក្រោមទង់នៃការពង្រីកសាសនាអ៊ីស្លាមពាសពេញពិភពលោក។

ត្រឹមឆ្នាំ៦៦១ កងកម្លាំងអារ៉ាប់ បានកាន់កាប់ និងបង្កើតសាសនាអ៊ីស្លាម ជាសាសនាផ្លូវការនៅប្រទេស Palestine, Syria, Persia, and Egypt។ ទីក្រុង Bagdad, Cairo, Damacus, and Cordoba បានក្លាយជាមជ្ឈមណ្ឌលដ៏មានកិត្តិនាមនៃការអប់រំ និងវប្បធម៌អ៊ីស្លាម។ ក្រុងបាជាដជាមជ្ឈមណ្ឌលអប់រំដ៏ធំមួយនោះ ជាកន្លែងដែលអ្នកប្រាជ្ញពួកអារ៉ាប់ ក្រិក អ៊ីរ៉ង់ និងជ្វីហ្វ បានផ្ទាស់ប្តូរគំនិតគ្នា។

បន្ទាប់មក សាវ័ករបស់ Mohammed បានបន្តពង្រីកឥទ្ធិពលសាសនាអ៊ីស្លាមតាមរយៈសញ្ជ័យ និងកំណែប្រែថ្មី។ ក្រោយពេលវាយដណ្តើមបានទ្វីបអាហ្វ្រិកខាងជើង អំណាចអារ៉ាប់ លាតសន្ធឹងដល់អេស្ប៉ាញ។ នៅទីនោះ ជនអារ៉ាប់អ៊ីស្លាមនិងពួកអ្នកកាន់សាសនាគ្រិស្តលោកខាងលិចបានតស៊ូប្រយុទ្ធដើម្បីអំណាច និងទឹកដី ប៉ុន្តែក៏បានខ្ចីគំនិតពីគ្នាទៅវិញទៅមក[២៧]។ រាជាណាចក្រអ៊ីស្លាម (Moorish)នៃប្រទេសអេស្ប៉ាញ បានបន្តរហូតដល់ឆ្នាំ១៤៩២ នៅពេលដែលពួកគេត្រូវបានវាយ

[២៦] Malise Ruthven, *Islam in the World* (New York: Oxford University Press, 2000)

[២៧] Http://www.islamicity.com/mosque/ihame/sec5.htm (09/25/3003), pp.1-2

ដណ្តើម ដោយពួកសត្រូវនៃប្រទេសអេស្ប៉ាញ ដែលកាន់សាសនាគ្រិស្ត[២៨]។ ក្នុងអំឡុងពេលនៃពួក Moorish, Cordoba ដោយមានប្រជាជនចំនួន៥០០ ០០០នាក់ ព្រះវិហារម៉ូស៧០០និងបណ្ណាល័យ ចំនួន៧០បានក្លាយជាមជ្ឈមណ្ឌលអប់រំ និងវប្ប ធម៌អារ៉ាប់ដែលនាំមុខគេ[២៩]។

អ្នកប្រាជ្ញអ៊ីស្លាម បានបកប្រែអត្ថបទចេញ ពីអ្នកនិពន្ធក្រិកបុរាណ ដូចជា Aristotle, Euclid, Archimedes, Hippocrates ទៅជាភាសាអារ៉ាប់។ ស្នាដៃដែលបានបកប្រែ មានសារៈសំខាន់ដល់ការ អប់រំអ៊ីស្លាម ហើយតាមរយៈការទាក់ទងគ្នារវាងពួក អារ៉ាប់ និងពួកអឺរ៉ុប ត្រូវបាននាំយកទៅប្រើប្រាស់ ទៅជាការអប់រំលោកខាងលិច។ ជាពិសេស Ibn-Rushd, or Averroës (1126-1198) បាននិពន្ធបទអត្ថាធិ ប្បាយដ៏សំខាន់ ទៅលើអារីស្តូត ដែលជះឥទ្ធិពល ដល់ អ្នកអប់រំពួកអឺរ៉ុប នៅមជ្ឈិមសម័យ។

ភាពមានវិជ្ជាជ្រៅជ្រះខាងអ៊ីស្លាម បាននាំ ទៅដល់ភាពជឿនលឿនខាងតារាសាស្ត្រ គណិត វិទ្យា និងវេជ្ជសាស្ត្រ។ ខាងគណិតវិទ្យា អ្នកប្រាជ្ញអា រ៉ាប់ បានចាប់ប្រើប្រព័ន្ធលេខពីឥណ្ឌា ប៉ុន្តែបាន បង្កើតបន្ថែមលេខសូន្យដ៏ចាំបាច់។ នវានុវត្តន៍នេះ បានបង្កើតភាពងាយស្រួលក្នុងការជំនួសប្រព័ន្ធឡា តាំងដែលទើសទែង។

នៅសតវត្សទី២១ អន្តរកម្មបានបន្តរវាងវប្ប ធម៌អ៊ីស្លាម និងអារ៉ាប់ និងពិភពលោកខាងលិច។ ទោះបីជាមានទំនាស់នាពេលថ្មីៗយ៉ាងខ្លាំងក៏ ដោយរវាងលោកខាងលិច ជាពិសេសសហរដ្ឋ អាម៉េរិក និងអារ៉ាប់ និងក្រុមអ៊ីស្លាមក៏ការជួបប្រទះ ជាវិជ្ជមានថែមទៀត បានកើតឡើងរវាងពួកអារ៉ាប់ និងអាម៉េរិក។ ជាពិសេសពួកអាម៉េរិកជាច្រើន កំពុងបានការយកចិត្តទុកដាក់ និងសិក្សាថែមទៀត អំពីការរួមចំណែកនៃអរិយធម៌អារ៉ាប់ និងសាសនា អ៊ីស្លាមចំពោះវប្បធម៌ពិភពលោក។

ក្នុងលទ្ធផលនៃការវាយប្រហារទៅលើ មជ្ឈមណ្ឌលពាណិជ្ជកម្មពិភពលោកនៅថ្ងៃទី១១ ខែកញ្ញាឆ្នាំ២០០១ និងការឆ្លើយតបរបស់សហរដ្ឋ អាម៉េរិកជាមួយការយកចិត្តទុកដាក់លើសង្គ្រាមកេ រវកម្មនិយម បានកើនឡើង ចំពោះការសិក្សាវប្ប ធម៌អារ៉ាប់ និងសាសនាអ៊ីស្លាម។ ទោះបីជាពួកគេវ ជនមួយចំនួនត្រូវបានកំណត់អត្តសញ្ញាណថាមាន សញ្ជាតិមកពីប្រទេស អារ៉ាប់ក៏ដោយក៏សកម្មភាព ទាំងឡាយតិចតួច មិនបានតំណាងការគិតដល់ជន អារ៉ាប់ទាំងអស់ និងធ្ងន់បញ្ចាំងដល់ជំនឿអ៊ីស្លាម។ ដើម្បីយល់ដឹងពីការផ្លាស់ប្តូរកម្លាំងពិភពលោក នោះសាលារៀន និងមហាវិទ្យាល័យអាម៉េរិកកំពុង យកចិត្តទុកដាក់ថែមទៀតដើម្បីរាប់បញ្ចូលមុខវិជ្ជា សិក្សាទៅលើប្រជាជននិងវប្បធម៌អារ៉ាប់ និង សាសនាអ៊ីស្លាម។

---

[២៨] Mortimer Chamber, Raymont Grew, David Herlihy, Theodore Rabb, and Isser Woloch, *The Western Experience* (New York: Knopf, 1983), pp.228-235.

[២៩]Http:// www.islamicity.com/mosque/ihame/sec5.htm (09/25/3003), pp.1-2

ឯកសារយោង

1. Allan C. Ornstein et al., *Foundation of Education*, Wadsworth, Canada. 2008.
2. Allan C. Ornstein et al., *Foundation of Education*, Wadsworth, Canada. 20011.
3. Barzun, Jacques. *From Dawn to Decadence: 500 Years of Western Cultural Life, 1500 to the Present.* New York: HarperCollins, 2001.
4. Black, Robert. *Humanism and Education in Medieval and Renaissance Italy:Tradition and Innova tion in Latin Schools from the Twelfth to the Fifteenth Century.* New York:Cambridge Uni versity Press, 2001.
5. Gutek, Gerald. *Historical and Philosophical Foundations of Education: A Biographical Introduction.* Columbus, Ohio: Merrill/Prentice Hall, 2005.
6. Gutek, Gerald. *Historical and Philosophical Foundations of Education:Selected Readings.* Columbus, Ohio: Merrill/Prentice Hall, 2001.
7. Hanson, Victor D, and Heath, John. *Who Killed Homer? The Demise d of Classical Education and the Recovery of Greek Wisdom.* New York: Encounter Books, 2001.
8. Lascarides, V.Celia, and Hinitz, Blythe F. *History of Early Childhood Education.* New York:Falmer Press, 2000.
9. Palmer, Joy A, Cooper, David E., and Bresler, Liora, eds. *Fifty Major Thinkers on n Education:From Confucius to Dewey.* New York: Routledge, 2001.
10. Ruthven, Malise. *Islam in the World.* New York: Oxford University Press, 2000.

ប្រភពនៃការអប់រំក្នុងពិភពលោកចាប់ពីមជ្ឈិមសម័យ

ដោយ៖ លោកបណ្ឌិត **សូ សុធីរ**
មន្ត្រីស្រាវជ្រាវនាយកដ្ឋានវិទ្យាសាស្ត្រអប់រំ,វិទ្យាស្ថាន
មនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម,រាជបណ្ឌិត្យសភាកម្ពុជា

១, ទប្បធម៌ និង ការអប់រំនៅមជ្ឈិមសម័យ

ក-ឱនភាព បន្ទាប់មកការនិយមឡើងវិញក្នុងការសិក្សា

ប្រវត្តិវិទូបានកំណត់យកសហស.វត្សនៅចន្លោះឱនភាពនៃក្រុងរ៉ូម និងបុនសម័យ (៥០០-១៤០០គ.ស.) ថាជាមជ្ឈិមសម័យ (Middle Ages or midieval period)។ សកវប្បធម៌ និងការអប់រំលោកខាងលិចនេះបានលាតសន្ធឹងពីចុងបញ្ចប់នៃសកវប្បធម៌ក្លាស៊ីករ៉ូម៉ាំង-ក្រិក និងការចាប់ផ្តើមនៃអ្វីដែលយើងហៅថា នវសម័យ។ វាត្រូវបានកំណត់ជាលើកដំបូងដោយឱនភាពក្នុងការសិក្សា ហើយបន្ទាប់មកដោយការនិយមឡើងវិញនៃពួកអ្នកអប់រំដែលមានវិជ្ជាជ្រៅជ្រះ។

ខ-ស្ថាប័ននៃការសិក្សា

ក្រោយពេលដែលចក្រភពរ៉ូម៉ាំងខាងលិចត្រូវបានដួលរលំទៅ ព្រះវិហារកាតូលិក (The Chatolic Church) ដែលត្រូវបានដឹកនាំដោយសម្តេចប៉ូប (The pope) ក្នុងទីក្រុងរ៉ូមនោះ ពោរពេញទៅដោយភាពគ្មានអ្នកគ្រប់គ្រងផ្នែកអប់រំ វប្បធម៌ នយោបាយដែលទទួលបានលទ្ធផលឡើយ។ ក្នុងអំឡុងពេលមជ្ឈិមសម័យ ការអប់រំក្នុងប្រព័ន្ធនៅបឋមសិក្សាអឺរ៉ុប បានធ្លាក់ទៅលើព្រះវិហារក្នុងសាលារៀនបព្វជិត អ្នកស្រុកជើងវត្ត។ នៅកម្រិតមធ្យមសិក្សាទាំងសាលាបព្វជិតទាំងមហាព្រះវិហារផ្តល់កម្មវិធីសិក្សាទូទៅ។ ឧត្តមសិក្សាបានកើតឡើងឡើងនៅក្នុងសាកវិទ្យាល័យនៃក្រុង Paris, Bolo-gna, Salerno, Oxford, and Cambridge[9]។ ពាណិជ្ជករ និងអ្នកមានវិជ្ជាជីវៈកសិក្នុងសង្គមក៏បានបង្កើតសាលារៀនមួយចំនួនដែលផ្តល់ការអប់រំមូលដ្ឋាន ព្រមទាំងបណ្តុះបណ្តាលពាណិជ្ជកម្ម។ អស្សព្ទិ សិក្សាយុទ្ធសាស្ត្រទ័ព និងគោលការណ៍ ភាពជាអ្នកក្លាហានប្រកបដោយសីលធម៌ក្នុងប្រាសាទនានា។

[9] C. Stephen Jaeger, *The Envy of Engels: Cathedral Schools and Social Ideals in Medieval Europe, 950-1200* (Philaidelphia: University of Pennsylvania Press, 1994), p.153.

គ-ការចូលសិក្សា

នៅក្នុងសកលរាជក្រិក និងរ៉ូម៉ាំងមុននេះ មនុស្សតិចតួចបំផុតបានចូលសិក្សានៅមជ្ឈិមសម័យ ជាបឋមមនុស្សប្រុសមានផែនការចូលទៅក្នុងវិជ្ជាជីវៈសាសនាក្នុងនាមជាបព្វជិត ព្រះសង្ឃ ឬសមាជិកនៃបទបញ្ជាបព្វជិត។ មនុស្សមួយភាគធំបំផុត គឺជាសេរីកាដែលជាកម្មករកសិកម្មនៅលើទ្រព្យសម្បត្តិម្ចាស់ដីពួកសក្តិភូមិនោះ ជាទូទៅជាអនក្ខរជន។

ឃ-ការអប់រំស្ត្រីនៅមជ្ឈិមសម័យ

លក្ខខណ្ឌស្ត្រីក្នុងសង្គមមជ្ឈិមសម័យមានភាពផ្សេងៗគ្នាទៅតាមវណ្ណៈសេដ្ឋកិច្ចសង្គមរបស់គេ។ ទោះបីជាសាសនាគ្រិស្តនៅមជ្ឈិមសម័យបានសង្កត់ធ្ងន់ទៅលើសមភាពខាងស្មារតីនៃស្ត្រី និងធម្មជាតិនៃអាពាហ៍ពិពាហ៍ទៅតាមសច្ចាប្រណិធានក្តី ស្ត្រីនៅតែបន្តមានតួនាទីដែលបានបញ្ជាក់ខាងផ្លូវសមធម៌កេទតាមប្រពៃណី។ ទាសីនិងវណ្ណៈកសិករបានសិក្សាពីផ្ទះសម្បែង និងកិច្ចការចិញ្ចឹមកូនជាធម្មតាតាមការត្រាប់តាមមាតារបស់ពួកគេ។ ស្ត្រីវណ្ណៈអភិជនក៏បានធ្វើតាមផងដែរនូវបញ្ញត្តិនៃវណ្ណៈរបស់ខ្លួនគេ និងបានសិក្សាពីតួនាទីដ៏សមរម្យទៅនឹងគោលការណ៍នៃភាពក្លាហាន ប្រកបដោយសីលធម៌ (Chivalry) ជាញឹកញាប់មានបំណង ចាត់ចែងជីវិតនៅក្នុងគេហដ្ឋានដ៏ស្កុកស្តម្ភ និងនៅក្នុងប្រាសាទ[២]។ ព្រះវិហារនៅមជ្ឈិមសម័យ បានផ្តល់នូវឱកាសអប់រំសម្រាប់ស្ត្រីតាមរយៈសហគមន៍សាសនា។ អារ៉ាសដូនជី ដូចជាវត្តទាំងឡាយ មានបណ្ណាល័យនិងសាលារៀន ដើម្បីត្រៀមរៀបចំដូនជី ធ្វើតាមវិធានសាសនានៃសហគមន៍របស់ពួកគេ។

៧-១-Aquinas: **ការអប់រំប្រកបដោយតាពមានឥទ្ធិពលជ្រៅជ្រះ**

អំឡឿនិងហេតុផលមួយចួលគ្នា

នៅត្រឹមសតវត្សទី១១ អ្នកអប់រំនាមជ្ឈិមសម័យ បានអភិវឌ្ឍប្រព័ន្ធទស្សនវិជ្ជាដែលផ្អែកលើសិទ្ធាន្តសាសនវិទ្យា (Scholasticism) ដែលជាវិធីមួយនៃការអង្កេតភាពមានវិជ្ជាជ្រៅជ្រះ និងការគ្រឿនៗ។ បព្វជិត ដែលជាអ្នកបង្រៀនផ្អែកលើជំនឿ និងហេតុផលជាប្រភពនៃជំនឿបន្ថែម។ ពួកគេបានទទួលយកគម្ពីរពិសិដ្ឋ និងការនិពន្ធរបស់បិតាព្រះវិហារថា ជាប្រភពនៃពាក្យដែលបានលាតត្រដាងដោយព្រះ។ គ្រូបង្រៀនដែលជាបព្វជិតជឿជាក់ថា ចិត្តរបស់មនុស្ស អាចធ្វើគោលការណ៍អនុមានលើកទីមួយដែល (នៅពេលដែលបំភ្លឺឱ្យច្បាស់ដោយប្រភពព្រះគម្ពីរ) ជាប្រភពនៃជំនឿ។

ខ-ការផ្សះផ្សារព្រះគម្ពីរ ជាមួយ

---

[២] Judith M. Bennet, *Medieval Women in Modern Perspective* (Washington,D.C.:Americal Histori-cal Associa- tion, 2000).

ទិដ្ឋភាពក្រិក

ទស្សនវិជ្ជា ដែលមានវិជ្ជាជ្រៅជ្រះ និងការអប់រំបានឈានដល់កាពកំពូល (Zenith) នៅក្នុង The Summa Theologiae of Saint Thomas Aquinas (1225-1274) ជាសាសនវិទូ Dominican នៅសាកលវិទ្យាល័យប៉ារីស។ Aquinas ត្រូវបានយកចិត្តទុកដាក់ជាលើកដំបូងជាមួយការផ្សះផ្សារប្រកពទាំង ឡាយ ដែលជាការផ្សារភ្ជាប់ជំនឿតាមព្រះគម្ពីរ ជាមួយទស្សនវិជ្ជាក្រិករបស់អារីស្តូត។ Aquinas បានប្រើប្រាស់ទាំងជំនឿ ទាំងវិចារ ដើម្បីឆ្ងើយសំណួរជាមូលដ្ឋាន អំពីបញ្ញត្តិព្រះរបស់សាសនាគ្រិស្ត ដែលជាធម្មជាតិមនុស្ស និងចក្រវាឡ ហើយនិងទំនាក់ទំនងរវាងព្រះ និងមនុស្ស[៣]។ សម្រាប់ Aquinas មនុស្សបានដំណើរការរចនាទៅដោយផ្នែកវាងកាយ និងផ្នែកព្រលឹង។ ទោះបីជាគេរស់នៅជាបណ្តោះអាសន្នលើផែនដី គោលបំណងកំពូលរបស់គេ ដើម្បីទទួលយកបទពិសោធអនន្តភាពជាមួយព្រះ។ ដូចអារីស្តូត Aquinas អះអាងថា ចំណេះដឹងរបស់មនុស្សចាប់ផ្តើមតាមឥន្ទ្រីយារម្មណ៍ ហើយបញ្ចប់ដោយបញ្ញត្តិនីយកម្ម។

នៅក្នុងស្នាដៃ de **Magistro** (Concerning teacher) Aquinas បានបរិយាយវិជ្ជាជីវៈរបស់គ្រូថា ជាជំនឿផ្សំគ្នាគឺក្តីស្រឡាញ់ និងការសិក្សា។ គ្រូបង្រៀនជាវិជ្ជាករដែលចេះសញ្ជឹង គិតភ្ជាក់ងារសិក្សាសកម្មជំនាញការលើមុខវិជ្ជា អ្នកបង្រៀនប្រកបដោយបំណិន និងជាអ្នកស្រឡាញ់មនុស្ស។

គ-មុខវិជ្ជាដែលជាកម្មវត្ថុសិក្សា

គ្រូបង្រៀន ដែលមានវិជ្ជាជ្រៅជ្រះ ជាបព្វជិត ហើយសាលារៀនត្រូវបានគ្រប់គ្រង និងការពារដោយព្រះវិហារ។ កម្មវិធីសិក្សាត្រូវបានរៀបចំឱ្យទៅជាមុខវិជ្ជាផ្លូវការ ដោយអនុវត្តតាមប្រពៃណីសិល្បៈសេរី ដូចជា នៅឧត្តមសិក្សាមុខវិជ្ជាត្រូវមានតក្កវិទ្យា គណិតវិទ្យា ទស្សនវិជ្ជាសីលធម៌ និងធម្មជាតិ បរមត្តវិទ្យា និងសាសនវិទ្យា។ ក្នុងការបង្រៀនរបស់ខ្លួន គ្រូត្រូវប្រើអំណះអំណាងប្រកបដោយតក្កវិទ្យា គឺវិចារអនុមានញែក (Deductive reasoning) ដើម្បីបង្កើតអង្គពុទ្ធិដែលត្រូវបានរៀបចំរួចហើយ។ វាសង្កត់ធ្ងន់ទៅលើគោលការណ៍មូលដ្ឋាននិងការអនុវត្ត។ ក្នុងការបន្ថែមទៅលើការសិក្សាក្នុងប្រព័ន្ធ Aquinas បានទទួលស្គាល់សារៈសំខាន់នៃការអប់រំមិនផ្លូវការ តាមរយៈគ្រួសារ មិត្តភ័ក្ត្រ និងបរិស្ថាន[៤]។

នៅក្រោយកាលដ៏យូរនៃមជ្ឈិមសម័យ និងរហូតមកដល់ពេលបច្ចុប្បន្ន

[៣] Francis J. Selman, Saint Thomas Aquinas: Teacher of Truth (Edinburg, Scotland: T& Clark, 1994); and Etienne Gilson, The Christian Philosophy of Saint Aquinas (Notre Dame, Ind.: University of Notre Dame Press, 1994.

[៤] John W. Donohue. St. Thomas Aquinas and Education (New York: Random House, 1968), pp. 76-79.

ទស្សនវិជ្ជារបស់Aquinas ត្រូវបានគេហៅថា Thomism បានជះឥទ្ធិពលដល់ការអប់រំក្នុងវិហារកាតូលិក ដែលវាត្រូវបានប្រើជាមូលដ្ឋាននៃសាលារៀន ដែលមានជំនឿទៅលើសាលារៀន។ នៅក្នុងសហរដ្ឋអាម៉េរិក សាលារៀនកាតូលិក គឺជាប្រព័ន្ធសាលារៀនមិនមែនសាធារណៈដ៏ធំបំផុត ដែលមានសិស្សចុះឈ្មោះចូលរៀនចំនួន២,៥១១,០៤០នាក់ នៅក្នុងសាលារៀនចំនួន ៨,១០២សាលា[៥]។ Thomism ក៏បានជះឥទ្ធិពលផងដែរដល់ពួកមនុស្សនិយមដែលមិនមែនជាសាសនា ដូចជា Mortimer Adler បានអភិវឌ្ឍសំណើ Paideia(បកស្រាយនៅពេលក្រោយ)។

៧-២-ការរួមចំណែកពីមជ្ឈិមសម័យ ចំពោះការអប់រំលោកខាងលិច ចំណេះដឹងដែលបានរក្សាទុក និងការបង្កើតគ្រឹះស្ថានអប់រំ

អ្នកអប់រំមជ្ឈិមសម័យបានរួមចំណែកដល់ការអប់រំមជ្ឈិមសម័យជាបឋម គឺតាមការរក្សាទុក និងការបង្កើតគ្រឹះស្ថានអប់រំ គឺថាតាមការបង្ហាញវាជាមួយក្របខណ្ឌ ដែលបានរៀបចំត្រឹមត្រូវ។ សាលារៀនព្រះវិហារវត្ត និងជើងវត្តទាំងអស់បានផ្ទេរចំណេះដឹងតាមរបៀបនេះ។ តួយ៉ាងនៃនិន្នាការនេះ គឺជាសាកលវិទ្យាល័យមជ្ឈិមសម័យដែលជាមូលដ្ឋានគ្រឹះសម្រាប់សាកលវិទ្យាល័យទំនើប។ ជាមួយកំពែងទាំងនេះ អ្នកអប់រំមជ្ឈិមសម័យមិនគ្រាន់តែបានបង្រៀនទេ ប៉ុន្តែថែមទាំងបានរក្សាទុកចំណេះដឹង តាមការកត់ត្រា និងប្រមូលចងក្រងជាក្រមទៀតផងដែរ។

៨. មនុស្សនិយមនៅបុនសម័យ

ក-ការនិយមឡើងវិញនូវទិដ្ឋភាពនៃភ្លាស៊ីក

បុនសម័យ ដែលបានចាប់ផ្តើមក្នុងសតវត្សទី១៤ ហើយឈានដល់ចំណុចកំពូលក្នុងសតវត្សទី១៥ ដោយកត់សម្គាល់ទៅលើការនិយមឡើងវិញនូវទិដ្ឋភាពមនុស្សនិយមនៃអក្សរសាស្ត្រ ឡាតាំង និងក្រិក។ វាត្រូវបានគេចាត់ទុកជារយៈពេលអន្តរកាលរវាងមជ្ឈិមសម័យ និងនវសម័យ។ អ្នកប្រាជ្ញបុនសម័យនៃមនុស្សនិយមភ្លាស៊ីក ដូចជាការអប់រំនិងសាលារៀនមជ្ឈិមសម័យ បានបង្កើតប្រភពជំនាញរបស់គេក្នុងអតីតកាលនិងសង្កត់ធ្ងន់លើអក្សរសិល្ប៍ភ្លាស៊ីក។ ទោះជាយ៉ាងនេះក្តីមិនដូចទស្សនវិជ្ជាមជ្ឈិមសម័យទេ ពួកមនុស្សនិយមភ្លាស៊ីកយកចិត្តទុកដាក់តែទៅលើអក្សរសិល្ប៍ជាងសាសនវិទ្យា[៦]។

ខ-មនុស្សនិយមបែបភ្លាស៊ីកក្នុងប្រទេសអ៊ីតាលី

[៥] Private School Universe Survey, 1999-2000, http: nces.ed.gov/pubsearch (01/12/2003).

[៦] J. R. Hale, Renaissance Europe (New York: Basli Blackwell, 2000).

បុនសម័យ ត្រូវបានគេកត់សម្គាល់ជាពិសេសក្នុងប្រទេសអ៊ីតាលីជាកន្លែងដែលការរស់ឡើងវិញខាងពាណិជ្ជកម្ម ផ្តល់មូលនិធិដ៏ច្រើនពីសិល្បៈ និងអក្សរសាស្ត្រ។ មនុស្សនិយមក្លាស៊ីកអ៊ីតាលីដោយចាត់ទុកខ្លួនឯងជាវេជនអក្សរសាស្ត្រ នោះគឺត្រូវបានស្វ័យប្រកាសថា ឆ្មាំចំណេះដឹង (Custodians of knowledge)។ នៅអ៊ីតាលី ស្នាដៃ Dante, Petrarch, and Boccaccio បានធ្វើបញ្ជាំងការនិយមឡើងវិញ ផ្នែកអក្សរសាស្ត្រមនុស្សនិយម។ ពួកអភិជនអ៊ីតាលី បានបង្កើតសាលារៀនមនុស្សនិយមដើម្បីរៀបចំកុមារក្នុងការសិក្សាបែបក្លាស៊ីកដែលត្រូវនិយមឡើងវិញ។

គ-ពួកបរិវារស្តេចជាគំរូមួយ

ដោយជំទាស់ទៅនឹងប្រព័ន្ធទស្សនវិជ្ជាសិទ្ធាន្តសាសនា អ្នកអប់រំមនុស្សនិយមក្លាស៊ីក បានត្រឡប់សាជាថ្មីទៅរកអ៊ីសូក្រាត (Isocrates and Quintilian)។ ក្នុងអក្សរសិល្ប៍ក្រិក និងឡាតាំង គេបានរកឃើញគំរូនៃឧត្តមភាពអក្សរសាស្ត្រ និងរចនាបថ ឧត្តមគតិនៃមនុស្សដែលមានការអប់រំនិងទស្សនៈ គតិបណ្ឌិតបុពណាកាល ដែលគួរស្រឡាញ់ជាទីបំផុត។ សម្រាប់អ្នកអប់រំមនុស្សនិយម ពួកបរិវារស្តេចបានក្លាយជាមនុស្សគំរូមានការអប់រំ។ មនុស្សម្នាក់មាបែបបទ និងភាពថ្លៃថ្នូរ ត្រូវអប់រំដោយសេរីក្នុងអក្សរសាស្ត្រក្លាស៊ីក។ ពួកបរិវារស្តេច ជាអ្នកការទូតដ៏ប៉ិនប្រសប់ ដែលអាចធ្វើជាអ្នកគ្រប់គ្រងដ៏ល្អក្នុងកិច្ចការរបស់រដ្ឋ។ Baldesar Casti- gliore (1478-1529) បានពិពណ៌នាពួកបរិវារស្តេច និងការអប់រំ ដែលមានសារៈសំខាន់ដល់អក្សរសាស្ត្រក្រិក និងឡាតាំង ព្រមទាំងសេចក្តីគួរសម តាមរបៀបបរិវារស្តេចក្នុងសៀវភៅរបស់គាត់ The Book of the Courtier[៧]។

ឃ-ការគិតដ៏ល្អិតល្អន់

អ្នកអប់រំមនុស្សនិយមបុនសម័យជាមនុស្ស ដែលមានការចេះដឹងខាងអក្សរសាស្ត្រ ដូចជាអ្នកនិពន្ធ កវី អ្នកបកប្រែ និងអ្នកវិះគន់។ គ្រូបង្រៀនដែលជាសិល្បករអ្នកវិះគន់សង្គម និងការនិយម ពួកគេនាំមកនូវការប៉ិនប្រសប់កំប្លែងសម្រស់ និងការនិពន្ធដៀលត្មះ ព្រមទាំង**ពហុសុតភាព** ចំពោះការងាររបស់ពួកគេ។ ដោយប្រមើលមើលការបញ្ជាក់អះអាង នាពេលសព្វថ្ងៃនេះ ទៅលើការគិតល្អិតល្អន់នោះ ពួកគេស្វែងរកអប់រំមនុស្សដែលមានចិត្តគិតបានល្អិតល្អន់ អាចប្រឆាំងនឹងទំនៀមទម្លាប់ ដែលមានរួចហើយបង្ហាញ និងកែភាពសមរម្យក្នុងអក្សរសាស្ត្រ និងជីវិត។ នៅក្នុងអឺរ៉ុបប៉ែកខាងជើង ពួកអ្នកប្រាជ្ញមនុស្សនិយម បានពិនិត្យ

[៧] Baldesar Castigliore, *The Book of the Courtier*, trans. C. S. Singleton (New York: Doubleday, 1959). A Commentary is Peter Burke, *The Fortunes of Courtiers: The European Reception of Castigliore's Cortigiano* (University Park: Pennsylvania State University Press, 1996).

យ៉ាងល្អិត ល្អន់នូវស្នាដៃសាសនវិទ្យាមជ្ឈិមសម័យ។

ប៉ុន្តែ ពួកមនុស្សនិយមបុនសម័យជាញឹកញាប់បានចៀសវាងរវាងខ្លួនឯង និងចំនួនមនុស្សដ៏ច្រើន ដោយដកយកបញ្ញត្តិដ៏សំខាន់នៃធម្មជាតិមនុស្ស ពីអក្សរសាស្ត្រដែលមានវ័យចំណាស់ដោយប្រុងប្រយ័ត្ន។ នៅពេលដែលស្រាទំពាំងបាយជូរដែលបានផលិតដ៏ល្អ ត្រូវបានគេប្រើប្រាស់ដើម្បីលំអអាហារល្ងាចដ៏ថ្លៃថ្នូរនោះ ការអប់រំមនុស្សនិយម គឺជាមនុស្សដែលស្គាល់ពីស្ថានភាពពិតប្រាកដ។ វាមិនត្រូវបានគេផ្តល់ឱ្យជនគ្រប់គ្នានោះទេ តែរក្សាទុកសម្រាប់វរជន។

ខ-ការចូលរៀនដែលមានកំណត់

បុនសម័យ មិនបានពង្រីកការយកចិត្តទុកដាក់ ដល់សាលារៀនខ្ពាំងពេកទេ។ ពួកមនុស្សនិយម ដែលបានត្រៀមរៀបចំទុក(បឋមសិក្សា) និងសាលាមធ្យមសិក្សាបានអប់រំកុមារ អភិជន និងវណ្ណៈខ្ពស់។ សាលាបឋមសិក្សា បានបម្រើវណ្ណៈពាណិជ្ជកម្មកណ្តាល។ កុមារដែលមានវណ្ណៈសេដ្ឋកិច្ចសង្គមទាបបានទទួលការអប់រំក្នុងប្រព័ន្ធតិចតួច។

៨-១ -Erasmus: **អ្នកនិពន្ធ និង មនុស្សនិយមវិទូ**

ក- Erasmus **អំពីការអប់រំ**

Desiderius Erasmus (28 October 1466-12 July 1536, Dutch) ជាមនុស្សនិយមវិទូក្វាស៊ីកនាំមុខគេនៅបុនសម័យ ត្រូវបានពណ៌នាថាជាគ្រូគំរូក្នុងនាមជាមនុស្សនិយមសកល[៨]។ ឥរិយាបថរបស់គ្រូមនុស្សនិយមវិទូសកលគួរតែផ្តល់នូវបឋមវិជានក្នុងសិល្បៈសេរី ជាពិសេសនៅក្នុងមុខវិជ្ជា ដូចជាអក្សរសាស្ត្រ ភាសា ប្រវត្តិវិទ្យា និងសាសនា ដែលមានប្រយោជន៍ នៅក្នុងការបកប្រែស្នាដៃក្វាស៊ីក។ ដូចជាQuintilianដែរ Erasmus មានទស្សនៈទូលំទូលាយពីការអប់រំ ការផ្តល់ដំបូន្មានដល់មាតាបិតា ដែលការអប់រំនៅសម័យដើម មានភាពចាំបាច់ក្នុងការបង្កើតឥរិយាបថ និងអាកប្បកិរិយាកុមារសម្រាប់ការអប់រំសម័យក្រោយ។ កុមារ ត្រូវបានគេផ្តល់សិទ្ធិឱ្យមាតាបិតា និងគ្រូ ដែលជាគំរូនៃសេចក្តីគួរសម (Civility) និងវប្បធម៌។

ខ-ការលើកកម្ពស់ដល់សៀវភៅ និងអក្សរសិល្ប៍

ក្នុងនាមជាមនុស្សនិយម Erasmus មានការព្រួយបារម្ភបំផុតជាមួយការបង្រៀនអក្សរសិល្ប៍។ គាត់បានផ្តល់យោបល់ថា ការជំរុញសិស្សឱ្យអានសៀវភៅល្អៗ តាមការឱ្យពួកគេ ស្រាវជ្រាវអត្ថន័យរបស់អ្នកនិពន្ធនៅក្នុងជីវិតផ្ទាល់ខ្លួនរបស់ពួកគេ។ គាត់បានលើកទឹកចិត្តគ្រូបង្រៀនឱ្យប្រើប្រាស់ការសន្ទនា ល្បែង និងសកម្មភាពទាំងឡាយដើម្បីពន្យល់អត្ថន័យនៃសៀវ

[៨] For Biographies of Erasmus, see Leon E. Halkin, *Erasmus: A Critical Biography* (Oxford, U.K., and Cambri- dge, Mass.: Basil Blackwell, 1993); and James McConics, *Erasmus* (New York: Oxford University Press, 1991).

កៅ។ Erasmus បានអភិវឌ្ឍវិធីដូចតទៅដើម្បីបង្រៀនអក្សរសិល្ប៍៖

1-បង្ហាញជីវប្រវត្តិរបស់អ្នកនិពន្ធ។

2-កំណត់អត្តសញ្ញាណប្រភេទនៃសៀវភៅ។

3-ពិភាក្សាដំណើរសាច់រឿង។

4-ធ្វើបញ្ហាំងទៅលើការអនុវត្តផ្នែកទស្សនវិជ្ជា និងសីលធម៌របស់សៀវភៅ។

5-វិភាគរចនាបថនិពន្ធរបស់អ្នកនិពន្ធ[៩]។

គ-ការប្រឆាំងជំទាស់ ចំពោះអំពើហិង្សា

ការជំទាស់របស់ Erasmus ចំពោះសង្គ្រាម និងហិង្សា ត្រូវបានគេបង្ហាញឱ្យឃើញក្នុងសៀវភៅរបស់គាត់មានឈ្មោះថា ការអប់រំព្រះអង្គម្ចាស់ដែលជាគ្រិស្តសាសនិក(១៥១៦) (The Education of the Christian Prince)[90]។ គាត់បានផ្តល់ដំបូន្មានដល់អ្នកទាំងឡាយ នឹងធ្វើជាគ្រូបង្រៀនទោលដល់ព្រះអង្គម្ចាស់ដើម្បីឱ្យជឿជាក់ថាព្រះអង្គ បានសិក្សាបានច្រើនដូចដែលគាត់អាច អំពីប្រជាជននៃព្រះរាជាណាចក្ររបស់ព្រះអង្គ ដូចជាប្រពៃណីទំនៀមទម្លាប់ស្នាដៃ និងបញ្ហាទាំងឡាយ។ មិនដូច្នោះ Machiavelli ដែលបានអះអាងថា ព្រះរាជាគួរតែគ្រប់គ្រងដោយសេចក្តីកោតក្រែង និងភាពបិនប្រសព្វឬសម្របសម្រួលនោះ Erasmus បានផ្តល់ដំបូន្មានដល់ព្រះអង្គម្ចាស់ឱ្យទទួលបានសេចក្តីស្រឡាញ់ពីមុខវិជ្ជារបស់ខ្លួនហើយនិងសិក្សាសិល្ប:នៃសន្តិភាពជាពិសេសការទូតនិងជៀសវាងសង្គ្រាម។

៨-២-យុគសម័យដល់ការអប់រំលោកខាងលិច

ក-ការបញ្ចាក់ឆ័ន្ទៈលើអក្សរសិល្ប៍និងភាសាឡាតាំង

ពួកមនុស្សនិយមវិទូបុនសម័យបានសង្កត់ធ្ងន់ទៅលើចំណេះដឹងភាសាក្រិក និងឡាតាំង ថាជាសញ្ញាសម្គាល់ពិតនៃមនុស្ស ដែលមានការអប់រំ។ អស់រយៈពេលជាច្រើនសតវត្សចំណូលចិត្តមនុស្សនិយមវិទូក្វាសីក បានបង្កើតការអប់រំមធ្យមសិក្សានិងឧត្តមសិក្សាលោកខាងលិច។ នៅទ្វីបអឺរ៉ុប និងសហរដ្ឋអាម៉េរិក សាលាវិជ្ជាជីវៈ មហាវិទ្យាល័យ និងសាកលវិទ្យាល័យជាច្រើនតម្រូវឱ្យមានចំណេះដឹងខាងភាសាឡាតាំង សម្រាប់ការចូលរៀនរហូតដល់ចុងសតវត្សទី១៩។

ខ-ចំណេះដឹងខាងមនុស្សនិយម (មិនមែនខាងវិទ្យាសាស្ត្រ)

វាជារឿងសំខាន់ផងដែរ ដើម្បីកត់សម្គាល់ថា Erasmusនិងអ្នកអប់រំបុនសម័យផ្សេងទៀតកំពុងជំរុញដល់បញ្ញត្តិនៃចំណេះដឹងខាងមនុស្សនិយម ឬ មជ្ឈមណ្ឌលមនុស្ស។ ជាជាងការឈានទៅដល់

[9] William H. Woodward, *Desiderius Erasmus: Concerning the Aim and Method of Education* (New York: Teachers College Press, 1994).

[90] Robert D. Sider and John B.Payne, eds. *Collected Works of Erasmus* (Toronto: University of Toronto Press, 1990).

ប្រជានបទមនុស្សនិយមរបស់គេ តាមរយៈការអង្កេតបែបវិទ្យាសាស្ត្រនោះ អ្នកអប់រំមនុស្សនិយម បានស្រាវជ្រាវការយកចិត្តទុកដាក់របស់គេ តាមអក្សរសិល្ប៍។ ក្រោយមកគោលវិធីនេះអាចទប់ទល់បាននឹងកំណែទម្រង់របស់ Rousseau, Comenius, Pestalozzi, and Dewey ដែលអ្នកទាំងអស់គ្នាបានពោលអាងប្រឆាំង នឹងការបង្រៀន ដែលបានសង្កត់ធ្ងន់ទៅលើអក្សរសិល្ប៍នៅពេលដែលមិនបានយកចិត្តទុកដាក់ទៅលើបទពិសោធ។

គ-រោងពុម្ព

ការច្នៃប្រឌិតរោងពុម្ពក្នុងឆ្នាំ ១៤២៣ ក្នុងទ្វីបអឺរ៉ុប បានធ្វើឱ្យជឿនលឿនដល់អក្ខរកម្ម និងការសិក្សាអប់រំគួរឱ្យចាប់ចិត្ត។ មុនពេលមានរោងពុម្ព សិស្សបានចម្លងដោយផ្ទៃតផ្ទង់នូវការសរសេរតាមអានពីគ្រូ។ ការបង្រៀននៅសាកលវិទ្យាល័យ គឺជាបទពិសោធពិសេស ចាំបាច់ដែលក្នុងនោះសិស្សឬនិស្សិត កត់ត្រាពាក្យសម្តីរបស់សាស្ត្រាចារ្យរបស់ពួកគេ។

ត្រឹមពាក់កណ្តាលសតវត្សទី ១៥ ពួកអឺរ៉ុបបានឆ្ងាត់នូវបទពិសោធជាមួយនឹងប្រភេទលោហធាតុដែលអាចធ្វើចលនាបាន។ Johannes Gutenberg ជាងទងជាតិអាល្លឺម៉ង់ម្នាក់ បានប្រឌិតសំលោហធាតុដ៏រឹងមាំ ដើម្បីបង្កើតអក្សរសម្រាប់រោងពុម្ព។ គម្ពីររបស់គាត់ក្នុងឆ្នាំ ១៤៥៥ គឺជាសៀវភៅលើកដំបូង ដែលបានបោះពុម្ពបែបនោះ។ ការបោះពុម្ព បានរាលដាលពាសពេញទ្វីបអឺរ៉ុប ដោយផលិតផលកើនទ្វេដងច្រើនជាងមុន ហើយនិងកាត់បន្ថយចំណាយ ទៅលើសៀវភៅ។ វាបង្កើតព័ត៌មានដែលអាចឈានទៅដល់ការអានដែលមានភាពទូលំទូលាយជាងមុន[11]។ វាជានវកម្មបច្ចេកទេសដ៏សំខាន់ ដែលផលរបស់វា នាំមកដល់ការសាយភាយព័ត៌មានកុំព្យូទ័រ។

៩. ការកែទម្រង់ខាងសាសនា និងការអប់រំ

ក-សេរីភាពពីប្រភពអំណាចសម្តេចសង្ឃប៉ាប(ប៉ាបជាតិសាសនាំង)

ការកែទម្រង់ខាងសាសនា នៅ សតវត្សទី ១៦ និងទី ១៧ ត្រូវបានធ្វើឱ្យមានការរំជើបរំជួល ដោយការរិះគន់ពួកមនុស្សនិយមនៅអឺរ៉ុបខាងជើងនៃស្ថាប័ន និងអំណាចនៅមជ្ឈិមសម័យ។ នៅពេលដែលពួកមនុស្សនិយម បានជំនួសប្រព័ន្ធទស្សនវិជ្ជាសិទ្ធាន្តសាសនវិទ្យានោះ អំណាចកណ្តាលរបស់ព្រះវិហារកាតូលិក ដើម្បីដាក់ឱ្យប្រតិបត្តិភាពដូចគ្នាខាងសាសនា បានកាត់បន្ថយបន្តិចម្តងៗ។ រឿងនេះ បានត្រួសត្រាយផ្លូវឱ្យមតិខាងសាសនាផ្សេងៗគ្នា ដែលនាំឱ្យមានជម្លោះខ្លាំងក្លាអំពីការអប់រំ។

---

[11] Lucien Febvre and Henri-Jean Martin, *The Coming of the Book: The Impact of Printing, 1450-1800* (London: Verso, 1990).

ការកើនឡើងនៃវណ្ណៈពាណិជ្ជកម្ម កណ្តាល និងរដ្ឋដែលជាជាតិដ៏ខ្លាំងនោះ រួមចំណែក ដល់ចលនាកំណែទម្រង់។ ទោះជាយ៉ាងណាក៏ដោយ អ្នកកែទម្រង់សាសនាប្រូតែស្តង់ជាលើកដំបូង ដែលរួមបញ្ចូលទាំង John Calvin, Martin Luther, Phillipe Melanchthon, and Ulrich Zwingli បានស្វែងរកវិធីដោះខ្លួនគេ ហើយនិងសាវ័កបស់គេ ពីអំណាចសម្តេចប៉ូប និងបកស្រាយលទ្ធិ និងការប្រតិបត្តិខាងសាសនាផ្ទាល់ខ្លួនរបស់គេ[12]។ នៅពេលដែលកំពុងធ្វើដូច្នេះ អ្នកកែទម្រង់ប្រូតែស្តង់ បានបង្កើតទ្រឹស្តីអប់រំផ្ទាល់ខ្លួនរបស់គេបង្កើតសាលារៀនផ្ទាល់ខ្លួន រៀបចំរចនាសម្ព័ន្ធកម្មវិធីសិក្សាចិញ្ចឹមកូនរបស់ពួកគេតាមគោលជំនឿដែលបានកែទម្រង់។

ខ-ការពង្រីកវិសាលភាពនៃអក្ខរកម្មដ៏មានប្រជាប្រិយ

Luther, Melanchthon, Calvin និងមេដឹកនាំកែទម្រង់ផ្សេងទៀត បានយកចិត្តទុកដាក់ ដោយខ្លួនគេ ជាមួយបញ្ហានៃចំណេះដឹងការអប់រំនិងការសិក្សាពីព្រោះពួកគេចង់ឱ្យអារ្ធជ័ មានឥទ្ធិពលទាំងនេះ ដើម្បីធ្វើឱ្យជឿនលឿនដល់បុព្វហេតុប្រូតែស្តង់។ ស្តីពីបញ្ហានៃចំណេះដឹងអំណាចកំពូលរបស់ពួកគេគឺព្រះគម្ពីរ(The Bible)។ ដោយចាត់ទុកការអានព្រះគម្ពីរថា ជារឿងចាំបាច់ដើម្បីការជួសង្គ្រោះនោះ អ្នកកែទម្រង់ប្រូតែស្តង់ បានជំរុញដល់សកលកម្មបឋមសិក្សាដើម្បីធ្វើឱ្យមានភាពជឿនលឿនដល់អក្ខរកម្ម។

ពួកប្រូតែស្តង់បានបង្កើតសាលារៀនភាសាតាមតំបន់ដើម្បីបង្រៀនកុមារក្នុងភាសាធម្មតារបស់គេ ដូចជា អាល្លឺម៉ង់ ស្វីស ស៊ុយអែត ឬអង់គ្លេស ជាជាងភាសាឡាតាំង។ សាលាបឋមសិក្សាទាំងនេះ ផ្តល់នូវកម្មវិធីសិក្សាជាមូលដ្ឋាននៃការអាន សរសេរ និងនព្វន្តសាស្ត្រ ព្រមទាំងសាសនា។ ប្រជាករខាងកាតូលិក និងការធ្វើសក្ការៈក្នុងព្រះវិហារនៅតែជាភាសាឡាតាំងជាជាងភាសាក្នុងតំបន់ ទោះបីជាត្រូវប្រកួតប្រជែងជាមួយប្រូតែស្តង់ក៏ដោយ។ សាលារៀនកាតូលិកក៏បានចាប់ផ្តើមរៀនភាសាក្នុងតំបន់ផងដែរ ស្របជាមួយភាសាឡាតាំង។

គ-សន្ទនានិយមនាមរបបសាសនា

ទាំងសាសនាប្រូតែស្តង់ និងកាតូលិក បានប្រើប្រាស់សាលារៀន ដើម្បីអប់រំកុមារ ជាមួយនឹងជំនឿ និងការប្រតិបត្តិសាសនាដ៏ត្រឹមត្រូវ។ មានតែសមាជិកនៃព្រះវិហារដែលបានអនុម័តិជាផ្លូវការទេ ដែលត្រូវបានគេជួលឱ្យធ្វើជាគ្រូ ហើយគ្រូត្រូវបានគេត្រួតពិនិត្យដោយយកចិត្តទុកដាក់ដើម្បីធ្វើឱ្យប្រាកដថា ពួកគេបានបង្រៀនតាមលទ្ធិដែលបានយល់ស្របរួច

[12] W. Robert Godfrey, Reformation Sketches: Insights into Luther, Calvin, and the Confessions (Phillipsburg, N.J: P&R Publishers, 2003).

ហើយ។ ដើម្បីជានាដល់សមភាពខាងលទ្ធិ អ្នកអប់រំខាងសាសនាបានអភិវឌ្ឍវិធីបង្រៀនតាមគោលការណ៍សួរ និងឆ្លើយ។ នៅក្នុងទម្រង់សំណួរ និងចម្លើយ វាត្រូវបានសង្ខេបនូវលទ្ធិ និងការប្រតិបត្តិរបស់និកាយពិសេស។ ទោះបីជាការទន្ទេញតែងតែជារូបភាពមួយនៃការបង្រៀនក៏ដោយ វិធីចោទឆ្លើយ បានសង្កត់ធ្ងន់ទៅលើរឿងនេះ។ វត្ថុបំណង គឺត្រូវឱ្យកុមារ ទន្ទេញ តាមវិធីចោទឆ្លើយ និងដោយហេតុដូច្នេះហើយ ធ្វើឱ្យមានភាពជឿនលឿនខាងផ្នែកក្នុងនូវលទ្ធិនៃព្រះវិហារ របស់ពួកគេ។ ទម្រង់ចោទឆ្លើយទទួលបានឥទ្ធិពលយ៉ាងខ្លាំងទៅលើសាលារៀន ដែលវាត្រូវបានប្រើតាមមុខវិជ្ជាដែលមិនទាក់ទងដល់សាសនា ដូចជា ប្រវត្តិវិទ្យា និងភូមិវិទ្យា។

ឧ. វិធីចោទឆ្លើយ តាមបែបសាសនារបស់ខាល់វីននៅព្រះវិហារហ្សឺណែវ (Geneva) បានប្រើវិធីចោទ និងឆ្លើយ៖

គ្រូ: អ្វីជាគោលបំណងសំខាន់នៃជីវិតមនុស្ស?

សិស្ស: ដើម្បីស្គាល់ព្រះ ដែលបានបង្កើតមនុស្ស។

នៅសតវត្សទី១៩ វិធីតែមួយបានបង្ហាញខ្លួនក្នុងប្រវត្តិរបស់ Davenport នៃសហរដ្ឋអាម៉េរិក៖

សំណួរ: សង្គ្រាមនៅ Lexington បានកើតឡើងនៅពេលណា?

ចម្លើយ: នៅថ្ងៃទី១៩ មេសា ១៧៧៥ ការបង្ហូរឈាមបានកើតឡើងនៅទីនោះ ជាលើកដំបូងក្នុងបដិវត្តន៍ជនជាតិអាម៉េរិក[១៣]។

ឃ-អក្ខរកម្មកំពុងតែមានការកើនឡើង

ដោយមានការសង្កត់ធ្ងន់ទៅលើអក្ខរកម្មដ៏មានប្រជាប្រិយ និងការកើនឡើងនូវការចូលរៀននៅតាមសាលារៀននោះ ការកែទម្រង់ប្រូតេស្តង់ បានចាប់ផ្តើមមានការផ្លាស់ប្តូរយ៉ាងសំខាន់ក្នុងការអប់រំ និងក្នុងអត្រាអក្ខរកម្ម។

ឧទាហរណ៍ មានតែមនុស្សប្រុស ១០% និងស្ត្រី២%ប៉ុណ្ណោះក្នុងប្រទេសអង់គ្លេស ជាអក្ខរជននៅឆ្នាំ១៥០០។ ត្រឹមឆ្នាំ ១៦០០ បរិមាណនេះបានកើនឡើងដល់ ២៨% ចំពោះបុរសនិង៩%សម្រាប់ស្ត្រី ហើយត្រឹមឆ្នាំ១៧០០ មានបុរសជិត៦០% និងស្ត្រីប្រហែល៣២% ជាអក្ខរជន។

អត្រាអក្ខរជនមានកម្រិតខ្ពស់នៅអឺរ៉ុបខាងជើងជាងអឺរ៉ុបខាងត្បូង នៅតំបន់ទីក្រុង ធ្ងុយគ្នាទៅនឹងតំបន់ជនបទ ហើយ

---

[១៣] John Calvin, *Tracts nad Treatises on the Doctrine and Worship of the Church, II*, Translated by Henry Beveride (Grand Rapidd, MI: Wm. B. Erdmans Publishing Co., 1958) p. 37; and Bishop Davenport, *Histiry of the United States* (Philadelphia: William Marchall and Co. 1883), p. 31.

អត្រានេះទៀតសោតមានកម្រិតខ្ពស់ចំពោះពួកវណ្ណៈខ្ពស់ជាងវណ្ណៈទាប[១៤]។

ខ-កំណើនការចូលរៀន

តាមតួលេខខាងលើនេះ អ្នកកែទម្រង់ ចង់ឱ្យទាំងក្មេងប្រុស ទាំងក្មេងស្រីបានសិក្សា នៅសាលាបឋមសិក្សាភាសាថ្នាក់តំបន់ ហើយការខិតខំប្រឹងប្រែងរបស់គេ បានបង្កើនការចូល រៀននៅសាលាសម្រាប់កេទទាំងពីរ។ ទោះជាយ៉ាងនេះក្តី អ្នកកែទម្រង់ប្រូតែស្តង់បានបន្ត បម្រើ ពួកមនុស្សនិយមក្លាស៊ីកនូវសាលាបឋមសិក្សាបង់ថ្លៃ និងសាលាមធ្យមសិក្សា សម្រាប់ក្មេងប្រុសវណ្ណៈខ្ពស់។ សាលាបឋមសិក្សា និងមធ្យមសិក្សាដូចជា ភាសាអាល្លឺម៉ង់ Gymnasium ដែលជាសាលាបឋមសិក្សាឡាតាំងអង់គ្លេស ហើយភាសាបារាំង **Lycée** បានត្រៀមរៀបចំក្មេងប្រុសត្រកូលខ្ពស់ ជាភាសាឡាតាំង និងក្រិក ដែលជាភាសាក្លាស៊ីក ដែលចាំបាច់សម្រាប់ចូលរៀននៅសាកលវិទ្យាល័យ។ វរជននេះត្រូវបានកំណត់ជោគវាសនាសម្រាប់តួនាទីជាអ្នកដឹកនាំក្នុងព្រះវិហារឬរដ្ឋ។

មនុស្សដែលមានភាពល្បីល្បាញជាច្រើនដូចជា Calvin, Zwingli, Ignatius Loyola, and Henry VIII សុទ្ធតែស្ថិតក្នុងចំណោមពួកគេទាំងនេះ បានបង្កើតឥទ្ធិពល ទៅលើការកែទម្រង់និង ការកែទម្រង់តបទៅពួកវ៉ូម៉ាំងកាតូលិក។ Martin Luther ដែលជាជនជាតិអាល្លឺម៉ង់ គឺជាអ្នកកែទម្រង់ដែលនាំមុខគេ។

ឆ-១-Luther: អ្នកកែទម្រង់សាសនាដោយប្រូតែស្តង់

ក- Luther ប្រឆាំងព្រះវិហារកាតូលិក

Martin Luther (1483-1546) លេចឡោក្នុងនាមជាអ្នកកែទម្រង់សាសនាដ៏សំខាន់បំផុតម្នាក់ ដោយបានបង្កើតប្រវត្តិសាស្ត្រនិងការអប់រំលោកខាងលិច[១៥]។ ក្នុងនាមជាព្រះសង្ឃ Augustinian មួយអង្គក្នុងប្រទេសអាល្លឺម៉ង់ Luther បានបង្កើនការរិះគន់ទៅលើការប្រតិបត្តិពួកកាតូលិក។ ក្នុងឆ្នាំ១៥១៧ នៅ Wittenberg គាត់បានដាក់ស្នើសំណើ៩៥ដ៏ល្បីល្បាញ នៅច្រកទ្វារនៃព្រះវិហារដែលជាប្រាសាទ ដោយបានប្រឆាំងនឹងព្រះវិហារវ៉ូម៉ាំងកាតូលិកនិងសង្ឃរាជវិហារកាតូលិក។ ការប្រឆាំងរបស់ Luther គឺជាកត្តាលើកសម្រាប់ការកែទម្រង់ប្រូតែស្តង់ដែលរាលដាលដល់អឺរ៉ុបភាគខាងលិច។

ខ-ការអប់រំជាផ្នែកមួយនៃការកែទម្រង់សាសនា

Luther បានទទួលស្គាល់ការអប់រំ ថាជាសម្ព័ន្ធមិត្ត ដ៏មានសក្តានុពលនៃការកែ

[១៤] Mary Jo Maynes, *Schooling in Western Europe: A Social History* (Albany: State University of New York Press 1985).

[១៥] Biographies of Luther are James A. Nestigen, *Martin Luther: A Life* (Minneapolis, Minn: Augsburg, 2003); Fredrick Nohl, *Luther: Biography of a Reformer* (St. Louis, Mo.: Concordia Publishing House, 2003); James M. Kittelson, *Luther: The Reformer* (Philadelphia: Penn.: Fortress, 2003).

ទម្រង់សាសនា។ គាត់យល់ថា ព្រះវិហារ រដ្ឋ គ្រួសារ និងសាលារៀន ជាភ្នាក់ងារកែទម្រង់ដ៏ចាំបាច់។ ដោយជឿជាក់ថា គ្រួសារមានតួនាទីដ៏សំខាន់ ក្នុងការបង្កើតអត្តចរិត និងអាកប្បកិរិយាកុមារ Luther បានលើកទឹកចិត្តអាន និងការសូត្រធម៌តាមគម្ពីរនៅក្នុងគ្រួសារ។ គាត់ក៏ចង់ឱ្យឪពុកម្តាយមានការជឿជាកផងដែរថា កុមារបានបណ្តុះបណ្តាលវិជ្ជាជីវៈដើម្បីអាចឱ្យគេអាចទ្រទ្រង់ខ្លួនគេ នៅពេលក្លាយជាមនុស្សចាស់ ហើយក្លាយជាពលរដ្ឋមានប្រយោជន៍។

គ-Luther ស្តីពីសាលារៀន

សំបុត្រLuther ចំពោះចៅហ្វាយក្រុង និងសមាជិកក្រុមប្រឹក្សាក្រុង (Aldermen) នៃទីក្រុងទាំងអស់ តាងនាមឱ្យសាលាគ្រិស្តទាំងឡាយ បានផ្តល់ដំបូន្មានឱ្យមន្ត្រីសាធារណៈដើម្បី ទទួលខុសត្រូវលើការអប់រំ និងសង្កត់ធ្ងន់ទៅលើប្រយោជន៍នៃនយោបាយសេដ្ឋកិច្ច និងស្មារតីនៃការសិក្សាអប់រំ។ Luther បានស្នើដោយទទូចថា សាលារៀនគួរតែត្រូវបានរៀបចំ និងត្រួតពិនិត្យ ដោយមន្ត្រីរដ្ឋ ដើម្បីបណ្តុះបណ្តាលអក្ខរជន ឬរៀមច្បង និងពលរដ្ឋដែលជាផលិតករ និងសមាជិកនៃព្រះវិហារ។ ការអប់រំជាន់ខ្ពស់នៅសាលា Gymnasium និងសាកលវិទ្យាល័យ នឹងត្រៀមរៀបចំរដ្ឋមន្ត្រីដែលមានការអប់រំល្អ សម្រាប់ព្រះវិហារ Lutheran។

ឃ- Luther ស្តីពីការអប់រំស្ត្រី

ទស្សនៈរបស់ Lutherស្តីពីការអប់រំស្ត្រី ធ្ងុបញ្ចាំងភាពតឹងរឹងទៅតាមប្រពៃណីតែក៏មាន គំនិតសេរីផងដែរ។ ដោយបានទទួលឥទ្ធិពលពី Saint Paul គាត់ជឿជាក់ថា ស្វាមី ដែលជាមេគ្រួសារមានអំណាចទៅលើករិយា។ តួនាទីក្នុងផ្ទះ និងការចិញ្ចឹមកូននៅតែជាតួនាទីដ៏សមរម្យរបស់ស្ត្រី។ ម្យ៉ាងវិញទៀត ការបញ្ជាក់អះអាងរបស់ Luther ទៅលើការអានព្រះគម្ពីរតាមភាសាផ្ទាល់របស់ខ្លួន មានន័យថា ក្មេងស្រីព្រមទាំងក្មេងប្រុសត្រូវទៅរៀននៅសាលាបឋមសិក្សា ដូច្នោះហើយ ការសិក្សាផ្តល់ឱ្យស្ត្រីនូវតួនាទីបន្ទាប់បន្សំ និងតាមផ្នែកក្នុងការអប់រំកូនរបស់ពួកគេ។

ង-គោលការណ៍សាលារៀន

ដើម្បីរៀបចំ និងអនុវត្តការកែទម្រង់អប់រំ Luther បានពឹងផ្អែកជាខ្លាំងទៅលើ Philipp Melanch- thon(1497-1560)។ ដើម្បីស្វែងរកការបញ្ចប់ការគ្រប់គ្រង របស់សាលារៀនរ៉ូម៉ាំងកាតូលិក ទៅលើសាលារៀននោះ Luther and Melanchthon ចង់ឱ្យរដ្ឋត្រួតពិនិត្យទៅលើសាលារៀន និងផ្តល់លិខិតបញ្ជាក់ដល់គ្រូ។ នៅឆ្នាំ១៥៥៩ Melanchthon បានព្រាងគោលការណ៍សាលារៀន Wurtemberg ដែលបានក្លាយជាគំរូមួយសម្រាប់រដ្ឋអាល្លឺម៉ង់ផ្សេងទៀត។ គោលការណ៍នោះ បានបញ្ជាក់យ៉ាងជាក់លាក់ នូវសាលារៀនបឋម

សិក្សាភាសាក្នុងតំបន់នៅគ្រប់ភូមិដើម្បីបង្រៀនសាសនា ការអាន ការសរសេរ នព្វន្ត សាស្ត្រ និងតន្ត្រី។ សាលាមធ្យមសិក្សាក្លាស៊ីក (Gymnesien) ត្រូវផ្តល់ការបង្រៀនភាសាក្រិក និងឡាតាំង សម្រាប់អ្នកទាំងឡាយដែលជ្រើសរើសមនុស្សក្មេងៗ ដែលបានរំពឹងថានឹងត្រូវចូលរៀននៅសាកលវិទ្យាល័យ។

៩-២-ការរួមចំណែកនៃការកែទម្រង់ ដល់ការអប់រំនៅលោកខាងលិច

កំណែទម្រង់ប្រូតេស្តង់បានអះអាងឡើងវិញនូវការអភិវឌ្ឍស្ថាប័នជាច្រើនពីបុនសម័យ ជាពិ សេសប្រព័ន្ធទ្វេនៃសាលារៀន។ នៅពេលដែលសាលារៀន ដែលប្រើភាសាក្នុងតំបន់បានផ្តល់ការបង្រៀននៅបឋមសិក្សាដល់វណ្ណៈសេដ្ឋកិច្ចសង្គមកម្រិតទាប ដែលជាសា លារៀនបឋមសិក្សាមនុស្សនិយមក្លាស៊ីកផ្សេងៗបានរៀបចំវណ្ណៈខ្ពស់សម្រាប់ឧត្តមសិក្សា។ ពួកអាណានិគមអឺរ៉ុប ជាបន្តបន្ទាប់បាននាំនូវសាលារៀនតាមប្រព័ន្ធទ្វេ ទៅដល់ពិភពលោកថ្មី។

តាមរយៈការបញ្ជាក់ន័យ ទៅលើការអានព្រះគម្ពីរនោះ អ្នកកែទម្រង់ប្រូតេស្តង់ក៏បានទុកកេរ្តិ៍ឱ្យអ្នកអប់រំជំនាន់ក្រោយនូវការបញ្ជាក់ន័យដ៏សំខាន់ទៅលើអក្ខរកម្ម។ ឥរិយាបថនេះ ជួយបង្កើនល្បឿនចលនាឆ្ពោះទៅកាន់ការអប់រំសកល។

សាសនា មានឥទ្ធិពលដ៏ធំធេង ទៅលើការអប់រំ និងការសិក្សា ពីសម័យកាលបុរាណ ទៅកាន់សតវត្សទី២១។ សាលារៀនជាច្រើន បានផ្សារភ្ជាប់ទៅនឹងព្រះវិហារវត្ត និងព្រះវិហារកាតូលិក។ នៅសហរដ្ឋអាម៉េរិក សាលារៀន សាលាវិជ្ជាជីវៈ និងមហាវិទ្យាល័យសម័យដើមបានផ្សារភ្ជាប់យ៉ាងជិតស្និទ្ធទៅនឹងសាសនា។ ថ្មីៗនេះ មានសិស្សសាលាបឋមនិងមធ្យមសិក្សាប្រហែល៤,៣៥៤,៤២០នាក់កំពុងសិក្សានៅសាលារៀនដែលពាក់ព័ន្ធដល់សាសនា[១៦]។

ទោះជាយ៉ាងណាក៏ដោយ នៅសតវត្សទី១៨ ឥទ្ធិពលសាសនាទៅលើការអប់រំបានពើបប្រទះនឹងការប្រឆាំង។ ធម្មជាតិនិយម និងវិចារណញ្ញាណនិយមនៃជំនឿសមហេតុផល និងវិទ្យាសាស្ត្រដែលជាយុគសម័យគិតពីហេតុផល បានរាលដាលពាសពេញទ្វីបអឺរ៉ុប។

១០. ឥទ្ធិពលនៃជំនឿប្រកបដោយវិចារណញ្ញាណនិងវិទ្យាសាស្ត្រទៅលើការអប់រំ

នៅពេលដែលយើងពិនិត្យមើលយុគសម័យជំនឿសមហេតុផល និងវិទ្យាសាស្ត្រ នាសតវត្សទី១៨ (ក៏ត្រូវបានគេ ហៅថា យុគសម័យនៃវិចារណញ្ញាណ) ចូរចាំថាស្ថាប័ននយោបាយសហរដ្ឋអាម៉េរិក គឺជាផលិតផលនៃសកវាជនោះ។ គំនិត

[១៦] Private School Universe Survey, 1999-2000; **http:nces.ed.gov/pubsearch/**(01/12/2003).

វិចារណញ្ញាណ និងវិទ្យាសាស្ត្រ បានជះឥទ្ធិពលដល់អ្នកកែទម្រង់អប់រំយ៉ាងចម្បង ដូចជា Rousseau, Pestalozzi, and Froebel។ គំនិតនៃអ្នកកែទម្រង់អឺរ៉ុប បានរាលដាលដល់ទ្វីបអាម៉េរិក។

ក-ទិចារ និចវិធីវិទ្យាសាស្ត្រ

គំនិតប្រកបដោយវិចារណ ញ្ញាណ និងវិទ្យាសាស្ត្រដ៏ល្បីល្បាញ គឺឥទ្ធិពលនៃវិចារណញ្ញាណ។ ទស្សនវិទូ អ្នកវិទ្យាសាស្ត្រ និងវិជ្ជាករទាំងនេះ បានជឿជាក់យ៉ាងខ្លាំងថា មនុស្សអាចកែលំអជីវិត និងស្ថាប័នរបស់ពួកគេ តាមការប្រើប្រាស់វិចារណញ្ញាណដើម្បីដោះស្រាយបញ្ហា[៧]។ ដោយសង្កត់ធ្ងន់ទៅលើការអង្កេតបែបវិទ្យាសាស្ត្រនោះ អ្នកផ្តើមគំនិតទាំងនេះ បានប៉ុនប៉ងរកឱ្យឃើញ"ច្បាប់ធម្មជាតិ" លំនាំតាមលំដាប់លំដោយដែលធម្មជាតិមានមុខងារ។ ពួកគេក៏បានប្រឌិតទ្រឹស្តីកំណែទម្រង់សង្គម។

ឧទាហរណ៍: មនោគមវិជ្ជាដែលមានមូលដ្ឋានលើបដិវត្តន៍អាម៉េរិក និងបាពាំងបានស្វែងរកដើម្បីស្ថាបនាឡើងវិញនូវសណ្តាប់ធ្នាប់នយោបាយ យោងទៅតាមវិចារណញ្ញាណ។

មនោគមវិជ្ជាវិចារណញ្ញាណ និងវិទ្យាសាស្ត្រ បានបញ្ជាក់ថា សាលារៀនគួរតែបណ្តុះបំណិនសិស្ស ដើម្បីធ្វើវិចារ និងរំដោះខ្លួនគេឱ្យចេញផុតពីជំនឿឆ្កួតហួសហេតុ។

ខ-ជំនឿក្នុចការអតិវឌ្ឍ

មនុស្សដែលមានវិចារណញ្ញាណ និងវិទ្យាសាស្ត្រគួរឱ្យកត់សម្គាល់ មានដូចជា Diderot,Rousseau,Franklin, and Jefferson បានឃើញមនុស្សជាតិថា ជាការឈានឆ្ពោះទៅមុខ ចំពោះពិភពលោកថ្មី និងប្រសើរជាងមុន។ ពួកគេលែងត្រូវការសម្លឹងមើលត្រឡប់ទៅក្រោយទៅយុគមាសរបស់ក្រិកឬរ៉ូមទៀតហើយ។ ដោយប្រើប្រាស់វិចារណ-ញ្ញាណ និង វិធីវិទ្យាសាស្ត្រមនុស្សអាចសម្រេចបាននូវការអភិវឌ្ឍនៅលើកពផែនដី។ សាលារៀនត្រូវតែជាស្ថាប័នមានការរីកចម្រើន ដែលលើកទឹកចិត្តសិស្សឱ្យអភិវឌ្ឍឥរិយាបថដែលចេះសួរចិត្តទូលាយនិងកាពចង់ចេះដឹងដើម្បីប្រើប្រាស់វិធីសង្កេតពិសោធបែបវិទ្យាសាស្ត្រ។

គំនិតប្រកបដោយវិចារណញ្ញាណ និងវិទ្យាសាស្ត្រ បានចាប់កំណើតនៅសហរដ្ឋអាម៉េរិក ដែលជាកន្លែងដែលពួកគេបានអភិវឌ្ឍ ទៅជាជំនឿប្រកបដោយសុទិដ្ឋិនិយមក្នុង នយោបាយប្រជាធិបតេយ្យ និងសកលកម្មការអប់រំ។ ពួកគេ បានអនុវត្តតាមគំនិតរបស់លោក Benjamin Franklin ស្តីពីការអប់រំដែលមានប្រយោជន៍ និងបែបវិទ្យាសាស្ត្រ និងការអះអាងរបស់ Thomas Jefferson សម្រាប់សាលារៀនដែលគាំទ្រ

[៧] Ulrich Im Hoff, The Enlightenment (Cambridge, Mass.: Basli Blackwell, 1994).

ដោយរដ្ឋ។ ដោយបានជឿជាក់ពីបំណិនរបស់គេដើម្បីដឹកនាំអនាគតខ្លួនគេ ជនជាតិអាម៉េរិកបានយល់ឃើញថា ការអប់រំជាគន្លឹះសម្រាប់ការអភិវឌ្ឍ (Education as the key to progress)[១៨]។

១១. ការសន្ទនៈ រយៈពេលជាគន្លឹះក្នុងប្រវត្តិអប់រំ

ក-សង្គមបុរេអក្ខរកម្ម (៧000-៥000 មុនគ.ស.)

1-គោលដៅអប់រំ៖ បង្រៀនបំណិនគង់នៅរបស់ក្រុមនិងភាពពាក់ព័ន្ធរបស់ក្រុម។

2-សិស្ស៖ កុមារនៅក្នុងក្រុម។

3-វិធីបង្រៀន៖ ការបង្រៀនមិនផ្លូវការ កុមារត្រាប់តាមមនុស្សចាស់នូវបំណិននិងតម្លៃ។

4-កម្មវិធីសិក្សា៖ បំណិនគង់នៅនៃការប្រមាញ់ នេសាទ ការប្រមូលផ្តុំអាហារ រឿងនិទាន ជំនឿសាមញ្ញ ចម្រៀង កំណាព្យ និងរបាំ។

5-ភ្នាក់ងារ៖ មាតាបិតា រៀមច្បងក្នុងកុលសម្ព័ន្ធ និងបព្វជិត។

6-ឥទ្ធិពលទៅលើការអប់រំទំនើប៖ ការសង្កត់ធ្ងន់ទៅលើការអប់រំមិនផ្លូវការដើម្បីផ្ទេរបំណិន និងតម្លៃ។

ខ-ចិន (៣000 មុនគ.ស.-១៩00 គ.ស.)

1-គោលដៅអប់រំ៖ ត្រៀមរៀបចំមន្ត្រីដែលជាវរជន ដើម្បីគ្រប់គ្រងចក្រភពដោយយោងទៅតាមគោលការណ៍ ខុង ជឺ។

2-សិស្ស៖ មនុស្សប្រុស ដែលមានវណ្ណៈខ្ពស់។

3-វិធីបង្រៀន៖ ការទន្ទេញ និងការសូត្រអត្ថបទបែបបុរាណ។

4-កម្មវិធីសិក្សា៖ គំរូតាមខុងជឺ។

5-ភ្នាក់ងារ៖ មន្ត្រីរដ្ឋាភិបាល។

6-ឥទ្ធិពលទៅលើការអប់រំទំនើប៖ ការប្រឡងបែបសរសេរ សម្រាប់សេវាកម្មស៊ីវិល និងវិជ្ជាជីវៈផ្សេងទៀត។

គ-ឥណ្ឌា (៣000-មុនគ.ស.-បច្ចុប្បន្ន)

1-គោលដៅអប់រំ៖ សិក្សាអាកប្បកិរិយា និងទម្លាប់ដោយផ្អែកលើគម្ពីរវេទ។

2-សិស្ស៖ មនុស្សប្រុស ដែលមានវណ្ណៈខ្ពស់។

3-វិធីបង្រៀន៖ ការទន្ទេញ និងបកប្រែគម្ពីរពិសិដ្ឋ។

4-កម្មវិធីសិក្សា៖ អត្ថបទសាសនា និងគម្ពីរវេទ។

5-ភ្នាក់ងារ៖ វិជ្ជាករដែលជាបព្វជិតព្រាហ្មណ៍។

---

[១៨] Daniel Feller, The Jacksonian Promise: America, 1815-1840 (Baltimore: Johns Hopkins University Press, 1995), pp viii-xiv.

6-ឥទ្ធិពលទៅលើការអប់រំទំនើបៈ ការផ្ទេរ និងការជ្រួតជ្រាបវប្បធម៌ភាពដោយឡែកខាងស្មារតី។

ឃ-អេហ្ស៊ីប(៣000-៣00 មុនគ.ស.)

1-គោលដៅអប់រំៈ ត្រៀមរៀបចំមនុស្សឱ្យចេះកត់ត្រាអក្សរ ដែលបព្វជិតបានបង្រៀន ដើម្បីគ្រប់គ្រងចក្រភព។

2-សិស្សៈ មនុស្សប្រុស ដែលមានវណ្ណៈខ្ពស់។

3-វិធីបង្រៀនៈ ទន្ទេញ និងការចម្លងអត្ថបទ ដែលគេហៅឱ្យកត់ត្រា។

4-កម្មវិធីសិក្សាៈ អត្ថបទខាងបច្ចេកទេស ឬសាសនា។

5-ភ្នាក់ងារៈ បព្វជិត និងអ្នករៀនកត់ត្រាអក្សរ។

6-ឥទ្ធិពលទៅលើការអប់រំទំនើបៈ ភាពរឹតបន្តឹងនៃការគ្រប់គ្រងអប់រំ និងសេវាកម្មដល់វរជនដែលជាបព្វជិត ប្រយោជន៍នៃការអប់រំដើម្បីត្រៀមរៀបចំការិយាធិបតេយ្យ។

ង-ក្រិក (១៦00-៣00 មុនគ.ស.)

1-គោលដៅអប់រំៈ

-អាថែនៈ បណ្តុះការទទួលខុសត្រូវនៃពលរដ្ឋ និងកំណត់អត្តសញ្ញាណជាមួយទីក្រុងដែលជារដ្ឋ និងដើម្បីអភិវឌ្ឍមនុស្សដែលល្អគ្រប់ជ្រុងជ្រោយ។

-ស្ប៉ាតៈ បណ្តុះបណ្តាលទាហាន និងមេដឹកនាំកងទ័ព។

2-សិស្សៈ កុមារ និងមនុស្សប្រុសដែលជាពលរដ្ឋមានអាយុពី៧-២០ឆ្នាំ។

3-វិធីបង្រៀនៈ ហ្វឹកហាត់ទន្ទេញសូត្រ នៅសាលាបឋមសិក្សា បង្រៀនពិភាក្សា និងសន្ទនា នៅមធ្យមសិក្សា។

4-កម្មវិធីសិក្សាៈ

-អាថែនៈ ការអាន សរសេរ នព្វន្ត សាស្ត្រ វិនាដសាស្ត្រ តន្ត្រី អប់រំកាយ អក្សរសិល្ប៍ កំណាព្យ។

-ស្ប៉ាតៈ ហ្វឹកហាត់ ចម្រៀងកងទ័ព និងយុទ្ធវិធី។

5-ភ្នាក់ងារៈ

-អាថែនៈ សាលា និងគ្រូបង្រៀនឯកជន ពួកសូហ្ស៊ីស ទស្សនវិទូ។

-ស្ប៉ាតៈ មន្ត្រីកងទ័ព។

6-ឥទ្ធិពលទៅលើការអប់រំទំនើបៈ

-អាថែនៈ បញ្ញត្តិនៃមនុស្ស ដែលមានការអប់រំសេរីល្អគ្រប់ជ្រុងជ្រោយ

-ស្ប៉ាតៈ បញ្ញត្តិនៃការបម្រើរដ្ឋដែលជាកងទ័ព។

ច-រ៉ូម៉ាំង (៧៥0មុនគ.ស.-៤៥0នៃគ.ស.)

1-គោលដៅអប់រំៈ អភិវឌ្ឍការទទួលខុសត្រូវរបស់ពលរដ្ឋ សម្រាប់សាធារណរដ្ឋ ហើយបន្ទាប់មកចក្រភព អភិវឌ្ឍបំណិនរដ្ឋបាល និងកងទ័ព។

2-សិស្សៈ កុមារ និងមនុស្សប្រុសដែលមានវណ្ណៈខ្ពស់ អាយុ៧-២0ឆ្នាំ។

3-វិធីបង្រៀន៖ ហ្វឹកហាត់ ទន្ទេញ សូត្រ នៅសាលាកម្រិតទាប ការនិយាយ ថ្លែងទៅកាន់ទស្សនិកជន ក្នុងសាលាកម្រិតខ្ពស់។

4-កម្មវិធីសិក្សា៖ ការអាន ការសរសេរ ពុទ្ធសាស្ត្រ ច្បាប់តារាង១២ច្បាប់ទស្សនវិជ្ជា។

5-ភ្នាក់ងារ៖ សាលាឯកជន និងគ្រូបង្រៀន សាលារោហារសាស្ត្រ។

6-ឥទ្ធិពលទៅលើការអប់រំទំនើប៖ សង្កត់ធ្ងន់ទៅលើការអប់រំ សម្រាប់បំណិនរដ្ឋបាល ជាក់ស្តែង ទំនាក់ទំនងការអប់រំ ទៅនឹងការទទួលខុសត្រូវរបស់ពលរដ្ឋ។

ឆ-អរ៉ាប់ (**៧00-១៣៥0ឆៃគ.ស**.)

1-គោលដៅអប់រំ៖ បណ្តុះការតស៊ូប្តូរផ្តាច់ ចំពោះជំនឿសាសនាអ៊ីស្លាម អភិវឌ្ឍអ្នកជំនាញខាងគណិតវិទ្យា វេជ្ជសាស្ត្រ និងវិទ្យាសាស្ត្រ។

2-សិស្ស៖ កុមារ និងមនុស្សប្រុសដែលមានវណ្ណៈខ្ពស់ អាយុ៧-២0ឆ្នាំ។

3-វិធីបង្រៀន៖ ហ្វឹកហាត់ ទន្ទេញ សូត្រ នៅសាលាកម្រិតទាប ត្រាប់តាម និងពិភាក្សា និងសន្ទនា នៅសាលាកម្រិតខ្ពស់។

4-កម្មវិធីសិក្សា៖ ការអាន ការ សរសេរ គណិតវិទ្យា អក្សរសាស្ត្រខាងសាសនា ការសិក្សាខាងវិទ្យាសាស្ត្រ។

5-ភ្នាក់ងារ៖ ព្រះវិហារម៉ូស សាលារៀនវាំង។

6-ឥទ្ធិពលទៅលើការអប់រំទំនើប៖ លេខអារ៉ាប់ និងការគិតលេខ ការបញ្ចូលសម្ភារៈបែបបុរាណ ចំពោះវិទ្យាសាស្ត្រ និងវេជ្ជសាស្ត្រ។

ជ-មជ្ឈិមសម័យ(**៥00-១៤00គ.ស**.)

1-គោលដៅអប់រំ៖ អភិវឌ្ឍការតស៊ូប្តូរផ្តាច់ ចំពោះសាសនា ចំណេះដឹង និងទម្លាប់ ត្រៀមរៀបចំមនុស្សសម្រាប់តួនាទីសមរម្យ តាមឋានានុក្រម។

2-សិស្ស៖ក្មេងប្រុសវណ្ណៈខ្ពស់ឬអ្នកទាំងឡាយដែលកំពុងចូលរួមជីវិតសាសនា ក្មេង ស្រីនិងស្ត្រីក្មេងៗដែលកំពុងចូលរួមសហគមន៍សាសនាពីអាយុ៧-២0ឆ្នាំ។

3-វិធីបង្រៀន៖ ហ្វឹកហាត់ ទន្ទេញ សូត្រ ស្នូត្រ នៅសាលាកម្រិតទាប ការវិភាគអត្ថបទ និងការពិភាក្សាជាផ្លូវការ នៅសាលាកម្រិតខ្ពស់ និងសាកលវិទ្យាល័យ។

4-កម្មវិធីសិក្សា៖ ការអាន ការសរសេរ ពុទ្ធសាស្ត្រ សិល្បៈសើរៗ ទស្សនវិជ្ជា ការប៉ិនប្រសប់ យុទ្ធ សាស្ត្រយោធា និងភាពជាអ្នកក្លាហានប្រកបដោយ សីលធម៌។

5-ភ្នាក់ងារ៖ សាលារៀនជើងវត្ត ច្រៀងចម្រៀងជាពួក និងព្រះវិហារ សាកលវិទ្យាល័យភាពជាអ្នកហាត់ការអស្សុប្ញទ្ធិភាព។

6-ឥទ្ធិពលទៅលើការអប់រំទំនើប៖ រចនាសម្ព័ន្ធដែលបានបង្កើតឡើង ខ្ចីមសារ និងការចាត់តាំងសាកលវិទ្យាល័យជាស្ថាប័ន

ចម្បងនៃឧត្តមសិក្សាស្ថាប័ននីយកម្ម និង
ការរក្សានូវចំណេះដឹង។

ឈ-បុនសម័យ(១៣៥0-១៥00 គ.ស.)

1-គោលដៅអប់រំ៖ បណ្តុះអ្នក
ជំនាញការមនុស្សនិយម ក្នុងអក្សរសិល្ប៍
ក្រិក និងឡាតាំង ត្រៀមរៀបចំបរិវារស្តេច
សម្រាប់សៅកម្ម ចំពោះមេដឹកនាំសន្តតិវង្ស។

2-សិស្ស៖ ក្មេងប្រុសនៃវណ្ណៈអភិជន
និងវណ្ណៈខ្ពស់ អាយុ៧-២0ឆ្នាំ។

3-វិធីបង្រៀន៖ ការទន្ទេញ ការបក
ប្រែនិងការវិភាគអក្សរសិល្ប៍ក្រិកនិងរ៉ូម៉ាំង។

4-កម្មវិធីសិក្សា៖ភាសាក្រិក ឡាតាំង
អក្សរសិល្ប៍ កំណាព្យ សិល្បៈ។

5-ភ្នាក់ងារ៖ អ្នកអប់រំមនុស្សនិយម
និងសាលា ដូចជា វិទ្យាល័យ និងសាលា
ភាសា ឡាតាំង។

6-ឥទ្ធិពលទៅលើការអប់រំទំនើប៖
ការសង្កត់ធ្ងន់ទៅលើចំណេះអក្ខរកម្ម ឧត្តម
ភាព និងរចនាបថដែលបានបង្ហាញក្នុង
អក្សរសិល្ប៍ក្រិក និងឡាតាំង និងប្រព័ន្ធពីរ
បែបនៃសាលារៀន។

ឈ -សម័យការកែទម្រង់
(១៥00-១៦00 គ.ស.)

1-គោលដៅអប់រំ៖ បំពាក់បំប៉ននការ
តស៊ូសន្យាដល់និកាយសាសនា ពិសេស
បណ្តុះអក្ខរកម្មទូទៅ។

2-សិស្ស៖ ក្មេងប្រុស និងស្រី អាយុ
ពី៧-១២ឆ្នាំ នៃសាលារៀនក្នុងតំបន់ណា
មួយ ក្មេងប្រុសអាយុពី៧-១២ ដែលមាន
ប្រវត្តិវណ្ណៈខ្ពស់ក្នុងសាលាមនុស្សនិយម។

3-វិធីបង្រៀន៖ ទន្ទេញ ហ្វឹកហាត់
ការបញ្ចុះបញ្ចូលឱ្យធ្វើតាមការបង្រៀនតាម
ព្រះវិហារ ក្នុងសាលារៀន នៅតំបន់ណា
មួយ ការបកប្រែ វិភាគអក្សរសិល្ប៍ក្រិក និង
ឡាតាំង ក្នុងសាលាមនុស្សនិយម។

4-កម្មវិធីសិក្សា៖ ការអាន សរសេរ
នព្វន្ត សាស្ត្រការសង្ខេបគោលការណ៍
សាសនា បញ្ញត្តិសាសនានិងទម្ងាប់សាសន
វិទ្យាក្រិក និងឡាតាំង។

5-ភ្នាក់ងារ៖ សាលាបឋមសិក្សាក្នុង
តំបន់ណាមួយ សម្រាប់ប្រជាករ សាលា
បែបបុរាណ សម្រាប់ត្រកូលខ្ពស់។

6-ឥទ្ធិពលទៅលើការអប់រំទំនើប៖
ការតស៊ូសន្យា ចំពោះការអប់រំសកល ដើម្បី
ផ្តល់ អក្សរ ដល់ប្រជាករ ប្រភពនៃប្រព័ន្ធ
សាលារៀន ជាមួយការត្រួតពិនិត្យ ដើម្បី
ជានាការអនុលោមទៅតាមលទ្ធិប្រព័ន្ធ
សាលាពីរបែប ដោយផ្អែកទៅលើវណ្ណៈ
សេដ្ឋកិច្ចសង្គម និងគោលដៅវិជ្ជាជីវៈ។

១២-ទ្រឹស្តីវិទ្យុអប់រំចម្បងៗ ដល់
ឆ្នាំ១៦00នៃគ.ស.

ក-ខុងជឺ ៥៥១-៤៧៩ មុនគ.ស. (ចិន)

1-*ការតម្រង់ទិសខាងទស្សនវិជ្ជា*

-បានអភិវឌ្ឍប្រព័ន្ធសីលវិទ្យា ដោយផ្អែកលើការរៀបចំទៅតាមឋានានុក្រមនៃទំនាក់ទំនងមនុស្ស និងតួនាទី។

-សង្កត់ធ្ងន់ទៅលើរបៀបរៀបរយ និងស្ថិរភាពតាមរយៈការនៅក្រោមបង្គាប់។

2-ទស្សនៈធម្មជាតិមនុស្ស

មនុស្សជាតិ ត្រូវការសណ្តាប់ធ្នាប់នៃសង្គម ដែលមានស្ថិរភាពកម្រិតខ្ពស់ក្នុងនោះ មនុស្សទទួលយកករណីកិច្ច ដែលគិតដល់ឋានៈក្នុងជីវិត។

3-ទស្សនៈទៅលើការអប់រំ និងកម្មវិធីសិក្សា

-ការអប់រំត្រៀមរៀបចំមនុស្ស សម្រាប់តួនាទីនយោបាយសង្គម តាមការបណ្តុះ**គរុការភាព** (Reve- rence) សម្រាប់បុព្វបុរស និងប្រពៃណី។

-កម្មវិធីសិក្សារបស់អ្នកនិពន្ធចិនបុរាណដែលមានគុណសម្បត្តិនិងតម្លៃអមតៈ និងការប្រមូលផ្តុំនៃអ្នកជំនាញការពីស្នាដៃអក្សរសិល្ប៍ (Analects)របស់ ខុង ជឺ។

-ការប្រឡងជ្រើសរើសកម្រិតខ្ពស់។

4-ការរួមចំណែក និងឥទ្ធិពល

ក្រមសីលវិទ្យារបស់ ខុង ជឺ បានបង្កើតវប្បធម៌ចិនអស់រយៈពេលជាច្រើនសតវត្សដោយ បានបង្កើតប្រព័ន្ធតម្លៃដែលនៅស្ថិតស្ថេរដ៏មានសារៈសំខាន់។

ខ-សូក្រាត ៤៦៩-៣៩៩ មុនគ.ស. (ក្រិក)

1-ការតម្រង់ទិសខាងទស្សនវិជ្ជា

អ្នកបំផ្លាញជំនឿសាសនា មានភាពលំអៀងទៅរកឧត្តមគតិនិយមទស្សនវិជ្ជា និងអភិរក្សនិយមនយោបាយ។

2-ទស្សនៈស្តីពីធម្មជាតិមនុស្ស

មនុស្សជាតិអាចកំណត់ខ្លួនឯងបានតាមការពិនិត្យទៅលើខ្លួនឯងប្រកបដោយវិចារណញ្ញាណ។

3-ទស្សនៈទៅលើការអប់រំ និងកម្មវិធីសិក្សា

-ប្រើប្រាស់ការស្វែងរកការសន្ទនាប្រកបដោយភាពឈ្លាសវៃ ដើម្បីឆ្ងើយទៅនឹងការយកចិត្តទុកដាក់របស់មនុស្សជាមូលដ្ឋាន។

-ការអប់រំ គួរតែបណ្តុះឧត្តមភាពខាងសីលធម៌។

4-ការរួមចំណែក និងឥទ្ធិពល

-ការសន្ទនា តាមបែបសូក្រាត ជាវិធីបង្រៀន។

-គ្រូ មានតួនាទីជាគំរូ។

គ-ឡាតុង ៤២៧-៣៤៦ មុនគ.ស. (ក្រិក)

1-ការតម្រង់ទិសខាងទស្សនវិជ្ជា

អ្នកមានឧត្តមគតិផ្នែកទស្សនវិជ្ជា អ្នកអភិរក្សផ្នែកនយោបាយសង្គម។

2-ទស្សនៈស្តីពីធម្មជាតិមនុស្ស

មនុស្សជាតិ អាចត្រូវបានគេចាត់ថ្នាក់ទៅតាមមូលដ្ឋាននៃសមត្ថភាពបញ្ញា។

3-ទស្សនៈទៅលើការអប់រំ និងកម្មវិធីសិក្សា

-ការសំណេរៈសំណាលពីគំនិតដែលមិនទាន់បង្ហាញឱ្យឃើញ។

-តន្ត្រី កីឡាកាយសម្ព័ន្ធធរណីមាត្រ សាស្ត្រ តារាសាស្ត្រ បំណិនខាងអក្សរសិល្ប៍ជាមូលដ្ឋាន។

-ទស្សនវិជ្ជា សម្រាប់គ្រប់គ្រងវដ្តនៃអធិរាជខាងទស្សនវិជ្ជា។

4-ការរួមចំណែក និងឥទ្ធិពល

-ប្រើប្រាស់សាលារៀនទៅតាមប្រភេទសិស្សយោងទៅតាមសមត្ថភាពបញ្ញា។

-ការអប់រំ ត្រូវផ្សារភ្ជាប់ទៅនឹងគោលបំណង(នយោបាយ)ពលរដ្ឋ។

ឃ-អារីស្តូត ៣៨៤-៣២២ មុន គ.ស. (ក្រិក)

1-ការតម្រង់ទិសខាងទស្សនវិជ្ជា

-អ្នកមានគំនិតតឋៈខាងផ្នែកទស្សនវិជ្ជា។

-ទស្សនៈនៃសង្គម នយោបាយ និងការអប់រំដោយផ្អែកលើតថនិយមក្វាស៊ីក។

2-ទស្សនៈស្តីពីធម្មជាតិមនុស្ស

មនុស្សជាតិ មានអំណាចប្រកបដោយវិចារណញ្ញាណ ដែលគួរតែបង្ហាញផ្លូវចរិយារបស់គេ។

3-ទស្សនៈទៅលើការអប់រំ និងកម្មវិធីសិក្សា

-ការសង្កត់ធ្ងន់ទៅលើខាងវិទ្យាសាស្ត្រ និងជាសត្យានុម័តិ។

-បំណិនខាងអក្សរសាស្ត្រជាមូលដ្ឋាន គណិតវិទ្យា វិទ្យាសាស្ត្រធម្មជាតិ និងពាងកាយ ទស្សនវិជ្ជា។

4-ការរួមចំណែក និងឥទ្ធិពល

-ការសង្កត់ធ្ងន់លើមនុស្សដែលល្អគ្រប់ជ្រុងជ្រោយមានការអប់រំផ្នែកអក្សរសាស្ត្រ។

-សារៈសំខាន់នៃវិចារណញ្ញាណ។

ង-អ៊ីស៊ូក្រាត ៤៣៦-៣៨៨ មុន គ.ស.(ក្រិក)

1-ការតម្រង់ទិសខាងទស្សនវិជ្ជា

រៀហារសាស្ត្រវិទូ ការអប់រំសិល្បៈនៃការថ្លែងសុន្ទរកថា ក្នុងសេវាកម្មដោយខ្លួនឯង និងសង្គម។

2-ទស្សនៈស្តីពីធម្មជាតិមនុស្ស

មនុស្សមានថាមពល ដើម្បីប្រើប្រាស់ពាក្យសម្តីសម្រាប់ការកែលំអនយោបាយ និងសង្គម។

3-ទស្សនៈទៅលើការអប់រំ និងកម្មវិធីសិក្សា

ការសិក្សារៀហារសាស្ត្រ បំណិនអក្សរសាស្ត្រជាមូលដ្ឋាន នយោបាយ ប្រវត្តិសាស្ត្រ ការថ្លែងទៅកាន់ទស្សនិកជន និងការនិយាយ នៅក្នុងទីសាធារណៈ។

4-ការរួមចំណែក និងឥទ្ធិពល

-ប្រើប្រាស់ចំណេះដឹងក្នុងកិច្ចការសាធារណៈ និងក្នុងមគ្គុទ្ទេសក៍ការពន្យោបាយ។

-ការអប់រំគ្រូ មានទាំងវិសាលភាពខ្ញឹមសារ និងការប្រតិបត្តិ។

ច-ឃ្វីនធីលាន ៣៥-៩៥ នៃគ.ស.(រ៉ូម៉ាំង)

1-ការតម្រង់ទិសខាងទស្សនវិជ្ជា

រ៉ោមារសាស្ត្រវិទូ សិល្បៈក្នុងការថ្លែងសុន្ទរកថា សម្រាប់គុណប្រយោជន៍បុគ្គល និង សេវាកម្មសាធារណៈ។

2-ទស្សនៈស្តីពីធម្មជាតិមនុស្ស

បុគ្គលពិតប្រាកដ មានសមត្ថភាពសម្រាប់ដឹកនាំ ដោយផ្អែកលើអារម្មណ៍ចំណេះដឹងសើរើ និងបំណិនថ្លែងសុន្ទរកថា។

3-ទស្សនៈទៅលើការអប់រំ និងកម្មវិធីសិក្សា

បំណិនអក្សរសាស្ត្រជាមូលដ្ឋានវេយ្យាករណ៍ ប្រវត្តិសាស្ត្រ អក្សរសិល្បវិនិាជសាស្ត្រ ទស្សនវិទូ ការនិយាយជាសាធារណៈ និងច្បាប់។

4-ការរួមចំណែក និងឥទ្ធិពល

តួនាទីនៃកម្លាំងជំរុញចិត្ត ក្នុងការសិក្សាការទទួលស្គាល់ភាពខុសគ្នាខាងបុគ្គល។

ឆ-អេឃ្វីណា ១២២៥-១២៧៤ នៃគ.ស.(សាសនវិទូមជ្ឈិមសម័យអ៊ីតាលី)

1-ការតម្រង់ទិសខាងទស្សនវិជ្ជា

សាសនវិទូគ្រិស្ត និងទស្សនវិជ្ជាតថភាពរបស់អារីស្តូត។

2-ទស្សនៈស្តីពីធម្មជាតិមនុស្ស

មនុស្ស មានទាំងធម្មជាតិខាងចិត្ត និងរាងកាយ។

3-ទស្សនៈទៅលើការអប់រំ និងកម្មវិធីសិក្សា

ការអប់រំ គួរតែផ្អែកទៅលើធម្មជាតិមនុស្សដោយមានការសិក្សាសមរម្យសម្រាប់ចិត្ត និងរាងកាយ។

4-ការរួមចំណែក និងឥទ្ធិពល

-គ្រូជាភ្នាក់ងារសីលធម៌។ ការអប់រំទាក់ទងទៅនឹងសាសនវិទ្យាសកល។

-សំយោគខាងសាសនវិទ្យានិងទស្សនវិជ្ជា។

-មូលដ្ឋាននៃទស្សនវិជ្ជា បានប្រើប្រាស់ក្នុងសាលារៀនរ៉ូម៉ាំងកាតូលិក។

ជ-អ៊ីរ៉ាស្មឹស ១៤៦៥-១៥៣៦ នៃគ.ស.(មនុស្សនិយមមុនសម័យហ្លួចង់)

1-ការតម្រង់ទិសខាងទស្សនវិជ្ជា

ការតម្រង់ទិសខាងសាសនាគ្រិស្តអ្នកអប់រំ ជាអ្នករិះគន់ដោយឈ្លាសវៃ និងទាក់ទងដល់សង្គម។

2-ទស្សនៈស្តីពីធម្មជាតិមនុស្ស

មនុស្សមានសមត្ថភាពបង្កើតសមិទ្ធផលដ៏ជ្រាលជ្រៅតែក៏មានភាពភ្លើតភ្លើលដ៏ខ្លៅខ្ចាំងណាស់ដែរ។

3-ទស្សនៈទៅលើការអប់រំ និងកម្មវិធីសិក្សា

ការអប់រំ សម្រាប់រាជនអក្សរសាស្ត្រ ដែលសង្កត់ធ្ងន់ទៅលើការរិះគន់និយម និងការវិភាគ។

4-ការរួមចំណែក និងឥទ្ធិពល

តួនាទីនៃសាលាមធ្យមសិក្សា និងឧត្តមសិក្សា ក្នុងការរិះគន់សង្គម និងអក្សរសាស្ត្រ ការសង្កត់ធ្ងន់ពីការគិតល្អិតល្អន់។

ឈ-ល្ងង់ ១៤៨៣-១៥៣៦ នៃ គ.ស. (ប្រូតែស្តង់អាល្លឺម៉ង់)

1-ការតម្រង់ទិសខាងទស្សនវិជ្ជា

ការតម្រង់ទិសសាសនវិទ្យាប្រូតែស្តង់ ការសង្គ្រោះតាមជំនឿ និងមនសិការបុគ្គល។

2-ទស្សនៈស្តីពីធម្មជាតិមនុស្ស

មនុស្ស ត្រូវបានសង្គ្រោះដោយជំនឿ មនសិការបុគ្គលម្នាក់ៗ បង្កើតឡើងដោយព្រះគម្ពីរ និងសាសនវិទ្យា ដែលបានកែទម្រង់រួចហើយ។

3-ទស្សនៈទៅលើការអប់រំ និងកម្មវិធីសិក្សា

-សាលាបឋមសិក្សា ត្រូវបង្រៀនការអាន ការសរសេរ នព្វន្តសាស្ត្រ សាសនា។

-សាលាមធ្យមសិក្សា ត្រូវត្រៀមរៀបចំមេដឹកនាំតាមការផ្តល់ស្នាដៃប្រកបដោយគុណសម្បត្តិ និងតម្លៃកំពូល ភាសាក្រិក ឡាតាំង សាសនា និងការបណ្តុះបណ្តាលវិជ្ជាជីវៈ។

4-ការរួមចំណែក និងឥទ្ធិពល

-ការសង្កត់ធ្ងន់ទៅលើសកលកម្មអក្ខរកម្ម។

-សាលារៀនត្រូវសង្កត់ធ្ងន់ទៅលើតម្លៃខាងសាសនា បំណិនវិជ្ជាជីវៈ ចំណេះដឹង។

-ទំនាក់ទំនងយ៉ាងជិតស្និទ្ធនៃសាសនា សាលារៀន និងរដ្ឋ។

ឯកសារយោង

1. Allan C. Ornstein et al., *Foundation of Education*, Wadsworth, Canada. 2008.
2. Allan C. Ornstein et al., *Foundation of Education*, Wadsworth, Canada. 20011.
3. Barzun, Jacques. *From Dawn to Decadence: 500 Years of Western Cultural Life, 1500 to the Present.* New York: HarperCollins, 2001.
4. Black, Robert. *Humanism and Education in Medieval and Renaissance Italy:Tradition and Innova tion in Latin Schools from the Twelfth to the Fifteenth Century.* New York:Cambridge Uni versity Press, 2001.
5. Gutek, Gerald. *Historical and Philosophical Foundations of Education: A Biographical Introduction.* Columbus, Ohio: Merrill/Prentice Hall, 2005.
6. Gutek, Gerald. *Historical and Philosophical Foundations of Education:Selected Readings.* Columbus, Ohio: Merrill/Prentice Hall, 2001.
7. Hanson, Victor D, and Heath, John. *Who Killed Homer? The Demise d of Classical Education and the Recovery of Greek Wisdom.* New York: Encounter Books, 2001.
8. Lascarides, V.Celia, and Hinitz, Blythe F. *History of Early Childhood Education.* New York:Falmer Press, 2000.
9. Palmer, Joy A, Cooper, David E., and Bresler, Liora, eds. *Fifty Major Thinkers on n Education:From Confucius to Dewey.* New York: Routledge, 2001.
10. Ruthven, Malise. *Islam in the World.* New York: Oxford University Press, 2000.

ការអប់រំជាកិច្ចការទាំងអស់គ្នា

ដោយ៖ លោក **ប៉ាន់ សំណាង**
មន្ត្រីនាយកដ្ឋានវិទ្យាសាស្ត្រអប់រំ,វិទ្យាស្ថាន
មនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម,ពាជបណ្ឌិត្យសភាកម្ពុជា

១. សេចក្តីផ្តើម

ការអប់រំជាឆ្អឹងខ្នងនៃការអភិវឌ្ឍជាតិ។ វិទ្យាសាស្ត្រមានការរីកចម្រើនយ៉ាងណាក៏ដោយ ក៏មិនអាចខ្វះបាននូវការអប់រំដែរ។

កម្ពុជាជាប្រទេសមួយមានខឿនវប្បធម៌ដ៏ចំណាស់មួយនៅដែនដីអាស៊ីអាគ្នេយ៍ ហើយក៏ជាប់ជាអរិយប្រទេស ជាពិសេសសម័យអង្គរដ៏រុងរឿង។ កម្ពុជាបច្ចុប្បន្នបាននិងកំពុងឈានដល់ដំណាក់កាលថ្មីមួយទៀតនៃការអភិវឌ្ឍវិស័យអប់រំឆ្ងើយតបនឹងបរិបទតំបន់និងសកលលោក។ មិនតែប៉ុណ្ណោះ កម្ពុជាក៏មានមហិច្ឆតា និងវិសាលភាពធំទូលាយជាងមុនសំដៅលើកកម្ពស់គុណភាពប្រកបដោយសមធម៌បរិយាបន្ន និងការសិក្សាពេញមួយជីវិតក្នុងក្របខណ្ឌទូលំទូលាយ គ្របដណ្តប់លើគ្រប់ប្រភេទនិងកម្រិតនៃការអប់រំជាពិសេស ស្របនឹងទស្សនវិស័យអភិវឌ្ឍន៍កម្ពុជា។

វាចង់បង្ហាញថា ជាការរួមចំណែកជាមួយនឹងវិស័យនានាប្រែក្លាយកម្ពុជាជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ត្រឹមឆ្នាំ ២០៣០ និងប្រទេសមានចំណូលខ្ពស់នៅឆ្នាំ ២០៥០។ សមិទ្ធផលអប់រំ និងឧត្តមានុវត្តន៍ជាច្រើនដែលកម្ពុជាទទួលបានពីការអនុវត្តគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ និងផែនការអប់រំសម្រាប់ទាំងអស់គ្នា គឺជាមូលដ្ឋានដ៏សំខាន់ដើម្បីឈានទៅសម្រេចការអប់រំក្នុងបរិបទឆ្នាំ២០៣០ខាងមុខ[1]។ វិស័យអប់រំមានតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍធនធានមនុស្សឱ្យមានចំណេះដឹង និងសមត្ថភាពខ្ពស់ ភាពច្នៃប្រឌិត ស្មារតីសហគ្រិនភាព នវានុវត្តន៍ និងក្រមសីលធម៌ខ្ពស់ ដើម្បីរួមចំណែកលើកកម្ពស់ការអភិវឌ្ឍឧស្សាហកម្មដែលជួយបង្កើនកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងបរិ

[1] ក្រសួងអប់រំ យុវជននិងកីឡាផែនទីបង្ហាញផ្លូវការអប់រំកម្ពុជា ឆ្នាំ២០៣០គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ទី៤ ឆ្នាំ២០០៩។

យោបន្តតាមរយៈការធ្វើពិពិធកម្មសេដ្ឋកិច្ច ការពង្រឹងភាពប្រកួតប្រជែង និងលើកកម្ពស់ផលិតភាព។

ក្នុងន័យនេះ ការអប់រំជាការងារយើងទាំងអស់គ្នាដែលផ្តោតលើការសិក្សា ការរៀន ការបង្រៀនដោយលៃយ៉ាងណាផ្តល់នូវសេវាអប់រំប្រកបដោយគុណភាពនិងផលិតភាព។ ផែនទីបង្ហាញផ្លូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ២០៣០ ស្តីពីការអប់រំនៅកម្ពុជារៀបចំឡើងដោយមានការពិគ្រោះយោបល់និងការវិភាគយ៉ាងល្អិតល្អន់រវាងក្រសួង-ស្ថាប័នអ្នកពាក់ព័ន្ធនឹងដៃគូអភិវឌ្ឍន៍ ដើម្បីជានាបានទូវភាពប្រទាក់ក្រឡាគ្នាទៅនឹងគោលនយោបាយមានស្រាប់ដែលធ្វើឱ្យផែនទីបង្ហាញផ្លូវនេះមានចក្ខុវិស័យ គោលនយោបាយ និងយុទ្ធសាស្ត្រ ប្រកបដោយភាពច្រោកដប្រជាមានសង្គតិភាពក្នុងការសម្រេចឱ្យបានទូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពស្តីពីការអប់រំឆ្នាំ២០៣០ ខាងមុខ។

ក្រសួងអប់រំក៏ដូចជាស្ថាប័នពាក់ព័ន្ធ បានខិតខំរៀបចំផែនការអប់រំគោលនយោបាយអប់រំដែលមានលក្ខណៈច្រោកដប្រជាច្បាស់លាស់ តែក្រៅពីនេះ គ្រួសារ សហគមន៍ និងបុគ្គលម្នាក់ៗក៏ត្រូវមានគោលការណ៍អប់រំផ្ទាល់ខ្លួនផងដែរ ដើម្បីអភិវឌ្ឍន៍បញ្ញាញាណឆ្ពោះទៅកាន់គោលដៅអភិវឌ្ឍន៍រួមគ្នាដូចពាក្យមួយឃ្លាលើកឡើងថា «ការអប់រំដើម្បីទាំងអស់គ្នា ទាំងអស់គ្នាដើម្បីការអប់រំ»[២]។

គំនរសៀវភៅ៖ រូបភាពដកស្រង់ចេញពីបណ្តាញសង្គមហ្វេសប៊ុក

២. ទស្សនៈទូទៅអំពីការអប់រំ

២-១.និយមន័យ

តាម**វចនានុក្រមសម្តេចសង្ឃរាជ ជួន ណាត** បានផ្តល់ន័យពាក្យ«អប់រំ»ថាជា «ហាត់ចិត្ត; បង្វឹកចិត្ត; ជួសជុលចំពោះវិជ្ជាឬកិរិយាមារយាទ, ហ្វឹកហាត់ឲ្យស្ទាត់ជំនាញជាងមុន, កែឲ្យបានល្អប្រពៃជាងមុនជាលំដាប់; ខំប្រឹងបំពេញឧបនិស្ស័យឲ្យបរិបូណ៌, ខំកសាងសន្សំបុណ្យកុសលរក្សាទុកពុំឲ្យមានហ្មង, មិនឲ្យមានថ្នាំងថ្នាក់; បន្ទុំបារមី,ព្រះបរមពោធិសត្វបានអប់រំបន្ទុំបារមីអស់កាលយូរអង្វែង។ បើយោងតាមវចនានុក្រមបរទេសមួយបាន

[២] Education For All (EFA)

បញ្ជាក់ថា «ការអប់រំជាដំណើរការនៃការទទួលឬផ្តល់ជូននូវការបង្រៀនឬការណែនាំជាប្រព័ន្ធ ជាពិសេសនៅសាលារៀនឬសាកលវិទ្យាល័យ»។ តាមវចនានុក្រម **Cambridge Dictionary** ពន្យល់ថា៖ «ដំណើរការនៃការបង្រៀនឬការសិក្សា ជាពិសេសនៅក្នុងសាលា ឬ មហាវិទ្យាល័យ ឬ ចំណេះដឹង ដែលយើងទទួលបាន»[៣]។

ការអប់រំមានន័យថា ការសិក្សាដើម្បីទទួលបានចំណេះដឹងនិងការយល់ដឹងកាន់តែស៊ីជម្រៅលើមុខវិជ្ជាផ្សេងៗដែលត្រូវយកមកអនុវត្តក្នុងជីវិតប្រចាំថ្ងៃ។ ការអប់រំមិនត្រូវបានកំណត់ចំពោះតែចំណេះដឹងពីសៀវភៅប៉ុណ្ណោះទេ ប៉ុន្តែវាក៏អាចទទួលបានតាមរយៈបទពិសោធន៍ជាក់ស្តែងនៅខាងក្រៅថ្នាក់រៀនផងដែរ។ ក្រៅពីនេះក៏មានការលើកឡើងបន្ថែមទៀតថា ការអប់រំ គឺកិច្ចដំណើរការអភិវឌ្ឍការសិក្សាឬការបណ្តុះបណ្តាលកាយសម្បទា សតិបញ្ញានិងសីលធម៌តាមរយៈគ្រប់សកម្មភាពអប់រំ ការធ្វើឲ្យអ្នកសិក្សាទទួលបាននូវសំណុំចំណេះដឹង ជំនាញ សមត្ថភាព និងតម្លៃ។ ការធ្វើឲ្យមនុស្សក្លាយជាបុគ្គលល្អដែលមានប្រយោជន៍សម្រាប់ខ្លួនឯង គ្រួសារ សហគមន៍ សមាគម ប្រទេសជាតិ និងពិភពលោកទាំងមូល[៤]។

ជាការពិតណាស់ ការអប់រំគឺជាសកម្មភាពដែលមានគោលបំណងសំដៅដល់ការសម្រេចបាននូវគោលបំណងមួយចំនួន ដូចជាការបញ្ជូនចំណេះដឹង ឬការជំរុញជំនាញ និងចរិតលក្ខណៈ។ គោលបំណងទាំងនេះអាចរួមបញ្ចូលការអភិវឌ្ឍការយល់ដឹង សនិទានភាព សេចក្តីសប្បុរស និងភាពស្មោះត្រង់។ ទ្រឹស្តីខ្លះ តម្រូវឱ្យការអប់រំនាំឱ្យសិស្សមានភាពប្រសើរឡើងខណៈពេលដែលអ្នកផ្សេង ទៀតចូលចិត្តនិយមន័យអញ្ជាក្រឹតតម្លៃនៃពាក្យ។ ក្នុងន័យខុសគ្នាបន្តិច ការអប់រំក៏អាចសំដៅទៅលើដំណើរការនេះ មិនមែនសំដៅទៅលើផលិតផលនៃដំណើរការនេះទេះ ស្ថានភាពផ្លូវចិត្ត និងអាកប្បកិរិយាមនុស្សដែលមានការអប់រំ។

[៣] The process of teaching or learning, especially in a school or college, or the knowledge that you get from.

[៤] *ការធ្វើយតបសំណួរដែលថាតើអ្វីជាការអប់រំ?ចុះផ្សាយក្នុងគេហទំព័រ*Khsearch.com

ពាក្យស្វែកអប់រំ៖ *តាមរបងវិទ្យាល័យហ៊ុនសែនសេរីភាព ក្រុងតាខ្មៅ ខេត្តកណ្តាល*

២-២.ប្រវត្តិនៃការអប់រំ

២.២.១-ប្រវត្តិនៃការអប់រំសកលៈ

ក្នុងសៀវភៅដែលមានចំណងជើងថា«ការអប់រំនៅក្នុងប្រវត្តិសាស្ត្រពិភពលោក»របស់លោកម៉ាក ស ចនសាន់ (Mark S.Johnson) *និង លោក ភីតធឺ អិន*(Peter N.)*បានបង្ហាញពីរបៀបដែលជាចរន្តទូលំទូលាយនៅក្នុងប្រវត្តិសាស្ត្រឆ្លងដែនដោយផ្សារភ្ជាប់នឹងនិន្នាការនៅក្នុងស្ថាប័នអប់រំ និងការអនុវត្តការបង្រៀនតាមពេលវេលា។ ចាប់ពីសម័យបុរាណ និងសង្គមបុរាណរហូតដល់បច្ចុប្បន្ន សៀវភៅនេះបង្ហាញពីវិធីដែលការផ្លាស់ប្តូរក្នុងជីវិតខាងសាសនា និងបញ្ញា និងគំរូសេដ្ឋកិច្ចនៅក្នុងតំបន់សំខាន់ៗនៃពិភពលោកបានបង្កើតការអភិវឌ្ឍក្នុងការអប់រំ។ ចាប់តាំងពីសម័យក្រោយបុរាណមក ទំនាក់ទំនងឆ្លងវប្បធម៌ក៏មានឥទ្ធិពលលើការផ្លាស់ប្តូរផ្នែកអប់រំផងដែរ។ បើយោងតាមប្រវត្តិអប់រំចិន និងក្រិក ការអប់រំគឺកើតតាំងពីមុនគ្រឹស្តសករាជមកម្ល៉េះ។*

នៅក្នុងសង្គមមុនចេះអក្សរ នេះត្រូវបានសម្រេចដោយផ្ទាល់មាត់ និងតាមរយៈការធ្វើត្រាប់តាម។ ការនិទានរឿងបានឆ្លងកាត់ចំណេះដឹង គុណតម្លៃ និងជំនាញពីមួយជំនាន់ទៅមួយជំនាន់ទៀត។

សកម្មភាពបង្រៀនប្រវត្តិអប់រំនៃអាម៉ែរិក

(Image: History of The American Education System)

ខាងក្រោមនេះ ជាប្រវត្តិខ្លះនៃការអប់រំនៃប្រទេសមួយចំនួន៖

-ប្រទេសឥណ្ឌា៖

ការអប់រំនៅក្នុងឧបទ្វីបឥណ្ឌាបានចាប់ផ្តើមជាមួយនឹងការបង្រៀនអំពីជាតុប្រពៃណីដូចជា សាសនាឥណ្ឌា គណិតវិទ្យាឥណ្ឌា តក្កវិជ្ជាឥណ្ឌា ហិណ្ឌូ និងមជ្ឈមណ្ឌលពុទ្ធសាសនាដូចជានៅតាកសាស៊ីឡាបុរាណ(នៅប៉ាគីស្ថានសម័យទំនើប) និងណាឡាន់ដា (នៅឥណ្ឌា)។

ការអប់រំឥស្លាម បានជាប់ពាក់ព័ន្ធជាមួយនឹងការបង្កើតអាណាចក្រអ៊ីស្លាមនៅក្នុងឧបទ្វីបឥណ្ឌាក្នុងយុគសម័យកណ្តាលខណៈដែលការមកដល់នៃពួកអឺរ៉ុប ហើយក្រោយមកបាននាំយកការអប់រំលោកខាងលិចទៅកាន់ប្រទេសឥណ្ឌាអាណានិគម។

[5] https://www.routledge.com



Chanakyaជាទស្សនវិទូជាអ្នកច្បាប់ និងជាគ្រូដ៏អស្ចារ្យម្នាក់របស់ឥណ្ឌា (ស.វទី៤)

សាកលវិទ្យាល័យតាមបែបបស្ចិមប្រទេសជាច្រើនត្រូវបានបង្កើតឡើងក្នុងអំឡុងពេលនៃការគ្រប់គ្រងរបស់អង់គ្លេសក្នុងសតវត្សទី១៩។ ទីបំផុត វិធានការបន្តបន្ទាប់គ្នាពេញមួយពាក់កណ្តាលដើមសតវត្សទី២០ បានក្លាយជាមូលដ្ឋានគ្រឹះនៃប្រព័ន្ធអប់រំនៃសាធារណរដ្ឋឥណ្ឌា ប៉ាគីស្តាន និងភាគច្រើននៃឧបទ្វីបឥណ្ឌា។

-ប្រវត្តិសង្ក្រឹះ

ការអប់រំសម្រាប់ប្រជាជនក្រិក ត្រូវបាន "ប្រជាធិបតេយ្យ" យ៉ាងទូលំទូលាយនៅសតវត្សទី៥មុនគ.ស. ដែលទទួលឥទ្ធិពលដោយ សុកីស ផ្លាតូ និង អ៊ីសូក្រាត។ ក្រោយមក នៅសម័យហេលៃនីស្តីក (Hellenistic)[៦] នៃប្រទេសក្រិកបុរាណ ការអប់រំនៅក្នុងសាលាកាយសម្ព័ន្ធ (Gymnasium) ត្រូវបានគេចាត់ទុកថា មានសារៈសំខាន់សម្រាប់ការចូលរួមក្នុងវប្បធម៌ក្រិក។ តម្លៃនៃការអប់រំកាយចំពោះជនជាតិក្រិកនិងរ៉ូមបុរាណ មានលក្ខណៈពិសេសជាប្រវត្តិសាស្ត្រ។ ការអប់រំនៅប្រទេសក្រិកបុរាណមានពីរទម្រង់៖ ផ្លូវការនិងក្រៅផ្លូវការ។ ការអប់រំផ្លូវការ ត្រូវបានសម្រេចតាមរយៈការចូលរៀននៅសាលារដ្ឋ ឬត្រូវបានផ្តល់ដោយគ្រូដែលជួល។ ការអប់រំក្រៅប្រព័ន្ធត្រូវបានផ្តល់ដោយគ្រូដែលមិនមានប្រាក់ខែ ហើយបានកើតឡើងនៅក្នុងកន្លែងមិនសាធារណៈ។ ការអប់រំ គឺជាធាតុផ្សំដ៏សំខាន់នៃអត្តសញ្ញាណរបស់មនុស្ស។ ការអប់រំភាសាក្រិក ជាផ្លូវការជាចម្បងសម្រាប់បុរស និងមិនមែនជាទាសករ។ នៅក្នុងរដ្ឋប៉ូលីស(Polis) ភាគខ្លះ ច្បាប់ត្រូវបានអនុម័តដើម្បីហាមឃាត់ការអប់រំទាសករ។ អ្នករស់នៅស្ប៉ាតាឬប្រជាជនស្ប៉ាតា(Spartans) ក៏បានបង្រៀនតន្ត្រី និងរបាំផងដែរ ប៉ុន្តែក្នុងគោលបំណងបង្កើនភាពបត់បែនរបស់ពួកគេក្នុងនាមជាទាហាន។

---

[៦] ពេលដែលរីកចម្រើនដាលនៃវប្បធម៌ក្រិកពាសពេញមេឌីទែរ៉ាណេខាងកើតនិងអាស៊ីបន្ទាប់ពីការសោយទិវង្គត់ របស់អេឡិចសាន់ឌឺ(Alexander ស្តេចអេហ្សីប)។



Pythagoras *គឺជាទស្សនវិទូក្រិកម្នាក់ដែលគេស្គាល់ដោយសារការរួមចំណែករបស់គាត់ចំពោះគណិតវិទ្យា*

-ប្រទេសចិន៖

នៅឆ្នាំ២០០០មុនគ.ស ការអប់រំរបស់ចិន បានរីកចម្រើនដល់កម្រិតដែលបានបង្កើតឡើងជាពិសេសនូវកន្លែងសិក្សាសម្រាប់គោលបំណងនៃការរៀនសូត្រ។ ពីឆ្នាំ ៨០០ ទៅ ឆ្នាំ៤០០ មុនគ.ស. ប្រទេសចិនមានទាំង គួស្សៀរ (Guoxue:សាលារដ្ឋាភិបាល) និង ហ្សាំងស្សៀរ (Xiangxue: សាលាក្នុងស្រុក)។ ការអប់រំនៅក្នុងប្រទេសចិនបែបប្រពៃណី ត្រូវបានគ្រប់ដណ្តប់ដោយឃូជិ (keju:ប្រព័ន្ធប្រឡងសេវាស៊ីវិល)[7] ដែលបានចាប់ផ្តើមអភិវឌ្ឍប្រហែល ឆ្នាំ៤០០ នៃគ.សនិងកាន់តែរីកចម្រើននៅក្នុងរជ្ជកាលរាជវង្សតាំង (ឆ្នាំ ៦១៨ដល់៨៩៦នៃគ.ស)។

ឃូជិ(Keju) គឺជាកម្មវិធីស្រាវជ្រាវមួយដែលផ្អែកលើគោលគំនិតខុងជឺ។ ប្រព័ន្ធប្រឡងចូលបម្រើការងារស៊ីវិល(Keju) នេះនៅតែជាមធ្យោបាយដាច់ខាតមួយសម្រាប់មុខតំណែងរដ្ឋាភិបាលសម្រាប់ឥស្សរជនដែលមានការអប់រំរបស់ប្រទេសចិនអស់ រយៈពេលជាង១០០០ ឆ្នាំ[8]។

ខុង ជឺ គឺជាទស្សនវិទូ និង អ្នកនយោបាយចិនដែលជាឥស្សរជនជាន់ខ្ពស់ចិនហើយបានផ្តល់គំនិតអប់រំល្អក្នុងសង្គមចិន [9]។

២.២.២-ប្រវត្តិអប់រំនៃកម្ពុជា

នៅប្រទេសកម្ពុជា ការសិក្សាកើតមានឡើងតាំងពីសម័យព្រេងនាយ។ ប៉ុន្តែកាលពីដើមឡើយ មាននៅតែត្រកូលស្តេចប៉ុណ្ណោះ។

[7] civil service examination system

[8] *អានបន្ថែម៖*

https://education.stateuniversity.com/pages/269/China-HISTORY-BACKGROUND.html#ixzz7hXi8Mzb

[9] *ការបង្រៀន និងទស្សនវិជ្ជារបស់ ខុងជឺ គាំទ្រវប្បធម៌ និងសង្គមអាស៊ីបូព៌ា ដែលនៅតែមានឥទ្ធិពលនៅទូទាំងប្រទេសចិន និងអាស៊ីបូព៌ារហូតមកដល់សព្វថ្ងៃនេះ។*

រូបព្រះនាងឥន្ទ្រទេវី៖ (រូបភាពរបស់គេហទំព័រសាបាយ news.sabay.com.kh ចុះផ្សាយនៅថ្ងៃទី២៦ ខែសីហា ឆ្នាំ ២០២១)

ក្រោយៗមក ការសិក្សាអប់រំមានការធ្លាក់ចុះដូចជានៅសវទី១៨ និងសម័យខ្មែរក្រហមជាដើម។ អ្វីដែលយើងគួរកត់សម្គាល់គឺនៅ**ការអប់រំសម័យអាណាពីគមនិយមបារាំង** ប្រទេសកម្ពុជាមានទីតាំងស្ថិតនៅក្នុងជ្រោយឥណ្ឌូចិន ហើយបានស្ថិតនៅក្រោមរបបអាណាព្យាបាលបារាំង ចាប់ពីឆ្នាំ១៨៦៣ ដល់ឆ្នាំ១៩៥៣។ នៅពេលមុននឹងប្រទេសបារាំងចូលមកកាន់កាប់ប្រទេសកម្ពុជា ត្រូវបានទទួលរងនូវការគាបសង្កត់ពីសំណាក់ប្រទេសជិតខាងឥតឈប់ឈរ។ ទាក់ទងនឹងវិស័យអប់រំ របស់ប្រទេសកម្ពុជានាសម័យនោះ ការសិក្សាបានធ្វើឡើងនៅតាមទីវត្តអារាមដែលជាមជ្ឈមណ្ឌលវប្បធម៌ អរិយធម៌ដ៏សំខាន់របស់ខ្មែរ។ ការអប់រំតាមបែបប្រពៃណីនាពេលនោះ គឺបុត្រាបុត្រីស្តេច មន្ត្រីតូចធំសុទ្ធតែបានទទួលការសិក្សាបរិបូរណ៌។ ដោយប្រទេសកម្ពុជាទទួលឥទ្ធិពលពុទ្ធសាសនា និង ព្រាហ្មណ៍សាសនា។ ប្រទេសកម្ពុជាគោរពសាសនាទាំងពីរនេះ។ នៅសម័យហ្វូណន ការសិក្សាមានការរីកចម្រើនហើយ។ កិក្ខុសាមណេរបានទទួលលើករហូតដល់វិជ្ជាជាន់ខ្ពស់។ កាលនោះមានព្រះថេរអង្គខ្លះបានសិក្សាខ្ពង់ខ្ពស់ចេះវិជ្ជាច្រើនប្រការ។ ជាពិសេសទៀតនោះ នៅសម័យអង្គរការសិក្សាឡើងដល់ថ្នាក់ខ្ពស់បំផុត។ មានអ្នកប្រាជ្ញច្រើននាក់ អ្នកប្រាជ្ញពុទ្ធសាសនា អ្នកប្រាជ្ញសាសនាព្រាហ្មណ៍ ខ្លះជាបុរោហិត ខ្លះជាព្រះរាជគ្រូ។ ក្នុងរាជដំណាក់មានមហាវិទ្យាល័យជាន់ខ្ពស់សម្រាប់ព្រះរាជត្រកូលនៅក្នុងវត្តជ័យស្រីព្រះខាន់។ **ព្រះនាងឥន្ទ្រទេវី** ជាព្រះអគ្គមហេសីនៃ**ព្រះបាទជ័យវរ្ម័នទី៧**ជាទ្រង់ជាសាកលវិទ្យាធិការ[10]។

[10] កង ឱម ការអប់រំនិងការអភិវឌ្ឍនៅកម្ពុជា ទំព័រទី៤ ការផ្សាយរបស់វិទ្យាស្ថានមនុស្សសាស្ត្រ និងវិទ្យាសាស្ត្រសង្គម ២០២០។

ព្រះសង្ឃបានដើរតួនាទីយ៉ាងសំខាន់ជាគ្រូបង្រៀនជាអ្នកផ្ទេរចំណេះដឹងដល់កូនខ្មែរ។

ក្រោយសម័យទាមទារឯករាជ្យបានពីអាណានិគមបារាំង ថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣ វិស័យអប់រំនៅកម្ពុជាមានការរីកចម្រើនយ៉ាងខ្លាំងក្លា។ សាលារៀនកើតមាននៅគ្រប់វត្តអារាម និងទីប្រជុំជន។ ក្នុងសម័យសង្គមរាស្ត្រនិយម ព្រះករុណាព្រះបាទនរោត្តមសីហនុទ្រង់សព្វព្រះទ័យក្នុងការធ្វើឲ្យវិស័យអប់រំអភិវឌ្ឍដល់កម្រិតខ្ពស់តាំងពីថ្នាក់បឋមសិក្សារហូតដល់ឧត្តមសិក្សា។ ទីជនបទធ្ងាយដាច់ស្រយាលក៏មានសាលាបឋមសិក្សា និង អនុវិទ្យាល័យដែរ ហើយក្រោយពីផ្ដួលរំលំរបបប្រល័យពូជសាសន៍ប៉ុលពត ក្រោយថ្ងៃរំដោះ ៧ មករា ឆ្នាំ១៩៧៩ ប្រព័ន្ធអប់រំជាតិទាំងមូលត្រូវបានបង្កើត និង ស្តារឡើងវិញ តាមរយៈការប្រមែប្រមូលធនធានគ្រូ សិស្ស និស្សិត ដែលនៅសេសសល់ពីការកាប់សម្លាប់ក្រោមការឧបត្ថម្ភជំនួយបច្ចេកទេសពីបណ្តាប្រទេសសង្គមនិយមនានា។ គ្រូបង្រៀនដែលនៅរស់រានមានជីវិតមានចំនួនតិចតួចពេក នៅពេលនោះក្រសួងអប់រំក៏អនុវត្តគោលការណ៍ «អ្នកចេះច្រើនបង្រៀនអ្នកចេះតិចអ្នកចេះតិចបង្រៀនអ្នកមិនចេះ»។ គ្រូបង្រៀនគ្មានចំណេះដឹង និងខ្វល់គ្មានកោសល្យហៅថា «គ្រូចាត់តាំង»។ គ្រូបង្រៀនដែលនៅរស់រានមានជីវិតពីរបប ប៉ុល ពត ហៅថា "គ្រូចាស់ ក៏មានតួនាទីជាអ្នកផ្តល់ចំណេះដឹងគរុកោសល្យដល់-គ្រូចាត់តាំង»។ ដោយផ្អែកលើគោលការណ៍ ការសិក្សាត្រូវផ្សារភ្ជាប់នឹងជីវភាព។ ទាំងសៀវភៅសិក្សា និងកម្មវិធីសិក្សាសុទ្ធសឹងតាក់តែងនិងរៀបចំថ្មីទាំងអស់។

កំណែទម្រង់រចនាសម្ព័ន្ធនៃប្រព័ន្ធអប់រំនៅកម្ពុជា ការប្រែប្រួលផ្នែកនយោបាយ និងសង្គម-សេដ្ឋកិច្ច បានតម្រូវឱ្យមានកំណែទម្រង់ប្រព័ន្ធអប់រំជាបន្តបន្ទាប់។ នៅមុនឆ្នាំ ១៩៧៥ កម្ពុជារក្សាប្រព័ន្ធអប់រំមួយ តាមកេរដំណែលរបស់បារាំង មានរយៈពេលសិក្សា ១៣ឆ្នាំ (៦+៤+២+១) និង ធ្វើការកាត់ការប្រឡងធំៗ ៤ ឬ ៥ដង។ ក្រោយឆ្នាំ១៩៧៩ ផ្អែកតាមតម្រូវការបន្ទាន់របស់ប្រទេសជាតិ ក្រសួងអប់រំបានអនុវត្តប្រព័ន្ធអប់រំ១០ឆ្នាំ (៤+៣+៣) ហើយចាប់ផ្តើមពង្រីកឲ្យទៅជាប្រព័ន្ធ១១ឆ្នាំ (៥+៣+៣) ចាប់ពីឆ្នាំ១៩៨៦-១៩៩៦[99]។ ក្នុងបរិបទថ្មីរបស់ប្រទេសជាតិ ក្រសួងអប់រំយុវជន និង កីឡា បានបន្តកែលម្អប្រព័ន្ធអប់រំ តម្រង់កម្មវិធីសិក្សា ពាក់តែងសៀវភៅសិក្សាថ្មី បំប៉នសមត្ថភាពជាថ្មីដល់គ្រូបង្រៀន ដើម្បី

[99] កង ឌិម ការអប់រំនិងការអភិវឌ្ឍនៅកម្ពុជា ទំព័រទី៨ ការផ្សាយរបស់វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម ២០២០។

ត្រៀម លក្ខណៈផ្តើមអនុវត្តប្រព័ន្ធអប់រំ១២ឆ្នាំ (៦+៣+៣) នៅក្នុងឆ្នាំសិក្សា១៩៩៦-១៩៩៧ មកទល់បច្ចុប្បន្ន។ ប្រព័ន្ធអប់រំថ្មី បានបង្កើនម៉ោងសិក្សាសម្រាប់គ្រប់កម្រិតថ្នាក់រៀនបឋមសិក្សា។ រចនាសម្ព័ន្ធនៃប្រព័ន្ធអប់រំកម្ពុជាចុងក្រោយបានបង្កើនចំណេះដឹងសិស្សមួយកម្រិតទៀត គឺពី១១ឆ្នាំ ដល់១២ឆ្នាំ ដោយបន្ថែម១ឆ្នាំ ទៀតនៅបឋមសិក្សា។ ប្រព័ន្ធនេះបង្ហាញពីការចូលរៀនរបស់កុមារនៅអាយុ៣ឆ្នាំនៅមត្តេយ្យសិក្សារយៈពេល៣ឆ្នាំគឺ កម្រិតមត្តេយ្យកម្រិតទាបមត្តេយ្យកម្រិតមធ្យមនិងមត្តេយ្យ កម្រិតខ្ពស់ បន្ទាប់ពីមុនពេល គេចូលរៀននៅបឋមសិក្សា ដែលមានអាយុ៦ឆ្នាំ ឬយ៉ាងតិច៧២ខែ។ ប្រព័ន្ធនេះ ក៏មានភាពទន់ភ្លន់ផងដែរ ចំពោះសិស្សដែលបញ្ចប់អនុវិទ្យាល័យ អាចបន្តការសិក្សាទៅរកឯកទេសណាមួយតាមមជ្ឈមណ្ឌល ឬ សាលាបច្ចេកទេសនិងវិជ្ជាជីវៈសម្រាប់ឈានឆ្ពោះទៅទីផ្សារពលកម្មការងារ។

ក្រោយមក នៅដំណាក់កាលថ្មី ចាប់ពីឆ្នាំ ១៩៩៧ ក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាលកម្ពុជាដែលមាន**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុនសែន នាយករដ្ឋមន្ត្រី** វិស័យអប់រំមានការរីកចម្រើនយ៉ាងខ្លាំង។ សំណង់អគារសិក្សា អគារឆនឆាន អគារកាត់ដេរ សួនបន្លែ ឬបន្ទប់កុំព្យូទ័រ មានស្ទើរគ្រប់ទីកន្លែង ទោះបីសាលារៀននៅតំបន់ជនបទ ក៏ដូចទីក្រុងដែរ ពិសេសក្រសួងអប់រំ យុវជននិងកីឡា មានគោលនយោបាយបង្កើតវិទ្យាល័យឱ្យមានគ្រប់តាមឃុំ-សង្កាត់នៅទូទាំងប្រទេស។

រូបសិស្សានុសិស្សរៀនកុំព្យូទ័រនៅវិទ្យាល័យពេជ្រចិន្តា ស្ថិតក្នុងភូមិភ្នំតូច ឃុំពេជ្រចិន្តា ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង។

***រូបសិស្សានុសិស្សរៀបចំអគារកាត់ដេរ**៖វិទ្យាល័យប៊ុនរ៉ានី ហ៊ុនសែនអម្ពវ័នជំនីក ក្នុងស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ*

រូបអគារជនជាន៖ *វិទ្យាល័យប៊ុនរ៉ានីហ៊ុនសែនអម្ពវ័ន ជំនីក ក្នុងស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ*

រូបសួនបន្លែនិងសិស្សានុសិស្សប្រមូលផលបន្លែរបស់ខ្លួន៖ *នៅវិទ្យាល័យពេជ្រចិន្តា ស្ថិតក្នុងភូមិភ្នំតូច ឃុំពេជ្រចិន្តា ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង។*

រូបអគារជនជាន៖ *វិទ្យាល័យហ៊ុនសែនសេរីភាពក្នុងក្រុងតាខ្មៅ ខេត្តកណ្តាល*

កំណែទម្រង់ប្រព័ន្ធអប់រំនៅកម្ពុជាបានទទួលផ្លែផ្កាជាច្រើន ក្នុងការអភិវឌ្ឍអប់រំដូចរូបភាពខាងលើបញ្ជាក់ស្រាប់ មិនថាក្នុងទីក្រុងឬជនបទចុងកាត់មាត់ញកឬ តាមបន្ទាត់ព្រំដែនក៏មានការរីកចម្រើនបានទៅដល់ដែរ។

រូបភាពលោកគ្រូ-អ្នកគ្រូនិងថ្នាក់ដឹកនាំអប់រំ៖ *វិទ្យាល័យពេជ្រចិន្តា ជា**អង្គភាពឆ្នើម**ដែលជាអតីតម្ចាស់ជ័យលាភីសម្រាប់ការប្រកួតអង្គភាពឆ្នើមរបស់ក្រសួងអប់រំ។*

២-៣.ឧស្សាហ៍អ្នកអប់រំល្បីៗ៖

ការអប់រំបែបប្រពៃណីក្តី ការអប់រំទំនើបក្តីច្រើនអនុវត្តតាមទ្រឹស្តីល្អៗនៃអ្នកប្រាជ្ញឬអ្នកអប់រំ(Educators)។ តទៅនេះយើងសូមលើកយកគោលទ្រឹស្តីរបស់អ្នកប្រាជ្ញខ្លះៗមកបង្ហាញ៖

-**ព្រះពុទ្ធ៖**(Guatama Buddha)

ព្រះពុទ្ធ គឺជាសាស្ត្រាចារ្យដ៏ជំនាញមួយរូប ហើយព្រះអង្គមានជំនឿយ៉ាងមោះមុតក្នុងអានុភាពនៃពាក្យពោលដើម្បីបញ្ចុះបញ្ចូលមនុស្សឲ្យផ្លាស់ប្តូរបែបបទនៃជីវិតរបស់គេ,ឲ្យគេព្រមប្រកាន់យកតម្លៃថ្មីនិងស្វែងរកគោលដៅថ្មី។ នៅពេលមួយនោះកាលដែលគ្រូប្រដៅសាសនាជាបដិបក្ខទាំងឡាយបានពឹងផ្អែកលើមន្តអាគមនិងសកម្មភាព

អច្ឆរិយៈ ដើម្បីបញ្ចុះបញ្ចូល ប្រមូលសាវ័កឲ្យបានច្រើនសម្រាប់ក្រុមរបស់គេ, ព្រះពុទ្ធបានប្រកាន់យកតែអច្ឆរិយភាពតែមួយប្រភេទប៉ុណ្ណោះ គឺ "អច្ឆរិយភាពនៃការប្រៀនប្រដៅ" (អនុសាសនីបាដិហារិយៈ)។

សម្រង់សម្តីអាក់ឧចការបង្រៀន៖«*មហាសមុទ្រ មានរសតែមួយ អំបិលក៏មានរសដូច្នោះដែរ ការបង្រៀន និង ច្បាប់វិន័យនេះ ក៏មានរសតែមួយ គឺរសនៃសេរីភាព។ ការបង្រៀនរបស់ខ្ញុំមិនមែនជាទស្សនវិជ្ជាទេ។ វាជាលទ្ធផលនៃបទពិសោធន៍ផ្ទាល់... ការបង្រៀនរបស់ខ្ញុំ គឺជាមធ្យោបាយនៃការ អនុវត្ត មិនមែនជាអ្វីដែលត្រូវតម្កល់ឬថ្វាយបង្គំទេ។ ការបង្រៀនរបស់ខ្ញុំប្រៀបដូចជាក្បួនដែលប្រើសម្រាប់ឆ្លងទន្លេ។ គឺមានតែមនុស្សល្ងីល្ងើទេដែលជិះក្បួនជុំវិញ បន្ទាប់ពីគាត់បានទៅដល់ច្រាំងទន្លេហើយ*[12]*។*



*ក្រៅពីទស្សនៈនេះ ព្រះអង្គក៏បានមានពុទ្ធដីកាបន្ថែមថា៖«**ការសិក្សាគឺមិនចេះចប់ពីព្រោះជីវិតក៏មិនដែលឈប់សិក្សាដែរ**»*[13]*។*

-**លោកចាន់ណាក់យៈ**(Chanakya)

*ប្រហែលឆ្នាំ៣២១ មុនគ.ស. **ព្រះត្រូវចាន់ណាក់** បានជួយអធិរាជ Mauryan ដំបូងបង្អស់ Chandragupta ក្នុងការឡើងកាន់អំណាច ហើយត្រូវបានគេសរសើរយ៉ាងទូលំទូលាយថាបានដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្កើតអាណាចក្រ Maurya។ លោកជាគ្រូបង្រៀន ទស្សនវិទូ សេដ្ឋវិទូ អ្នកច្បាប់ ទីប្រឹក្សា Chandragupta Maurya ត្រូវបានគេស្គាល់ថា: តួនាទីលេចធ្លោនៅក្នុងមូលដ្ឋានគ្រឹះនៃអាណាចក្រ Maurya។*

សម្រង់សម្តី៖ «*ការអប់រំគឺជាមិត្តល្អបំផុត។ អ្នកពូកែដោយទង្វើរបស់អ្នក។ សេចក្តីល្អរបស់បុគ្គលនោះ ផ្សាយទៅគ្រប់ទិសទី។ សៀវភៅ គឺសម្រាប់អ្នកមានប្រាជ្ញា»។*

-**សាវីត្រីប៉ៃ ភូលេ** (Savitribai Phute)

សាវីត្រីប៉ៃ (Savitribai) *ជាអ្នកគ្រូបង្រៀន ជាទីប្រឹក្សា និងជាម្តាយនៃទ្រឹស្តីស្ត្រីនិយមរបស់ឥណ្ឌា។*

[12] http://www.azquotes.com

[13] Never stop learning, because life never stop teaching.

សាវីទ្រីប៉ៃ ភូលេ (Savitribai Phute:1831-1887)

សាវីទ្រីប៉ៃ(Savitribai) តែងតែនិយាយអំពីថាតើការអប់រំមានសារៈសំខាន់យ៉ាងណា។ នាងចង់ឲ្យ មនុស្សប្រុសស្រីគ្រប់រូបមានអប់រំ និង មានសេរីភាព។ ទោះបីជាមានការប្រឆាំងពីសង្គមក៏ដោយ នាងដឹងថា***ការអប់រំគឺជាមធ្យោបាយតែមួយគត់ដើម្បីសម្រេចបាននូវឯកភាពជ្យភាព***។ គំនិតដែលគួរអោយកត់សំគាល់បំផុតរបស់ **សាវីទ្រីប៉ៃ ភូលេ** (Savitribai Phule) គឺអំពីសមភាពវណ្ណៈ។ នាងមានចំណេះខ្ពង់ខ្ពស់ខ្លាំងជាងអ្នកផ្សេងៗទៀតដែលរស់នៅសម័យកាលនោះ។

សម្រង់សម្ដី៖ «*ការអប់រំគឺជាមធ្យោបាយតែមួយគត់ដើម្បីសម្រេចបាននូវឯកភាពជ្យភាព*»។

-អារីស្តូត(Aristotle)

អារីស្តូត ជាជនជាតិក្រិកបុរាណដែលដឹងរឿងមួយចំនួនអំពីការអប់រំ ធ្លាប់បានធ្វើការសង្កេតមួយដើម្បីដាក់ចំណាត់ថ្នាក់សមាជិកមួយចំនួននៃ PTA ។



លោកបានមានប្រសាសន៍ថា "***អ្នកដែលអប់រំកូនឲ្យបានល្អ គឺ មានកិត្តិយសជាងអ្នកដែលបង្កើតវា ទៅទៀត។ សម្រាប់អ្នកទាំងនេះបានផ្តល់ជីវិតតែមួយគត់ គឺសិល្បៈនៃការរស់នៅដ៏ល្អ***»។ ម្យ៉ាងវិញទៀត ឪពុកម្តាយជាអ្នកបង្កើតកូន គ្រូ ជាអ្នកប្រែក្លាយពួកគេទៅជាមនុស្ស។

-ចន ឌីវី (JOHN Dewey)

លោក ចន ឌីវី(JOHN Dewey)ជាទស្សនវិទូអាមេរិកដ៏ល្បីល្បាញម្នាក់នាសវទី២០។



លោក ចន ឌីវី (JOHN Dewey:1859-1952)

ឥទ្ធិពលរបស់ **ចន ឌីវី** លើការអប់រំត្រូវបានបង្ហាញឱ្យឃើញនៅក្នុងទ្រឹស្តីរបស់គាត់អំពីការរៀនសូត្រសង្គម។ គាត់ជឿថា ***សាលាគួរតែជាតំណាងនៃបរិយាកាសសង្គមហើយសិស្សរៀនបានល្អបំផុតនៅពេលស្ថិតនៅក្នុងសង្គមធម្មជាតិ***។

-**អ្រាហាម ម៉ាស្លូវ** (Abraham Maslow)

អ្រាហាម ម៉ាស្លូវ (Abraham Maslow) គឺជាអ្នកចិត្តវិទ្យាអាមេរិកាំង[១៤]ដ៏ល្បីល្បាញនា.ស.វទី២០។ លោកបានផ្តល់ជាទស្សន:ជាច្រើនទាក់ទងការអប់រំ ដោយលោកបានលើកឡើងថា «តម្រូវការកាន់តែច្រើនដែលត្រូវបានបំពេញ សិស្សនឹងរៀនកាន់តែច្រើន»។ ឋានានុក្រមរបស់ Maslow ត្រូវបានបង្កើតឡើងដោយ **អ្រាហាម ម៉ាស្លូវ** (Abraham Maslow) ក្នុងឆ្នាំ១៩៥៤ គឺជាវិធីនៃការរៀបចំតម្រូវការមូលដ្ឋានរបស់សិស្សនៅកម្រិតផ្សេងៗគ្នា[១៥]។

កម្រិតណាដែលធ្វើយតបកាន់តែច្រើន សិស្សនឹងរៀនកាន់តែច្រើន។



សម្រង់សម្តី៖ «មនុស្សដែលសម្រេចបិត្តដោយខ្លួនឯង អ្នកដែលឈានដល់កម្រិតនៃភាពចាស់ទុំ សុខភាពនិងការបំពេញដោយខ្លួនឯងមានច្រើនណាស់ក្នុងការបង្រៀនយើងដែលពេលខ្លះហាក់ដូចជាពូជមនុស្សខុសគ្នា»។

(Self-actualizing people, those who have come to a high level of maturation, health, and self-fulfillment, have so much to teach us that sometimes seem almost like a different breed of human beings.)

ការលើកឡើងពីសម្រង់សម្តីខ្លះៗរបស់អ្នកអប់រំ ឬទស្សនវិទូមួយចំនួនមកខាងលើនេះ

[១៤] https://www.verywellmind.com

[១៥] *សូមអានបន្ថែមនៅ*(McLeod, 2007)។

វាគ្រាន់ជាទស្សនទានដែលឆ្លុះបញ្ចាំងពីការខិតខំប្រឹងប្រឹងរួមគ្នានៃមនុស្សជាតិទូទៅលើកពផែនដីនេះៗគឺអ្នកទាំងអស់នេះហើយ ជាបុព្វបុរសអប់រំដែលជួយដល់ការកែប្រែសង្គមនិងអភិវឌ្ឍគោលគំនិតនានាឆ្ពោះមកសតវត្សថ្មីនេះ។

៣. ការអប់រំជាការងារទាំងអស់គ្នា

មនុស្សយើងម្នាក់ៗ មិនអាចរស់នៅផ្តាច់ចេញពីគ្នាបានទេ ហើយការប្រាស្រ័យទាក់ទងគ្នា ជាមធ្យោបាយមួយកសាងសុខដុមនីយកម្មសម្រាប់ពួកយើង។ការសិក្សា អប់រំ ជាមូលដ្ឋានចាំបាច់បំផុតក្នុងការជួយបុគ្គលម្នាក់ៗ គ្រួសារនីមួយៗ សហគមន៍មួយ ប្រទេសមួយ ក៏ដូចពិភពលោកទាំងមូលពោរពេញទៅដោយធនធានមនុស្ស ដើម្បីឆ្លើយតបនឹងការអភិវឌ្ឍប្រកបដោយចីរភាព និងនិរន្តរភាព។ នេះគឺជាកោសិកាសំខាន់ៗដែលត្រូវរួមគ្នាដើម្បីការអប់រំ៖

៣-១.គ្រួសារ

ឪពុកម្តាយ ជាគ្រូដើម(បុព្វាចារ្យ)របស់កូនប្រុសស្រី។ ម្តាយឪពុកឬឪពុកឬម្តាយ មានតួនាទីជាអាណាព្យាបាលលើសមាជិកដទៃក្នុងគ្រួសារ។ ពួកគេ ជាអ្នកទទួលខុសត្រូវលើសមាជិកគ្រួសារក្នុងការផ្តល់តម្រូវការចាំបាច់គ្រប់យ៉ាងឱ្យគ្រួសារ។ ការកិច្ចរបស់ម្តាយឪពុកចំពោះកូនមាន[16]៖

- ស្រឡាញ់ថ្នាក់ថ្នមនិងយោគយល់ដល់កូនទាំងអស់ស្មើៗគ្នា។
- ពង្រីកការអប់រំខាងស្មារតី សីលធម៌ វិន័យផ្ទាល់ខ្លួន និងសាសនា ។
- ត្រួតពិនិត្យពាល់សកម្មភាពនិងការគំសាន្ត។
- អប់រំកូនឱ្យឧស្សាហ៍ព្យាយាមអត់ធ្មត់ សន្សំសំចៃនិងមានជំនឿលើខ្លួនឯង។
- ជួយជំរុញ លើកទឹកចិត្តកូនឱ្យធ្វើកិច្ចការផ្ទះកិច្ចការសាលារៀននិងកិច្ចការសង្គម។ បង្រៀនគេពីការកិច្ចជាពលរដ្ឋនិងធ្វើឱ្យពួកគេមានគំនិតចេះស្រឡាញ់ជាតិ ។
- ផ្តល់ដំបូន្មានល្អៗ ចំពោះការអភិវឌ្ឍនិងសុខុមាលភាព ។
- ធ្វើជាគំរូល្អដល់ពួកគេ។ ទុកដាក់ពួកគេឱ្យមានគូស្រករតាមប្រពៃណីនិងចែកទ្រព្យសម្បត្តិប្រសិនបើម្តាយឪពុកមានលទ្ធភាព។

[16] ដកស្រង់ពីសៀវភៅសិក្សាសង្គម ថ្នាក់ទី៧ បោះពុម្ពដោយក្រសួងអប់រំ ទំព័រ១៩៣។

គ្រួសារមានវិន័យ កូនៗច្រើនទទួលបានការអប់រំបានល្អ និងសិក្សាបានខ្ពង់ខ្ពស់។

រូបម្តាយបង្រៀនកូន៖ រូបភាពមន្ទីរអប់រំខេត្តកំពង់ឆ្នាំង

៣-២.សហគមន៍-អង្គការពាក់ព័ន្ធ

ការសិក្សាមិនមែនចេះតែជោគជ័យឬសំណាងនោះទេ ។ពាក្យ«សំណាង»ជាពាក្យកម្ចាយបានមកពីពាក្យ «សាង» ហេតុនេះដើម្បីទទួលបានភាពជោគជ័យក្នុងការសិក្សាអប់រំ លុះត្រាតែមានផែនការអប់រំបណ្តុះបណ្តាលមួយត្រឹមត្រូវ ពិសេសនោះក៏ត្រូវមានគ្រូបង្ហោលឬអ្នកដឹកនាំអប់រំមានជំនាញច្បាស់លាស់។ ជាក់ស្តែងនៅកម្ពុជា យើងមានសហគមន៍ជាច្រើនចូលរួមសកម្មភាពអប់រំក្រៅពីប្រព័ន្ធអប់រំនៅសាលាសាធារណៈដោយមានសមាគមមាតាបិតាជាច្រើនៗក្រៅពីនេះ នៅក្នុងសៀវភៅមួយមានចំណងជើងថា«ប្រព័ន្ធអប់រំអាស៊ាន»[17] បានលើកឡើងពីបាវចនាអាស៊ានថា «ទស្សនវិស័យតែមួយ អត្តសញ្ញាណតែមួយ សហគមន៍តែមួយ»(One Vision, One Identity,One Community)។ តាមបាវចនាអាស៊ាននេះ មានន័យថា អាស៊ានជាសហគមន៍មួយដែលរួមគ្នាក្នុងការអភិវឌ្ឍវិស័យអប់រំរួមគ្នា។

ទន្ទឹមនឹងនេះ យើងក៏សង្កេតឃើញមានអង្គការជាច្រើនបម្រើឱ្យវិស័យអប់រំ ទាំងអង្គការជាតិ និងអង្គការអន្តរជាតិ ដូចជាអង្គការយូនីសែហ្វ (UNICEF)[18] អង្គការទស្សន:ពិភពលោក (World Vision) អង្គការយូណេស្កូ (UNESCO) សហគមន៍សិក្សាអែហ្វ ធូ អេស[19] ជាដើម។

---

[17] *សៀវភៅប្រព័ន្ធអប់រំនៅអាស៊ាន បោះពុម្ពដោយគ្រឹះស្ថានស្រាវជ្រាវនិងបោះពុម្ពហាតប៊ិក ២០២២។*

[18] *យូនីសែហ្វគឺជាអង្គការមួយក្នុងចំណោមអង្គការដំបងៗដែលបានវិលត្រឡប់មកប្រទេសកម្ពុជាវិញ ក្រោយការដួររលំរបបខ្មែរក្រហមក្នុងឆ្នាំ១៩៧៩ដើម្បីដឹកនាំកិច្ចខិតខំប្រឹងប្រែងធ្វើយតប ចំពោះស្ថានភាពអាសន្ន។*

[19] *ជាសាលាឯកជនមួយដែលបម្រើសេវាអប់រំអ្នករៀនខ្ពាយឱ្យរៀនប្រសើរឡើងវិញ។*

រូបសាលាមត្តេយ្យសហគមន៍ៈ នៅស្រុកបាកាន ខេត្តពោធិសាត់

៣-៣.សាលារៀន

សាលារៀន ជាអង្គភាពមួយផ្តល់សេវាកម្ម នៃការសិក្សា វិន័យ។សាលា ក៏ជាកន្លែងដែលក្មេងៗទៅរៀនដើម្បីទទួលបានការអប់រំ(a place where children go to be educated)[20]។ នៅលើពិភពលោកនេះ នៅប្រទេសនានា សាលាមានសាលារដ្ឋផង សាលាឯកជនផង ហើយប្រទេសខ្លះមានការវិវត្តខ្លាំងជាយូរមកហើយ ដោយគ្រាន់តែរូបភាពផ្សេងគ្នាប៉ុណ្ណោះ ដូចជា ករណីប្រទេសចិន[21] ដែលបានលើកមកខាងលើជាដើម។

នៅស.វ.ទី២១នេះ ចរន្តសកលភាវូបនីយកម្ម វិស័យអប់រំមានតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍធនធានមនុស្សឱ្យមានចំណេះដឹង និងសមត្ថភាពខ្ពស់ ភាពច្នៃប្រឌិត ស្មារតីសហគ្រិនភាព នវានុវត្តន៍ និងក្រមសីលធម៌ខ្ពស់ ដើម្បីរួមចំណែក លើកកម្ពស់ការអភិវឌ្ឍឧស្សាហកម្ម ដែលជួយបង្កើនកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និង បរិយាបន្ន តាមរយៈ ការធ្វើពិពិធកម្ម សេដ្ឋកិច្ច ការពង្រឹងភាពប្រកួតប្រជែង និងលើកកម្ពស់ផលិតភាព[22]។ ដូច្នេះសាលារៀន មិនថាសាលារដ្ឋឬសាលាឯកជនដើរតួនាទីសំខាន់ណាស់ក្នុងការរៀបចំផែនការអប់រំ ដែលជួយឱ្យលោកគ្រូ-អ្នកគ្រូឬអ្នកអប់រំ បញ្ជ្រាបចំណេះដឹងដល់សិស្ស-និស្សិតស្របតាមគោលនយោបាយអប់រំរបស់រដ្ឋាភិបាល ដែលមានក្រសួងអប់រំ យុវជន និងកីឡាជាសេនាធិការ។

៣-៤.ក្រសួងអប់រំ-ស្ថាប័នពាក់ព័ន្ធ

នៅតាមប្រទេសនានា ក្រសួងអប់រំរបស់ប្រទេសនោះ មានតួនាទីសំខាន់ក្នុងការអប់រំដោយគ្រប់គ្រងទាំងសាលារដ្ឋនិងសាលា

---

[20] *ដកស្រង់ពីវចនានុក្រម* Cambridge Dictionary *តាមគេហទំព័រ*dictionary.cambridge.org

[21] *ឆ្នាំ*800 *ទៅ ឆ្នាំ*400 *មុនគ.ស. ប្រទេសចិនមានទាំង គួស្ងៀរ*(Guoxue:*សាលារដ្ឋាភិបាល*)*និង*ហ្សាំងស្ងៀរ (Xiangxue: *សាលាក្នុងស្រុក*)។ *ការអប់រំនៅក្នុងប្រទេសចិនបែបប្រពៃណី ត្រូវបានគ្រប់ដណ្តប់ដោយយូដិ* (keju: *ប្រព័ន្ធប្រឡងសេវាស៊ីវិល*)[21] *ដែលបានចាប់ផ្តើមអភិវឌ្ឍប្រហែល ឆ្នាំ*400 *នៃគ.ស*និងកាន់តែរីកចម្រើននៅក្នុងរជ្ជកាលរាជវង្សតាំង(ឆ្នាំ៦១៨ដល់៨៩៦នៃគ.ស)។

[22] *សេដ្ឋកិច្ចអាស្រ័យការអប់រំ*(Economy based on Khnowledge)

ឯកជន។ ជាក់ស្តែងនៅប្រទេសព្រុយណេ រដ្ឋាភិបាលគ្រប់គ្រងទាំងសាលារដ្ឋនិងសាលាឯកជន[២៣]។

ចំពោះក្រសួងអប់រំកម្ពុជា កម្ពុជាត្រូវឆ្ងង់ដំណាក់កាលជាច្រើនទម្រាំមកដល់ថ្ងៃនេះ។ រដ្ឋាភិបាលមានបំណងជំរុញឱ្យកម្ពុជាឡើងឋានៈជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់ក្នុងឆ្នាំ២០៣០។ ប្រសិនបើកម្ពុជាមិនអាចដោះស្រាយបានទូរបញ្ហានានាដែលរាំងស្ទះដល់ការអភិវឌ្ឍប្រព័ន្ធអប់រំដ៏រឹងមាំនោះទេ កម្ពុជាអាចជាប់ផុងនៅក្នុងស្ថានភាពមានចំណូលកម្រិតមធ្យមតែមានកំណើនយឺត[២៤]។ តែបើយើងពិនិត្យដោយល្អិតល្អន់ ក្រសួងអប់រំមានការខិតខំប្រឹងប្រែងជាទីបំផុត ដោយរៀបចំកម្មវិធីជារៀងរាល់ឆ្នាំក្នុងការបម្រើឱ្យវិស័យអប់រំ ដូចជាសិក្ខាសាលាបំប៉នសមត្ថភាពការប្រឡងជ្រើសរើសគ្រូបង្រៀន ការចុះអនុស្សារណៈជាមួយអង្គការ ក្រុមហ៊ុន និងប្រទេសជាដៃគូជាដើម។

***រូបភាពនៃការចុះអនុស្សារណៈ**៖ ក្រសួងអប់រំ យុវជន និងកីឡា និងក្រុមហ៊ុនមិត្តហ្វូន បានចុះ**អនុស្សារណៈជាដៃគូយុទ្ធសាស្ត្រយូរអង្វែងដើម្បីសហការគ្នាលើគម្រោង "បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ក្នុងវិស័យអប់រំ" ដែលកិច្ចសហការនេះ ជាភាពជោគជ័យមួយបន្ថែមទៀតនៃកម្មវិធី "អ៊ីនធឺណែតសម្រាប់សាលារៀន" ដែលធ្លាប់បានសហការអនុវត្តនាពេលកន្លងមក។*

***រូបឯកឧត្តម ប្រាក់ កុសល** អគ្គលេខាធិការរងនៃគណៈកម្មាធិការជាតិគាំពារនិងអភិវឌ្ឍន៍កុមារតូច **ឯកឧត្តម សរ សុពុត្រា** អភិបាលរងនៃគណៈអភិបាលខេត្តកំពង់ស្ពឺ និង**លោកស្រី Staphanie Selle** ប្រធានអង្គការពិភពកុមារ*

[២៣] *សៀវភៅប្រព័ន្ធអប់រំនៅអាស៊ាន បោះពុម្ពដោយគ្រឹះស្ថានស្រាវជ្រាវនិងបោះពុម្ពហាតប៊ិក ២០២២។*

[២៤] *ស្រង់ពីសៀវភៅការអប់រំនៅកម្ពុជាឆ្នាំ២០១៥ បោះពុម្ពដោយវិទ្យាស្ថានបណ្តុះបណ្តាលនិងស្រាវជ្រាវដើម្បីអភិវឌ្ឍកម្ពុជា ទំព័រ១ ឆ្នាំ២០១៥។*

និងអភិវឌ្ឍន៍ៈ *បានអញ្ជើញជាអធិបតីក្នុងពិធីបើកវគ្គបំប៉ន ស្តីពីការងារគ្រប់គ្រង ការផ្តល់សេវាទារកដ្ឋានក្នុងសហគមន៍ និងចំណេះដឹងការអភិវឌ្ឍន៍កុមារតូចដល់គណៈកម្មការប្រឹក្សាយោបល់នឹងអ្នកពាក់ព័ន្ធ ដែលប្រព្រឹត្តទៅពីថ្ងៃទី6-7 ខែកញ្ញា ឆ្នាំ2022 នៅបណ្ណាល័យខេត្តកំពង់ស្ពឺ។*

មិនតែប៉ុណ្ណោះ ក្រសួងអប់រំក៏មានកិច្ចសហប្រតិបត្តិការជាដៃគូជាមួយស្ថាប័នផ្សេងៗទៀតផងដែរ ដែលរួមគ្នាលើកកម្ពស់ វិស័យអប់រំនៅកម្ពុជាៗកន្ទងមកនៅថ្ងៃទី២០ ខែមេសា ឆ្នាំ២០២០ ក្រសួងអប់រំ យុវជន និងកីឡា បានចេញសេចក្តីជូនដំណឹងស្តីពីកិច្ចសហការរវាងក្រសួងអប់រ យុវជន និងកីឡា ជាមួយក្រសួងព័ត៌មានក្នុងការរៀបចំផលិត និងផ្សព្វផ្សាយកម្មវិធី «ការសិក្សាពីចម្ងាយ» និង «ការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក»។ កម្មវិធីនេះបានជួយច្រើនដល់សិស្ស និស្សិត ពិសេស កុមារតូចៗក្នុងការសិក្សាពីចម្ងាយក្នុងបរិបទកូវីដ-១៩។

រដ្ឋមន្ត្រីក្រសួងអប់រំ និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន

ជារួម មិនថាក្រសួងអប់រំ ឬស្ថាប័នពាក់ព័ន្ធដទៃទៀតដូចជាក្រសួងនានាដែលជាសេនាធិការរដ្ឋាភិបាលទេ ក្រុមហ៊ុនឬដៃគូរអភិវឌ្ឍសុទ្ធតែខិតខំពុះពារ ដើម្បីការអប់រំដើម្បីទាំងអស់គ្នា ដូចជាករណីថ្មីៗនេះ ឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រីអប់រំ បានធ្វើជាអធិបតីក្នុងកិច្ចប្រជុំក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំតាមប្រព័ន្ធ Zoom ក្នុងគោលដៅពិនិត្យឡើងវិញអំពីការអនុវត្តអាទិភាពសកម្មភាពសំខាន់ៗនិងការបង្កើតយុទ្ធសាស្ត្រថ្មីដើម្បីប្រើប្រាស់ធនធានឱ្យបានសមស្របសម្រាប់កែលម្អការអប់រំនៅកម្ពុជា[២៥]*។*

រូបឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រីអប់រំ និងសកម្មភាពប្រជុំក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំតាមប្រព័ន្ធ Zoom

[២៥] *យោងតាមការចុះផ្សាយរបស់គេហទំព័រក្រសួងអប់រំ នៅថ្ងៃទី០៩សីហា ២០២២។*

សន្និដ្ឋាន

ជាចុងបញ្ចប់ ការអប់រំសម្រាប់ទាំងអស់មានគោលបំណងជាច្រើនត្រូវបានបង្កើតឡើងដើម្បីកសាងមូលដ្ឋានគ្រឹះសម្រាប់រចៀបវារៈនៃការអប់រំថ្មីៗ

តាមការលើកយកមកខាងលើ ទោះបីមានគំនិតរួមគ្នាយ៉ាងណាក៏ដោយ តែបើគ្មានធនៈក៏មិនអាចទៅរួចដែរ។ អ្វីៗផ្សារភ្ជាប់គ្នាទាំងអស់ ទាំងធនជាន មនុស្ស ទាំងគោលនយោបាយ ទាំងថវិកា ហើយបើយើងនិយាយពីថវិកាគឺផ្តោតលើសេដ្ឋកិច្ចនេះឯង។ ការបើកបេះដូងទទួលយករួមគ្នា ពិសេសការផ្តល់ការអប់រំដំបូងដោយឥតគិតថ្លៃ និងជាកាតព្វកិច្ចការអភិវឌ្ឍជំនាញដែលទាក់ទងនឹងការងារជារឿងចាំបាច់។ នោះវាអាចជួយជំរុញភាពជាពលរដ្ឋសកលលោក និងការអភិវឌ្ឍន៍ប្រកបដោយចីរភាព ការបង្កើនចំនួននៃគ្រូបង្រៀន និងគុណភាពនៃការអប់រំ ដោយមានការជានាថា រដ្ឋាភិបាលមានធនៈក្នុងការធ្វើនិងប្រកាន់ខ្ជាប់នូវការប្តេជ្ញាចិត្តផ្នែកហិរញ្ញវត្ថុចាំបាច់។ ចំណែកស្ថាប័ន ឬបុគ្គលពាក់ព័ន្ធ ត្រូវបំពេញការងារដោយសីលធម៌វិជ្ជាជីវៈខ្ពស់ ឈរលើការអភិវឌ្ឍការអប់រំរួមគ្នា។

ឯកសារពិគ្រោះ

1. កង ឱម ***ការអប់រំនិងការអភិវឌ្ឍនៅកម្ពុជា*** ការផ្សាយរបស់វិទ្យាស្ថានមនុស្សសាស្ត្រ និងវិទ្យាសាស្ត្រសង្គម ២០២០។
2. ក្រសួងអប់រំ ***ផែនទីបង្ហាញផ្លូវការអប់រំកម្ពុជាឆ្នាំ២០៣០គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤*** ២០១៩។
3. ក្រសួងអប់រំ ***សិក្សាសង្គមថ្នាក់ទី៧*** ២០១៩។
4. ក្រុមអ្នកសរសេរហាតប៊ុក ***ប្រព័ន្ធអប់រំអាស៊ាន*** ការផ្សាយរបស់គ្រឹះស្ថានស្រាវជ្រាវនិង បោះពុម្ពហាត ប៊ុក ២០២២។
5. ឃៀង សុធី ស្រ៊ីនីវាសា ម៉ាឌូ ឆែម រិទ្ធី ***ការអប់រំនៅកម្ពុជាឆ្នាំ២០១៥*** ការផ្សាយរបស់វិទ្យាស្ថានបណ្តុះបណ្តាលនិងស្រាវជ្រាវ ដើម្បីអភិវឌ្ឍកម្ពុជា ២០១៥។
6. ជួន ណាត ***វចនានុក្រមខ្មែរ*** ការផ្សាយដោយវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ១៩៦៧។

ប្រភពគេហទំព័រ

7. www.khsearch.om
8. http://www.moeys.gov.kh
9. www.cnbc.com
10. https://education.stateuniversity.com
11. https://www.verywellmind.com
12. https://www.azquotes.com
13. www.dictionary.cambridge.org
14. www.thefamouspeople.com
15. www.pinterest.com
16. https://www.routledge.com

តម្លៃនៃការអប់រំបរិយាបន្ន

The Value OF Inclusive Education

ដោយ៖ លោក **ប៉ាន់ សំណាង**

មន្ត្រីនាយកដ្ឋានវិទ្យាសាស្ត្រអប់រំ.វិទ្យាស្ថានមនុស្ស

សាស្ត្រនិងវិទ្យាសាស្ត្រសង្គម,រាជបណ្ឌិត្យសភាកម្ពុជា

១. សេចក្តីផ្តើម

*ការអប់រំ ចាប់បដិសន្ធិតាំងពីកូនៗនៅក្នុងផ្ទៃម្តាយ ដោយម្តាយឪពុកតែងនិទានរឿងអានអក្សរនេះនោះដែលបង្កប់នូវន័យល្អៗពោរពេញដោយខ្ចីមសារអប់រំដល់កូនៗរបស់ខ្លួនៗ ម្តាយនិងកូនមានសមានចិត្តឆ្លងគ្នា ពីព្រោះម្តាយជាអ្នកពរពោះៗពេលចម្រើនវ័យ ការអប់រំក៏ត្រូវធ្វើយតបតាមអាយុកាលដែរ។ កុមារតូចដែលកើតមកដល់អាយុក្រោម៦ឆ្នាំតែងមានការអភិវឌ្ឍលើផ្នែកពង្កាយនិងស្មារតីដែលជាតម្រូវការចាំបាច់សម្រាប់កុមារ។ ការលូតលាស់ទាំងនេះ តែងមានឥទ្ធិពលគ្នាទៅវិញទៅមក។ កុមារគ្រប់រូបមានសិទ្ធិទទួលបានការគាំទ្រពីឪពុកម្តាយនិងសហគមន៍របស់ពួកគេ ដើម្បីទទួលបានការរីកលូតលាស់រូបពង្កាយ ទទួលបានការសិក្សា និងមានការអភិវឌ្ឍបញ្ញាស្មារតីមុនដល់អាយុចូលសាលា ហើយពេលពួកគេដល់អាយុចូលរៀន ពួកគេត្រូវទទួលបានការសិក្សាតាមរយៈគ្រូបង្រៀននិងមិត្តរួមថ្នាក់។ នេះមានន័យថា វាជាការអប់រំរួមបញ្ចូលដោយសិស្សឬកុមារមានស្ថានភាពជីវិត និងលក្ខណៈខុសៗគ្នាទាំងជីវភាពរស់នៅទាំងការទំនុកបម្រុងផ្សេងៗរៀនថ្នាក់ជាមួយគ្នា។

ក្នុងបរិបទនៃការធ្វើសមាហរណកម្មក្នុងតំបន់និងពិភពលោក សេវាអប់រំកុមារតូចបានដើរតួនាទីយ៉ាងសំខាន់ក្នុងការធ្វើឱ្យសម្រេចគោលដៅនៃការអប់រំ[1]។ ការបណ្តុះបណ្តាលដោយវិធីសាស្ត្រគ្រប់ជ្រុងជ្រោយ (Holistic Approach) ក៏ដូចជាវិធីសាស្ត្រពីររួមគ្នា(Twin Track Approach) បានជួយយ៉ាងច្រើនដល់កុមារ

[1] ដកស្រង់ពីគេហទំព័រភ្នំពេញប៉ុស្តិ៍ចុះផ្សាយនៅថ្ងៃទី១ កញ្ញា ២០២១។

ក្នុងការអប់រំបរិយាបន្ន។ ដើម្បីធ្វើយតបនឹងគោលដៅអភិវឌ្ឍប្រកបដោយចីរភាពត្រង់ចំណុចទី៤ «ការអប់រំបរិយាបន្ន សមធម៌ គុណភាព និងការលើកកម្ពស់ការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា» ក្រសួងអប់រំ យុវជន និងកីឡា បានខិតខំយកចិត្តទុកដាក់លើកកម្ពស់គុណភាពអប់រំ ជាពិសេសបង្កើនអត្រាឡើងថ្នាក់ កាត់បន្ថយអត្រាបោះបង់ការសិក្សា ផ្តោតសំខាន់លើការអនុវត្តសិទ្ធិកុមារជាមូលដ្ឋានដែលជានាសមធម៌នៃការចូលរៀនរបស់កុមារគ្រប់ប្រភេទ[2]។ ប្រព័ន្ធបរិយាបន្នផ្តល់នូវការអប់រំប្រកបដោយគុណភាពប្រសើរជាងមុន សម្រាប់កុមារទាំងអស់និងជាឧបករណ៍សំខាន់ក្នុងការផ្ទាស់ប្តូរឥរិយាបថរើសអើងផងដែរ។ សាលារៀនផ្តល់នូវបរិបទសម្រាប់ទំនាក់ទំនងដំបូងរបស់កុមារជាមួយនឹងពិភពលោកខាងក្រៅគ្រួសាររបស់ពួកគេ ដោយអនុញ្ញាតឱ្យមានការអភិវឌ្ឍទំនាក់ទំនងសង្គម និងអន្តរកម្ម។ ការគោរពនិងការយល់ដឹងកើនឡើងនៅពេលដែលសិស្សមានសមត្ថភាព និងប្រវត្តិផ្សេងៗគ្នា លេងទំនាក់ទំនងសង្គម និងរៀនជាមួយគ្នា។ ទន្ទឹមនឹងនេះ ថ្នាក់អប់រំ បរិយាបន្ន គឺដាក់បញ្ចូលកុមារទាំងអស់ឱ្យរៀនជាមួយគ្នានៅក្នុងប្រព័ន្ធអប់រំទាំងក្នុង ឬក្រៅប្រព័ន្ធអប់រំដោយមិនបែងចែកអំពីភេទ អត្តចរិត កាយសម្បទា បញ្ញាស្មារតី ស្ថានភាពសង្គម ភាសាវប្បធម៌ សាសនា ឬលក្ខណៈផ្សេងៗទៀត។ មិនតែប៉ុណ្ណោះ ជនពិការភាព ក៏ជាកង្វល់ដ៏ធំធេងមួយដែលយើងមិនអាចមើលរំលងបានទេ។ នៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៦ មហាសន្និបាតអង្គការសហប្រជាជាតិ បានអនុម័តអនុសញ្ញាស្តីពីសិទ្ធិជនពិការ ដើម្បីធានាថាជនមានពិការភាពក៏ដូចជាមនុស្សជាតិទាំងអស់ត្រូវទទួលបានសិទ្ធិដូចគ្នា រួមមានសិទ្ធិពលរដ្ឋ សិទ្ធិនយោបាយ សិទ្ធិសេដ្ឋកិច្ចសង្គម និងសិទ្ធិវប្បធម៌ ដោយគ្មានការបែងចែកនិងរើសអើង[3]។ ប្រទេសកម្ពុជាបានឆ្លងកាត់សង្គ្រាម និងរបបប្រល័យពូជសាសន៍ ដែលបានបន្សល់ទុកនូវផលវិបាកជាច្រើនរួមទាំងជនមានពិការភាពផងដែរ។

ពីឆ្នាំ២០០៨-២០១៨ ក្រសួងបាន អនុវត្តគោលនយោបាយស្តីពីការអប់រំកុមារពិការដែលជានាចំពោះកុមារ និងយុវជនកម្ពុជាទាំងអស់ឱ្យ

[2] ដកស្រង់ពីឯកសារស្តីពីការអប់រំបរិយាបន្ន សម្រាប់គ្រូសិស្ស ឆ្នាំ២០១៧។

[3] ក្រសួងអប់រំ យុវជន និងកីឡា គោលនយោបាយស្តីពីការអប់រំបរិយាបន្ន ទំព័រ១ ឆ្នាំ២០១៨។

មានឱកាសស្មើៗគ្នាក្នុងការទទួលបានការអប់រំ កម្រិតមូលដ្ឋាន និងក្រៅប្រព័ន្ធដោយមិនប្រកាន់កម្រិតជីវភាព គេទ ភូមិសាស្ត្រ កាយសម្បទា និងជនជាតិឡើយ។

ក្នុងន័យនេះ ការអប់រំបរិយាបន្នជាការអប់រំរួមបញ្ចូលដែលធានាគុណភាពសិក្សាធិការដល់មនុស្សគ្រប់រូបគ្រប់ពណ៌សម្បុរមិនថាមានឬក្រ ស្ថានភាពរស់នៅបែបណានោះទេ។ ការអភិវឌ្ឍកាយសម្បទានិងបញ្ញាស្មារតីដល់ជនគ្រប់រូប ជាគន្លឹះចាំបាច់បំផុតក្នុងការអប់រំសម្រាប់ទាំងអស់គ្នា។

២. ប្រវត្តិខ្លះៗនៃការអប់រំ

២.១.ប្រវត្តិអប់រំ៖

កាលដើមឡើយ រាប់រយពាន់ឆ្នាំ កុមារបានអប់រំខ្លួនឯងតាមរយៈការលេង និងការរុករកដោយខ្លួនឯង[៤]។ នៅក្នុងសង្គមមុនចេះអក្សរនេះត្រូវបានសម្រេចដោយផ្ទាល់មាត់ និងតាមរយៈការធ្វើត្រាប់តាម។ ការនិទានរឿងបានឆ្លងកាត់ចំណេះដឹង គុណតម្លៃ និងជំនាញពីមួយជំនាន់ទៅមួយជំនាន់ទៀត។

នៅក្នុងប្រវត្តិសាស្ត្រមនុស្សជាតិជាច្រើនសតវត្សន៍ដែលឈានទៅដល់សង្គមកសិកម្ម ជាង ១០ ០០០ឆ្នាំមុន កុមារបានរៀនជំនាញដែលពួកគេត្រូវការសម្រាប់ភាពជោគជ័យក្នុងជីវិតមនុស្សពេញវ័យតាមរបៀបដែលខុសពីអ្វីដែលពួកគេចង់បាននៅពេលក្រោយ។

ការអប់រំមានន័យថា ការសិក្សាដើម្បីទទួលបានចំណេះដឹងនិងការយល់ដឹងកាន់តែស៊ីជម្រៅលើមុខវិជ្ជាផ្សេងៗដែលត្រូវយកមកអនុវត្តក្នុងជីវិតប្រចាំថ្ងៃ។ ការអប់រំ គឺកិច្ចដំណើរការអភិវឌ្ឍការសិក្សាឬការបណ្តុះបណ្តាលកាយសម្បទា សតិបញ្ញា និងសីលធម៌តាមរយៈគ្រប់សកម្មភាពអប់រំ។ ការធ្វើឲ្យអ្នកសិក្សាទទួលបាននូវសំណុំចំណេះដឹង ជំនាញ សមត្ថភាពនិងតម្លៃ។ ជាការពិតណាស់ ការអប់រំគឺជាសកម្មភាពដែលមានគោលបំណងសំដៅដល់ការសម្រេចបាននូវគោលបំណងមួយចំនួន ដូចជាការបញ្ជូនចំណេះដឹង ឬការជំរុញជំនាញ និងចរិតលក្ខណៈ។ ជាក់ស្តែងដូចជាប្រទេសចិន ការអប់រំបែបប្រពៃណី ត្រូវបានគ្រប់ដណ្តប់ដោយឃូជិ (keju:ប្រព័ន្ធប្រឡងសេវាស៊ីវិល)[៥] ដែលបានចាប់ផ្តើមអភិវឌ្ឍប្រហែលឆ្នាំ400នៃគ្រឹស្តសករាជនិងកាន់តែរីកចម្រើននៅក្នុងរជ្ជកាលរាជវង្សតាំង(ឆ្នាំ៦១៨ដល់៨៩៦នៃ

[៤] https://www.psychologytoday.com

[៥] civil service examination system

គ.ស)[៦]។ នាអតីតកាល ចិនមានប្រព័ន្ធឃូជី ហើយសកលលោកក៏ដូចជាប្រទេសនីមួយៗ ក៏មានកំណែទម្រង់ប្រព័ន្ធអប់រំដូចគ្នាក្នុងការពង្រឹងគុណភាពអប់រំឱ្យមានប្រសិទ្ធភាពនិងប្រសិទ្ធផលដោយក្នុងនោះ មានប្រព័ន្ធអប់រំឌីជីថល[៧] ប្រព័ន្ធអប់រំពិសេស និងប្រព័ន្ធអប់រំបរិយាបន្នជាដើម។

២.២.ប្រភេទនៃប្រព័ន្ធអប់រំ

ពាក្យ "ប្រព័ន្ធអប់រំ" រួមមានស្ថាប័នទាំងអស់ដែលពាក់ព័ន្ធនឹងការអប់រំរបស់កុមារ យុវជន និងមនុស្សពេញវ័យ ជាពិសេសមត្តេយ្យសិក្សា បឋមសិក្សា អនុវិទ្យាល័យ មធ្យមសិក្សាទុតិយភូមិ ឬកន្លែងហាត់ប្រាណ សាលាវិជ្ជាជីវៈ និងនៅកម្រិតឧត្តមសិក្សាពហុបច្ចេកទេស សាកលវិទ្យាល័យ និងស្ថាប័នអប់រំសម្រាប់មនុស្សពេញវ័យផងដែរ ដូចជា មជ្ឈមណ្ឌលអប់រំមនុស្សពេញវ័យជាដើម។

រចនាសម្ព័ន្ធនៃប្រព័ន្ធអប់រំមានភាពខុសប្លែកគ្នារវាងប្រជាជាតិនានា ហើយជួនកាលផងដែរនៅក្នុងប្រជាជាតិក្នុងតំបន់ឬរដ្ឋផ្សេងៗគ្នា (ឧទាហរណ៍នៅប្រទេសអាល្លឺម៉ង់)។ ភាពខុសគ្នាជាក់លាក់ទាក់ទងនឹងសំណួរថាតើនៅពេលណាដែលក្មេងឬកុមារត្រូវបានបំបែក និងជ្រើសរើសឱ្យទៅសាលារៀនផ្សេងៗគ្នា។ ការបែងចែកទៅជាប្រភេទសាលាមួយ ឬច្រើនអាចជាការពិតបន្ទាប់ពីបញ្ចប់ការសិក្សារយៈពេល 4 ឆ្នាំ ឬក្រោយសាលាបឋមសិក្សា ហើយនៅក្នុងប្រព័ន្ធមួយចំនួន លទ្ធភាពត្រូវបានបើកឱ្យលឿនបំផុតដើម្បីបន្តក្នុងផ្លូវផ្សេងៗគ្នានៅចុងបញ្ចប់នៃប្រភេទនីមួយៗនៃសាលា[៨]។ នៅក្នុងប្រព័ន្ធមួយចំនួន សាលារៀនមានភាពទូលំទូលាយជាងយ៉ាងហោចណាស់ក្នុងអំឡុងពេលប្រាំបួនឆ្នាំដំបូង។ ទោះបីជាប្រព័ន្ធអប់រំផ្សេងៗគ្នាប្រែប្រួលទៅតាមការជ្រើសរើស ឬសិក្សាទូលំទូលាយក៏ដោយ ក៏ប្រព័ន្ធទាំងអស់អាចត្រូវបានចាត់ថ្នាក់តាមស្តង់ដារអន្តរជាតិនៃការអប់រំ (ISCED) ដល់កម្រិតជាក់លាក់ក្នុងលក្ខខណ្ឌនៃការអប់រំផ្លូវការ និងក្រៅប្រព័ន្ធ៖ការអប់រំកុមារតូច(កម្រិត 0) ការអប់រំបឋមសិក្សា(កម្រិតទី១) មធ្យមសិក្សាទុតិយភូមិ (កម្រិតទី២) ការអប់រំមធ្យមសិក្សាទុតិយភូមិ (កម្រិតទី៣) ការអប់រំក្រោយមធ្យមសិក្សាមិន

[៦] ដកស្រង់និងកែសម្រួលពីអត្ថបទ «ការអប់រំ ជាកិច្ចការទាំងអស់គ្នា» ប៉ាន់ សំណាង ការផ្សាយរបស់រាជបណ្ឌិត្យសភាកម្ពុជា ឆ្នាំ២០២២។

[៧] ថ្មីៗនេះ ក្រសួងអប់រំ បានសរសេរសៀវភៅមួយ«ការអប់រំឌីជីថល៖បិវត្តកម្មឌីជីថលនៅក្នុងអេកូស៊ីស្តែមនៃការអប់រំ» របស់ឯកឧត្តមបណ្ឌិត សាន វឌ្ឍនា។

[៨] https://www.sutori.com

មែនឧត្តមសិក្សា (កម្រិតទី៤) ការអប់រំកម្រិតឧត្តមសិក្សារយៈពេលខ្លី(កម្រិតទី៥) បរិញ្ញាបត្រ ឬសញ្ញាបត្រដែលមានតម្លៃស្មើ (កម្រិត៦) អនុបណ្ឌិត ឬសមមូល (កម្រិតទី៧) បណ្ឌិត ឬសមមូល (កម្រិតទី៨) និងមិនត្រូវបានចាត់ថ្នាក់នៅកន្លែងផ្សេងទៀត(កម្រិតទី៩)។ ការស្រាវជ្រាវនេះ យើងធ្វើការស្រាវជ្រាវជាពិសេសលើមនុស្សពេញវ័យដែលមានអាយុពី១៨ទៅ២៩ឆ្នាំ ដូច្នេះស្ថាប័ន និងស្ថាប័ន អប់រំផ្លូវការ និងក្រៅផ្លូវការដែលទាក់ទងនឹងក្រុមអាយុនេះភាគច្រើនស្ថិតនៅក្នុងកម្រិតមធ្យមសិក្សា និងឧត្តមសិក្សា ព្រមទាំងកម្រិតអប់រំមនុស្សពេញវ័យផងដែរៗនេះ មានន័យថា កម្រិត ISCED កម្រិត ៣,៤,៥និង៨ មានចំណាប់អារម្មណ៍ជាពិសេសទាក់ទងនឹងការផ្ទាស់ប្តូរពីសាលារៀនទៅកន្លែងធ្វើការ ឬការបណ្តុះបណ្តាលវិជ្ជាជីវៈ ឬពីសាលារៀនទៅការអប់រំបន្ថែមរៀងៗខ្លួន ដោយហេតុនេះទាក់ទងនឹងចំណុចនៃការផ្ទាស់ប្តូរទាំងនេះជាស្ថានភាពនៃភាពងាយរងគ្រោះផ្នែករចនាសម្ព័ន្ធ។

ដូច្នេះ គំនិតនៃប្រព័ន្ធអប់រំ ជាការរួមបញ្ចូលយ៉ាងពេញលេញ ដែលធ្វើឲ្យសិស្សឆ្ងាត់ត្រូវបានចុះខ្សោយ។ ការបែងចែកប្រភេទនៃប្រព័ន្ធអប់រំដោយយោងទៅតាមការធ្វើមាត្រដ្ឋាន និងស្តង់ដារ។ ទោះជាយ៉ាងណាក៏ដោយ គុណលក្ខណៈទាំងនេះគួរតែត្រូវបានចាត់ទុកថាជាការវាយតម្លៃ[៩]។

៣. តម្លៃនៃការអប់រំបរិយាបន្ន

ពេលដែលនិយាយពី«ការអប់រំបរិយាបន្ន» ហាក់ដូចជាថ្មី មិនធ្លាប់លឺ តែការអនុវត្តបានដើរមុនបាត់ទៅហើយ ដូចកូនសិស្សខ្លះមានឈ្មោះសុទ្ធតែប្រើភាសាបាលីសំស្ក្រឹត[៩០]តែខ្លួនមិនស្គាល់និងចេះពាក្យបាលីសំស្ក្រឹតនោះដែរ។ តទៅនេះ សូមអនុញ្ញាតិសិក្សាស្វែងយល់ពីការអប់រំបរិយាបន្នដូចខាងក្រោម៖

៣.១.បរិយាបន្ន

តើបរិយាបន្ន ជាអ្វី? តាម **អ៊ិក្ខុហាក់ សៀងហៃ** ព្រះអង្គមានសង្ឃដីកាបកស្រាយថា ពាក្យ«***បរិយាបន្ន***» បានមកពី **«បរិ+ យ+ អា+ បទ+ ត»** មានន័យថា រួមបញ្ចូលគ្នា ហើយត្រូវនឹងពាក្យអង់គ្លេស (Inclusiveness) [៩១]។បើតាមវចនានុក្រម Oxfort គឺ បរិយាបន្ន ជាការអនុវត្តឬជាគោលនយោបាយក្នុងការផ្តល់ជូននូវឱកាស

[៩] https://www.young-adulllt.eu

[៩០] ឈ្មោះដូចជា«បុប្ផា វិចិត្រ រាជិនី សុខា.....»សុទ្ធតែជាពាក្យបាលីសំស្ក្រឹត។

[៩១] ដកស្រង់ពីឆេណេលយូធូបHak Sienghai។

និងជនជាតិស្មើៗគ្នាសម្រាប់មនុស្សជាតិដែលគេមើលរំលងដោយការទាត់ចោលឬការកាត់បន្ថយដូចជាអ្នកដែលមានពិការភាពផ្លូវកាយឬផ្លូវចិត្តឬផ្តោតលើជនជាតិភាគតិច។ (Inclusiveness: the practice or policy of providing equal access to opportunities and resources for people who might otherwise be excluded or marginalized, such as those having physical or mental disabilities or belonging to other minority groups.)

ទស្សន:មួយទៀតបានលើកឡើងថា«បរិយាបន្ន ជាការដាក់បញ្ចូលសមាសភាគផ្សេងៗក្នុងប្រព័ន្ធឬកន្លែងតែមួយ»[12]។

៣.២.ការអប់រំបរិយាបន្ន

ដើម្បីធ្វើយតបនឹងគោលដៅអភិវឌ្ឍប្រកបដោយចីរភាពត្រង់ចំណុចទី៤«ការអប់រំបរិយាបន្ន សមធម៌ គុណភាព និងការលើកកម្ពស់ការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា» ក្រសួងអប់រំ យុវជន និងកីឡា បានខិតខំយកចិត្តទុកដាក់លើកកម្ពស់គុណភាពអប់រំ ជាពិសេសបង្កើនអត្រាឡើងថ្នាក់ កាត់បន្ថយអត្រាបោះបង់ការសិក្សា ផ្តោតសំខាន់លើការអនុវត្តសិទ្ធិកុមារជាមូលដ្ឋានដែលជានាសមធម៌នៃការចូលរៀនរបស់កុមារគ្រប់ប្រភេទ។ មិនតែប៉ុណ្ណោះ ក្រសួងក៏បានរៀបចំគោលនយោបាយស្តីពីការអប់រំបរិយាបន្នដែលមានចក្ខុវិស័យ គោលបំណង គោលដៅ យុទ្ធសាស្ត្រផែនការសកម្មភាព និងការត្រួតពិនិត្យវាយតម្លៃច្បាស់លាស់និងត្រឹមត្រូវ។

ក.ការស្វែងយល់ពីការអប់រំបរិយាបន្ន

អង្គការ UNESCO ឱ្យនិយមន័យការអប់រំបរិយាបន្ន គឺជា «វិធីសាស្ត្រសកម្មនៃការធ្វើយតបដោយវិជ្ជមានទៅកាន់ភាពចម្រុះគ្នានៃសិស្ស និងការមើលឃើញនូវភាពខុសគ្នារបស់សិស្សមិនមែនជាបញ្ហា ប៉ុន្តែជាឱកាសសម្រាប់ធ្វើឱ្យការសិក្សាប្រសើរឡើង»។

ជាតុផ្សំដែលចាំបាច់នៅក្នុងការកំណត់និយមន័យការអប់រំបរិយាបន្ន៖

[12] ស្រង់ពីគេហទំព័រwww.sangapac,com

- ការអប់រំបរិយាបន្ន ជាការស្វាគមន៍ភាពចម្រុះ
- ជាការផ្តល់អត្ថប្រយោជន៍ដល់សិស្សទាំងអស់មិនមែនផ្តោតលើសិស្សដែលត្រូវផាត់ចេញ
- ការដាក់បញ្ចូលកុមារដែលដែលមានអារម្មណ៍ថាត្រូវបានផាត់ចេញទៅក្នុងសាលារៀន
- ការទទួលបានការអប់រំដោយស្មើភាព
- ការផ្តល់ដោយជាក់លាក់ដល់ក្រុមកុមារដោយមិនផាត់ពួកគេចេញ។

ក្រៅពីនេះ នៅមានជាតុផ្សំសំខាន់៤ទៀតនៅក្នុងការកំណត់បញ្ញត្តិនៃការអប់រំបរិយាបន្ន។ ជាតុទាំង៤មានដូចខាងក្រោម៖

- ការអប់រំបរិយាបន្ន គឺជាដំណើរការស្វែងរកមិនមានទីបញ្ចប់ ដើម្បីរុករកមធ្យោបាយកាន់តែប្រសើរនៃការឆ្លើយតបទៅនឹងភាពចម្រុះ។វាគឺជាការរៀនពីរបៀបរស់នៅជាមួយភាពខុសគ្នានិងរៀនពីភាពខុសគ្នា។ការធ្វើបែបនេះ ភាពខុសគ្នាត្រូវបានមើលឃើញថា កត្តាជំរុញកាន់តែវិជ្ជមានសម្រាប់ជំរុញការរៀននៅក្នុងចំណោមកុមារ និងមនុស្សពេញវ័យ។
- ការអប់រំបរិយាបន្ន គឺជាការកំណត់អត្តសញ្ញាណនិងលុបបំបាត់ឧបសគ្គ។ ដូច្នោះ វាទាក់ទងនឹងការប្រមូល រៀបចំនិងវាយតម្លៃព័ត៌មានពី ធនធានច្រើនយ៉ាងដើម្បីរៀបចំផែនការសម្រាប់ការធ្វើឱ្យប្រសើរនូវគោលនយោបាយនិងការអនុវត្ត។
- ការអប់រំបរិយាបន្នទាក់ទងវត្តមាន ការចូលរួម និងការសម្រេចរបស់សិស្សទាំងអស់។ «វត្តមាន»សម្តៅដល់ទីកន្លែងដែលកុមារត្រូវបានអប់រំ និងការមករៀនទៀងទាត់។ «ចូលរួម» ទាក់ទងទៅនឹងគុណភាពបទពិសោធន៍របស់សិស្ស ដូច្នេះត្រូវរួមបញ្ចូលទស្សនៈរបស់ពួកគេ។ ចំណែក«ការសម្រេច» គឺ សម្តៅដល់លទ្ធផលនៃការសិក្សានៅក្នុងកម្មវិធីសិក្សាទាំងមូល មិនមែនគ្រាន់តែលទ្ធផលប្រឡងនោះទេ។
- ការអប់រមបរិយាបន្ន ទាក់ទងនឹងការផ្តោតជាពិសេសលើក្រុមសិស្សដែលងាយរងគ្រោះពីការបាត់បង់ឱកាស ការផាត់ចេញ ឬបរាជ័យ។នេះបញ្ជាក់ពីការទទួលខុសត្រូវសីលធម៌ ដើម្បីជានាថាក្រុមដែលងាយរងគ្រោះបំផុតត្រូវបានត្រួតពិនិត្យតាមដានដោយយកចិត្តទុកដាក់ និងនៅក្នុងករណីចាំបាច់ វិធានការត្រូវបានធ្វើឡើងដើម្បី

ជានាវត្តមាន ការចូលរួម និងការសម្រេច របស់ពួកគេនៅក្នុងប្រព័ន្ធអប់រំ[១៣]។

***រូបភាពវេទិកាថ្នាក់ជាតិលើកទី៨ស្តីពីការអប់រំបរិយាបន្ន**ៈស្តីពី«បង្កើនការវិនិយោគលើការកសាងសមត្ថភាពគ្រូបង្រៀននិងគណៈគ្រប់គ្រងសាលារៀនអំពីការអប់រំបរិយាបន្នសម្រាប់កុមារមានពិការភាព»រៀបចំនៅរាជធានីភ្នំពេញថ្ងៃ១១-១២ ខែធ្នូ ឆ្នាំ២០១៩*

ខ.បរិយាកាសសាលារៀនបរិយាបន្ន

រូបខាងក្រោមជាបរិយាកាសសាលារៀនបរិយាបន្ន៖

គ.វិធីបង្រៀនអប់រំបរិយាបន្ន

គ.១.ការបង្ហាញវិធីបង្រៀន

វិធីបង្រៀនការអប់រំបរិយាបន្នមិនទទួលយក ឬបដិសេធ៖

- *ទស្សន:ដែលគិតថាកុមារមានសមត្ថភាពថេរតែមួយ*

[១៣] *ក្រសួងអប់រំ យុវជន និងកីឡា ឯកសារស្តីពីការអប់រំបរិយាបន្ន ទំព័រ១០ ឆ្នាំ២០១៧។*

- ការរៀនរបស់កុមារពេលបច្ចុប្បន្នអាចយកទៅព្យាករណ៍សក្តានុពលនាពេលអនាគត
- បញ្ញាអាចកំណត់តាមរយៈពេលធ្វើតេស្តផ្អែកលើជំនាញតក្កវិជ្ជា គណិតវិទ្យា ទាញហេតុផលៗផ្ទុយមកវិញវិធីបង្រៀនការអប់រំបរិយាបន្នមានជំនឿថា៖
- សមត្ថភាពកុមារគ្រប់គ្នាក្នុងការរៀនមានការផ្លាស់ប្តូរ
- អ្វីដែលគ្រូបង្រៀនជ្រើសរើសធ្វើ ឬមិនធ្វើនាពេលបច្ចុប្បន្នអាចផ្លាស់ប្តូរសមត្ថភាពរៀនរបស់កុមារនាពេលអនាគត។

វិធីបង្រៀនការអប់រំបរិយាបន្នអាចត្រូវរៀបចំ និងអនុវត្តនៅក្នុងរបៀបដែលពាក់ព័ន្ធមានន័យគ្រប់គ្រាន់និងអាចទទួលយកបានដោយកុមារទាំងអស់។ ដូច្នេះគរុសិស្ស ត្រូវយល់ដឹងពី៖

- ចរិតលក្ខណៈនៃគ្រូបង្រៀនបរិយាបន្ន
- វិធីដែលគ្រូបង្រៀនអាចបំពេញសេចក្តីត្រូវការផ្សេងៗនៅក្នុងថ្នាក់រៀន
- ពហុបញ្ញា
- របៀបរៀន
- ការកំណត់ឧបសគ្គដែលកុមារអាចមាននៅក្នុងការរៀន
- មូលហេតុការរៀនតាមរយៈការលេង និងសិល្បៈថ្នៃប្រឌិតអាចលើកកម្ពស់ការរៀន
- ការដាក់បញ្ចូលកុមារទាំងអស់នៅក្នុងការរៀន តាមរយៈការការប្រើប្រាស់ឫងំសកលសម្រាប់ការរៀន
- របៀបបង្កើតផែនការអប់រំសិស្សម្នាក់ៗមានប្រយោជន៍សម្រាប់គ្រូបង្រៀន ដើម្បីតាមដានសេចក្តីត្រូវការរបស់កុមារម្នាក់ៗដែលត្រូវការគាំទ្របន្ថែម.....។

៥.២.ការរៀនតាមរយៈការលេងកំសាន្ត

ការរៀនតាមរយៈការលេង និងបរិស្ថានបានក្លាយជាប្រធានបទថ្មីមួយសម្រាប់អប់រំកុមារកម្ពុជា។

ការលេងមានភាពសប្បាយរីករាយសម្រាប់កុមារ ប៉ុន្តែវាក៏អាចជួយពង្រឹងគោលគំនិតអប់រំ និងសម្រួលដល់ការរៀនសូត្រផងដែរ។ តាមរយៈការលេង និងហ្គេម កុមារមិនគ្រាន់តែនៅក្នុងមេរៀនប៉ុណ្ណោះទេ ថែមទាំងមានភាពសប្បាយរីករាយផងដែរ។ សាលាបញ្ចប់ការសិក្សារបស់ Harvard បានចោះពុម្ពផ្សាយរឿងមួយដែលមានចំណងជើងថា "ការលេងដើម្បីរៀន" ដែលរៀបរាប់លម្អិតអំពីរបៀបដែលការលេងគឺជាផ្នែកសំខាន់មួយនៃការរៀនសូត្រ និង

របៀបដែលប្រទេសដាណឺម៉ាក និងអាហ្វ្រិកខាងត្បូងរួមបញ្ចូលម៉ោងលេងទៅក្នុងម៉ោងសិក្សា។ការអប់រំកុមារតូចជាចំណុចយ៉ាងសំខាន់បំផុតក្នុងចំណោមដំណាក់កាលនានានៃការអប់រំ ព្រោះវ័យនេះជាវ័យដែលត្រូវការយកចិត្តទុកដាក់ ខ្ពស់ និងជាវ័យចាប់ផ្តើមកំណត់ពីដំណើរជីវិតរបស់កុមារ។

ដោយមើលឃើញពីសារៈសំខាន់នៃការអប់រំកុមារតូច ក្រសួងអប់រំ យុវជន និងកីឡា បានយកចិត្តទុកដាក់ជំរុញការអប់រំកុមារតូចដោយការបង្កើតកម្មវិធីអប់រំថ្មីៗ ដើម្បីឱ្យមានប្រសិទ្ធភាពខ្ពស់។ ថ្មីៗនេះ ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំសម្ពោធ អគារសិក្សានៃសាលាមត្តេយ្យសិក្សាធនធាន បាត់ដំបង និងសម្ពោធបើកដំណើរការ គម្រោងកសាងមូលដ្ឋានគ្រឹះនៃការអនុវត្តទ្រឹស្តី "រៀនតាមរយៈ ការលេង និង បរិស្ថាន" ដើម្បីជំរុញការអប់រំកុមារតូចឱ្យកាន់តែមានសមត្ថភាពខ្លាំង។

អ្នកស្រាវជ្រាវណែនាំថា ការលេងគឺជាធាតុផ្សំសំខាន់ក្នុងការរៀនសូត្រ អនុញ្ញាតឱ្យកុមារធ្វើត្រាប់តាមអាកប្បកិរិយារបស់មនុស្សពេញវ័យ អនុវត្តជំនាញសំខាន់ៗ ដែលមានដំណើរការប្រកបដោយចិត្តរំភើប និងរៀនច្រើនអំពីពិភពលោករបស់ពួកគេ[១៤]។

រូបភាពរបស់គេហទំព័រ bizkhmer*៖ រៀនដោយស្នាមញញឹមរបស់កុមារមានពិការភាព*

គ.៣.ការអភិវឌ្ឍជំនាញប្រាស្រ័យទាក់ទងល្អ

ឥទ្ធិពលនៃពាក្យសម្តីរបស់អ្នក អាចបង្កើតនូវសម្ពន្ធភាពមួយដ៏ស្និតរមួត ប្រកបដោយការយល់ចិត្តយល់ថ្លើមគ្នាទៅវិញទៅមកឬជាសម្ពន្ធភាពមួយដែលមានភាពល្អក់កករនឹងគ្នាកើតឡើងដោយសារការយល់ច្រឡំចំពោះគ្នាបាន។ ចំណុចនេះបានទ្ទុះបញ្ជាំងឲ្យឃើញពីភាពសំខាន់នៃការប្រាស្រ័យទាក់ទងទៅលើគុណភាពនៃសម្ពន្ធភាពក្នុងជីវិតអ្នក។ ការយល់ដឹងពី

[១៤] Researchers suggest that play is a central ingredient in learning, allowing children to imitate adult behaviors, practice motor skills, process emotional events, and learn much about their world.

របៀបនៃការប្រាស្រ័យទាក់ទងបែបណាទើប អាចបណ្តុះបាននូវទំនាក់ទំនងរបស់អ្នក និងមនុស្សជុំវិញខ្លួនឲ្យប្រព្រឹត្តទៅដោយភាពវិជ្ជមាន នឹងបង្កើតបាននូវទំនុកចិត្តរវាងគ្នា ការយល់ចិត្តគ្នា និងឈានទៅដល់ការបំពេញប្រយោជន៍ឲ្យគ្នាទៅវិញទៅមកបានយ៉ាងគាប់ប្រសើរផងដែរ។ ខាងក្រោមនេះ គឺជាចំណុចទាំង ៤ ដែលនិយាយអំពីជំនាញក្នុងការប្រាស្រ័យទាក់ទងដែលមនុស្សគ្រប់រូបគួររៀនសូត្រ៖

១. កាយវិការ ទោះជាពាក្យសម្តីរបស់អ្នកមានឥទ្ធិពលយ៉ាងណាក៏ដោយ ប្រសិនបើកាយវិការរបស់អ្នកមិនបង្ហាញពីជំនឿជាក់ និងភាពរួសរាយរាក់ទាក់របស់អ្នកទេនោះ អ្នកនឹងគ្មានឥទ្ធិពលអ្វីទៅលើពួកគេនោះឡើយ។

២. យកចិត្តទុកដាក់ស្តាប់យ៉ាងសកម្ម ការប្រាស្រ័យទាក់ទងមួយដែលល្អ មិនមែនគ្រាន់តែជាការប្រើប្រាស់ពាក្យសម្តី និងកាយវិការឲ្យបានសមរម្យនោះទេ អ្នកត្រូវបណ្តុះទម្លាប់ក្នុងការស្តាប់ដៃគូរបស់អ្នកដោយការយកចិត្តទុកដាក់ និងស្តាប់ចេញពីចិត្ត ព្រមទាំងយល់បានច្បាស់ពីខ្លឹមសារដែលពួកគេកំពុងនិយាយផងដែរ។

៣. ការដោះស្រាយភាពមិនចុះសម្រុងគ្នា ថ្វីបើមនុស្សភាគច្រើនជ្រើសរើសចៀសវាងពីភាពទាស់ទែងគ្នា ក៏ព្រោះតែពួកគេរៀងខ្លួនមិនចង់ទទួលនូវអារម្មណ៍ល្អក់កករ និងការឈឺចាប់តែការដោះស្រាយភាពមិនចុះសម្រុងគ្នាទាំងឡាយជាមួយដៃគូសន្ទនារបស់អ្នក គឺជារឿងមួយដ៏សំខាន់បំផុតក្នុងការរក្សាបាន និងពង្រឹងនូវសម្ពន្ធភាពរបស់អ្នកជាមួយពួកគេ។ កាលណាអ្នកបានគ្រប់គ្រងទៅលើអារម្មណ៍របស់អ្នកបាន ដោយឆ្លើយតបទៅកាន់ពួកគេវិញជាមួយការតាំងចិត្តឲ្យស្ងប់ មិនព្យាយាមនិយាយការពារខ្លួនឯង និងមានការគោរពចំពោះគ្នា នោះគំនិតរបស់អ្នកក៏នឹងទទួលបានការស្តាប់ពីអ្នកដទៃ រហូតឈានដល់ការសម្របសម្រួលគ្នាមួយយ៉ាងពេញចិត្តពេញថ្លើម។

៤. ចោទសួរនូវសំណួរដ៏ល្អ សំណួរដែលមានលក្ខណៈបើកចំហ ដែលបំផុសពីអារម្មណ៍ដែលកប់ជ្រៅនៅក្នុងជម្រៅចិត្តរបស់ពួកគេទៅលើហេតុការណ៍សំខាន់ណាមួយ គឺជាសំណួរដែលបង្ហាញពីការយកចិត្តទុកដាក់របស់អ្នកទៅលើពួកគេ និងចំណាប់អារម្មណ៍របស់អ្នកចំពោះការប្រាស្រ័យទាក់ទងនោះ ដែលវានឹងលើកទឹកចិត្តពួកគេឲ្យបើកចំហក្នុងការចែករំលែកពីខ្លួនពួកគេកាន់តែច្រើនជាង មុន។

ម្យ៉ាងទៀត អ្នកមិនត្រូវចូលទៅនិយាយកាត់ពួកគេ នៅពេលភាពស្ងប់ស្ងាត់បានលេចមកនោះទេ ព្រោះថាអាចជាភាពស្ងប់ស្ងាត់មួយរំពេចនេះហើយ ដែលជាឱកាសឲ្យពួកគេនិយាយពីរឿងក្នុងចិត្តប្រាប់អ្នកច្រើនជាងមុននោះៗ[១៥]

ជាការពិតណាស់ ការលើកឡើងមកខាងលើ សុទ្ធជាមធ្យោបាយគន្លឹះល្អៗ ហើយវាក៏អាចជួយដល់កុមារឬសិស្សានុសិស្សរកសាងជំនាញប្រាស្រ័យទាក់ទងបានល្អដែរៗដើម្បីឱ្យក្មេងទទួលបានលទ្ធផល គ្រូបង្រៀនត្រូវយល់ដឹងពីជំនាញចាំបាច់ដូចរៀបរាប់មកនិងចេះកំណត់ពីការពិបាកនៃការប្រាស្រ័យទាក់ទងចេះបំពេញតម្រូវការគាំទ្រការប្រាស្រ័យទាក់ទងជាដើម។



គ.៤.ការប្រើប្រាស់វិធីបង្រៀននិងរៀនសកម្ម

ការបង្រៀន យើងត្រូវចេះកំណត់សកម្មភាពទាំងវិធីបង្រៀននិងរៀនសកម្ម និងអកម្ម ហើយប្រើប្រាស់វិធីរៀនបែបសហការប្រកបដោយប្រសិទ្ធភាព។ ការរៀនបែបសហការ គឺផ្អែកលើទស្សនៈថា ចំណេះដឹងជាការបង្កើតសង្គម។សកម្មភាពសហការជាទូទៅមានមូលដ្ឋានលើគោលការណ៍៤ៈ

1. អ្នករៀនគឺជាចំណុចផ្តោតសំខាន់នៃការបង្រៀន
2. ទំនាក់ទំនង និងការធ្វើសកម្មភាព គឺជាចំណុចសំខាន់បំផុត

[១៥] ដកស្រង់ពីគេហទំព័រwww.bizkhmer.com

3. ការធ្វើការងារជាក្រុម គឺជារបៀបរៀនសំខាន់
4. វិធីសាស្ត្រជាប្រព័ន្ធ ដើម្បីបង្កើតដំណោះស្រាយចំពោះបញ្ហាជាក់ស្តែងគួរដាក់បញ្ចូលក្នុងការរៀន។



៣.៣.តម្លៃនៃការអប់រំបរិយាបន្ន

ការអប់រំបរិយាបន្ន គឺជាតម្លៃនៃភាពចម្រុះ និងការរួមចំណែកតែមួយគត់ដែលសិស្សម្នាក់ៗនាំយកមកក្នុងថ្នាក់រៀន។ នៅក្នុងការកំណត់ដែលរួមបញ្ចូលយ៉ាងពិតប្រាកដ កុមារគ្រប់រូបមានអារម្មណ៍ថាមានសុវត្ថិភាព និងមានភាពជាម្ចាស់។ សិស្ស និងឪពុកម្តាយរបស់ពួកគេចូលរួមក្នុងការកំណត់គោលដៅសិក្សា និងចូលរួមក្នុងការសម្រេចចិត្តដែលប៉ះពាល់ដល់ពួកគេ។ បុគ្គលិកសាលាមានការបណ្តុះបណ្តាលការគាំទ្រ ភាពបត់បែន និងធនធាន ដើម្បីចិញ្ចឹមបីបាច់ លើកទឹកចិត្ត និងឆ្លើយតបទៅនឹងតម្រូវការរបស់សិស្សទាំងអស់។

ប្រព័ន្ធអប់រំបរិយាបន្ន ផ្តល់នូវការអប់រំប្រកបដោយគុណភាពកាន់តែប្រសើរសម្រាប់កុមារទាំងអស់ និងជាឧបករណ៍សំខាន់ក្នុងការផ្ទាស់ប្តូរអាកប្បកិរិយាពើរសើរអើង។ សាលារៀនផ្តល់បរិបទសម្រាប់ទំនាក់ទំនងដំបូងរបស់កុមារជាមួយពិភពលោកនៅខាងក្រៅគ្រួសាររបស់ពួកគេ ដោយអនុញ្ញាតឱ្យមានការអភិវឌ្ឍទំនាក់ទំនងសង្គម និងអន្តរកម្ម។ ការគោរព និងការយល់ដឹងកើនឡើងនៅពេលដែលសិស្សដែលមានសមត្ថភាព និងប្រវត្តិផ្សេងៗគ្នា លេងធ្វើសង្គម និងរៀនជាមួយគ្នា។ ការអប់រំដែលមិនរាប់បញ្ចូលនិងបែងចែកដាច់ដោយឡែកបន្តការពើរសើរអើងប្រឆាំងនឹងក្រុមដែលមានលក្ខណៈ តិចតួចតាមប្រពៃណី។ នៅពេលដែលការអប់រំមានលក្ខណៈរួមបញ្ចូលកាន់តែច្រើន គំនិតនៃការចូលរួមរបស់ប្រជាពលរដ្ឋ ការងារ និងជីវិតសហគមន៍កាន់តែប្រសើរ។

៤. ការសន្និដ្ឋាន

ការអប់រំបរិយាបន្ន គឺជាការឆ្លើយតបទៅនឹងបរិបទថ្មីរបស់ពិភពលោក ក៏ដូចជាតំបន់ដែលមានការអភិវឌ្ឍរីកចម្រើនឥតឈប់ឈរ។ គ្រប់ស្ថាប័នពាក់ព័ន្ធក៏ដូចក្រសួងអប់រំ បានដាក់ចេញនូវផែនការអប់រំ យុទ្ធសាស្ត្រ ស្របតាមគោលនយោបាយការអប់រំបរិយាបន្នដោយលៃយ៉ាងណាឱ្យប្រព័ន្ធអប់រំបរិយាបន្នផ្តល់នូវការអប់រំប្រកបដោយគុណភាពកាន់តែប្រសើរសម្រាប់កុមារ និងយុវជនទាំងអស់ ។

ប្រទេសកម្ពុជាស្ថិតនៅលើផ្លូវបង្កើតការអប់រំបរិយាបន្នសម្រាប់កុមារពិការចាប់តាំងពីឆ្នាំ២០០៣ ជាមួយការបង្កើតកម្មវិធីសិក្សាអប់រំបរិយាបន្នសម្រាប់កុមារមានសេចក្តីត្រូវការអប់រំពិសេស។ ក្រោយមកទៀត សៀវភៅការអប់រំបញ្ចូលគ្នា ត្រូវបានបង្កើតនៅក្នុងឆ្នាំ២០១២។ បន្ទាប់មកសៀវភៅការបញ្ចូលគ្នាសម្រាប់ កុមារមានបញ្ហាបញ្ញា កុមារមានបណ្តាស្តាប់និងកុមារ មានបញ្ហាការមើលត្រូវបានបង្កើតឡើង។ ឯកសារទាំងនេះ ផ្តោតសំខាន់លើការសិក្សាប្រភេទពិការ និងផ្តល់គន្លឹះបង្រៀនមួយចំនួនសម្រាប់ប្រភេទពិការផ្សេងៗនៅក្នុងថ្នាក់រៀនបរិយាបន្ន។ ការអភិវឌ្ឍកាយសម្បទានិងបញ្ញាស្មារតីដល់ជនគ្រប់រូប ជាគន្លឹះចាំបាច់បំផុតក្នុងការអប់រំសម្រាប់ទាំងអស់គ្នា។ «***កុមារដែលគ្មានការអប់រំ ប្រៀបដូចជាបក្សីគ្មានស្លាប***»

ឯកសារពិគ្រោះ

1. ក្រសួងអប់រំ ***គោលនយោបាយស្តីពីការអប់រំបរិយាបន្ន*** ២០១៨
2. ក្រសួងអប់រំ ***ឯកសារការអប់រំបរិយាបន្ន ២០១៧***
3. ជួន ណាត ***វចនានុក្រមខ្មែរ*** ការផ្សាយដោយវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ១៩៦៧
4. ប៉ាន់ សំណាង ***ការអប់រំ ជាកិច្ចការខាំងអស់គ្នា*** ផ្សាយរបស់រាជបណ្ឌិត្យសភាកម្ពុជា ២០២២

គេហទំព័រ៖

1. https://www.aii.edu.kh
2. https://www.bizkhmer.com
3. https://dict.antkh.com
4. https://m.postkhmer.com
5. https://www.opensocietyfoundations.com
6. https://www.psychologytoday.com
7. https://www.unicef.org
8. https://www.sangapac.com
9. https://education.stateuniversity.com
10. https://verywellmind.com
11. https://www.sutori.com
12. https://www.young-adulllt.eu
13. Channel YouTube: Hak Sienghai

ស្វែងយល់ពីទ្រឹស្តីអភិវឌ្ឍន៍ពឹងផ្អែក *(Dependency)*

In what ways and to what extent does dependency lead to underdevelopment?

ដោយ៖ លោកបណ្ឌិត **អួច សុផារី** និង លោក **សាន ចេន**
មន្ត្រីនាយកដ្ឋានវិទ្យាសាស្ត្រសេដ្ឋកិច្ចនិងទេសចរណ៍,វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម,ពជបណ្ឌិត្យសភាកម្ពុជា

១. សេចក្តីផ្តើម

ប្រទេសក្នុងប្រព័ន្ធសេដ្ឋកិច្ចសកលលោកពឹងផ្អែកលើគ្នាទៅវិញទៅមកដើម្បីអភិវឌ្ឍ និងរីកចម្រើនទៅមុខ។ មានសំណួរជុំវិញការអភិវឌ្ឍន៍របស់ប្រទេសតតិយលោកដែលក្នុងនោះមានក្រុមប្រទេសនៅទ្វីបអាម៉េរិកឡាទីន និង អាហ្វ្រិក ជាអាទិ៍ត្រូវបានលើកឡើង ជាពិសេសនៅក្រោយសង្គ្រាមលោកលើកទីពីរ។ គោលនយោបាយជំនួសដោយការនាំចូលដែលត្រូវបានផ្តួចផ្តើមឡើងនៅក្នុងប្រទេសជាច្រើននៅទ្វីបអាហ្វ្រិកក្នុងអំឡុងពេលអាណានិគម នាំឱ្យមានការពឹងផ្អែកកាន់តែច្រើនលើការនាំចូលធនធាន គ្រឿងចក្រ ទំនិញឧស្សាហកម្ម និងបច្ចេកវិទ្យាទំនើប ព្រមទាំងធនធានមនុស្សសំខាន់ដែរ *(Chukwuemeka, Anazodo,&Nzewi,2011)*។ តើការពឹងផ្អែករបស់ប្រទេសណាបសេដ្ឋកិច្ចលើមជ្ឈមណ្ឌលស្នូលនៃអំណាចសេដ្ឋកិច្ចរបស់បច្ចិមលោកនាំឱ្យមានការអភិវឌ្ឍមិនបានឬយ៉ាងណា? ទ្រឹស្តីពឹងផ្អែក *(Dependency Theory)* បានកើតឡើងដំបូងនៅដើមទសវត្សរ៍ឆ្នាំ ១៩៦០ ជាការឆ្លើយតបទៅនឹងការបរាជ័យនៃកម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិមួយដែលមានឈ្មោះថាគណៈកម្មការសេដ្ឋកិច្ច សម្រាប់ការអភិវឌ្ឍន៍អាម៉េរិកឡាទីន *(Economic Commission for Latin America)(Hite, 2000; Isbister, 1991; P. Preston, 2011; So, 1990; Webster, 1984)*។ លោក *P. W. Preston (1996)* បង្ហាញបង្ហាញថា វាត្រូវបានបង្កើតឡើងដោយបទពិសោធន៍ប្រវត្តិសាស្ត្រ ពិសេសនៃទ្វីបអាម៉េរិកឡាទីនក្នុងទសវត្សរ៍ឆ្នាំ១៩៨០ និង ១៩៥០ នៅពេលដែលគំរូពាណិជ្ជកម្មនិងសេដ្ឋកិច្ចបង្កើតឡើងជាយូរមកហើយនោះ រំខានដោយព្រឹត្តការណ៍សង្គ្រាមលោកលើកទីពីរនិងការកំណត់នូវវិធានការ និង គោលនយោបាយជាតិឧស្សាហកម្មជំនួសដោយការនាំចូល *(Import-Substitution Industrialisation)*។ អ្នករៀបចំគោលនយោបាយនេះរិះគន់និងមិនគាំទ្រលើទ្រឹស្តីទំនើបការូបនីយកម្ម *(Modernisation Theory)* ដែលកើតចេញមកពីប្រព័ន្ធសេដ្ឋកិច្ចមូលធនអឺរ៉ុប។ គោលនយោបាយនេះផ្តល់ហេតុផលនិងអះអាងថាការអភិ

វឌ្ឍន៍តាមលំនាំទ្រឹស្តីទំនើបការរួបនីយកម្មពាណិជ្ជកម្ម វឌ្ឍនភាពហើយព្រមទាំងបានទាញយក ផលប្រយោជន៍ ពីប្រទេសមិនមានការអភិវឌ្ឍន៍ខ្លាំង (The Global South)ទៅវិញទេ។ លើសពីនេះទៀត វាថែមទាំងធ្វើឱ្យយើងយល់ច្បាស់អំពីទំនាក់ទំនងនយោបាយនិង សេដ្ឋកិច្ចនៃប្រទេសកំពុងអភិវឌ្ឍឬតតិយលោកដែរ ជាពិសេសបណ្តាប្រទេសនៅអាម៉េរិកឡាទីននិងទ្វីបអាហ្វ្រិក ជាមួយបណ្តាប្រទេសមូលធននិយមសំខាន់ៗនៅអឺរ៉ុបខាងលិច និង អាម៉េរិកខាងជើង (Desai & Potter, 2002)។ ក្នុងទិដ្ឋភាពនេះ វាបានបង្ហាញយ៉ាងច្បាស់ថាក្រុមប្រទេសមូលធននិយម ជាពិសេសនៅអឺរ៉ុបខាងលិចនិងអាម៉េរិកខាងជើងពឹងផ្អែកលើក្រុមប្រទេសកំពុងអភិវឌ្ឍឬតតិយលោកដើម្បីរីកចម្រើនទៅវិញ។ ឈរលើទស្សនៈនៃទ្រឹស្តីពឹងផ្អែក (Dependency Theory)បណ្តា ប្រទេសតតិយលោកមានសន្ទុះអភិវឌ្ឍតិចតួច នៅក្នុងប្រព័ន្ធសេដ្ឋកិច្ចមូលធននិយមដោយសារតែការកេងប្រវ័ញ្ចមិនអាចកែប្រែរបស់ប្រទេសដែលមានសេដ្ឋកិច្ចជឿនលឿនតាមរយៈការផ្ទាស់ប្តូរពាណិជ្ជកម្មមិនស្មើគ្នា ការវិនិយោគនៃក្រុមហ៊ុនសាជីវកម្មពហុជាតិបរទេសច្រើន (Multinational Corporations) និងការពឹងផ្អែកលើប្រព័ន្ធសេដ្ឋកិច្ចមូលធនដែលមាន។ អត្ថបទនេះនឹងពន្យល់និងបញ្ជាក់ពីមធ្យោបាយនានាដែលធ្វើឱ្យការអភិវឌ្ឍន៍លំនាំពឹងផ្អែក (Dependency) ធ្វើឱ្យប្រទេសក្រីក្រ មានសន្ទុះអភិវឌ្ឍតិចតួចទៅវិញ ហើយអត្ថបទនេះនឹងរិះគន់រកត្នាផ្សេងៗ ដែលរួមចំណែកធ្វើឱ្យមានការអភិវឌ្ឍន៍តិច និងយឺត (Underdevelopment) ចំពោះប្រទេសតតិយលោកផងដែរ។

២. ទំនាក់ទំនងនៃសេដ្ឋកិច្ចពឹងផ្អែកទៅនឹងការ អភិវឌ្ឍន៍តិចតួច

ហេតុផលទីមួយបង្ហាញថា ការពឹងផ្អែកលើពាណិជ្ជកម្មអន្តរជាតិ និង ការវិនិយោគពីបរទេស អាចនាំប្រទេសតតិយលោកទៅរកការអភិវឌ្ឍន៍តិចតួច (Underdevelopment)។ ទីផ្សារនិងពាណិជ្ជកម្មរបស់ប្រទេសក្រីក្រ ជាធម្មតាពឹងផ្អែកខ្លាំងលើប្រព័ន្ធទីផ្សាររបស់ប្រទេសជឿនលឿន (Developed Countries) (Hite,2000)។ ការផ្ទាស់ប្តូរមិនស្មើគ្នានៅក្នុងទីផ្សារសកលអាចឱ្យយើងមើលឃើញយ៉ាងច្បាស់ថា ជាការកេងប្រវ័ញ្ចមិនប្រែប្រួល និង មិនអាចកែប្រែបាន។ លោក Isbister (1991) អះអាងថាបណ្តាប្រទេសក្រីក្រនិងទន់ខ្សោយ ជាធម្មតាទទួលបានផលចំណេញសេដ្ឋកិច្ចតិចជាងបណ្តាប្រទេសធំដែលមានសេដ្ឋកិច្ចជឿនលឿន ចំពោះការដោះដូរទំនិញនៅក្នុងទីផ្សារពាណិជ្ជកម្មអន្តរជាតិ បើទោះបីជាពួកគេបានខាតបង់ផលចំណេញច្រើនហើយក៏ដោយក្តី។ តម្លៃផលិតផលកសិកម្មដែលនាំចេញទៅក្រៅប្រទេស ដោយប្រទេសក្រីក្រនៅមានកម្រិតទាប បើធៀបនឹងតម្លៃនៃការនាំចូលផលិតផល និង ទំនិញនៃប្រទេសឧស្សាហកម្ម។ ប្រទេសជឿនលឿនមានអំណាចខ្លាំង និង ដើរតួនាទីយ៉ាងសំខាន់ក្នុងការសម្រេចចិត្តថា តើនៅ

ពេលណា និង របៀបណាចំពោះការផ្ទាស់ប្តូរពាណិជ្ជកម្មនៅក្នុងទីផ្សារសកល ហើយពួកគេជាអ្នកកំណត់តម្លៃទៅតាមលំហូរប្រព័ន្ធសេដ្ឋកិច្ចរបស់ពួកគេ។ Matunhu (2011) អះអាងថា វត្ថុជាតុដើមរបស់ប្រទេសក្រីក្រដែលមានគឺប្រើប្រាស់សម្រាប់ជាការផ្គត់ផ្គង់ដល់សង្វាក់ផលិតកម្មរបស់ប្រទេសអ្នកមាន។ ប្រាក់ឈ្នួលពលកម្មដែលទទួលបានសម្រាប់កម្មករនៅក្នុងប្រទេសក្រីក្រគឺមានចំនួនតិចជាងតម្លៃដែលកម្មករនៅប្រទេសអ្នកមានទទួលបានច្រើន។ តាមរយៈការដោះដូរពាណិជ្ជកម្មនេះ ប្រទេសអ្នកមានទទួលបានអត្ថប្រយោជន៍លើការផ្ទេរតម្លៃ (Value Transfer) ច្រើនលើសលប់ (Hite, 2000)។ ប្រទេសក្រីក្រដែលស្ថិតនៅក្រោមឥទ្ធិពលប្រព័ន្ធសេដ្ឋកិច្ចមូលធននេះត្រូវបានគេមើលឃើញថាជាជនរងគ្រោះ និង បាត់បង់ធនធាននៅក្នុងក្របខណ្ឌនិងសកម្មភាពដោះដូរពាណិជ្ជកម្មអន្តរជាតិ និងការវិនិយោគបរទេស។ ទិដ្ឋភាពនេះហាក់ដូចជាបានបង្ហាញពីរូបភាពអាណានិគមនិយមបែបថ្មី ដែលអ្នកសាមញ្ញធម្មតាមើលមិនឃើញនិងស្វែងយល់បាន។ នៅក្នុងដំណើរការនេះ ប្រទេសអ្នកមានអាចបង្កើនមូលធនកាន់តែច្រើន ពីប្រទេសក្រីក្រទាំងនោះដែលមានការអភិវឌ្ឍន៍តិចតួច។ ជាឧទាហរណ៍នៅក្នុងកំឡុងសម័យសង្គ្រាមត្រជាក់ លោក Bodenheimer (1971) អះអាងនិងបញ្ជាក់ថា ការវិនិយោគបរទេសជាពិសេសពីសហរដ្ឋអាម៉េរិក និងពីបណ្តាប្រទេសឧស្សាហកម្មជឿនលឿន បណ្តាលឱ្យមានលំហូរមូលធនចេញយ៉ាងច្រើនពីប្រទេសដែលមិនទាន់មានការអភិវឌ្ឍន៍ជាពិសេសពីបណ្តាប្រទេសនៅទ្វីបអាម៉េរិកឡាទីន។ ដូចអ្វីដែលបានលើកឡើងខាងដើម វាបានបង្ហាញឱ្យឃើញកាន់តែច្បាស់ថា ប្រទេសក្រីក្រត្រូវបានកេងប្រវ័ញ្ចយ៉ាងខ្លាំងដោយប្រទេសអ្នកមានហើយកាន់តែធ្វើឱ្យពួកគេក្រទៅ។

ហេតុផលទីពីរស្រដៀងនឹងការពិភាក្សាក្នុងហេតុផលទីមួយដែរៗការជ្រៀតចូលនៃក្រុមហ៊ុនសាជីវកម្មពហុជាតិរបស់ប្រទេសឧស្សាហកម្មជឿនលឿនក៏អាចជាកត្តាធ្វើឱ្យមានការអភិវឌ្ឍន៍តិចតួចនៅក្នុងបណ្តាប្រទេសក្រីក្រដែលទទួលយកក្រុមហ៊ុនទាំងនោះដែរក្នុងក្របខណ្ឌពាណិជ្ជកម្មអន្តរជាតិដែរ។ ប្រទេសអ្នកមានកេងប្រវ័ញ្ចប្រជាជនក្រីក្រដោយយកអតិរេកសេដ្ឋកិច្ចពីប្រទេសក្រីក្រដែលគេស្គាល់ថាជាទម្រង់នៃការធ្វើអាណានិគមបែបថ្មី។ ប្រាក់ចំណេញ និងមូលធនសន្សំដែលទទួលបានដោយក្រុមហ៊ុនសាជីវកម្មពហុជាតិក្នុងប្រទេសក្រីក្រត្រូវបានបញ្ជូនទៅប្រទេសអ្នកមានតាមរយៈប្រតិបត្តិការហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។ អ្នកជំនាញ Isbister (1991) ចង្អុលបង្ហាញថា ក្រុមហ៊ុនសាជីវកម្មពហុជាតិមានដើមទុនតិចតួចដើម្បីវិនិយោគក្នុងប្រទេសក្រីក្រ ប៉ុន្តែពួកគេខ្ចីពីអ្នកសន្សំក្នុងស្រុក ហើយប្រាក់ចំណេញដែលពួកគេរកបានគឺតែងតែបញ្ជូនទៅកាន់ប្រទេសដើមរបស់ពួកគេ។ លើសពីនេះ ក្រុមហ៊ុនសាជីវកម្មពហុជាតិបរទេសនាំយកមកជាមួយនូវបច្ចេកវិទ្យា

ជឿនលឿនខ្ពស់ខ្លាំងសម្រាប់បម្រើក្នុងដំណើរការសង្វាក់ផលិតកម្មទំនិញដែលមិនស៊ីគ្នានឹងកម្លាំងពលកម្មច្រើនលើសលប់នៃប្រទេសក្រីក្រ។ នេះជាហេតុធ្វើឱ្យមានភាពអត់ការងារធ្វើមួយចំនួនធំនៅក្នុងតំបន់នៃប្រទេសក្រីក្រទាំងនោះ (Stein, 1979)។ លើសពីនេះទៅទៀត ក្រុមហ៊ុនសាជីវកម្មពហុជាតិទាំងនោះដែលបានវិនិយោគនៅក្នុងតំបន់ប្រទេសក្រីក្រទាំងនោះ តែងតែប្រើប្រាស់អំណាចផ្តាច់មុខ(Monopoly Power)ក្នុងការលក់និងការប្រើប្រាស់ផលិតផលដែលវាបានជះឥទ្ធិពលអវិជ្ជមានដល់ការបែងចែកធនធាននៅក្នុងប្រទេសក្រីក្រដែលមានសេដ្ឋកិច្ចពឹងផ្អែក។ លទ្ធភាពនៃការបង្កើតការវិនិយោគថ្មីគឺពឹងផ្អែកលើរូបិយប័ណ្ណបរទេសដើម្បីទិញគ្រឿងម៉ាស៊ីន និងសម្ភារៈមួយចំនួនដែលជារបស់មិនមែនផលិតក្នុងស្រុក (Santos, 1970) ដូចនេះតម្លៃគឺខ្ពស់ដែលកំណត់ដោយសង្វាក់តម្រូវការនិងផ្គត់ផ្គង់របស់ប្រទេសឧស្សាហកម្មជឿនលឿនទាំងនោះ។ ប្រទេសដែលមានកម្លាំងសេដ្ឋកិច្ចទាបឬប្រទេសក្រីក្រនិយាយជារួម គឺមិនអាចធ្វើការប្រកួតប្រជែងដោយស្មើភាពក្នុងទីផ្សារសេរីសកលបានទេ ហើយពួកគេគ្រាន់តែអាចជ្រើសរើសគំរូឧស្សាហកម្មដែលអាស្រ័យលើគោលនយោបាយពន្ធបង្កើតឡើងដោយអនុត្តរភាពនៃប្រទេសមានសេដ្ឋកិច្ច ជឿនលឿនប៉ុណ្ណោះ។ ឧទាហរណ៍ ធនាគារពិភពលោក (The World Bank) និងមូលនីធិរូបិយវត្ថុអន្តរជាតិ (IMF) ដែលបានផ្តួចផ្តើមបង្កើតដំបូងដោយសហរដ្ឋអាម៉េរិក ឈរនៅពីក្រោយ និងគាំទ្រក្រុមហ៊ុនសាជីវកម្មពហុជាតិបរទេសទាំងនោះ ហើយបង្កើតគោលនយោបាយសេដ្ឋកិច្ចនិងវិធានការនានាដែលបម្រើដល់ផលប្រយោជន៍ក្រុមហ៊ុនបរទេសទាំងនោះ និងអាចរកប្រាក់ចំណេញបានពីប្រទេសក្រីក្រទាំងនោះ (Isbister, 1991)។ ជាទូទៅ នៅក្នុងប្រព័ន្ធសេដ្ឋកិច្ចសកល ប្រទេសទន់ខ្សោយជាធម្មតារណបនឹងប្រទេសខ្លាំងដែលមានអំណាចជាងនៅក្នុងទីផ្សារអន្តរជាតិ។ ប្រទេសខ្លាំងនិងមានអំណាចទាំងនោះគឺជាអ្នកកំណត់តម្លៃនិងផលចំណេញដែលទទួលបាននៅក្នុងទីផ្សារ។ តួអង្គប្រទេសដែលមានឥទ្ធិពលច្រើនជាង តែងតែប្រើអំណាចរបស់ពួកគេដើម្បីត្រួតត្រា ហើយអាចកំណត់ក្នុងការបែងចែកប្រាក់ចំណេញនៃដំណើរការអាជីវកម្ម (Hite, 2000)។ ក្នុងកាលៈទេសៈមួយចំនួននៃការធ្លាក់ចុះដំណើរការពាណិជ្ជកម្ម វាអាចបង្ខំឱ្យប្រទេសក្រីក្រទាំងនោះខ្ចីឥណទានបរទេសកាន់តែច្រើនពីទីភ្នាក់ងារជំនួយអន្តរជាតិ ហើយពួកគេអាចជាប់បំណុលយ៉ាងធ្ងន់ធ្ងរ (Saul, 2006)។

សម្រាប់ហេតុផលចុងក្រោយចំពោះការពិភាក្សានេះ គឺការពឹងផ្អែកផ្នែកសេដ្ឋកិច្ចក៏អាចរួមចំណែកយ៉ាងសំខាន់ធ្វើឱ្យមានការអភិវឌ្ឍន៍មិនប្រក្រតីនៅក្នុងប្រទេសក្រីក្រ។ ការបង្ខិចទ្រង់ទ្រាយនៃប្រព័ន្ធសេដ្ឋកិច្ចនិងឥទ្ធិពលនៃទីផ្សារពាណិជ្ជកម្មអន្តរជាតិអាចបង្ខំឱ្យប្រទេសក្រីក្រទទួលយករចនាសម្ព័ន្ធសេដ្ឋកិច្ចដែលជារឿយៗមិនស៊ីសង្វាក់គ្នាជាមួយនឹងបែបផែន

នៃការអភិវឌ្ឍន៍សេដ្ឋកិច្ចតាមតំបន់ប្រទេស ក្រីក្រទាំងនោះ។ លោក So (1990) អះអាងថា តាមទស្សនៈនេះ សេដ្ឋកិច្ចរបស់ប្រទេសក្រីក្រទាំងនោះជាធម្មតាទទួលគំនៀបនិងឥទ្ធិពល ហើយកេងប្រវ័ញ្ចដោយអំណាចប្រទេសអ្នក មាន។ ហេតុដូចនេះហើយបានជាប្រទេសកំពុងអភិវឌ្ឍមួយចំនួនកាន់តែក្រីក្រ និង អភិវឌ្ឍតិចតួចដោយសារការកេងប្រវ័ញ្ចពីប្រទេសមូលធននិយម។ លោក Isbister (1991) ចង្អុលបង្ហាញ ថាការរីកចម្រើននៃប្រទេសអ្នកមាននាពេលបច្ចុប្បន្នគឺជាការធ្ងុះបញ្ចាំងពីភាពក្រីក្រនៃប្រទេសក្រីក្រដែលមានទំនាក់ទំនងនយោបាយ សេដ្ឋកិច្ច និងពាណិជ្ជកម្មជាមួយខ្លួន។ Isbister (1991) បន្ថែមថា ការអភិវឌ្ឍន៍តិចតួចមិន មែនគ្រាន់តែជាការបរាជ័យក្នុងការអភិវឌ្ឍន៍ប៉ុណ្ណោះទេ ប៉ុន្តែវាគឺជាដំណើរការដែលធ្វើឱ្យមានភាពក្រីក្រមិនចេះរីងស្ងួត (ទំព័រ 43)។ ប្រទេសមហាអំណាចសេដ្ឋកិច្ចស្នូលប្រើប្រាស់មធ្យោបាយផ្សេងៗដើម្បីបង្ខិចទម្រង់និងបែបផែននៃការអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់ប្រទេសទន់ខ្សោយ។ ពួកគេគ្រប់គ្រងរចនាសម្ព័ន្ធសេដ្ឋកិច្ចដើម្បីពារាំងវឌ្ឍនភាពនៅក្នុងប្រទេសទន់ខ្សោយទាំងនោះ។ ជាឧទាហរណ៍ ការបែងចែកពលកម្មសកលនានាបង្កើតឱ្យមានឧបសគ្គដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ចក្នុងប្រទេសក្រីក្រ។ កម្មករនៅក្នុងប្រទេសក្រីក្រអាចទទួលបានប្រាក់ឈ្នួលទាបខ្លាំងបើប្រៀបធៀបនឹងប្រាក់ឈ្នួលនិងអត្ថប្រយោជន៍ដែលទទួលបានដោយកម្មករនៅក្នុងប្រទេសអ្នកមាន។ ជាងនេះទៅទៀត បណ្តាប្រទេសមូលធននិយម មើលឃើញនិងចាត់ទុកថា ប្រទេសក្រីក្រទាំងនោះជាអ្នកផ្គត់ផ្គង់វត្ថុជាតុដើមដល់ពួកគេ ដើម្បីជំរុញការរីកចម្រើននៃឧស្សាហូបនីយកម្មពួកគេ។ ដូច្នេះហើយ ពួកគេតម្រែតម្រង់បណ្តាប្រទេសក្រីក្រទាំងនោះឱ្យមានលទ្ធភាពក្នុងការផលិតវត្ថុជាតុដើមដែលមិនមានលក្ខណៈខុសគ្នា ដើម្បីបំពេញតម្រូវការពួកគេ។ ស្ថានភាពមិនប្រែប្រួលនិងដដែលៗនេះអាចធ្វើឱ្យប្រទេសក្រីក្រទាំងនោះមិនមានការប្រកួតប្រជែងក្នុងប្រព័ន្ធសេដ្ឋកិច្ចសកល។ លោក Ray (1973) ចង្អុលបង្ហាញថា ការអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់អាម៉េរិកឡាទីនក្នុងប្រវត្តិសាស្ត្រក្រោយសង្គ្រាមលោកលើកទីពីរ ត្រូវបានបន្ទុចបង្អាក់និងកំណត់ដោយតម្រូវការរបស់ប្រទេសមហាអំណាចសេដ្ឋកិច្ចស្នូលនៅក្នុងទីផ្សារពិភពលោក។ តម្លៃទំនិញប្រើប្រាស់នៃប្រទេសក្រីក្រធ្លាក់ដោយសារផលិតកម្មឧស្សាហកម្មផលិតដោយប្រទេសអ្នកមាន។ Hite (2000) ចង្អុលបង្ហាញថា នេះអាចបង្កការលំបាកដល់ប្រទេសក្រីក្រក្នុងការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍសេដ្ឋកិច្ច ជាតិ។ ការគៀបសង្កត់សេដ្ឋកិច្ចជាប្រព័ន្ធបែបនេះអាចធ្វើឱ្យប្រជាជននៃប្រទេសទន់ខ្សោយកាន់តែលំបាកនិងមិនអាចរីកចម្រើនទៅមុខឱ្យដូចប្រជាជននៅក្នុងប្រទេសអ្នកមាន។

៣. ការរិះគន់លើទ្រឹស្តីសេដ្ឋកិច្ចពឹងផ្អែក

ទោះជាយ៉ាងណាក៏ដោយ អ្នករិះគន់ទ្រឹស្តីពឹងផ្អែក(Dependency Theory) មួយចំនួនបានអះអាងថាទំនាក់ទំនងដ៏រឹងមាំនៃប្រទេសក្រីក្(ប្រទេសរណបសេដ្ឋកិច្ច)ជាមួយនឹងប្រទេសមហាអំណាចសេដ្ឋកិច្ចស្នូលផ្តល់ផលវិជ្ជមានច្រើនជាងភាពអសកម្មដែលបានលើកឡើង ជាពិសេសនិយាយដោយចំពោះក្នុងទំនាក់ទំនងពាណិជ្ជកម្មក៏ដូចជាការដោះដូរការវិនិយោគរបស់ក្រុមហ៊ុនសាជីវកម្មពហុជាតិ និងការពឹងផ្អែកនានាក្នុងសកម្មភាពសេដ្ឋកិច្ច។ ឧ. ក្រុមហ៊ុនសាជីវកម្មពហុជាតិបាននាំមកនូវអត្ថប្រយោជន៍ច្រើនដល់ប្រទេសក្រី ក្រតាមរយៈការវិនិយោគ ដូចជា ការផ្តល់ដើមទុន ការងារ និងប្រាក់ចំណូលផងដែរ (Chukwuemeka et al., 2011) ។ ជាងនេះទៅទៀត ការលេចចេញនូវទម្រង់ការអភិវឌ្ឍន៍តិចតួច (Underdevelopment) ក៏ដោយសារតែរចនាសម្ព័ន្ធសង្គមទន់ខ្សោយរបស់ប្រទេសក្រីក្រខ្លួនឯង (Webster, 1984)។ ក្រុមអភិជនក្នុងប្រទេសមានជំនួញ និង អំណាចសេដ្ឋកិច្ចមានទំនាក់ទំនង ហើយពឹងផ្អែកលើអ្នកវិនិយោគប្រទេសអ្នកមានក្នុងប្រទេស ដើម្បីគ្រប់គ្រងការអភិវឌ្ឍន៍កសិកម្មនិងឧស្សាហកម្ម ហើយផ្តើមកេងប្រវ័ញ្ចលើវណ្ណៈកសិករតាមរយៈសកម្មភាពពាណិជ្ជកម្មនិងសេដ្ឋកិច្ចក្នុងស្រុក។

អ្នករិះគន់ទ្រឹស្តីខ្លះទៀត ប្រកែកថាតម្លៃអតិរេកដែលបានផ្ទេរទៅប្រទេសមូលធននិយមតាមរយៈប្រតិបត្តិការហិរញ្ញវត្ថុក្រុមហ៊ុនសាជីវកម្មពហុជាតិ គឺគ្រាន់តែជាចំនួនជាក់ស្តែងនៃរូបិយវត្ថុប៉ុណ្ណោះ។ តម្លៃអតិរេកចាំបាច់ត្រូវបង្ហាញពីរបៀបដែលគេថាវាត្រូវបានកេងប្រវ័ញ្ច ហើយតាមពិតប្រទេសក្រីក្រទាំងនោះទេដែលពឹងផ្អែកយ៉ាងខ្លាំងលើប្រព័ន្ធផលិតកម្មមូលធននិយមទាំងស្រុង ដើម្បីជំរុញកំណើនសេដ្ឋកិច្ច (Webster, 1984)។ ការចោទប្រកាន់លើការកេងប្រវ័ញ្ចលើអតិរេកតម្លៃរបស់ក្រុមហ៊ុនសាជីវកម្មពហុជាតិគឺមិនសមហេតុសមផលឡើយ។ ជាការពិតណាស់ ដំណាក់កាលដំបូង ប្រទេសក្រីក្រត្រូវពឹងលើប្រទេសអ្នកមានដើម្បីអភិវឌ្ឍ ព្រោះពួកគេមិនមានលទ្ធភាពគ្រប់គ្រាន់ដោយខ្លួនឯងដើម្បីដើរទៅមុខឡើយ (Grosfoguel, 2000)។ ក្នុងប្រវត្តិសាស្ត្រជាពិសេសនៅក្រោយសង្គ្រាមលោកលើកទីពីរ មានប្រទេសក្រីក្រជាច្រើនដែលបានអភិវឌ្ឍខ្លួន និងអាចឈានដល់ដំណាក់កាលនៃឧស្សាហូបនីយកម្ម។ មានឧទាហរណ៍ជាក់ស្តែងដូចជា បណ្តាប្រទេសឧស្សាហកម្មថ្មី (Newly-Industrialised Countries) ដែលរួមមានកូរ៉េខាងត្បូង និង ដែនកោះតៃវ៉ាន់នៃប្រទេសចិន បានធ្វើសមាហរណកម្មទៅក្នុងទីផ្សារអន្តរជាតិ និងប្រព័ន្ធមូលធននិយមពិភពលោក ហើយបានក្លាយទៅជាប្រទេសឧស្សាហកម្ម និង មានសេដ្ឋកិច្ចជឿនលឿននៅក្នុងតំបន់ដូចបណ្តាប្រទេសនៅអឺរ៉ុបខាងលិច និង អាម៉េរិកខាងជើងដែរ (Saul, 2006)។

បន្ថែមលើនេះទៀត លោក Cardoso និង លោក Faletto (1979) ពន្យល់ថា នៅពេលដែលការវិនិយោគបរទេសចាប់ផ្តើមនៅក្នុងប្រទេស

ដែលមានសេដ្ឋកិច្ចពឹងផ្អែក ទីផ្សារក្នុងស្រុកមានមុខងារហើយដំណើរការហើយក្រុមអភិជនដែលនៅស្រទាប់លើនៃរចនាសម្ព័ន្ធសង្គមទទួលបានអត្ថប្រយោជន៍ច្រើនបំផុត ក្នុងការបែងចែកផលចំណេញ។ Matunhu (2011) អះអាងថា ខណៈពេលដែលប្រទេសអ្នកមានកំពុងកេងប្រវ័ញ្ចនិងទាញយកធនធានរបស់ប្រទេសរណបសេដ្ឋកិច្ចខ្លួនក្នុងសកម្មភាពសេដ្ឋកិច្ចលើទីផ្សារអន្តរជាតិនិងការវិនិយោគ ពេលនោះអ្នកមានឥទ្ធិពល(ក្រុមអភិជនដែលមានអំណាច) នៅក្នុងប្រទេសក្រីក្រនោះក៏កំពុងកេងប្រវ័ញ្ចប្រជាជនក្រីក្រនិងទន់ខ្សោយតាមរយៈសកម្មភាពពាណិជ្ជកម្មក្នុងស្រុកដែរ។ ទិដ្ឋភាពនេះ គឺបានបង្ហាញពីរចនាសម្ព័ន្ធកេងប្រវ័ញ្ចចេញពីអំណាចខាងក្រៅនិងខាងក្នុងផងចំពោះប្រទេសនិង ជនក្រីក្រ។ ទោះបីជាក្រុមហ៊ុនសាជីវកម្មពហុជាតិគ្រប់គ្រងសេដ្ឋកិច្ចពិភពលោកក៏ដោយ អន្តរាគមន៍កាន់តែខ្លាំងរបស់អាជ្ញាធរ និងរដ្ឋាភិបាលប្រទេសក្រីក្រអាចទប់ស្កាត់ការកេងប្រវ័ញ្ចទាំងនោះបាន ហើយតម្លៃអតិរេកអាចត្រូវបានប្រើប្រាស់ជាប្រយោជន៍សម្រាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិបាន។ អ្នករិះគន់ទាំងនោះពន្យល់បន្ថែមថា មូលហេតុចំបងគឺថា អាជ្ញាធរនិងរដ្ឋាភិបាលទាំងនោះពុករលួយ និងអសមត្ថភាពក្នុងការរៀបចំវិធានការទប់ស្កាត់ ជាពិសេសគឺការអនុវត្តន៍គោលនយោបាយផ្ទាល់តែម្តង(Willis, 2011)។ លើសពីនេះទៅទៀត ប្រទេសក្រីក្រទាំងនោះមិនមានបច្ចេកវិទ្យានិងមធ្យោបាយ ដូច្នេះហើយឧស្សាហូបនីយកម្មមានភាពយឺតយ៉ាវ និងទន់ខ្សោយដែលត្រូវពឹងផ្អែកលើបច្ចេកទេសរបស់ប្រទេសជឿនលឿនទាំងស្រុង។ ទាហរណ៍ សង្គមអាម៉េរិកឡាទីនត្រូវបានគេជឿថា មានលក្ខណៈបុព្វណានិងមិនងាយកែប្រែហើយឈានទៅរកសង្គមទំនើបបែបអឺរ៉ុបខាងលិចនិងអាម៉េរិកខាងជើងឡើយ (Grosfoguel, 2000)។ ទិដ្ឋភាពបុព្វណានៃសង្គមនេះ ធ្វើឱ្យយើងកាន់តែនឹកដល់សង្គមអាស៊ីនិងអាហ្វ្រិកមួយចំនួនដែលភាគច្រើនលើសលប់មិនងាយឈានទៅរកទំនើបកម្មលឿនបានឡើយទោះជានៅក្នុងសតវត្សទី២១នេះ។

៤. គំនិតគាំទ្រចំពោះទ្រឹស្តីសេដ្ឋកិច្ចពឹងផ្អែក

ទោះជាយ៉ាងណាក៏ដោយ អ្នកទ្រឹស្តីពឹងផ្អែក *(Dependency Theorist)* មួយចំនួននៅតែប្រកែកថា លើសពីការកេងប្រវ័ញ្ចធនធានរបស់ប្រទេសក្រីក្រ ការវិនិយោគបរទេសអាចបង្កើតភាពអត់ការងារធ្វើដោយសារតែការប្រើប្រាស់បច្ចេកវិទ្យាខ្ពស់នៅក្នុងវោងចក្ររបស់ទាំងនោះ (Chukwuemeka et al.,2011)។ ជាងនេះទៅទៀត ការវិនិយោគរបស់ក្រុមហ៊ុនសាជីវកម្មពហុជាតិនៅក្នុងប្រទេសក្រីក្រទាំងនោះអាចជះ ឥទ្ធិពលអវិជ្ជមានដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ។ ការអភិវឌ្ឍន៍ទាំងនោះអាចមិនមានតុល្យភាពដោយសារតែកម្លាំងពលកម្មទាបនិងពន្ធដែលកំណត់ហើយ ប្រព័ន្ធទីផ្សារទាំងមូលនៅក្នុងសេដ្ឋកិច្ចនៃ

ប្រទេសក្រីក្រទាំងនោះត្រូវបានបំផ្លាញ(Hite, 2000)។ ធនធានរបស់ប្រទេសក្រីក្របាត់បង់ច្រើនជាងពួកគេទទួលបានអត្ថប្រយោជន៍ពីពាណិជ្ជកម្មអន្តរជាតិ និងការវិនិយោគបរទេស។ សំខាន់ជាងនេះទៅទៀត រចនាសម្ព័ន្ធសេដ្ឋកិច្ចប្រទេសទាំងមូលដែលរណបកំណត់និងទទួលឥទ្ធិពលពីប្រទេសសេដ្ឋកិច្ចស្នូល អាចធ្វើឱ្យមានលំហូរធនធានមនុស្សយ៉ាងច្រើនចេញពីប្រទេសក្រីក្រទៅកាន់ប្រទេសអ្នកមានដើម្បីស្វែងរកការងារ។ កង្វះធនធានមនុស្សនេះនឹងធ្វើឱ្យប្រទេសក្រីក្រកាន់តែលំបាកក្នុងការអភិវឌ្ឍសង្គមនិងសេដ្ឋកិច្ច។ Matunhu(2011) បានចង្អុលបង្ហាញថាក្នុងប្រវត្តិសាស្ត្រក្នុងក្រប ខណ្ឌអភិវឌ្ឍន៍កន្ទុងមកមានវេជ្ជបណ្ឌិត គិលានុបដ្ឋាយិការីស្វកនិងស្តាបត្យករជនជាតិអាហ្វ្រិក ជាច្រើនបានផ្ទាស់ទៅធ្វើការឱ្យប្រទេសអាណានិគមរបស់ខ្លួនពីមុន ជាពិសេសនៅអឺរ៉ុបនិងអាម៉េរិកខាងជើង ដោយសារពួកគេអាចទទួលបានប្រាក់ខែខ្ពស់។ ដូច្នេះ ការកេងប្រវ័ញ្ចនៃប្រទេសសេដ្ឋកិច្ចស្នូល គឺជាមូលហេតុជាក់ ស្តែងបញ្ជាក់ពីការអភិវឌ្ឍន៍តិចតួចរបស់ប្រទេសរណបសេដ្ឋកិច្ច។

៥. សេចក្តីសន្និដ្ឋាន

សរុប រមក វាហាក់បីដូចជាមានគំនិតពីផ្ទុយគ្នា ចំពោះការអភិវឌ្ឍន៍តិចតួចនៃបណ្តាក្រីក្រនៅក្នុងទស្សនទានទ្រឹស្តីពឹងផ្អែក (Dependency)។ អ្នកទ្រឹស្តីនេះមួយចំនួនបានចង្អុលបង្ហាញថាឥទ្ធិពលនៃប្រព័ន្ធមូលធននិយមពិភពលោកធ្វើឱ្យប្រទេសទន់ខ្សោយមានការអភិវឌ្ឍន៍តិចតួច។ ពួកគេត្រូវបានកេងប្រវ័ញ្ចគ្រប់រូបភាពនិងជាប្រព័ន្ធដោយការដោះដូរផលិតផលមិនស្មើភាពគ្នានៅក្នុងលក្ខខណ្ឌនៃទីផ្សារអន្តរជាតិកំណត់ដោយប្រទេសមហាអំណាចសេដ្ឋកិច្ច។ ប្រទេសក្រីក្រទទួលបានកម្រៃទាបបំផុតពីផលិតផលកសិកម្មដែលនាំចេញទៅលក់នៅក្រៅប្រទេស (នៅប្រទេសអ្នកមាន) ខណៈដែលប្រទេសសេដ្ឋកិច្ចស្នូលទទួលបានអត្ថប្រយោជន៍ច្រើនជាងខ្លាំងពីទំនិញនិងផលិតផលឧស្សាហកម្មដែលបាននាំចេញ។ ជាងនេះទៅទៀត វត្ថុជាតុដើម ដូចជា ប៉ែមាស និង បុកស៊ីតជាដើម ត្រូវបានរុករក និងដឹកជញ្ជូនទៅកាន់ប្រទេសមូលធននិយមតាមរយៈការដោះដូរពាណិជ្ជកម្មនេះ (Isbister, 1991)។ លើសពីនេះទៀត ការអភិវឌ្ឍន៍តិចតួច (Underdevelopment) របស់បណ្តាប្រទេសតតិយលោក អាចបកស្រាយពន្យល់តាមរយៈការជ្រៀតចូលនៃក្រុមហ៊ុនសាជីវកម្មពហុជាតិបរទេសនៅក្នុងប្រទេសក្រីក្រទាំងនោះ។ ក្រុមហ៊ុនទាំងនោះទទួលបានអតិរេកសេដ្ឋកិច្ចយ៉ាងច្រើនពីប្រទេសក្រីក្រ ហើយបញ្ជូនទៅប្រទេសកំណើតរបស់ពួកគេ។ ពួកគេនាំយកមកនូវដើមទុនតិចតួច ប៉ុន្តែខ្ចីពីអ្នកសន្សំក្នុងស្រុកនិងធនាគារដើម្បីរកផលចំណេញ។ ដូចគ្នានេះផងដែរពួកគេបង្កើតលំនាំឧស្សាហកម្ម ដើម្បីបម្រើផលប្រយោជន៍ឱ្យប្រទេសសេដ្ឋកិច្ចស្នូលរបស់ពួកគេ ដែលធ្វើឱ្យប្រទេសរណបសេដ្ឋកិច្ចទាំងនោះមិនអាចប្រកួតប្រជែងដោយស្មើភាពក្នុងពាណិជ្ជកម្ម

និងទីផ្សារអន្តរជាតិបាន។ ជាចំណុចចុងក្រោយ រចនាសម្ព័ន្ធសេដ្ឋកិច្ចនៃប្រទេសក្រីក្រត្រូវបានខូចទ្រង់ទ្រាយដែលកំណត់ដោយអំណាចនយោបាយរបស់ប្រទេសសេដ្ឋកិច្ចស្នូល។ ប្រការនេះធ្វើឲ្យប្រទេសក្រីក្រកាន់តែលំបាកក្នុងការវិវត្តន៍ទៅមុខនិងរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ ទោះជាយ៉ាងណាក៏ដោយ អ្នករិះគន់ទ្រឹស្តី (Dependency Critics) នេះមួយចំនួនបានអះអាងផ្ទុយថា ភាពក្រីក្រនៅក្នុងប្រទេសតតិយលោកគឺបណ្តាលមកពីភាពទន់ខ្សោយ និងកត្តាខាងក្នុងជាជាងការភ្ជាប់ហេតុផលទៅខាងក្រៅជាពិសេសប្រព័ន្ធមូលធននិយមពិភពលោក។ ទំនាក់ទំនងដ៏រឹងមាំនៅក្នុងលក្ខខណ្ឌនៃទំនាក់ទំនងពាណិជ្ជកម្ម ការជ្រៀតចូលនៃក្រុមហ៊ុនសាជីវកម្មពហុជាតិ និង ស្ថានភាពប្រព័ន្ធសេដ្ឋកិច្ចសកលផ្តល់ឱ្យប្រទេសក្រីក្រនូវអត្ថប្រយោជន៍ជាច្រើនទៅវិញទេ។ផ្ទុយទៅវិញរដ្ឋាភិបាលពុករលួយ និងអសមត្ថភាព កង្វះបច្ចេកវិទ្យា និង រចនាសម្ព័ន្ធសង្គមដែលគ្មានផលិតភាពទេ គឺជាមូលហេតុនៃភាពក្រីក្រក្នុងប្រទេសតតិយលោក។ ទោះយ៉ាងណា អ្នកគាំទ្រទ្រឹស្តីនេះនៅតែប្រកែកថា ភាពក្រីក្របន្តកើតមានក្នុងបណ្តាប្រទេសតតិយលោកដោយសារភ្ជាប់ហេតុផលនៃការកេងប្រវ័ញ្ចគ្រប់រូបភាពនិងជាប្រព័ន្ធពីសំណាក់ប្រទេសសេដ្ឋកិច្ចស្នូល (Fenyo, 2000; Long, 1977)។ ពួកគេមិនត្រឹមតែកេងប្រវ័ញ្ចធនធានធម្មជាតិនោះទេ ប៉ុន្តែព្រមទាំងធនធានមនុស្សទៀតផង។ ជាឧទាហរណ៍ ប្រទេសមួយចំនួននៅអាម៉េរិកឡាទីនធ្លាប់មានភាពរឹងមាំខាងសេដ្ឋកិច្ច ប៉ុន្តែចុងក្រោយមានការអភិវឌ្ឍន៍តិចតួចបន្ទាប់ពីមានការជ្រៀតជ្រែកនិងកេងប្រវ័ញ្ចពីប្រព័ន្ធសេដ្ឋកិច្ចមូលធន ជាពិសេសក្រោយសង្គ្រាមលោកលើកទីពីរ (Ray, 1973; Valenzuela & Valenzuela, 1978) ។ តាមទស្សន:ខ្ញុំផ្ទាល់ ការវិវត្តន៍តិចតួចនិងយឺតយ៉ាវនៃបណ្តាប្រទេសក្រីក្រក្នុងពិភពលោក គឺបណ្តាលមកពីការកេងប្រវ័ញ្ចនៃប្រទេសសេដ្ឋកិច្ចស្នូល និង ភាពអសកម្មនៅខាងក្នុងរបស់ប្រទេសទាំងនោះផងដែរ ដូចជាអំពើពុករលួយ អសមត្ថភាព កង្វះខាតបច្ចេកវិទ្យា និងរចនាសម្ព័ន្ធសង្គមខ្សោយ ដូចដែលបានលើកឡើងខាងលើ ។

ឯកសារយោង

1. *Bodenheimer, S. (1971). Dependency and imperialism: The roots of Latin American underdevelopment. Politics & Society, 1(3), 327-357.*
2. *Cardoso, F. H., & Faletto, E. (1979). Dependency and Development in Latin America (Dependencia Y Desarrollo en América Latina, Engl.): Univ of California Press.*
3. *Chukwuemeka, E., Anazodo, R., & Nzewi, H. N. P. (2011). African Underdevelopment and the Multinationals - A Political Commentary. Journal of Sustainable Development, 4(4), 101-109.*
4. *Desai, V., & Potter, R. B. (2002). The companion to development studies.*
5. *Fenyo, M. D. (2000). Persistent Underdevelopment: Change and Economic Moderization in the West Indies. Journal of Third World Studies, 17(1), 270-272.*
6. *Grosfoguel, R. (2000). Developmentalism, Modernity, and Dependency Theory in Latin America.*
7. *Hite, A. (2000). From Modernization to Globalization: Perspectives on Development and Social Change (Blackwell Readers in Sociology).*
8. *Isbister, J. (1991). Promises not kept: The betrayal of social change in the Third World: Kumarian Press Inc.*
9. *Long, N. (1977). An introduction to the sociology of rural development: Tavistock London.*
10. *Matunhu, J. (2011). A critique of modernization and dependency theories in Africa: Critical assessment. African Journal of History and Culture, 3(5), 65-72.*
11. *Preston, P. (2011). Theories of development (Vol. 107): Routledge.*
12. *Preston, P. W. (1996). Development theory: An introduction: Blackwell Oxford.*
13. *Ray, D. (1973). The dependency model of Latin American underdevelopment: Three basic fallacies. Journal of Interamerican Studies and World Affairs, 15(1), 4-20.*
14. *Santos, T. d. (1970). The structure of dependence. The American Economic Review, 60(2), 231-236.*
15. *Saul, J. S. (2006). Development after globalization: Theory and practice for the embattled South in a new imperial age: Cambridge Univ Press.*
16. *So, A. Y. (1990). Social change and development: Modernization, dependency and world-system theories (Vol. 178): SAGE Publications, Incorporated.*
17. *STEIN, L. (1979). Dependency theories and underdevelopment. Journal of Economic Studies, 6(1), 64-85.*

18. *Valenzuela, J. S., & Valenzuela, A. (1978). Modernization and dependency: Alternative perspectives in the study of Latin American underdevelopment. Comparative politics, 10(4), 535-557.*
19. *Webster, A. (1984). Introduction to the Sociology of Development (Vol. 84): Macmillan London.*
20. *Willis, K. (2011). Theories and practices of development: Taylor & Francis.*

ទស្សន:ដុំវិញបញ្ហានយោបាយសេដ្ឋកិច្ច

Perspectives on Political and Economic Issues

ដោយ៖ លោកបណ្ឌិត ឈឿន សាវន

ប្រធាននាយកដ្ឋានវិទ្យាសាស្ត្រសេដ្ឋកិច្ចនិងទេសចរណ៍,វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម, រាជបណ្ឌិត្យសភាកម្ពុជា

សេចក្តីផ្តើម

នយោបាយសេដ្ឋកិច្ច គឺសំដៅដល់ការគ្រប់គ្រង និងត្រួតពិនិត្យរបស់រដ្ឋាភិបាលទៅលើប្រព័ន្ធសេដ្ឋកិច្ច ដោយសិក្សាពីការកំណត់លើអត្រាពន្ធ ការកំណត់ប្តាប់ធ្មប់ថវិកាជាតិ ការគ្រប់គ្រងរូបិយវត្ថុ ការត្រួតពិនិត្យអត្រាការប្រាក់ និងបូករួមទាំងទីផ្សារពលកម្ម និងការគ្រប់គ្រងលើទ្រព្យសម្បត្តិជាតិប្រកបដោយប្រសិទ្ធភាពជាដើម។ នៅក្នុងខ្លឹមសារនៃទស្សន: ដុំវិញបញ្ហានយោបាយសេដ្ឋកិច្ច គឺសិក្សាទៅលើចំណុច សំខាន់ៗចំនួន៤ គឺ៖(ទី១) គោលការណ៍ទ្រឹស្តីសេដ្ឋកិច្ច (ទី២) ទំនាក់ទំនងនយោបាយសេដ្ឋកិច្ច (ទី៣)សញ្ញាណនៃកស្តុការ និងហិរញ្ញវត្ថុ (ទី៤)គោលការណ៍គ្រប់គ្រងកស្តុការ និងហិរញ្ញវត្ថុ ដែលសំដៅការធ្វើឲ្យមានការកើនឡើងនៃសមត្ថភាពផលិតកម្មនៅក្នុងសេដ្ឋកិច្ច[1]។

១. គោលការណ៍ទ្រឹស្តីសេដ្ឋកិច្ច

នៅក្នុងចំណុចនេះ គឺយើងសិក្សាវិភាគអត្ថន័យសំខាន់ៗចំនួនពីរ គឺអត្ថន័យសេដ្ឋកិច្ច និងប្រព័ន្ធសេដ្ឋកិច្ចវិទ្យាសាស្ត្រ[2]។

១.១-អត្ថន័យសេដ្ឋកិច្ច

*មានទស្សន:របស់អ្នកសេដ្ឋកិច្ចល្បីៗជាច្រើនបានឱ្យនិយមន័យសេដ្ឋកិច្ចផ្សេងៗគ្នា រួមមានដូចជា **សេដ្ឋកិច្ច** គឺជាវិទ្យាសាស្ត្រសង្គមដែលសិក្សាពីការប្រើប្រាស់ធនធានកំរក្នុងសង្គម ដើម្បីបម្រើឱ្យការទាមទារគ្មានព្រំដែនរបស់មនុស្សដែលចង់បាន។ អ្នកសេដ្ឋកិច្ចខ្លះទៀតបានអះអាងថា សេដ្ឋកិច្ច គឺជាវិទ្យាសាស្ត្រសង្គមដែលសិក្សាអំពីដំណើរការ ឬការប្រព្រឹត្តិទៅរបស់មនុស្សម្នាក់ៗ និងដំណើរការរបស់ស្ថាប័ននានាដែលផ្សាភ្ជាប់ជាមួយនឹងដំណើរការឬការប្រព្រឹត្តិទៅរបស់ផលិតកម្មការផ្ទាស់ប្តូរទំនិញ ការបែងចែកទំនិញ ការប្រើប្រាស់ទំនិញ និងរាល់ការប្រព្រឹត្តិទៅរបស់សេវាកម្មផ្សេងៗ។ រីឯមតិខ្លះទៀត*

---

[1] *គាត ឈន់ និង អូន ព័ន្ធមុនីរ័ត្ន "ការអភិវឌ្ឍន៍សេដ្ឋកិច្ចកម្ពុជា នៅក្នុងបរិការណ៍អាស៊ាន" វិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព ១៩៩៨។*

[2] The ASEAN Declaration (Bangkok Declaration) 8 August 1967

បានបញ្ជាក់ថា សេដ្ឋកិច្ច គឺជាសំណុំនៃទំនាក់ទំនងផលិតកម្ម ការប្រើប្រាស់ ការដោះដូរ និងការបែងចែកធនធានក្នុងសង្គមមានន័យថា "សេដ្ឋកិច្ច" គឺជាខឿននៃទំនាក់ទំនង។

ឧទាហរណ៍៖ សំណុំទំនាក់ទំនងផលិតកម្មក្នុងសេដ្ឋកិច្ចទីផ្សារ ខឿនសេដ្ឋកិច្ចជាតិ និងរចនាសម្ព័ន្ធសេដ្ឋកិច្ចទីផ្សារឬសេដ្ឋកិច្ចផែនការជាដើម។ នៅក្នុងអត្ថន័យមួយទៀត សេដ្ឋកិច្ចត្រូវបានគេកំណត់អំពីអត្តសញ្ញាណវិស័យ ឬផ្នែកនិងរាស់ទំហំសេដ្ឋកិច្ចមួយ[៣]។

ឧទាហរណ៍៖ សេដ្ឋកិច្ចឧស្សាហកម្ម សេដ្ឋកិច្ចកសិកម្ម សេដ្ឋកិច្ចជនបទដែលទាំងអស់ នេះជាការកំណត់អត្តសញ្ញាណថាជាវិស័យ ឬជាផ្នែកមួយនៃសេដ្ឋកិច្ច។ ផ្ទុយទៅវិញនៅពេលដែលយើងនិយាយអំពីសេដ្ឋកិច្ចជាតិ សេដ្ឋកិច្ចតំបន់និងសេដ្ឋកិច្ចពិភពលោក ក្នុងនៃន័យនេះយើងចង់បញ្ជាក់ពីទំហំឬបរិមាណសេដ្ឋកិច្ចពីព្រោះសេដ្ឋកិច្ចជាតិតូចជាងសេដ្ឋកិច្ចតំបន់ ចំណែកសេដ្ឋកិច្ចតំបន់ តូចជាងសេដ្ឋកិច្ចពិភពលោកទាំងមូល។ ចំពោះន័យវិទ្យាសាស្ត្រវិញគេបានឱ្យតម្លៃថា "សេដ្ឋកិច្ច" គឺជាកម្មវត្ថុសិក្សា ឬជាវិទ្យាសាស្ត្រ ឧទាហរណ៍៖ វិទ្យាសាស្ត្រសេដ្ឋកិច្ច សេដក្ឋិច្ចនយោបាយ ឬទ្រឹស្តីសេដ្ឋកិច្ច ជាដើម។ ពាក្យសេដ្ឋកិច្ចក្នុងអត្ថន័យនេះយើងចង់បញ្ជាក់អំពីកម្មវត្ថុសិក្សា ឬជាវិទ្យាសាស្ត្រដែលសិក្សាអំពីទំនាក់ទំនងក្នុងសង្គម។ តាមប្រសាសន៍របស់លោក Dr. Janos Kornai ជា សាស្ត្រាចារ្យនៅបណ្ឌិតសភាវិទ្យាសាស្ត្រ ហុងគ្រី និងសកលវិទ្យាល័យហាវើដ (Hungarian Academy of Sciences and Harvard University) បានអះអាងថា សេដ្ឋកិច្ចសង្គមនិយម មានជាប្រចាំនូវឱនភាពទំនិញ (Deficit of goods)។ ក្នុងខណៈនេះគាត់ចង់គូសបញ្ជាក់ពីទំនាក់ទំនងផលិតកម្មនៃប្រព័ន្ធសេដ្ឋកិច្ច សង្គមនិយម ជាទូទៅគឺជំរុញខ្លួនឯងឱ្យមានឱនាភាពទំនិញ[៤]។ ដោយឡែក នៅពេលដែលលោកនិយាយអំពីសេដ្ឋកិច្ចមួយកំពុងស្ថិតនៅក្នុងសភាពមានវិបត្តិសេដ្ឋកិច្ចក្នុងន័យនេះគាត់ចង់បញ្ជាក់អំពីស្ថានភាពឬទំហំនៃសេដ្ឋកិច្ចមួយ[៥]។ ឧទាហរណ៍៖ ស្ថានភាពសេដ្ឋកិច្ចជាតិ សេដ្ឋកិច្ចតំបន់ ឬស្ថានភាពសេដ្ឋកិច្ចពិភពលោក។ ម៉្យាងទៀត គាត់បានបញ្ជាក់ថា«សេដ្ឋកិច្ច គឺជាការសិក្សា វិះរកមធ្យោបាយសម្រាប់លើកកម្ពស់ឱ្យមានប្រសិទ្ធភាពធនធានដែលមាននៅក្នុងសង្គមនិងដើម្បីបំពេញឱ្យបាននូវសេចក្តីត្រូវការរបស់ខ្លួន»។ ពាក្យ សេដ្ឋកិច្ច ន័យនេះលោកសម្តៅកម្មវត្ថុ សិក្សាវិទ្យាសាស្ត្រសេដ្ឋកិច្ច ឬទ្រឹស្តីសេដ្ឋកិច្ច។

១.២-ប្រព័ន្ធសេដ្ឋកិច្ចវិទ្យា

ជាការពិត ដើម្បីរកឱ្យឃើញនូវប្រសិទ្ធភាពក្នុងការប្រើប្រាស់កត្តាផលិតកម្មដែលមានក្នុងការផលិតទំនិញ សម្រាប់បំពេញសេចក្តីត្រូវការនៅក្នុងសង្គមមនុស្ស គឺត្រូវយល់ពីកម្មវត្ថុនៃ

[៣] Economic Principles Problems and Policies by Mc Connell and Brue, Fourteenth Edition 1999,P.5

[៤] Logistical Management: by Donold J. Bowersox and David J. Closs, 1996 P.5

[5] Microeconomics by Robert S. Pindyck and Daniel L. Rubinfeld, 1995, P.10-12

ប្រព័ន្ធសេដ្ឋកិច្ចវិទ្យាសាស្ត្រ[៦]។ នៅពេលឱ្យនិយមន័យរបស់វិទ្យាសាស្ត្រសេដ្ឋកិច្ចសេដ្ឋវិទូអង់គ្លេស (JeanBaptisteSay.176701 832) បានសរសេរថា "ទស្សន: ស្តីពីសេដ្ឋកិច្ចនយោបាយបានបង្ហាញឱ្យឃើញថា តើធនធានធម្មជាតិនានាកើតឡើងដូចម្តេច? និងប្រើប្រាស់ដូចម្តេច? ដើម្បីបំពេញឱ្យបាននូវសេចក្តីត្រូវការរបស់សង្គមមនុស្ស"។ គួបផ្សំទស្សន:ខាងលើនេះ ទស្សនវិទូសេដ្ឋវិទូ និងជាទ្រឹស្តីនៃសង្គមនិយម អាល្វឺម៉ង់ បានសរសេរថា(Karl Mark,1818-1883) "សេដ្ឋកិច្ចនយោបាយជាវិទ្យាសាស្ត្រសិក្សាពីក្រឹត្យក្រម មុខងារ និងការអភិវឌ្ឍន៍ទំនាក់ទំនងមនុស្សនិងមនុស្ស តាមរយៈផលិតកម្ម ការបែងចែក ការផ្លាស់ប្តូរ និងការប្រើប្រាស់ធនធាននានាក្នុងដំណាក់កាលនៃការអភិឌ្ឍន៍សង្គមមនុស្ស"។ ដោយឡែក អាល់ហ្វ្រេដ ម៉ារស្សាល (Alfred Marchall, 1842-1924) សេដ្ឋកិច្ចវិទូអង់គ្លេសបានអះអាងថា "ទស្សន:វិទ្យាសាស្ត្រសេដ្ឋកិច្ចជាសកម្ម ភាពជីវភាពធម្មតារបស់មនុស្ស "ក្នុងន័យនេះលោកចង់គូសបញ្ជាក់ថា "បញ្ហាជ្រើសរើសក្នុង សេដ្ឋកិច្ចអំពីការប្រើប្រាស់ភោគទ្រព្យធម្មជាតិដែលមានសម្រាប់បំពេញសេចក្តីត្រូវការរបស់មនុស្សជាបញ្ហាទូទៅដែលត្រូវជួបជាប្រចាំក្នុងជីវភាពនៃការរស់នៅ"។ ជាក់ស្តែងការជ្រើសរើសនេះក្នុងជីវភាពរស់នៅយើងជួបប្រទះស្ទើរគ្រប់វិនាទី ឧទាហរណ៍ ការបែងចែកពេលវេលាដែលមានកំណត់រវាងការសិក្សានិងការកំសាន្តឬការឈប់សម្រាកជាដើម។

ទស្សន:វិទ្យាសាស្ត្រសេដ្ឋកិច្ចដែលផ្តល់ដោយសេដ្ឋវិទូខាងលើគេអាចសន្និដ្ឋានថា ពិតមែនតែទម្រង់នៃទស្សន:ទាំងអស់នេះមានលក្ខណៈខុសៗគ្នា ប៉ុន្តែជាទូទៅមានអត្ថន័យប្រហាក់ប្រហែលគ្នា។ ដូច្នេះយើងអាចឱ្យនិយមន័យរួមគ្នាថា "វិទ្យាសាស្ត្រសេដ្ឋកិច្ចជាការសិក្សាស្រាវជ្រាវរកវិធី ដោយធ្វើយ៉ាងដោះស្រាយបញ្ហាប្រើប្រាស់ និងគ្រប់គ្រងធនធានសេដ្ឋកិច្ច ដែលមានដោយកម្រឱ្យបានប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិ ដើម្បីបំពេញឱ្យតម្រូវការរបស់សង្គមមនុស្ស"។ ក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ជាពិសេសប្រទេសក្រីក្រប្រសិនបើយើងនិយាយ អំពីការប្រើប្រាស់ធនធានដែលមានបានប្រកបដោយប្រសិទ្ធភាព ពោលស្របទៅតាមសេចក្តីត្រូវការជាក់ស្តែងរបស់សង្គម និងឱ្យបានប្រកបដោយភាពស័ក្តិសិទ្ធិ ប្រការនេះបានចេញជាផ្លែផ្កានូវកំណើនសេដ្ឋកិច្ចខ្ពស់ប្រកបដោយចីរភាព និងមានសមធម៌ គឺជាការពិបាក និងស្មុគ្រស្មាញ។ ស្របទៅតាមសេចក្តីត្រូវការរបស់សង្គមសំដៅទៅលើការប្រើប្រាស់ធនធានមនុស្ស ធនធានធម្មជាតិ និងទំនិញវិនិយោគដែលមានក្នុងប្រទេសឱ្យអស់លទ្ធភាព និងស្របទៅតាមលក្ខខណ្ឌនៃការអភិវឌ្ឍសេដ្ឋកិច្ច។ ឆ្លងតាមរយៈការប្រើប្រាស់ឱ្យអស់លទ្ធភាព និងស្របតាមលក្ខខណ្ឌតាមរយៈការប្រើប្រាស់ឱ្យអស់លទ្ធភាព និងស្របតាមលក្ខខណ្ឌនៃការអភិវឌ្ឍន៍សេដ្ឋកិច្ច។

[៦] Economic: Theory and Applications by Hoon Hian Teck, Koh Ai Tee, Anthony Chin and Euston Quah, International Edition 2003, P.23-24

ប្រព័ន្ធសេដ្ឋកិច្ចវិទ្យាសាស្ត្រត្រូវបានបែងចែកជាបីសំខាន់ៗគឺ៖

ក.សេដ្ឋកិច្ចទីផ្សារសិរី (Free market economy)

ក្នុងប្រព័ន្ធសេដ្ឋកិច្ចទីផ្សារសិរី កម្មសិទ្ធលើធនធានសេដ្ឋកិច្ចមួយភាគធំស្ថិតនៅក្នុងវង្វង់នៃការគ្រប់គ្រងរបស់ផ្នែកឯកជនដែលជានីតិបុគ្គលនិងរូបវន្តបុគ្គល។ ដោយឡែកយន្តការគ្រប់គ្រង និងសម្របសម្រួលគឺផ្នែកទាំងស្រុងលើយន្តការទីផ្សារដែល«តាមទ្រឹស្តីក្លាសុិក ហៅថា ជាសេដ្ឋកិច្ចដែលធ្វើនិយ័តកម្មដោយខ្លួនឯង (Economy is self-regulating)»។ប្រព័ន្ធសេដ្ឋកិច្ចបែបនេះសេចក្តីសម្រេចចិត្តក្នុងការបែងចែកធនធានជាសេរីភាពរបស់ភ្នាក់ងារសេដ្ឋកិច្ចនីមួយៗ។ ជាការពិត សេរីភាពនេះអាស្រ័យទៅនឹងសេក្តីត្រូវការ និងការផ្គត់ផ្គង់ក្នុងសង្គម សេដ្ឋកិច្ច ពីព្រោះមុននឹងផលិតរបស់អ្វីមួយភ្នាក់ងារសេដ្ឋកិច្ចដែលជាផលិតករត្រូវសិក្សាអំពីសេចក្តីត្រូវការរបស់អតិថិជន ឬអ្នកប្រើប្រាស់។ ករណី នេះច្បាស់ណាស់ថាសកម្មភាពផលិតកម្មការផ្ទាសប្តូរ និងការប្រើប្រាស់ទំនិញនិងសេវាជាទូទៅត្រូវមានសេរីភាពបរិបូរណ៍។ ក្នុងក្របខ័ណ្ឌសេដ្ឋកិច្ចទីផ្សារសេរី ភ្នាក់ងារសេដ្ឋកិច្ចនីមួយៗត្រូវគ្រប់គ្រងដោយខ្លួនឯងនូវអត្ថប្រយោជន៍ផ្ទាល់ខ្លួន និងខិតខំប្រឹងប្រែងធ្វើឱ្យស្ថានភាពអាជីវកម្មរបស់ខ្លួនកាន់តែល្អប្រសើរតាមរយៈការប្រកួតប្រជែង[៧]។

អាដាម ស្មីត សេដ្ឋវិទូក្លាសុិក (Adam Smith,1723-1790 បានអះអាងក្នុងស្នាដៃល្បីល្បាញឈ្មោះ«គោគទ្រព្យប្រជាជាតិ» ដែលបានពិពន្ធក្នុងឆ្នាំ១៧៧៦ ថាក្នុងអាជីវភាពសេដ្ឋកិច្ចសកម្មភាពរបស់បុគ្គលម្នាក់ៗប្រព្រឹត្តទៅតាមអត្ថប្រយោជន៍ផ្ទាល់ខ្លួនដែលពិនិត្យមើលទៅហាក់ដូចជា«ដៃអរូបី» សម្រាប់ចូលរួមបង្កើតអត្ថប្រយោជន៍សង្គមទាំងមូល។ ដូច្នេះ ដៃ"អរូបី" មានសកម្មភាពក្នុងសេដ្ឋកិច្ចនាំឱ្យការបែងចែកធនធានសេដ្ឋកិច្ចមានប្រសិទ្ធភាព ប្រការនេះរដ្ឋមិនចាំបាច់ ធ្វើអន្តរាគមន៍នោះទេ។ អាដាម ស្មីត បានអះអាងទៀតថា ប្រព័ន្ធគ្រប់គ្រងសេដ្ឋកិច្ចបែបទីផ្សារសេរីមានលក្ខណៈល្អប្រសើរពីព្រោះ៖

- ការប្រើប្រាស់ធនធានសេដ្ឋកិច្ច ប្រកបដោយវិចារណភាព
- មានកំណើនផលិតកម្ម និងអាចកាត់បន្ថយអត្រានិកម្មភាព
- សេដ្ឋកិច្ចមានស្ថិរភាព

ដូច្នេះហើយអ្នកនិយមសេដ្ឋវិទូក្លាសុិកនៅមានជំនឿថាក្នុងសកម្មភាពសេដ្ឋកិច្ចរដ្ឋពុំចាំបាច់លូកដៃធ្វើអន្តរាគមន៍ រដ្ឋមានតួនាទីត្រឹមជាអ្នកការពារកម្មសិទ្ធិ ឬជាអ្នកបង្កើត និងចាត់ចែងស្ថាប័នសង្គមព្រមទាំងចងក្រងឡើងនូវមូលដ្ឋានច្បាប់ផ្សេងៗដែលចាំបាច់សម្រាប់ជំរុញ និងសម្របសម្រួលការប្រព្រឹត្តទៅនៃប្រព័ន្ធសេដ្ឋកិច្ច

[៧] Leo Melamed, "Evolution of the International Monetary Market " Cato Journal, 8:2, Fall 1988 P.393-404

ទីផ្សារប៉ុណ្ណោះ[៨]។ ទន្ទឹមនឹងនេះដែរប្រព័ន្ធគ្រប់គ្រងសេដ្ឋកិច្ចទីផ្សារអាចនឹងជំរុញការទៅបានមានប្រសិទ្ធភាព គឺដោយសារមានសមាសភាពយន្តការទីផ្សារសំខាន់ៗច្រើនដូចខាងក្រោម៖

-កម្មសិទ្ធិឯកជន៖ ក្នុងទ្រឹស្តីប្រព័ន្ធកិច្ច ទីផ្សារធនធានសម្ភារៈមួយភាគធំជាកម្មសិទ្ធិ រូបវន្តបុគ្គល ឬនីតិបុគ្គលនិងមួយផ្នែកទៀតជាកម្មសិទ្ធិសាធារណៈ។ កម្មសិទ្ធឯកជនជាមួយនឹងភាពគ្រប់បៃបយ៉ាងអាចធ្វើឱ្យម្ចាស់ កម្មសិទ្ធិទិញត្រួតពិនិត្យ ប្រើប្រាស់ និងលក់ធនធានសម្ភារៈដែលជាកម្មសិទ្ធរបស់ខ្លួនក្នុងគោលបំណងស្វែងរកចំណូលសម្រាប់បំពេញ សេចក្តីត្រូវការរបស់ខ្លួនដោយសេរី។ ទន្ទឹមនោះរដ្ឋតាមរយៈស្ថាប័នច្បាប់គឺជាអ្នកធានា និងទទួលស្គាល់កម្មសិទ្ធិផ្ទេរកម្ម សិទ្ធិរបស់ខ្លួនទៅអ្នកដ៏ទៃ។ ក្នុងប្រឈ័ណ្ឌនេះរដ្ឋជាអាជ្ញាកណ្តាល ជាអ្នកពិន័យ និងលើកទឹកចិត្តដល់ភ្នាក់ងារសេដ្ឋកិច្ចនានា។ ស្របនឹងសេរីភាពដ៏ទូលំទូលាយនេះការប្រើប្រាស់កម្មសិទ្ធិឯកជនក៏មានការកំណត់ដែរ ជាពិសេសការប្រើប្រាស់ធនធានដែលនាំឱ្យប៉ះពាល់ដល់បរិស្ថានសង្គម និងបរិស្ថានធម្មជាតិ។ ម៉្យាងទៀតធនធានមួយចំនួនត្រូវស្ថិតនៅជាកម្មសិទ្ធិរបស់រដ្ឋ ទោះជាក្នុងសេដ្ឋកិច្ចទីផ្សារសេរីក៏ដោយគេទទួលស្គាល់ថាដើម្បីជំរុញឱ្យមានប្រសិទ្ធភាពក្នុងការប្រើប្រាស់ធនធានសេដ្ឋកិច្ចរដ្ឋត្រូវមានកម្មសិទ្ធិលើធនធានមួយចំនួនជាការចាំបាច់។

សេរីភាពក្នុងការជ្រើសរើស លក្ខខណ្ឌសេដ្ឋកិច្ចទីផ្សារសេរី ដែលជិតស្និទ្ធជាមួយនឹងកម្មសិទ្ធឯកជនគឺ សេរីភាពសហគ្រិនក្នុងការជ្រើសរើស។ ក្នុងសេដ្ឋកិច្ចទីផ្សារសេរី សេរីភាពជ្រើសរើសរបស់សហគ្រិនមានសារៈ សំខាន់ណាស់ក្នុងការទទួលខុសត្រូវ និងការសម្រេចចិត្តដើម្បីការប្រើប្រាស់ឱ្យមានប្រសិទ្ធិភាពនិងដើម្បីឱ្យមានជាអតិបរមានូវធនធានដែលមានតាមរាល់មធ្យោបាយ និងនីតិវិធីដែលមានក្នុងរង្វង់នៃប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ។

សេរីភាពសហគ្រិនមានន័យថា៖ ម្ចាស់កម្មសិទ្ធិអាចទិញដូរដោយសេរីនូវធនធានសេដ្ឋកិច្ចសម្រាប់ប្រើប្រាស់ និងចាត់ចែងធនធានទាំងនោះក្នុងគោលបំណងដំណើរការផលិតទំនិញ ឬសេវាតាមការជ្រើស រើសមុខរបរអាជីវកម្មរបស់ខ្លួនផ្ទាល់ហើយមានសិទ្ធិ ក្នុងការលក់ដូរទំនិញទាំងនេះក្នុងផ្សារតាមតម្លៃ និងបរិមាណ ផលិតផលនិងតាមការសម្រេចចិត្តរបស់ខ្លួនដោយគ្មានឧបសគ្គ ឬការកំណត់ផ្សេងៗដែលរៀបចំដោយភាគីរដ្ឋឡើង។ ទន្ទឹមនឹងនោះគ្មានណាត្រូវហាមឃាត់សហគ្រិន ក្នុងការសម្រេចចិត្តចូលធ្វើអាជីកម្មក្នុងវិស័យណាមួយដែលជាផ្នែករបស់សេដ្ឋកិច្ចជាតិ ឬចាកចេញពីអាជីវកម្មវិស័យនោះទេលើកលែងតែប៉ះពាល់ដល់សណ្តាប់ធ្នាប់សង្គម

[៨] អនុក្រឹត្យលេខ ៦៦ អន.ក្រ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការបង្កើតអគ្គនាយកដ្ឋានកសិកម្ម និងហិរញ្ញវត្ថុ ភ្នំពេញ, ថ្ងៃទី ១១ ខែឧសភា ឆ្នាំ២០០៧។

ឬបរិស្ថាន។ ជាមួយគ្នានេះដែរ សេរីភាពក្នុងការជ្រើសរើសមានន័យថា៖

-ម្ចាស់កម្មសិទ្ធិធនធានសេដ្ឋកិច្ច(ធនធានធម្មជាតិ កម្លាំងពលកម្ម និងទំនិញវិនិយោគ) អាចប្រើប្រាស់ជួល ឬលក់ ធនធានទាំងនេះតាមការយល់ឃើញរបស់ខ្លួន ឧទាហរណ៍៖ ម្ចាស់កម្លាំងពេលអាចព្រមព្រៀងលក់កម្លាំងពលកម្មតាមតម្លៃនៃសកម្មភាពរបស់ខ្លួន។

-អ្នកប្រើប្រាស់ មានសេរីភាពក្នុងក្របខ័ណ្ឌថវិកា ឬចំណូលដែលខ្លួនមានសម្រាប់ទិញទំនិញ និងសេវាក្នុងតម្លៃ និងបរិមាណដែលខ្លួនយល់ថា សមស្រប និងបំពេញបំណងរបស់ខ្លួនបាន។

ក្នុងប្រការទាំងនេះគួរកត់សម្គាល់ថា៖ សេរីភាពរបស់អ្នកប្រើប្រាស់ មានលក្ខណៈទូលំទូលាយណាស់ ពីព្រោះសេរីភាពរបស់ផលិតករតាមការជាក់ស្តែងស្ថិតក្នុងព្រំដែននៃសេចក្តីត្រូវការរបស់អ្នកប្រើប្រាស់ ដែលអ្នកប្រើប្រាស់ជាអ្នកសម្រេចឱ្យផលិតករថា តើត្រូវផលិតអ្វី? ផលិតដូចម្តេច? ផលិតចំនួនប៉ុន្មាន? ពីព្រោះផលិតករមិនអាចផលិតអ្វីដែលអ្នកប្រើប្រាស់មិនប្រាថ្នានោះទេ។ បទពិសោធន៍និងការអនុវត្តន៍ជាក់ស្តែងបានបង្ហាញច្បាស់ពីបញ្ហាទាំងនេះ។

-អត្ថប្រយោជន៍បុគ្គល ដោយសេដ្ឋកិច្ចទីផ្សារសេរី មានលក្ខណៈជាប្រព័ន្ធសេដ្ឋកិច្ចបុគ្គលគ្មានអ្វីគួរងឿងឆ្ងល់ថាកម្លាំងចលករសេដ្ឋកិច្ចស្ថិតក្នុងការជំរុញផលប្រយោជន៍បុគ្គលនោះទេ។ ភ្នាក់ងារសេដ្ឋកិច្ចនីមួយៗមានគោលបំណងដូចគ្នាគឺត្រូវធ្វើយ៉ាងណាដើម្បីឱ្យអាជីវកម្មរបស់ខ្លួនបានទទួលផលប្រយោជន៍ច្រើនជាពិសេសបានទទួលចំណូលជាអតិបរមា ក្នុងហានិភ័យជាអប្បបរមា។ ជាមួយគ្នានោះម្ចាស់កម្មសិទ្ធិធនធានខិតខំលក់ ឬជួលធនធានទាំងនេះ ក្នុងតម្លៃខ្ពស់ ឯអ្នកប្រើប្រាស់ក្នុងពេលទិញទំនិញ ឬសេវា ត្រូវការអ្វីដែលមានគុណភាពខ្ពស់ និងតម្លៃទាប។ និយាយរួមសេដ្ឋកិច្ចទីផ្សារសេរីបង្ហាញឡើងពីអត្ថប្រយោជន៍បុគ្គលក្នុងការបង្កើតមូលដ្ឋានជាគំរូសម្រាប់ការប្រព្រឹត្តទៅរបស់ភ្នាក់ងារសេដ្ឋកិច្ចនីមួយៗក្នុងការអនុវត្តន៍សេរីភាពជ្រើរើសរបស់ខ្លួន។ ក្នុងន័យនេះលំនាំអត្ថប្រយោជន៍បុគ្គលមាន តួនាទីសម្របសម្រួល និងធ្វើឱ្យរលូនទៅតាមគន្លងសេដ្ឋកិច្ចទីផ្សារពីព្រោះប្រសិនបើខ្វះលំនាំនេះ ភាពអនាធិបតេយ្យនឹងកើតឡើង។

-ការប្រកួតប្រជែង: សេរីភាពក្នុងការជ្រើសរើសដែលប្រព្រឹត្តទៅក្នុងគោលបំណងដើម្បីទទួលចំណូលសម្រេចបានដោយធ្ងន់កាត់ការប្រកួតប្រជែង។ ការប្រកួតប្រជែងអាចធ្វើទៅបានក្នុងករណីវត្តមានអ្នកលក់ និងអ្នកទិញច្រើនក្នុងទីផ្សារ ហើយនឹងសេរីភាពអ្នកលក់និងទិញ។ ជាទូទៅនៅពេលមានវត្តមានអ្នកលក់ និងអ្នកទិញច្រើនលើទីផ្សារ ជាប្រការដែលមិនអាចធ្វើឱ្យអ្នកលក់ ឬអ្នកទិញណាម្នាក់កំណត់ឬមានឥទ្ធិពលលើតម្រូវការ ឬការផ្គត់ផ្គង់លើមុខទំនិញណាមួយឡើង ជាពិសេសគេមិនអាចមានឥទ្ធិពលលើថ្លៃទំនិញបានទេ។ ទន្ទឹមនឹងនេះ យើងដឹងថាកាលណាបរិមាណទំនិញ ឬសេវាមួយ

មានចំនួនតិច ថ្លៃទំនិញ ឬសេវានោះនឹងមានតម្លៃខ្ពស់ម៉្យាងទៀតផលិតករមួយចំនួនតួចអាចព្រួតដៃគ្នា ដើម្បីនឹងកាត់បន្ថយការផ្គត់ផ្គង់ហើយជាបន្ត ពួកគេអាចតម្រើងថ្លៃទំនិញបាន។ នេះជាករណីមួយ ក៏ប៉ុន្តែជាទូទៅខ្វឹមសារការប្រកួតប្រជែង គឺសំដៅពេលណាដែលក្នុងទីផ្សារមានចំនួនអ្នកលក់ និងអ្នកទិញច្រើន ដូច្នេះភ្នាក់ងារសេដ្ឋកិច្ចនីមួយៗមិនអាចតម្លៃងថ្លៃទំនិញ ឬកាត់បន្ថយការផ្គត់ផ្គង់បានឡើយ។ ក្នុងន័យនេះ អ្នកលក់មានឥទ្ធិពលតិចណាស់ក្នុងការកាត់បន្ថយផ្គត់ផ្គង់ ដើម្បីតម្លៃថ្លៃទំនិញ ឬសេវា។ ដូចគ្នានឹងអ្នកប្រើប្រាស់ដោយមានចំនួនលើសលប់ក្នុងទីផ្សារហើយតាមធម្មតាម្នាក់ៗមានចំណង់ចំណូលចិត្តដាច់ដោយឡែកពីគ្នា និងគ្មានអ្នកណាអាស្រ័យដោយអ្នកណា ដូច្នេះគេមិនអាចនិងពួតដៃគ្នាដើម្បីកាត់បន្ថយ ឬបង្កើនតម្រូវការក្នុងសង្គម និងបញ្ចុះតម្លៃទំនិញ ឬសេវាបានទេ។ គួរកត់សម្គាល់ថាការផ្តល់សេរីភាពនៅក្នុងសកម្មភាពសេដ្ឋកិច្ច គឺជាមូលដ្ឋានរស់របស់ការប្រកួតប្រជែង។ តាមរយៈនេះសេរីភាពអាចទប់ស្កាត់មិនឱ្យមានជម្លោះ និងការរីវាទរវាងផលិតករ និងអ្នកប្រើប្រាស់នៅក្នុងការស្វែងរកលាភ ឬផលប្រយោជន៍ រៀងៗខ្លួនពីព្រោះការប្រកួតប្រជែងបង្កើតព្រំដែនសម្រាប់ដំណើរប្រព្រឹត្តទៅនៃការស្វែងរកអត្ថប្រយោជន៍បុគ្គល។ ជារួមការប្រកួតប្រប្រជែងជាកម្លាំង ឬជាយន្តការ ដ៏សំខាន់ក្នុងប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ ជាពិសេសការជំរុញឱ្យមានការប្រើប្រាស់បច្ចេកវិទ្យាទំនើប ដើម្បីលើកកម្ពស់ គុណភាពទំនិញ និងកាត់បន្ថយថ្លៃដើមក្នុងផលិតកម្ម។ ម៉្យាងទៀត នៅក្នុងប្រព័ន្ធសេដ្ឋកិច្ចទីផ្សារការប្រកួតប្រជែងជំរុញឱ្យផលិតការចេញ-ចូលពីវិស័យមួយទៅវិស័យណាមួយក្នុងសេដ្ឋកិច្ចជាតិតាមបំណង់ និងការជ្រើសរើសរបស់ខ្លួន។ អត្ថន័យការប្រកួតប្រជែងក្នុងចំណុចនេះមានសារៈសំខាន់ណាស់សម្រាប់រក្សាឱ្យបាននូវស្ថេរភាពសេដ្ឋកិច្ចយូរអង្វែង។ សេរីភាពក្នុងការផ្ទាស់ប្តូរពីអាជីវកម្មមួយទៀត មានភាពចាំបាច់ណាស់សម្រាប់សម្របសម្រួលសេចក្តីត្រូវការរបស់អ្នកប្រើប្រាស់ រួមទាំងការលើកកម្ពស់ប្រៀបគ្រប់គ្រងថ្មី មានបច្ចេកវិជ្ជាទំនើប និងការផ្គត់ផ្គង់ធនធានសេដ្ឋកិច្ច។

-ប្រព័ន្ធបង្កើតថ្លៃប្រព័ន្ធទីផ្សារ ឬប្រព័ន្ធបង្កើតថ្លៃជាយន្តការសម្របសម្រួលដ៏សំខាន់នៃសេដ្ឋកិច្ចទីផ្សារ។ ដំណោះ ស្រាយក្នុងការផ្តោះប្តូរទំនិញនិងសេវារវាងផលិតកនិងអ្នកប្រើប្រាស់ប្រព្រឹត្តទៅក្នុងទីផ្សារ ស្ថិតនៅលើថ្លៃទំនិញ ចំណែកការបង្កើតថ្លៃទំនិញស្ថិតនៅលើបរិមាណតម្រូវការ និងការផ្គត់ផ្គង់ទំនិញ។ ការព្រមព្រៀងគ្នាក្នុងការផ្ទាស់ប្តូរ ជាពិសេសសមតាមបរិមាណតម្រូវការ និងការផ្គត់ផ្គង់បង្កើតបានជាថ្លៃទីផ្សារ។ ផ្នែកលើថ្លៃទីផ្សារ និងស្ថានភាពទីផ្សារ ផលិតការអាចជ្រើសរើសបរិមាណ និងមុខទំនិញដែលខ្លួនត្រូវផលិត ហើយដែលយល់ថា នឹងអាចមានអត្ថប្រយោជន៍ ដល់ខ្លួន។ ថ្លៃគឺជាសញ្ញាក់ប្រាប់ផលិតករ និង អ្នកប្រើប្រាស់ តើត្រូវមានសកម្មភាពដូចម្តេចក្នុងទីផ្សារ?។ ប្រសិនបើទំនិញ ឬសេវា

មិនអាចលក់បានតាមថ្លៃដើមដែលបានផលិត នោះទេមានន័យថា ទំនិញ និងសេវាទាំងនេះ មានតម្រូវការទាប ឬមានគុណភាពមិនស្របទៅនឹងថ្លៃសញ្ញានេះជាព័ត៌មានសម្រាប់ផលិតករក្នុងការពិចារណាដើម្បីកាត់បន្ថយបរិមាណ ឬកែតម្រូវផលិតកម្មរបស់ខ្លួនឱ្យស្របទៅនឹងតម្រូវការទីផ្សារ។ ប្រសិនបើថ្លៃទំនិញកើនឡើងខ្ពស់ មានន័យថាបរិមាណទំនិញ ទាំងនេះមានតំការខ្ពស់ប្រការនេះជាសញ្ញាសម្រាប់ផលិតករបង្កើនផលិតកម្មបន្ថែមស្របទៅតាមតម្រូវការទីផ្សារ។ ការកាត់បន្ថយ និងការបង្កើនផលិតកម្ម និងការឡើងចុះថ្លៃទំនិញផ្ទាស់ប្តូរហូតដល់កម្រិតមួយដែលកិច្ចព្រមព្រៀងគ្នា ក្នុងខណៈដែលទំនិញមានបរិមាណស្មើនឹងតម្រូវការតាមរយៈសមភាពតម្រូវការ និងការផ្គត់ផ្គង់ក្នុងទីផ្សារបង្កើតបានជាថ្លៃសម តាដែលហៅថា ថ្លៃទីផ្សារ។ ផ្នែកតាមរយៈថ្លៃនេះផលិតករ និងអ្នកប្រើប្រាស់អាចតតែតម្រូវការជ្រើសរើសរបស់ខ្លួនដើម្បីទទួលអត្ថប្រយោ-ជន៍ដែលខ្លួនប្រាថ្នាឱ្យបានជាតិបរមា។ ដូច្នេះថ្លៃទំនិញមានតាទីយ៉ាងសំខាន់ក្នុងការដោះស្រាយបញ្ហាចំបងរបស់សេដ្ឋកិច្ចថាតើត្រូវផលិតអ្វី? ផលិតដូចម្តេច?និងត្រូវបែងចែកចំណូលយ៉ាងណា?រវាងភ្នាក់ងារសេដ្ឋកិច្ចនីមួយៗ។ក្នុងក្រខ័ណ្ឌនេះ លោក អាដាមស្មីត បានចាត់ទុកទីផ្សារជាអ្នកសម្របសម្រួលដ៏សំខាន់។ យន្តការប្រកួតប្រជែងតាមរយៈ ថ្លៃនិងគុណភាពទំនិញ មានតួនាទីសម្របសម្រួលនិងជំរុញឱ្យសេដ្ឋកិច្ចដំណើរការទៅតាមលំដាប់លំដាយនិងលើកកម្ពស់ការប្រើប្រាស់ធនធានដែលមាន ជាពិសេសរួមចំណែកក្នុងការបង្កើតឱ្យមានសហគ្រិនដែលមានទេពកោសល្យ និងមានសមត្ថភាពចូលរួមក្នុងដំណើរការអាជីវកម្ម។ ទន្ទឹមនឹងនេះអត្ថប្រយោជន៍បុគ្គលក្នុងការស្វែងរកប្រាក់ចំណូលខ្ពស់ត្រូវអនុវត្តក្នុងលក្ខខ័ណ្ឌការប្រកួតប្រជែងដោយយុត្តិធម៌។

ខ. សេដ្ឋកិច្ចបញ្ជា (Command economy)

ផ្ទុយនឹងសេដ្ឋកិច្ចទីផ្សារសេរី ក្នុងប្រព័ន្ធសេដ្ឋកិច្ចបញ្ជារដ្ឋ មានកម្មសិទ្ធិលើធនធាន និងកត្តាផលិតកម្មស្ទើរតែទាំងអស់ ឯយន្តការគ្រប់គ្រង់ និងសម្របសម្រួលផ្នែកលើមូលដ្ឋានការរបស់រដ្ឋមានន័យថា ដំណើរការផលៀតកម្មស្ថិតក្រោមការគ្រប់គ្រង់របស់រដ្ឋស្ទើរទាំងស្រុង។ ដំណោះស្រាយធំៗទាក់ទងទៅនឹងផលិតកម្ម ការប្រើប្រាស់ ការបែងចែកធនធានផ្សេងៗ ត្រូវស្ថិតនៅក្រោមការកំណត់របស់រដ្ឋ។ សហគ្រាសជាកម្មសិទ្ធិរបស់រដ្ឋ ដូច្នេះសកម្មភាពភ្នាក់ងារសេដ្ឋកិច្ច ទាំងក្នុងផលិតកម្ម ការបែងចែកព្រមទាំងការផ្ទាស់ប្តូរទំនិញ និងសេវាស្ថិតនៅក្រោមការត្រួតពិនិត្យ និងអនុវត្តតាមផែនការរបស់រដ្ឋ។ និយាយរួមផែនការផលិតកម្មរបស់សហគ្រាសនីមួយៗចាត់ចែង និងត្រួតពិនិតដោយរដ្ឋដែលមានក្រុមប្រឹក្សាផែនការីជាតំណាង ហើយជាទៅផែនការីទាំងនេះជាអ្នកកំណត់ ចំពោះសហគ្រាសនីមួយៗពីបរិមាណផលិតផលនិងតើត្រូវផលិតផលអ្វី?សម្រាប់អ្នកណា? ចំនួនប៉ុន្មាន?

ដូច្នេះសមាមាត្របរិមាណផលិតកម្មរវាងទំនិញវិនិយោគ និងទំនិញប្រើប្រាស់សម្រាប់ប្រជាពលរដ្ឋត្រូវបានគ្រប់គ្រង និងកំណត់ដោយផែនការរដ្ឋ។ ទន្ទឹមនោះគួរកត់សម្គាល់ថាប្រព័ន្ធសេដ្ឋកិច្ចតាមរបៀបសេដ្ឋកិច្ចបញ្ជា ឬសេដ្ឋកិច្ចទីផ្សារសេរីសុទ្ធសាធពុំមានលក្ខណៈប្រាកដនិយមឡើយ។

ជាក់ស្តែងការបកស្រាយខាងលើគ្រាន់តែជាអត្ថប្រយោជន៍សម្រាប់ការយល់ដឹងជារួមតែប៉ុណ្ណោះ។ បទពិសោធន៍ ក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចកន្លងមកបានបង្ហាញឱ្យឃើញថា ប្រព័ន្ធគ្រប់គ្រងសេដ្ឋកិច្ចទាំងអស់ក្នុងពិភពលោកនេះមានលក្ខណៈជាប្រព័ន្ធសេដ្ឋកិច្ចចម្រុះ ឬមួយសេដ្ឋកិច្ចចម្រុះបែបផែនការ ឬមួយសេដ្ឋកិច្ចចម្រុះបែបទីផ្សារ។

គ.សេដ្ឋកិច្ចចម្រុះ (Mixes economy)

ក្នុងប្រព័ន្ធគ្រប់គ្រងសេដ្ឋកិច្ចចម្រុះយន្តការរដ្ឋ និងយន្តទីផ្សារ មានតួនាទីសំខាន់ដូចគ្នាក្នុងការដោះស្រាយបញ្ហាថា តើត្រូវផលិតអ្វី? ផលិតដូចម្តេច? សម្រាប់អ្នកណា? ក្នុងការអនុវត្តកន្លងមកប្រព័ន្ធសេដ្ឋកិច្ចចម្រុះច្រើនស្ថិតនៅចន្លោះជាសេដ្ឋកិច្ចចម្រុះបែបទីផ្សារ ពីព្រោះថានៅក្នុងសកម្មភាព សេដ្ឋកិច្ចជាច្រើនដោយផ្នែកឯកជនហើយសកម្មភាពមួយចំនួនទៀតដើរតួដោយរដ្ឋខ្លួនឯងតាមរយៈការអនុវត្តបទបញ្ញត្តិផ្សេងៗព្រមទាំងកំណត់ការយកពន្ធនិងការឧបត្ថម្ភធនជាដើម។ ពិសេសជាងនេះទៅទៀត រដ្ឋមានតួនាទីយ៉ាងសកម្មក្នុងការប្រើប្រាស់ឧបករណ៍ម៉ាក្រូសេដ្ឋកិច្ចដែលមានក្នុងដៃសម្រាប់សម្របសម្រួលក្នុងការដំណើរការអភិវឌ្ឍសេដ្ឋកិច្ច ដូចជា អនុវត្តន៍គោលនយោបាយសារពើពន្ធ ដើម្បីរក្សាស្ថេរភាពការផ្គត់ផ្គង់ និងជំរុញកំណើនសេដ្ឋកិច្ច ព្រមទាំងផ្គត់ផ្គង់ទំនិញនិងសេវាសាធារណៈជាពិសេសទិញនិងសេវាដែលអវត្តមានក្នុងទីផ្សារ ឬមានពុំគ្រប់គ្រាន់ជាដើម។ តាមរយៈនេះដែរ ការធ្វើអន្តរាគមន៍របស់រដ្ឋអាចកែសម្រួល និងបំពេញចន្លោះនូវកង្វះខាតរបស់យន្តការទីផ្សារ និងដើម្បីផ្ទេរសកម្មភាពទាំងនេះឱ្យក្លាយទៅជាសកម្មភាពមានប្រយោជន៍សម្រាប់សង្គមជាតិទាំងមូល។

គួរកត់សម្គាល់ថា កម្មសិទ្ធិឯកជនលើធនធានសេដ្ឋកិច្ច និងការគ្រប់គ្រងឈរលើមូលដ្ឋានសេដ្ឋកិច្ចទីផ្សារ គឺមានលក្ខណៈដូចគ្នានឹងកម្មសិទ្ធិសង្គមលើធនធានសេដ្ឋកិច្ច និងការគ្រប់គ្រងមានលក្ខណៈសេដ្ឋកិច្ចផែនការដែលជានិច្ចកាលមិនមានភាពស្របគ្នានោះទេ។

២. ទំនាក់ទំនងនយោបាយសេដ្ឋកិច្ច

២.១-គោលការណ៍នយោបាយសេដ្ឋកិច្ច

នៅក្នុងយុគសម័យសកលភាវូបនីយកម្ម សមាហរណកម្មសេដ្ឋកិច្ចនេះ គឺជាបាតុភូតមួយដែលមានអត្ថន័យ និងសារសំខាន់កាន់តែសំខាន់ឡើងៗពីមួយថ្ងៃទៅមួយថ្ងៃ។ ពិភពលោកបាននឹងកំពុងតែតាមដានយ៉ាងយកចិត្តទុកដាក់ទៅលើដំណើរចរាចរក្នុងក្របខ័ណ្ឌអង្គការពាណិជ្ជកម្មពិភពលោក។ ដែលបច្ចុប្បន្នប្តូរពាណិជ្ជកម្មដែលមានការអភិវឌ្ឍន៍ខ្ពស់ជាងគេគឺសហភាពអឺរ៉ុប។

+ សមាហរណកម្មសេដ្ឋកិច្ច:បច្ចុប្បន្ននេះ គេអាចឃើញដោយប្រត្យក្សថា សមាហរណកម្មសេដ្ឋកិច្ចបានបង្កើតឱ្យមានទំនាក់ទំនងយ៉ាងជិតស្និទ្ធិ រវាងប្រទេសដែលចូលរួមតាមរយៈដំណើរការសេរីភាវូបនីយកម្មទំនិញសេវាចរាចរមូលធន និងកម្លាំងពលកម្មព្រមទាំងកិច្ចការសម្របសម្រួលផ្នែកនយោបាយ សេដ្ឋកិច្ចហិរញ្ញវត្ថុ ប្រព័ន្ធច្បាប់ លិខិតបទដ្ឋាន ស្តង់ដារនិង គុណភាពទំនិញប្រព័ន្ធផ្សាស់ប្តូរព័ត៌មានផ្សេងៗ។ ប្រការទាំងនេះ គឺជាកត្តាដ៏មានសារសំខាន់ក្នុងការជំរុញដំណើរការសកលភាវូបនីយកម្មសេដ្ឋកិច្ចព្រមទាំងការបង្កើត «វិមាត្រសេដ្ឋកិច្ច» ចលនភាពនៃកត្តាផលិតកម្ម និងបញ្ចុះថ្លៃទំនិញនាំចូល។ ដូច្នេះលទ្ធផលចុងក្រោយនៃសមាហរណកម្មសេដ្ឋកិច្ចគឺការទាក់ទាញវិនិយោគសម្រាប់កំណើនផលិតភាពនៃកត្តាផលិតកម្ម និងជំរុញ «ឧត្តមភាពប្រៀបធៀប»(comparative advantage) របស់ជាតិតាមរយៈការចូលរួមក្នុងការប្រណាំងប្រជែងជាលក្ខណៈអន្តរជាតិ និងក្នុងដំណើរការងារឯកទេសកម្ម។

ទន្ទឹមនឹងនោះគួរកត់សម្គាល់ថា សមាហរណកម្មសេដ្ឋកិច្ច គឺជាដំណើរការដែលបែងចែកចេញជាដំណាក់ៗហើយក្នុងនោះគេកំណត់កម្រិតនៃនយោបាយពាណិជ្ជកម្មដែលកាត់បន្ថយ ឬលុបបំបាត់រនាំងពាណិជ្ជកម្មរវាងប្រទេសសមាជិក។ ជាទូទៅគេចែករបាំងពាណិជ្ជកម្មជាពីរៈ ទីមួយ របាំងពាណិជ្ជកម្មសារពើពន្ធដែលក្នុងនោះរួមមាន ពន្ធនាំចេញនាំចូល និងទីពីរ របាំងមិនមែនសារពើពន្ធ ដែលក្នុងនោះ គឺជាការកំណត់ចំនួនបរិមាណទំនិញនាំចូលកម្រិតបរិមាណទំនិញនាំចេញដោយស្ម័គ្រចិត្ត (voluntary export restraints) តាមដានវិធានការច្បាប់ លិខិតបទដ្ឋាន ព្រមទាំងបែបបទបច្ចេកទេស និងផ្នែករដ្ឋបាល ដែលតម្រូវឱ្យគោរពតាម ហើយជាទូទៅប្រការទាំងអស់នេះធ្វើឱ្យរាំងស្ទះដល់សកម្មភាពពាណិជ្ជកម្ម។ ទន្ទឹមនឹងនេះគួរកត់សម្គាល់ថាការឧបត្ថម្ភធនដើម្បីទ្រទ្រង់ការនាំចេញក៏ជាផ្នែកមួយនៃគោលនយោបាយរបាំងមិនពាណិជ្ជកម្មផងដែរ។

ជាទូទៅសមាហរណកម្មសេដ្ឋកិច្ច អាចមានសណ្ឋានផ្សេងៗគ្នាស្របទៅតាមកម្រិតនៃការរីវត្តរបស់តំបន់នីមួយៗ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយកម្រិតនីមួយៗសុទ្ធតែមានគោលរណ៍រួមដែលក្នុងនោះគេអាចចែកចេញជាដំណាក់កាលសំខាន់ៗដូចជា:

ក.តំបន់ពាណិជ្ជកម្មសេរី:ពាណិជ្ជកម្មសេរីជាគោលរណ៍សំខាន់កម្រិតទី១ នៃសមាហរណកម្មសេដ្ឋកិច្ច ដែលក្នុងនោះជាដំបូងគេផ្តោតជាសំខាន់ទៅលើការលុបបំបាត់របាំងផ្សេងៗសម្រាប់ពាណិជ្ជកម្មទំនិញ និងសេវា រវាងប្រទេសចូលរួម។ ក្នុងគោលឥបំណងនេះប្រទេសចូលរួមបានឯកភាពគ្នា លុបបំបាត់របាំងពន្ធគយ និងកូតា និងរបាំងមិនមែនពន្ធគយផ្សេងៗទៀត។ ទន្ទឹមនឹងនោះការលុបបំបាត់ការើសអើងផ្សេងៗការគោរពគោលការណ៍ប្រព្រឹត្តកម្មជាតិ និងគោលការណ៍តម្លាភាពត្រូវបានចាត់ទុកថាជា

មូលដ្ឋានសម្រាប់ពាណិជកម្មសេរី។ ករណីខ្លះការអនុគ្រោះត្រូវបានអនុវត្តចំពោះប្រភេទទំនិញមួយចំនួនតែប៉ុណ្ណោះ តាមរយៈកិច្ចព្រមព្រៀងអនុគ្រោះពន្ធគយឬកិច្ចព្រមព្រៀងអនុគ្រោះពាណិជកម្ម។ លក្ខណៈសំខាន់មួយទៀតនៃតំបន់ពាណិជ្ជកម្មសេរី គឺសេរីភាពរបស់ប្រទេសជាសមាជិកនីមួយៗក្នុងការកំណត់គោលនយោបាយ និងទំនាក់ទំនងរបស់ខ្លួនជាមួយលើធនធានសេដ្ឋកិច្ច ប៉ុន្តែការគ្រប់គ្រងមានលក្ខណៈបញ្ជា និងត្រួតពិនិត្យយ៉ាងតឹងរឹង។

តំបន់ការូបនីយកម្មសេដ្ឋកិច្ច បានក្លាយទៅជាប្រធានបទដ៏មានសារសំខាន់មួយក្នុងរបៀបវារៈជាតិ និងរបស់បណ្តាប្រទេសស្ទើរតែទាំងអស់ក្នុងពិភពលោក ជាពិសេសនៅតំបន់អាស៊ីប៉ាស៊ីហ្វិក។ សេដ្ឋកិច្ចតំបន់និយមមានទ្រង់ទ្រាយច្រើនបែបច្រើនយ៉ាង ដោយសារទទួលរងឥទ្ធិពលពីកម្លាំងនៃការរីកចម្រើនដែលមានប្រភេទផ្សេងៗគ្នា។ នៅក្នុងយុគសម័យសកលភាវូបនីយកម្មសមាហរណកម្មសេដ្ឋកិច្ចនេះ គឺជាបាតុភូតមួយដែលមានអត្ថន័យ និងសារសំខាន់កាន់តែសំខាន់ឡើងៗពីមួយថ្ងៃទៅមួយថ្ងៃ។ បច្ចុប្បន្នបុកពាណិជ្ជកម្មដែលមានការអភិវឌ្ឍន៍ខ្ពស់ជាងគេគឺ សហភាពអឺរ៉ុប។

+ សមាហរណកម្មសេដ្ឋកិច្ច បច្ចុប្បន្ននេះគេអាចឃើញថា សមាហិរណកម្មសេដ្ឋកិច្ចបានបង្កើតឱ្យមានទំនាក់ទំនងយ៉ាងជិតស្និទ្ធិរវាងប្រទេសដែលចូលរួមតាមរយៈដំណើរការសេរីភាវូបនីយកម្មទំនិញសេវាចរាចរមូលធន និងកម្លាំងពលកម្មព្រមទាំងកិច្ចការសម្របសម្រួលផ្នែកនយោបាយ សេដ្ឋកិច្ចហិរញ្ញវត្ថុ ប្រព័ន្ធច្បាប់ លិខិតបទដ្ឋានស្តង់ដារនិងគុណភាពទំនិញ ប្រព័ន្ធផ្សាស់ប្តូរព័ត៌មានផ្សេងៗ។ ប្រការទាំងនេះ គឺជាកត្តាដ៏មានសារសំខាន់ក្នុងការជំរុញដំណើរការសកលភាវូបនីយកម្មសេដ្ឋកិច្ចព្រមទាំងការបង្កើត "វិមាត្រសេដ្ឋកិច្ច" ចលនភាពនៃកត្តាផលិតកម្មនិងបញ្ចុះថ្លៃទំនិញនាំចូល។ ដូច្នេះលទ្ធផលចុងក្រោយនៃសមាហរណកម្មសេដ្ឋកិច្ចគឺការទាក់ទាញ វិនិយោគសម្រាប់កំណើនផលិតភាពនៃកត្តាផលិតកម្មនិងជំរុញ "ឧត្តមភាពប្រៀបធៀប"(comparative advantage)របស់ជាតិតាមរយៈការចូលរួមក្នុងការប្រណាំងប្រជែងជាលក្ខណៈអន្តរជាតិ និងក្នុងដំណើរការឯកទេសកម្ម។

ទន្ទឹមនឹងនោះគួរកត់សម្គាល់ថា សមាហរណកម្មសេដ្ឋកិច្ច គឺជាដំណើរការដែលបែងចែកចេញជាដំណាក់ៗ ហើយក្នុងនោះគេកំណត់កម្រិតនៃនយោបាយពាណិជ្ជកម្ម ដែលកាត់បន្ថយឬលុបបំបាត់រនាំងពាណិជ្ជកម្មរវាងប្រទេសសមាជិកៗជាទូទៅគេចែករបាំងពាណិជ្ជកម្មជាពីរ៖ ទីមួយរបាំងពាណិជ្ជកម្មសារពើពន្ធដែលក្នុងនោះរួមមានពន្ធនាំចេញនាំចូល និងទីពីររបាំងមិនមែនសារពើពន្ធដែលក្នុងនោះ គឺជាការកំណត់ចំនួនបរិមាណទំនិញនាំចូល កម្រិតបរិមាណទំនិញនាំចេញដោយស្ម័គ្រចិត្ត (voluntary export restraints) តាមដាកវិធានការច្បាប់ លិខិតបទដ្ឋានព្រមទាំងបែបបទបច្ចេកទេស និងផ្នែករដ្ឋបាលដែលតម្រូវឱ្យគោរពតាមហើយជាទូទៅប្រការ

ទាំងអស់នេះធ្វើឱ្យរាំងស្ទះដល់សកម្មភាពពាណិ-
ជ្ជកម្ម។ ទន្ទឹមនឹងនេះគួរកត់សម្គាល់ថា ការឧបត្ថម
ធនដើម្បីទ្រទ្រង់ការនាំចេញក៏ជាផ្នែកមួយនៃ
គោលនយោបាយរបាំងមិនពាណិជ្ជកម្មផងដែរ។

ជាទូទៅសមាហរណកម្មសេដ្ឋកិច្ចអាច
មានសណ្តានផ្សេងៗគ្នាស្របទៅតាមកម្រិតនៃ ការ
រីវត្តរបស់តំបន់នីមួយៗ។ ប៉ុន្តែទោះជាយ៉ាងណា
ក៏ដោយកម្រិតនីមួយៗសុទ្ធតែមានគោលការណ៍
រួមដែលក្នុងនោះគេអាចចែកចេញជាដំណាក់
កាលសំខាន់ៗដូចជា:

ក.តំបន់ពាណិជ្ជកម្មសេរី: ពាណិជ្ជកម្ម
សេរី ជាគោលរណ៍សំខាន់កម្រិតទី១ នៃសមាហរ
ណកម្មសេដ្ឋកិច្ច ដែលក្នុងនោះជាដំបូងគេផ្តោត
ជាសំខាន់ទៅលើការលុបបំបាត់របាំងផ្សេងៗ
សម្រាប់ពាណិជ្ជកម្មទំនិញ និងសេវារវាងប្រទេស
ចូលរួម។ ក្នុងគោលបំណងនេះប្រទេសចូលរួម
បានឯកភាពគ្នាលប់បំបាត់របាំងពន្ធគយនិងកូតា
និងរបាំងមិនមែនពន្ធគយផ្សេងៗទៀត។ ទន្ទឹម
នឹងនោះការលុបបំបាត់ការរើសអើងផ្សេៗការ
គោរពគោលការណ៍ប្រព្រឹត្តកម្មជាតិ និងគោល
ការណ៍តម្លាភាពត្រូវបានចាត់ទុកថាជាមូលដ្ឋាន
សម្រាប់ពាណិជកម្មសេរី។ ករណីខ្លះការ
អនុគ្រោះត្រូវបានអនុវត្តចំពោះប្រភេទទំនិងមួយ
ចំនួនតែប៉ុណ្ណោះ តាមរយៈកិច្ចព្រមព្រៀងអនុ
គ្រោះពន្ធគយ ឬកិច្ចព្រមព្រៀងអនិគ្រោះពាណិជ
កម្ម។ លក្ខណៈសំខាន់មួយទៀតនៃកតតំបន់
ពាណិជ្ជកម្មសេរី គឺសេរីភាពរបស់ប្រទេសជា
សមាជិកនីមួយៗក្នុងការកំណត់គោលនយោបាយ
និងទំនាក់ទំនងរបស់ខ្លួនជាមួយនឹងដៃគូពាណិជ្ជ
កម្មដទៃទៀត ដែលមិនមែនជាសមាជិក។ ប្រការ
នេះមានន័យថាប្រទេសជាសមាជិកនីមួយៗមាន
សិទ្ធិគ្រប់គ្រាន់ក្នុងការកំណត់ពន្ធគយ ក្នុងការដាក់
កំហិតកូតា និងការកំណត់ របាំងមិនមែនពន្ធគយ
ផ្សេងៗទៀត សម្រាប់ដៃគូពាណិជ្ជកម្ម ដែលមិន
មែនជាសមាជិកតំបន់ពាណិជ្ជកម្មសេរីនេះ។

ខ.សហភាពគយ: ការបង្កើតសហភាព
គយ គឺជាការរីវត្តន៍ដំណាក់កាលមួយថ្មីទៀត
បន្ថែមលើតំបន់ ពាណិជ្ជកម្មសេរី។ ដូចជា តំបន់
ពាណិជ្ជកម្មសេរី សមាជិកសហភាពគយត្រូវលុប
បំបាត់របាំងពាណិជ្ជកម្មទំនិញ និងសេវាសម្រាប់
ប្រទេសជាសមាជិកដទៃទៀត។ ប៉ុន្តែបន្ថែមពីលើ
នេះទៀត ប្រទេសជាសមាជិកចូលរួមសម្រប
សម្រួល និងកំណត់ជាមួយគ្នានូវនយោបាយ
ពាណិជ្ជកម្មរួមនេះ មានទ្រង់ទ្រាយជាការកំណត់
ពន្ធគយខាងក្រៅរួមដែលក្នុងនោះទំនិញនាំចូល
ពីក្រៅសហគមន៍សម្រាប់លក់ក្នុងប្រទេសមួយនៃ
សហគមន៍ ត្រូវបានគេយកពន្ធគយតាមអត្រាដូច
គ្នា ហើយចំណូលពន្ធគយដែលបានមកនោះ
ត្រូវបែងចែកគ្នាក្នុងចំណោមប្រទេសជាសមាជិក
ស្របតាមរូបមន្ត ដែលបានឯកភាពគ្នាជាមុន។

គ.ទីផ្សាររួម : ដូចសហភាពគយដែរ
ប្រទេសសមាជិកទីផ្សាររួម ត្រូវលុបបំបាត់របាំង
ពាណិជ្ជកម្មសម្រាប់ប្រទេស ជាសមាជិកដទៃ
ទៀត និងចូលរួមសហការគ្នាកំណត់នយោបាយ
ពាណិជ្ជកម្មក្រៅសហគមន៍។ លើសពីនេះទៀត
ប្រទេស ជាសមាជិកទីផ្សាររួមត្រូវឯកភាពគ្នា

អនុញ្ញាតឱ្យកត្តាផលិតកម្មទាំងអស់ធ្វើចរាចរណ៍ដោយសេរីលើទីផ្សាររួម។ កត្តាផលិតកម្មមានរាប់បញ្ចូលមូលធនពលកម្ម និងបច្ចេកវិទ្យា។

ឃ.សហភាពសេដ្ឋកិច្ច៖ ជាទូទៅសហភាពសេដ្ឋកិច្ច គឺជាការបន្ថែមពីលើលក្ខណៈវិនិច្ឆ័យសំខាន់ៗទាំងប៉ុន្មានរបស់ទីផ្សាររួម។ ប្រការនេះសហភាពសេដ្ឋកិច្ច ទាមទារឱ្យមានសមាហរណកម្មនយោបាយសេដ្ឋកិច្ចថែមទៀត។ មានន័យថា ក្រៅពីអនុញ្ញាតឱ្យមានចរាចរដោយ សេរីទូទំនិញ សេវា និងកត្តាផលិតកម្ម ពោលគឺ មូលធនពលកម្ម និងបច្ចេកវិទ្យាសមាជិកសហភាពសេដ្ឋកិច្ចត្រូវធ្វើសុខដុមភាវូនីយកម្ម និងត្រូវសម្របសម្រួលនយោបាយសេដ្ឋកិច្ចជាមួយគ្នាថែមទៀត ដែលក្នុងនោះរួមមាននយោបាយ ម៉ាក្រូសេដ្ឋកិច្ច ហិរញ្ញវត្ថុសាធារណៈ ពន្ធដារ រូបិយវត្ថុ និងធនាគារជាដើម។ បន្ថែមពីលើនេះសហភាពសេដ្ឋកិច្ច អាចឯកភាពគ្នាលើការប្រើប្រាស់ប្រព័ន្ធ អត្រាប្តូរប្រាក់រួម ឬអនុម័តដាក់ឱ្យប្រើប្រាស់រូបិយវត្ថុរួមដូចដែលបាន និងកំពុងអនុវត្តក្នុងតក្កៈផ្ទៃក្នុងរបស់វា។ ដំណើរការវិវត្តន៍របស់ដំណាក់កាលនីមួយៗ គឺជាមូលហេតុនៃដំណាក់កាលមួយដែលខ្ពស់ជាងនិងសាំញ៉ាំជាង។ ការព្រមព្រៀងគ្នាលើការអនុគ្រោះពាណិជ្ជកម្ម គឺជាកត្តាផ្ទៃក្នុង ដែលជំរុញឱ្យមានចំណងទាក់ទងផ្ទៃក ហេដ្ឋារចនាសម្ព័ន្ធសេរីភាវូបនីយកម្ម រចនាសម្ព័ន្ធសេដ្ឋកិច្ច ច្បាប់និងនយោបាយ ។ល។ ម៉្យាងទៀត តថភាពនេះបានបង្ហាញឱ្យឃើញថា សមាហរណកម្មសេដ្ឋកិច្ច គឺជាដំណើរដែលប្រព្រឹត្តទៅក្រោមរូបភាពនិងយន្តការផ្សេងៗទៀតតថភាពនេះបានបង្ហាញឱ្យឃើញថា សមាហរណកម្មសេដ្ឋកិច្ច គឺជាដំណើរដែលប្រព្រឹត្តទៅក្រោមរូបភាព និងយន្តការ ផ្សេងៗគ្នាទាំងក្នុងកម្រិតតំបន់ និងសកលលោក។ ប្រការនេះគឺជាមូលហេតុធ្វើឱ្យមានការលំបាកក្នុងការប្រើប្រាស់លក្ខណៈវិនិច្ឆ័យនៃដំណាក់កាលសំខាន់ៗដូចដែលបានលើកឡើងដើម្បីកំណត់កម្រិតសមាហរណកម្ម ពិតប្រាកដនៃសេដ្ឋកិច្ចតាមតំបន់ ឬតាមរូបភាពជាក់ស្តែងនីមួយៗ។ ជាការពិតណាស់ថាដំណាក់កាលសំខាន់ៗ នៃសមាហរណកម្មសេដ្ឋកិច្ចដែលបានលើកមកជាឧទាហរណ៍ខាងលើ គឺមានលក្ខណៈ ទ្រឹស្តីដែលបានមកពីការបូកសរុបសកម្មភាព ដែលបានអនុវត្តដោយមានការពិភាក្សា និងវែកញែកច្បាស់លាស់ ដើម្បីឱ្យងាយយល់អំពីបាតុភូត ដែលអាចកើតមានឡើងជាជាងការយកចិត្តទុកដាក់ទៅលើជីវិតជាក់ស្តែងដែលតែងតែមានលក្ខណៈសាំញ៉ាំ និងភាពសំបូរបែបជាងទ្រឹស្តី។ ម៉្យាងទៀត អ្វីដែលមានសារៈសំខាន់ក្នុងការបកស្រាយនេះគឺត្រូវគួសបញ្ជាក់ថា សមាហរណកម្មសេដ្ឋកិច្ច គឺជា«ដំណើរ»មិនមែនជាបាតុភូតសម្រាប់អនាគតនោះទេ។

ការបង្កើតសមាគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍ (ASEAN)

ក.មូលហេតុ៖ នៅទសវត្សរ៍ឆ្នាំ៥០ភាពរង្គោះរង្គើរនៃការថែរក្សាឯករាជ្យរបស់បណ្តាប្រទេសនៅបណ្តា អាស៊ីអាគ្នេយ៍កាន់តែធ្ងន់ធ្ងរឡើង។ ដោយសារមានទំនាស់ និងបញ្ហាស្មុគ

ស្មាញជាច្រើនដែលកើតឡើងក្នុងដំណាក់កាលសង្គ្រាមត្រជាក់។ ដូច្នេះហើយដោយមានការផ្តួចផ្តើមរបស់សហរដ្ឋអាមេរិកនៅឆ្នាំ១៩៦៥ នាំឱ្យឈានដល់ការបង្កើតបក្សសម្ព័ន្ធនយោបាយ និងយោធា (The southeast Asia Treaty Organization SEATO) ដែលមានប្រទេសបីនៅទ្វីបអាស៊ីចូលរួម ប៉ាគីស្ថាន ថៃ និងហ្វីលីពីន។ ប៉ុន្តែអង្គការនេះមិនបានពង្រឹង និងពង្រីកការងាររបស់ខ្លួនឱ្យបានរឹងមាំទេ ដោយសារបណ្តាប្រទេសដទៃទៀតដែលស្ថិតនៅតំបន់ជាមួយគ្នាមិនបានចូលរួម។ ក្នុងទសវត្សរ៍ឆ្នាំទី៦០ និន្នាការតំបន់និយម បានកើតឡើងតាមរយៈកត្តាសំខាន់ពីរ (១)កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចក្នុងគោលបំណងបង្កើតរចនាសម្ព័ន្ធ ទីផ្សាររួមនិងតំបន់ពាណិជ្ជកម្មសេរី (២)ការពារការរាំទទីផ្នែកពាណិជ្ជកម្មរបស់មហាអំណាចសេដ្ឋកិច្ចធំៗ ជាពិសេសវត្តមានរបស់ប្រទេសជប៉ុន និងចិន នៅឥណ្ឌូចិន និងក្នុងតំបន់ទាំងមូល។ ដោយប្រការនេះហើយទើបចាប់ពីពេលនោះមកបណ្តាប្រទេសនៅអាស៊ីអាគ្នេយ៍បានចាកចេញពីគោលការណ៍សមាហរណកម្មនយោបាយយោធា ទៅជាសមាហរណកម្មនយោបាយសេដ្ឋកិច្ចវិញ។ គោលគំនិតសំខាន់នៃការបង្កើតសមាគមថ្មីក្នុងតំបន់អាស៊ីអាគ្នេយ៍នេះជាដំបូងមិនត្រឹមតែជំនួសបក្សសម្ព័ន្ធយោធា SEATO នោះទេ ប៉ុន្តែចង់ទាក់ទាញដល់បណ្តាប្រទេសអព្យាក្រឹត្យថែមទៀតផង។ អនុវត្តគំនិតផ្តួចផ្តើមនេះជាដំបូងមានប្រទេស៣ ថៃហ្វីលីពីន និងម៉ាឡេស៊ី ដែលបានប្រកាសប្រឆាំងដាច់ខាតនិងទិសដៅកុម្មុយនីសនិយម ប៉ុន្តែក្រោយមកគេបាន ទទួលស្គាល់ថា ការប្រកាសនេះនឹងមិនទាក់ទាញដល់ប្រទេសដែលមិនចូលបក្សសម្ព័ន្ធទេ ជាពិសេសប្រទេសកូមា កម្ពុជា និងឥណ្ឌូនេស៊ី ដូច្នេះពួកគេបានធ្វើ សេចក្តីថ្លែងការណ៍ថ្មី ដោយសម្រេចចិត្តបង្កើត សមាគន៍មួយដែលអព្យាក្រឹត្យ និងគ្មានទំនាក់ទំនងជាមួយបក្សសម្ព័ន្ធយោធា SEATO។ នៅទីបញ្ចប់នៅខែសីហា ឆ្នាំ១៩៦១ ប្រទេសថៃ ហ្វីលីពីននិងម៉ាឡេស៊ីដែលមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយសហរដ្ឋអាមេរិក និងអង់គ្លេសបានចុះហត្ថលេខាលើកតិកាសញ្ញាស្តីពីការបង្កើតសមាគម ថ្មីមួយមានឈ្មោះថា "សមាគមអាស៊ីអាគ្នេយ៍"។ ទិសដៅ និងកម្មវិធីសំខាន់នៃសមាគមនេះក្រៅពីកិច្ចសហប្រតិបត្តិការ និងការជួយគ្នាទៅវិញទៅមករវាងប្រទេសជាសមាជិកក្នុងវិស័យសេដ្ឋកិច្ច សង្គមកិច្ចនិងអតិបាលកិច្ច គឺការបង្កឱ្យមានទំនាក់ទំនងល្អជាមួយនឹងប្រទេសដែលមានទិសដៅរួមគ្នាដើម្បីស្វែងយល់ពីគ្នាទៅវិញទៅមក គឺបង្កឱ្យមានទំនាក់ទំនងល្អជាមួយនឹងប្រទេសដែលមានទិសដៅរួមគ្នាដើម្បីស្វែងយល់ពីគ្នាទៅវិញទៅមក ជាមួយប្រទេសក្នុងតំបន់អាស៊ីអាគ្នេយ៍ឱ្យកាន់តែប្រសើរឡើង។ ទន្ទឹមនោះលក្ខន្តិក:របស់សមាគមបានគូសបញ្ជាក់ច្បាស់ថែមទៀតថា "សមាគមមិនមានទំនាក់ទំនង ឬស្ថិតនៅ ក្រោមឥទ្ធិពលប្រទេសមហាអំណាចណាមួយ ឬបុគ្គណាមួយទេ ហើយទិសដៅរបស់សមាគមក៏មិនប្រឆាំងនឹង ប្រទេសណាដែរ"។ នៅខែតុលា ១៩៦១ គណៈកម្មការ

អ្នកឯកទេសសេដ្ឋកិច្ចនៃសមាគមអាស៊ីអាគ្នេយ៍ បានជួប ប្រជុំគ្នាជាលើកទីមួយនៅទីក្រុងកូឡាឡាំពួរ។ ជាលទ្ធផលអង្គប្រជុំបានសម្រេចបង្កើតគណកម្មការពាណិជ្ជកម្មឧស្សាហកម្ម និងទេសចរណ៍ ហើយនៅខែមេសា ឆ្នាំ១៩៦២ បានបើកផ្លូវគមនាគមន៍កូឡាឡាំពួ-បាងកក។ ជាមួយគ្នានោះ នៅទីក្រុងកូឡាឡាំពួ នៅខែឧសភា ឆ្នាំ១៩៦២ សន្និសីទគណៈកម្មាធិការអចិន្ត្រៃយ៍សមាគមអាស៊ីអាគ្នេយ៍បានរៀបចំឡើង និងការពិភាក្សាអំពីការបង្កើត "ទីផ្សាររួម" ។ ក្នុងកិច្ចប្រជុំខែសីហា ឆ្នាំ១៩៦៧ នៅក្រុងបាងកក រដ្ឋ មន្ត្រីការបរទេសនៃប្រទេសឥណ្ឌូនេស៊ី ម៉ាឡេស៊ី ថៃ ហ្វីលីពីន និងសឹង្ហបុរី បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងដើម្បីបង្កើតសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍។ ដូច្នេះសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ដែលហៅកាត់ថា អាស៊ាន ត្រូវបានបង្កើតឡើងដោយមានប្រទេសជាសមាជិកស្ថាបនិក អាស៊ាន៥ ៖ ឥណ្ឌូនេស៊ី ម៉ាឡេស៊ី ថៃ ហ្វីលីពីន និង សឹង្ហបុរី និងបន្ទាប់មក ក្រោយពីទទួលបានឯករាជ្យពីប្រទេសអង់គ្លេសឆ្នាំ១៩៨៤មកប្រទេសប្រ៊ុយនេ ក៏ចូលជាសមាជិកអាស៊ានដែរ។ ហើយជាបន្តបន្ទាប់ប្រទេសវៀតណាម ក៏បានចូលជាសមាជិកនៅឆ្នាំ១៩៩៦ ប្រទេសឡាវនិងប្រទេសមីយ៉ាន់ម៉ា នៅឆ្នាំ១៩៩៧ និងប្រទេសកម្ពុជានៅឆ្នាំ១៩៩៩។ បានធ្វើទំនាក់ទំនងជាមួយគ្នា ឬបានព្រមព្រៀងគ្នាដោយកត្តាផ្សេងៗនៅក្នុងសកម្មភាពទូទាត់ ឬការផ្តត់ផ្តង់ជាទូទៅ រហូតមកដល់បច្ចុប្បន្ន។

២.២-គោលការណ៍មីក្រូសេដ្ឋកិច្ច និងម៉ាក្រូសេដ្ឋកិច្ច

វិទ្យាសាស្ត្រសេដ្ឋកិច្ចមានទំនាក់ទំនង និងមានឬសគល់យ៉ាងជ្រៅទៅនឹងទស្សនវិជ្ជាស្តីពីសង្គម។ គោលបំណងសំខាន់របស់ទស្សនវិជ្ជានេះ គឺការវែកញែក និងពន្យល់អំពីយុត្តិធម៌នៅក្នុងសង្គម ហេតុអ្វីបានជាមានអ្នកមាន និងអ្នកក្រ? តើគេត្រូវធ្វើដូចម្តេច ដើម្បីបំពេញឱ្យបាននូវសេចក្តីត្រូវការដែលគ្មានព្រំដែនទៅនឹងធនធានដែលមានកំណត់? ហេតុដូចម្តេចបានជាគេនិយាយថា សេដ្ឋកិច្ចទីផ្សារមានយុត្តិធម៌ ប៉ុន្តែគ្មានសីលធម៌ ផ្ទុយទៅវិញសេដ្ឋកិច្ចផែនការ ឬសេដ្ឋកិច្ចសង្គមនិយមយកចិត្តទុកដាក់លើសីលធម៌ និងសហភាពសង្គមប៉ុន្តែគ្មានយុត្តិធម៌? ចេញពីសំណួរ ទាំងអស់នេះ ទើបកើតមានឡើងនូវវិទ្យាសាស្ត្រសេដ្ឋកិច្ច។ តាមទស្សនៈ និងបាតុភូតការសិក្សាដែលពាក់ព័ន្ធនឹងជីវភាពរស់នៅវិទ្យាសាស្ត្រសេដ្ឋកិច្ចចែកចេញជាពីរ គឺមីក្រូ និងម៉ាក្រូសេដ្ឋកិច្ច។

មីក្រូសេដ្ឋកិច្ច គឺជាផ្នែកមួយនៃវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលសិក្សាពីមុខងារ ឬចរិតសេដ្ឋកិច្ចដែលសម្រេចចិត្តដោយបុគ្គលម្នាក់ៗ។ ម៉ាក្រូសេដ្ឋកិច្ច សិក្សាចរិតសេដ្ឋកិច្ចទាំងមូលដូចជា ការកើនឡើង និងការថយចុះនៃសេដ្ឋកិច្ច បរិមាណសរុបនៃទំនិញ និងសេវា ដែលផលិតក្នុងសេដ្ឋកិច្ចមួយ កំណើនបរិមាណសរុបនៃផលិតផលអត្រាអតិផរណា និងអត្រានិកម្មភាព ជញ្ជីងទូទាត់ និងអត្រាប្តូរប្រាក់ជាដើម។ ដូច្នេះមីក្រូសេដ្ឋកិច្ចសិក្សាពិ

កំណើនសេដ្ឋកិច្ចទាំង រយៈពេលវែង ទាំងការប្រែប្រួលរយៈពេលខ្លី ដែលបង្កើតបានជាខួបធុរកិច្ច។

ម៉ាក្រូសេដ្ឋកិច្ច សិក្សាអំពីបញ្ហាសេដ្ឋកិច្ចចំបង់ៗនៃសម័យកាល ឬជីវភាពសង្គមនីមួយៗ។

ឧទាហរណ៍៖ បញ្ហាដែលឆ្ទុះបញ្ចាំងអំពីទំនាក់ទំនងរវាងទីផ្សារទំនិញ ទីផ្សារពលកម្ម និងទីផ្សារហិរញ្ញវត្ថុ ទំនាក់ទំនងរវាងសេដ្ឋកិច្ចជាតិ និងសេដ្ឋកិច្ចនៃប្រទេសផ្សេងទៀត។ល។ ដូច្នេះ ម៉ាក្រូសេដ្ឋកិច្ច សិក្សាក្នុងកម្រិតសេដ្ឋកិច្ចទាំងមូល ឧទាហរណ៍ ម៉ាក្រូសេដ្ឋកិច្ច សិក្សាពី ទីផ្សារពលកម្មទាំងមូល ពោលគឺមិនមែនតែទីផ្សារ ពលកម្មជំនាញ ឬមិនជំនាញ ឬទីផ្សារ ពលកម្មជាង កំបោរ ឬវេជ្ជបណ្ឌិតនោះទេ។ ម៉្យាងទៀតម៉ាក្រូសេដ្ឋកិច្ចសិក្សាអំពីទីផ្សារទំនិញទាំងមូល ពោលគឺមិនមែនសិក្សាតែទីផ្សារសម្លៀកបំពាក់ ឬទីផ្សារម្ហូបអាហារនោះទេ។ល។ ការសិក្សាទីផ្សារទំនិញ ឬទីផ្សារពលកម្មតែមួយប្រភេទជាការសិក្សាក្នុងកម្រិត មីក្រូសេដ្ឋកិច្ច។

ភាពខុសគ្នាសំខាន់មួយរវាងមីក្រូសេដ្ឋកិច្ច និងម៉ាក្រូសេដ្ឋកិច្ច គឺអថេរដែលត្រូវសិក្សា។ មីក្រូសេដ្ឋកិច្ច សិក្សាពីថ្លៃធៀប (ឧទាហរណ៍៖ ថ្លៃអង្ករធៀបនឹងថ្លៃទំនិញផ្សេងទៀត) ចំណែកម៉ាក្រូសេដ្ឋកិច្ច សិក្សាពីកម្រិតថ្លៃមធ្យមដែលគណនេយ្យបានរាប់បញ្ចូលគ្រប់ទំនិញ និងសេវា ប្រើប្រាស់ទាំងអស់។ ភាពខុសគ្នាមួយទៀត គឺការសន្មត។ ក្នុងការសិក្សាមីក្រូសេដ្ឋកិច្ចគេឱ្យប្រាក់ចំណូលសរុបរបស់អ្នកប្រើប្រាស់ថេរហើយគេសិក្សាពីរបៀប ដែលអ្នកប្រើប្រាស់ចាយប្រាក់ ចំណូលរបស់ខ្លួន ដើម្បីទិញទំនិញផ្សេងៗ យ៉ាងដូចម្តេច?។ ចំណែកឯក្នុងការសិក្សា ម៉ាក្រូសេដ្ឋកិច្ចវិញ កម្រិតនៃប្រាក់ចំណូលសរុប ឬចំណាយគឺស្ថិតក្នុងចំណោមអថេរសំខាន់ៗ ដែលត្រូវសិក្សា។ ក្រៅពីនេះមីក្រូសេដ្ឋកិច្ច និងម៉ាក្រូសេដ្ឋកិច្ចសិក្សាអំពី ទិដ្ឋភាពសេដ្ឋកិច្ចផ្សេងគ្នា។ សរុបឱ្យខ្លីទៅការសិក្សាមីក្រូសេដ្ឋកិច្ចគេយកថ្លៃជាកត្តាកំណត់ចំណែកការសិក្សាក្នុង ម៉ាក្រូសេដ្ឋកិច្ចវិញគេយកចំណូលសរុបជាកត្តាកំណត់។ បញ្ហាសេដ្ឋកិច្ចតែចោទឡើងទោះក្នុងប្រព័ន្ធសេដ្ឋកិច្ចណាក៏ដោយ។ ជាការពិត ភាពខុសគ្នាសំខាន់ៗរវាងសេដ្ឋកិច្ចផែនការប្រមូលផ្តុំ សេដ្ឋកិច្ចចម្រុះ និងសេដ្ឋកិច្ចទីផ្សារ គឺស្ថិតនៅត្រង់របៀបនៃការដោះស្រាយបញ្ហាខាងលើ។ ដូច្នេះដើម្បីប្រើប្រាស់ធនធានមនុស្ស ធនធានធម្មជាតិ និងទំនិញវិនិយោគដែលមានដោយកម្រឱ្យមានប្រសិទ្ធភាពក្នុងការផលិតទំនិញ និងសេវាសម្រាប់បំពេញសេចក្តីត្រូវការរបស់សង្គមតម្រូវឱ្យមានការជ្រើសរើសយន្តការគ្រប់គ្រងនិងសម្របសម្រួលសេដ្ឋកិច្ចជាក់លាក់។

ក.គោលការណ៍មីក្រូសេដ្ឋកិច្ច

តម្រូវការការផ្គត់ផ្គង់ និងទីផ្សារ៖ *គឺជាកត្តាគន្ធឹះធ្វើប្រតិបត្តិការក្នុងទីផ្សារ។ កត្តាគន្ធឹះទាំងពីនេះរួមគ្នាកំណត់បានថ្លៃទីផ្សារ។ ទីផ្សារនិងបានលក់ទំនិញអស់នៅពេលតម្រូវការស្មើនឹងការផ្គត់ផ្គង់ពោលគឺ បានទៅដល់ចំណុចដែលថា **សមតាទីផ្សារ**។ ការប្រែប្រួលនៃតម្រូវការ និងការផ្គត់ផ្គង់នឹងមានផលប៉ះពាល់ទៅលើចំណុចសមតានេះពោលគឺធ្វើឱ្យថ្លៃ និងបរិមាណទំនិញប្រែប្រួល។*

<u>ទីផ្សារ និងថ្លៃទីផ្សារ</u>៖ បច្ចុប្បន្ននេះស្ទើទាំងពិភពលោកទទួលស្គាល់ថា ប្រព័ន្ធសេដ្ឋកិច្ចទីផ្សារមានតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច។ ទីផ្សារជាប្រភពនៃការរីកចម្រើននៃជីវភាពសេដ្ឋកិច្ចសង្គម។ ទីផ្សារ កន្លែងដែលរៀបចំឡើងសម្រាប់បង្កើតនូវទំនាក់ទំនងរវាងអ្នកលក់ និងអ្នកទិញដើម្បីដោះដូរទំនិញ និងសេវាតាមរយៈ នៃការដោះដូរនេះបង្កើតឱ្យមានកិច្ចព្រមព្រៀងគ្នាក្នុងការចងក្រងថ្លៃនិងកំណត់បរិមាណផលិតផលដែលចាំបាច់សម្រាប់សង្គម។ ការលូតលាស់របស់ទីផ្សារប្រព្រឹត្តទៅតាមរយៈលក្ខខ័ណ្ឌគោលការណ៍ និងមានមុខងារសំខាន់ៗដូចខាងក្រោម។ លក្ខខណ្ឌសំខាន់ៗដែលទីផ្សារអាចមានសកម្មភាពរួមមាន៖ ការបែងចែកពលកម្ម ឯកទេសកម្ម និងផលិតកម្ម។ ទីផ្សារនៃវិមាត្រគឺជាបរិមាណតម្រូវការរបស់អ្នកទិញនិងបរិមាណផ្គត់ផ្គង់របស់អ្នកលក់។ ការប្រកួតប្រជែងរបស់ផលិតករ ក្នុងដំណើរការផលិតកម្ម ក្នុងការស្វែងរកទីផ្សារ និងធនធានសេដ្ឋកិច្ច។ ការរីកចម្រើនប្រព័ន្ធរូបិយប័ណ្ណ និងផ្នែកឥណទាន។ ម៉្យាងទៀតដើម្បីឱ្យទីផ្សារមានសកម្មភាពដោយសេរីក្នុងដំណើរការផលិតកម្ម និងពាណិជ្ជកម្មតម្រូវឱ្យមានគោលការណ៍ដូចជា៖ សិទ្ធិជាម្ចាស់លើកម្មសិទ្ធិ និងសិទ្ធិសហគ្រិនក្នុងការប្រកបមុខរបរអាជីវកម្ម និងពាណិជ្ជកម្មដោយសេរី ព្រមជាមួយការលុបបំបាត់ទំរង់និងបែបបទផ្សេងៗ ដែលក្លាយជាឧបសគ្គដល់ផលិតកម្ម និងពាណិជ្ជកម្ម។ ហើយម៉្យាងទៀតថ្លៃទំនិញ និងសេវាត្រូវបង្កើត ឬចងក្រងឡើងក្នុងលទ្ធផលកិច្ចព្រមព្រៀងរវាងបរិមាណការផ្គត់ផ្គង់ និងបរិមាណតម្រូវការលើទំនិញ និងសេវាក្នុងទីផ្សារ។ ការធ្វើអន្តរាគមន៍របស់រដ្ឋក្នុងទីផ្សារត្រូវមានកម្រិត និងស្ថិតនៅក្នុងក្រមខ័ណ្ឌច្បាប់ធុរកិច្ចជាពិសេស ជៀសវាងការប្រើប្រាស់វិធានការរដ្ឋបាលប្រមូលផ្តុំ ដែលប៉ះពាល់ដល់គោលការណ៍ទីផ្សារ។ ទន្ទឹមនឹងលក្ខខ័ណ្ឌព្រមទាំងគោល ការណ៍ដូចដែលបានរៀបរាប់ខាងលើទីផ្សារមានមុខងារសំខាន់ៗដូចជា៖ មុខងារធ្វើនិយ័តកម្ម គឺការធ្វើឱ្យទៀងទាត់នូវផលិតកម្មទំនិញនិងសេវាកម្ម។ ផលិតកម្មទំនិញ និងសេវាគ្រប់មុខនិងប្រព្រឹត្តទៅដោយទៀងទាត់ ដោយស្តែងឡើងនៅទីផ្សារជាអ្នកត្រួតពិនិត្យ និងជំរុញឱ្យមានផលិតកម្មទំនិញ និងសេវាដែលមានប្រយោជន៍សម្រាប់សង្គមតាមរយៈផលិតកម្មទំនិញដែលមានគុណភាពខ្ពស់និងចំណាយក្នុងផលិតកម្មទាបដែលនាំឱ្យតម្លៃទំនិញនោះមានលក្ខណៈ សមរម្យ។ មុខងារបង្កើនទឹកចិត្តជំរុញការកាត់បន្ថយចំណាយក្នុងផលិតកម្ម។ តាមរយៈការប្រកួតប្រជែងដោយជំហ និងទីផ្សារជាអ្នកលើកទឹកចិត្តចំពោះផលិតករដែលចំណាយតិចក្នុងដំណើរការផលិតកម្ម ហើយរក្សាបាននូវគុណភាពផលិតផលរបស់ខ្លួន។ ក្នុងន័យនេះ ផលិតករនឹងអាចបញ្ចោញលក់ទំនិញបានច្រើន ដែលនឹងនាំឱ្យគេទទួលបានប្រាក់ចំណូល និងចំណេញច្រើន។ មុខងារបែងចែកបង្កើតឱ្យមានសមាមាត្រនៃបុរេផលិតកម្ម និងការផ្គត់ផ្គង់ឱ្យមានតុល្យភាពក្នុងសេដ្ឋកិច្ច។

ក្នុងក្របខ័ណ្ឌមុខងារនេះទីផ្សារជាអ្នកបែងចែកធនធានសេដ្ឋកិច្ច (ធនធានធម្មជាតិទំនិញវិនិយោគ និងធនធានមនុស្ស) នៅគ្រប់ទីកន្លែងដោយផ្អែកលើមូលដ្ឋាន តម្រូវការ និងការផ្គត់ផ្គង់។ មុខងារផ្តល់ព័ត៌មាន គឺបានផ្តល់ព័ត៌មានអំពីជីវភាពនៃសង្គម និងសេដ្ឋកិច្ចជាតិ។ ជាការពិតគេអាចទទួលព័ត៌មានអំពីសេចក្តីត្រូវការនូវទំនិញផ្សេងៗឬការលក់ដូរវត្ថុជាតុដើម ឬពលកម្មតាមរយៈទីផ្សារ។ ជាងនេះទៀតតាមរយៈ ទីផ្សារគេអាចទទួលបានស្ថានភាពវិនិយោគទុន ថ្លៃទំនិញឡើងចុះ និងស្ថានភាពជាច្រើនទៀតដែលពាក់ព័ន្ធទៅនឹងសេចក្តីត្រូវការ និងការផ្គត់ផ្គង់ទំនិញ និងសេវាក្នុងទីផ្សារ។

គួរកត់សម្គាល់ថា លក្ខណៈពិសេសនៃ ទីផ្សារបច្ចុប្បន្ននេះមានភាពខុសប្លែកពីសម័យដើមជាពិសេសការធានាវ៉ាប់រងពីសំណាក់ទីផ្សារក្នុងការលក់ទំនិញ និងសេវា។ រដ្ឋមានសកម្មភាពជាប្រចាំក្នុងការធ្វើនិយ័តកម្មតាមរយៈ គោលនយោបាយហិរញ្ញវត្ថុ ឥណទាន និងសារពើពន្ធ ព្រមទាំងមានប្រព័ន្ធការពារប្រជាជន ដែលមានកម្រិតជីវភាពទាបនិងក្រីក្រ។ នៅក្នុងទីផ្សារបច្ចុប្បន្ននេះមានការរីកចម្រើនយ៉ាងឆាប់នូវទីផ្សារផ្នែកបច្ចេកវិទ្យាព័ត៌មាន។ តាមរយៈចរន្តនៃតំបន់ការូបនីយកម្ម និងសហការូបនីយកម្មនិងសហការូនីយកម្ម និងដែលជានិន្នាការដ៏មានសារសំខាន់ក្នុងជីវភាព សេដ្ឋកិច្ច និងដែលកំពុងមានដំណើរការយ៉ាងសកម្មនោះតម្រូវឱ្យមានការប្រណាំងប្រជែងផ្នែក សេដ្ឋកិច្ច ទាំងក្នុងតំបន់និងពិភពលោកទាំងមូល។ ទន្ទឹមនឹងការប្រណាំងប្រជែងផ្នែកសេដ្ឋកិច្ចតម្រូវឱ្យមានសេរីភាវូបនីយកម្មទីផ្សារនិងពាណិជ្ជកម្មអន្តរជាតិ កាន់តែខ្លាំងឡើងក្នុងបណ្តាប្រទេសនីមួយៗ។ ទីផ្សារសម័យទំនើប មាននិន្នាការបង្កើតទីផ្សារមួយបែបថ្មី តាមរយៈការកាត់បន្ថយអត្រាពន្ធគយ និងការលុបបំបាត់រនាំងមិនមែនពន្ធគយ ការធ្វើឱ្យមានលក្ខខណ្ឌស្មើគ្នាក្នុងដំណើរការការផលិតកម្ម ចំណាយលើប្រាក់ឈ្នួលត្រង់ និងការជានាវ៉ាប់រង។ ប្រការទាំងនេះពង្រីកកាន់តែខ្លាំងនូវវិសាលភាពក្នុងការបណ្តាក់ទុន និងការប្រើប្រាស់កម្លាំងពលកម្មពីប្រទេសមួយទៅប្រទេសមួយទៀត ជាពិសេសការនាំចូលមូលធនកាន់តែធ្វើឱ្យរីកដុះដាលនូវការបណ្តាក់ទុននិងកាន់តែមានលក្ខណៈនិងទ្រង់ទ្រាយធំព្រមទាំងក្លាយទៅជាសាជីវកម្មអន្តរជាតិ។ បាតុភូតសេដ្ឋកិច្ច ក្នុងតំបន់ក៏ដូចជាក្នុងពិភពលោកទាំងមូលមិនឈប់ នឹងមួយកន្លែងទេសាជីវកម្មអន្តរជាតិ។ បាតុភូតសេដ្ឋកិច្ចក្នុងតំបន់ក៏ដូចជាក្នុងពិភពលោកទាំងមូលមិនឈប់នឹងមួយកន្លែងទេ ផ្ទុយទៅវិញកំពុងវិវត្តផ្លាស់ប្តូរឥតឈប់ឈរឈានទៅរកប្រព័ន្ធបែបថ្មីមួយដែលមានចរិតសកលភាវូបនីយកម្ម ហើយពឹងផ្អែកលើចំណេះដឹង។ ក្នុងប្រព័ន្ធសេដ្ឋកិច្ចថ្មីនេះកំពុងតែផ្លាស់ប្តូរបន្តិចម្តងៗនូវទស្សនាទានផលិតកម្មជំនួសដោយទស្សនាទានអរូបីយដែលកំណត់ដោយមូលធនបញ្ញា និងសមត្ថភាព ក្នុងការនិម្មិតនិងច្នៃប្រឌិត។ ប្រព័ន្ធសេដ្ឋកិច្ចថ្មីនេះបានដាក់ចេញជាទំរង់នៃការអភិវឌ្ឍន៍ថ្មីមួយដែលក្នុងនោះ

ការបង្កើនសមត្ថភាពធនធានមនុស្សត្រូវបានដើរតួជាគន្លឹះក្នុងការជានាចីរភាពនៃការអភិវឌ្ឍន៍ប្រទេស។ ថ្លៃ៖ តើអ្វីទៅដែលកំណត់ថ្លៃផលិតផល ឬកត្តាថ្លៃផលិតកម្ម? ក្នុងសេដ្ឋកិច្ចផែនការប្រមូលផ្តុំថ្លៃទំនិញ ឬថ្លៃកត្តាផលិតកម្មត្រូវបានកំណត់ដោយរដ្ឋដើម្បីសម្រេចគោលដៅរបស់ខ្លួន។ ចំណែកបរិមាណ និងថ្លៃទំនិញប្រើប្រាស់ត្រូវបានកំណត់ទៅតាមផែនការ។ អ្នកប្រើប្រាស់អាចជ្រើសរើសដោយសេរី ប៉ុន្តែបានត្រឹមបរិមាណទិញ និងតាមថ្លៃតាមរដ្ឋបានកំណត់។ ក្នុងសេដ្ឋកិច្ចទីផ្សារ រដ្ឋមានតួនាទីតិចតួចក្នុងការកំណត់ថ្លៃ។ ថ្លៃទំនិញណាមួយអាស្រ័យទៅនឹងតម្រូវការ និងការផ្គត់ផ្គង់ទំនិញនេះអ្នកប្រើប្រាស់ និងអ្នកផលិតរួមគ្នាកំណត់ថ្លៃ។ និយាយរួមក្នុងសេដ្ឋកិច្ចទីផ្សារ ថ្លៃទំនិញអាស្រ័យទៅនឹងតម្រូវការ និងការផ្គត់ផ្គង់ទំនិញនោះក្នុងទីផ្សារ ដូច្នេះបរិមាណនិងថ្លៃទំនិញត្រូវស៊ីសង្វាក់គ្នា និងគោលដៅរបស់អ្នកប្រើប្រាស់ និងអ្នកផលិត។ ដើម្បីពន្យល់ពីថ្លៃទំនិញ យើងត្រូវបកស្រាយអ្វីទៅជាតម្រូវការ និងអ្វីទៅជាការផ្គត់ផ្គង់។

<u>ក្រឹត្យក្រមតម្រូវការ និងការផ្គត់ផ្គង់</u>៖ ការវិភាគតម្រូវការ និងការផ្គត់ផ្គង់នៅក្នុងក្របខ័ណ្ឌសេដ្ឋកិច្ច គឺជាមធ្យោបាយរួមមួយដែលអាចប្រើសម្រាប់វិភាគ និងដោះស្រាយបញ្ហាសង្គមសេដ្ឋកិច្ចយ៉ាងទូលំទូលាយ។

ឧទាហរណ៍៖ ព្យាករណ៍ការផ្លាស់ប្តូរថ្លៃទីផ្សារក្នុងក្របខ័ណ្ឌ សេដ្ឋកិច្ចក្នុងប្រទេស ក្នុងតំបន់ និងក្នុងពិភពលោកការប៉ាន់ស្មានឥទ្ធិពលលិខិតបទដ្ឋានរបស់រដ្ឋក្នុងការត្រួតពិនិត្យថ្លៃទីផ្សារការកម្រិតអប្បរមានៃប្រាក់បៀវត្ស ឥទ្ធិពលការយកពន្ធលើថ្លៃ ទំនិញ និងសេវាជាដើម។ ការសិក្សាពីតម្រូវការ និងការផ្គត់ផ្គង់គឺជាការបង្ហាញឡើងពី ដំណើរការយន្តការទីផ្សារ។ ជាទូទៅគេរំពឹងថា ប្រសិនបើគ្មានការធ្វើអន្តរាគមន៍របស់រដ្ឋ (គ្មានការត្រួតពិនិត្យរបស់រដ្ឋលើថ្លៃទំនិញ) តម្រូវការ និងការផ្គត់ផ្គង់អាចឆ្ពោះទៅរកសមភាពបានដោយឯកឯង ហើយឈរលើមូលដ្ឋាននេះអាចចង្កត់បានជាថ្លៃទីផ្សារលើទំនិញ និងសេវា និងផ្តល់ព័ត៌មានអំពីបរិមាណរួមនៃផលិតកម្ម។

- ***ក្រឹត្យក្រមតម្រូវការ៖*** *តម្រូវការគឺជាបរិមាណទំនិញឬសេវាដែលអ្នកទិញមានបំណង និងសមត្ថភាពទិញ តាមថ្លៃជាគោលការណ៍នៅក្នុងពេលមួយកំណត់ជាក់លាក់។ ជាទូទៅយើងឃើញថា តម្រូវការជាផ្នែកមួយដ៏សំខាន់ក្នុងយន្តការសេដ្ឋកិច្ចទីផ្សារ ហើយការផ្លាស់ប្តូរតម្រូវការជាផ្នែកមួយនៃមូលហេតុការកើនឡើង ឬថយចុះកំណើនសេដ្ឋកិច្ច។ ក្រឹត្យក្រមតម្រូវការ គឺជាគោលការណ៍បង្ហាញពីទំនាក់ទំនងផ្ទុយគ្នារវាងថ្លៃទំនិញមួយទៅនិងបរិមាណទំនិញមួយទៀតដែលអ្នកទិញមានបំណង និងមានលទ្ធភាពទិញក្នុងពេលមួយដ៏ជាក់លាក់ និងក្នុងលក្ខខណ្ឌដែលកត្តាដទៃទៀតមិនផ្លាស់ប្តូរ។ តម្រូវការស្ថិតនៅក្រោមឥទ្ធិពលនៃកត្តាសំខាន់ៗមួយចំនួន៖ (ទី១) ប្រសិនបើថ្លៃទំនិញមួយកើនឡើង ដោយប្រៀបធៀបជាមួយនឹងថ្លៃទំនិញដទៃទៀតអ្នកប្រើប្រាស់ (អ្នកទិញ) និងបន្តយការទិញទំនិញនោះហើយ*

ទៅទិញទំនិញផ្សេងទៀត ដែលបណ្តាលមកពីឥទ្ធិពលជំនួស ដូច្នេះឥទ្ធិពលជំនួសទំនិញមួយទៀត (ទី២)ដោយចំនួនមានកម្រិតអ្នកប្រើប្រាស់ជាទូទៅ និងទិញទំនិញតិច នៅពេលដែលថ្លៃទំនិញនោះកើនឡើង ក្នុងករណីចំនូលរបស់គេនៅដដែល។ ឥទ្ធិពលចំនូល គឺជាការប្រែប្រួលតម្រូវការដែលបណ្តាលមកពីការប្រែប្រួលថ្លៃ។ (ទី៣)តម្រូវការប្រែប្រួលទៅតាមកម្រិតខ្ពស់ ឬទាបនៃឱជារស ឬចំណង់ចំណូលចិត្តរបស់អ្នកប្រើប្រាស់។ (ទី៤)បរិមាណតម្រូវការនឹងប្រែប្រួលទៅតាម "ការសន្សំទ្រព្យសម្បត្តិ" ឬកម្រិតទ្រព្យសម្បត្តិរបស់អ្នកប្រើប្រាស់។ និយាយជារួមប្រសិនបើកត្តាទាំង ឡាយដែលបានរៀបរាប់ខាងលើប្រែប្រួលបរិមាណតម្រូវការក៏ប្រែប្រួលទៅតាមនោះដែរ។ ទន្ទឹមនឹងនេះថ្លៃទំនិញពុំមែនជាអថេរតែមួយគត់ដែលកំណត់តម្រូវការនៃទំនិញនោះទេ។ ដូចដែលបានបញ្ជាក់ខាងលើបរិមាណតម្រូវការ ស្ថិតក្រោមឥទ្ធិពលជំនួស ប្រាក់ចំណូល ចំណង់ចំណូលចិត្ត ឬការរំពឹងទុករបស់អ្នកប្រើប្រាស់។ ទំនាក់ទំនងរវាងបរិមាណតម្រូវការស្ថិតក្រោមឥទ្ធិពលជំនួសប្រាក់ចំណូល ចំណង់ចំណូលចិត្ត ឬការរំពឹងទុករបស់អ្នកប្រើប្រាស់។ ទំនាក់ទំនងរវាងបរិមាណតម្រូវការ និងប្រាក់ចំណូលអាចមានលក្ខណៈស្រប ឬកញ្ច្រាសអាស្រ័យទៅនឹងលក្ខណៈទំនិញ តើជាទំនិញធម្មតា ឬទំនិញមិនសូវមានសារៈសំខាន់ ឬអន់គុណភាព។ ចំពោះទំនិញធម្មតាតម្រូវការកើនឡើងនៅពេលប្រាក់ចំណូលកើនឡើង។ ជារួមទំនិញភាគច្រើន គឺជាទំនិញធម្មតា។

- **ក្រឹត្យក្រមការផ្គត់ផ្គង់៖** ក្រឹត្យក្រមការផ្គត់ផ្គង់ជាបរិមាណទំនិញដែលផលិតករប្រាថ្នា និងមានលទ្ធភាព តាមថ្លៃនីមួយៗដោយកំណត់ក្នុងពេលមួយជាក់លាក់។ កម្រិតការផ្គត់ផ្គង់ស្ថិតនៅក្រោមឥទ្ធិពលថ្លៃទំនិញ និងការប្រឈមមុខជាមួយទំនិញដទៃទៀត និងកត្តាផ្សេងៗដូចជា លក្ខណៈប្រើប្រាស់បច្ចេកវិទ្យា ការបង់ពន្ធ ការទទួលស្គាល់ទាយជ្ជទាន។ ក្រឹត្យក្រមការផ្គត់ផ្គង់ គឺជាគោលការណ៍មួយបញ្ជាក់ពីអត្ថិភាពនៃទំនាក់ទំនងស្របគ្នារវាងថ្លៃផលិតផល និងបរិមាណផិតផលផ្គត់ផ្គង់ប្រាថ្នានឹងមានលទ្ធភាពផ្គត់ផ្គង់ ក្នុងរយៈពេលមួយកំណត់ដោយជាក់លាក់ និងក្នុងលក្ខខណ្ឌដទៃទៀតមិនផ្លាស់ប្តូរ។ មូលហេតុដែលនាំឱ្យកើតមានឡើងនូវក្រឹត្យក្រមការផ្គត់ផ្គង់គឺ (ទី១)បណ្តាលមកពីចំណាយក្នុងផលិតកម្ម នៅពេលផលិតករ ចង់ផលិតបន្ថែមនូវផលិតកម្មទំនិញមួយធ្វើឱ្យអ្នកផលិតទំនិញនោះសង្ឃឹមថាគេនឹងចំណេញច្រើនប៉ុន្តែក៏ទាមទារឱ្យគេបង្វែរធនធានពិផលិតកម្មទំនិញដទៃទៀត ដើម្បីយកមកផលិតទំនោះ។ ជាទូទៅករណីនេះតម្រូវឱ្យបង្កើនថ្លៃទំនិញនោះទៀត។ ដូចគ្នានិងបរិមាណតម្រូវការដែរបរិមាណការផ្គត់ផ្គង់ស្ថិតនៅក្រោមឥទ្ធិពល និងប្រែប្រួលទៅតាមកត្តាជាច្រើនរួមមាន៖ ការប្រែប្រួលថ្លៃទំនិញនោះធៀបទៅនឹងថ្លៃទំនិញដទៃទៀត និងលក្ខណៈប្រើប្រាស់បច្ចេកវិទ្យាទំនើប និងតាមរយៈការបង់ពន្ធព្រមទាំងការ

ទទួលទាយជួញទាន។ ប្រសិនបើកត្តាទាំងនេះប្រែប្រួលបរិមាណការផ្គត់ផ្គង់ក៏ប្រែប្រួលទៅតាមនោះដែរ។ ម៉្យាងទៀត ប្រសិនបើចំនួនអ្នកលក់មានកាន់តែច្រើននោះការផ្គត់ផ្គង់នឹងអាចកើនខ្ពស់។ ករណីនេះដូចតម្រូវការដែរ ការរំពឹងទុករបស់អ្នកលក់គឺផ្អាកការផ្គត់ផ្គង់របស់គេ នៅពេលនោះដោយគេសង្ឃឹមថានឹងលក់ទំនិញរបស់ខ្លួនបានថ្លៃខ្ពស់នៅពេលក្រោយ។ ថ្លៃលើមុខទំនិញពាក់ព័ន្ធផ្សេងៗក៏មានឥទ្ធិពលទៅលើការផ្គត់ផ្គង់ដែរ។ កំណើនថ្លៃធៀបនៃទំនិញមួយដែលអាចផលិតបានដោយប្រើប្រាស់ធនធានដូចគ្នា និងធ្វើឱ្យការផ្គត់ផ្គង់ទំនិញនីមួយៗថយចុះហើយ នឹងមានការប្រែប្រួលបញ្ច្រាសមកវិញនៅពេលថ្លៃទំនិញទីពីរថយចុះ។

<u>សមតាទីផ្សារ</u> ទស្សន:សមតា គឺជាទស្សន:ដ៏សំខាន់មួយក្នុងសេដ្ឋកិច្ចទីផ្សារ។ ស្ថានភាពសមតានឹងកើតមានពេលដែលចលនានេះបង្កឱ្យមានកម្លាំងដែលព្យាយាមបង្កើតសមតាដោយគ្មាននិន្នាការនៃចលនាណាមួយផ្សេងទៀតរំកិលចេញ។ និយាយរួមសមតាទីផ្សារកើតមានតាមរយៈសមតាបរិមាណតម្រូវការ និងបរិមាណការផ្គត់ផ្គង់។ ប្រការនេះមានន័យថាមានសមតាថ្លៃ មានសមតាបរិមាណតម្រូវការ និងសមតាការផ្គត់ផ្គង់នៅពេលដែលថ្លៃស្មើបរិមាណតម្រូវការ និងបរិមាណការផ្គត់ផ្គង់ក៏ស្មើគ្នាដែរ។ ការណីនេះគ្មានឱនភាពទំនិញ និងអតិរេកទំនិញទេ ឬអាចនិយាយបានថាគ្មានឥទ្ធិពលដែលនាំឱ្យមានការផ្ទាស់ប្តូរថ្លៃតទៅទៀត។ ក្នុងទីផ្សារការផ្គត់ផ្គង់ និងតម្រូវការ មិនមែនជានិច្ចកាលមានសមតាទេពីព្រោះថានៅពេលមានការប្រែប្រួលក្នុងណាមួយចំនួនអាចជះឥទ្ធិពលនាំឱ្យផ្ទាស់ប្តូរបរិមាណតម្រូវការ និងការផ្គត់ផ្គង់។ ប៉ុន្តែជាទូទៅអាចសន្និដ្ឋានថា ក្នុងទីផ្សារបរិមាណតម្រូវការ និងការផ្គត់ផ្គង់មានសនិន្នាការបោះទៅរកសមតា។

ខ.គោលការណ៍ម៉ាក្រូសេដ្ឋកិច្ច

ម៉ាក្រូសេដ្ឋកិច្ច គឺជាការជានាឱ្យមានកំណើនសេដ្ឋកិច្ចនិងជីវភាពប្រជាពលរដ្ឋរុងរឿងប្រកបដោយចីរភាព។ ប៉ុន្តែអាទិភាពដ៏ជាក់លាក់មួយ គឺផ្នែកទៀតអាស្រ័យទៅលើកម្រិតការអភិវឌ្ឍន៍សេដ្ឋកិច្ច និងមួយផ្នែកទៅលើកត្តាមិនមែនសេដ្ឋកិច្ចដូចជា ការកំណត់ទិសដៅនយោបាយនិងទំហំនៃរដ្ឋាភិបាលជាដើម។

ជាទូទៅគោលការណ៍ ម៉ាក្រូសេដ្ឋកិច្ចដូចជា ការកំណត់ទិសដៅនយោបាយ និងទំហំនៃរដ្ឋាភិបាលជាដើម។ ជាទូទៅគោលការណ៍ម៉ាក្រូសេដ្ឋកិច្ច ដូចជា កំណត់ទិសដៅនយោបាយ និងទំហំនៃរដ្ឋាភិបាលជាដើម។ ជាទូទៅគោលការណ៍ម៉ាក្រូសេដ្ឋកិច្ចក្នុងបណ្តាប្រទេសជឿនលឿន គឺសម្តៅជានាឱ្យដំណើរផលិតកម្មប្រព្រឹត្តទៅដោយមានកំណើនសេដ្ឋកិច្ចមានការងារធ្វើពេញលេញ និងមានអត្រាអតិផរណាទាប។ ចំណែកនៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍វិញ គោលបំណងទាំងនេះត្រូវបត់បែនទៅតាមបញ្ហាជាច្រើនរួម ទាំងកំណែទំរង់សេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្ថាប័នច្បាប់ និងតុលាការ និងផ្នែករដ្ឋបាលសា

ជារណៈទៀតផង។ ជាទូទៅគោលបំណងសេដ្ឋកិច្ចសំខាន់ៗរួមមានដូចតទៅត:

១.ការបន្តយនិកម្មភាពឱ្យនៅទាបបំផុតនៅត្រឹម "អត្រានិកម្មភាពធម្មជាតិ"

២.រក្សាអត្រាអតិផរណាឱ្យនៅនឹង ឬត្រឹមអត្រាក្រោម ពីរខ្ទង់ (ក្រោម១០ភាគរយ)

៣.កាត់បន្តយអតុល្យភាពជញ្ជីងទូទាត់ឱ្យនៅទាបបំផុត ឬសម្រេចឱ្យបានជញ្ជីងទូទាត់មួយដែលមាន លំនឹងប្រកបដោយចីរភាព។

៤.គ្រប់គ្រងអាត្រាប្តូរប្រាក់បរទេសឱ្យមានលក្ខណៈប្រកួតប្រជែង

៥.កាត់បន្តយការធ្វើអន្តរាគមន៍របស់រដ្ឋក្នុងការបែងចែកធនធានឱ្យនៅតិចបំផុត និងជំរុញឱ្យថ្លៃទំនិញ និងសេវា ផ្សេងៗកំណត់ដោយទីផ្សារ។

៦.បង្កើនទុនបម្រុងឱ្យស្មើនឹង៣ដង នៃតម្លៃការនាំចេញទំនិញ និងសេវា

៧.កាត់បន្តយភាពក្រីក្រ និងជានាឱ្យមានសមធម៌ជាបណ្តើរៗក្នុងការបែងចែកប្រាក់ចំណូល

៨.សម្រេចឱ្យបានកំណើនសេដ្ឋកិច្ចខ្ពស់ និងប្រកបដោយចីរភាព។

ប្រទេសនីមួយៗមិនចាំបាច់សម្រេចឱ្យបាននូវគោលបំណងទាំងអស់ខាងលើដើម្បីដឹកនាំគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចនោះទេហើយក៏មិនចាំបាច់យល់ស្របថាគោលបំណងនីមួយៗមានសារៈសំខាន់ដូចគ្នាដែរ។ ពីព្រោះដំណោះស្រាយបញ្ហាសេដ្ឋកិច្ចសម្រាប់ប្រទេសកំពុងអភិវឌ្ឍគឺជា "អទិភាពក្នុងអាទិភាព"។

ឧទាហរណ៍ៈ ស្តេរភាពថ្លៃ និងភាពមានការងារធ្វើពេញលេញអាចជាគោលដៅពីរដែលមានចរិតផ្ទុយក្នុងរយៈពេលខ្លីដោយសារមានបញ្ហានិកម្មភាពតម្រូវឱ្យមានគោលនយោបាយដែលបង្កើតតម្រូវការសរុបចំណែកបញ្ហាអតិផរណាតម្រូវឱ្យមានគោលនយោបាយដែលកាត់បន្តយតម្រូវការសរុប។

៣. សញ្ញាណនៃតស្តុតារ និងហិរញ្ញវត្ថុ

៣.១-អត្ថន័យតស្តុតារ និងហិរញ្ញវត្ថុ

ក.អត្ថន័យនៃកស្តុការ

ការដឹកជញ្ជូនកស្តុការមានលក្ខណៈពិសេស ដោយវាមិនដែលឈប់សកម្មភាពឡើយវាកើតមានឡើង ជុំវិញពិភពលោក ២៤ម៉ោង ជារៀងរាល់៧ថ្ងៃក្នុង១សប្តាហ៍ និង ៥២សប្តាហ៍ក្នុងមួយឆ្នាំ។ មុខជំនួញខ្លះទាក់ទងនឹងភាពស្មុគស្មាញភូមិសាស្ត្រក្នុងការដឹកជញ្ជូន។ ការដឹកជញ្ជូនកស្តុការ (Logistics) គឺជាសំដៅលើផលិតផល និងសេវានានាដែលគេត្រូវការនោះ ដឹកទៅកន្លែងណា ហើយត្រូវការនៅពេលណាដែរ។ អ្នកប្រើប្រាស់ភាគច្រើនដែលនៅក្នុងប្រទេសឧស្សាហកម្មជឿនលឿនខ្ពស់គឺទទួលអំណោយផលសមត្ថភាព ដឹកជញ្ជូនប្រសិទ្ធភាពខ្ពស់។ ពេលដែលពួកគេទៅសាលារៀន ពួកគេគឺតថាទំនិញមានរួចជាស្រេចហើយស្រស់ៗទៀត។ និយាយទៅគេពុំអាចគឺតថាជោគជ័យខាងទីផ្សារ ឬផលិតកម្មអាចកើតឡើងបានដោយគ្មានការជួយគាំទ្រពីផ្នែកដឹកជញ្ជូននោះទេ។ ការដឹកជញ្ជូនកស្តុការ (Logisti-

cs) កើតមានតាំងពីការចាប់ផ្តើមនៃសម័យស៊ីវិលម៉ូះ។ ទោះយ៉ាងណាការអនុវត្តដ៏ប្រសើរនៃការដឹកជញ្ជូនគឺក្លាយទៅជាកត្តាដ៏អស្ចារ្យនិងប្រឈមបំផុតនៅក្នុងវិស័យជំនួញ និងការគ្រប់គ្រងវិស័យជំនួញ និងការគ្រប់គ្រងវិស័យសាធារណៈ។ ការដឹកជញ្ជូន ឬចែកចាយ គឺទាក់ទងនឹងការរួមបញ្ចូល និងសមាហរណកម្មនូវព័ត៌មានការដឹកជញ្ជូនសន្និធិការងារទុកដាក់ឥវ៉ាន់នៅក្នុងឃ្លាំង ការរៀបចំផលិតផលនិងការវេចខ្ចប់។ ផ្នែកនេះបានផ្តល់ការងារជាច្រើនផងដែរសម្រាប់មនុស្ស ហើយការងារទាំងនេះរួមបញ្ចូលការគ្រប់គ្រងដឹកជញ្ជូនទាំងឡាយឱ្យមានសមភាព។ ដោយសារកត្តាសំខាន់នៅក្នុងការងារដឹកជញ្ជូនប្រការនេះមន្ត្រីប្រតិបត្តិខាងការដឹកជញ្ជូនដ៏ជោគជ័យជាច្រើនកំពុងត្រូវបានតែងតាំងទៅជាគណៈគ្រប់គ្រងជាន់ខ្ពស់។

មន្ត្រីប្រតិបត្តិដឹកជញ្ជូនជាន់ខ្ពស់ដ៏ជោគជ័យ អាចបម្រើជាអ្នកមើលខុសត្រូវការងារតាមផ្នែកនានា ទាំងក្នុង និងក្រៅក្រុមហ៊ុន។ នៅក្នុងក្រុមហ៊ុន កត្តាចម្បង គឺត្រូវចេះសម្របសម្រួលជំនាញការងាររបស់បុគ្គលឱ្យទៅជាមានសមត្ថភាព អាចបម្រើសេវាអតិថិជនបានល្អ។ ក្នុងគំនិតជាយុទ្ធសាស្ត្រមន្ត្រីជាន់ខ្ពស់ទទួលបន្ទុកការងារដឹកជញ្ជូនត្រូវចេះផ្តើមគំនិតពង្រីកព្រំដែនអាជីវកម្ម ដើម្បីសម្រួលដល់ការទំនាក់ទំនងទៅនឹងចង្វាក់ផ្គត់ផ្គង់ឱ្យមានប្រសិទ្ធភាព។ ការទទួលខុសត្រូវប្រតិបត្តិការលើការដឹកជញ្ជូន គឺទាក់ទងនឹងចំណេះដឹងពីទីតាំងភូមិសាស្ត្រនៃវត្ថុជាតុដើមដំណើរការក្នុងការងារ និងសន្និធិដែលរៀបចំរួចហើយដែលត្រូវធ្វើឱ្យអស់ថ្ងៃដើមទាប បើសិនអាចធ្វើបាន។ កត្តាវាឆ្ងងកាត់ដំណើរការដឹកជញ្ជូនដែលវត្ថុជាតុដើមត្រូវហូរចូលទៅក្នុងសមត្ថភាពផលិតដែលមានជាទ្រង់ទ្រាយធំរបស់ប្រទេសឧស្សាហកម្ម ហើយផលិតផល នានាត្រូវបានចែកចាយតាមរយៈច្រកបណ្តាញទីផ្សារទៅកាន់អតិថិជន។

ខ.អត្ថន័យនៃហិរញ្ញវត្ថុ

ហិរញ្ញវត្ថុ គឺជាផ្នែកមួយដែលផ្តោតទៅលើការធានានូវមូលធនដើម្បីចាប់ផ្តើមដំណើរការនិងការពង្រីកអាជីវកម្មមួយ ហើយហិរញ្ញវត្ថុក៏ជាគ្រឹះសម្រាប់ការរីកចម្រើន និងការពង្រីកអាជីវកម្ម ព្រោះនៅក្នុងទីផ្សារសេរីតែងតែមានការប្រកួតប្រជែង ដូច្នេះគេត្រូវការវិនិយោគមូលធនបន្ថែមក្នុងការអភិវឌ្ឍន៍ចង្វាក់ផលិតកម្ម បច្ចេកទេស ផលិតកម្ម និងការទទួលបាននូវទ្រព្យសកម្មថ្មីសម្រាប់ការពង្រីកនាពេលអនាគត។

៣.២-ទំនាក់ទំនងសេដ្ឋកិច្ច តស៊ុតារនិងហិរញ្ញវត្ថុ

នៅក្នុងខ្លឹមសារនេះ គឺមានលក្ខខណ្ឌពី(ទី១) ទំនាក់ទំនងកស៊ុការនៅក្នុងសេដ្ឋកិច្ច និង(ទី២)ទំនាក់ទំនងហិរញ្ញវត្ថុក្នុងសេដ្ឋកិច្ច។

ក.ទំនាក់ទំនងកស៊ុការនៅក្នុងសេដ្ឋកិច្ច

ការប្រតិបត្តិការអាជីវកម្មពិភពលោក បានបង្កើនថ្លៃចំណាយសោហ៊ុយដឹកជញ្ជូន និងកត្តាស្មុគស្មាញ។ ទាក់ទងនឹងថ្លៃសោហ៊ុយដឹកជញ្ជូន និងកត្តាស្មុគស្មាញ។ កត្តាស្មុគ្រស្មាញនៃកិច្ចប្រតិ

បត្តិការពិភពលោកបានបង្កើនភាពមិនច្បាស់លាស់ ហើយកាត់បន្ថយសមត្ថភាពគ្រប់គ្រងទៀតផង។ លទ្ធផលមិនច្បាស់លាស់នេះបានកើតចេញមកពីរយៈចម្ងាយផ្លូវឆ្ងាយ ពេលវេលារៀបចំ ដឹកជញ្ជូនឥវ៉ាន់ និងចំណោះដឹងតិចតួចផ្នែកទីផ្សារ។ ចំពោះបញ្ហាទាក់ទងនឹងការគ្រប់គ្រង គឺបានកើតចេញមកពីការប្រើប្រាស់អន្តរការីច្រើនពេក ដោយផ្តួបផ្សំនឹងការអន្តរាគមន៍របស់រដ្ឋាភិបាលដូចជា ទាក់ទងនឹងតម្រូវការផ្សេងៗរបស់គយ និងកំហិតពាណិជ្ជកម្ម។ លក្ខណៈប្រឈមដ៏ពិសេស ទាំងនេះបានធ្វើឱ្យមានភាពស្មុគស្មាញដល់ដំណើរការក្នុងប្រសិទ្ធភាពប្រព័ន្ធដឹកជញ្ជូនពិភពលោក។ ទោះជាយ៉ាងណាក្នុងសេដ្ឋកិច្ចសម័យបច្ចុប្បន្នសកល ការរួបនីយកម្ម ក៏ពុំអាចជៀសរួចនោះដែរ។ ដូចនេះការដឹកជញ្ជូន (logistics) ត្រូវតែដោះស្រាយឱ្យបាននូវបញ្ហាកខ្វក់ និងបច្ច័យទាំងនេះ។ ជាសំណាងដែរ កម្លាំងទាំងអស់នេះលើកទឹកចិត្ត និងសម្រួលដល់សកលភាវូបនីយកម្ម ហើយធ្វើឱ្យការងារដឹកជញ្ជូនឥតព្រំដែនកាន់តែមានសារៈសំខាន់។ ទំនាក់ទំនងកស្តុការ នៅក្នុងសេដ្ឋកិច្ចនេះគឺមានពាក់ព័ន្ធនឹងកត្តាសំខាន់ៗដូចខាងក្រោម៖

- **កម្លាំងជំរុញឱ្យមានពិភពលោកដែលគ្មានព្រំដែន៖** មានកត្តាជំរុញជាច្រើន និងអ្នកសម្រួលការងារផង។ ប្រតិបត្តិការអាជីវកម្មពិភពលោកមានកត្តាជំរុញទាំង៥ គឺកំណើនសេដ្ឋកិច្ច ទស្សនៈលើចង្វាក់ផ្គត់ផ្គង់តំបន់ការរួបនីយកម្ម បច្ចេកទេសវិទ្យា និងការលប់ចោលកំហិត។

- **កំណើតសេដ្ឋកិច្ច** (Economic Growth) ៖ ចាប់តាំងពីសង្គ្រាមលោកលើកទី២មក ក្រុមហ៊ុននានានៅក្នុងប្រទេសដែលមានសេដ្ឋកិច្ចឧស្សាហកម្មជឿនលឿន បានទទួលកំណើនភាគរយនៃប្រាក់ចំណូល និងប្រាក់ចំណេញប្រចាំឆ្នាំ។ និន្នាការកំណើននេះកើតចេញមកពីកត្តាផ្សំនៃការជ្រៀតចូលទីផ្សារ ការពង្រីកខ្សែផលិតផលការពង្រីកអាជីវកម្មតាមតំបន់ភូមិសាស្ត្រ អាជីវកម្មកាន់តែជោគជ័យ និងទំហំទីផ្សារកាន់តែកើនឡើងដែលបណ្តាល មកពីអត្រាកំណើតកុមារខ្ពស់។ ការធ្លាក់ចុះនៃកំណើនសេដ្ឋកិច្ចនៅក្នុងប្រទេសឧស្សាហកម្មកើតឡើងស្របពេលដែល ផលិតភាពក្នុងវោងចក្រ និងក្នុងផ្នែកកសិកម្មបានកើនឡើងដែលជាលទ្ធផលនៃការប្រើបច្ចេកវិទ្យាថ្មី។ ក្នុងស្ថានភាពនេះវាជួយឱ្យសហគ្រាសបង្កើនប្រាក់ចំណូល និងផលចំណេញតាមរយៈការពង្រីកអាជីវកម្មទូទាំងពិភពលោក (Global expansion) ចូលទៅតំបន់អភិវឌ្ឍន៍នានា និងក្នុងប្រទេសកំពុងអភិវឌ្ឍន៍។ ដូចនេះការស្វែងរកកំណើន អាជីវកម្ម និងប្រាក់ចំណូល គឺជាកម្លាំងស្នូលនៃការជំរុញសហគ្រាសនានាឱ្យមានចិត្តបម្រើទីផ្សារពិភពលោក។

កត្តានានាជំរុញឱ្យមានសកលភាវូបនីយកម្ម



-ទស្សន:អំពីចង្វាក់ផ្គត់ផ្គង់ Supply chain perspectives **៖** នេះជាកត្តាជំរុញការដឹកជញ្ជូនកស្តុការពិភពលោក (Global logistics) ដែលមានការពេញនិយមភាគច្រើនទៅលើការអនុវត្តទស្សន:លើចង្វាក់ផ្គត់ផ្គង់ ដោយក្រុមហ៊ុន ផលិត និងក្រុមហ៊ុនចែកចាយទ្រង់ទ្រាយធំៗ តាំងពីមុនៗមកពួកអ្នកគ្រប់គ្រងបានផ្តោតទៅលើការកាត់បន្ថយនៅក្នុងសហគ្រាសរបស់ពួកគេៗ

ក្រុមហ៊ុនខិតខំស្វែងរកការគ្រប់គ្រងផ្នែកដឹកជញ្ជូនកស្តុការ Logistical control ដោយបំពេញការងារសំខាន់ៗ ជាច្រើនៗ ក្នុងនោះមានការទាក់ទងនឹងឃ្លាំងឥវ៉ាន់ឯកជន ការដឹកជញ្ជូន និងដំណើរការព័ត៌មានៗ ក្នុងខណៈដែលមានឯកជនភាវូបនីយកម្មបែបនេះកើនឡើង បានធ្វើឱ្យការគ្រប់គ្រងពង្រឹងសមត្ថភាព និងគ្រប់គ្រងឱ្យបានល្អដោយបង្កើនទ្រព្យសម្បត្តិ និងសម្ភារៈនានាដែលត្រូវជួយទ្រទ្រង់ដល់កិច្ចប្រតិបត្តិការផ្នែកកស្តុការៗ ពួកអ្នកគ្រប់គ្រងខាងដឹកជញ្ជូនកស្តុការយល់ថា ពួកគេអាចកាត់បន្ថយដើមទុនដែលត្រូវបានប្រើប្រាស់ ដោយសកម្មភាពជួលគេមកពីការទាក់ទងនឹងកិច្ចការកស្តុការៗ បទពិសោធន៍ជាមួយនឹងការជួលគេមកពីក្រៅបានបង្ហាញពីសារៈសំខាន់ខាងផ្នែកពង្រីកហិរញ្ញវត្ថុពិភពលោកៗ ក្រុមហ៊ុននានាព្យាយាមបង្កើតសម្ព័ន្ធនានា ជាមួយក្រុមហ៊ុនផ្គត់ផ្គង់លំដាប់ពិភពលោកក្នុងតម្លៃសមរម្យទាក់ទងសកម្មភាពផ្សេងៗដូចជាការដឹកជញ្ជូនរួមបញ្ចូលគ្នាជាអន្តរជាតិ ការដឹកជញ្ជូនអន្តរជាតិ ការរៀបចំបែបបទឯកសារ និងកិច្ចការសម្រួលដទៃទៀតៗ

-តំបន់ភាវូបនីយកម្ម (Regionalization)៖ តម្រូវការបង្កើតផ្សារថ្មីនានា ដើម្បីទ្រទ្រង់កំណើនគឺជាកម្ងាំងសំខាន់មួយដែលបានជួយដល់ការទឹកចិត្ត ក្រុមហ៊ុនឱ្យស្វែងរកអតិថិជននៅក្នុងប្រទេសរបស់ខ្លួនៗ មានន័យថា ដើម្បីជំរុញពាណិជ្ជកម្មតាមតំបន់ និងការពារដៃគូពាណិជ្ជកម្មដែលមានការប្រកួតមកពីខាងក្រៅប្រទេសនានា គឺចាប់ផ្តើមបង្កើតភាពជាដៃគូរតាមរយៈសន្ធិសញ្ញាផ្សេងៗៗ

ការធ្វើតំបន់ភាវូបនីយកម្មបែបនេះនាំមកនូវទំនាក់ទំនងឧស្សាហកម្មជាមួយគ្នា ទៅមកដែលទាក់ទងនឹងចំនួនប្រជាជនស្មើគ្នា និងកម្ងាំងសេដ្ឋកិច្ចៗ ការធ្វើពាណិជ្ជកម្មតំបន់ទៅវិញទៅមកទទួលបានការជួយសម្រួលដោយការកាត់បន្ថយតារាងពន្ធអាករ ការកាត់បន្ថយតម្រូវការរបស់គយ (Customs Requirements) ការបង្កើតការរៀបចំបែបបទដឹកជញ្ជូន និងការជួយទ្រទ្រង់ការដឹកជញ្ជូនទូទៅៗ តំបន់ព្រំដែនតាមប្រទេសពីមុនៗ គឺជារបាំងពាណិជ្ជកម្មមួយៗ

ឧទាហរណ៍៖ ចលនាដឹកជញ្ជូនមួយក្នុងសហរដ្ឋអាមេរិកដែលមានចម្ងាយ ៧៥០ម៉ៃល៍ តម្រូវឱ្យដល់កន្លែងក្រោមរយៈពេល២ថ្ងៃប៉ុណ្ណោះៗ បានសេចក្តីថាកិច្ចខំប្រឹងប្រែងឱ្យមានតំបន់ភាវូបនីយកម្មដែលគេបង្កើតឡើង គឺដើម្បីជួយសម្រួលពាណិជ្ជកម្ម បន្ធូរបន្ថយការដាក់កំហិតរបស់រដ្ឋាភិបាល និងការតម្រូវការផ្សេងៗ

ដែលចេះតែបន្តនាំឱ្យមានការបង្ហាក់ដល់ការដឹកជញ្ជូនកស្តុការ។

- **បច្ចេកវិទ្យា** (Technology) ៖ ការប្រាស្រ័យទាក់ទង និងបច្ចេកវិទ្យាព័ត៌មានបង្ហាញជាកម្លាំងជំរុញទី៤ ដែលជួយបង្កើនកិច្ចប្រតិបត្តិការណ៍អន្តរជាតិ។ ប្រព័ន្ធទំនាក់ទំនងទីផ្សារទូលំទូលាយបានបង្ហាញអតិថិជនអន្តរជាតិ។ ប្រព័ន្ធទំនាក់ទំនងទីផ្សារទូលំទូលាយបានបង្ហាញអតិថិជនអន្តរជាតិនូវផលិតផលបរទេសនានាដែលជាហេតុនាំឱ្យមានការប្រសព្វនៃតម្រូវការពិភពលោក និងចំណង់ចំណូលចិត្តនានា។ ទោះបីជាពួកគេមានសញ្ជាតិអ្វីក៏ដោយ ក៏ពួកគេនៅមានចិត្តស្វែងរករបៀបជីវិតរស់នៅល្អៗដូចគ្នាដែរ ហើយចង់បានផលិតផលស្រដៀងគ្នា។ ពួកគេត្រូវការផលិតផលដែលល្អជាងគេក្នុងតម្លៃទាបបើអាចធ្វើទៅបាន។ រីឯប្រព័ន្ធឃោសនាដូចជា Cable News Network (CNN),USA Today និងប្រព័ន្ធផ្សព្វផ្សាយផ្កាយរណបជំទៃ គឺអាចជួយជំរុញនូវប្រភេទផលិតផលនានា ហើយជំរុញឱ្យមានតម្រូវការលើការផលិតផល។

កម្លាំងពង្រីកម៉្យាងទៀត គឺកើតចេញមកពីការអភិវឌ្ឍន៍បច្ចេកវិទ្យា ដែលជាសមត្ថភាពបង្កើនមួយ ដើម្បីផ្ទាស់ប្តូរព័ត៌មានដែលសម្រួលដោយភាពសំបូរបែបនៃកុំព្យូទ័រ និងបណ្តាញគមនាគមន៍។ ការពីមុនៗការធ្វើឯកសារ ឬលិខិតស្នាមពាណិជ្ជកម្មអន្តរជាតិ ដូចជាបទបញ្ជានានាគឺមានការទាមទារតម្រូវផ្សេងៗទាក់ទងនឹងការដឹកជញ្ជូន និងបែបបទគយ ដែលជាឯកសារលិខិតស្នាមជាតុរឹង (hard-copy paper) ដែលទាមទារចំណាយពេលវេលាច្រើន ដើម្បីផ្ទេរដឹកឥវ៉ាន់ ហើយជាញឹកញាប់មានកំហុសច្រើនៗទៀតផង។ មុនពេលដែលបច្ចេកវិទ្យាទំនាក់ទំនងជឿនលឿនមកដល់ គឺវដ្តនៃសកម្មភាពការងារ ដែលចេញពីដំណាក់ការបញ្ជាទិញ (Order commitment) រហូតដល់ដំណាក់កាលចេញវិក័យបត្រ (Order receipt) គឺមានរយៈកាលដល់ទៅ៩ខែ ដើម្បីបូរស្បែកជើងម៉ាក Adidas ក្នុងសហរដ្ឋអាមេរិកពីរដ្ឋ Orient ។ ក្រោយមកដំណើរការនេះក៏ត្រូវកាត់មកនៅ៣ខែវិញតាមរយៈការប្រើបច្ចេកវិទ្យាព័ត៌មានទំនើប ដែលអាចបង្កើនល្បឿនទំនាក់ទំនងក្នុងការបញ្ជាទិញធ្វើគម្រោងពេលវេលាផលិតគម្រោងពេលវេលាដឹកជញ្ជូន និងរត់ការគយ។

- **ការលុបចោលការដាក់កម្រិត** (Deregulations)៖ ការលុបចោលការដាក់កំហិតទៅលើវិស័យសំខាន់ៗមួយចំនួន គឺជាកម្លាំងជំរុញមួយចំពោះពិភពលោកដែលគ្មានព្រំដែនកំណត់។ វិស័យសំខាន់ៗចំនួន២ ដែលត្រូវបានលុបចោលការកម្រិតមានដូចជាផ្នែកហិរញ្ញវត្ថុ និងការដឹកជញ្ជូន។

- **ការលុបចោលការដាក់កំហិតទៅលើ វិស័យដឹកជញ្ជូន** (Transportation Deregulation)៖ គំនិតផ្តួចផ្តើមរបស់អាមេរិក ដើម្បីលុបកំហិត ចំពោះវិស័យដឹកជញ្ជូនក្នុងអំឡុងដើមសតវត្សទី៨០ បានរីកដុះដាល់បន្តិចម្តងៗទូទាំងពិភពលោក។ ទោះបីជាការពិតដែលថា ការលុបចោលកំហិតនៅទូទាំងពិភពលោកទាំងមានលក្ខណៈយឺតជាងនៅក្នុងនៅក្នុងសហរដ្ឋអាមេរិក ក៏ដោយមានការដាក់

កំហិតបទបញ្ញត្តិនានាទាក់ទងនឹងសិទ្ធិគ្រប់គ្រង និងសិទ្ធិប្រតិបត្តិការអាជីវកម្មដឹកជញ្ជូនអន្តរជាតិ។ នាវាដឹកជញ្ជូនតាំងពីដើម គឺមានកម្រិតកំណត់ប្រតិបត្តិការនៅក្នុងមធ្យោបាយដឹកជញ្ជូនដែលមានការដាក់កំណត់ថ្លៃឈ្នួលរួម និងកិច្ចព្រមព្រៀងរកស៊ីតិចតួច។ ជាពិសេសក្រុមហ៊ុនផ្នែកកប៉ាល់ កាណូត គឺពុំអាចគ្រប់គ្រង ឬធ្វើជាម្ចាស់ទៅលើការរកស៊ីតាមដើងគោកបាន ដូចជា យានយន្ត ឬរថភ្លើងឡើយ។ ដោយគ្មានការគ្រប់គ្រងជាកម្មសិទ្ធិរួមកិច្ចប្រតិបត្តិការនានា និងការព្រមព្រៀងលើការកំណត់ថ្លៃនោះការដឹកជញ្ជូនអន្តរជាតិមានភាពស្មុគស្មាញដែលមកពីកត្តាពាក់ព័ន្ធមួយចំនួន។ ការដឹកជញ្ជូនអន្តរជាតិ គឺតម្រូវឱ្យមាននាវាច្រើនប្រភេទដើម្បីធ្វើការងារ និងគ្រប់គ្រងលំហូរគមនាគមន៍។ លើសពីនេះកិច្ចប្រតិបត្តិការដឹកជញ្ជូនតាមនាវាក៏មានកម្រិតដែរ។

ឧទាហរណ៍៖ នាវាដែលគ្រប់គ្រង ដោយជនបរទេសពុំអាចប្រតិបត្តិការក្នុងប្រទេសនានាដែលបិតនៅរវាងប្រទេសដើម(domestic origins) និងទិសដៅទៅដល់(destinations)។ ស្រដៀងគ្នានេះដែរក៏ឃើញការលុបចោលការដាក់កំហិតផ្សេងៗនៅក្នុងប្រទេសឧស្សាហកម្មជឿនលឿនភាគច្រើន។

កត្តាជំរុញលើការដឹកជញ្ជូនក្នុងសកលភាវូបនីយកម្មបានបង្កើតឱ្យមានឯកជនភាវូបនីយកម្មលើក្រុមហ៊ុនដឹកជញ្ជូន។ តាំងពីដើមក្រុមហ៊ុនដឹកជញ្ជូនអន្តរជាតិជាច្រើនត្រូវបានគ្រប់គ្រង និងប្រតិបត្តិអាជីវកម្ម ដោយរដ្ឋាភិបាល របស់ប្រទេសក្រៅដែលចូលមករកស៊ី (Home country) ដើម្បីជំរុញពាណិជ្ជកម្ម ហើយផ្តល់សម្ភារៈបម្រុងជាយុទ្ធសាស្ត្រ នៅក្នុងករណីពេលមានសង្គ្រាមកើតឡើង។

ឧទាហរណ៍៖ ក្រុមហ៊ុនអាកាសចរណ៍បាវ៉ាំង ជាដើម។ ក្រុមហ៊ុនដឹកជញ្ជូននានាដែលគ្រប់គ្រងដោយរដ្ឋាភិបាលពេលខ្លះក៏មានជួយឧបត្ថម្ភធនអាជីវកម្មដល់សហគ្រាស នៃប្រទេសក្រៅដែលចូលមករកស៊ីរបស់ពួកគេ (For their home country enterprises) ផងដែរហើយបែរជាបន្ថែមតម្លៃពន្ធទៅលើសហគ្រាសបរទេសនានាវិញ។ ក្នុងកិច្ចខិតខំកែលម្អសេវាកម្ម រដ្ឋាភិបាលជាច្រើនបានធ្វើឯកជនភាវូបនីយកម្មលើក្រុមហ៊ុនដឹកជញ្ជូនធំៗ។

ឧទាហរណ៍៖ ចក្រភពអង់គ្លេស ប្រទេសកាណាដា កំពុងតែធ្វើឯកជនភាវូបនីយកម្មទៅលើក្រុមហ៊ុនអាកាសចរណ៍ ក្រុមហ៊ុនរថយន្ត និងក្រុមហ៊ុនផ្លូវដែក។ សហគមន៍អឺរ៉ុប កំពុងតែបញ្ចប់ការធ្វើឯកជនភាវូបនីយកម្មជាទ្រង់ទ្រាយធំ និងគម្រោងហេដ្ឋារចនាសម្ព័ន្ធនានា ដើម្បីធ្វើយតបនឹងតម្រូវការជំនួញដែលចេះតែកើនឡើងៗ។ ដោយបិតនៅក្នុងទីមួយប្រកួតប្រជែង ក្រុមហ៊ុនដឹកជញ្ជូនជាឯកជនត្រូវតែកែលម្អ សេវាកម្មឱ្យបានប្រសើរ និងសមស្រប និងថ្លៃប្រកួតប្រជែងផងដែរ។

តាមការសិក្សាបានបង្ហាញថា រដ្ឋមន្ត្រីនៃក្រសួងគមនាគមន៍អឺរ៉ុបជាច្រើនរូបបានចុះកិច្ចសន្យាព្រមព្រៀង ដើម្បីបើកទ្វីបអឺរ៉ុប ឱ្យទៅជាទីផ្សារដឹកជញ្ជូនតែមួយវិញកាលឆ្នាំ១៩៩៧។ អង្គការ NAFTA ពុំបានអនុញ្ញាតឱ្យមានការរកស៊ីដឹកជញ្ជូនតាមផែប្រាំងតាមរយៈរថយន្តនោះទេ

ហើយទោះជាយ៉ាងណាក៏ដោយក្រុមហ៊ុន រថយន្ត (Trucking firms) អាចដឹកទំនិញអន្តរជាតិ ចូលទៅរដ្ឋ តាមព្រំដែនម៉ិចស៊ិចកូ នៅចុងឆ្នាំ១៩៩៥ និងចូល ទៅទូទាំង Mexico នៅចុងឆ្នាំ១៩៩៩។ ក្រុមហ៊ុន ដឹកជញ្ជូនតាមរថយន្តរបស់ Mexico ក៏ត្រូវអនុ ញ្ញាតឱ្យមានការអនុគ្រោះចូលទៅក្នុងសហរដ្ឋអា មេរិក ដូចគ្នាផងដែរ។

កិច្ចព្រមព្រៀងសេវាទ្វេភាគី តម្រូវថា ចំនួនតុល្យភាពមួយនៃក្រុមហ៊ុនដឹកជញ្ជូននានា ដែលបានចុះបញ្ជីពាណិជ្ជកម្មនៅក្នុងប្រទេស នីមួយៗត្រូវបានផ្តល់សិទ្ធិអនុញ្ញាតឱ្យរកស៊ីរវាង ចំណុចកន្លែងដើម និងទិសដៅទៅដល់ (Between Origin and Destination points)។ ការធ្វើកូសង់ស៊ីស (Consensus) នេះគឺថាកិច្ចព្រមព្រៀងទ្វេភាគីតាម របៀបរបបមុន កំពុងតែផ្លាស់ប្តូរទៅជារបៀបព ហុភាគី ដោយមានការគិតគូរពិចារណាដោយ ឡែកៗសម្រាប់ការដឹកជញ្ជូនដែលមានការកែ លម្អ ហើយស្របពេលនេះដែរក៏មានកាត់បន្ថយ អត្រាថ្លៃដឹកជញ្ជូនផងដែរ។

-បណ្តាញចែកចាយ (Distribution Channels) **៖** បណ្តាញចែកចាយមានភាពខុសគ្នាដូចជា ស្តង់ ដារ ហេដ្ឋារចនាសម្ព័ន្ធសំដៅទៅលើភាពខុសគ្នា នៃការដឹកជញ្ជូន បរិក្ខារគ្រប់គ្រងសម្ភារៈឃ្លាំង កំពង់ផែទំនិញនិងប្រព័ន្ធទំនាក់ទំនង។ ខណៈដែល មានការអនុវត្តថ្មីសម្រាប់ធ្វើឱ្យស្តង់ដារប្រសើរ ឡើងជាមួយនឹងទំនុកចិត្តនៅមានភាពខុសគ្នាសំ ខាន់ៗ នៅក្នុងបរិក្ខាដឹកជញ្ជូនសកលដូចជា ទំហំ ឡានសមត្ថភាពទម្ងន់ និងខ្នាត ផ្លូវរថភ្លើង។

-ការប្រកួតប្រជែងសកល (The Global Challenge) **៖** ក្រុមហ៊ុនចង់ពង្រីកតម្រូវការសកល ដើម្បីប៉ាន់ស្មានតុល្យភាពនៃកម្លាំងដែលជំរុញ សកម្មភាពទាំងនេះ និងត្រូវតែពុះពារឧបសគ្គ។ ការបង្កើនជំនួញអន្តរជាតិ ត្រូវការអ្នកគ្រប់គ្រង កស្តុការដើម្បីអភិវឌ្ឍសម្បជញ្ញៈនិងទស្សន: វិស័យសកល។ អ្នកគ្រប់គ្រងត្រូវដឹងពីឧបសគ្គព័ កស្តុការ ដែលមានរួចមកហើយ ដោយពិចារណា នូវបញ្ហាដែលធ្វាស់គ្នា និងមានការយល់ច្បាស់ ដើម្បីផាត់ចូលទៅបរិយាកាសមិនមែនជាប្រពៃ ណី។ ខណៈដែលគោលការណ៍កស្តុការក្នុងស្រុក និងសកលផង ដំណើរការបរិយាកាសមានភាព ស្មុគស្មាញ និងថ្ងៃ។ ភាពស្មុគ្រស្មាញ និងតម្លៃត្រូវ បានបង្ហាញ៤យ៉ាង៖ ចម្ងាយឯកសារភាពផ្សេងគ្នា នៃវប្បធម៌ និងការទាមទាររបស់អតិថិជន។ ចម្ងាយគឺកាន់តែវែងឯកសារ គឺមានភាពទូលំទូ លាយ។ អតិថិជនទាមទារ ការផ្លាស់ប្តូរទំនិញ និងសេវា ដើម្បីស្របតាមវប្បធម៌ខុសគ្នានៅក្នុង តំបន់ និងប្រទេស។ ការអភិវឌ្ឍន៍យុទ្ធសាស្ត្រ និងស្មៀតដើម្បីធ្វើយតបទៅនឹងប្រកេទបិរយោ កាស ៤យ៉ាង គឺជាការប្រកួតប្រជែងសកលនៃ ការគ្រប់គ្រងកស្តុការ។ ការអភិវឌ្ឍន៍កស្តុការ សកលតម្រូវឱ្យមានការរៀបចំដំណើរការទស្សន:វិជ្ជា និងចក្ខុវិស័យសកល។ ចក្ខុវិស័យត្រូវជាដំណើរ ការយុទ្ធសាស្ត្រ ការចង់បានស្នាដៃការវាស់ស្ទង់ និងការសម្រេចចិត្តធ្វាស់គ្នា។

ខ.ទំនាក់ទំនងហិរញ្ញវត្ថុនៅក្នុងសេដ្ឋកិច្ច

- ការលុបចោលការដាក់កម្រិតផ្នែកហិរញ្ញវត្ថុ (Financial Deregulation)

កត្តាហិរញ្ញវត្ថុពិភពលោកនិងការប្តូររូបិយវត្ថុអន្តរជាតិ ត្រូវបានសម្របសម្រួលជាច្រើនដោយមានការផ្លាស់ប្តូរ លើបទបញ្ញត្តិ និងនិតិវិធីនានា។ មានស្ថាប័ននានា ដូចជា ធនាគារផ្នែកអាហរ័ណ និងនីហរ័ណ សហរដ្ឋអាម៉េរិក និងស្ថាប័ន ហិរញ្ញវត្ថុដូចជា ស្ថាប័នទីផ្សាររូបិយវត្ថុអន្តរជាតិ ដែលអាចជួយពង្រីកនិងធានាបានន្ទូវក្រេឌីតនាំចេញ និងនាំចូលរយៈពេលយូរអង្វែងដែលលើសពីសមត្ថភាពរបស់ធនាគាររបស់បុគ្គលទៅទៀត។ វាអាចជួយបង្កើតនូវប្រាក់បម្រុងមូលធន ហើយកាត់បន្ថយហាយនិភ័យ ធនាគារជាបុគ្គល និងបង្កើនសមត្ថភាពាណិជ្ជកម្ម ទៀតផង។ ផ្សាររូបិយវត្ថុអន្តរជាតិ(The International Monetary Market-IMM) អាចជួយផ្តល់ជាយន្តការមួយដើម្បីប្តូររូបិយវត្ថុ និងការទិញដូរទំនិញនាពេលក្រោយទៅតាមហាងឆេងទីផ្សារ។ ទោះបីជាយ៉ាងណាក៏ IMM ចាប់បដិសន្ធិក្នុងឆ្នាំ១៩៧២ ឥទ្ធិពលរបស់វាបានកើនឡើងយ៉ាងខ្លាំងក្លានៅក្នុងឆ្នាំ១៩៨៧ ដោយមានការបង្កើតប្រព័ន្ធជំនួញជាអេឡិចត្រូនិចស្វ័យប្រវត្តិទូទាំងពិភពលោក។

ចំពោះកត្តាមួយទៀតនោះគឺ ការលុបបំបាត់នៃកម្រិតស្តង់ដាមាសដែលជាផ្នែកជំនួយនៅក្នុងរូបិយវត្ថុជាបុគ្គល(Individual Currencies)។ សហរដ្ឋអាម៉េរិកបានបោះបង់ចោលនូវកម្រិតស្តង់ដាមាសនៅដើមទសវត្សទី៧០ ដែលជាហេតុធ្វើឱ្យរូបិយវត្ថុធំៗដទៃ ត្រូវឡើងតម្លៃរបស់វាបើធៀបនឹងលុយដុល្លា តាមរយៈ កិច្ចព្រមព្រៀង របស់ IMM នេះឯង។ អត្រារូបិយវត្ថុថេរ (Fixed monetary Cates) បានដាក់កម្រិត ចំពោះការធ្វើពាណិជ្ជកម្ម ដោយមានការកំណត់ កម្រិតខ្ពស់ជាសប្បនិមិត្ត ចំពោះរូបិយប័ណ្ណ (Currencies) ធំៗរបស់ ប្រទេសឧស្សាហកម្មជឿនលឿន។ អត្រាដែលឡើងថ្លៃក៏ជួយសម្រួលដល់ចលនារូបិយវត្ថុសេរី ហើយតែងតែធ្វើឱ្យមានសមកាលកម្ម ដល់ការរីកចម្រើនពាណិជ្ជកម្មពិភពលោក និងការធ្លាក់ចុះសេដ្ឋកិច្ច។ លើសពីនេះទៀត អត្រាការប្រាក់មូលធន និងបរិយាកាសវិនិយោគទាំងមូលគឺមានទំនាក់ទំនងគ្នានិងអាស្រ័យរវាងគ្នាទៅវិញទៅ មកដោយសារប្រព័ន្ធរូបិយប័ណ្ណពិភពលោក[៥]។ លំហូរសេរីនៃការប្តូរប្រាក់(រូបិយប័ណ្ណ)គឺបញ្ជាក់យ៉ាងច្បាស់នៅក្នុងផ្សារហិរញ្ញវត្ថុនាសហសម័យ។ ឧទាហរណ៍ៈ លុយដុល្លាអាម៉េរិក ជួយសម្រួលដល់លំហូរទំនិញពិភពលោក ទោះបីជាមានប៉ះពាល់ដោយអត្រាប្រាក់បៀរវត្សរ៍ក្នុងប្រទេសនីមួយៗខុសគ្នាក៏ដោយ។

- ឧបសគ្គនានាចំពោះការដឹកជញ្ជូនកសិការក្នុងពិភពលោក (Barriers to Global Logistics)**៖** ខណៈដែលកម្លាំងជំរុញជាច្រើនជួយសម្រួលដល់កិច្ចប្រតិបត្តិការឥតព្រំដែននោះឧបសគ្គធំៗ

---

[៥] ក្រសួងមហាផ្ទៃ "សន្និបាតត្រួតពិនិត្យការងារឆ្នាំ ២០០៧ និងទិសដៅការងារឆ្នាំ ២០០៧ ភ្នំពេញ,ថ្ងៃទី ១២-១៣ ធ្នូ ២០០៨"។

មួយចំនួនបន្តរារាំងដល់ការធ្វើកសិកម្មក្នុងពិភពលោក។ ឧបសគ្គធំៗចំនួន៣ គឺកត្តាហិរញ្ញវត្ថុ ការប្រកួតប្រជែង និងទីផ្សារ ហើយនិងច្រកចែកចាយនានា។ ការគ្រប់គ្រងការដឹកជញ្ជូនសម្ភារៈកសិកម្មក្នុងពិភពលោកត្រូវតែមានតុល្យភាពហើយថ្លៃចំណាយលើការដោះស្រាយឧបសគ្គទាំងនេះជាមួយនឹងអត្ថប្រយោជន៍នៃពាណិជ្ជកម្មអន្តរជាតិដើម្បីសម្រេចបាននូវផលប្រយោជន៍ ជាក់ស្តែងនៃអាជីវកម្មអន្តរជាតិដ៏ជោគជ័យ ។

- ***ឧបសគ្គហិរញ្ញវត្ថុ*** **(Financial Barriers) ៖** ឧបសគ្គហិរញ្ញវត្ថុ នៃកសិកម្មសកលមានមកពីការព្យាករណ៍ និងស្ថាប័នហេដ្ឋារចនាសម្ព័ន្ធ។ ខណៈដែលវាមិនងាយស្រួលក្នុងការព្យាករណ៍នៃស្ថានការណ៍ណាក៏ដោយគឺជាការពិបាកណាស់នៅក្នុងបរិយាកាសសកល។ ការព្យាករណ៍នូវភាពប្រកួតប្រជែងក្នុងស្រុក ដើម្បីទាយពីកត្តានៃតម្លៃដុល្លាដោយផ្អែកលើនិន្នាការអតិថិជនសកម្មភាពប្រកួតប្រជែងក្នុងស្រុក គឺដើម្បីទាយពីកត្តានៃតម្លៃដុល្លា ដោយផ្អែកលើនិន្នាការអតិថិជនសកម្មភាពប្រកួតប្រជែង និងតាមរដូវ។ នៅក្នុងបរិយាកាសសកលការប្រកួតប្រជែងទាំងនេះត្រូវបានផ្សំដោយអត្រាប្តូរ ប្រាក់ សកម្មភាពពន្ធគយ និងភាពស្មុគស្មាញ នៃច្បាប់រដ្ឋាភិបាល។

៤. គោលការណ៍ការគ្រប់គ្រងតស៊ុតារឥណហិរញ្ញវត្ថុ

៤.១-គោលការណ៍គ្រប់គ្រងតស៊ុតារ

សមត្ថភាពនៃកសិកម្មអាចត្រូវបានសម្រេចដោយការសម្របសម្រួលដូចជា(ទី១)ការរៀបចំបណ្តាញ(ទី២)ព័ត៌មាន(ទី៣)ការដឹកជញ្ជូន(ទី៤)បញ្ជីសារពើភណ្ឌនិង(ទី៥)ការទុកដាក់ក្នុងឃ្លាំងការរៀបចំសម្ភារៈនិងការវិចខ្ចប់។ ការងារដែលជាប់ទាក់ទងនឹងផ្នែកមុខងារទាំងនេះត្រូវបានដាក់រួមបញ្ចូលគ្នា ដើម្បីបង្កើតសមត្ថភាពតម្រូវការ និង សម្រេចតម្រូវការកសិកម្ម។ ការយកចិត្តទុកដាក់ គឺផ្តោតទៅលើការពិភាក្សាលើចំណុចការងារកសិកម្មនីមួយៗនេះ និងរបៀបដែលការងារទាំងនេះធ្វើអន្តរកម្មក្នុងការងារអាជីវកម្មទូទៅ។ មានគុណវឌ្ឍន៍សំខាន់ពីរសម្រាប់ពិភាក្សាការងារកសិកម្មដែលជាចំណុចមានប្រៀបរបស់សហគ្រាសមួយគឺ៖ គុណវឌ្ឍន៍ទី១ ក្រុមហ៊ុននានា តម្រូវឱ្យមានការគាំទ្រ និងការសហប្រតិបត្តិការជាច្រើនលើការងារជាច្រើនទៀត ដើម្បីសម្រេចឱ្យបាននូវដំណើរការកសិកម្មនេះ។ សហប្រតិបត្តិការបែបនេះធ្វើឱ្យក្រុមហ៊ុនអាចដាក់បញ្ចូលគោលការណ៍ និងកម្មវិធី ផ្សេងៗចូលគ្នាបាន។ ចំពោះទស្សនៈវិស័យនៃចង្វាក់ផ្គត់ផ្គង់មានប្រសិទ្ធភាពគឺត្រូវបានធ្វើឱ្យប្រសើរឡើងដោយការលប់បំបាត់កំហុសដដែលៗនូវការងារអ្វីដែលឥតប្រយោជន៍។ ទោះបីជាយ៉ាងណាក៏ដោយការសម្របសម្រួលឆ្លងកាត់មុខងារ តម្រូវឱ្យមានការរៀបចំផែនការ និងការ

គ្រប់គ្រងទំនាក់ទំនងរួមគ្នា។ ដំណើរការនៃការបង្កើត និងការគ្រប់គ្រងទំនាក់ទំនងចង្វាក់ផ្គត់ផ្គង់គឺត្រូវសិក្សាអំពីតម្រូវការ និងប្រសិទ្ធភាពរបស់វា។ គុណវឌ្ឍន៍ទី២ មានក្រុមហ៊ុនសេវាកម្មជាច្រើន ដែលបានអនុវត្តន៍ការងារកស្តុកនេះជំនួសអតិថិជនរបស់ខ្លួនដូចជា ក្រុមហ៊ុនដឹកជញ្ជូន ឬក្រុមហ៊ុនទុកដាក់ទំនិញក្នុងឃ្លាំង។ អ្នកជំនាញបែបនេះ គឺជាជំនួយបន្ថែម ឬអាចជំនួសការងារបុគ្គលិករបស់អតិថិជនដែលធ្វើការងារនេះ។ នៅពេលអ្នកជំនាញខាងក្រៅត្រូវបានប្រើឱ្យធ្វើការងារជំនាញកស្តុកនេះពួកគេត្រូវតែមានឆន្ទៈទទួលយកការគ្រប់គ្រង និងការដឹកនាំប្រកបដោយហេតុផលសម្រាប់អតិថិជនរបស់ពួកគេ។ ហេតុ ដូច្នេះនៅពេលអនុវត្តការងារជាក់លាក់មួយប្រការចាំបាច់ត្រូវការជួលទៅឱ្យអ្នកជំនួញ ឬអ្នកគ្រប់គ្រងរបស់ក្រុមហ៊ុនដែលធ្វើកិច្ចសន្យាទទួលខុសត្រូវចំពោះជោគជ័យនៃការងារចាំបាច់នោះដែរ។

ក.ការរៀបចំបណ្តាញ (Network Design)

វិជ្ជាសេដ្ឋកិច្ច កាលពីបុរាណមិនបានយកចិត្តទុកដាក់ចំពោះសារៈសំខាន់នៃទីតាំងអាគារ និងការរៀបចំ បណ្តាញទាំងមូលនោះឡើយ។ នៅពេលដែលអ្នកសេដ្ឋកិច្ចធ្វើការសិក្សាលើទំនាក់ទំនងតម្រូវការ និងការផ្គត់ផ្គង់ទីតាំងអាគារ និងភាពខុសគ្នានៃតម្លៃចំណាយដឹកជញ្ជូនត្រូវបានសន្មតថា អាចនឹងក្លាយជាបញ្ហាក្នុងចំណោមគូប្រកួតប្រជែង។ ទោះបីជាយ៉ាងណាក៏ដោយ ចំនួនទំហំ និងទំនាក់ទំនងភូមិសាស្ត្រ នៃអាគារដែលត្រូវបានប្រើប្រាស់ដើម្បីអនុវត្តប្រតិបត្តិការកស្តុការ គឺប៉ះពាល់ផ្ទាល់លើការចំណាយ និងសមត្ថភាពបម្រើ សេវាកម្មដល់អតិថិជន។ ការរៀបចំបណ្តាញនេះ គឺការទទួលខុសត្រូវមួយចំពោះការគ្រប់គ្រងកស្តុការ ព្រោះថា រចនាសម្ព័ន្ធអាគាររបស់ក្រុមហ៊ុន គឺត្រូវបានប្រើដើម្បីផ្តល់ផលិតផលនិងសម្ភារៈទៅអតិថិជន។ អាគារកស្តុការជាធម្មតាមានពេងចក្រឃ្លាំងទំនិញសហប្រតិបត្តិ ការឆ្លងកាត់កំពង់ផែ និងការស្តុកទំនិញលក់រាយ។ ដើម្បីកំណត់ចំនួនប្រភេទអាគារនីមួយៗទីតាំងភូមិសាស្ត្រ និងការងារដែលត្រូវអនុវត្ត គឺជាផ្នែកសំខាន់នៃការរៀបចំបណ្តាញ។ នៅក្នុងស្ថានភាពជាក់លាក់ការប្រតិបត្តិលើអាគារនេះត្រូវបានជួលទៅឱ្យអ្នកជំនាញសេវាកម្មដោយមិនគិតថា អ្នកណាជាអ្នកបម្រើការងារជាក់ស្តែងនេះអាគារទាំងអស់បានគ្រប់គ្រងឱ្យជាផ្នែកបញ្ចូលគ្នាមួយនៃបណ្តាញកស្តុការរបស់ក្រុមហ៊ុន។

តម្រូវការរៀបចំបណ្តាញនេះ ត្រូវកំណត់ចំនួន និងទីតាំងនៃប្រភេទអគារដែលត្រូវបានតម្រូវសម្រាប់អនុវត្ត ការងារកស្តុកនេះ។ កត្តាចាំបាច់ផងដែរ ដើម្បីកំណត់អ្វីជាសារពើតណ្ហា និងចំនួនស្តុកប៉ុន្មានដែលត្រូវដាក់ក្នុងអគារនីមួយៗ និងកន្លែងណាដែលត្រូវរៀបចំចាត់ចែងបញ្ជារបស់អតិថិជនសម្រាប់ការដឹកជញ្ជូន។ បណ្តាញនៃអាគារ ទាំងអស់នេះបង្កើតនូវចនាសម្ព័ន្ធពីប្រតិបត្តិការមួយទៅប្រតិបត្តិការមួយ។ ដូច្នេះបណ្តាញនេះរួមបញ្ចូលព័ត៌មាននិងសមត្ថ

ភាពដឹកជញ្ជូន។ ការងារជាក់លាក់ដែលទាក់ទង នឹងដំណើរការបញ្ជារបស់អតិថិជនការថែរក្សា ទុកជាក់សារពើភណ្ឌ និងការរៀបចំចាត់ចែងសម្ភារៈត្រូវបានធ្វើឡើងក្នុងការរៀបចំបណ្តាញ នេះ។

ការរៀបចំបណ្តាញត្រូវពិចារណាលើ ភាពខុសគ្នានៃភូមិសាស្ត្រ។ ការពិតដែលថា ភាពខុសជាច្រើនត្រូវបានកើតឡើងក្នុងទីផ្សារភូមិសាស្ត្រគឺងាយស្រួលក្នុងការបង្ហាញ។ ទីផ្សារក្នុងក្រុងសហរដ្ឋអាមេរិកធំបំផុតចំនួនប្រាំ ដែលមានចំនួនប្រជាជនច្រើនជាងគេ គឺជាទីផ្សារ ទិសដៅដែលលក់ទំនិញបាន៥៥% នៃការលក់ ទំនិញទាំងអស់។ ហេតុដូច្នេះចំពោះសហគ្រាស មួយបើនិយាយពីទីផ្សារកម្រិតជាតិ ត្រូវបង្កើតសមត្ថភាពកស្តុការនេះ ដើម្បីបម្រើដល់ទីផ្សារសំខាន់ៗនេះ។ ភាពខុសគ្នានៃភូមិសាស្ត្រ ដែលស្រដៀងគ្នា គឺកើតឡើងក្នុងទីតាំងប្រកពនៃសមាសភាគផ្សំ និងសម្ភារៈទូទៅ។ នៅពេលដែលក្រុមហ៊ុនជាប់ទាក់ទងក្នុងកស្តុការក្នុងពិភពលោកបង្ហាញដែលពាក់ព័ន្ធក្នុងការរៀបចំបណ្តាញនេះ គឺកាន់តែមានភាពស្មុគស្មាញ។ តាមការពិភាក្សាការរៀបចំបណ្តាញតាម Laura Ashley បង្ហាញនូវលក្ខណៈស្មុគស្មាញបែបនេះ។ សារៈសំខាន់នៃការកែតម្រូវបន្តបន្ទាប់នៃបណ្តាញអាគារនេះ គឺត្រូវសម្របសម្រួលតាមការផ្ទាស់ប្តូរក្នុងរចនាសម្ព័ន្ធផ្គត់ផ្គង់ និងតម្រូវការហើយដែលមិនអាចមើលរំលងបាន ។ ការរៀបចំផលិតផលតាមថ្នាក់ប្រភេទនីមួយៗការផ្គត់ផ្គង់អតិថិជននីមួយៗ និងតម្រូវការផលិត គឺមានការប្រែប្រួលជាប់ជានិច្ចក្នុងបរិយាកាសដែលប្រកួតប្រជែង និងស្មាហាប់នេះ។ ទោះបីការដាក់ទីតាំងថ្មីនៃអាគារកស្តុការនេះ ត្រូវបានប្រើប្រាស់ នៅលើកដំបូងមិនមានលក្ខណៈងាយស្រួលក៏ដោយ ក៏បរិយាកាសជាច្រើនត្រូវបានកើតឡើងចំពោះការដាក់ទីតាំងថ្មីនេះ ឬការរៀបចំអាគារជាក់លាក់នេះ។ ពីពេលមួយទៅពេលមួយអាគារទាំងនេះគួរត្រូវបានវាយតម្លៃ ដើម្បីកំណត់ថា តើទីតាំងរបស់ពួកគេបានល្អប្រសើរដូចការចង់បាន ឬអត់។ ការជ្រើសរើសបណ្តាញទីតាំងដែលល្អត្រូវផ្តល់ជំហានដំបូងទៅរកអត្ថប្រយោជន៍នៃការប្រកួតប្រជែង។ សមត្ថភាពកស្តុការនេះគឺអាស្រ័យទៅលើរចនាសម្ព័ន្ធនេះនិងត្រូវបានកំណត់ដោយរចនាសម្ព័ន្ធ។ ចំពោះចំណុចច្បាស់លាស់ជាច្រើនសម្រាប់បង្ហាញការសម្រេចចិត្តការដាក់ទីតាំងនេះ គឺតាមរយៈការអានសៀវភៅនៅពេលដែលសមស្របព្រោះវាធ្វើឱ្យយើងមានការយល់ដឹងបានគ្រប់គ្រាន់។

ខ.កត្តាព័ត៌មាន (Information)

សារៈសំខាន់នៃព័ត៌មានសម្រាប់ការអនុវត្តន៍កស្តុការមិនត្រូវបានសង្កត់ធ្ងន់កាលពីសម័យមុនៗការមិនយកចិត្តទុកដាក់នេះបណ្តាល ឱ្យមានការខ្វះខាតបច្ចេកវិទ្យាសមស្របមួយ ដើម្បីបង្កើតព័ត៌មានដែលចង់បាន។ ការគ្រប់គ្រងខ្វះខាតការអនុវត្តន៍ពេញលេញ និងការយល់ដឹងច្បាស់លាស់លើវិធីនៃការប្រាស្រ័យទាក់ទងលឿន និងត្រឹមត្រូវអាចគ្មានប្រសិទ្ធភាពក្នុងការអនុវត្តន៍កស្តុការ។ ចំណុចនៃឱនភាពទាំងពីរនេះ

កាលពីសម័យមុនត្រូវបានលុបចោល។ បច្ចេកវិទ្យាបច្ចុប្បន្ននេះ គឺមានលទ្ធភាពគ្រប់គ្រាន់ ដើម្បីដោះស្រាយទៅតម្រូវការព័ត៌មានដែលត្រូវការបំផុត។ បាន សេចក្តីថា ការប្រមូលព័ត៌មាននេះ អ្នកគ្រប់គ្រងជាច្រើនកំពុងរៀនពីរបៀបប្រើបច្ចេកវិទ្យានេះ ដើម្បីកែច្នៃដំណោះស្រាយកសិកម្មដែលថ្មីនិងល្អ។ ដំបូងព័ត៌មានដែលទទួលបានប្រហែលជាមិនត្រឹមត្រូវ ចំពោះនិន្នាការ និងព្រឹត្តិការណ៍នានា។ ដោយសារចំនួនជាច្រើននៃកសិកម្ម អាចកើតឡើងដោយការស្រមៃទុក ចំពោះតម្រូវការអនាគត និងការវាយតម្លៃមិនត្រឹមត្រូវ ឬការព្យាករណ៍មិនត្រឹមត្រូវអាចបណ្តាលឱ្យខ្វះសារពើភណ្ឌ ឬការប្តេជ្ញានៃការគ្រប់គ្រង។ ព័ត៌មានទាក់ទងនឹងដំណើរការបញ្ជាទិញប្រហែលជាមិនត្រឹមត្រូវ បើនិយាយពីតម្រូវការរបស់ អតិថិជនជាក់លាក់។ ដំណើរការនៃបញ្ជាមិនសមស្របនឹងអាចបង្កើតឱ្យមានការខាតបង់ចំពោះកសិកម្ម ប៉ុន្តែជាធម្មតាមិនបណ្តាលឱ្យមានការលក់។ ពិតណាស់ថ្លៃដើមនៃកសិកម្ម គឺត្រូវបានកើនឡើងដោយសារថ្លៃចំណាយការបញ្ជូនសារពើភណ្ឌត្រឡប់មកវិញ ប្រសិនបើ ឱកាសលក់នៅតែមានថ្លៃដើម និងបង្កើតឱ្យមានសេវាកម្មដែលចង់បាន។ កំហុសនីមួយៗក្នុងការផ្សំនៃតម្រូវការព័ត៌មានបង្កើតឱ្យមានភាពរឹតរវែងចំពោះចង្វាក់ផលិតកម្មសរុប។ អត្ថប្រយោជន៍ នៃលំហូរព័ត៌មានលឿននេះគឺទាក់ទងផ្ទាល់ទៅនឹងតុល្យភាពនីតិវិធីការងារ។ វាមិនសូវល្អនោះទេ ចំពោះក្រុមហ៊ុន ដើម្បីបង្កើនការបញ្ជាទិញនៅការិយាល័យលក់ ឬ ក្នុងតំបន់រហូតដល់រយៈពេលមួយសប្តាហ៍ធ្វើការបញ្ជាទិញតាមអ៊ីម៉ែលទៅការិយាល័យតំបន់ចំពោះដំណើរការបញ្ជាទិញមានចំនួនច្រើន។ ប៉ុន្តែទោះជាយ៉ាងណាកត្តាព័ត៌មានជាលក្ខខណៈមួយមានឥទ្ធិពលសម្រាប់ការគ្រប់គ្រងកសិកម្ម។

ការព្យាករណ៍ និងការគ្រប់គ្រងការបញ្ជាទិញ គឺជាការងារកសិកម្មដែលពឹងផ្អែកលើព័ត៌មាន។

ការព្យាករណ៍កសិកម្ម គឺជាការខិតខំប្រឹងប្រែង ដើម្បីប៉ាន់ស្មានលក្ខខណៈតម្រូវការ។ ការព្យាករណ៍ គឺត្រូវបានធ្វើឡើងដើម្បីជាការចង្អុលបង្ហាញសម្រាប់ការដាក់ទីតាំងសារពើភណ្ឌដើម្បីធ្វើការតាមដានមិនមែនជាអ្វីប្លែកនោះទេ។ ហេតុដូច្នេះហេតុផលមួយនៃហេតុផលចម្បងជាច្រើនដែលអ្នកគ្រប់គ្រងប្រើព័ត៌មាន ដើម្បីសម្រេចការគ្រប់គ្រងប្រតិបត្តិការកសិកម្មបានល្អប្រសើរ គឺវាអាស្រ័យលើភាពបទបែន ដែលបានព្យាករណ៍ហើយនោះ ដើម្បីឆ្លើយតបឱ្យបានរហ័ស ចំពោះតម្រូវការអតិថិជន របស់ខ្លួន។ គោលគំនិតនៃការគ្រប់គ្រងនេះ គឺវាបានបង្ហាញពីភាពទាន់ពេលវេលាឆ្លើយតបបានរហ័ស ជាពិសេសការបំពេញស្តុកឱ្យបានជាប់ជានិច្ច ដែលជាវិធីសាស្ត្រមួយសម្រាប់ការគ្រប់គ្រងកសិកម្មឱ្យបានល្អប្រសើរ និងអាស្រ័យ លើការអនុវត្តន៍បច្ចេកវិទ្យាថ្មីៗផងដែរ។ ការងារចម្បងការគ្រប់គ្រងកសិកម្ម គឺត្រូវធ្វើផែនការ និងអនុវត្តយុទ្ធសាស្ត្ររបស់អង្គភាពខ្លួនហើយដែលយុទ្ធសាស្ត្រនោះ ត្រូវរួមបញ្ចូនការព្យាករណ៍ និងការគ្រប់គ្រងប្រតិបត្តិការ។

ជាការពិតណាស់ការគ្រប់គ្រងបញ្ជាទិញពាក់ព័ន្ធទៅនឹងការងារ ពាក់ព័ន្ធការដោះស្រាយសម្របសម្រួល ជាមួយតម្រូវការអតិថិជនឱ្យបានជាក់លាក់។ មានន័យថា ការបញ្ជាទិញរបស់អតិថិជន គឺជាប្រតិបត្តិការសំខាន់ ក្នុងការងារកស្តុការ។ ចំពោះសេវាកម្មកស្តុការរួមបញ្ចូលទាំងអតិថិជនខាងក្នុង និងអតិថិជនខាងក្រៅ។ អតិថិជន ខាងក្រៅ គឺជាអ្នកដែលប្រើផលិតផល ឬសេវាកម្ម ឬដៃគូរពាណិជ្ជកម្មដែលទិញផលិផល ឬសេវាកម្មសម្រាប់លក់ វិញ។ រីឯអតិថិជនខាងក្នុង គឺជាក្រុមការងារនៅក្នុងអង្គភាពហើយជាជំនួយការសម្រាប់ការងារកស្តុការដែលបានដាក់មក។ ចំណែកឯដំណើរការនៃការគ្រប់គ្រងបញ្ជាទិញ គឺទាក់ទងទៅនិងចំណុចទាំងអស់នៃការគ្រប់គ្រងការបញ្ជាទិញអាចចាត់ទុកថាជាសមត្ថភាពកស្តុការល្អមួយនៅក្នុងអង្គភាព។ ការរៀបចំប្រព័ន្ធកស្តុការរបស់ក្រុមហ៊ុនកាន់តែមានប្រសិទ្ធភាព និងមានភាពត្រឹមត្រូវនៃព័ត៌មាននោះ គឺជាប្រព័ន្ធកស្តុការរបស់ក្រុមហ៊ុនកាន់តែមាន ប្រសិទ្ធភាព និងមានភាពត្រឹមត្រូវនៃព័ត៌មាន នោះគឺជាប្រព័ន្ធកស្តុការដែលផ្នែកលើពេលវេលាដែលរៀបចំបាន ល្អនិងមិនធ្វើឱ្យមានសារពើតណ្ឌខ្វះខាត។ បានសេចក្តីថាព័ត៌មានមិនត្រឹមត្រូវ និងការពន្យាពេលក្នុងដំណើរការ បញ្ជាទិញអាចធ្វើឱ្យរាំងស្ទះដល់ការអនុវត្តន៍កស្តុការ។ ចំណែកឯលំហូរព័ត៌មានអាចធ្វើឱ្យការគ្រប់គ្រងប្រព័ន្ធកស្តុការបានល្អ។ ហេតុដូច្នេះ គុណភាព និងពេលវេលាកំណត់នៃព័ត៌មាន គឺជាកត្តាសំខាន់ក្នុងកិច្ចប្រតិបត្តិការកស្តុការ។

គ.ការដឹកជញ្ជូន (Transportation)

ឱ្យតែមានសមត្ថភាពខាងព័ត៌មាន និងបណ្តាញអាគារ ការដឹកជញ្ជូន គឺជាផ្នែកប្រតិបត្តិការនៃកស្តុការដែលដាក់ទីតាំងសន្និធិតាមភូមិសាស្ត្រ។ ដោយសារតែវាមានសារសំខាន់ និងការចំណាយជាក់ស្តែងត្រឹមត្រូវការដឹកជញ្ជូនត្រូវបានគេយកចិត្តទុកដាក់លើរបៀបគ្រប់គ្រងរបស់វាអស់រយៈពេលជាច្រើនមកហើយ។ ស្ទើរតែគ្រប់សហគ្រាសទាំងអស់មិនថា តូច ឬធំ សុទ្ធតែមានអ្នកគ្រប់គ្រងទទួលខុសត្រូវចំពោះការដឹកជញ្ជូន។ រីឯលក្ខខណ្ឌ តម្រូវចំពោះការដឹកជញ្ជូនអាចត្រូវបានបំពេញតាមវិធីមូលដ្ឋានបី (ទី១) ត្រូវមានឧបករណ៍ឯកជនផ្ទាល់ខ្លួនសម្រាប់ប្រតិបត្តិការ។ (ទី២) កិច្ចសន្យាត្រូវតែរៀបចំឡើងដោយអ្នកជំនាញខាងដឹកជញ្ជូន។ និង(ទី៣) សហគ្រាសមួយត្រូវមានសេវាកម្ម និងសម្ភារៈដឹកជញ្ជូនច្រើនបែបយ៉ាង ដើម្បីផ្តល់សេវាកម្មដឹកជញ្ជូនផ្សេងៗគ្នា។ តាមទស្សនៈប្រព័ន្ធកស្តុការមានចំណុចបីសំខាន់សម្រាប់ការងារដឹកជញ្ជូនគឺការចំណាយថ្ងៃដើមល្បឿន និងភាពជាប់លាប់។ ថ្ងៃដើមនៃការដឹកញ្ជូនផ្សេងៗគ្នា។ តាមទស្សនៈប្រព័ន្ធកស្តុការមានចំណុចបីសំខាន់សម្រាប់ការងារដឹកជញ្ជូនគឺការចំណាយថ្ងៃដើមល្បឿន និងភាពជាក់លាក់។ ថ្ងៃដើមនៃការដឹកជញ្ជូនគឺជាការចំណាយសម្រាប់ការដឹកជញ្ជូនពីភូមិសាស្ត្រមួយទៅភូមិសាស្ត្រមួយទៀត ហើយការចំណាយនេះពាក់ព

ន្ធទៅនឹងការចំណាយដ្ឋេបាល និងការថែរក្សាសន្និពីធីកន្លែងមួយទៅកន្លែងមួយទៀតៗ ប្រព័ន្ធកស្តុការ ត្រូវបានរៀបចំឡើងដើម្បីប្រើប្រាស់ការដឹកជញ្ជូនដែលកាត់បន្ថយតម្លៃប្រព័ន្ធសរុប។ បានន័យថា ការដឹកជញ្ជូនមានតម្លៃកាន់តែទាបមិនមែនមានន័យថា តម្លៃដឹកជញ្ជូនទាបនោះទេ។

- ***ល្បឿននៃការដឹកជញ្ជូន*** ជាពេលវេលាតម្រូវឱ្យបំពេញនូវការដឹកជញ្ជូនមានទំនាក់ទំនងពីរយ៉ាងគឺ (ទី១) ក្រុមហ៊ុនដឹកជញ្ជូនអាចផ្តល់នូវសេវាល្បឿនជាធម្មតែងតែតឹតតម្លៃខ្ពស់។ (ទី២) សេវាដឹកជញ្ជូនកាន់តែល្បឿន រយៈពេលដឹកជញ្ជូនកាន់តែខ្លី នៅពេលដែលបញ្ជីសាររតើកណ្តាត្រូវបានធ្វងកាត់ និងអាចប្រើប្រាស់បាន។ ដូចនេះវិធីសាស្ត្រសម្រាប់ការដឹកជញ្ជូនដែលត្រូវជ្រើសរើសគឺ ត្រូវថ្លឹងថ្លែងល្បឿន និងតម្លៃសេវា ។

- ***ស្ថិរភាពក្នុងការដឹកជញ្ជូន*** គឺសំដៅទៅលើការប្រែប្រួលទាន់ពេលវេលា នៃតម្រូវការដឹកជញ្ជូនទំនិញតាមរយៈនាវា។ ស្ថិរភាព គឺជាការទ្រុះបញ្ចាំងនៃភាពអាចទុកចិត្តបានសម្រាប់ការដឹកជញ្ជូន។ រយៈពេលជាច្រើន ឆ្នាំមកហើយ អ្នកគ្រប់គ្រងការដឹកជញ្ជូនបានកំណត់ស្ថិរភាពថាលក្ខណៈសំខាន់បំផុត សម្រាប់គុណភាពការដឹកជញ្ជូន បើការធ្វើសកម្មភាពដឹកជញ្ជូន ចំណាយពេល២ថ្ងៃ ក្នុងពេលមួយ និង ៦ថ្ងៃ ក្នុងពេលមួយទៀត ការប្រែប្រួលដោយមិនបានគ្រោងទុកនេះអាចបង្កបញ្ហាដល់ដំណើរការកស្តុការយ៉ាងធ្ងន់ធ្ងរ។ បើការដឹកជញ្ជូនខ្វះស្ថិរភាព បញ្ជីសារពើកណ្តានៃការស្តុកទំនិញ នឹងត្រូវឱ្យការពារ ចំពោះសេវាដែលដំណើរការមិនល្អ និងមិនបានគ្រោងទុក។ ស្ថិរភាព ក្នុងការដឹកជញ្ជូន មានឥទ្ធិពលទៅលើអ្នកលក់ និងអ្នកទិញ និងការប្រជុំយដែលពាក់ព័ន្ធផ្សេងៗ នៃបញ្ជីសារពើកណ្តាទាំងអស់ជាមួយនឹងការមកដល់នៃព័ត៌មានបច្ចេកវិទ្យាថ្មី ដើម្បីគ្រប់គ្រងនិងឱ្យរបាយការណ៍លើផ្នែកដឹកជញ្ជូន។ អ្នកដឹកនាំកស្តុការបានចាប់ផ្តើមស្វែងរកសេវាដែលលឿនបំផុតនិងមានស្ថិរភាព។ តម្លៃពេលវេលានៃការដឹកជញ្ជូនូ គឺសំខាន់បំផុតនៅក្នុងការរៀបចំប្រព័ន្ធកស្តុការ។ ប៉ុន្តែនៅក្នុងកាលៈទេសៈខ្លះតម្លៃទាបនៃសេវាការដឹកជញ្ជូនយឺតក៏អាចចាំបាច់ ដើម្បីសម្រេចគោលដៅប្រតិបត្តិការផងដែរ។ ការស្វែងរកនិងចាត់ចែងការដឹកជញ្ជូនូចម្រុះគ្នា គឺជាការទទួលខុសត្រូវសំខាន់នៃព័កស្តុការ ។ មានទិដ្ឋភាព៣ យ៉ាងក្នុងការដឹកជញ្ជូនដែលអ្នកគ្រប់គ្រងត្រូវចងចាំទុកអំពើបណ្តាញកស្តុការនេះ ដំបូងការជ្រើសរើសបរិក្ខាដើម្បីបង្កើតបណ្តាញរចនាសម្ពន្ធ័ នៃការរៀបចំគម្រោងនៃតម្រូវការដឹកជញ្ជូន និងការកាតបន្ថយជម្រើសផ្សេងៗទៀត។ (ទី២) តម្លៃសរុបនៃការដឹកជញ្ជូនទាក់ទងនឹងតម្លៃទំនិញ។ (ទី៣) ការប្រឹងប្រែងដើម្បីបញ្ចូលការដឹកជញ្ជូនទៅក្នុងប្រព័ន្ធកស្តុការដែលអាចបរាជ័យ បើសេវា ដឹកជញ្ជូនមានយូរៗម្តង និងមានការប្រែប្រួល។

ឃ.បញ្ជីសារពើកណ្តា (Inventory)

តម្រូវការបញ្ជីសារពើកណ្តារបស់ក្រុមហ៊ុនអាស្រ័យទៅលើបណ្តាញរចនាសម្ពន្ធ័ និងកម្រិតនៃសេវាដែល អតិថិជនចង់បាន។ តាមទ្រឹស្តី ក្រុម

ហ៊ុន អាចស្តុកគ្រាប់ទំនិញ ដែលលក់នៃបរិក្ខារទៅ
ឱ្យគ្រួបអតិថិជន។ ជំនួញ មួយចំនួនតូចអាចមាន
លទ្ធភាពចំណាយលើបញ្ជីសារពើភណ្ឌទំនើប។
ព្រោះការប្រជុំយ និងការចំណាយសរុបអាចត្រូវ
ហាមឃាត់។ ចំពោះកត្តាសំខាន់ គឺត្រូវបំពេញនូវ
តម្រូវការសេវាអតិថិជន ជាមួយនឹងតម្រូវការអប្ប
បរមានៃបញ្ជីសារពើ ភណ្ឌភ្ជាប់ជាមួយនឹងតម្លៃ
សរុបទាបបំផុត។ បញ្ជីសារពើភណ្ឌដែលហួស
ប្រមាណអាចទូទាត់សម្រាប់ភាពខ្វះខាតក្នុង
មូលដ្ឋានរៀបចំនៃបណ្តាញកស្តុការ និងការ
គ្រប់គ្រងក្រោមកម្រិត។ ទោះជាយ៉ាងណាក៏
ដោយបញ្ជីសារពើភណ្ឌដែលបម្រើហួស
ប្រមាណសម្រាប់ទប់ទល់ ទីបំផុតលទ្ធផលអាច
ខ្ពស់ជាងតម្លៃកស្តុការសរុប។ យុទ្ធសាស្ត្រ កស្តុការ
គឺរៀបចំឡើង ដើម្បីទប់នឹងបញ្ជីនៃហិរញ្ញវត្ថុ
ដែលទាបបំផុត។ ចំពោះគោលដៅសំខាន់បំផុត
ក្នុងការគ្រប់គ្រងបញ្ជីសារពើភណ្ឌ គឺដើម្បី
សម្រេចឱ្យបាននូវតម្រូវការរបស់អតិថិជន។ រីឯ
ច្បាប់គ្រប់គ្រងបញ្ជី គឺផ្អែកទៅលើទិដ្ឋភាព៥
យ៉ាង(ទី១ការបម្រើដល់អតិថិជន(ទី២)
ផលិតផលតម្រូវឱ្យមានបទដ្ឋានច្បាស់លាស់(ទី
៣) ការដឹកជញ្ជូនការដឹកជញ្ជូន (ទី៤) តម្រូវការ
ពេលវេលានិង(ទី៥)ការប្រកួតប្រជែងស្មាដៃ។
ចំពោះគុណប្រយោជន៍នៃ ជំនួញរបស់អតិថិជន
គឺពឹងផ្អែកទៅលើការជាវទំនិញ ចំនួននៃការលក់
តម្លៃតម្រូវការសេវាបន្ថែម និងសកម្មភាពផ្សេង។
ដើម្បីអភិវឌ្ឍន៍ និងបង្កើតទំនាក់ទំនងដែលកំពុង
តែកើតមានឡើង។ អតិថិជនដែលផ្តល់គុណ
ប្រយោជន៍ខ្ពស់ គឺបង្កើតទីផ្សារកណ្តាលសម្រាប់
សហគ្រាស។ យុទ្ធសាស្ត្រនៃបញ្ជីសារពើភណ្ឌ
តម្រូវឱ្យមានការប្រជុំញឹកញាប់សម្រាប់អតិថិជន
ប្រភេទកណ្តាល ដែលជាគន្លឹះសម្រាប់ឱ្យប្រព័ន្ធគ័
កស្តុការមួយមានប្រសិទ្ធភាព។ សហគ្រាសភាគ
ច្រើនមានបទពិសោធន៍លើចំណុចនៃគុណ
ប្រយោជន៍ធ្ងងកាត់ខ្សែទំនិញ។ ចំពោះការប៉ាន់
ស្មាននៃគុណភាពទំនិញទាបដែលត្រូវដឹកជញ្ជូន
នោះជាគន្លឹះសម្រាប់ជៀសវាងតម្លៃហួសហេតុ។
ជាក់ស្តែងសហគ្រាស ចង់ផ្តល់ប្រយោជន៍ខ្ពស់
និងការដឹកជញ្ជូនពិតប្រាកដទៅលើទំនិញដែល
មានប្រយោជន៍ជាច្រើនទៀត។ គន្លឹះសម្រាប់
ជៀសវាង គឺគុណភាពសេវាខ្ពស់ សម្រាប់ទំនិញ
មានប្រយោជន៍ប្រើប្រាស់ដោយអតិថិជនថ្នាក់ទា
ប។ ដូចនេះគុណប្រយោជន៍ ទំនិញ ត្រូវតែគឺតគូ
នៅពេលកំពុងបង្កើតច្បាប់បញ្ជីសារពើភណ្ឌ។
សហគ្រាស ជាច្រើនឃើញថាវាគួតែចង់បានដែរ
នូវការកាន់កាប់ទំនិញដែលយឺតឬមានប្រយោ
ជន៍ទាបនៅក្នុងឃ្លាំងចែកចាយកណ្តាល។ ការ
ដឹកជញ្ជូនពិតប្រាកដអាចរួមផ្សំទៅនឹងតម្រូវការ
អតិថិជននៅពេលទំនិញកុម៉ង់ត្រូវបានទទួល។
ការឱ្យតម្លៃទៅលើការដឹកជញ្ជូនភាគច្រើន
អាស្រ័យលើទំហំ និងចំណុះនៃមធ្យោបាយដឹកទំ
និញ។ ទោះជាយ៉ាងណាវាក៏ជាយុទ្ធសាស្ត្រមួយ
ដើម្បីស្តុកទុកទំនិញក្នុងឃ្លាំង ដើម្បីរៀបចំមធ្យោ
បាយដឹកជញ្ជូន សម្រាប់អតិថិជន ឬតំបន់ភូមិសា
ស្ត្រផ្សេង។។ ការសន្សំរួម គ្នាក្នុងការដកជញ្ជូន
អាចទូទាត់តម្លៃកើនឡើងក្នុងការកាន់បញ្ជីសារពើ

កណ្តា។ ការសន្យាផ្តល់ទំនិញរហ័ស ដើម្បីបំពេញនូវតម្រូវការអតិថិជន គឺជាអ្នកបើកបរដ៏សំខាន់នៃកស្តុការ។ ការរៀបចំពេលវេលាទៀតទាត់នាំឱ្យមានការកាត់បន្ថយនូវបញ្ជីសារពើកណ្តាសរុប ដោយបង្កើតសមត្ថភាពដើម្បីឆ្លើយតបយ៉ាងលឿនទៅនឹងតម្រូវការពិតប្រាកដនៃផលិតផល ឬអតិថិជន។ ការធ្វាស់គ្នានៃការស្តុកទំនិញ និងកាន់កាប់ស្តុកដែលមានសុវត្ថិភាព គឺត្រូវតែទទួលបរិមាណពិតប្រាកដនៃបញ្ជីសារពើកណ្តាដែលពេលវេលាតម្រូវឱ្យ។ ខណៈដែលកម្មវិធីឈរលើពេលវេលាពិតប្រាកដត្រូវកាត់បន្ថយបញ្ជីសារពើកណ្តារបស់អតិថិជន ក្នុងអប្បបរមាពិតប្រាកដការសន្សំត្រូវតែថ្លឹងថ្លែងទៅនឹងតម្លៃដែលកើតឡើងនៅក្នុងកម្មវិធីឈរលើពេលវេលានៃកស្តុការ។

ទីបំផុតយុទ្ធសាស្ត្របញ្ជីសារពើកណ្តាមិនអាចបង្កើតបាន ក្នុងភាពប្រកួតប្រជែងដោយគ្មានអ្នកដឹកនាំនោះទេ។ ដូចនេះវាចាំបាច់ណាស់សម្រាប់ដាក់បញ្ជីសារពើកណ្តានៅក្នុងឃ្លាំងទំនិញជាក់លាក់មួយដើម្បីចែកចាយសេវាកស្តុការទោះជាមានការកើនឡើងនូវតម្លៃសរុបក៏ដោយ។ ច្បាប់បញ្ជីសារពើកណ្តាសំខាន់ណាស់ដើម្បីបង្កើនប្រយោជន៍សេវាសម្រាប់អតិថិជន ឬត្រូវទប់ទល់នឹងកម្លាំងដែលអ្នកប្រកួតប្រជែង។ សម្ភារៈ និងសមាសភាពរបស់បញ្ជីសារពើកណ្តាដែលបានកើតឡើងក្នុងប្រព័ន្ធកស្តុការមានហេតុផលផ្សេងៗគ្នាជាងការបញ្ចប់ផលិតផលបញ្ជីសារពើកណ្តា។ គ្រប់ប្រភេទនៃបញ្ជីសារពើកណ្តា និងកម្រិតនៃការសន្យាត្រូវបង្ហាញពីតម្លៃចំណូលសរុប។ ចំពោះការយល់ដឹងពីទំនាក់ទំនងរវាងបរិក្ខា បណ្តាញការដឹកជញ្ជូន និងការវិនិច្ឆយ័លើបញ្ជីសារពើកណ្តា គឺជា គ្រឹះមួយដើម្បីបញ្ចូលក្នុងការគ្រប់គ្រងកស្តុការ។

ង.ឃ្លាំងទំនិញ ការកាន់កាប់សម្ភារៈ និងការរៀបចំរិចខ្ចប់

មុខងារទាំង៤ របស់កស្តុការ ការរៀបចំបណ្តាញព័ត៌មាន ដឹកជញ្ជូន និងបញ្ជីសារពើកណ្តាដែលអាចរៀបចំទៅជាប្រព័ន្ធប្រតិបត្តិការផ្សេងគ្នា។ ការរៀបចំនីមួយៗត្រូវមានសក្តានុពល ដើម្បីសម្រេចបាននូវគម្រិតសេវាសម្រាប់បម្រើអតិថិជននៅក្នុងតម្លៃសរុបរួមគ្នា។ ជារួមមុខងារទាំង៤នេះ គឺត្រូវបូកបញ្ចូលគ្នា ដើម្បីបង្កើតប្រព័ន្ធសម្រាប់ដឹកនាំកស្តុការរួមគ្នា។ មុខងារចុងក្រោយនៃកស្តុការ គឺឃ្លាំងទំនិញ ការគ្រប់គ្រងសម្ភារៈ និការរៀបចំខ្ចប់ក៏បង្ហាញពីផ្នែកមួយនៃដំណោះស្រាយក្នុងការចំណាយផ្សេងៗ។ ទោះជាយ៉ាងណា មុខងារ ទាំងនេះពុំមានឯកភាជ្ឈពីមុខងារ៤ដែលបានលើកមកពិភាក្សាពីមុននោះទេ។ ឃ្លាំងទំនិញការគ្រប់គ្រងទំនិញ និងការវិរចខ្ចប់ជាចំណែកមួយនៃចំណែកមួយនៃចំណែកកស្តុការផ្សេងទៀត។

ឧទាហរណ៍ៈ ទំនិញត្រូវតែផ្ទុកនៅក្នុងឃ្លាំងដែលជាគោលការណ៍កំណត់នៃប្រព័ន្ធកស្តុការ។

មធ្យោបាយដឹកទំនិញ គឺត្រូវការគ្រប់គ្រងសម្ភារៈសម្រាប់ផ្ទុកឬបញ្ចោញទំនិញ។ ទីបំផុត

ទំនិញនីមួយៗគឺងាយស្រួលក្នុងការគ្រប់គ្រង នៅពេលបានរឹចខ្ចប់បញ្ចូលគ្នាទៅក្នុងកុងតេណ័រនៃមធ្យោបាយដឹកជញ្ជូនធំៗ នៅពេលប្រព័ន្ធកស្តុការត្រូវការឃ្លាំងទំនិញក្រុមហ៊ុនអាចជ្រើសរើសរវាងការចង់បាន សេវាអ្នកឯកទេស ឬប្រតិបត្តិបរិក្ខាខ្លួនឯង។ ការសម្រេចចិត្តជ្រើសរើសទំហំ គឺប្រសើរជាងការជ្រើសរើសបរិក្ខាដើម្បីផ្ទុកបញ្ជឹកស្តុការ ហើយសកម្មភាពចាំបាច់ជាច្រើនត្រូវបានអនុវត្តខណៈដែលទំនិញត្រូវបានបញ្ចូលក្នុងឃ្លាំង។

ឧទាហរណ៍ៈ នៃសកម្មភាពទាំងនេះបានដាក់ទៅតាមប្រភេទលំដាប់របៀបនៃការជ្រើសរើសការរួបរួមគ្នានៃការដឹកជញ្ជូន ហើយក្នុងករណីខ្លះត្រូវមានការប្រជុំកែប្រែខាងទំនិញ។ នៅក្នុងឃ្លាំងការគ្រប់គ្រងទំនិញជាសកម្មភាពសំខាន់បំផុត។ ផលិតផលត្រូវបានទទួលយកចេញ និងដាក់ទៅតាមប្រភេទ និងរៀបចំសម្រាប់តម្រូវការអតិថិជន។ ការងារពិតប្រាកដនិងដើមទុនក្នុងការគ្រប់គ្រងសម្ភារៈ គឺជាចំណុចសំខាន់មួយនៃតម្លៃកស្តុការសរុប។ នៅពេលអនុវត្តការគ្រប់គ្រងទំនិញកាន់តែតិចកម្រិតនៃការខូចខាតក៏កាន់តែតិច ហើយផ្តល់ផលល្អដល់ឃ្លាំងទំនិញកាន់តែច្រើន។ សរុបមកគ្រប់ឃ្លាំងទំនិញ និងការគ្រប់គ្រងទំនិញទាំងអស់បង្ហាញពីប្រព័ន្ធមួយនៅក្នុងប្រព័ន្ធកស្តុការទាំងមូល។ ដើម្បីជួយសម្រួលដល់ការកាន់កាប់ទំនិញ ផលិតផលដែជាប្រភេទកំប៉ុងដប ឬប្រអប់ តែងតែបញ្ចូលជាក្រុមធំមួយ។ ក្រុមនេះ Master carton ត្រូវផ្តល់នូវលក្ខណៈពិសេស ២យ៉ាង គឺ (ទី១) ការពារទំនិញកុំឱ្យខូចខាតនៅពេលកំពុងដឹកជញ្ជូន។(ទី២)ងាយស្រួលទុកដាក់ទំនិញ ដោយប្រើតែកុងតែណ័រ ធំមួយដែលកត្តានេះគឺ ជៀសវាងទំនិញរាយនៅដោយឡែកពីគ្នា។ សម្រាប់ការគ្រប់គ្រង និងដឹកជញ្ជូន Master-Cartonតែងតែបញ្ចូលជាក្រុមរឹងមាំមួយ។ សម្ភារៈ Master Carton រួមមានក្រដាសកាតុង និងហិបដាក់ឥវ៉ាន់ផ្សេងៗទៀត។ នៅពេលបញ្ចូលទៅក្នុងប្រព័ន្ធសហគ្រាសកស្តុការ ឃ្លាំងទំនិញ ការគ្រប់គ្រងទំនិញ និងការរៀបចំរឹចខ្ចប់ជួយសម្រួលដល់ល្បឿន និង ភាពងាយស្រួលទាំងអស់នៅពេលទំនិញបាន ចូលទៅក្នុងប្រព័ន្ធកស្តុការ។

៤.២.គោលការណ៍គ្រប់គ្រងហិរញ្ញវត្ថុ

ការគ្រប់គ្រងហិរញ្ញវត្ថុ គឺជាការសម្រេចរបស់ហិរញ្ញវត្ថុ ដែលត្រូវបានលើកឡើងដើម្បីធ្វើការគាំទ្រដល់ការសម្រេចចិត្តលើកិច្ចការជំនួញខាងរដ្ឋបាល។ ទង្វើទាំងអស់នេះទាក់ទងទៅនឹងប្រភព និងការប្រើប្រាស់មូលនិធិក្នុងកិច្ចការជំនួញ។ លើសពីនេះទៀតគោលដៅនៃការសម្រេចចិត្តលើកិច្ចការហិរញ្ញវត្ថុ គឺត្រូវពង្រឹងឱ្យបានជាអតិបរមាតម្លៃរបស់ក្រុមហ៊ុនសម្រាប់ឱ្យម្ចាស់ក្រុមហ៊ុន។ ចំពោះអង្គភាពពាណិជ្ជកម្មជាច្រើន តម្លៃរបស់ក្រុមហ៊ុនត្រូវបែងចែកទៅជាភាគហ៊ុនហើយតម្លៃនៃភាគហ៊ុននោះតំណាងឱ្យទ្រព្យសម្បត្តិរបស់ម្ចាស់ហ៊ុន។ រីឯអ្នកគ្រប់គ្រង ប្រព័ន្ធហិរញ្ញវត្ថុ គឺជាការរៀបចំផែនការលើការទិញ និងការប្រើប្រាស់មូលនិធិ ដើម្បីធ្វើឱ្យតម្លៃភាគហ៊ុនលើងខ្ពស់ បំផុត។ ម៉្យាងទៀតការគ្រប់គ្រងហិរញ្ញវត្ថុ គឺអាចជានាដល់ការសម្រេចចិត្តពីប្រភពផ្សេងៗ

និងការប្រើប្រាស់ មូនិធិទាំងនោះឱ្យមានប្រសិទ្ធភាព។ អ្នកគ្រប់គ្រងហិរញ្ញវត្ថុមានតួនាទីជាទូទៅ គឺរៀបចំ និងគ្រប់គ្រងរាល់ប្រតិបត្តិ ការហិរញ្ញវត្ថុរបស់ក្រុមហ៊ុនទាំងមូល។ តួនាទី និងការទទួលខុសត្រូវសំខាន់ៗមានដូចជា៖

-បង្កើតប្រព័ន្ធព័ត៌មានគណនេយ្យឱ្យមានប្រសិទ្ធភាពដើម្បីធានានូវការត្រួតពិនិត្យតាមផ្នែកឱ្យមានភាពល្អិតល្អន់ដើម្បីជៀសវាងនូវការចាយវាយខ្ជះខ្ជាយ ការគ្រប់គ្រងមិនល្អ និងជៀសវាងកំហុស និងការបន្ទំ ។

-ការគ្រប់គ្រងគណនីសាច់ប្រាក់ និងធនាគារដើម្បីធានាថា ប្រតិបត្តិការបានកត់ត្រាត្រឹមត្រូវ និងពេញលេញ ហើយត្រូវធានាមានលុយគ្រប់គ្រាន់នៅពេលដែលក្រុមហ៊ុនត្រូវការប្រើប្រាស់។

-រៀបចំរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ក្រុមហ៊ុន ហើយត្រូវធានាថាវាត្រឹមត្រូវ និងទាន់ពេលវេលា។

-ត្រួតពិនិត្យយ៉ាងប្រុងប្រយ័ត្នពីស្ថានភាពហិរញ្ញវត្ថុ បើមានបញ្ហាត្រង់ណា ត្រូវដោះស្រាយជាបន្ទាន់។

-ត្រួតពិនិត្យ និងធ្វើសវនកម្មប្រព័ន្ធផ្ទៃក្នុងដើម្បីតាមដាននីតិវិធីនៃប្រតិបត្តិការហិរញ្ញវត្ថុអង្គភាព

-រៀបចំតារាងតុល្យការព្យាករណ៍ តម្រូវការថវិកា ដោយប្រៀបធៀបសកម្មភាពជាក់ស្តែងទៅនឹងថវិកា ដែលមាន

-ផ្តល់ហិរញ្ញវត្ថុភ្លាមៗ នៅពេលដែលអ្នកគ្រប់គ្រងជាន់ខ្ពស់ត្រូវការ។

-សហការជាមួយសវនកម្មខាងក្រៅ។

ជាសក្ខីភាព ចំពោះជាសកម្មភាពពិសេសមួយចំនួនដែលមានការពាក់ព័ន្ធជាមួយនឹងការគ្រប់គ្រងហិរញ្ញវត្ថុ គឺមានដូចជា (ទី១)ព្យាករណ៍ និងការធ្វើផែនការ និងគ្រប់គ្រងហិរញ្ញវត្ថុដោយត្រូវធ្វើការទាក់ទងទៅមកជាមួយប្រធានប្រតិបត្តិផ្សេងៗទៀត ព្រោះប្រតិបត្តិការទាំងនោះបានកត់ត្រាអំពីបង្ហាញអនាគតរបស់ក្រុមហ៊ុន។ (ទី២) ការវិភាគផ្នែក សំខាន់ៗ និងការសម្រេចចិត្តផ្តល់ហិរញ្ញវត្ថុ (ទី៣) ដោយផ្អែកលើផែនការរយៈពេលវែង នាយកគ្រប់គ្រងហិរញ្ញវត្ថុត្រូវតែស្វែងរកមូលនិធិ បន្ថែមទៀត ដើម្បីបំពេញសេចក្តីត្រូវការរបស់អង្គភាព។ ចំពោះក្រុមហ៊ុនមួយទទួលបានជោគជ័យ ជាធម្មតា គឺត្រូវធ្វើឱ្យអត្រាកំណើននៃការលក់ខ្ពស់ដើម្បីឱ្យមានការរីកចម្រើន។ (ទី៤) សហប្រតិបត្តិការ និងការត្រួតពិនិត្យ ការគ្រប់គ្រងហិរញ្ញវត្ថុត្រូវមានទំនាក់ទំនង និងប្រតិបត្តិការជាមួយប្រធានប្រតិបត្តិក្នុងផ្នែកផ្សេងៗទៀតនៃអាជីវកម្មបើអង្គភាពចង់ឱ្យមានដំណើរការប្រកបដោយប្រសិទ្ធភាពតាមដែលអាចធ្វើទៅបាន។ ការសម្រេចចិត្តទាំងអស់នៃអាជីវកម្ម គឺមានការជាប់ទាក់ទងនឹងផ្នែកគ្រប់គ្រងទាំងអស់តាមរយៈហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុ ដែលត្រូវបានដាក់ក្នុងគណនី។ (ទី៥) មានទំនាក់ទំនងការទិញទៅមកជាមួយ ទីផ្សារមូលធន ដោយសម្អាងថា ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ គឺជាការគ្រប់គ្រងមូលនិធិ និងទីផ្សារមូលធនឱ្យបានស្របទៅតាមឱកាសដែលអាចមានផលចំណេញដល់អង្គ

ភាពដូចជា ត្រូវការផ្ទើរនៅក្នុងធនាគារ ដើម្បីផលចំណេញ ជាការប្រាក់មកវិញ។ យើងដឹងថា អង្គភាពនីមួយៗ មានឥទ្ធិពល និងផលប៉ះពាល់ទៅវិញទៅមកតាមរយៈទីផ្សារ ហិរញ្ញវត្ថុជាទូទៅគឺជាកន្លែងដែលមូលនិធិសញ្ញាប័ណ្ណរបស់ក្រុមហ៊ុន ក្នុងការលក់ដូរ និងក៏ជាកន្លែងវិនិយោគសញ្ញាប័ណ្ណ អាចទទួលផលចំណេញ និងខាតផងដែរ។

ក.និយមន័យសាច់ប្រាក់៖ សាច់ប្រាក់គឺជាការចំណាយដែលបានបង់ ដើម្បីផលិតចេញជាផលិតផលមួយដែលការចំណាយនោះទាក់ទងនឹងការទិញវត្ថុជាតុដើម និងកម្លាំងពលកម្ម រួមទាំងសកម្មភាពចំណាយទៅលើការទិញទ្រព្យសកម្មរបស់ក្រុមហ៊ុនផងដែរ។ សាច់ប្រាក់គឺត្រូវបានបង្កើតដោយក្រុមហ៊ុន នៅពេលដែលមានការលក់ឬ ផ្តត់ផ្តង់ទ្រព្យ សេវាមូលប័ត្រជូនអតិថិជន និងសកម្មភាពដែលទាក់ទងនឹងការប្រាក់របស់ក្រុមហ៊ុន។ ម៉្យាងទៀត សាច់ប្រាក់គឺជាប្រភេទនៃវត្ថុម៉្យាងដែលគេទទួលស្គាល់យ៉ាងទូលំទូលាយ និងជាសេចក្តីត្រូវការចំបងរបស់មនុស្សពិភពលោក ហើយប្រភេទសាច់ប្រាក់រួមមានដូចជា ក្រដាស ឬប្រាក់កាក់ មូលប្បទានប័ត្រ ប័ណ្ណបញ្ជីប្រាក់ ប័ណ្ណបញ្ជីគ្មានកាលកំណត់ប័ណ្ណបើកប្រាក់របស់ធនាគារ សាច់ប្រាក់បន្ទាប់បន្សំ មូលនិធិអាចប្តូរបាន និងប្រាក់បញ្ញើសន្សំ។

ខ.ការទទួលខុសត្រូវនៃការគ្រប់គ្រងសាច់ប្រាក់៖ ការគ្រប់គ្រងសាច់ប្រាក់មានសារសំខាន់ណាស់ហើយ វាទាក់ដោយផ្ទាល់ទៅនឹងផ្នែកប្រតិបត្តិការសេដ្ឋកិច្ច និងផ្នែកគណនេយ្យរបស់ក្រុមហ៊ុនដែលគេតម្រូវឱ្យអ្នកគ្រប់គ្រងរូបត្រូវតែយល់ដឹងឱ្យបានច្បាស់លាស់នូវទំនាក់ទំនងនោះ។ ក្នុងក្រុមហ៊ុនមួយមានបញ្ហាសេដ្ឋកិច្ចជាច្រើន ដែលតែងតែកើតមានឡើងសម្រាប់អ្នកគ្រប់គ្រងដូចជា ការវិភាគពីគ្រោះថ្នាក់ដែលអាចកើតមានឡើង ការសិក្សាទ្រឹស្តី អំពីថ្លៃអ្នកផ្គត់ផ្គង់ និងអតិថិជនព្រមទាំងបរិយាកាសសេដ្ឋកិច្ចផ្សេងៗទៀត នៅក្នុងក្រុមហ៊ុនទាំងមូលដែលបម្រុង ឬអាចនឹងកើតឡើង ហើយទាមទារឱ្យអ្នកគ្រប់គ្រងធ្វើសេចក្តីសម្រេចទៅលើផ្នែកទាំងនោះ។ ជាងនេះទៅទៀត អ្នកគ្រប់គ្រងក៏ត្រូវយកវិចិត្តទុកដាក់ផងដែរ ទៅលើរចនាសម្ព័ន្ធរបស់ស្ថាប័នអង្គការប្រព័ន្ធធនាគារ ពាណិជ្ជកម្ម និងទំនាក់ទំនងអន្តរជាតិរវាងផ្នែកផ្សេងៗទៀតនៃសេដ្ឋកិច្ច។ ការគ្រប់គ្រងសាច់ប្រាក់មិនបានល្អបណ្តាលឱ្យមានអស្ថិរភាពផ្នែកសេដ្ឋកិច្ច កើតមានអតិផរណា លើអត្រាការប្រាក់ ការវិនិយោគថយចុះទាប ការអត់ការងារធ្វើកើនឡើងជាដើម។ បញ្ហាទាំងនេះបណ្តាលឱ្យមានឱនភាពផ្នែកសេដ្ឋកិច្ចដោយសារកង្វះខាតសាច់ប្រាក់ ពីព្រោះតែការគ្រប់គ្រងសាច់ប្រាក់មិនបានល្អ។

គ.ហេតុផលចំពោះការរក្សាទុកសាច់ប្រាក់៖ ជាទូទៅពាក្យថា គ្រប់គ្រងសម្តៅទៅលើការរៀបចំផែនការ ការចាត់ចែង ការដឹកនាំ និងការត្រួតពិនិត្យ។ ចំពោះការគ្រប់គ្រងសាច់ប្រាក់ក៏ដូច្នេះដែរចំណុចសំខាន់នោះគឺត្រូវ មានការរៀបចំផែនការ និងការអនុវត្តន៍ ដោយគោលបំណង

សំខាន់ៗនៃការគ្រប់គ្រងសាច់ប្រាក់ គឺប្រើប្រាស់សាច់ប្រាក់ឱ្យមានប្រសិទ្ធភាព រាល់ការចំណាយសាច់ប្រាក់ត្រូវតែទទួលបានលទ្ធផល ល្អជាងគោលបំណងរបស់ក្រុមហ៊ុនឬអង្គភាព។ ការគ្រប់គ្រងលើការចំណាយផ្សេងៗ ដែលអាចជៀសវាងបានអ្នកគ្រប់គ្រងទាំងអស់មិនត្រូវគិតតែពីការកាត់បន្ថយចំណាយនោះទេត្រូវគឺថា តើសាច់ប្រាក់ដែលបម្រុងទុកចំណាយវាស័ក្តសមនឹងចំណូលដែលទទួលបានឬលទ្ធផលដែលត្រូវទទួលឬអត់ ព្រោះថាពេលខ្លះអ្នកគ្រប់គ្រងព្យាយាមប្រើប្រាស់នូវពេលវេលាដើម្បីរកវិធីកាត់បន្ថយចំណាយឱ្យបានកម្រិតអប្បរមា ហើយសង្ឃឹមថានឹងទទួលបានលទ្ធផលខ្ពស់។ ការការពារ និងថែរក្សាដើម្បីកុំឱ្យបាត់បង់ និងការលួចបន្ទុំ មានព្រឹត្តិការណ៍មួយចំនួនដែលអាចកើតមានឡើងតម្រូវឱ្យក្រុមហ៊ុន ឬអង្គភាពចាំបាច់ត្រូវរក្សាទុកសាច់ប្រាក់សម្រាប់ការពារ និងកាត់បន្ថយនូវហានិភ័យនៃភាពពុំអាចសងបំណុលបាន និងសម្រាប់ការចំណាយផ្សេងៗទៀតដែលលើសពីតម្រូវការរំពឹងទុក។

តាមពិតមជ្ឈមណ្ឌល ជាទូទៅពុំសូវទុកសាច់ប្រាក់ទទេ ដោយមិនប្រើប្រាស់នោះឡើយ ព្រោះវាមិនបាន ផ្តល់ប្រភពចំណូលដល់មជ្ឈមណ្ឌលឡើយ។ ប្រសិនបើគេទុកសាច់ប្រាក់នោះឡើយព្រោះវាមិនបានផ្តល់ប្រភពចំណូលជាការប្រាក់ផងដែរ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយវាមានប្រយោជន៍ក្នុងការការពារបញ្ហាផ្សេងៗ (កាត់បន្ថយការបង្វិលលុយមិនទាន់) ដែលអាចកើតមានឡើង និងការពន្យាពេលរបស់ម្ចាស់ជំនួយ។ តែប្រសិនបើ មជ្ឈមណ្ឌលមានលទ្ធភាពគ្រប់គ្រងសាច់ប្រាក់វាជាការប្រសើរណាស់ ដោយមិនបាច់តំកល់ទុកសាច់ប្រាក់វាជាការ ប្រសើរណាស់ ដោយមិនបាច់តំកល់ទុកសាច់ប្រាក់ក្នុងមជ្ឈមណ្ឌលទេ ។

ឃ.សមតុល្យប្រតិបត្តិការរបស់អង្គភាព៖ គឺជាប្រតិបត្តិការ ដែលមានការទាក់ទងនឹងតម្រូវការចំណាយ ធម្មតា។ និងសកម្មភាពនៃការប្រមូលសាច់ប្រាក់រ៉បស់អង្គភាពជីវកម្ម។ ការចំណាយសាច់ប្រាក់ទាំងនោះរួមមាន ការទូទាត់សងប្រាក់កំរៃ និងប្រាក់ខែបុគ្គលិកទូទាត់សងអ្នកផ្គត់ផ្គង់ បង់ពន្ធដារ និងបង់ភាគលាភជាដើម។ សាច់ ប្រាក់ត្រូវបានគេប្រមូលមកពីប្រតិបត្តិការលក់ទំនិញ ទូទាត់សងអ្នកផ្គត់ផ្គង់ បង់ពន្ធដារ និងបង់ភាគលាភជាដើម។ សាច់ប្រាក់ត្រូវបានគេប្រមូលមក ពីប្រតិបត្តិការទំនិញ ពីការលក់ទ្រព្យសកម្ម និងការទទួលហិរញ្ញប្បទាន។ លំហូរចូលនៃសាច់ប្រាក់ (ការប្រមូលប្រាក់) និងលំហូរចេញ (ការចំណាយ) មិនត្រូវបានគេប្រើក្នុងពេលជាមួយគ្នាទាំងអស់នោះទេហើយកម្រិតនៃការរក្សាទុកសាច់ប្រាក់នេះ គឺចាំបាច់ដើម្បីបង្ការទុកដោះស្រាយដែលកើតមានផ្សេងៗ។ ប្រសិនបើអង្គភាពរក្សាសមតុល្យសាច់ប្រាក់ឱ្យនៅតិចបំផុតនោះវានឹងអាចជួបប្រទះនូវការខ្វះខាតសាច់ប្រាក់។

ង.តម្រូវការសមតុល្យទូទាត់៖ សមតុល្យសាច់ប្រាក់ត្រូវបានគេរក្សាទុកនៅឯធនាគារពាណិជ្ជកម្មដើម្បីទូទាត់សងសម្រាប់សេវាធនា

គារ ដែលផ្តល់ដល់អង្គភាព។ តម្រូវការទាបបំផុត នៃសមតុល្យរបស់ធនាគារ ដែលផ្តល់នូវសេវាឥណទានដល់អង្គភាពដែលរក្សាទុកសាច់ប្រាក់នោះ។ សមតុល្យសាច់ប្រាក់សម្រាប់អង្គភាពភាគច្រើនអាចត្រូវបានគេគឺតថា គឺជាការកើតឡើងនៃប្រតិបត្តិការសមតុល្យទូទាត់។ ទោះបីជាយ៉ាងណាក៏ដោយវាអាចមិនត្រឹមត្រូវសម្រាប់អង្គភាពមួយ ដើម្បីបន្ថែមនៃចំនួនតម្រូវការសាច់ប្រាក់ដើម្បីពេញពាល់តម្រូវការប្រតិបត្តិការទាំងនេះទៅលើចំនួននៃសាច់ប្រាក់ ដើម្បីពេញនូវសមតុល្យសម្រាប់ទូទាត់ ដោយបង្កើតឡើងនូវគោលដៅសមតុល្យសាច់ប្រាក់មួយ។ ដូចគ្នានេះដែរសាច់ប្រាក់អាចត្រូវបានគេប្រើប្រាស់ ដើម្បីបំពេញនូវតម្រូវការទាំងពីរខាងលើ។

ច.គម្រោងថវិកាមូលនិធិ៖ គម្រោងថវិកាសាច់ប្រាក់ គឺសម្តែងឱ្យឃើញពីលំហូរចេញ និងលំហូរចូលនៃសាច់ប្រាក់ដែលបានរំពឹងទុកហើយនិងសាច់ប្រាក់នៅចុងគ្រាសម្រាប់ពេលវេលាជាក់លាក់មួយ។ អង្គភាពភាគច្រើនគួរតែបង្កើតទាំងផែនការរយៈពេលខ្លី និងរយៈពេលវែងអំពីលំហូរនៃសាច់របស់ពួកគេគម្រោងថវិការយៈពេលខ្លី ដោយត្រូវបញ្ចូលទៅក្នុងការធ្វើផែនការ និងការប្រាក់ចំណេញប្រចាំឆ្នាំ។ ម៉្យាងទៀតគម្រោងថវិកាសាច់ប្រាក់រួមមានជាមូលដ្ឋាននូវផ្នែកពីរ គឺសាច់ប្រាក់ត្រូវទទួលដែលគេបានរំពឹតទុកហើយសាច់ប្រាក់ត្រូវចំណាយដែលគេព្យាករណ៍ទុក។ ការធ្វើផែនការទៅលើលំហូរចេញ និងលំហូរចូលនៃសាច់ប្រាក់នៅអំឡុងពេលមួយអាចឱ្យដឹងពីសាច់ប្រាក់ នៅដើមគ្រា និងសាច់ប្រាក់នៅចុងគ្រា ជាពិសេសទៅទៀត វាបានបង្ហាញនូវកត្តាពីរផ្សេងទៀត ទីមួយ គឺបង្ហាញពីតម្រូវការសាច់ប្រាក់ដែលយើងត្រូវខ្ចី ទីពីរ គឺតម្រូវការទៅលើការវិនិយោគបន្ថែម។ ការធ្វើគម្រោងថវិកាសាច់ប្រាក់ វាមានទំនាក់ទំនងដោយផ្ទាល់ជាមួយការធ្វើគម្រោងថវិកាលក់ និងគណនីត្រូវនឹងការចំណាយផ្សេងៗទៀត។ គម្រោងថវិកាសាច់ប្រាក់ជួយអ្នកគ្រប់គ្រងក្នុងការរក្សាសមតុល្យសាច់ប្រាក់ក្នុងការទំនាក់ទំនងសមតុល្យមួយនោះដើម្បី តម្រូវការរបស់ពួកគេ ដែលជាជំនួយក្នុងការជៀសវាងការចំណាយសាច់ប្រាក់ខ្ជះខ្ជាយដោយមិនចាំបាច់ និងកង្វះខាតសាច់ប្រាក់ដែលកើតមាន។

ឆ.សាច់ប្រាក់លើស ឬខ្វះ ៖ សាច់ប្រាក់លើស ឬខ្វះ រួមមានការខុសប្លែងគ្នារវាងសាច់ប្រាក់ទទួលបាន សរុប និងការចំណាយប្រាក់សរុប បើខ្វះខាតកើនឡើងអង្គភាពត្រូវការមូលនិធិដែលត្រូវខ្ចីពីកំឡុងពេលមុនចូលនៃសាច់ប្រាក់ដែលបានព្យាករណ៍ដកការចំណាយជាសាច់ប្រាក់ដែលបានព្យាករណ៍ចេញ ដើម្បីធ្វើការប៉ាន់ស្មានសាច់ប្រាក់ ដែលនៅទំនេរសម្រាប់ប្រើប្រាស់ក្នុងរយៈពេលនោះ។ សមតុល្យនៃគណនីសាច់ប្រាក់អប្បរមាត្រូវតែគណនាផងដែរ ដើម្បីកំណត់រកសាច់ប្រាក់ដែលលើសពីសេចក្តីការខ្ចីទៀត ខ្វះខាតកើនឡើងអង្គភាពត្រូវការខ្ចីខាងក្រៅបន្ថែម។ បើសាច់ប្រាក់ដែលមានលើសពីសាច់ប្រាក់អប្បបរមា យើងអាចយកចំនួនដែល

លើសនោះទៅធ្វើវិនិយោគរយៈពេលខ្លីណាមួយ ដើម្បីស្វែងរកចំណេញ។

ជ.ផ្នែកហិរញ្ញប្បទាន៖ ផ្នែកនេះតែងផ្តល់នូវគណនីពិស្តារនៃប្រាក់កម្ចី និងការទូទាត់សងដែលបានគ្រង ទុកជានឹងកើតមានឡើងនៅក្នុងការបរិច្ឆេទគម្រោងថវិការ។ វាក៏រួមបញ្ចូលនូវភាពពិស្តារការទូទាត់សាច់ប្រាក់ប្រាក់នៅពេលដែលដល់កំណត់ត្រូវទូទាត់លើប្រាក់កម្ចីទាំងនោះបណ្តាលឱ្យធនាគារប្រកាន់ជំហររបស់ខ្លួនថាអង្គភាពណាដែលត្រូវការខ្ចីប្រាក់គួរតែផ្តល់នូវព័ត៌មានយ៉ាងច្បាស់លាស់ថាតើប្រាក់នោះត្រូវការចំនួនប៉ុន្មាន និងមានរយៈពេលវែង ឬខ្លី។ បញ្ហានេះវាអាចអនុញ្ញាតទាំងការធ្វើផែនការ និងជួយអះអាងថាប្រាក់ទាំងនេះនឹងមានគ្រប់គ្រាន់តាមពេលដែលត្រូវការ។ លើសពីនេះទៀត ការធ្វើផែនការយ៉ាងប្រុងប្រយ័ត្ននៃតម្រូវការសាច់ប្រាក់តាមរយៈដំណើរការធ្វើគម្រោងថវិកា ដែលជាប្រការមួយ ដើម្បីទប់ស្កាត់ នូវការជះឥទ្ធិពលអវិជ្ជមានចំពោះអង្គភាព។ បញ្ហាមួយចំនួនទៀតបណ្តាលឱ្យមានភាពសៅហ្មងដល់អង្គភាព គឺទាក់ទងទៅនឹងគណនីបេឡា។ កម្មវិធីគម្រោងដែលស៊ីគ្នាល្អតែងតែលប់បំបាត់ចោលនូវភាពមិនច្បាស់លាស់យោងទៅតាមអ្វីដែលស្ថានភាពបេឡា និងរយៈពេលមួយត្រីមាសទៅមួយឆមាស ឬមួយឆ្នាំ។

ឈ.ការសម្រេចចិត្តលើការគ្រប់គ្រង សាច់ប្រាក់៖ ការសម្រេចចិត្តលើការគ្រប់គ្រងសាច់ប្រាក់មានមូលដ្ឋាន ផ្អែកទៅលើការព្យាករណ៍លំហូរចូល និងលំហូរចេញនៃសាច់ប្រាក់ទៅអនាគត។ តាមរយៈការវិភាគទៅលើវិភ័យប័ត្រសាច់ប្រាក់ដែលត្រូវបានទូទាត់ និង វិភ័យប័ត្រត្រូវប្រមូលដែលគេរំពឹងទុកថា អ្នកគ្រប់គ្រងផ្នែកហិរញ្ញវត្ថុអាច មានលទ្ធភាពរកប្រាក់បន្ថែម ក្នុងករណីខ្វះសាច់ប្រាក់ ហើយក្នុងករណីនៅសល់ក៏អាចមានលទ្ធភាពយកទៅដាក់ក្នុងការវិនិយោគរយៈពេលខ្លីដែរ។ លំហូរចេញនៃសាច់ប្រាក់រួមមានដូចជាការទូទាត់សងការប្រាក់ដែលមានអត្រាថេរណាមួយការចំណាយបង់ពន្ធ គឺសុទ្ធតែជាប្រតិបត្តិការមានភាពច្បាស់លាស់តែចំពោះការលក់ និងការចំណាយ ផ្សេងៗទៀតពុំមានភាពច្បាស់លាស់ឡើយ។

ដោយសារតែភាពមិនច្បាស់លាស់នេះហើយ ដែលធ្វើឱ្យមានការបង្កើតឡើងនូវការគ្រប់គ្រងមួយ គឺការ គ្រប់គ្រងសាច់ប្រាក់ដ៏តឹងរឹង និងការត្រួតពិនិត្យព័ត៌មានស្តីពីសមតុល្យសាច់ប្រាក់ប្រចាំថ្ងៃទៀត។ ហើយការសម្រេចចិត្តលើការគ្រប់គ្រងសាច់ប្រាក់ គឺសម្តៅទៅលើប្រសិទ្ធភាពនៃការប្រមូលសាច់ប្រាក់ទូទាត់ការទិញបណ្តាក់ និងប្រសិទ្ធភាពនៃការបញ្ចោញសាច់ប្រាក់ទូទាត់សងវិញ។ ចំពោះការទិញបណ្តាក់កម្រិតសមរម្យណាមួយនៃសមតុល្យសាច់ប្រាក់ប្រតិបត្តិការ និងការប្រើប្រាស់សាច់ប្រាក់ដែលលើសបណ្តោះអាសន្ននោះ គឺអាចរក្សាឱ្យមានប្រសិទ្ធិភាព។ សមតុល្យសាច់ប្រាក់ច្រើនកាត់បន្ថយគ្រោះថ្នាក់នៃការខ្វះខាតសាច់ប្រាក់ ប៉ុន្តែក៏កាត់បន្ថយលទ្ធភាពនៃប្រាក់ចំណេញដែរ។ អង្គ

ភាពមួយតែងប្រកាន់យកគំនិតមួយ គឺប្រមូលប្រាក់ពីការលក់បណ្តាក់ឱ្យបានកាន់តែ ប្រសើរតែផ្ទុយទៅវិញ ចំពោះការទូទាត់សងការទិញបណ្តាកបើពន្យល់ពេលកាន់ តែយូរក៏កាន់តែប្រសើដែរ ដោយមិនបណ្តាលឱ្យប៉ះពាល់ដល់នយោបាយការទិញបណ្តាក់ឡើយ។ ដំណាក់កាលនៃការគ្រប់គ្រងសាច់ប្រាក់នេះគឺសម្តៅទៅលើការបង្កើនល្បឿននៃការប្រមូលសាច់ប្រាក់ដែលគេជំពាក់ និងការពន្យល់ពេលនៃការទូទាត់ចំពោះការទិញបណ្តាក់ ដោយហេតុថា ពេលវេលាមាសប្រាក់ដូចនេះយុទ្ធសាស្ត្រគ្រប់គ្រងសាច់ប្រាក់ដ៏ឆ្លាតវៃក៏ត្រូវយកមកប្រើប្រាស់ ដើម្បីសម្រេចឱ្យបាននូវគោលដៅមួយដ៏មានប្រសិទ្ធភាពខ្ពស់។

ញ.វិធីសាស្ត្រនៃការស្វែងរកទុន៖ ដើម្បីស្វែងយល់នូវប្រភពដែលអ្នកអាចទទួលបាននូវមូលធនដ៏ចាំបាច់សម្រាក់ការចាប់ផ្តើមដំណើរការអាជីវកម្ម ឬពង្រីកមុខរបរផ្សេងៗជាដំបូងយើងចាប់ផ្តើមសិក្សាពីប្រភេទផ្សេងគ្នានៃការស្វែងរកថវិកាថា តើត្រូវចាបផ្តើមរកវាយ៉ាងដូចម្តេច? និងអ្វីដែលត្រូវបង្កើនឡើង ដើម្បីឱ្យអ្នកទទួលបានថវិការនោះ តើយើងមានវិធីអ្វីខ្លះជាការចាំបាច់ យើងមានវិធីសាស្ត្រពីរយ៉ាងសំខាន់ៗគឺ ការស្វែងរកថវិកាពីខាងក្រៅ និងខាងក្នុង។ ការស្វែងរកថវិកាពីខាងក្រៅ គឺជាមធ្យោបាយមួយដែលងាយស្រួលជាងគេបំផុត ដើម្បីបង្កើតនូវដើមទុននោះព្រោះថាអ្នកកំពូងពឹងពាក់ទៅលើប្រតិបត្តិការរបស់ខ្លួនផ្ទាល់ដើម្បីស្វែងរកនូវថវិការដ៏ចាំបាច់។ មានន័យថា និងការស្វែងរកពីខាងក្រៅនេះ គឺគ្រាន់តេជាអ្វីដែលមិនមែនជាទុន ដែលទទួលបានពីខាងក្រៅរបស់អង្គភាព។ ចំពោះថនធានខាងក្រៅនោះរួមបញ្ចូលធនាគារ អ្នកផ្គត់ផ្គង់ក្រុមហ៊ុនហិរញ្ញវត្ថុពាណិជ្ជកម្ម និងវិនិយោគ។ នៅដែលមានការធ្វើផែនការ ដើម្បីរកថវិកាអ្នកគួរតែពិចារណាទៅលើជម្រើសខាងក្នុងមុនពេលធ្វើការស្វែងរកធនធានពីខាងក្រៅ។ វាមិនមែនគ្រាន់តែជាមធ្យោបាយដ៏សមស្របនោះទេ ប៉ុន្តែវាអាចធ្វើឱ្យអ្នកជៀសវាងបាននូវ ចំណាយទៅលើការខ្ចីទុននោះ។ ប្រសិនបើអ្នកមិនអាចបង្កើតនូវទុនដែលអ្នកត្រូវការពីប្រភពខាងក្នុងទេ ជម្រើសតែមួយគត់ដែលអ្នកគួរតែស្វែងរកនោះ គឺតាមរយៈធនធានពីប្រភពខាងក្រៅ។ បញ្ហាមួយទៀតដែលត្រូវបញ្ចូលនៅក្នុងការប្រើប្រាស់ប្រភពទុនខាងក្នុងអ្នកអាចខ្ចីទុនគេបានយ៉ាងធាប់រហ័ស ដើម្បីធ្វើការក៏ប៉ុន្តែអ្នកត្រូវមានការប្រុងប្រយ័ត្នចំពោះហានិភ័យ ដែលអាចមានរួមទាំងក្រុមហ៊ុនរបស់អ្នកផងដែរ។ នៅក្នុងការងាររកស៊ីនោះពួកគេក៏មានទំនុកចិត្តផងដែរទៅលើសមត្ថភាពគ្រប់គ្រងរបស់អ្នក នៅពេលដែលអ្នកបង្ហាញថាអ្នកយល់ពីការងារទាំងនោះហើយតើអ្នកត្រូវធ្វើដូចម្តេច ប្រសិនបើគ្មានធនធានពីខាងក្នុង? អ្នកអាចបញ្ចប់ការវិនិយោគដោយគតិតែទៅលើផ្នែកមួយនៃទ្រព្យសកម្មរបស់អ្នកដែលបានដាក់ចូលទៅក្នុងមុខជំនួញធ្វើអ្នកមានការទាក់ទាញចំពោះគេ ឬជាទូទៅការនិយាយពីគំនិតសហគ្រិន គឺប្រើប្រាស់ធនធានខាងក្នុងមុននឹងពួកគេធ្វើការស្វែង

រកប្រភពខាងក្រៅជាបទពិសោធន៍ គឺបានទទួលជោគជ័យយូរអង្វែង។

ដ.របាយការណ៍ហិរញ្ញវត្ថុ៖ របាយការណ៍ហិរញ្ញវត្ថុ គឺជារបាយការណ៍មួយដែលពិពណ៌នាអំពីស្ថានភាព ហិរញ្ញវត្ថុ សកម្មភាពហិរញ្ញវត្ថុ និងសកម្មភាពអាជីវកម្មរបស់ក្រុមហ៊ុននៅចុងកាលបរិច្ឆេទ។ របាយការណ៍ហរិញ្ញវត្ថុ សមត្ថភាពរបស់អ្នកគ្រប់គ្រង និងប្រសិទ្ធភាពអាជីវកម្មរបស់អង្គភាពព្រមទាំងស្វែងរកចំណុច ខ្លាំងនិងចំណុចខ្សោយ ដើម្បីរៀបចំយុទ្ធសាស្ត្រ សម្រាប់អនុវត្តនៅពេលខាងមុខទៀត។

- គណនេយ្យហិរញ្ញវត្ថុ៖ គណនេយ្យហិរញ្ញវត្ថុ គឺសម្តៅទៅលើព័ត៌មានដែលពណ៌នាអំពីធនធានហិរញ្ញវត្ថុ កាតព្វកិច្ច និងសកម្មភាពរបស់អង្គភាពសេដ្ឋកិច្ច។ គណនេយ្យហិរញ្ញវត្ថុផ្តល់ព័ត៌មានដល់អ្នកធ្វើសេចក្តីសម្រេចចិត្តដែលមានអតិថិជន អ្នករៀបចំផែនការអ្នកវិនិយោគ និងអ្នកផ្តល់ប្រាក់កម្ចី។ ព័ត៌មានទាំងនេះត្រូវបានគេរៀបចំឡើងដើម្បីជួយដល់អ្នកវិនិយោគ និងម្ចាស់បំណុលថា តើគួរដាក់ទុនរបស់ខ្លួនកន្លែងណាមួយ ឬក្នុងវិស័យណាមួយ? ចំណែកឯអ្នកគ្រប់គ្រង និងនិយោជិកវិញត្រូវការព័ត៌មានទាំងនេះ ដើម្បីដំណើរការ និងត្រួតពិនិត្យការធ្វើអាជីវកម្មរបស់ក្រុមហ៊ុន។

ឧទាហរណ៍៖ ពួកគេចាំបាច់ត្រូវដឹងចំនួនលុយរបស់ក្រុមហ៊ុននៅក្នុងធនាគារ នូវប្រភេទ និងបរិមាណ សន្និធិក្នុងក្រុមហ៊ុន ព្រមទាំង ចំនួនដែលជំពាក់បំណុលគេ។ ព័ត៌មានគណនេយ្យហិរញ្ញវត្ថុត្រូវបានប្រើនៅក្នុងការគណនាប្រាក់ពន្ធផងដែរ។ របាយការណ៍ហិរញ្ញវត្ថុពិពណ៌នាពីស្ថានភាពរបស់ក្រុមហ៊ុន និងព្រឹត្តិការណ៍ព្រមទាំងប្រតិបត្តិការសំខាន់ៗក្នុងរយៈពេលប្រតិបត្តិការសំខាន់ៗក្នុងរយៈពេលមួយ។ ដំណើរការនៃការរៀបចំរបាយការណ៍ ហិរញ្ញវត្ថុទាមទារឱ្យមានទូវភាពចូលរួមពីបណ្តាបុគ្គលជាច្រើនដែលស្ថិតនៅក្នុងផ្នែក និងក្រៅផ្នែកគណនេយ្យ។

ភាគច្រើននៃរបាយការណ៍ហិរញ្ញវត្ថុ គឺត្រូវបានចេញផ្សាយដោយមានភ្ជាប់នូវរបាយការណ៍សវនកម្មរបស់គណនេយ្យករសាធារណៈផងដែរ។ ការធ្វើសវនកម្ម គឺជាការត្រួតពិនិត្យ ការកត់ត្រា និងជាប្រព័ន្ធគណនេយ្យរបស់ធនាគារដោយការប្រើប្រាស់ការធ្វើតេស្តផ្សេងៗ។ វាជួយបង្កើតភាពគួរឱ្យទុកចិត្តបាននៃរបាយការណ៍ទាំងនោះ។ ធនាគារតែងតែតម្រូវឱ្យមានការត្រួតពិនិត្យទៅលើរបាយការណ៍ហិរញ្ញវត្ថុនៅពេលដែលក្រុមហ៊ុនដាក់ពាក្យស្នើសុំប្រាក់កម្ចីដែលមានចំនួនច្រើន។ ច្បាប់របស់រដ្ឋាភិបាលក៏តម្រូវឱ្យក្រុមហ៊ុនមានការធ្វើសវនកម្មទៅលើរបាយការណ៍របស់ក្រុមហ៊ុន និងលក់មូលបត្រទៅឱ្យក្រុមហ៊ុនមុន និងលក់មួយប័ត្រទៅឱ្យសាធារណៈជន។ គោលដៅរបស់សវនករ គឺសម្រេចថា តើរបាយការណ៍ទាំងនេះបានបង្ហាញពីធនាគារ និងលទ្ធផលប្រតិបត្តិការតាមរយៈការប្រើប្រាស់គោលការណ៍គណនេយ្យដែលគេទទួលស្គាល់ទូទៅដែរទេ? នៅពេលដែលការធ្វើសវនកម្មត្រូវបានបញ្ចប់គ្រានោះសវនករត្រូវរៀបចំរបាយ

ការណ៍ ដែលបង្ហាញពីយោបល់របស់អាជីពថា របាយការណ៍ហិរញ្ញវត្ថុត្រូវបានគេរៀបចំឡើងត្រឹមត្រូវដែរឬទេ?។ វាជាការបញ្ចេញមតិយោបល់ព្រោះថា សវនករប្រើប្រាស់ប៉ាន់គំរូដើម្បីត្រួតពិនិត្យលើរបាយការណ៍តែមិនត្រួតពិនិត្យមើលទៅលើគ្រប់ប្រតិបត្តិការនោះទេ។ អង្គភាពរដ្ឋាភិបាលដែលជាអង្គការត្រូវត្រួតពិនិត្យទៅលើទីផ្សារមូលបត្រ នៅសហរដ្ឋអាម៉េរិកមានការពាក់ព័ន្ធនៅក្នុងការធ្វើនិយ័តកម្មទៅលើព័ត៌មានគណនេយ្យហិរញ្ញវត្ថុរប់សក្រុមហ៊ុនដើម្បីឱ្យដឹងច្បាស់ថា ក្រុមហ៊ុនទាំងនោះគោរពទៅតាមច្បាប់មូលប័ត្រ ឬយ៉ាងណា ចំណែកឯនិយោជិកដែលធ្វើការឱ្យ ភ្នាក់ងារ និយុត្រ័កម្ម ផ្សេងៗទៀតដូចជា គណៈកម្មាការពាណិជ្ជកម្ម សហព័ន្ធតែងតែធ្វើការត្រួតពិនិត្យលើរបាយការណ៍ដែលដាក់ជូនឱ្យអង្គភាពអាជីវកម្មនានា។ ពីព្រោះពួកគេក៏ជួយដល់អង្គភាពអាជីវកម្មដើម្បីស្វែងយល់និងប្រតិបត្តិតាមច្បាប់ទាំងនោះដែរ។

និយោជិត រដ្ឋាភិបាលខ្លះទៀតធ្វើការស៊ើបអង្កេត បទល្មើសទៅនឹងច្បាប់និយ័តកម្ម។

- **គណនេយ្យគ្រប់គ្រង៖** គណនេយ្យគ្រប់គ្រង គឺមានពាក់ព័ន្ធទៅនឹងការបង្កើត និងបកស្រាយព័ត៌មានគណនេយ្យដែលមានគោលបំណងជាពិសេសក្នុងការជួយគ្រប់គ្រងក្នុងដំណើរការអាជីវកម្ម។ អ្នកគ្រប់គ្រងប្រើប្រាស់នូវព័ត៌មានទាំងនេះ ដើម្បីកំណត់គោលដៅរួមរបស់ក្រុមហ៊ុន ដោយតាមរយៈនោះគេអាចវាយតម្លៃលើការអនុវត្តន៍របស់ផ្នែក ឬបុគ្គលម្នាក់ៗដោយធ្វើការសម្រេចចិត្តរបស់ក្រុមហ៊ុនឬរបស់អ្នកប្រើប្រាស់ខាងក្នុង។ គណនេយ្យគ្រប់គ្រងផ្តល់នូវព័ត៌មានដល់អ្នកធ្វើការសម្រេចចិត្តរបស់ក្រុមហ៊ុន ឬរបស់អ្នកប្រើប្រាស់ខាងក្នុង។ របាយការណ៍របស់គណនេយ្យគ្រប់គ្រង គឺតែងតែរួមបញ្ចូលគ្នានូវព័ត៌មាន ជាច្រើននៅក្នុងគនេយ្យហិរញ្ញវត្ថុ ក៏ប៉ុន្តែគណនេយ្យគ្រប់គ្រងក៏ពយការណ៍ផងដែរនូវព័ត៌មានដែលមិនបានពយការណ៍ទៅខាងក្រៅក្រុមហ៊ុន។ ជាទូទៅព័ត៌មានទាំងនោះចែកចេញជា៣ផ្នែកគឺ៖ (ទី១)គណនេយ្យទូទៅ គឺជាការកត់ត្រាប្រតិបត្តិការទិន្នន័យ និងរៀបចំរបាយការណ៍សម្រាប់ប្រើប្រាស់ផ្ទៃក្នុង។ វាក៏រួមទាំងមានការរៀចំរបាយការណ៍ហិរញ្ញវត្ថុដែលក្រុមហ៊ុនបោះផ្សាយទៅឱ្យអ្នកប្រើប្រាស់ខាងក្រៅ។ និយោជិកនៅក្នុងក្រុមហ៊ុនផ្ទាល់ គឺជាអ្នករៀបចំតំលើងនូវប្រព័ន្ធព័ត៌មានដែលចាំបាច់ដោយមានការជួយជ្រោមជ្រែងពីអ្នកខាងក្រៅផងដែរ។ គណនេយ្យទូទៅត្រូវបានត្រួតពិនិត្យ។ មុខតំណែងទុះបញ្ចាំងឱ្យឃើញថា ព័ត៌មានគណនេយ្យត្រូវបានប្រើប្រាស់ ដើម្បីត្រួតពិនិត្យមើលឃើញសកម្មភាពរបស់ក្រុមហ៊ុននោះ។ (ទី២) គណនេយ្យថ្លៃដើម គឺជាផែនការ និងការត្រួតពិនិត្យមើលលើដំណើរការនៃការប្រមូលព័ត៌មានអំពីថ្លៃដើមដែលអ្នកគ្រប់គ្រងត្រូវការដែលអាចជួយដល់អ្នកគ្រប់គ្រងក្នុងការផ្តល់ទំនិញ ឬសេវាកម្មផ្សេងៗទៀត។

ព័ត៌មានគណនេយ្យថ្លៃដើម មានប្រយោជន៍ជាពិសេសសម្រាប់ការវាយតម្លៃទៅ

លើការយល់ដឹងដល់អកគ្រប់គ្រងម្នាក់ៗថាតើសកម្មភាពរបស់ខ្លួនមានឥទ្ធិពលយ៉ាងណាដល់ក្រុមហ៊ុនទាំងមូល។ ក្រោយពេលដែលគម្រោងបរិការត្រូវបានអនុម័តនោះវាផ្តល់នូវមូលដ្ឋានគ្រឹះសម្រាប់ការវាយតម្លៃទៅលើការអនុវត្តន៍ជាក់ស្តែង។ (ទី៣)ការប្រឹក្សាយោបល់ផ្នែកគ្រប់គ្រងបុគ្គលដែលមានចំណេះដឹងខាងផ្នែកគណនេយ្យ គឺកំពុងត្រូវបានស្វែងរកដោយក្រុមហ៊ុនជាច្រើនដែលចង់ដឹងយ៉ាងជ្រៅជ្រះទៅលើនីតិវិធីគណនេយ្យរបស់ក្រុមហ៊ុន នៅពេលដែលពួកគេធ្វើការត្រួតពិនិត្យទៅលើក្រុមហ៊ុន។

- ***ការប្រើប្រាស់ព័ត៌មានគណនេយ្យដោយអ្នកធ្វើសេចក្តីសម្រេចចិត្ត***៖ តួនាទីរបស់អ្នកធ្វើការសម្រេចចិត្តគឺសំខាន់ណាស់បើអ្នកជាអ្នកគ្រប់គ្រងអ្នកវិនិយោគ អ្នកមានអាជីពជាក់លាក់ជាម្ចាស់ក្រុមហ៊ុន ឬជាភាគីមានចំណាប់អារម្មណ៍ទៅលើអង្គភាពណាមួយក៏ដោយអ្នកធ្វើសេចក្តីសម្រេចចិត្តតែងតែប្រើប្រាស់នូវវិធីសាស្ត្រជាច្រើនដើម្បីជ្រើសរើសយកដំណោះស្រាយដ៏ល្អណាមួយនៅក្នុងចំណោមដំណោះស្រាយដ៏ច្រើនដើម្បីដោះស្រាយបញ្ហាដែលគេកំពុងតែជួបប្រទះ។ ការជ្រើសរើសយកនូវជម្រើសដ៏ប្រសើ គឺជាមូលដ្ឋានគ្រឹះនៃការសម្រេចចិត្តរបស់អ្នកសម្រេចចិត្តដែលតែងតែមានការខ្វាយខ្វល់ពីបញ្ហាអនាគតកាល ព្រោះការសម្រេចចិត្តណាមួយពុំអាចកែប្រែអតីតកាលបានឡើយ។ ប៉ុន្តែអ្នកធ្វើសេចក្តីសម្រេចចិត្តដ៏ល្អម្នាក់ពុំអាចបដិសេធចោលមិនពិចារណាពីព្រឹត្តិការណ៍ និងលទ្ធផលរបស់វាកាលពីអតីតកាលបានឡើយ។ ការយល់ដឹង និងការបកស្រាយពីអ្វីដែលបានកើតឡើងពីអតីតកាលអាចជួយដល់យើងបានក្នុងការសម្រេចចិត្ត ព្រោះថា ប្រវត្តិសាស្ត្រ គឺជាពន្លឺដែលឆ្លុះបញ្ចាំងបង្ហាញឱ្យឃើញពីអ្វីដែលអាចកើតឡើងនាពេលអនាគតបាន។ ដូច្នេះមូលដ្ឋានគ្រឹះនៃការធ្វើសេចក្តីសម្រេចចិត្ត គឺទិន្នន័យជាប្រវត្តិដែលទាក់ទងនឹងអ្វីអាចទុកចិត្តបាន។ ភាគច្រើននៃទិន្នន័យជាប្រវត្តិ ដែលមានការទាក់ទងទៅនឹងអាជីវកម្ម ដែលត្រូវបានបង្ហាញក្នុងទម្រង់អាជីវកម្មដែលរួមមានដូចជាថ្លៃដើម ចំណូល ទ្រព្យសម្បត្តិ បំណុល និងមូលធនជាដើម។ ដូចនេះគណនេយ្យករផ្តល់ព័ត៌មានដ៏ចាំបាច់សម្រាប់ធ្វើការសម្រេចចិត្តទទួលស្គាល់មួយ។

ចំណែករបាយការណ៍ជួលដល់អ្នកប្រើប្រាស់ទាំងឡាយតាមរបៀបបីយ៉ាងគឺ៖ ទី១, គណនេយ្យផ្តល់ព័ត៌មានដែលមានសារៈប្រយោជន៍ទោះបីជាអ្នកប្រើប្រាស់ជាមនុស្សប្រភេទណាក៏ដោយការសម្រេចចិត្តដ៏សំខាន់ គឺផ្អែកលើការពិចារណាទៅលើផ្នែកហិរញ្ញវត្ថុដ៏ស្មុគស្មាញជាច្រើន។ គណនេយ្យផ្តល់មូលដ្ឋានគ្រឹះនៃព័ត៌មានដ៏សំខាន់និងការវិភាគដែលអាចជួយអ្នកបានក្នុងការធ្វើការសម្រេចចិត្តវាយតម្លៃលើអ្វីដែលមានពាក់ព័ន្ធផ្នែកហិរញ្ញវត្ថុទាំងពេលបច្ចុប្បន្ននិងពេលអនាគតនឹងលទ្ធផលដែលកើតមាននៃជម្រើសផ្សេងៗដែលគេពិចារណា។ ទី២គឺគណនេយ្យករពីផលប៉ះពាល់ទៅលើអង្គភាពផ្នែកសេដ្ឋកិច្ចហិរញ្ញវត្ថុសំខាន់ៗនឹងត្រូវកើតឡើងដែលវាចា

កត្តាសំខាន់ដែលកំណត់នូវភាពជោគជ័យរបស់អង្គភាព។ ការវិវត្តន៍នៃផលប៉ះពាល់នេះនិងត្រូវរាស់វែងជាបន្តបន្ទាប់ហើយត្រូវរាយការណ៍ជាប្រចាំដើម្បីឱ្យអ្នកធ្វើសេចក្តីសម្រេចចិត្តដឹងនូវបញ្ហា ដែលកំពុងវិវត្តនៅក្នុងកំឡុងពេលមួយ។

គណនេយ្យផ្តល់ព័ត៌មានមកឱ្យយើងវិញស្តីពីផលប៉ះពាល់សេដ្ឋកិច្ច ដែលកើតមានឡើងពីការសម្រេចចិត្តណាមួយ ដែលជាលទ្ធផលត្រូវបានគេផ្សាយភ្ជាប់ទំនាក់ទំនងទៅនឹងអ្នកសម្រេចចិត្តតាមរយៈរបាយការណ៍ហិរញ្ញវត្ថុ។ ទី៣ គឺគណនេយ្យការរក្សាការចងចាំនូវគណនីជាច្រើនដើម្បីឆ្លើយតបទៅនឹងការទទួលខុសត្រូវរបស់អង្គភាពទាំងមូលទៅលើកិច្ចការពារនិងថែរក្សាគណនីទាំងនោះដែលរួមមានតើមានប្រាក់ ដែលអាចប្រើប្រាស់បានចំនួនប៉ុន្មានមានអតីថិជនចំនួនប៉ុន្មានដែលប៉ះពាល់ក្រុមហ៊ុន តើក្រុមហ៊ុនជំពាក់បំណុលគេអ្វីខ្លះ តើក្រុមហ៊ុនមនាទ្រព្យសម្បត្តិអ្វីខ្លះដូចជាគ្រឿងម៉ាស៊ីនសម្ភារៈនិង សន្និធិជាដើម។

- គោលបំណងរបស់របាយការណ៍ហិរញ្ញវត្ថុ: *របាយការណ៍ហិរញ្ញវត្ថុ គឺជាប្រភពព័ត៌មានសំខាន់ណាស់ពីអ្វីៗដែលជាភាពពិតរបស់ក្រុមហ៊ុនទាំងអស់នោះទេ ប៉ុន្តែជាព័ត៌មានដ៏មានសារៈសំខាន់សម្រាប់អ្នកប្រើប្រាស់ទាំងឡាយ សម្រាប់ដឹងពីសកម្មភាពរួមដែលវាមានសារៈសំខាន់សម្រាប់អ្នកប្រើប្រាស់ទាំងឡាយ។ របាយការណ៍ហិរញ្ញវត្ថុមាន៤ចំណុចដែលត្រូវបានប្រើប្រាស់ដើម្បីបង្ហាញពីព័ត៌មានគណនេយ្យរបស់ក្រុមហ៊ុន គឺរបាយការណ៍លទ្ធផលតារាងតុល្យការលំហូរ សាច់ប្រាក់ និងរបាយការណ៍ដើមទុន។*

គន្ថនិទ្ទេស

១. ឯកសារជាភាសាខ្មែរ

1. *ហ៊ីង ចូវ៉ាក់សុី «ការអភិវឌ្ឍន៍វិស័យវិនិយោគកម្ពុជា: គោលនយោបាយ និងការអនុវត្តន៍» ភ្នំពេញ ២០០២*
2. *សុក ហាច និង Sarthi Acharya «របាយការណ៍ស្តីពីសេដ្ឋកិច្ចកម្ពុជា (លេខ ០២)» ភ្នំពេញ ២០០២*
3. *ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា «ឈានឡើងទៅមុខក្នុងការស្តារ និងអភិវឌ្ឍន៍កម្ពុជាតាមទស្សនវិស័យរយៈពេលវែង» ភ្នំពេញ ១៩៩៨ - ១២៧ ទំព័រ*
4. *ក្រសួងផែនការ «ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមកិច្ច ៥ ឆ្នាំលើកទី២ (២០០១-២០០៥)»*
5. *ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ «ព្រឹត្តិប័ត្រស្ថិតិប្រចាំខែ» ឆ្នាំទី ៧ លេខ ៨០ ខែ សីហា ២០០២*
6. *ក្រសួងផែនការ «ផែនការវិនិយោគអាហារូបត្ថម្ភកម្ពុជា ២០០៣-២០០៧» ភ្នំពេញ ២០០២*

7. *ក្រសួងពាណិជ្ជកម្ម «កម្ពុជា៖ ការសិក្សាពីសមាហរណ៍កម្ម និងការប្រកួតប្រជែង» ភ្នំពេញ ២០០២*
8. *រាជរដ្ឋាភិបាលកម្ពុជា «ច្បាប់វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា» ភ្នំពេញ ១៩៩៤*
9. *ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សឆ្នាំ២០១៣."ចំនួន និងទីតាំង នៃមេធាវីជំនួយផ្នែកច្បាប់នៅកម្ពុជា." ចូលអាននៅថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៥*
10. *រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា. អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងយុត្តិធម៌." ចូលអាននៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៥។*

២. ឯកសារគោលបរទេស

1. UN ESCAP. Promotion of Investment in Tourism Infrastructure, New York, 2001, 99 pages.
2. UNs. Opportunities and Challenges for Tourism Investment: A case study of the Republic of Korea and reports from selected countries in Asia and the Pacific, New York, 2001, 236 p.
3. ASEAN Tourism Investment Guide, (1998), 233pages.
4. FIAS (Foreign Investment Advisory Service) 2000, Cambodia, Reform of the System of Investment Incentives, Volume I- A Review of Cambodia's Competitive Position, FIAS
5. 2001a, Cambodia, Drafting Guideline for Amendments to the Law on Investment and Associated Legislation by Purpose, FIAS.
6. 2001b, An analysis of the Impact of Various Proposals to Reform the Provisions of Duty Exemptions to Approved Investors, Aide Memories, FIAS.
7. IBC (International Business Club) 2001, Report to the Royal Government: A Private Sector Analysis of the Proposed Changes to the Investment Law and Recommendations for Revenue Enhancements, Submission to the Royal Government of Cambodia.
8. IMF (International Monetary Fun) 2001, Cambodia, Improving the Structure and the Performance of the Tax System and its Tax Administration, Confidential Report, Fiscal Affair Department, IMF
9. World Bank/MIGA, Understanding Foreign Direct Investment, Investment Promotion Toolkit, Module 1, Washington D.C. World Bank, January 2001,
10. Yasheng Huang, Foreign Direct Investment in China, Singapore, Institute of Southeast Asia studies, 1998,
11. World Bank, World Investment Report: Promoting Linkages, New York and Geneva, United Nations, 2001, p.275-276.
12. ADB, Growth and Challenge in Asia and the Pacific: Key Indicators of Developing Asian and Pacific Countries, Volume XXXII, by Oxford University Press, 2001,
13. World Bank, World Investment Report: Promoting Linkages, op. cit., p. 275-276.

ប្រព័ន្ធចំណាត់ថ្នាក់វិទ្យាប៊្លូម

Bloom's Taxonomy

ដោយ៖ លោក **ហាយ សារី**,លោកបណ្ឌិត **សូ សុធីរ៖** លោក **លី តុង**
,លោកស្រី **ឃាង ធានី** នាយកដ្ឋានវិទ្យាសាស្ត្រអប់រំ.វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម.ពាជបណ្ឌិត្យសភាកម្ពុជា

សាវតារ

ចំណាត់ថ្នាក់វិទ្យារបស់ប៊្លូម ជាសំណុំនៃគំរូហានានុក្រមបី ដែលត្រូវបានប្រើ ដើម្បីចាត់ថ្នាក់គោលបំណងនៃការអប់រំនៅក្នុងកម្រិតនៃភាពពេញលេញ និងជាក់លាក់។ ហានានុក្រមទាំងបីនេះ គ្របដណ្តប់លើវត្ថុបំណងនៃការរៀនសូត្រនៅក្នុងវិស័យពុទ្ធិ វិស័យសញ្ចេតនា និងវិស័យចិត្តចលនា។ ហានានុក្រមវិស័យពុទ្ធិ ជាការផ្តោតជាចម្បងនៃការអប់រំបែបប្រពៃណីភាគច្រើន ហើយត្រូវបានប្រើជាញឹកញាប់ ដើម្បីរៀបចំវចនាសម្ព័ន្ធវត្ថុបំណងសិក្សាតាមកម្មវិធីសិក្សាការវាយតម្លៃ និងសកម្មភាពសិក្សា។

គំរូទាំងនោះ ត្រូវបានគេដាក់ឈ្មោះតាមបេនចាមីន ប៊្លូម(Bloom)ដែលជាប្រធានគណៈកម្មាធិការអ្នកអប់រំ និងដែលបានបង្កើតចំណាត់ថ្នាក់វិទ្យានេះ។ គាត់ក៏បានកែសម្រួលកម្រិតស្តង់ដាដំបូងនៃអត្ថបទចំណាត់ថ្នាក់វិទ្យានៃវត្ថុបំណងអប់រំ៖ ការធ្វើចំណាត់ថ្នាក់នៃវត្ថុបំណងអប់រំ។

ថ្វីបើការដាក់ឈ្មោះតាមប៊្លូមក៏ដោយ ការបោះពុម្ពសៀវភៅចំណាត់វិទ្យានៃវត្ថុបំណងអប់រំ បានធ្វើតាមសន្និសីទជាបន្តបន្ទាប់ពីឆ្នាំ ១៩៤៩ ដល់ ១៩៥៣ ដែលត្រូវបានរចនាឡើង ដើម្បីធ្វើឱ្យប្រសើរនូវទំនាក់ទំនងរវាងអ្នកអប់រំ អំពីការរចនាកម្មវិធីសិក្សា និងការប្រឡង។

នៅឆ្នាំ ១៩៥៦ សៀវភៅទី ១៖ វិស័យពុទ្ធិ ត្រូវបានបោះពុម្ពផ្សាយ។

នៅឆ្នាំ ១៩៦៤ សៀវភៅទី ២៖ វិស័យសញ្ចេតនា ត្រូវបានបោះពុម្ព។

ចំណែកវិស័យចិត្តចលនាចម្បងចំនួនបួនត្រូវបានបង្កើតឡើងដោយ RH Dave (១៩៦៧),EJ Simpson(១៩៧២),AJ Harrow (១៩៧២)និងARomiszowski។ វិស័យចិត្តចលនារបស់Daveជាវិស័យដ៏សាមញ្ញបំផុត និងងាយស្រួលក្នុងការអនុវត្តនៅក្នុងបរិស្ថានរួម។

ចំណាត់ថ្នាក់វិទ្យារបស់ប៊្លូម មានបីគឺ វិស័យពុទ្ធិ វិស័យចិត្តចលនា និងវិស័យសញ្ចេតនា។ កំណែប្រែថ្មីនៃចំណាត់ថ្នាក់វិទ្យាសម្រាប់វិស័យពុទ្ធិ ត្រូវបានបង្កើតឡើងក្នុងឆ្នាំ ២០០១។

១. វិស័យពុទ្ធិ

ចំណាត់ថ្នាក់វិទ្យាបែបចាស់



១.១-ចំណេះដឹង (Knowledge)

ចំណេះដឹង ពាក់ព័ន្ធនឹងការស្គាល់ ឬចងចាំការពិត ពាក្យសព្ទ បញ្ញត្តិមូលដ្ឋាន ឬចម្លើយដោយមិនចាំបាច់យល់ពីអត្ថន័យរបស់វា។

លក្ខណៈរបស់វារួមមាន៖ ចំណេះដឹងជាក់លាក់៖ វាក្យសព្ទវិទ្យា អង្គហេតុជាក់លាក់។ ចំណេះដឹងអំពីវិធី និងមធ្យោបាយនៃការដោះស្រាយជាក់លាក់៖ អនុសញ្ញានិន្នាការ និងលំដាប់ចំណាត់ថ្នាក់និងប្រភេទ។ ចំណេះដឹងអំពីសាកលភាវូបនីយកម្មនិងអរូបីក្នុងវិស័យមួយ៖ គោលការណ៍ និងទូទៅនីយកម្ម ទ្រឹស្តី និងរចនាសម្ព័ន្ធ។

ឧទាហរណ៍៖ ចូររាប់ឈ្មោះប្រាសាទបុរាណឱ្យបានបី។

១.២-ការយល់ដឹង

(Comprehension)

ការយល់ដឹង រួមបញ្ចូលការបង្ហាញការយល់ដឹងអំពីការពិត និងគំនិតដោយការរៀបចំសង្ខេបបកប្រែទូទៅផ្តល់ការពិពណ៌នា និងបញ្ជាក់ពីគំនិតសំខាន់ៗ។

ឧទាហរណ៍៖ចូរសង្ខេបអំពីលក្ខណៈសម្គាល់ប្រាសាទក្នុងរចនាបថក្នុងដា។

វិស័យពុទ្ធិបែបចាស់ ចែកជា៖

១.៣-ការអនុវត្ត (Application)

ការអនុវត្ត ពាក់ព័ន្ធនឹងការប្រើប្រាស់ចំណេះដឹង ដែលទទួលបានដោះស្រាយបញ្ហានៅក្នុងស្ថានភាពថ្មីដោយអនុវត្តចំណេះដឹងបច្ចេកទេស និងច្បាប់ដែលទទួលបាន។ អ្នកសិក្សាគួរតែអាចប្រើចំណេះដឹងជាមុនដើម្បីដោះស្រាយបញ្ហាកំណត់ទំនាក់ទំនងនិងរបៀបដែលពួកគេ អនុវត្តក្នុងស្ថានភាពថ្មី។ ឧទាហរណ៍៖ តើគេអាចប្រើប្រាស់វិធីណាខ្លះ ដើម្បីការពារប្រាសាទឬបុរាណឱ្យនៅគង់វង្សយូរអង្វែង?

១.៤-ការវិភាគ (Analysis)

ការវិភាគពាក់ព័ន្ធនឹងការពិនិត្យ និងបំបែកព័ត៌មានទៅជាផ្នែកសមាសធាតុកំណត់ពីរបៀបដែលផ្នែកទាក់ទងគ្នា ទៅវិញទៅមក កំណត់អត្តសញ្ញាណមូលហេតុឬមូលហេតុការសន្និដ្ឋាននិងការស្វែងរកកស្តុតាងដើម្បីគាំទ្រដល់ការធ្វើទូទៅនីយកម្ម។ លក្ខណៈរបស់វារួមមាន៖

- ការវិភាគលើជាតុ
- ការវិភាគទំនាក់ទំនង
- ការវិភាគអំពីអង្គការ

ឧទាហរណ៍៖ ប្រៀបធៀបប្រាសាទខ្មែរក្នុងរចនាបថអង្គរវត្ត និងរចនាបថបាយ័ន។

១.៥-សំយោគ (Synthesis)

សំយោគ ពាក់ព័ន្ធនឹងការបង្កើតរចនាសម្ព័ន្ធ ឬលំនាំពីជាតុចម្រុះ។ វាក៏សំដៅទៅលើ

ទង្វើនៃការដាក់ផ្នែករួមគ្នា ដើម្បីបង្កើតទាំងមូល។ លក្ខណៈរបស់វារួមមាន៖

ការផលិតទំនាក់ទំនងតែមួយគត់ការផលិតផែនការ ឬសំណុំប្រតិបត្តិការដែលបានស្នើ ឧទាហរណ៍: ចូររៀបរាប់ពីជាតុ

១.៦-ទ្វាយតម្លៃ (Evaluation ឬផ្នែកផ្សេងៗដើម្បីសាងសង់បានទូវប្រាសាទ នៅសម័យចេនឡា។)

វង្វាយយតម្លៃ រួមមានការបង្ហាញ និងការពារមតិដោយផ្ទើការវិនិច្ឆ័យអំពីព័ត៌មានសុពលភាពនៃគំនិតឬគុណភាពការងារដោយផ្អែកលើលក្ខណៈវិនិច្ឆ័យ។ លក្ខណៈរបស់វារួមមាន៖

-ការវិនិច្ឆ័យទាក់ទងនឹងកស្តុតាងផ្ទៃក្នុង

-ការវិនិច្ឆ័យតាមលក្ខណៈវិនិច្ឆ័យខាក្រៅ ឧទាហរណ៍ តើប្រាសាទបុរាណខ្មែរមានគុណតម្លៃជាប្រវត្តិសាស្ត្រយ៉ាងដូចម្តេចខ្លះ?

ចំណាត់ថ្នាក់វិទ្យាបែបថ្មី

កំណែប្រែថ្មីនៃចំណាត់វិទ្យាសម្រាប់វិស័យពុទ្ធិត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០០១។



រូបភាពទី១៖ ការកែសម្រួលខ្លឹមសារនៅឆ្នាំ២០០១(ប្រភព៖ Google Images)

ការកែសម្រួលខាងលើនេះ បង្ហាញថា ការផ្លាស់ប្តូរការប្រើពាក្យក្នុងឋានានុក្រមនេះពីពាក្យនាម មកជា កិរិយាសព្ទសម្មភាព មិនមែននាម ឬកិរិយាសព្ទសភាពដូចពីមុនទេ។

ម្យ៉ាងវិញទៀត គេបានលុបចោលកម្រិតសំយោគទី៥ចោល ទម្លាក់ការវាយតម្លៃនៅកម្រិតទី៦ មកកម្រិតទី៥ និងបន្ថែមកម្រិតទី៦ ជាកម្រិតបង្កើត ឬច្នៃប្រឌិត។



រូបភាពទី២៖ ការកែសម្រួលខ្វឹមសារ នៅឆ្នាំ២០០១ និងនិយមន័យនៃកម្រិតនីមួយៗ

(ប្រភព៖ Google Images)

ចំណាត់ថ្នាក់វិទ្យាឫម បានជ្រាបចូលទៅក្នុងការធ្វើផែនការបង្រៀន និងការបង្រៀនអស់រយៈពេលជិត៥០ឆ្នាំ មុនពេលវាត្រូវបានកែសម្រួលនៅក្នុងឆ្នាំ២០០១។ ទោះបីជាមានការកែប្រែសំខាន់ទាំងនេះ ត្រូវបានបោះពុម្ពផ្សាយក្នុងឆ្នាំ២០០១ក៏ដោយ ក៏គួរឱ្យភ្ញាក់ផ្អើលដែរ ដែលនៅតែមានអ្នកអប់រំដែលមិនធ្លាប់ឮពី Anderson and Krathwohl *ឬការងារសំខាន់របស់ពួកគេ ទាក់ទងនឹងចំណាត់ថ្នាក់វិទ្យាឫមខាងពុទ្ធិ។ អ្នកនិពន្ធបឋមទាំងពីរនេះស្ថិតក្នុងទីតាំងល្អឥតខ្ចោះ ដើម្បីរៀបចំចំណាត់ថ្នាក់វិទ្យាយ៉ាងសំខាន់។ ពួកគេបានហៅក្រុមចិត្តវិទូអប់រំ និងអ្នកអប់រំ ដើម្បីជួយពួកគេក្នុងការកែប្រែ។* Lorin Anderson *ធ្លាប់ជានិស្សិតម្នាក់របស់* Benjamin Bloom *ដ៏ល្បីល្បាញហើយ* David Krathwohl *ជាដៃគូម្នាក់របស់ប៊ូមដូចដែលគាត់បានបង្កើតចំណាត់ថ្នាក់វិទ្យាពុទ្ធិបែបបុរាណរបស់គាត់។*

នៅសហរដ្ឋអាម៉េរិក ចាប់ពីចុងទសវត្សឆ្នាំ១៩៥០ ដល់ដើមទសវត្សឆ្នាំ១៩៧០ មានការប៉ុនប៉ងបំបែក និងចាត់ថ្នាក់វិស័យផ្សេងៗគ្នានៃការរៀនសូត្ររបស់មនុស្ស៖ ពុទ្ធិ (ការចេះដឹង)សញ្ចេតនា(ចិត្តរំកើបអារម្មណ៍)និងចិត្តចលនា(ការអនុវត្តឬចលនារាងកាយកាយវិញ្ញាណការប៉ះឬដៃ/រាងកាយ)។ កិច្ចខិតខំប្រឹងប្រែងនេះ ទទួលបានលទ្ធផលជាសេរីនៃចំណាត់ថ្នាក់វិទ្យា សម្រាប់វិស័យនីមួយៗ។ ចំណាត់ថ្នាក់វិទ្យា ដែលបានរៀបរាប់ខាងលើ ទាក់ទងនឹងទិដ្ឋភាពផ្សេងៗគ្នានៃការរៀនសូត្ររបស់មនុស្ស ហើយត្រូវបានរៀបចំឡើង តាមឋានានុក្រមដែលមានការនាំមុខពីមុខងារសាមញ្ញបំផុត ទៅមុខងារដែលស្មុគស្មាញជាង។ ចំណាត់ថ្នាក់វិទ្យាពុទ្ធិរបស់

Bloom ជាមូលដ្ឋានគ្រឹះនៃការបណ្តុះបណ្តាលគ្រូ និងការរៀបចំវិជ្ជាជីវៈសម្រាប់ជិត៤០ឆ្នាំមុនពេលដែល Anderson និង Krathwohl បានបង្កើតកំណែថ្មីៗ ទិដ្ឋភាពទូទៅនៃការផ្លាស់ប្តូរទាំងនោះ បង្ហាញនៅខាងក្រោម។

ខណៈពេលដែលចំណាត់ថ្នាក់វិទ្យាទាំងអស់ខាងលើ ត្រូវបានកំណត់ និងប្រើប្រាស់អស់ជាច្រើនឆ្នាំមកហើយ នៅនាដើមសតវត្សទី២១ នៅក្នុងកំណែថ្មីនៃចំណាត់ថ្នាក់វិទ្យាពុទ្ធិ ដែលគេស្គាល់ជាទូទៅថាជាចំណាត់ថ្នាក់វិទ្យារបស់ Bloom។ គេក៏អាចស្វែងរកគេហទំព័រ សម្រាប់ឯកសារយោងផ្សេងៗគ្នាទូវចំណាត់ថ្នាក់វិទ្យាពីរផ្សេងទៀត គឺសញ្ចេតនា និងចិត្តចលករ។ មានការពិភាក្សាដ៏មានតម្លៃជាច្រើន ពីការអភិវឌ្ឍហានានុក្រមទាំងអស់ ព្រមទាំងឧទាហរណ៍នៃអត្ថប្រយោជន៍ និងកម្មវិធី នៅក្នុងការបង្រៀន។ ទោះយ៉ាងណាក៏ដោយ វាជាការសំខាន់ក្នុងការកត់សម្គាល់ថា នៅក្នុងការពិភាក្សាមួយចំនួននេះ អ្នកនិពន្ធគេហទំព័រខ្លះ បានបកស្រាយខុសនូវដែនប៉ះពាល់និងចិត្តសាស្ត្រជាផ្នែកបន្ថែមនៃការងាររបស់Bloom។ អ្នកនិពន្ធទាំងនេះ មានកំហុសធ្ងន់ធ្ងរ។ វិស័យពុទ្ធិដំបូង ត្រូវបានពិពណ៌នា ហើយត្រូវបានបោះពុម្ពផ្សាយនៅឆ្នាំ១៩៥៦។ David Krathwohl ជាអ្នកនិពន្ធម្នាក់នៅក្នុងចំណោមអ្នកនិពន្ធដើម ស្តីអំពីចំណាត់ថ្នាក់វិទ្យានេះ។ ការងារនេះ ត្រូវបានដាក់ឈ្មោះតាមអ្នកនិពន្ធជាន់ខ្ពស់ ឬអ្នកនិពន្ធទីមួយB. Bloom។ វិស័យសញ្ចេតនា មិនត្រូវបានចាត់ថ្នាក់រហូតដល់ឆ្នាំ១៩៦៤ ហើយដោយសារលោក David Krathwohl ជាអ្នកនិពន្ធឈានមុខគេក្នុងការខិតខំនេះ គួរតែមានឈ្មោះរបស់គាត់មិនមែនឈ្មោះ Bloom ទេ។ Bloom មិនបានធ្វើអ្វីមួយជាមួយវិស័យចិត្តចលករទេ និងវាមិនត្រូវបានពិពណ៌នា ឬដាក់ឈ្មោះទេរហូតដល់ដើមទសវត្សឆ្នាំ ១៩៧០។ មានកំណែ៣នៃចំណាត់ថ្នាក់វិទ្យា ដោយអ្នកនិពន្ធ៣ផ្សេងគ្នាគឺHarrow(១៩៧២)Simpson (១៩៧២) និង Dave (១៩៧០)។

វិស័យពុទ្ធិបែបថ្មីចែកជា៖

១-ចងចាំ (Remember)

រំលឹកឡើងវិញនូវចំណេះដឹង ពាក់ព័ន្ធទៅនឹងលំនឹកវែង ដែលគេបានរៀន ឬជួបប្រទះពីពេលមុន។ កិរិយាសព្ទដែលត្រូវប្រើមានដូចជាឱ្យអត្ថន័យពិពណ៌នាកំណត់អត្តសញ្ញាណដាក់ស្លាកសម្គាល់ រាយនាម ផ្គូផ្គងដាក់ឈ្មោះ ផ្តល់នូវចំណុចសំខាន់ៗរំលឹកស្គាល់ ចម្ងល់តាមជ្រើសរើសបញ្ជាក់កំណត់ទីតាំង...។

ឧទាហរណ៍៖ ចូរពិពណ៌នាផ្សារទំនើបមួយដែលប្លន់ ទើបបានទស្សនាកាលពីសប្តាហ៍មុន។

២-យល់ (Understand)

បង្កើតន័យពីខ្លឹមសាររៀន ឬបង្រៀន រួមបញ្ចូលទាំងទំនាក់ទំនងផ្ទាល់មាត់ការសរសេរ និងក្រាហ្វិក។

កិរិយាសព្ទដែលត្រូវប្រើ មានដូចជាពន្យល់ ការពារ ប្រៀបធៀប ប៉ាន់ប្រមាណ ធ្វើចំណាត់ថ្នាក់ ធ្វើទូទៅនីយកម្ម បកស្រាយ ព្យាករ សរសេរឡើងវិញ សង្ខេបបកប្រែ...។

ឧទាហរណ៍៖ ចូរប្រៀបធៀបតួអង្គនាងវិជាវី និងឃុន នារី។

៣-អនុវត្ត (Apply)

អនុវត្ត ឬប្រើប្រាស់នីតិវិធី ក្នុងស្ថានភាពដែលបានផ្តល់ឱ្យ។ កិរិយាសព្ទដែលត្រូវប្រើ មានដូចជា អនុវត្តរៀបចំ ចាត់ចែងសម្តែង ធ្វើវិនាដកម្ម ដោះស្រាយស្ថាបនា បង្ហាញធ្វើ ឱ្យមើលរកឃើញ កែកុន កែតម្រូវ ប្រតិបត្តិ ព្យាករ រៀបចំត្រៀមបម្រុងផលិត/បង្កើត ភ្ជាប់ទំនាក់ទំនង/ផ្សារភ្ជាប់ បង្ហាញ ដាក់តាំង ជ្រើសរើស

ឧទាហរណ៍៖ ចូរអនុវត្តឬប្រតិបត្តិ ច្បាប់នៃស្តិតិ ដើម្បីវាយតម្លៃភាពគួរទុកចិត្ត បាននៃតេស្តសំណេរ។

៤-វិភាគ (Analyze)

បែងចែកចំណេះដឹងទៅតាមផ្នែក ហើយកំណត់ពីទំនាក់ទំនងរវាងគ្នាទៅវិញទៅមក និងចំពោះរចនាសម្ព័ន្ធ ឬគោលបំណងជារួម។ កិរិយាសព្ទដែលត្រូវប្រើ មានដូចជា វិភាគ វាយលម្អិត ប្រៀបធៀប ជ្រើសរើស ផ្ទុយ បំបែកញែក ឬបែងចែក...។

ឧទាហរណ៍៖ ប្រមូលទិន្នន័យពីនាយកដ្ឋាន ឬផ្នែក និងជ្រើសកិច្ចការ ដែលបានតម្រូវសម្រាប់ការបណ្តុះបណ្តាល។

៥-វាយតម្លៃ (Evaluate)

ធ្វើការវាយតម្លៃដោយផ្អែកលើលក្ខណៈវិនិច្ឆ័យ និងស្តង់ដា។ កិរិយាសព្ទដែលត្រូវប្រើ មានដូចជា ចាត់ថ្នាក់ វាយតម្លៃ ពិនិត្យជាន ត្រួតពិនិត្យ តេស្ត វិនិច្ឆ័យ ជ្រើសរើស ធ្វើយុត្តិកម្ម...។ ឧទាហរណ៍៖ ជ្រើសដំណោះស្រាយ ដែលមានប្រសិទ្ធភាពបំផុត សម្រាប់ដោះស្រាយភាពក្រីក្រ។

៦-បង្កើតថ្មី (Create)

ដាក់សមាសភាពរួមគ្នា ដើម្បីបង្កើតមុខងារទាំងមូល។ រៀបចំឡើងវិញនូវសមាសភាពឱ្យទៅជាគំរូឬរចនាសម្ព័ន្ធថ្មី។ កិរិយាសព្ទដែលត្រូវប្រើ មានដូចជា បង្កើតធ្វើផែនការនិពន្ធអភិវឌ្ឍបង្កើតថ្មី ច្នៃប្រឌិត រៀបចំ ស្ថាបនា ផលិតចង់ក្រង មានគម្រោងបង្កើតឡើង...។

ឧទាហរណ៍៖ បង្កើតម៉ាស៊ីនបូមទឹកដោយមិនប្រើឋាមពលប្រេងឥន្ធនៈដើម្បីស្រោចដំណាំក្នុងចម្ការរបស់អ្នក។

២-វិស័យចិត្តចលនា The psycho-motor domain (action-based)

ឋានានុក្រមនៃចិត្តចលនាទាក់ទងនឹងការរៀន (A scaffolding hierarchy of the pyscho- motor domain related to learning)។ ជំនាញនៃវិស័យចិត្តចលនា ពិពណ៌នាអំពីសមត្ថភាព នៅក្នុងការប្រើឧបករណ៍ ឬការប្រើប្រាស់ចលនានៃរាងកាយ ដូចជាការធ្វើអ្វីដោយដៃឬញញួរ។ គោលបំណងនៃចិត្តចលនាជាធម្មតាផ្តោតលើការផ្ទាស់ប្តូរ ការអភិវឌ្ឍវិយោបថ ឬជំនាញ។ លោកប៊ឹម និងសហការីរបស់គាត់មិនដែលបែងចែកវិស័យចិត្តចលករជាចំណាត់ថ្នាក់ទេ។ ក៏ប៉ុន្តែ ក្រោយមកមានអ្នកអប់រំដទៃទៀតបានបង្កើតវិស័យចិត្តចលករជាចំណាត់ថ្នាក់។ លោក Simpson (១៩៧២) បានលើកឡើងនូវចំណាត់ថ្នាក់ដូចខាងក្រោម៖

១-ប្រត្យក្សារម្មណ៍ (Perception)

សមត្ថភាពក្នុងការប្រើអារម្មណ៍ដើម្បីបង្ហាញសកម្មភាពមានចលនា៖ ចាប់ផ្តើមពីការក្ងោចអារម្មណ៍តាមរយៈការជ្រើសរើសគំរូជាតម្រុយទៅដល់ភាពអាចចេះបកស្រាយបាន។

ឧទាហរណ៍៖ ការប៉ាន់ស្មានកន្លែងដែលគ្រាប់បាល់មួយនឹងធ្លាក់ចំទីតាំងដ៏ត្រឹមត្រូវបន្ទាប់ពីវាត្រូវបានគេបោះទៅ។ គេអាចកំណត់សីតុណ្ហភាពដ៏ត្រឹមត្រូវក្នុងចង្ក្រានមួយ ដែលកំណត់ដោយក្ងិន និងរសជាតិអាហារ។ គេអាចកំណត់កម្ពស់របស់ដៃកចូក នៅលើរថយន្តដឹកទំនិញ ដោយធៀបនឹងកន្លែងដែលដៃលើកទំនិញទាក់ទងនឹងក្តាររបស់រថយន្ត។

ពាក្យគន្លឹះ៖ជ្រើសរើសពិពណ៌នារកឃើញខុសប្លែកគ្នា កត់សម្គាល់កំណត់អត្តសញ្ញាណជាក់ដោយឡែកទាក់ទងជ្រើសរើស។

២-សំណុំ/ការកំណត់ (Set)

ការត្រៀមខ្លួនដើម្បីធ្វើសកម្មភាព៖ រួមបញ្ចូលទាំងផ្នែកផ្លូវចិត្ត ផ្លូវកាយ និងផ្លូវអារម្មណ៍។ ផ្នែកទាំងបីនេះ មិនអាចកំណត់ទុកជាមុននូវការឆ្លើយតបរបស់មនុស្ស ចំពោះស្ថានភាពផ្សេងៗគ្នាបានទេ (ពេលខ្លះគេហៅថាផ្នត់គំនិត)។ ចិត្តចលករនេះ មានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងបំណែងចែករង "ឆ្លើយតបទៅនឹងបាតុភូត" នៃដែនដែលមានឥទ្ធិពល។

ឧទាហរណ៍៖ ដឹងនិងធ្វើសកម្មភាពតាមលំដាប់លំដោយនៃដំណើរការផលិត។ ទទួលស្គាល់សមត្ថភាព និងចំណុចខ្សោយរបស់គាត់។ បង្ហាញពីបំណងចង់រៀនពីដំណើរការថ្មីៗ (ការលើកទឹកចិត្ត) ។

ពាក្យគន្លឹះ ៖ ចាប់ផ្តើមបង្ហាញពន្យល់ផ្ទាស់ទី ដំណើរការប្រតិកម្ម បង្ហាញបញ្ជាក់ស្ម័គ្រចិត្ត។

៣-ឆ្លើយតបតាមការណែនាំ (Guided response)

ដំណាក់កាលដំបូងនៃការរៀនជំនាញដែលស្មុគស្មាញរួមមាន ធ្វើត្រាប់តាម រៀនសាកល្បងតាម និងរៀនពីកំហុស៖ ក្នុងការសម្រេចលទ្ធផលបានល្អកម្រិតណា គឺវាអាស្រ័យលើការអនុវត្តជាក់ស្តែង។

ឧទាហរណ៍៖ ដោះស្រាយសមីការគណិតវិទ្យាតាមរយៈការធ្វើបទបង្ហាញជាមុន។ ធ្វើតាមការណែនាំដើម្បីបង្កើតបានជាគំរូ។ ធ្វើតាមការលើកដៃជាសញ្ញារបស់អ្នកណែនាំ ខណៈពេលយើងកំពុងរៀនប្រតិបត្តិការរថយន្តស្ទូច។ ពាក្យគន្លឹះ៖ ថតចម្លង ផ្តានតាមធ្វើតាមធ្វើប្រតិកម្ម ធ្វើឡើងវិញ ឆ្លើយតប។

៤-យន្តការ (Mechanism)

ដំណាក់កាលកម្រិតមធ្យមក្នុងការរៀនជំនាញដ៏ស្មុគស្មាញ៖ ការឆ្លើយតបទៅនឹងអ្វីដែលបានរៀន វាបានក្លាយជាទម្លាប់នៃការធ្វើដដែលៗ ហើយវាត្រូវបានអនុវត្តប្រកបដោយទំនុកចិត្តនិងប្រកបដោយជំនាញច្បាស់លាស់។

ឧទាហរណ៍ ប្រើកុំព្យូទ័រផ្ទាល់ខ្លួន ជួសជុលម៉ាស៊ីន ដែលលេចធ្លាយ បើករថ យន្ត។

ពាក្យគន្លឹះ៖ ប្រមូលផ្តុំ ក្រិតតាមខ្នាត ស្តាបនា រុះរើ សម្តែង តោង ជួសជុល កិន កំ

ដៅរៀបចំ វាស់វែង ជួសជុល លាយបញ្ចូលគ្នា រៀបចំ គំនូសព្រាង។

៥-ភាពពេញលេញលើចម្លើយតប

(Complex overt response)

ការអនុវត្ត ប្រកបដោយភាពប៉ិន ប្រសប់នៃសកម្មភាពចលករ រួមបញ្ចូលនូវ គំរូដ៏ពេញលេញ៖ ភាពត្រឹមត្រូវត្រូវ បាន ចង្អុលបង្ហាញយ៉ាងរហ័ស ត្រឹមត្រូវ និងមាន ការសម្របសម្រួលកម្រិតខ្ពស់ និងត្រូវការ ថាមពលអប្បបរមា។ ក្នុងផ្នែកនេះ រួមបញ្ចូល ទាំងការអនុវត្តដោយគ្មានការស្ទាក់ ស្ទើរ និង ការអនុវត្តដោយស្វ័យប្រវត្តិ។

ឧទាហរណ៍៖ បត់រថយន្តទៅកន្លែង ចតរថយន្តបានស្របគ្នា។ ដំណើរការកុំព្យូទ័រ បានរហ័សនិងត្រឹមត្រូវ។ បង្ហាញសមត្ថភាព នៅពេលកំពុងលេងព្យាណូ។

ពាក្យគន្លឹះ៖ ប្រមូលផ្តុំបង្កើតក្រិតតាម ខ្នាតស្តាបនារុះរើ បង្ហាញ តោងជួសជុល កិន កម្តៅ រៀបចំវិធានការជួសជុល លាយបញ្ចូល គ្នា រៀបចំគំនូសព្រាង។

សម្គាល់៖ ពាក្យគន្លឹះ គឺដូចគ្នានឹងយន្ត ការដែរ ប៉ុន្តែមានគុណកិរិយាឬគុណនាម ដែលបង្ហាញពីដំណើរការលឿនល្អប្រសើរ ត្រឹមត្រូវជាង។ល។

៦-ការសម្របខ្លួន (Adaptation)

ជំនាញត្រូវបានអភិវឌ្ឍយ៉ាងល្អ ហើយបុគ្គល ម្នាក់ៗអាចកែប្រែលំនាំចលនាឱ្យសមនឹងតម្រូវ ការពិសេស។

ឧទាហរណ៍៖ ឆ្លើយតបប្រកបដោយ ប្រសិទ្ធភាពចំពោះបទពិសោធដែលមិនបាន រំពឹងទុក។ កែប្រែការណែនាំដើម្បីបំពេញ តម្រូវការរបស់អ្នកសិក្សា។ ធ្វើកិច្ចការដោយ ម៉ាស៊ីនវាទទួលលទ្ធផលលើសពីការរំពឹងទុក (ម៉ាស៊ីនមិនខូចហើយមិនមានគ្រោះ ថ្នាក់ ក្នុង ការបំពេញការកិច្ចថ្មីទេ)។ពាក្យ គន្លឹះ៖ សម្របតាម ជ្រើសរើស រៀបចំឡើងវិញ រំលឹក ឡើងវិញ ប្រែប្រួល។

៧-ប្រភពដើម (Origination)

បង្កើតគំរូសកម្មភាពថ្មី ដើម្បីឱ្យសម ស្របទៅនឹងស្ថានភាពជាក់លាក់ ឬបញ្ហាជាក់ លាក់៖ លទ្ធផលនៃការសិក្សាបញ្ជាក់ពីភាពច្នៃ ប្រឌិតដោយផ្អែកលើជំនាញ ដែលមានការ អភិវឌ្ឍកម្រិតខ្ពស់។

ឧទាហរណ៍៖ បង្កើតសំណុំថ្មីឬគំរូថ្មី ទាក់ទងនឹងគំនិត ឬទ្រឹស្តីថ្មីៗ។ បង្កើតកម្មវិធីប ណ្តុះបណ្តាលថ្មីនិងទូលំទូលាយ។ បង្កើត ទម្លាប់ហាត់ប្រាណជាប្រចាំ។

ពាក្យគន្លឹះ៖ រៀបចំបង្កើតកសាង រួម បញ្ចូលគ្នារចនា ផ្តួចផ្តើមតែងសរសេរ រចនា បង្កើតថ្មី គំនិតផ្តួចផ្តើម ប្រភពដើម។



៣-ទិស័យសញ្ចេតនា(ផ្នែកលើចិត្តរំភើប) The Affective Domain (Emotionbased)

៣-១.និយមន័យនៃទិស័យសញ្ចេតនា

វិស័យសញ្ចេតនា ពិពណ៌នាអំពីវត្ថុបំណងនៃការសិក្សា ដែលសង្កត់ធ្ងន់លើអារម្មណ៍ ចិត្តរំភើប ឬកម្រិតនៃការទទួលយក ឬការបដិសេធ។ វត្ថុបំណងសញ្ចេតនាប្រែប្រួលពីការយកចិត្តទុកដាក់សាមញ្ញទៅជាតុក្កដែលបានជ្រើសរើសទៅជាលក្ខណៈ ស្មុគស្មាញ ប៉ុន្តែមានលក្ខណៈស្របគ្នាខាងក្នុងនៃចរិតលក្ខណៈ និងមនសិការ។ យើងបានរកឃើញវត្ថុបំណងធំមួយចំនួននៅក្នុងអក្សរសិល្ប៍ ដែលបានសម្តែងចេញជាចំណាប់អារម្មណ៍ ឥរិយាបថកោតសរសើរ គុណតម្លៃ និងឈុតអារម្មណ៍ឬភាពលំអៀង (From Krathwohl et al., ១៩៦៤)។

វិស័យសញ្ចេតនា គឺជាផ្នែកមួយនៃប្រព័ន្ធមួយ ដែលត្រូវបានបោះពុម្ពផ្សាយនៅឆ្នាំ ១៩៦៥ សម្រាប់ការកំណត់ការយល់ដឹង និងការដោះស្រាយរបៀបដែលមនុស្សរៀន។ ផ្នែកមួយនៅក្នុងវិចារណកថារបស់ ប៊ូម ការចាត់ថ្នាក់នៃវត្ថុបំណងអប់រំនេះ រួមបញ្ចូលទាំងវិស័យពុទ្ធិ និងវិស័យចិត្តចលនា។

វិស័យសញ្ចេតនា គឺជាវិស័យមួយក្នុងចំណោមវិស័យចំនួនបីរបស់ប៊ូមដែលពីរផ្សេងទៀត គឺជាវិស័យពុទ្ធិ និងវិស័យចិត្តចលនា (Bloom et all., ១៩៥៦)។

វិស័យសញ្ចេតនា (Krathwohl, Bloo-m, Masia,*១៩៧៣*) *រួមបញ្ចូលទាំងរបៀបដែលយើងដោះស្រាយជាមួយវត្ថុអារម្មណ៍ ដូចជាអារម្មណ៍ គុណតម្លៃ ការកោតសរសើរភាពរីករាយ ការលើកទឹកចិត្ត និងអាកប្បកិរិយា។ ប្រភេទធំៗ*

ទាំង៥ ត្រូវបានចុះបញ្ជីពីតរិយោបថសាមញ្ញ បំផុតរហូតដល់ស្មុគស្មាញបំផុត៖

នេះ គឺជាការពិពណ៌នាអំពីជំហាន នីមួយៗនៅក្នុងវិចារណកថា ដោយចាប់ផ្តើម ពីកម្រិតមូលដ្ឋានបំផុត។ (ដកស្រង់ចេញពី វចនានុក្រមវិចារណកថារបស់Krathwhl)។

៣-២.តើអ្វីជាវិស័យសញ្ចេតនា ដែលជះឥទ្ធិពលដល់ការអប់រំ?

ប្រសិនបើយើងខំប្រឹងអនុវត្តនិន្នាការរបស់Krathwohl et al.,ចំពោះការបង្រៀនរបស់យើង បន្ទាប់មកយើងកំពុងលើកទឹកចិត្តសិស្សមិនត្រឹមតែទទួលបានព័ត៌មាននៅផ្នែកខាងក្រោមនៃឋានានុក្រមសញ្ចេតនានោះទេ។ យើងចង់ឱ្យពួកគេឆ្លើយតបទៅនឹងអ្វីដែលពួកគេរៀនផ្តល់តម្លៃរៀបចំវា ហើយថែមទាំងអាចកំណត់ថា ខ្លួនជានិស្សិតវិទ្យាសាស្ត្រជំនាញ វិទ្យាសាស្ត្រ ឬអ្នកវិទ្យាសាស្ត្រទៀតផង។

យើងក៏ចាប់អារម្មណ៍លើអាកប្បកិរិយារបស់និស្សិត ចំពោះវិទ្យាសាស្ត្រ អ្នកវិទ្យាសាស្ត្រ ការរៀនវិទ្យាសាស្ត្រ និងប្រធានបទវិទ្យាសាស្ត្រជាក់លាក់។ យើងចង់ស្វែងរកវិធីបង្រៀនដែលលើកទឹកចិត្តសិស្សនិងទាក់ទាញពួកគេចូលរៀន។ ប្រធានបទវិស័យសញ្ចេតនានៅក្នុងការអប់រំរួមមានអាកប្បកិរិយា ការលើកទឹកចិត្តរបៀបទំនាក់ទំនង របៀបគ្រប់គ្រងថ្នាក់រៀន របៀបរៀន ការប្រើប្រាស់បច្ចេកវិទ្យាក្នុងថ្នាក់រៀន និងការប្រាស្រ័យទាក់ទងមិនមែនពាក្យសម្តី។ វាក៏សំខាន់ផងដែរដែលមិនត្រូវបិទសកម្មភាពសិស្ស ឬការប្រាស្រ័យទាក់ទងល្អៗដែលឆ្ពោះទៅរកវិស័យសញ្ចេតនា និងរារាំងសិស្សមិនឱ្យចូលរួម។

នៅក្នុងការអប់រំ ស្ទើរតែគ្រប់អ្នកនិពន្ធណែនាំនៅក្នុងសំណេររបស់ពួកគេដោយបញ្ជាក់ថា វិស័យសញ្ចេតនាគឺចាំបាច់សម្រាប់ការរៀនសូត្រ ប៉ុន្តែវាត្រូវបានសិក្សាតិចតួចបំផុត ដែលភាគច្រើនត្រូវបានគេមើលរំលងដែលមានភាពវៃឆ្លាតបំផុត និងពិបាកវាយតម្លៃបំផុត ចំពោះវិស័យទាំងបីរបស់ប៊ូម។ នៅក្នុងការបង្រៀនក្នុងថ្នាក់ជាផ្លូវការកិច្ចខិតខំប្រឹងប្រែងភាគច្រើនរបស់គ្រូជាធម្មតាចូលទៅក្នុងផ្នែកយល់ដឹងនៃការបង្រៀន និងការរៀន ហើយភាគច្រើនម៉ោងសិក្សាត្រូវបានរចនាឡើងសម្រាប់លទ្ធផលនៃការយល់ដឹង។ ដូចគ្នាដែរ ការវាយតម្លៃការរៀនសូត្រយល់ដឹង គឺងាយស្រួល ប៉ុន្តែការវាយតម្លៃលទ្ធផលសិក្សាដែលទទួលបានគឺពិបាក។ ដូច្នេះមានតម្លៃសំខាន់ក្នុងការសម្រេចបាននូវសក្តានុពល ក្នុងការបង្កើនការសិក្សារបស់សិស្ស តាមរយៈការចូលទៅក្នុងវិស័យសញ្ចេតនា។ ដូចគ្នានេះដែរ និស្សិត អាចជួបប្រទះនូវឧបសគ្គ ដែលរារាំងដល់ការរៀនសូត្រដែលមិនអាចទទួលស្គាល់ ឬមិនអាចដោះស្រាយបាន នៅពេលប្រើគោលវិធីពុទ្ធិសុទ្ធសាធ។

វិស័យសញ្ចេតនារួមមាន អារម្មណ៍ចិត្តរំភើប និងអាកប្បកិរិយារបស់បុគ្គល។

ប្រភេទនៃវិស័យសញ្ញេតនា រួមមាន ការទទួលបាតុភូត ការឆ្លើយតបទៅនឹងបាតុភូត ការវាយតម្លៃ ការរៀបចំ និងការកំណត់លក្ខណៈ (Anderson et all., ២០១១)។ វិស័យសញ្ញេតនានៃបាតុភូតទទួលបានបង្កើតការយល់ដឹងអំពីអារម្មណ៍ និងចិត្តវិជ្ជ ក៏ដូចជាសមត្ថភាពប្រើប្រាស់ការយកចិត្តទុកដាក់ដែលបានជ្រើសរើស។ នេះអាចរួមបញ្ចូលការស្តាប់ដោយយកចិត្តទុកដាក់ ចំពោះមេរៀននៅក្នុងថ្នាក់។ អនុវិស័យនៃការឆ្លើយតបទៅនឹងបាតុភូតពាក់ព័ន្ធនឹងការចូលរួមយ៉ាងសកម្មរបស់អ្នកសិក្សានៅក្នុងថ្នាក់ឬក្នុងកំឡុងពេលពិភាក្សាជាក្រុម (Cannon and Feinstein, ២០០៥)។ ការឱ្យតម្លៃទាក់ទងនឹងសមត្ថភាពក្នុងការមើលឃើញពីតម្លៃរបស់អ្វីមួយ ហើយបង្ហាញវាបាន។ នេះរួមបញ្ចូលទាំងសមត្ថភាពរបស់អ្នកសិក្សាក្នុងការចែករំលែកទស្សនៈ និងគំនិតរបស់ពួកគេអំពីបញ្ហាផ្សេងៗ ដែលបានលើកឡើងនៅក្នុងថ្នាក់។ សមត្ថភាពរបស់សិស្សក្នុងការផ្តល់អាទិភាពដល់គុណតម្លៃមួយផ្សេងទៀត និងបង្កើតប្រព័ន្ធតម្លៃពិសេសមួយត្រូវបានគេស្គាល់ថាជាការរៀបចំ។ នេះអាចត្រូវបានវាយតម្លៃដោយតម្រូវការឱ្យតម្លៃលើការងារសិក្សារបស់មនុស្សម្នាក់ ដែលផ្ទុយពីទំនាក់ទំនងសង្គមរបស់ពួកគេ។ ដែនបន្ទាប់នៃចរិតលក្ខណៈពន្យល់ ពីសមត្ថភាពក្នុងការធ្វើឱ្យតម្លៃខាងក្នុង និងអនុញ្ញាតឱ្យពួកគេគ្រប់គ្រងអាកប្បកិរិយារបស់បុគ្គលម្នាក់ៗ។ ដោយមើលឃើញពីចំណុចនេះ និស្សិតចាត់ទុកថាការងារសិក្សាមានសារៈសំខាន់ខ្ពស់ ព្រោះវាដើរតួនាទីយ៉ាងសំខាន់ក្នុងការសម្រេចចិត្តលើផ្លូវអាជីព ដែលត្រូវជ្រើសរើស ជាជាងអ្វីដែលអាចមាន។





ប្រភេទនៃវិស័យសញ្ចេតនារួមមាន៖

ការទទួលបានជាការយល់ដឹង ចំពោះអត្ថិភាពនៃគំនិត សម្ភារៈ ឬបាតុភូតជាក់លាក់ ហើយមានឆន្ទៈក្នុងការអត់ធ្មត់ចំពោះពួកគេ។

ឧទាហរណ៍ រួមមាន៖ ដើម្បីធ្វើឱ្យមានភាពខុសគ្នា ដើម្បីទទួលយកស្តាប់(សម្រាប់) ដើម្បីឆ្លើយតប។

ការឆ្លើយតប ត្រូវបានប្តេជ្ញាចិត្តក្នុងវិធានការតូចមួយចំពោះ គំនិត សម្ភារៈ ឬបាតុភូតដែលពាក់ព័ន្ធ ដោយឆ្លើយតបយ៉ាងសកម្មចំពោះពួកគេ។

ឧទាហរណ៍គឺ៖ គោរពតាម,ធ្វើតាម, សរសើរ, ស្ម័គ្រចិត្ត, ចំណាយពេលទំនេរនៅក្នុង,ការអបអរសាទរ។

ការឱ្យតម្លៃ គឺមានឆន្ទៈឱ្យអ្នកដទៃយល់ឃើញថា ជាការផ្តល់តម្លៃដល់ គំនិត សម្ភារៈ ឬបាតុភូតជាក់លាក់។

ឧទាហរណ៍ រួមមាន៖ ដើម្បីបង្កើនជំនាញវាស់វែងក្នុងការបោះបង់ ការឧបត្ថម្ភធន ការគាំទ្រ ការជជែកវែកញែក។

ការរៀបចំ គឺទាក់ទងតម្លៃទៅនឹងអ្វីដែលមានរួចហើយ ហើយនាំវាទៅជាទស្សនវិជ្ជាប្រកបដោយភាពសុខដុមនិងខាងក្នុងខ្លួន។

ឧទាហរណ៍ រួមមាន៖ ពិភាក្សា ទ្រឹស្តីកម្ម ការបង្កើត តុល្យភាព ត្រួតពិនិត្យ។

ការកំណត់លក្ខណៈ គឺត្រូវធ្វើសកម្មភាពជាប់លាប់ ស្របតាមគុណតម្លៃដែលគេបានកំណត់។ ឧទាហរណ៍រួមមាន៖ ពិនិត្យឡើងវិញការទាមទារ ការវាយតម្លៃខ្ពស់ ការចៀសវាងការទប់ទល់ការគ្រប់គ្រងការដោះស្រាយ។

ការពិពណ៌នាអំពីប្រភេទសំខាន់ៗនៅក្នុងវិស័យសញ្ចេតនា៖

វិស័យសញ្ចេតនា Affective Domain	**កិរិយាសព្ទសមរម្យ** Illustrative Verbs
ការទទួលបាន៖ *ការយល់ដឹង ធន្ទ:ក្នុងការស្តាប់ ការយកចិត្តទុកដាក់ដែលបានជ្រើសរើស។*	*ឧទាហរណ៍៖ ស្តាប់អ្នកដទៃដោយការគោរព។ ស្តាប់ និងចងចាំឈ្មោះមនុស្ស ដែលបានណែ នាំថ្មីៗ។* *ពាក្យគន្ធីះ៖ សួរជ្រើសរើស ពិពណ៌នា ធ្វើតាម ផ្តល់ឱ្យ កាន់ កំណត់ ទីតាំង ឈ្មោះ, ចង្អុលទៅ ជ្រើសរើស អង្គុយ កំណត់ ធ្វើយតប ប្រើប្រាស់*
ការធ្វើយតប៖ ការចូលរួមយ៉ាងសកម្មលើផ្នែកនៃអ្នកសិក្សា។ ចូលរួម និងប្រតិកម្មចំពោះបាតុភូតជាក់លាក់មួយ។ លទ្ធផលនៃការសិក្សាអាចសង្កត់ធ្ងន់លើការអនុលោមតាមការធ្វើយតប ធន្ទ:ក្នុងការធ្វើយតបឬការពេញចិត្តក្នុងការធ្វើយតប (ការលើកទឹកចិត្ត)។	*ឧទាហរណ៍៖ ចូលរួមក្នុងការពិភាក្សាថ្នាក់។ ផ្តល់បទបង្ហាញ។ សំណួរអំពីឧត្តមគតិ គំនិត គំរូ ជាដើម ដើម្បីស្វែងយល់ឱ្យបានពេញលេញ។ ដឹងពីច្បាប់សុវត្ថិភាព និងអនុវត្តវា។* *ពាក្យគន្ធីះ៖ ចម្លើយ ជួយ ជំនួយអនុលោម ពិភាក្សា ស្វាគមន៍ ជួយ ស្វាក អនុវត្ត បង្ហាញ អាន សូត្រ របាយការណ៍ ជ្រើសរើស ប្រាប់សរសេរ។*
ការវាយតម្លៃ៖ *តម្លៃ ឬការឱ្យតម្លៃដែលមនុស្សម្នាក់ភ្ជាប់ទៅនឹងវត្ថុបាតុភូត ឬអាកប្បកិរិយាជាក់លាក់។ នេះរាប់ចាប់ពីការទទួលយកសាមញ្ញ រហូតដល់ស្ថានភាពនៃការប្តេជ្ញាចិត្តកាន់តែស្មុគស្មាញ។ ការវាយតម្លៃគឺផ្អែកលើការបំប្លែងផ្ទៃក្នុងនៃសំណុំនៃតម្លៃដែលបានបញ្ចាក់ខណៈពេលដែលតម្រុយនៃតម្លៃទាំងនេះត្រូវបានបង្ហាញអាកប្បកិរិយានៃអ្នកសិក្សាហើយជារឿយៗអាចកំណត់អត្តសញ្ញាណបាន។*	***ឧទាហរណ៍៖*** *បង្ហាញពីជំនឿលើដំណើរការប្រជាធិបតេយ្យ។ មានភាពរសើបចំពោះភាពខុសគ្នាបុគ្គលនិងវប្បធម៌(ភាពចម្រុះនៃតម្លៃ) បង្ហាញពីសមត្ថភាពក្នុងការដោះស្រាយបញ្ហាសំណើផែនការដើម្បីកែលម្អសង្គម និងអនុវត្តតាមដោយការប្តេជ្ញាចិត្ត។ ជូនដំណឹងដល់អ្នកគ្រប់គ្រងលើបញ្ហា ដែលមនុស្សម្នាក់មានអារម្មណ៍ខ្លាំងអំពីអ្វីមួយ។* ***ពាក្យគន្ធីះ៖*** *បញ្ចប់ បង្ហាញភាពខុសគ្នា ពន្យល់ ធ្វើតាម ទម្រង់ ផ្តួចផ្តើម អញ្ជើញ ចូល*

	រួម បង្ហាញអំពីភាពត្រឹមត្រូវ ស្មើ អាន របាយការណ៍ ជ្រើសរើស ចែករំលែក សិក្សាធ្វើការ។
ការរៀបចំ៖ *រៀបចំតម្លៃទៅជាអាទិភាពដោយប្រៀបធៀបតម្លៃផ្សេងៗគ្នា ដោះស្រាយជម្លោះរវាងពួកវា និងបង្កើតប្រព័ន្ធតម្លៃពិសេសមួយ។ ការសង្កត់ធ្ងន់ លើការប្រៀបធៀប ការទាក់ទង និងការសំយោគតម្លៃ។*	***ឧទាហរណ៍៖*** *ទទួលស្គាល់តម្រូវការសម្រាប់គុណភាពរវាងសេរីភាព និងអាកប្បកិរិយាទទួលខុសត្រូវ។ ទទួលយកទំនួលខុសត្រូវចំពោះអាកប្បកិរិយារបស់មនុស្សម្នាក់។ ពន្យល់ពីតួនាទីនៃការរៀបចំផែនការជាប្រព័ន្ធក្នុងការដោះស្រាយបញ្ហា។ ទទួលយកស្តង់ដាសីលធម៌វិជ្ជាជីវៈ។ បង្កើតផែនការជីវិតដែលសមស្របនឹងសមត្ថភាព ចំណាប់អារម្មណ៍ និងជំនឿ។ ការផ្តល់អាទិភាពដល់ពេលវេលាប្រកប ដោយប្រសិទ្ធភាព ដើម្បីបំពេញតម្រូវការអង្គភាព គ្រួសារនិងខ្លួនឯង។* ***ពាក្យគន្លឹះ៖*** *ប្រកាន់ខ្ជាប់កែប្រែរៀបចំផ្សំប្រៀបធៀប បំពេញ ការពារ ពន្យល់ បង្កើតទូទៅ កំណត់ រួមបញ្ចូល កែប្រែបញ្ជារៀបចំ រៀបចំ ទាក់ទង សំយោគ។*
ការកំណត់លក្ខណៈ: (characterization)៖ *មានប្រព័ន្ធតម្លៃដែលគ្រប់គ្រងឥរិយាបថរបស់ពួកគេ។ ឥរិយាបថ មានលក្ខណៈទូលំទូលាយ ជាប់លាប់ អាចទស្សន៍ទាយបាន និងសំខាន់បំផុតលក្ខណៈរបស់អ្នកសិក្សា។ គោលបំណងនៃការបង្រៀន គឺទាក់ទងនឹងគំរូទូទៅ នៃការកែតម្រូវរបស់សិស្ស(ផ្នាល់ខ្លួនសង្គម អារម្មណ៍)!*	***ឧទាហរណ៍៖*** *បង្ហាញពីការពឹងផ្អែកលើខ្លួនឯងនៅពេលធ្វើការដោយឯកពជ្យ។ សហការក្នុងសកម្មភាពជាក្រុម(បង្ហាញការងារជាក្រុម) ប្រើវិធីសាស្ត្រគោលបំណងនៅក្នុងការដោះស្រាយបញ្ហា។ បង្ហាញការប្តេជ្ញាចិត្តប្រកប ដោយវិជ្ជាជីវៈចំពោះការអនុវត្តក្រមសីលធម៌ជារៀងរាល់ថ្ងៃ។ កែប្រែការវិនិច្ឆ័យនិងផ្លាស់ប្តូរអាកប្បកិរិយាដោយពន្ធឹនៃកស្តុតាង់ថ្មី។ ឱ្យតម្លៃមនុស្សសម្រាប់អ្វី ដែលពួកគេមាន មិនមែនរបៀបដែលពួកគេមើលទៅ។* ***ពាក្យគន្លឹះ៖*** *ធ្វើសកម្មភាព រើសអើង បង្ហាញឥទ្ធិពល ស្តាប់ កែប្រែ អនុវត្ត អនុវត្ត ស្មើ មានលក្ខណៈគ្រប់គ្រាន់ សំណួរ កែប្រែ បម្រើ*

ដោះស្រាយ ផ្ទៀងផ្ទាត់។



៤. ការអនុវត្តនានៃប្រព័ន្ធចំណាត់ថ្នាក់ថ្មីវិទ្យាប៊ូម

៤.១-ការវាយតម្លៃទៅលើការសិក្សាតាមកម្រិតទាំង៦នៃប្រព័ន្ធចំណាត់ថ្នាក់ថ្មីវិទ្យាប៊ូម

ដើម្បីងាយស្រួលក្នុងការធ្វើវង្វាយតម្លៃទៅលើស្នាដៃសិក្សារបស់សិស្ស យើងត្រូវរៀបចំសំណួរសរសេរក្តី និងសំណួរផ្ទាល់មាត់ក្តីទៅតាមប្រព័ន្ធចំណាត់ថ្នាក់វិទ្យាប៊ូម (Bloom's Taxonomy) ដែលជាទ្រឹស្តីរបស់លោក Bloom។ ការរៀបចំការវាយតម្លៃនេះ ក៏ធ្វើទៅតាមកម្រិតទាំង៦នៃប្រព័ន្ធគោលបំណងនៃការសិក្សារបស់លោកBloomជាប្រព័ន្ធចំណាត់ថ្នាក់ដែលគិតចាប់ពីកម្រិតទាបទៅកម្រិតខ្ពស់ រួមមានចងចាំ(Remember) យល់ដឹង(Understand) អនុវត្ត(Apply) វិភាគ(Analyze) វាយតម្លៃ (Eval-uate) និងបង្កើតថ្មី(Create)។

ដោយផ្អែកតាមចំណាត់ថ្នាក់នៃប្រពន្ធ័នេះយើងអាចរៀបចំទៅបាននូវសំណួរសម្រាប់ការវាយតម្លៃនៃប្រពន្ធ័លោក Bloom ដូចខាងក្រោម៖

ក/សំណួរចងចាំ៖ សំណួរកម្រិតនេះជាសំណួរកម្រិតទាបបំផុតនៃប្រពន្ធ័ចំណាត់ថ្នាក់វិទ្យាប៊ូម ដែលតម្រូវឱ្យសិស្សរំលឹកឡើងវិញ ឬស្គាល់ព័ត៌មាននៃមេរៀន ដូចជា៖ <u>រំលឹកឡើងវិញ ទទួលស្គាល់ឱ្យនិយមន័យពិនិត្យសម្គាល់ និងប្រើសំណួរ ថា៖ អ្នកណា? នៅឯណា? អ្វី?នៅពេលណា? ជាដើម។</u>

ខ/សំណួរយល់ដឹង ៖ កម្រិតនេះស្ថិតក្នុងលំដាប់ទី២នៃប្រពន្ធ័ដែលតម្រូវឱ្យសិស្សប្រើគំនិតរបស់ខ្លួនដោយនិយាយអំពីខ្លឹមសារ

នៃមេរៀនរៀនរួចហើយ ឬដោយការធ្វើឃ្លាសាជាថ្មីជាដើម។ ការធ្វើទាំងនោះ រួមមាន៖ ពណ៌នាប្រៀបធៀប ពន្យល់ដោយទាញឧទាហរណ៍ បកស្រាយធ្វើឃ្លាសាជាថ្មី តម្រៀបសាឡើងវិញតាមលំដាប់លំដោយបកស្រាយដោយប្រើភាពផ្ទុយគ្នា វែកញែក_ឱ្យឃើញភាពផ្ទុយគ្នាការរិះរកគំនិតសំខាន់ៗ។

គ/សំណួរអនុវត្ត៖ ស្ថិតក្នុងលំដាប់ទី៣ នៃប្រព័ន្ធសំណួរកម្រិតនេះតម្រូវឱ្យសិស្សជ្រើសរើសកំណត់ចម្ងើយត្រឹមត្រូវតែមួយគត់ដោយផ្អែកទៅលើចំណុច និងសេចក្តីផ្សេងៗរបស់មេរៀនដែលរៀនរួចហើយ។ ការវាយតម្លៃក្នុងកម្រិតអនុវត្តទៅងនេះរួមមាន៖ អនុវត្ត រៀបចំតាមលំដាប់លំដោយនៃព័ត៌មាន ដោះស្រាយបញ្ហា សម្រេចចិត្តយកអ្វីមួយជ្រើសរើសយកចម្ងើយតែមួយដែលត្រូវការប្រើប្រាស់ ការធ្វើចំណែកថ្នាក់ ការសរសេរឧទាហរណ៍ ឬការឱ្យឧទាហរណ៍ ឬក៏ការប្រើសំណួរថា៖ មួយណាដែល...? អ្វីទៅដែលល្អ...? ជាដើម។

ឃ/សំណួរវិភាគ៖ សំណួរប្រភេទវិភាគនេះ ស្ថិតក្នុងលំដាប់កម្រិតខ្ពស់ និងជាកម្រិតទី៤នៃប្រព័ន្ធចំណាត់ថ្នាក់វិទ្យា ដែលនឹងតម្រូវឱ្យសិស្សពិនិត្យសម្គាល់ និងទាញលទ្ធផលសម្អាងជាទូទៅអំពីគោលគំនិតណាមួយមុននឹងសម្រេចយកមតិបញ្ចប់ឬធ្វើទូទៅនីយកម្ម។ សំណួរបែបវិភាគដែលស្ថិតក្នុងកម្រិតវិភាគនេះរួមមាន៖ ធ្វើវិភាគ ធ្វើសេចក្តីសន្និដ្ឋានទាញលទ្ធផលសម្អាងទៅលើអ្វីមួយ ផ្តល់នូវលក្ខណៈផ្សេងៗ ផ្តល់យោបល់ដើម្បីគាំទ្រមតិ រកបុព្វហេតុដើមនៃបញ្ហា កំណត់ជ្រើសយកកស្តុតាង ពិនិត្យសម្គាល់មូលហេតុ ឬសេចក្តីសម្អាងផ្សេងៗ និងត្រូវសួរថា ហេតុអ្វី...?

ង/ សំណួរវាយតម្លៃ៖ កម្រិតសំណួរប្រភេទនេះ គឺស្ថិតក្នុងកម្រិតទី៥នៃប្រព័ន្ធចំណាត់ថ្នាក់វិទ្យា Bloom ដែលតម្រូវឱ្យសិស្សប្រើប្រាស់ការវិនិច្ឆ័យ ឬផ្តល់យោបល់ក្នុងសកម្មភាពរួមមាន ៖ បញ្ចេញមតិយោបល់សម្រេចចិត្តវាយតម្លៃ ជជែកឬនិយាយគាំទ្រវិនិច្ឆ័យ ឬក៏ប្រើសំណួរថា៖ តើអ្នកយល់ស្របឬទេបើ.?តើអ្នកយល់យ៉ាងដូចម្តេច..? តើមួយណាដែលគ្រាន់ បើជាងគេ...?

ច/សំណួរបង្កើតថ្មី៖កម្រិតសំណួរប្រភេទនេះ គឺស្ថិតក្នុងកម្រិតទី៦នៃប្រពន្ធ័ចំណាត់ថ្នាក់វិទ្យាBloom ដែលតម្រូវឱ្យសិស្សប្រើប្រាស់ និងផ្តល់នូវគំនិតដើម ដើម្បីរៀបចំឡើងវិញនូវធាតុដើម្បីឱ្យទៅជាគំរូ និងរចនាសម្ព័ន្ធថ្មី។ កម្រិតនេះសិស្សមានសមត្ថភាពបង្កើតគំនិតថ្មី ឬគួសវាសនូវអ្វីដែលថ្មីដើម្បីធ្វើយនឹងសំណួរបស់គ្រូ។ ការបង្កើតថ្មីរួមមាន៖ ធ្វើផែនការនិពន្ធអភិវឌ្ឍបង្កើតថ្មីច្នៃប្រឌិត រៀបចំស្ថាបនាផលិតចង់ក្រងរៀបចំគម្រោង។ល។ឬក៏ប្រើសំណួរថា៖ តើការផ្លាស់ប្តូរអ្វីខ្លះដែលអ្នកមានដើម្បីកែលម្អ? តើអ្នកនឹងពន្យល់ហេតុផល... តាមវិធីណា?តើអ្នកបង្កើត.តាមវិធីណាដែរ? តើអ្នកអាចបង្កើតអ្វីបាន.....?

៤.២- ប្រព័ន្ធចំណាត់ថ្នាក់វិទ្យាប្លឹម នៅក្នុងការកំណត់វត្ថុបំណងនៃការអប់រំ

ប្រភេទ (Categories)	អត្ថន័យនៃការអនុវត្តជាក់ស្តែង
ក.ចងចាំ (Remember) សមត្ថភាពនៃការរំលឹកឡើងវិញបាន... ចំណេះដឹងពាក់ព័ន្ធនៃព័ត៌មានពិត រំលឹកព័ត៌មានឡើងវិញបានតំណាងប្រព័ន្ធចំណាត់ថ្នាក់ពិសេស ទទួលស្គាល់ព័ត៌មាននៅក្នុងខ្លឹមសារកម្រិតទាប។	ធ្វើបញ្ជីឱ្យនិយមន័យបញ្ជាក់កិនភាគ ចំណាត់ថ្នាក់ពិសេស មេរៀន ស្គាល់ឈ្មោះ...។
ខ. យល់ខ្លឹមសារ (Understand) សមត្ថភាពនៃការយល់អត្ថន័យព័ត៌មានដែលបានរៀន ... សិក្សារួចហើយ...	ព្យាករណ៍ បកស្រាយអត្ថន័យ ពន្យល់ន័យ សង្ខេបឱ្យតម្លៃ ចេះវាយតម្លៃ...។ ឧទាហរណ៍៖ បកស្រាយអត្ថន័យនៃកន្សោមពាក្យ ឃ្លា ប្រយោគ ឬល្បះក្នុងកំណាព្យ។
គ. អនុវត្ត (Apply) សមត្ថភាពនៃបម្រើបម្រាស់ព័ត៌មានដែលសិក្សារួចមកហើយទៅអនុវត្តក្នុងស្ថានភាពថ្មីថ្មោងនៃជីវភាពរស់នៅ។	ស្រាយបំភ្លឺពន្យល់ ដោះស្រាយគណនា បញ្ជាក់ពីអត្តសញ្ញាណ បង្ហាញមតិយោបល់ ប្រើប្រាស់នៃព័ត៌មាន យកចំណេះដឹងទៅអនុវត្ត...។ ឧ.កំណត់អត្តសញ្ញាណសមាសភាពកំណាព្យដែលត្រូវលើយកមកបង្រៀន។
ឃ. វិភាគ (Analyze)	
សមត្ថភាពនៃការញែកដាច់នៃខ្លឹមសារមេរៀនទៅតាមផ្នែកនីមួយៗរបស់វានៅក្នុងបំណងនៃការយល់ដឹងបានពីរចនាសម្ព័ន្ធនៃមេរៀន។	វែកញែក បែងចែក ចែកជាប្រភេទ ធ្វើគម្រោងបញ្ជាក់អត្តសញ្ញាណ ញែកខ្លឹមសារដាច់ពីគ្នា...។ ឧ. បែងចែករចនាបថនៃអត្តបទកំណាព្យពីរ
ង. □វាយតម្លៃ (Evaluate) សមត្ថភាពនៃការចេះវិច្ច័យទៅលើតម្លៃនៃខ្លឹមសារមេរៀនដោយយោលទៅតាមលក្ខណៈវិនិច្ច័យពិសេស។	ទិតៀន ពិនិត្យពិច័យ រៀបចំ ធ្វើកម្ងាយ ឱ្យរួបមន្ត និពន្ធកំណាព្យ សរសេរបានល្អ...។ ឧ. ឱ្យសិស្សនិពន្ធអត្តបទកំណាព្យមួយ។
ឧ. នាំឱ្យសិស្សនិពន្ធអត្តបទកំណាព្យមួយ ។	
ច. បង្កើតថ្មី (Create) ដាក់ផ្សំធាតុបញ្ចូលគ្នាដើម្បីបង្កើតនូវភាពទាំង	បង្កើត ធ្វើផែនការ និពន្ធ អភិវឌ្ឍ បង្កើតថ្មី ច្នៃប្រឌិត រៀបចំ ស្ថាបនា ផលិត ចងក្រង រៀប

មូល តាមមុខងារ ឬទំនាក់ទំនង ឬតួនាទីទាំងមូល រៀបចំឡើងវិញនូវធាតុដើម្បីឱ្យទៅជាគំរូនិងរចនាសម្ព័ន្ធថ្មី សិស្សមានសមត្ថភាពបង្កើតគំនិតថ្មី ឬគួសវាសនូវអ្វីដែលថ្មី។	*ចំគម្រោង...។* *ខ. សិស្សបង្កើតសម្ភារៈរៀនដោយប្រើប្រាស់ធនធានដែលមានក្នុងមូលដ្ឋាន។*

៤.៣. សកម្មភាពរបស់សិស្ស ដើម្បីទទួលបានចំណេះដឹងពីការអប់រំ

ចំណាត់ថ្នាក់ (Categories)	*វាក្យសព្ទទាក់ទងនឹងអាកប្បកិរិយា* Illustrative behavioral terms
ក. ទទួលចំណេះដឹង (Receiving) *ចំណងចំណូលចិត្តក្នុងការយល់ដឹងលើអត្ថប្រយោជន៍នៃការសិក្សាគួបផ្សំគ្នាជាមួយនឹងបំណងប្រាថ្នា ចេះផ្តោតស្មារតីទៅលើសកម្មភាពសិក្សា។*	*ស្តាប់គ្រូ សួរគ្រូ ផ្តោតស្មារតី ពិនិត្យសង្កេតអនុវត្តតាម ខិតខំយកចិត្ត ទុកដាក់ ស្រាយបំភ្លឺបញ្ហា...។* *ខ. ចេះពិនិត្យសង្កេតថា សិស្សខូចរស់នៅក្នុងស្ថាន ភាពដ៏ក្រលំបាក។*
ខ. ទំទួលខុសត្រូវ (Responding) *បំណងប្រាថ្នាចូលរួមយ៉ាងសកម្មនៅក្នុងសកម្មភាពដែលគ្រូបញ្ជា ហើយមានការពេញចិត្តចូលរួមសកម្មភាពនេះជាមួយមិត្តភ័ក្ត្រ។*	*មានសុឆន្ទៈ ស្តាប់គ្រូបង្ហាញស្នាដៃល្អឆ្វើយសំណួរ ជួយមិត្តភ័ក្ត្រ...។* *ខ. មានសុឆន្ទៈធ្វើអំណោយជាប្រដាប់លេងកម្សាន្តដល់អង្គការសប្បុរសធម៌។*
គ. វាយតម្លៃ (Valuing) *មានប្រត្យក្សារម្មណ៍ទៅលើបាតុភូត ឬប្រកាន់ឥរិយាបថដ៏មានតម្លៃ។ វាយតម្លៃផងដែរទៅលើការជួយផ្តល់ជាមតិយោបល់ឬគោលជំហររបស់គណៈកម្មការណាមួយ។*	*ឱ្យតម្លៃ វែកញែកភាពខុសគ្នា វិនិច្ឆ័យ ចងក្រង បែងចែក វាយតម្លៃ អញ្ជើញភ្ញៀវ ...។*
ឃ. ចាត់ចែង រៀបចំ (Organizing) *ដំណើរការធ្វើសមាហរណកម្មទៅលើតម្លៃផ្សេងៗគ្នា បង្រួបបង្រួមភាពខុសផ្ទៃកគ្នា និងបង្កើតរូបមន្តទៅលើប្រព័ន្ធនៃតម្លៃទំនិញដ៏មានស្ថិរភាពក្នុងស្រុក។*	*ប្រៀបធៀប គួបផ្សំគ្នា រៀបចំ ការពារ ធ្វើសំយោគ ធ្វើសមាហរណកម្ម ទទួលស្គាល់...។* *ខ.ធ្វើសមាហរណកម្មទៅលើជំនឿរបស់បុគ្គលសំដៅធ្វើឱ្យប្រព័ន្ធនៃតម្លៃផ្ទាល់ខ្លួនអភិវឌ្ឍឡើង។*

ង.ការចេះបង្ហាញលក្ខណៈពិសេសតាមតម្លៃ ស្មុគ្រស្មាញ (Characterization by Value Complex) ការភ្ជាប់បាននូវប្រព័ន្ធនៃតម្លៃដែលចេះគ្រប់គ្រងឥរិយាបទប្រកបដោយស្ថិរភាពទៅតាមប្រព័ន្ធនៃតម្លៃផ្ទាល់ខ្លួន។	បញ្ចេញកាយវិការ បង្ហាញកាយវិការដ៏ថ្លៃថ្នូរ ប្រើពាក្យសម្តីដ៏សមរម្យ បង្ហាញឥទ្ធិពលក្នុងចំណោមអនុវត្ត បកស្រាយបំភ្លឺឱ្យគេយល់...។

៥. ផលប៉ះពាល់

ចំណាត់ថ្នាក់វិទ្យាប្បិម ដើរតួនាទីបែបទស្សនវិជ្ជាក្នុងការបង្រៀន ជាពិសេសអ្នកដែលពឹងផ្អែកលើជំនាញជាជាងទ្រឹស្តី។ អ្នកអប់រំ ចាត់ទុកខ្លឹមសារនេះថា ជាត្រីវិស័យសម្រាប់ជំនាញនៅក្នុងការបង្រៀន។ ការសង្កត់ធ្ងន់លើការគិតតាមលំដាប់លំដោយដែលមាននៅក្នុងទស្សនវិជ្ជា។ ទាំងនេះគឺផ្អែកលើការគិតកម្រិតខ្ពស់រួមមាន ការអនុវត្ត ការវិភាគ ការសំយោគ និងការវាយតម្លៃ។ ចំណាត់ថ្នាក់វិទ្យាប្បិមអាចត្រូវបានប្រើធ្វើជាឧបករណ៍សម្រាប់បង្រៀន និងដើម្បីជួយធ្វើឱ្យមានតុល្យភាពរវាងការវាយតម្លៃ និងការសិក្សាការស្រាវជ្រាវរៀនសូត្ររបស់សិស្ស និស្សិតក៏ដូចជាការចូលរួមក្នុងថ្នាក់រៀនដើម្បីជានាថា រាល់ការគិតគូរត្រូវបានអនុវត្តនៅក្នុងការរៀនសូត្ររបស់និស្សិតរួមទាំងទិដ្ឋភាពនៃការស្វែងរកព័ត៌មានផ្សេងៗ។

ចំណាត់ថ្នាក់វិទ្យាប្បិម នៅតែជាប្រភពនៃការបំផុសគំនិតសម្រាប់ទស្សនវិជ្ជាអប់រំ និងសម្រាប់ការអភិវឌ្ឍយុទ្ធសាស្ត្របង្រៀនថ្មីៗការអភិវឌ្ឍជំនាញដែលប្រព្រឹត្តទៅតាមលំដាប់លំដោយនៃការគិតគូរមានទំនាក់ទំនងល្អជាមួយការអភិវឌ្ឍផ្តោតជាសកលលើអក្សរសាស្ត្រ និងគំរូជាច្រើនទៀតក្នុងការរៀនសូត្រ និងមុខវិជ្ជាផ្សេងៗត្រូវបានរួមបញ្ចូលគ្នា។ សមត្ថភាពក្នុងការធ្វើអន្តរកម្មជាមួយនិងបង្កើតប្រព័ន្ធផ្សព្វ ផ្សាយ ត្រូវផ្អែកទាំងពីរ គឺពឹងលើជំនាញក្នុងការគិតកម្រិតខ្ពស់(ការវិភាគការបង្កើតនិងការវាយតម្លៃ) និងពឹងលើជំនាញការគិតកម្រិតទាប(ចំណេះដឹងការយល់ដឹងនិងការអនុវត្ត)។

សេចក្តីសន្និដ្ឋាន

ចំណាត់ថ្នាក់វិទ្យាប្បិម ជាគំរូឯកសារយោងដ៏អស្ចារ្យមួយ សម្រាប់អ្នកចូលរួមទាំងអស់ក្នុងការបង្រៀន ការបណ្តុះបណ្តាលការរៀន ការបង្វឹកនៅក្នុងការរចនា ការផ្តល់ និងការវាយតម្លៃនៃវិធីសាស្ត្រអភិវឌ្ឍទាំងនេះ។ ចំណាត់ថ្នាក់វិទ្យាប្បិម ផ្តល់នូវបញ្ជីត្រួតពិនិត្យដ៏សាមញ្ញ រហ័ស និងងាយស្រួលដើម្បីចាប់ផ្តើមរៀបចំផែនការអភិវឌ្ឍផ្ទាល់ខ្លួនណាមួយ។ ដូចទៅនឹងបញ្ជីត្រួតពិនិត្យណាមួយដែរ វាជួយកាត់បន្ថយហានិភ័យនៃការមើលរំលងទិដ្ឋភាពសំខាន់ៗមួយចំនួននៃការអភិវឌ្ឍដែលត្រូវការ។ ជាតុលម្អិតបន្ថែមទៀតនៅក្នុងដែននីមួយៗ(ម៉ាទ្រីស)ផ្តល់នូវចំណុចយោងបន្ថែមសម្រាប់ការរចនា និងការវាយតម្លៃការសិក្សា មិនថាសម្រាប់មេរៀនតែមួយវគ្គ ឬ

សកម្មភាព ឬតម្រូវការបណ្តុះបណ្តាល ឬ
សម្រាប់កម្មវិធីសិក្សាទាំងមូល។

គន្ថនិទ្ទេស

1. -*មាឃ សារី* ***ឧបទេសវិទ្យាទំនើប*** *ឆ្នាំ២០១០។*
2. -Paola Ostinelli, ***Assessing the Affective Domain in Child and Youth Care,*** MARCH 2021.
3. -Allen, K., & Friedman, B.D. (2010). Affective learning: A taxonomy for teaching social work values. Journal of Social Work Values and Ethics, 7(2).
4. -Armstrong, P. (n.d.). Bloom's Taxonomy. Center for Teaching, Vanderbilt University. https://cft.vanderbilt.edu/guides-sub-pages/blooms-taxonomy/
5. -Association for Child and Youth Care Practice. (2010). Competencies for Professional Child & Youth Work Practitioners.
6. Association of American Colleges and Universities. (2017). VALUE: Valid Assessment of Learning in Undergraduate Education.
7. -Avci, E. (2017). Learning from experiences to determine quality in ethics education. International Journal of Ethics Education. 2, 3-16. https://doi.org/10.1007/s40889-016-0027-6
8. -Baker, J. D. (2004). An investigation of relationships among instructor immediacy and affective and cognitive learning in the online classroom. The Internet and Higher Education, 7, 1-13. https://doi.org/10.1016/j.iheduc.2003.11.006
9. -Batt, A. (2015). Teaching and evaluating the affective domain in paramedic education. Canadian Paramedicine. 38, 22-23.
10. -Broussard, J. D. & Teng, E. J. (2019). Models for enhancing the development of experiential learning approaches within mobile health technologies. Professional Psychology: Research and Practice. 50(3). 195-203. http://dx.doi.org/10.1037/pro0000234

11. -Budd, D. (2020). Reflective practice in child and youth care. Canadian Scholars Press.
12. -Burns, M. (2016). The self in child and youth care. Child Care Press.
13. -Camelia, F., Ferris, T. L. J., & Cropley, D. H. (2018). Development and Initial Validation of an Instrument to Measure Students´ Learning About Systems Thinking: The Affective Domain. IEEE Systems Journal. 12(1). 115-124. https://doi.org/10.1109/JSYST.2015. 2488022
14. -Centre for Teaching Excellence. (n.d.) Bloom´s Taxonomy. University of Waterloo. Retrieved from: https://uwaterloo.ca/centre-for-teaching-excellence/sites/ca.centre-for-teaching-excel lence/files/uploads/files/affective_domain_-_blooms_taxonomy.pdf

ទ្រឹស្តីផ្សារភ្ជាប់នឹងការអនុវត្ត ចងភ្ជាប់ជោយលទ្ធផល
ហើយត្រូវមានក្រមសីលធម៌វិជ្ជាជីវៈ